CONTESSA
Contemporary Teaching Skills for South Asia

Co-funded by the Erasmus+ Programme of the European Union

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ឯកសារស្រាវជ្រាវ ស្តីពី វិធីសាស្ត្របង្រៀនសម័យថ្មី សម្រាប់អាស៊ីខាងត្បូង

CONTESSA

ក្រសួងអប់រំ យុវជន និងកីឡា
ឆ្នាំ២០២២

បុព្វកថា

គោលនយោបាយជាតិស្តីពីការសិក្សាពេញមួយជីវិត មានចក្ខុវិស័យអភិវឌ្ឍប្រជាជនកម្ពុជាគ្រប់រូបឱ្យមានវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា កាយសម្បទា និងគុណសម្បទា ដើម្បីរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច និងលើកកម្ពស់សុខុមាលភាពបុគ្គល គ្រួសារ និងសង្គម តាមរយៈការផ្តល់ឱកាសសិក្សាពេញមួយជីវិតគ្រប់ពេលវេលា គ្រប់ទីកន្លែង និងគ្រប់មធ្យោបាយ។

ការលើកកម្ពស់គុណភាពអប់រំ ជាពិសេសគុណភាពនៃការរៀន និងបង្រៀន ជាកត្តាគន្លឹះដែលក្រសួងអប់រំ យុវជន និងកីឡា និងអ្នកគ្រប់គ្រងអប់រំគ្រប់លំដាប់ថ្នាក់បាននិងកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំងក្លា និងជាប្រចាំ។ ការអភិវឌ្ឍសមត្ថភាព និងការសិក្សាស្រាវជ្រាវជាប្រចាំ ជានិន្នាការនៃការសិក្សាពេញមួយជីវិត ដើម្បីជំរុញឱ្យការរៀន និងបង្រៀន មានប្រសិទ្ធភាពខ្ពស់ ពោលគឺជានាឱ្យការរៀនល្អ និងបង្រៀនល្អ សំដៅសម្រេចគោលដៅអប់រំជាតិដោយជោគជ័យ។

ក្រសួងបានសហការជាមួយសាកលវិទ្យាល័យនានាក្នុងប្រទេសនិងក្រៅប្រទេស ដើម្បីរៀបចំកសាង**ឯកសារស្រាវជ្រាវ ស្តីពីវិធីសាស្ត្របង្រៀនសម័យថ្មីសម្រាប់អាស៊ីខាងត្បូង** (CONTESSA) ចំនួន ៥ម៉ូឌុល រួមមាន៖ (១) ការយល់ដឹងអំពីការអប់រំនៅបឋមសិក្សា (២) ឧត្តមភាពក្នុងការបង្រៀន (៣) ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល (៤) ការអប់រំបរិយាបន្ន និង (៥) ការរៀន និងបង្រៀនតាមបែបឌីជីថល។

ឯកសារនេះត្រូវបានរៀបចំឡើង ដើម្បីឱ្យបុគ្គលិកអប់រំ និងអ្នកពាក់ព័ន្ធមានភាពងាយស្រួលក្នុងការសិក្សាស្រាវជ្រាវ រួមចំណែកក្នុងការលើកកម្ពស់កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន និងគាំទ្រដល់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរបស់គ្រូឧទ្ទេសសាលាគរុកោសល្យ គ្រូបង្រៀន គរុសិស្ស-និស្សិត និងអ្នកពាក់ព័ន្ធ តាមរយៈការផ្តល់នូវការអប់រំសម័យថ្មី និងវិធីសាស្ត្របង្រៀនសម្បូរបែប សម្រាប់លើកទឹកចិត្តសិស្ស និងផ្តល់សិទ្ធិក្នុងការសម្រេចចិត្តឱ្យសិស្សចូលរួមក្នុងការសិក្សា។

ដើម្បីអនុវត្តខ្លឹមសារនេះប្រកបដោយប្រសិទ្ធភាព បុគ្គលិកអប់រំ និងអ្នកពាក់ព័ន្ធគប្បីៈ (១) ស្វែងយល់ខ្លឹមសារឯកសារឱ្យបានស៊ីជម្រៅ ដើម្បីជាគ្រឹះវិស័យសម្រាប់ជំរុញការរៀន និងបង្រៀន (២) អនុវត្តខ្លឹមសារ និងសកម្មភាពបង្រៀនតាមគោលវិធីសិស្សមជ្ឈមណ្ឌលប្រកបដោយប្រសិទ្ធភាព និង (៣) វាយតម្លៃជាប្រចាំរាល់សកម្មភាពនៃការរៀន និងបង្រៀន ដើម្បីមានវិធានការកែលម្អទាន់ពេលវេលា ។

ក្រសួងសង្ឃឹមថា បុគ្គលិកអប់រំនិងអ្នកពាក់ព័ន្ធ នឹងខិតខំសិក្សាឈ្វេងយល់ និងអនុវត្តតាមទ្រឹស្តីដែលបានរកឃើញក្នុងឯកសារនេះ ដើម្បីបំពេញបន្ថែមនូវចំណេះដឹង និងអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំប្រកបដោយប្រសិទ្ធភាព និងគុណភាព។ ជាមួយគ្នានេះ ខ្ញុំសូមថ្លែងអំណរគុណចំពោះក្រុមការងារនាយកដ្ឋានបឋមសិក្សា និងសាកលវិទ្យាល័យនានា ដែលបានយកអស់កម្លាំងកាយចិត្តក្នុងការកសាង និងកែសម្រួលឯកសារដ៏មានសារៈសំខាន់នេះ។

ថ្ងៃ[illegible]ខែ[illegible] ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ[illegible] ឆ្នាំ២០២២
រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

CONTESSA
Contemporary Teaching Skills for South Asia

Co-funded by the Erasmus+ Programme of the European Union

ម៉ូឌុល ១

ការយល់ដឹងពីការអប់រំនៅបឋមសិក្សា

១.១- ការបង្រៀន និងការរៀនសតវត្សទី២១

ការកសាងការយល់ដឹងអំពីការអប់រំនៅបឋមសិក្សា

មេរៀននេះត្រូវបានបង្កើតឡើងដោយដៃគូសហការនៅក្នុងគម្រោងនៅ វិធីសាស្ត្របង្រៀនសម័យថ្មីនៅអាស៊ីខាងត្បូង (Contemporary Teaching Skill for South Asia) ហៅកាត់ថា CONTESSA ក្រោមការចូលរួមឧបត្ថម្ភថវិកាដោយកម្មវិធី Eramus+ នៃសហភាពអឺរ៉ុបដែលមានលេខគម្រោង598756-EPP-1-2018-1-AT-EPPKKA2-CBHE-JP-/CONTESSA

អ្នកសម្របសម្រួល :

Sandra Hummel, សាកលវិទ្យាល័យហ្គ្រាស UNIVERSITY OF GRAZ (អូទ្រីស)

ក្រោមការចូលរួមសហការពី :

សាកលវិទ្យាល័យបច្ចេកវិទ្យា ជ្រៃសឺន (អាលល្លឺម៉ង់)

សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា (កម្ពុជា)

សាកលវិទ្យាល័យកម្ពុជា (កម្ពុជា)

(ស្រីលង្កា) សាកលវិទ្យាល័យអូភេននៃប្រទេសស្រីលង្កា

(ស្រីលង្កា) សាកលវិទ្យាល័យកូឡំបូ

អ្នកនិពន្ធ: Regina Elias, Sandra Hummel, Mirjam Brodacz-Geier, Bridget Sheehan

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

សេចក្តីប្រកាស

គណៈកម្មការអឺរ៉ុបសូមធ្វើការគាំទ្រដល់ការបោះពុម្ពឯកសារនេះ ដែលមិនមែនឆ្លុះបញ្ចាំងតែពីទស្សនៈរបស់អ្នកនិពន្ធខាងលើទេ ហើយយើងក៏មិនទទួលខុសត្រូវចំពោះការប្រើប្រាស់ព័ត៌មានដែលដកស្រង់ចេញពីការបោះពុម្ពនេះដោយប្រការណាមួយដែរ។ ព័ត៌មានលម្អិតបន្ថែមនៃមេរៀននេះអាចរកបានដោយបើកចំហ និងឥតគិតថ្លៃនៅលើគេហទំព័រ CONTESSA :

https://contessa_project.eu/

រក្សាសិទ្ធិ

មេរៀននេះត្រូវបានផ្តល់អាជ្ញាប័ណ្ណឱ្យប្រើប្រាស់ក្រោមលក្ខខណ្ឌនៃ Creative Commons

Attribution_ShareAlike 4.0 Internatinal License

(https://creativecommons.org(licenses/by_sa/4.0/)

ដែលអនុញ្ញាតឱ្យប្រើប្រាស់ ចែករំលែក សម្របសម្រួលដើម្បីប្រើប្រាស់បន្ត ចែកចាយផលិតផលសារជាថ្មី ក្នុងទ្រង់ទ្រាយណាមួយ ដរាបណាអ្នកប្រើប្រាស់ផ្តល់កិត្តិយសឱ្យបានសមរម្យដល់អ្នកនិពន្ធទាំងអស់។ សូមផ្តល់ជាតំណភ្ជាប់ (link) ទៅកាន់ Creative Commons License និងសូមបញ្ជាក់ផងដែរ បើមានការផ្លាស់ប្តូរណាមួយ។ ប្រសិនបើអ្នកបញ្ចូលគំនិតកែសម្រួល ឬបន្ថែមអត្ថន័យលើមេរៀននេះអ្នកត្រូវតែធ្វើការសុំសិទ្ធិកែសម្រួលឯកសារតាមលក្ខខណ្ឌខាងលើ។ រូបភាព ខ្សែសំឡេង វីដេអូ ក៏ដូចជាឯកសារដទៃទៀតដែលមាននៅក្នុងមេរៀនទាំងនេះមិនត្រូវបានបូកបញ្ចូលទៅក្នុងឯកសារអាជ្ញាប័ណ្ណ Creative Commons ទេ លើកលែងតែមានការអនុញ្ញាតឱ្យប្រើប្រាស់។ ប្រសិនបើផ្នែកណាមួយនៃមេរៀននេះមិនត្រូវបានបញ្ចូលទៅក្នុងឯកសារអាជ្ញាប័ណ្ណ ហើយការប្រើប្រាស់មិនត្រូវបានអនុញ្ញាតដោយច្បាប់ ឬក៏ប្រើប្រាស់លើសពីច្បាប់អនុញ្ញាត ត្រូវតែសុំការអនុញ្ញាតដោយផ្ទាល់ពីម្ចាស់កម្មសិទ្ធិ។

CC BY SA

សេចក្តីផ្តើម

តើវគ្គសិក្សា CONTESSA ជាអ្វី?

វគ្គសិក្សា CONTESSA ជាលទ្ធផលមួយក្នុងចំណោម លទ្ធផលនៃគម្រោងស្តីអំពី "ជំនាញក្នុងការបង្រៀនសម័យថ្មីសម្រាប់អាស៊ីខាងត្បូង" ដែលផ្តល់មូលនិធិរួម ដោយកម្មវិធី Erasmus+ Program នៃសហភាពអឺរ៉ុប។ គោលបំណងរបស់វគ្គសិក្សានេះគឺ ដើម្បីជាការរួមចំណែកក្នុងការបង្កើតកម្មវិធីអប់រំគ្រូបង្រៀនដោយជោគជ័យសម្រាប់គ្រូបឋមសិក្សា ជាពិសេសក្នុងប្រទេសកម្ពុជា និងស្រីលង្កាដែលនឹងនាំដល់ការបង្កើតបានផលវិជ្ជមានរយៈពេលវែងទៅលើប្រព័ន្ធអប់រំទូទៅ។ វាមានសារៈសំខាន់កាន់តែខ្លាំងឡើង សម្រាប់អ្នកអប់រំដែលជោគជ័យក្នុងការតាមឱ្យទាន់សម័យជាមួយនឹងជំនាញ និងវិធីសាស្ត្រក្នុងសម័យថ្មី ដើម្បីយកមកប្រើក្នុង និងក្រៅថ្នាក់រៀន។ ដូច្នេះ វគ្គសិក្សា CONTESSA ផ្តល់ជូនមេរៀន ដែលត្រូវបានជ្រើសរើសដោយប្រុងប្រយ័ត្នចំនួន៥ម៉ូឌុល ដែលម៉ូឌុលនីមួយៗមានការផ្តោតការយកចិត្តទុកដាក់ទៅលើចំណុចចំនួនបី ដែលតម្រង់ទៅរកការអភិវឌ្ឍលើជំនាញបង្រៀនបែបសម័យថ្មី។ ម៉ូឌុលទាំងឡាយ និងការផ្តោតការយកចិត្តទុកដាក់របស់វាគឺមានដូចខាងក្រោម៖

ម៉ូឌុល១៖ ការកសាងការយល់ដឹងអំពីការអប់រំនៅបឋមសិក្សា
១.ការបង្រៀន និងការរៀននៅសតវត្សទី២១
២.ការរៀបចំកិច្ចតែងការបង្រៀន និងជំនាញគរុកោសល្យ ៖ គំនិត ឧបករណ៍ និងការអនុវត្ត
៣.ការរៀបចំបរិយាកាសសិក្សា

ម៉ូឌុល២៖ ភាពអស្ចារ្យក្នុងការបង្រៀន៖ សមត្ថភាពជាក់លាក់ប្រកបដោយវិជ្ជាជីវៈរបស់គ្រូបង្រៀនបឋមសិក្សា
១. ការយល់ដឹងពីការបង្រៀន៖ តួនាទី ការកិច្ច និងមុខងារ
២. ការវាយតម្លៃលទ្ធផលនៃការសិក្សា
៣. ជំនាញវិជ្ជាជីវៈគរុកោសល្យ

ម៉ូឌុល៣៖ការអប់រំឈានមុខគេបែបវិធីសាស្ត្រសិស្សមជ្ឈមណ្ឌល៖ ការលើកកម្ពស់ដំណើរការសិក្សាដែលបានបង្កើតរួមគ្នា
១. ការអភិវឌ្ឍលក្ខណៈបុគ្គល និងជំនាញដោះស្រាយបញ្ហា
២. ការអះអាងពីពិភពជីវិតជាក់ស្តែង និងក្តីសង្ឃឹមទៅអនាគត
៣. ការប្តេជ្ញាចិត្តដោយខ្លួនឯង ការផ្តល់សិទ្ធិអំណាច និងប្រសិទ្ធភាពផ្ទាល់ខ្លួន

ម៉ូឌុល៤៖ ការរួមបញ្ចូលភាពខុសគ្នា៖ គោលវិធីគរុកោសល្យសម្រាប់ភាពចម្រុះគ្នា ភាពមិនស្មើគ្នា និងតម្រូវការពិសេស
១. គរុកោសល្យបរិយាបន្ន ៖ គោលវិធី និងយុទ្ធសាស្ត្រ
២. ការបង្រៀន និងរៀនក្នុងភាពចម្រុះគ្នា ៖ ការរៀបចំ ការយល់ដឹងការវាយតម្លៃ
៣. ការគ្រប់គ្រងថ្នាក់រៀនដែលមានភាពចម្រុះគ្នា

ម៉ូឌុល៥៖ ការបង្រៀន និងរៀនតាមបែបឌីជីថល
១. គរុកោសល្យ នៃការសិក្សាពីចម្ងាយ និងបរិយាកាសសិក្សាដែលបំពាក់ទៅដោយបច្ចេកវិទ្យា
២. ប្រព័ន្ធផ្សព្វផ្សាយ និងបច្ចេកទេសឌីជីថល៖ ឧបករណ៍ និងទម្រង់សម្រាប់គោលបំណងនៃការអប់រំ
៣. ការរៀបចំមេរៀន និងដំណើរការបង្រៀនតាមអ៊ីនធឺណែត
នៅពេលដែលបញ្ចប់វគ្គសិក្សានេះ អ្នកចូលរួមនឹងអាចអនុវត្តជំនាញបង្រៀនសម័យថ្មី ដែលទើបទទួលបានធ្វើឱ្យសិស្សទាំងអស់អាចចូលរួមសកម្មភាពក្នុងថ្នាក់ និងរៀនពីវិធីថ្មីៗដើម្បីជួយឱ្យសិស្សឈានទៅដល់ចំណុចសក្តានុពលពេញលេញរបស់ពួកគេ។

តើវគ្គសិក្សា CONTESSA សម្រាប់អ្នកណា?

គម្រោងស្តីពីជំនាញក្នុងការបង្រៀនសម័យថ្មីសម្រាប់អាស៊ីខាងត្បូង មានបំណងក្នុងការលើកតម្កើងជំនាញបង្រៀនសម័យថ្មីសម្រាប់គរុសិស្ស/និស្សិត និងគ្រូបង្រៀនដែលកំពុងបម្រើការក្នុងសាលាបឋមសិក្សានានា។ ឯកសារខាងក្រោមត្រូវបានសម្របសម្រួលជាពិសេសសម្រាប់គរុសិស្ស/និស្សិត។
លើសពីនេះទៅទៀត វគ្គសិក្សា CONTESSA ក៏សម្រាប់អ្នកដែលមានចំណាប់អារម្មណ៍ក្នុងការធ្វើខ្លួនឱ្យទាន់សម័យកាលជាមួយនិងជំនាញបង្រៀនសម័យថ្មី។ ឯកសារមានជាភាសាអង់គ្លេស ហើយក៏មានជាភាសាខ្មែរ ភាសាសិង្ហាលា (Sinhala) និងភាសាតាមីល (Tamil) ដែលប្រើប្រាស់នៅប្រទេសស្រីលង្កា។

តើរចនាសម្ព័ន្ធនៃវគ្គសិក្សា CONTESSA មានអ្វីខ្លះ?

ដូចដែលបានលើកឡើងពីមុនរួចហើយ វគ្គសិក្សា CONTESSA នេះរួមមាន៥ម៉ូឌុល ដែលម៉ូឌុលនីមួយៗមានតម្លៃស្មើនឹង៣ ក្រេឌីតតាមប្រព័ន្ធផ្ទេរការសិក្សារបស់អឺរ៉ុប។ ជាការល្អ ម៉ូឌុលទាំងនេះត្រូវបានប្រើប្រាស់រួមគ្នា ពីព្រោះម៉ូឌុលនីមួយៗយោងឯកសារលើម៉ូឌុលដទៃទៀត។ ប៉ុន្តែក្នុងមេរៀន ម៉ូឌុលទាំងនេះក៏ត្រូវបានបង្កើតឡើងក្នុងវិធីមួយ ដែលអាចប្រើបានដោយខ្លួនឯងឯងផ្ទាល់ផងដែរ។ ម៉ូឌុលនីមួយៗមានការផ្តោតលើប្រធានបទចំនួនបី ហើយឯកសារទាំងឡាយក៏បង្កើតឡើងសម្រាប់ការផ្តោតនីមួយៗផងដែរ។ វាបង្កើតឱ្យមានឯកសារសរុបចំនួន១៥ផ្នែកសម្រាប់វគ្គសិក្សា CONTESSA ។ ឯកសារនីមួយៗរួមមានសេចក្តីផ្តើមបែបទ្រឹស្តីចំពោះចំណុចផ្តើម ហើយតាមពីក្រោយដោយលំហាត់អនុវត្ត ដោយផ្អែកលើទ្រឹស្តី។

ជំហាន១ – ទ្រឹស្តី – គឺជាការរំឭកនូវអ្វីដែលបានអាននៅក្នុងសេចក្តីផ្តើមនៃទ្រឹស្តីលំហាត់អនុវត្តទាំងនេះ ត្រួតពិនិត្យការយល់ដឹងនៃអត្ថបទ ដើម្បីប្រាកដថាទ្រឹស្តីជាមូលដ្ឋានដែលត្រូវបានយល់ដឹង។

ជំហាន២ – បទពិសោធ – ផ្តល់ជូននូវឧទាហរណ៍នៃគ្រូបង្រៀនពិតប្រាកដ និងវិធីដែលពួកគាត់អនុវត្តទ្រឹស្តីផ្សារភ្ជាប់នឹងការអនុវត្តជាក់ស្តែង។ ឧទាហរណ៍ទាំងនេះបានភ្ជាប់លំហាត់អនុវត្តទៅនឹងទ្រឹស្តីដែលបានរៀនពីមុនរួចហើយ។ **ជំហាន៣ – ការឆ្លុះបញ្ចាំងដោយខ្លួនឯងផ្ទាល់** – រាប់បញ្ចូលសំណួរបែបឆ្លុះបញ្ចាំងដោយផ្អែកទៅលើចំណុចផ្តោតនីមួយៗ។

ជំហាន៤ – ការអនុវត្ត – គឺជាជំហានចុងក្រោយដែលមានគម្រោងគោលនៃការបង្រៀនមួយត្រូវបានបង្កើតឡើងផ្អែកទៅលើអ្វីដែលបានប្រទះឃើញពីមុននៅក្នុងជំហានទីមួយ និងទីពីរ។

លំហាត់អនុវត្តនៅក្នុងជំហានទីមួយ និងទីពីរអាចត្រូវបានបំពេញដោយផ្ទាល់ក្នុងឯកសារនេះ។ ជំហានទី៣ និងទីបួនជាផ្នែកនៃឯកសារដែលរៀបជាសំណុំដាច់ដោយឡែកដែលនឹងត្រូវបង្កើតដោយបុគ្គលម្នាក់ៗ។ គំរូសម្រាប់ការរៀបចំសំណុំឯកសារ (portfolio) មានជាឯកសារដាច់ដោយឡែកពីគ្នា។

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

មាតិកា

១- គោលការណ៍សំខាន់ៗក្នុងការបង្រៀននៅសតវត្សទី២១ 1

១.១- ការចូលរួមសកម្មក្នុងថ្នាក់ 2

១.២- ការចូលរួមចំណែកក្នុងសង្គម 3

១.៣- សកម្មភាព ឬលំហាត់ដែលប្រកបដោយអត្ថប្រយោជន៍ 5

១.៤- ភ្ជាប់ព័ត៌មានថ្មីៗទៅនឹងចំណេះដឹងពីមុន 7

១.៥- ការរៀនបែបយុទ្ធសាស្ត្រ 8

១.៦- មានវិន័យផ្ទាល់ខ្លួន និងការរៀនឆ្លុះបញ្ចាំង 9

១.៧- ពិនិត្យរៀបចំចំណេះដឹងពីមុនឡើងវិញ 10

១.៨- ផ្តោះទៅការយល់មេរៀនជាជាងការទន្ទេញចាំមាត់ 11

១.៩- ជួយសិស្សឱ្យចេះផ្ទេរចំណេះដឹង 13

១.១០- ចំណាយពេលដើម្បីអនុវត្តផ្ទាល់ 14

១.១១- ភាពខុសគ្នារវាងការអភិវឌ្ឍ និងបុគ្គលម្នាក់ៗ 16

១.១២- បង្កើតអ្នកសិក្សាប្រកបដោយកម្លាំងចិត្ត 17

២- សរុបសេចក្តី 18

៣- ចំណុចសំខាន់ៗ 19

ឯកសារពិគ្រោះ 21

ជំហានទី១៖ សំណួរពង្រឹងចំណេះដឹង 22

ជំហានទី២៖ អនុវត្ត 28

ជំហានទី១៖ ចម្លើយពង្រឹងចំណេះដឹង 36

ជំហានទី២៖ ចម្លើយ 42

ជំហានទី៣៖ កិច្ចការរៀបចំឯកសារជាសំណុំ (Portfolio) – សំណួរបែបឆ្លុះបញ្ចាំងផ្ទាល់ខ្លួន 52

ជំហានទី៤៖ កិច្ចការរៀបចំឯកសារជាសំណុំ (Portfolio) – គម្រោងការបង្រៀន 52

ឧបសម្ព័ន្ធ 53

កំណត់ត្រាពីសំឡេង៖ Audio File 1.1.1 – គ្រូបង្រៀន ក 53

កំណត់ត្រាសំឡេង៖ Audio File 1.1.2 – គ្រូបង្រៀន ខ 53
កំណត់ត្រាពីសំឡេង ៖ Video File 1.1.1(វីដេអូ) 54

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

១- គោលការណ៍សំខាន់ៗក្នុងការបង្រៀនសៅសតវត្សទី២១

តាមប្រវត្តិសាស្ត្រដំណើរការនៃការបង្រៀនផ្តោតសំខាន់ទៅលើគ្រូ និងលទ្ធផលដែលសិស្សទទួលបាន។ សិស្សទាំងអស់ ជាអ្នកទទួលព័ត៌មានពីគ្រូសុទ្ធសាធដោយអង្គុយ និងស្តាប់នៅនឹងកៅអីរបស់ពួកគេ។ វិធីសាស្ត្របង្រៀនបែបគ្រូមជ្ឈមណ្ឌលនេះធ្វើឱ្យសិស្សដែលរៀនខ្សោយ បាត់បង់នូវព័ត៌មាន ឬមិនយល់មេរៀនតែម្តង។ ហេតុនេះហើយវាបានបង្កឱ្យពួកគេមានការពិបាកក្នុងការចាប់យល់មេរៀនបន្ទាប់ៗទៀតនៅពេលអនាគត។ សិស្សទាំងអស់មានកម្រិត នៃការរៀនខុសៗគ្នា ហើយមុខវិជ្ជាដែលគេរៀនបានពូកែក៏ខុសៗគ្នាដែរ។ សិស្សខ្លះមិនពូកែរៀនគណិត-វិទ្យា តែរៀនពូកែខាងមុខវិជ្ជាហត្ថកម្ម។ ការស្វែងយល់ពីសិស្សអាចជួយឱ្យគ្រូយល់ពីសិស្សនិងជួយគេបាន។ ប្រសិនបើសិស្សគិតថា គេគ្មានជំនាញរៀនដូចសិស្សដទៃ ពួកគេអាចនឹងលែងចង់រៀនហើយវានឹងជះឥទ្ធិពលទៅលើការសិក្សារបស់ពួកគេ រួចក៏បោះបង់ការសិក្សាទាំងស្រុងតែម្តង(UNESCO,2015)។ ហេតុដូច្នេះពួកគេនឹងមិនមានឱកាសបង្ហាញទេពកោសល្យរបស់ពួកគេទេ។

វិធីសាស្ត្របង្រៀននៅសតវត្សទី២១នេះ នឹងជួយតម្រង់ផ្លូវសិស្សម្នាក់ៗឱ្យចេះស្វែងរកអនាគត(ជីវិត ការងារ) មានន័យថាវិធីសាស្ត្រនេះនឹងផ្តោតការទាញយកនូវសក្តានុពល និងការបង្រៀនឱ្យកាន់តែប្រសើរ (ឧទាហរណ៍៖ ការបញ្ចេញមតិ ឬការសហការគ្នាក្នុងក្រុម)(Turmala, 2019)។ ក្នុងន័យនេះវាពិតជាសំខាន់ណាស់ដែលយើងត្រូវតែផ្លាស់ប្តូរពីវិធីសាស្ត្របង្រៀនតាមបែបគ្រូមជ្ឈមណ្ឌល ទៅសិស្សមជ្ឈមណ្ឌល។ វិធីសាស្ត្រសិស្សមជ្ឈមណ្ឌលអាចសម្រេចបានតាមរយៈ ការប្តូររបៀបរៀនដោយចាំមាត់ទៅជាយុទ្ធសាស្ត្រប្រើប្រាស់សមត្ថភាពរបស់សិស្សម្នាក់ៗវិញ។ តាមទិដ្ឋភាពរួមរបស់សមាគមអប់រំអន្តរជាតិដែលកាត់ថា (IAE) ដែលផ្តោតទៅលើទិដ្ឋភាពអប់រំតាមបែបវិទ្យាសាស្ត្រ និងការអនុវត្តជាក់ស្តែងបានបង្ហាញថាមានគោលការណ៍បង្រៀន និងរៀនឯករាជ្យចំនួន១២ ដែលនឹងគាំទ្រដល់វិធីសាស្ត្របែបជាក់ស្តែង និងដំណើរការរៀនបែបផ្ទាល់ខ្លួន។ គោលការណ៍ទាំង១២មិនត្រឹមតែមានទំនាក់ទំនងគ្នាប៉ុណ្ណោះទេថែមទាំងមានតួនាទីសំខាន់ក្នុងដំណើរការបណ្តុះបណ្តាល។ គោលការណ៍ទាំងនោះរួមមាន៖

- ការចូលរួមសកម្មក្នុងថ្នាក់
- ការចូលរួមចំណែកក្នុងសង្គម
- លំហាត់អនុវត្ត/សកម្មភាពដែលមានអត្ថប្រយោជន៍

គ្រូមជ្ឈមណ្ឌល
សំដៅលើស្ថានភាពរៀនដែលគ្រូបង្រៀនគ្រប់គ្រងខ្លឹមសារ និងរបៀបរៀនរបស់សិស្ស។

(The Glossary of Education Reform, 2014, online)

សិស្សមជ្ឈមណ្ឌល
សំដៅលើទម្រង់នៃការបង្រៀនដែល [...] ផ្តល់ឱកាសឱ្យសិស្សដឹកនាំសកម្មភាពរៀន [...] ហើយជាទូទៅសិស្សជាអ្នកធ្វើផែនការសិក្សាដោយខ្លួនឯងផ្ទាល់

(The Glossary of Education Reform, 2014, online)

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

- ភ្ជាប់ព័ត៌មានថ្មីៗទៅនឹងចំណេះដឹងពីមុន
- ការរៀនបែបយុទ្ធសាស្ត្រ
- មានវិន័យផ្ទាល់ខ្លួន និងរៀនឆ្លុះបញ្ចាំង
- ពិនិត្យរៀបចំចំណេះដឹងពីមុនឡើងវិញ
- ឆ្ពោះទៅការយល់មេរៀនជាជាងការទន្ទេញចាំមាត់
- ជួយឱ្យសិស្សចេះរៀនផ្ទេរចំណេះដឹង
- ចំណាយពេលដើម្បីអនុវត្តផ្ទាល់
- ភាពខុសគ្នារវាងការអភិវឌ្ឍនិងបុគ្គល
- បង្កើតអ្នកសិក្សាប្រកបដោយកម្លាំងចិត្ត

(Vosniadou,2001)

រូបទី១៖ គោលការណ៍សំខាន់ៗក្នុងការបង្រៀននៅក្នុងសតវត្សទី២១

១.១- ការចូលរួមសកម្មភាពក្នុងថ្នាក់

ការសិក្សាជោគជ័យទាមទារឱ្យមានចំណេះដឹង និងសកម្មភាពក្នុងការគិតដូចជាការផ្តោតអារម្មណ៍ ការសង្កេត និងការយកចិត្តទុកដាក់។ ដើម្បីសម្រេចបានយើងត្រូវឱ្យអ្នកសិក្សាចូលរួមក្នុងការរៀនសូត្រ ដើម្បីឱ្យពួកគេកំណត់ដឹងនូវអ្វីដែលខ្លួនបានរៀន។ ក្នុងន័យនេះ គ្រូត្រូវមានការកិច្ចជួយជ្រោមជ្រែងអ្នកសិក្សាឱ្យមានសកម្មភាពរស់រវើកក្នុងពេលសិក្សា។ ការចូលរួមដោយសកម្មអាចធ្វើបានតាមរយៈការបង្កើតបរិយាកាសសិក្សាដ៏គួរជាទីចាប់អារម្មណ៍ ដែលជួយជំរុញទឹកចិត្ត

អ្នកសិក្សាឱ្យរៀនកាន់តែខ្លាំង និងបង្កើតប្រធានបទសិក្សាឱ្យកាន់តែទាក់ទាញ។ ខាងក្រោមនេះជាគន្លឹះមួយចំនួនសម្រាប់ជួយគ្រូឱ្យសម្រេចគោលដៅខាងលើ (Vosniadou, 2001)

- បញ្ចូលលំហាត់ និងសកម្មភាពសិក្សាទាំងឡាយណាដែលទាមទារឱ្យសិស្សផ្តោតការយកចិត្តទុកដាក់ និងចូលរួមដោយសកម្ម
- បញ្ចូលលំហាត់ទាំងឡាយណា ដែលទាមទារឱ្យមានការចូលរួមដូចជាការពិសោធន៍ ឬក៏ការបង្កើតគម្រោងស្រាវជ្រាវផ្សេងៗ
- រៀបចំឱ្យមានដំណើរការកម្សាន្តទៅខាងក្រៅ ដោយចាត់ទុកវាជាផ្នែកមួយនៃការសិក្សា
- ផ្សព្វផ្សាយឱ្យមានការចូលរួមតាមរយៈ ការពិភាក្សា ឬការធ្វើការជាក្រុម
- ផ្តល់ឱកាសឱ្យអ្នកសិក្សា គ្រប់គ្រងការសិក្សារបស់ពួកគេតាមរបៀបរៀនផ្ទាល់ខ្លួនតាមតែអាចធ្វើបាន
- ស្វែងយល់ពីជំនាញពិសេសរបស់សិស្សម្នាក់ៗ និងចំណង់ចំណូលចិត្តរបស់ពួកគេ ហើយគាំទ្រពួកគេក្នុងគោលដៅសិក្សា (Elmore et al, 1996)

ជារួមដំណើរការបង្រៀនទាមទារឱ្យមានការចូលរួមយ៉ាងសកម្ម ពីគ្រូបង្រៀនផងដែរ ហើយវាជាការផ្លាស់ប្តូរដ៏សំខាន់ក្នុងទស្សនៈនៃការបង្រៀន ជាទូទៅ (Sileo et al, 1998) ។ កាលពីមុន ធ្លាប់មានទស្សនៈលើកឡើងថា ការសិក្សា ឬការរៀនសូត្រ គឺមិនត្រូវបានគេរាប់បញ្ចូលការទទួលខុសត្រូវរបស់សិស្សទេតែពេលនេះការស្រាវជ្រាវថ្មីបានបង្ហាញថា "ការរៀនសូត្រតម្រូវឱ្យមានការចូលរួមរបស់អ្នករៀន ប្រកបដោយគំនិតស្ថាបនា និងសកម្មផងដែរ"។ (Vosniadou, 2001, p.8)

→ សូមមើលនៅម៉ូឌុល ៣, ចំណុចទី២ «ពិភពជីវិត សេចក្តីបញ្ជាក់ និងទស្សនវិស័យអនាគត»

១.២- ការចូលរួមចំណែកក្នុងសង្គម

ដោយនិយមន័យនៃការសិក្សាមានន័យថា ការពង្រីកចំណេះដឹងឱ្យកាន់តែទូលំទូលាយនៅក្នុងសកម្មភាពសង្គម ដូច្នេះ វាមានសារៈសំខាន់ដែលសិស្សម្នាក់ៗត្រូវទទួលបាននូវបទពិសោធជីវិតសង្គមនៅក្នុងសាលារៀន។ ការសិក្សាថ្មីៗនេះបានរកឃើញថា កិច្ចការជាក្រុម ទំនាក់ទំនងក្នុងសង្គម ក្នុងបរិយាកាសនៃការសិក្សា ព្រមទាំងការសហការគ្នាបាននាំទៅដល់លទ្ធផលល្អនៅក្នុងការសិក្សា។ ការសហការនៅក្នុងថ្នាក់មួយបែបទៀតនោះគឺ អនុញ្ញាតឱ្យពួកគេធ្វើកិច្ចការរួមគ្នា។

សង្គមកាវូបនីយកម្ម

ត្រូវបានគេស្គាល់ថាជាដំណើរការដែលបុគ្គលម្នាក់បង្កើតទំនាក់ទំនងជាមួយបុគ្គលដទៃផ្សេងទៀត ជាទូទៅជាប្រភេទជាតិសាសន៍ដូចគ្នា។ ដំណើរការនៃសង្គមកាវូបនីយកម្មគឺមានលក្ខណៈដ៏

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

សិស្សនឹងខិតខំបន្ថែមទៀត នៅពេលដែលពួកគេដឹងថាពួកគេនឹងត្រូវធ្វើបទបង្ហាញ ឬក៏ចែករំលែកដល់មិត្តរួមថ្នាក់។ ទោះបីជាយ៉ាងណាក៏ដោយ ការចូលរួមចំណែកក្នុងសង្គមមិនត្រឹមតែមានឥទ្ធិពលដល់ដំណើរការរៀនសូត្ររបស់សិស្សតែនៅក្នុងថ្នាក់ប៉ុណ្ណោះទេ វាថែមទាំងជួយដល់ការរៀននៅក្រៅសាលាថែមទៀតផង។ ឧទាហរណ៍ នៅពេលក្មេងៗទាក់ទងជាមួយឪពុកម្តាយ ពួកគេអាចនិយាយតបតទៅកាន់ពួកគាត់។ ក្មេងៗក៏ចាប់យកទម្លាប់សកម្មភាព និងអាកប្បកិរិយាដែលពួកគេបានសង្កេតពីឪពុកម្តាយក្នុងគ្រួសារ ឬក្នុងសហគមន៍ ដែលទាំងអស់នេះជាផ្នែកមួយនៅក្នុងដំណើរការសង្គមភាវូបនីយកម្ម។ នេះមានន័យថាបរិយាកាសនៅសាលារៀន ដែលជំរុញឱ្យមានការសហការ និងការធ្វើសហប្រតិបត្តិភាគីនាំមកនូវជោគជ័យក្នុងការសិក្សានិងការអភិវឌ្ឍផ្ទាល់ខ្លួន។ គ្រូអាចចូលរួមចំណែកក្នុងការជំរុញឱ្យសិស្សមានការចូលរួមក្នុងសង្គម ដោយការធ្វើឱ្យថ្នាក់រៀន ជាកន្លែងដែលសិស្សអាចចែករំលែកសម្ភារសិក្សា មានការពិភាក្សា និងការធ្វើការជាក្រុម។ ការចូលរួមក្នុងសង្គម គឺជាទិដ្ឋភាពមួយដ៏សំខាន់ក្នុងការលើកកម្ពស់ការសិក្សារបស់សិស្ស (Vosniadou, 2001) ។ ការសិក្សាថ្មីៗបានរកឃើញថា ការចូលរួមចំណែកក្នុងសង្គមគឺជាគន្លឹះដ៏សំខាន់ ដែលនាំទៅដល់ការសិក្សាបានជោគជ័យ។ ដំណើរការបង្រៀន និងរៀនមិនមែនគ្រាន់តែកើតចេញពីគ្រូ ទៅសិស្សប៉ុណ្ណោះទេ ប៉ុន្តែវាជាទំនាក់ទំនងរវាងគ្នា និងគ្នាហើយវាអាស្រ័យទាំងស្រុងទៅលើទំនាក់ទំនងរវាងគ្រូនិងសិស្ស សិស្សនិងសិស្សដូចជា ការធ្វើការជាក្រុម និងការពិភាក្សាជាដើម (Sileo et al, 1998) ។

ទាំងនេះជាសកម្មភាពមួយចំនួន ដែលមានសារៈប្រយោជន៍ចំពោះគ្រូក្នុងការលើកកម្ពស់ការចូលរួមក្នុងសង្គមនៅក្នុងថ្នាក់រៀន៖

- បង្កើតឱកាសដែលនាំឱ្យមានការសហការគ្នា ពិភាក្សា និងធ្វើការជាក្រុម
- រៀបចំឱ្យមានទំនាក់ទំនងរវាងមេរៀនដែលត្រូវរៀននិងជីវិតពិតក្នុងសហគមន៍ដែលសិស្សអាចពិភាក្សានិងយល់បាន
- ផ្តល់ឱកាសឱ្យសិស្សបានបញ្ចេញយោបល់និងទទួលយោបល់ហើយ និងបង្ហាញនូវគំនិតរបស់ពួកគេ
- នៅពេលឱ្យសិស្សធ្វើការជាក្រុម ត្រូវចាត់តាំងសិស្សម្នាក់ក្នុងក្រុមធ្វើជាអ្នកសម្របសម្រួល ដែលនេះនឹងទាមទារឱ្យមានសម្ថតភាពដឹកនាំ វានឹងជួយកែលម្អជំនាញក្នុងសង្គម (Sileo et al. ,1998)។

សហគមន៍ ឯនិកសត្វខុសៗគ្នា រួមទាំងសង្គមមនុស្សផងដែរ។ (Thomas & Anderson 2013, p. vii)

សូមមើល ម៉ូឌុល ១, ចំណុចទី៣ «ការរៀបចំបរិស្ថានសិក្សា»

សូមមើល ម៉ូឌុល ៤, ចំណុចទី១ «គុរុកោសល្យបរិយាបន្ន»

ដូចបានរៀបរាប់ខាងលើរួចមកហើយថាគោលការណ៍ទាំង១២ ត្រូវពឹងពាក់គ្នាទៅវិញទៅមក។ ហើយយើងទើបតែបានពិភាក្សាគោលការណ៍ទី១ និងទី២ ដែលមានទំនាក់ទំនងជាមួយគ្នាយ៉ាងច្បាស់ គឺជាសិក្សាដែលប្រកបដោយជោគជ័យ តម្រូវឱ្យមានការចូលរួមយ៉ាងសកម្ម ក្នុងសកម្មភាពពាក់ព័ន្ធនឹងសង្គម។

គោលដៅរបស់គោលការណ៍ទាំង២គឺ ការចែករំលែកនិងសហប្រតិបត្តិការ ដើម្បីទាញយកផលប្រយោជន៍ឱ្យបានច្រើនពីដំណើរការនៃការសិក្សា។ សរុបមក "ការសិក្សា គឺជាការចូលរួមសកម្មភាពក្នុងសង្គមដោយយកសាលារៀនជាកន្លែងពិភាក្សារៀនសូត្រ" (Vosniadou, 2001, 9) ។

១.៣- សកម្មភាព ឬលំហាត់ដែលប្រកបដោយអត្ថប្រយោជន៍

សកម្មភាព ឬលំហាត់ ដែលចាត់ទុកថាមានប្រយោជន៍ លុះត្រាណាតែ វាផ្តល់អត្ថប្រយោជន៍ដល់ដំណើរការនៃការសិក្សា។ ត្រូវចាំថាគ្រូអាចបង្កើតសកម្មភាព ឬលំហាត់ដែលមានប្រយោជន៍នានា បានដោយការដឹងពីប្រវត្តិផ្សេងៗរបស់សិស្ស និងអត្ថប្រយោជន៍ផ្ទាល់ខ្លួន ដែលទទួលបានពីសាលារៀន។ ហេតុផលដែលគ្រូបង្រៀនចាំបាច់ត្រូវដឹងអំពីប្រវត្តិខុសៗគ្នារបស់សិស្ស ព្រោះថាចំណេះដឹងទាំងនោះអាចនឹងមានឥទ្ធិពលលើទស្សនៈរបស់សិស្ស នៅក្នុងការបញ្ចេញសកម្មភាពក្នុងថ្នាក់។ សិស្សម្នាក់ៗអាចមានប្រវត្តិ សាវតារ ចំណេះដឹង និងសមត្ថភាពខុសៗគ្នា។ លើសពីនេះទៀតអ្នកអប់រំត្រូវដឹងច្បាស់អំពីសិស្សណា ដែលមិនទាន់មានទម្លាប់ជាមួយនឹងប្រព័ន្ធរៀបចំនៅក្នុងសាលារៀន។ សិស្សទាំងអស់នេះចាំបាច់ត្រូវណែនាំឱ្យស្គាល់ អំពីប្រព័ន្ធថ្មីក្នុងសាលារៀនដោយប្រុងប្រយ័ត្ន។ វប្បធម៌ផ្សេងៗគ្នាអាចមានឥទ្ធិពលដល់គំនិតយោបល់របស់សិស្សដែលមានក្នុងសង្គមមួយៗផងដែរ។

ទិដ្ឋភាពនេះផ្សារភ្ជាប់ទៅនឹងគោលការណ៍ទី២ ដែលនិយាយអំពីការចូលរួមក្នុងសង្គម ពីព្រោះវាអាចមានឥទ្ធិពលទៅលើរបៀបដែលសិស្សធ្វើទំនាក់ទំនងគ្នាពីម្នាក់ទៅម្នាក់ ក៏ដូចជាទំនាក់ទំនងជាមួយគ្រូ ដែលជាហេតុនាំឱ្យមានការលើកទឹកចិត្តធ្វើការទាំងអស់គ្នានៅក្នុងថ្នាក់។ ក្នុងន័យនេះ សកម្មភាព ឬក៏លំហាត់អនុវត្តខ្លះគឺវាសក្តិសមសម្រាប់សិស្សមួយចំនួន ប៉ុន្តែ វាក៏មិនសក្តិសមសម្រាប់សិស្សមួយចំនួនទៀតទេ។ ដូច្នេះហើយ ដើម្បីរៀបចំសកម្មភាពក្នុងថ្នាក់ឱ្យបានល្អ គ្រូត្រូវ

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ជ្រើសរើសយកសកម្មភាពទាំងឡាយណាដែលពាក់ព័ន្ធនឹងជីវិតពិត តាមកាល:ទេស: របស់សិស្សដែលមានក្នុងសង្គម។ ការធ្វើបែបនេះនឹងធ្វើឱ្យសិស្សបានដឹងពីអត្ថប្រយោជន៍នៃអ្វីដែលពួកគេកំពុងសិក្សា ហើយពួកគេនឹងធ្វើឱ្យការសិក្សារបស់ពួកគេកាន់តែល្អប្រសើរ(Vosniadou,2001) ។ សកម្មភាពសិក្សាទាំងអស់នេះវាក៏បានផ្តល់អត្ថប្រយោជន៍ទៅដល់ការយល់ច្បាស់អំពីមេរៀនដែលពួកគេកំពុងរៀន ហើយក៏ជួយឱ្យពួកគេមានការគិត ដែលប្រកបទៅដោយការវិភាគត្រឹមត្រូវផងដែរ (Sileo et al.1998) ។

ខាងក្រោមនេះ ជាគំនិតមួយចំនួនដែលមានជំនួយដល់ការរៀបចំលំហាត់អនុវត្ត ឬសកម្មភាពដែលមានអត្ថប្រយោជន៍នានា៖

- ប្តឹងថ្លែងពីជំនាញជាមួយនឹងលំហាត់ឱ្យអ្នកសិក្សាធ្វើ ឧទាហរណ៍៖ ឱ្យសិស្សធ្វើបទបង្ហាញ ឬចូលរួមក្នុងការតស៊ូមតិ ដើម្បីដុសខាត់ជំនាញនិយាយរបស់ពួកគេ ឬក៏យកអត្ថបទ កាសែតមកបង្រៀនក្នុងថ្នាក់ហើយជំរុញឱ្យសិស្សទាំងឡាយរៀនសរសេរអត្ថបទ ដើម្បីពង្រឹងការសរសេរបស់ពួកគេ (Sileo et al.1998) ។
- អញ្ជើញអ្នកជំនាញ ឬអ្នកវិទ្យាសាស្ត្រឱ្យធ្វើកបកថាអំពីជីវិតពិត និងការងារប្រចាំថ្ងៃ ដើម្បីផ្សព្វផ្សាយការយល់ដឹងរបស់សិស្សានុសិស្សផ្សារភ្ជាប់រវាងសាលា និងការងារ (Collins et al.1989)។
- ការដើរតួ៖ ការដើរតួធ្វើតាមដោយការសម្តែងអាចលើកកម្ពស់ការសិក្សាឱ្យច្បាស់លាស់និងមានការវិភាគត្រឹមត្រូវ(Sileo et al., 1998) ។

សរុបសេចក្តីមក សារៈសំខាន់នៃការផ្សារភ្ជាប់រវាងសាលាទៅនឹងស្ថានភាពជីវិតជាក់ស្តែង វាមិនត្រឹមតែត្រូវបានគេសង្កត់ធ្ងន់ក្នុងគោលការណ៍ទី៣ប៉ុណ្ណោះទេ វាថែមទាំងមាននិយាយក្នុង គោលការណ៍ទី៨ និងទី៩ផងដែរ។ វានឹងត្រូវបាននិយាយម្តងហើយម្តងទៀតក្នុងទិដ្ឋភាពគោលការណ៍បង្រៀនទាំងអស់ ក៏ព្រោះតែវាជាគោលដៅដ៏សំខាន់តែមួយគត់ នៃប្រព័ន្ធអប់រំនៅពេលបច្ចុប្បន្ន ដើម្បីរៀបចំឱ្យអ្នកសិក្សាទទួលបាននូវជីវិតដ៏ល្អប្រសើរក្នុងពេលអនាគត។ "អ្នកសិក្សាទទួលបានលទ្ធផលល្អបំផុត នៅពេលដែលពួកគេបានចូលរួមធ្វើសកម្មភាពសិក្សានានា ដែលមានប្រយោជន៍ក្នុងជីវិតពិតរបស់ពួកគេ និងមានទំនាក់ទំនងទៅនឹងប្រវត្តិវិប្បធម៌ផ្ទាល់ខ្លួន។"

សូមមើល ម៉ូឌុល ៣, ចំណុចទី២ «ពិភាពជីវិត សេចក្តីបញ្ជាក់ និងទស្សនវិស័យអនាគត»

១.៤- ភ្ជាប់ព័ត៌មានថ្មីៗទៅនឹងចំណេះដឹងពីមុន

ការស្រាវជ្រាវថ្មីៗបានបង្ហាញថា ការសិក្សាអាចប្រព្រឹត្តទៅបាន នៅពេលដែលវាត្រូវបានគេភ្ជាប់ពីព័ត៌មានថ្មីទៅនឹងចំណេះដឹងចាស់ពីមុនៗមក ប៉ុន្តែសិស្សមិនអាចមើលឃើញពីទំនាក់ទំនងនេះទេ។ ហេតុដូចនេះហើយគ្រូបង្រៀនចាំបាច់ត្រូវយល់ដឹងឱ្យបានច្បាស់អំពីចំណេះដឹងពីមុនៗ របស់សិស្ស ដើម្បី ជួយពួកគេក្នុងការយល់ពីទំនាក់ទំនងអ្វីដែលពួកគេបានរៀនពីអតីតកាលនិងអ្វីដែលពួកគេកំពុងរៀនបច្ចុប្បន្ន។ នេះមានន័យថាដើម្បីឆ្លុះកកាយចំណេះដឹងពីមុនៗរបស់សិស្សគ្រូបង្រៀនត្រូវជួយពួកគេឱ្យភ្ជាប់ទៅនឹងព័ត៌មានថ្មីៗ។ គ្រូបង្រៀនក៏គួរតែដឹងប្រាកដថាព័ត៌មាន ដែលសិស្សមានគឺត្រឹមត្រូវនិងពេញលេញ ហើយយើងក៏ត្រូវផ្តល់ព័ត៌មានបន្ថែមសំខាន់ៗទាំងឡាយណាដល់សិស្ស។ បើសិនដឹងថាព័ត៌មានខ្លះបាត់បង់ ឬខុសឆ្គងត្រូវកែតម្រូវនូវព័ត៌មានទាំងឡាយនោះមកជាព័ត៌មានត្រឹមត្រូវវិញ។ គ្រូអាចសួរសំណួរមួយចំនួនទៅកាន់សិស្សដើម្បីស្វែងយល់ពីទំនាក់ទំនងព័ត៌មានថ្មី និងព័ត៌មានចាស់ ដែលសិស្សប៉ាន់ស្មានរួចមកហើយ(Vosniadou,2001)។ នៅពេលដែលយើងបង្រៀនមេរៀនថ្មីគ្រូចាំបាច់ត្រូវតែរកលំហាត់អនុវត្តទាំងឡាយណាជាក់ស្តែងត្រូវជាមួយមេរៀន ហើយបូកបញ្ចូលគ្នាទៅនឹងព័ត៌មានដែលសិស្សបានរៀនពីមុនមក។ ផ្នែកដ៏សំខាន់មួយនោះគឺ ការបញ្ចូលលំហាត់ជាក្រុមឱ្យច្រើនធ្វើដូចនេះអាចនឹងជួយលើកកម្ពស់ការចូលរួមក្នុងសង្គមរបស់សិស្សានុសិស្ស។ ចំណុចសំខាន់ចុងក្រោយក្នុងការណែនាំព័ត៌មានថ្មីគឺគ្រូត្រូវដឹងថា "សិស្សមិនមែនជាធុងទទេដែលរង់ចាំតែចាក់បំពេញនោះទេ" ប៉ុន្តែពួកគេសុទ្ធតែជាអ្នកសិក្សាដ៏វៃឆ្លាតនិងមានសមត្ថភាពយល់ដឹងនូវអ្វីដែលគេរៀនដោយចំណេះដឹង និងព័ត៌មានដែលពួកគេមានក្នុងពិភពលោក (Sileo et al,1998,187f.)។

ដើម្បីយល់ដឹងឱ្យកាន់តែច្បាស់នូវចំណេះដឹងពីមុនៗរបស់សិស្ស និងជួយពួកគេឱ្យចេះភ្ជាប់ទៅនឹងចំណេះដឹងថ្មី គ្រូអាចអនុវត្តតាមវិធីខាងក្រោមនេះ ៖

- ប្រាប់ឱ្យសិស្សម្នាក់ៗរៀបចំធ្វើបទបង្ហាញប្រធានបទថ្មីមុនពេលពិភាក្សាលើប្រធានបទនោះនៅក្នុងថ្នាក់ ការធ្វើរបៀបនេះសិស្សទាំងអស់នឹងអាចយកចំណេះដឹងដែលពួកគេបានរៀនពីមុនមកប្រើប្រាស់ជាមុនសិន។
- ជំរុញឱ្យមានការពិភាក្សានៅក្នុងថ្នាក់មុន និងណែនាំប្រធានបទថ្មី។

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

បង្កើតសំណួរនៅពេលបង្រៀនអត្ថបទអំណាន ធ្វើដូច្នេះទើបផ្សារភ្ជាប់បានរវាងអ្វីដែលសិស្សបានអាន និងបង្កើតជាចំណេះដឹងសម្រាប់សិស្ស។ ជាថ្មីម្តងទៀត ទំនាក់ទំនងនៅក្នុងសង្គម ពិតជាមានភាពចាំបាច់ណាស់ក្នុងដំណើរការសិក្សា។ ក្នុងករណីនេះ ទំនាក់ទំនងក្នុងសង្គមផ្តោតសំខាន់ទៅលើទំនាក់ទំនងរវាងសិស្ស និងគ្រូជាជាងផ្តោតទៅលើកិច្ចសហការនិងការពិភាក្សាជាក្រុមដែលជាទំនាក់ទំនងរវាងសិស្សនិងសិស្ស "ចំណេះដឹងថ្មីនឹងត្រូវកើតឡើងបានបន្ទាប់ពីបានយល់ និងជឿលើអ្វីមួយ។" (Vosniadou,2001,12)

១.៥- ការរៀនបែបយុទ្ធសាស្ត្រ

មនុស្សតែងតែស្វះស្វែងរកយុទ្ធសាស្ត្រដើម្បីចងចាំព័ត៌មាន ឬរៀនមុខជំនាញអ្វីមួយ។ ឧទាហរណ៍ សូម្បីតែក្មេងៗក៏ត្រូវអាន ឬមើលព័ត៌មានម្តងហើយម្តងទៀតដើម្បីចងចាំ ទោះបីពួកគេមិនដែលដឹងពីយុទ្ធសាស្ត្រក៏ដោយ។ ទោះបីជាយ៉ាងណាគេគ្រាន់តែដឹងថាយុទ្ធសាស្ត្រនេះដំណើរការល្អនៅពេលដែលគេព្យាយាមចាំព័ត៌មានអ្វីមួយដូចជា បញ្ជីរាយមុខម្ហូបត្រូវទិញនៅផ្សារ។ នៅសាលារៀន យុទ្ធសាស្ត្រទាំងអស់នេះត្រូវបង្រៀនដោយគ្រូបង្រៀន តាមរយៈការជួយពួកគេឱ្យជ្រើសរើសយកយុទ្ធសាស្ត្រអ្វីមួយ ដែលសក្តិសមសមត្ថភាព ដូចជា របៀបដោះស្រាយ លំហាត់គណិតវិទ្យាជាដើម។ ប្រសិនបើមានការរៀនសូត្រ និងយុទ្ធសាស្ត្រដោះស្រាយបញ្ហាដ៏ត្រឹមត្រូវ វានឹងធ្វើឱ្យការសិក្សាមានសន្ទុះកាន់តែខ្លាំងឡើង។ គ្រូបង្រៀនមានតួនាទីយ៉ាងសំខាន់ ក្នុងការបណ្តុះយុទ្ធសាស្ត្រ តាមគ្រប់រូបភាពឱ្យសិស្ស អាចដោះស្រាយបញ្ហាបាននៅចំពោះមុខ។ យុទ្ធសាស្ត្រទាំងនេះអាចធ្វើបានដោយផ្ទាល់ ឬដោយប្រយោល។ ដោយប្រយោលគឺ គ្រូត្រូវឱ្យសិស្សធ្វើការងារថ្មីមួយហើយសួរសំណួរទៅពួកគេ ហើយបើអាចធ្វើបានគ្រូអាចបង្កើតចំណោទបញ្ហាឱ្យសិស្សរៀនរាវរកយុទ្ធសាស្ត្រ ដើម្បីដោះស្រាយនូវអ្វីដែលផ្ទុយស្រឡះទៅនឹងវិធីបង្ហាញយុទ្ធសាស្ត្រដោយផ្ទាល់ទៅសិស្ស។

ខាងក្រោមនេះជាលំហាត់អនុវត្ត ដែលអាចឱ្យសិស្សរៀននិងទទួលយកយុទ្ធសាស្ត្រថ្មីៗដែលសក្តិសមនិងកិច្ចការដែលគ្រូឱ្យធ្វើ៖

- ឱ្យសិស្សសង្ខេបអត្ថបទបន្ទាប់ពីពួកគេបានអាន ដើម្បីបង្កើនចំណេះដឹងផ្នែកអំណាន។
- ឱ្យសិស្សធ្វើការងារជាក្រុម ឧទាហរណ៍៖ ដូចជាការពិភាក្សា ឬការធ្វើពិសោធ ព្រោះវាជួយបង្កើតយុទ្ធសាស្ត្ររៀនសូត្ររបស់សិស្ស។

- ជួយសិស្សក្នុងការរកយុទ្ធសាស្ត្រថ្មីៗ ប៉ុន្តែក៏ត្រូវជួយគេឱ្យចេះប្រើយុទ្ធសាស្ត្រដែលគេមានស្រាប់ឱ្យកាន់តែប្រសើរផងដែរ។
  (Vosniadou,2001)

សរុបមក យើងអាចឃើញយ៉ាងច្បាស់រវាងទំនាក់ទំនងគោលការណ៍បង្រៀនពីមុនដែលជាអន្តរបុគ្គលរវាងគ្រូនិងសិស្ស។ ការរៀនពីយុទ្ធសាស្ត្រត្រឹមត្រូវ គឺពិតជាមានសារៈសំខាន់ក្នុងដំណើរការរៀនសូត្រ និងជាពិសេសទទួលបានលទ្ធផលល្អ ពីព្រោះ មនុស្សត្រូវចេះរៀនប្រើយុទ្ធសាស្ត្រ"ឱ្យមានប្រសិទ្ធភាព និងបត់បែនតាមកាលៈទេសៈ ដើម្បីអាចជួយពួកគេឱ្យចេះរកហេតុផលចងចាំ និងដោះស្រាយបញ្ហា។" (Vosniadou,2001,15)

១.៦- មានន័យផ្ទាល់ខ្លួន និងការរៀនឆ្លុះបញ្ចាំង

និន័យផ្ទាល់ខ្លួនក្នុងការបង្រៀន និងរៀននេះមានន័យថា ការយល់ដឹងពីសមត្ថភាពផ្ទាល់ខ្លួន ដឹងចំណុចខ្វះខាតរបស់ខ្លួនហើយកែនូវកំហុសទាំងអស់នោះ។ យើងត្រូវរៀនវាយតម្លៃខ្លួនឯង និងរកយុទ្ធសាស្ត្រដើម្បីកែលម្អលទ្ធផលសិក្សារបស់ខ្លួន។ ដើម្បីសម្រេចកិច្ចការនេះបាន យើងត្រូវចេះរៀនតាមដានខ្លួនឯង ដើម្បីធ្វើការឆ្លុះបញ្ចាំងកែលម្អ។ លទ្ធភាពដែលយើងអាចតាមដាន និងកែលម្អបានគឺតាមរយៈការពិភាក្សា និងសហប្រតិបត្តការជាមួយសិស្សដទៃ គ្រូអាចជួយសិស្សបានតាមរយៈផ្តល់ការគាំទ្រដល់សិស្សក្នុងដំណើរការដោះស្រាយបញ្ហា។ ម្យ៉ាងទៀត គ្រូអាចជួយសិស្សឱ្យចេះបង្កើតគោលដៅសិក្សារបស់ពួកគេផ្ទាល់។ (Boelaerts,2000)

គ្រូអាចលើកកម្ពស់ការមានវិន័យផ្ទាល់ខ្លួន និងការឆ្លុះបញ្ចាំងត្រលប់របស់សិស្សតាមរយៈ៖

- ផ្តល់ជម្រើសឱ្យសិស្សចេះបង្កើតគម្រោង និងសរសេរលំហាត់អនុវត្តន៍ ឬផ្តល់យោបល់ឱ្យពួកគេក្នុងការរៀបចំផែនការពិសោធ។
- ផ្តល់ឱកាសឱ្យសិស្សវាយតម្លៃការងារផ្ទាល់របស់ពួកគេនិងការងារមិត្តរួមថ្នាក់
- ឱ្យពួកគេវាយតម្លៃយុទ្ធសាស្ត្រនានាដែលពួកគេបានប្រើប្រាស់ពីមុនៗមក
- លើកទឹកចិត្តឱ្យពួកគេលើកជាសំណួរអំពីយុទ្ធសាស្ត្ររបស់ពួកគេ ក៏ដូចជាសួរសំណួរអំពីយុទ្ធសាស្ត្រដែលគ្រូបានផ្តល់ឱ្យ។
- ផ្តល់ឱកាសដល់សិស្សក្នុងការវាយតម្លៃខ្លួនឯង ដូចជាសួរថា "ហេតុអ្វីបានជាខ្ញុំធ្វើលំហាត់ហ្នឹងតាមរបៀបហ្នឹងអញ្ចឹង? តើធ្វើរបៀបហ្នឹង ដោគដ័យដែរ ឬទេ?"

- ជំរុញឱ្យសិស្សជ្រើសរើសយកយុទ្ធសាស្ត្រដែលអាចនាំឱ្យពួកគេទទួលបានជោគជ័យនូវការងារដែលពួកគេកំពុងធ្វើ
- ផ្តល់ឱកាសឱ្យសិស្សវាយតម្លៃ និងបញ្ចេញទស្សនៈរបស់ពួកគេចំពោះកិច្ចការសាលារបស់គេឱ្យដាក់ច្បាស់ដែលអាចឱ្យគេចេះបង្កើតគោលដៅរបស់ពួកគេ។

ចំពោះគោលការណ៍ទី៦នេះគឺត្រូវការគោលការណ៍ទី៤ ដើម្បីយកមកអនុវត្តជាមួយគ្នាពីព្រោះថាចំណេះដឹងដែលមានស្រាប់វាពិតជាសំខាន់ នៅពេលដែលយើងយកមកវាយតម្លៃការងាររបស់ខ្លួនហើយឆ្លុះបញ្ចាំងកែម្ត។ មានតែធ្វើដូចនេះទេទើបទាំងសិស្ស ទាំងគ្រូអាចកត់សម្គាល់ពីយុទ្ធសាស្ត្រសមស្របរបស់សិស្សម្នាក់ៗ។ សិស្សត្រូវដឹងពីរបៀបរៀបចំផែនការ និងត្រួតពិនិត្យតាមដានលើការសិក្សារបស់ពួកគេ ដឹងពីរបៀបកំណត់គោលដៅការសិក្សា និងកែកំហុសឆ្គងដែលមាននៅក្នុងដំណើរការសិក្សារបស់ពួកគេ។ (Vosniadou,2001,16)

១៧- ពិនិត្យរៀបចំចំណេះដឹងពីមុនឡើងវិញ

ការយកព័ត៌មានចាស់ៗមកប្រើប្រាស់នៅក្នុងខ្លឹមសារមេរៀនថ្មី ពិតជាសំខាន់ណាស់ ដោយពេលខ្លះចំណេះដឹងពីមុនៗអាចរាំងស្ទះដល់ដំណើរការសិក្សាថ្មីៗ។ ក្នុងករណីមួយចំនួនចំណេះដឹងចាស់ៗ ដែលយើងកំពុងមានគឺមិនទាន់សម័យ ឬមិនទាន់មានបច្ចុប្បន្នភាពដោយសារតែមិនមានការស្រាវជ្រាវបន្ថែម។ ឧទាហរណ៍ជាក់ស្តែង ការយកចំណេះដឹងពីមុនៗមកប្រើប្រាស់នៅក្នុងថ្នាក់នៅពេល ដែលសិស្សរៀនពីប្រភាគនៅក្នុងគណិតវិទ្យា ប៉ុន្តែពួកគេស្គាល់ ឬចេះតែលេខទូទៅ។ នៅពេលនេះសិស្សត្រូវចេះរៀបចំនូវក្បួនច្បាប់ ដែលពួកគេមានពីមុនមកសម្របទៅនឹងទិដ្ឋភាពថ្មី។ ដើម្បីរៀបចំយកចំណេះដឹងពីមុនៗមករៀបចំប្រើប្រាស់ គ្រូបង្រៀនត្រូវចាំបាច់យល់ដឹងពីចំណេះដឹងរបស់សិស្ស និងផ្តល់ឱកាសឱ្យពួកគេប្រើប្រាស់ចំណេះដឹងទាំងនោះ។ បន្ថែមពីនេះត្រូវផ្តល់ឱកាសឱ្យសិស្សយល់អំពីហេតុផល ឬមូលហេតុដែលចំណេះដឹងពីមុនៗរបស់ពួកគេមិនគ្រប់គ្រាន់ ឬមិនត្រឹមត្រូវ។ សិស្សានុសិស្សអាចនឹងត្រូវការពេលខ្លះដើម្បីទទួលយកព័ត៌មានថ្មីៗ និងរៀបចំឡើងវិញនូវព័ត៌មាន ចាស់ៗមកប្រើប្រាស់ដែលពេលវេលាទាំងនេះគួរតែធ្វើឡើងនៅក្នុងថ្នាក់ (Vosniadou,2001)។ ខាងក្រោមនេះជាវិធីសាស្ត្រមួយចំនួនដែលគ្រូអាចប្រើបានក្នុងការរៀបចំព័ត៌មានចាស់ៗ ដើម្បីយកមកប្រើឱ្យមានប្រយោជន៍ឡើងវិញ ៖

សូមមើលម៉ូឌុល ៣, ចំណុចទី២ «ពិភពជីវិត សេចក្តីបញ្ជាក់ និងទស្សនវិស័យអនាគត»

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

- គ្រូទាំងឡាយត្រូវដឹងថា សិស្សទាំងអស់ពិតជាមានចំណេះដឹងពីមុនៗមក ហើយចំណេះដឹងទាំងនោះអាចផ្ទុយទៅនឹងអ្វី ដែលពួកគេកំពុងរៀននៅក្នុងថ្នាក់។
- គ្រូត្រូវបង្កើតបរិយាកាសដែលអនុញ្ញាតឱ្យសិស្សបង្កើនការជឿជាក់ផ្សេងៗ ហើយឱ្យសិស្សបញ្ចេញនូវចំណេះដឹងទាំងនោះ ទោះបីជាពេលខ្លះវាជាព័ត៌មានមិនត្រឹមត្រូវក៏ដោយ
- គ្រូត្រូវបង្កភាពងាយស្រួលក្នុងការបញ្ចូលនូវជំនឿពីមុនៗរបស់សិស្សដោយការពន្យល់
- គ្រូអាចប្រើប្រាស់នូវឧទាហរណ៍មួយចំនួនដូចជា ព្រឹត្តិការណ៍ ប្រវត្តិសាស្ត្រ ការធ្វើពិសោធនានា ដើម្បីបង្ហាញសិស្សនូវអ្វីដែលថ្មីដែលពួកគេរៀននៅក្នុងថ្នាក់។
- គ្រូត្រូវរកកស្តុតាងបែបវិទ្យាសាស្ត្រ ដើម្បីបង្ហាញនូវចំណេះដឹងដែលត្រូវយកមកកែលម្អប្រើប្រាស់ឡើងវិញ
- ផ្តល់ពេលវេលាឱ្យសិស្សទទួលនូវទស្សនៈចំណេះដឹងដែលបានកែប្រែថ្មីៗ ហើយដើម្បីធ្វើបែបនេះបានគ្រូត្រូវបញ្ចូលនូវប្រធានបទមួយចំនួនសម្រាប់អនុវត្តឱ្យបានស៊ីជម្រៅ។

នៅក្នុងគោលការណ៍បង្រៀនទី៧នេះ វាពាក់ព័ន្ធគ្នាជាមួយគោលការណ៍ទី៤ ដែលបានចែងអំពីសារៈសំខាន់នៃទំនាក់ទំនងរវាងចំណេះដឹងចាស់ និងចំណេះដឹងថ្មី។ មូលដ្ឋានគ្រឹះនៅទីនេះ គឺត្រូវប្រាកដថាចំណេះដឹងចាស់ៗពីមុនបានផ្តល់ជាគ្រឹះដល់ចំណេះដឹងថ្មីៗ។ ដើម្បីធ្វើបានយើងត្រូវធ្វើការកែតម្រូវនូវចំណេះដឹង មុនៗឱ្យបានត្រឹមត្រូវតាមកាលៈទេសៈដ៏សមស្របមួយ (Vosniadou, 2001)។ "ជួនកាល ចំណេះដឹងដែលយើងមានអាចជាឃានមួយក្នុងការរៀនអ្វីថ្មីៗ។ អ្នកសិក្សាត្រូវរៀនចេះដោះស្រាយនូវភាពមិនសមស្របដែលកើតមាន និងកែច្នៃការយល់ដឹង នៅពេលដែលចាំបាច់ (Vosniadou, 2001, 18)។"

១.៨- ឆ្ពោះទៅការយល់មេរៀនជាជាងការទន្ទេញចាំមាត់

សិស្សច្រើនតែមានទំនោរទៅរកការទន្ទេញចាំព័ត៌មានដែលគេយល់ ជាជាងការពិតដែលពួកគេបានរៀនដោយប្រឹងប្រែង។ ការយល់ច្បាស់ពីមេរៀនធ្វើឱ្យសិស្សមិនងាយនឹងភ្លេចព័ត៌មានទៅវិញបាន ហើយវាស្រួលក្នុងការប្រើប្រាស់ជាមួយប្រធានបទថ្មីៗ។ ដូច្នេះ គ្រូគួរតែជំរុញឱ្យសិស្សពន្យល់អ្វីដែលគេបានដឹង ឬរៀន

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ដោយប្រើពាក្យសម្តីផ្ទាល់របស់ពួកគេ ឬក៏ពិភាក្សាគ្នាជាមួយមិត្តភក្តិរបស់ពួកគេ។ ការធ្វើរបៀបនេះគ្រូអាចប្រាកដក្នុងចិត្តថាសិស្សទទួលបានព័ត៌មាន ឬចំណេះដឹងថ្មីៗដោយសិស្សចេះពន្យល់នូវគំនិតរបស់ពួកគេដោយផ្ទាល់ដែលជាឱកាសមួយឱ្យពួកគេចេះគិតនូវអ្វីដែលពួកគេកំពុងរៀន។ ក្នុងខណៈដែលសិស្សអាចមានឱកាសដើម្បីពន្យល់ ដោយប្រើពាក្យរបស់ខ្លួនឯងផ្ទាល់ អាចជួយសិស្សឱ្យយល់បានច្រើន ហើយក៏អាចជាឱកាស ដែលគ្រូអាចដឹងពីចំណុចណាមួយដែលសិស្សយល់ខុស។ លើសពីនេះទៀតគ្រូមិនគួរពន្យល់តែព័ត៌មានពិតៗទៅសិស្សមួយមុខនោះទេ ប៉ុន្តែគួរពន្យល់ទៅសិស្សដោយមានឧទាហរណ៍ផងដែរ ដោយឈរលើអ្វីដែលសិស្សអាចទទួលយកបាន និងប្រៀបធៀបភាពខុសគ្នានៃមធ្យោបាយសិក្សានីមួយៗ ហើយពេលនេះមិនមែនគ្រាន់តែទន្ទេញចាំមាត់ប៉ុណ្ណោះទេ។

(Vosniadou,2001) ដើម្បីជួយសិស្សឱ្យយល់មេរៀន គ្រូអាចសាកល្បងនូវគំនិតមួយចំនួនដូចខាងក្រោមនេះ៖

- ឱ្យសិស្សពន្យល់ពីដំណើរការអ្វីមួយ ឬហេតុការណ៍ពិតផ្សេងៗដោយមិនចាំបាច់ប្រើប្រាស់សៀវភៅសិក្សា (ឬក៏ឯកសារផ្សេងៗទៀត)
- ប្រើប្រាស់ឧទាហរណ៍ណាដែលបង្ហាញពីវិធី ហេតុការណ៍ផ្សេងៗ ឬគោលការណ៍ដែលអាចភ្ជាប់ទៅនឹងស្ថានភាពជីវិតពិតប្រចាំថ្ងៃ
- គ្រូត្រូវឱ្យសិស្សចេះដោះស្រាយបញ្ហាដែលពាក់ព័ន្ធ នឹងប្រធានបទនានា ដែលដំណោះស្រាយរបស់ពួកគេត្រូវតែយកសេចក្តីពន្យល់របស់គ្រូពីមុនៗមកប្រើ
- ឱ្យសិស្សយល់ពីខ្លឹមសារមេរៀនជាជាងឱ្យពួកគេទន្ទេញចាំមាត់
- បង្រៀនឱ្យសិស្សចេះប្រៀបធៀបមេរៀនពីមុនៗ ឱ្យចេះស្វែងយល់ពីភាពខុសគ្នានៃមេរៀននីមួយៗ និងឱ្យចេះទាញយកនូវខ្លឹមសារគន្លឹះសំខាន់ៗ នៃមេរៀន។

សូមមើលម៉ូឌុល ៤, ចំណុចទី១ «គរុកោសល្យបរិយាបន្ន»

នៅក្នុងគោលការណ៍ទី៧ និងទី៨នេះមានភាពស្រដៀងគ្នាមួយចំនួន។ ចំណុចសំខាន់មួយនៅក្នុងគោលការណ៍ទាំងពីរគឺត្រូវយល់ទស្សនៈ គំនិត ឬប្រធានបទឱ្យបានច្បាស់។ គោលបំណងនៃគោលការណ៍ទាំងពីរគឺដើម្បីណែនាំប្រធានបទមេរៀនថ្មីៗឱ្យសិស្ស។ ចំណុចដែលខុសប្លែកគ្នានោះ គឺស្ថិតលើចំណុចសំខាន់នៃខ្លឹមសារមេរៀន។ គោលការណ៍ទី៧ ផ្តោតទៅលើចំណេះដឹងពីមុន និងរបៀបដែលយើងយកវាមកប្រើសម្រាប់ប្រធានបទថ្មី។ ប៉ុន្តែសម្រាប់គោលការណ៍ទី៨ គឺផ្តោតទៅលើរបៀបចងចាំព័ត៌មានចាស់និងប្រើប្រាស់ ដើម្បីទទួលបានចំណេះដឹងថ្មី។

ក្នុងវិធីទាំងពីរនេះគ្រូត្រូវប្រើឧទាហរណ៍ ដើម្បីពន្យល់ ឬបង្ហាញខ្លឹមសារពិតនៃមេរៀន។ មានគោលការណ៍ពីរទៀត ដែលមានទំនាក់ទំនងយ៉ាងជិតស្និតជាមួយគោលការណ៍នេះគឺគោលការណ៍ទី៣ និងគោលការណ៍បន្ទាប់(ទី៩) ព្រោះគោលការណ៍ទាំងពីរនេះ ផ្តោតទៅលើទំនាក់ទំនងរវាងអ្វី ដែលយកមកបង្រៀននិងស្ថានភាពជីវិតពិត។ គោលការណ៍ទាំង១២ មានគោលដៅតែមួយគឺរៀបចំឱ្យសិស្សទទួលបាននូវជីវិត ដែលមានអនាគតល្អ ហើយយកចំណេះដឹងទាំងនេះទៅប្រើប្រាស់នៅក្នុង និងក្រៅសាលារៀន។ "ការសិក្សាវានឹងមានភាពប្រសើរឡើងនៅពេល ដែលយើងចេះប្រើប្រាស់សម្ភារឧបទ្ទេសឱ្យបានត្រឹមត្រូវស្របតាមខ្លឹមសារមេរៀន និងការពន្យល់ ជាជាងផ្តែកទៅលើការទន្ទេញឱ្យចាំព័ត៌មាន ដែលវាបានកាត់ផ្តាច់ទំនាក់ទំនងអង្គហេតុពិត និងដំណើរការជាក់ស្តែង" (Vosniadou,2001, 20)។

១.៩- ជួយសិស្សឱ្យចេះផ្ទេរចំណេះដឹង

សិស្សយល់ខ្លឹមសារមេរៀនច្រើនប្រសិនបើអាចផ្សារភ្ជាប់អ្វីដែលពួកគេរៀនទៅនិងស្ថានភាពជីវិតពិតក្នុងជីវភាពប្រចាំថ្ងៃ។ វាពិតជាសំខាន់ណាស់ដែលគ្រូអាចជួយបង្រៀនសិស្សឱ្យចេះផ្ទេរចំណេះដឹងរបស់ពួកគេពីទ្រឹស្តីទៅជាការអនុវត្ត។ គ្រូអាចជួយសិស្ស ដោយគ្រាន់តែធ្វើឱ្យគេយល់ដឹងព័ត៌មានឱ្យបានច្បាស់លាស់ ដោយសារនេះគឺជាមូលដ្ឋានគ្រឹះ ក្នុងការប្រើប្រាស់ចំណេះដឹងនៅក្នុងជីវិតពិត។ មានការសិក្សាជាច្រើនបានបង្ហាញថា សិស្សមួយចំនួនមិនអាចប្រើចំណេះដឹង(ទ្រឹស្តី)ដែលពួកគេទទួលបាននៅសាលារៀន សម្រាប់ដោះស្រាយបញ្ហាក្នុងជីវិតពិតរបស់ពួកគេបាន ទោះបីនេះជាគោលដៅដ៏សំខាន់នៅក្នុងការអប់រំក៏ដោយ។ សមត្ថភាពក្នុងការប្រើប្រាស់អ្វីដែលបានរៀននៅសាលារៀន ដើម្បីដោះស្រាយបញ្ហាជីវិតប្រចាំថ្ងៃ គឺជាគន្លឹះសំខាន់ដំរុញទឹកចិត្ត ដែលញុំាងឱ្យសិស្សចង់តែទៅសាលារៀន (Vosniadou,2001)។

គ្រូគួរតែប្រើលំហាត់អនុវត្តទាំងឡាយណា ដែលសិស្សអាចយកចំណេះដឹងពីមុខវិជ្ជាផ្សេងៗមកប្រើប្រាស់។ បន្ថែមពីនេះទៀត គ្រូគួរតែលើកឧទាហរណ៍ដែលពាក់ព័ន្ធនឹងទ្រឹស្តីផ្សេងៗមកអនុវត្តក្នុងជីវិតពិត។

ខាងក្រោមនេះជាគំនិតមួយចំនួន ដែលគ្រូអាចប្រើប្រាស់បានធ្វើក្នុងដំណើរជួយសិស្សដែលអាចផ្ទេរចំណេះដឹងដែលបានសិក្សាពីសាលារៀន៖

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

- គ្រូត្រូវប្រាកដក្នុងចិត្តថា ការយល់មេរៀនគឺជាមូលដ្ឋានគ្រឹះនៃការផ្ទេរព័ត៌មាន
- លើកឧទាហរណ៍ប្រាប់សិស្សនូវទ្រឹស្តីដែលបានរៀនពីមុនៗ ដោយបញ្ចូលទៅក្នុងស្ថានភាពជីវិតពិតប្រចាំថ្ងៃ
- ប្រើទ្រឹស្តីដែលកំពុងពិភាក្សា ហើយបង្ហាញពីវិធីដែលវាទាក់ទងទៅនឹងជីវិតពិតប្រចាំថ្ងៃ ឧទាហរណ៍ បង្ហាញរូបមន្តគណិតវិទ្យា និងបន្តទៅដោះស្រាយចំណោទគណិតវិទ្យា
- បង្ហាញពីទំនាក់ទំនងរបស់មេរៀនពីរផ្សេងគ្នា ឬមានទំនាក់ទំនងជាមួយគ្នា
- បង្ហាញពីភាពអរូបីនៃគោលការណ៍សំខាន់ៗពីគំនិតពិតនានា(មើលគោលការណ៍ទី៨)
- ពន្យល់ប្រាប់សិស្សឱ្យបានច្បាស់ពីរបៀបសួរ និងប្រើប្រាស់ចម្លើយដើម្បីឆ្លុះបញ្ចាំងកែលម្អលទ្ធផលសិក្សារបស់គេ
- ព្យាយាមធ្វើឱ្យសិស្សយល់ពីមេរៀនជាជាងឱ្យពួកគេទន្ទេញចាំមាត់។ (គោលការណ៍ទី៨)

ដើម្បីទទួលបានជោគជ័យក្នុងការផ្ទេរព័ត៌មាន វាចាំបាច់ណាស់ដែលត្រូវយល់មេរៀនជាជាងទន្ទេញរត់មាត់(ដែលបានភ្ជាប់គោលការណ៍ទី៨ និងគោលការណ៍ទី៩)។ ចំណុចទាក់ទងគ្នារវាងគោលការណ៍ទាំងពីរនេះ គឺបានស្នើឱ្យយើងចេះប្រើប្រាស់ឧទាហរណ៍នៅក្នុងជីវិតពិតប្រចាំថ្ងៃ ដើម្បីជួយសិស្សឱ្យយល់ច្បាស់មេរៀន និងប្រើប្រាស់ព័ត៌មាន។ ការចេះលើកជាសំណើ សុំមតិឆ្លើយតបវាបានជួយសិស្សឱ្យយល់ដឹងពីដំណើរការសិក្សាឆ្លុះបញ្ចាំងពីចំណេះដឹងខ្លួន គឺជាការទាក់ទងគ្នារវាងគោលការណ៍មួយទៅគោលការណ៍មួយ ដូចដែលមានចែងនៅក្នុងគោលការណ៍ទី៦។ ការសិក្សាកាន់តែមានន័យនៅពេលដែលមេរៀនដែលបានរៀនអាចយកមកបកប្រែប្រាស់បាននៅក្នុងជីវិតពិតប្រចាំថ្ងៃ(Vosniadou, 2001, 22)។

សូមមើលម៉ូឌុល ៣, ចំណុចទី៣ «ប្រសិទ្ធភាពអំណាច និងការប្តេជ្ញាចិត្តខ្លួនឯង»

១.១០- ចំណាយពេលដើម្បីអនុវត្តផ្ទាល់

ការសិក្សា អាចជាសកម្មភាពដែលងាយនឹងឈឺចាប់។ យើងត្រូវទទួលស្គាល់ថា ចំណេះដឹងដែលយើងមានគឺ មិនគ្រប់គ្រាន់ទេ យើងនៅតែត្រូវការព័ត៌មានថ្មី និងគំនិតថ្មីបន្ថែមទៀតជាចាំបាច់។ (Mehta,2015,online) ការទទួលស្គាល់អំពីកង្វះសមត្ថភាពព្រមទាំងការទទួលបាននូវសមត្ថភាពថ្មី ដែលបាននិយាយខាង

ដើមទាមទារនូវពេលវេលា និងកិច្ចខិតខំប្រឹងប្រែង។ ដើម្បីឱ្យសិស្សមានពេលវេលាគ្រប់គ្រាន់ក្នុងការភ្ជាប់ខ្លួនគេក្នុងការអភិវឌ្ឍសមត្ថភាព គ្រូបង្រៀនទាំងឡាយគួរតែផ្តល់បទពិសោធក្នុងការសិក្សាតែលើមួយប្រធានបទបានហើយ នៅក្នុងលំហាត់ឬមេរៀននីមួយៗ។ ការធ្វើរបៀបនេះ ធ្វើឱ្យសិស្សបង្កើតសមត្ថភាពយល់មេរៀនកាន់តែល្អ និងមិនធ្វើឱ្យសិស្សមានការពិបាក។ លើសពីនេះគ្រូអាចជួយដល់ដំណើរការសិក្សារបស់សិស្សឱ្យកាន់តែល្អប្រសើរ ដោយធ្វើការទាក់ទងជាមួយអាណាព្យាបាលរបស់សិស្ស ហើយធ្វើបច្ចុប្បន្នភាពឱ្យពួកគេបានដឹងនូវអ្វីដែលខ្លួនបង្រៀននៅក្នុងថ្នាក់។ ធ្វើដូច្នេះគ្រូបានគាំទ្រឪពុកម្តាយរបស់សិស្សក្នុងការផ្តល់ឱ្យសិស្សនូវបទពិសោធនៃការសិក្សាប្រកបដោយផ្លែផ្កា (Vosniadou,2001)។

- ត្រូវបង្កើនម៉ោងសិក្សាដល់សិស្សដែលត្រូវរៀនមុខវិជ្ជានៅក្នុងថ្នាក់។
- ត្រូវដាក់កិច្ចការឱ្យសិស្សនូវអ្វីដែលសមស្របទៅនឹងអ្វីដែលពួកគេបានរៀននៅក្នុងថ្នាក់។
- ត្រូវយកចំណុចសំខាន់តែមួយ ឬពីរប៉ុណ្ណោះនៅក្នុងម៉ោងសិក្សាមួយពេលដើម្បីឱ្យសិស្សចាប់បាននូវចំណេះដឹងថ្មីបានល្អ។
- លើកទឹកចិត្តសិស្សឱ្យចូលរួមធ្វើការឆ្លុះបញ្ចាំងត្រលប់ឱ្យបានសកម្មទៅលើព័ត៌មានថ្មីៗ ហើយបន្ទាប់មកឱ្យសិស្សសាកល្បងប្រើចំណេះដឹងថ្មីទាំងនោះ
- ត្រូវផ្តល់សម្ភារៈសិក្សា ឬរៀបសាយឱ្យសិស្សបានដឹងដែលគេអាចចូលទៅប្រើប្រាស់បាន
- ត្រូវមានទំនាក់ទំនងល្អជាមួយឪពុកម្តាយសិស្ស។

ជាថ្មីម្តងទៀតគោលការណ៍នេះជាប់ទាក់ទងជាមួយនឹងគោលការណ៍ដទៃទៀតដូចជាគោលការណ៍ទី១ ។"ចូលរួមយ៉ាងសកម្ម" នេះជាជំហានដំបូងដែលធ្វើឱ្យសិស្សជ្រើសរើសទៅរៀន ដោយសារនៅក្នុងមុខវិជ្ជានោះមានការចូលរួមពីពួកគេធ្វើឱ្យពួកគេចាប់អារម្មណ៍ ហើយនឹងបានយល់ច្រើន។ យើងឃើញថា នៅក្នុងគោលការណ៍ទី៨នេះផ្តោតលើការយល់មេរៀនជាជាងរៀនដោយទន្ទេញចាំមាត់។ "ការសិក្សាគឺជាដំណើរដ៏ស្មុគស្មាញមួយក្នុងការកសាងសមត្ថភាព ចំណេះដឹង) (បំណិនអនុវត្ត និងឥរិយាបទ ដែលយើងមិនអាចបង្ខំបានទេ។ វាទាមទារឱ្យមានពេលវេលានិងការអនុវត្តឱ្យបានច្រើនដង ដើម្បីឱ្យបានស្ទាត់ជំនាញនៅក្នុងវិស័យអ្វីមួយ" (Vosniadou,2001)។

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

១.១១- ភាពខុសគ្នារវាងការអភិវឌ្ឍ និងបុគ្គលម្នាក់ៗ

នៅក្នុងថ្នាក់នីមួយៗតែងតែមានសិស្សដែលមានសមត្ថភាព ចំណេះដឹង និងមកពីស្ថានភាពគ្រួសារវប្បធម៌ខុសគ្នា។ ជាមួយនឹងចំណេះដឹងថ្មីដែលពួកគេបានរៀន សិស្សអាចធ្វើការផ្លាស់ប្តូរទស្សនៈ និងយុទ្ធសាស្ត្រក្នុងការប្រើប្រាស់ចំណេះដឹងថ្មីៗជាមួយគ្នា (Vosniadou,2001)។

សិស្សនីមួយៗមិនត្រឹមតែមានចំណេះដឹងខុសៗទេ ថែមទាំងដំណើរការយល់មេរៀនក៏ខុសគ្នាដែរ។ សាលាចាំបាច់ត្រូវផ្តល់បរិយាកាសឱ្យពួកគេម្នាក់ៗបង្កើនល្បឿនសិក្សារៀងៗខ្លួន ហើយយកចិត្តទុកដាក់ទៅលើសមត្ថភាពរបស់ពួកគេផងដែរ។ ដូចនេះ គ្រូត្រូវផ្តល់មធ្យោបាយសិក្សា និងលំហាត់អនុវត្តទៅតាមសិស្សម្នាក់ៗតាមដែលអាចធ្វើបាន។ លើសពីនេះទៀតស្វែងរកចំណុចខ្លាំងរបស់គេដើម្បីឱ្យយល់កាន់តែស៊ីជម្រៅ។ លំហាត់អនុវត្តដែលមានប្រយោជន៍មួយចំនួនទៀតនោះគឺឱ្យសិស្សប្រាស្រ័យទាក់ទងជាមួយក្រុមមនុស្សដែលមានចំណេះដឹងដូចគេ ហើយស្វះស្វែងជួយសិស្សក្នុងដំណើរការសិក្សានេះ (Vosniadou,2001)។

ដើម្បីឱ្យបានយល់ច្បាស់ពីសិស្សទាំងអស់ ពីភាពខុសប្លែកគ្នារវាងសិស្សម្នាក់ៗ និងការលើកកម្ពស់ការអភិវឌ្ឍនៅក្នុងសាលារៀន គ្រូអាចប្រើប្រាស់គំនិតខាងក្រោម៖

- យល់ឱ្យបានច្បាស់នូវវិធីសាស្ត្រវាយតម្លៃការសិក្សារបស់សិស្ស ដោយគិតពីសមត្ថភាពយល់ដឹងរបស់សិស្សម្នាក់ៗ
- ផ្តល់សម្ភារៈសិក្សាឱ្យសិស្សឱ្យបានច្រើនប្រភេទតាមតែអាចធ្វើបាន ដូចជាសៀវភៅ វេបសាយ និងទៅសារៈមន្ទីរ។ល។
- ស្វែងយល់ឱ្យច្បាស់លាស់អំពីសមត្ថភាពខ្លាំងរបស់សិស្សនៅត្រង់ណា ជាពិសេសផ្តោតទៅលើសមត្ថភាពទាំងនោះនៅពេលដែលសិស្សអនុវត្ត
- ចេះប្រើចំណុចខ្លាំងរបស់សិស្ស ដើម្បីជួយគេឱ្យរៀនកាន់តែពូកែឡើង
- ត្រូវបង្ហាញទំនាក់ទំនងរវាងអ្វីដែលកំពុងរៀន និងអ្វីដែលមានក្នុងជីវិតពិត
- ជំរុញសិស្សឱ្យចេះពិនិត្យឡើងវិញនូវអ្វីដែលពួកគេបានរៀនដោយបង្កើតសំណួរត្រិះរិះ
- ត្រូវចេះទាញចំណាប់អារម្មណ៍សិស្សឱ្យផ្តោតលើសមត្ថភាពរបស់ពួកគេក្នុងការប្រើប្រាស់ចំណុចខ្លាំងដើម្បីស្វែងរកដំណោះស្រាយដែលមានក្នុងជីវិត

- ផ្តល់ឱកាសឱ្យសិស្សមានទំនាក់ទំនងជាមួយគ្នា ហើយពិភាក្សាជាមួយមនុស្សពេញវ័យទាំងឡាយណាដែលមានចំណេះដឹងទូលំទូលាយ
- បង្កើតឱកាសឱ្យសិស្សសាកល្បងប្រើប្រាស់សមត្ថភាពចំណេះដឹងដែលទើបតែរៀនថ្មីៗ

ជារួមគោលការណ៍នេះ ជាការបូកបញ្ចូលនៃគោលការណ៍ដទៃទៀតជាច្រើន។ យុទ្ធសាស្ត្រដែលគួរយកមកប្រើ ស្រដៀងនឹងគោលការណ៍ទី៣ ដែលបង្ហាញពីសកម្មភាពដ៏មានសារៈប្រយោជន៍។ នៅក្នុងគោលការណ៍ទី៨ គ្រូត្រូវប្តូរពីការឱ្យសិស្សទន្ទេញមេរៀន មកជាការសិក្សាឱ្យយល់ពីមេរៀនធ្វើ។ ដូចនេះទើបបង្កើនចំណាប់អារម្មណ៍របស់សិស្សឱ្យចំណាយពេលវេលា និងកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត(ដូចគ្នានឹងគោលការណ៍ទី១០ដែរ)។ គោលការណ៍ដែលស្រដៀងនឹងគោលការណ៍ទី១១នេះដែរគឺ គោលការណ៍ទី៩ដែលផ្តោតលើការផ្ទេរចំណេះដឹងជាទ្រឹស្តីដែលបានរៀននៅក្នុងថ្នាក់យកទៅអនុវត្តនៅក្នុងស្ថានភាពពិតជាក់ស្តែង។ "សិស្សម្នាក់អាចរៀនពូកែបាននៅពេលមានការយកចិត្តទុកដាក់ទៅលើភាពខុសគ្នារបស់ពួកគេ" (Vosniadou,2001,25)។

១.១២- បង្កើតអ្នកសិក្សាប្រកបដោយកម្លាំងចិត្ត

ដំណើរការសិក្សា ដែលប្រកបដោយជោគជ័យកើតឡើងដោយសារកម្លាំងចិត្តរបស់អ្នកសិក្សា។ កំលាំងចិត្តនេះវាអាចកើតឡើងចំពោះសិស្សបានដោយសារគ្រូបង្រៀនរបស់ពួកគេ។ មានកម្លាំងចិត្តពីរប្រភេទគឺ កម្លាំងចិត្តខាងក្រៅ និងកម្លាំងចិត្តខាងក្នុង។ កម្លាំងចិត្តខាងក្រៅអាចជាការ បានពិន្ទុល្អពីគ្រូ ឬជាការលើកទឹកចិត្តមួយចំនួនដូចជា ការសរសើរពីគ្រូជាដើម។ ចំណែកឯកម្លាំងចិត្តខាងក្នុងគឺជាកម្លាំងចិត្តពីខាងក្នុងចិត្តរបស់សិស្ស ដែលគេចូលចិត្តរៀនមុខវិជ្ជាណាមួយ ឬមេរៀនណាមួយ។ គ្រូទាំងឡាយអាចបង្កើតការលើកទឹកចិត្តឱ្យសិស្សតាមរយៈការសរសើរសិស្សចំពោះកិច្ចការរបស់ពួកគេ។ វិធីមួយទៀតនោះគឺ ឱ្យមតិត្រឡប់ទៅសិស្ស។ ដូច្នេះពួកគេយល់ច្បាស់នូវអ្វីដែលពួកគេកំពុងធ្វើ និងអ្វីដែលត្រូវកែលម្អ។ សរុបមក គ្រូបង្រៀនអាចផ្តល់កម្លាំងចិត្តឱ្យសិស្សរបស់ពួកគេបានតាមរយៈបង្កើតឱ្យមានបរិយាកាសសហប្រតិបត្តិការជាជាងការប្រកួតប្រជែងគ្នា។

ដើម្បីលើកទឹកចិត្តសិស្សបានគ្រូបង្រៀនត្រូវ៖

- ទទួលស្គាល់នូវស្នាដៃ ឬសមិទ្ធផលផ្សេងៗរបស់សិស្ស

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

- ភ្ជាប់ស្នាដៃរបស់សិស្សទៅនឹងខ្លួនរបស់គេផ្ទាល់ ឧទាហរណ៍ដូចជា "វិធីសាស្ត្រដោះស្រាយបញ្ហារបស់ប្អូនពិតជាមានភាពច្នៃប្រឌិតណាស់" ឬក៏ "គំនិតរបស់ប្អូនល្អមែន" ជាជាងនិយាយតែថា "នេះគឺជាគំនិតដ៏ល្អមួយ"
- បង្កើតការទុកចិត្តលើខ្លួនឯងដល់សិស្ស ឧទាហរណ៍ដូចជា "ប្អូនកំពុងធ្វើវាបានល្អ សូមប្អូនបន្តធ្វើឱ្យបានល្អបន្ថែមទៀត" ឬក៏ "ខ្ញុំដឹងថាប្អូនកំពុងតែខិតខំធ្វើកិច្ចការសាលារបស់អ្នក ហើយនិទ្ទេសរបស់ប្អូននឹងបានល្អប្រសើរ"។
- ជួយសិស្សបង្កើតគោលដៅច្បាស់លាស់មួយ
- ផ្តល់មតិត្រឡប់ដែលមានប្រយោជន៍ដល់សិស្ស។

ចំណុចសំខាន់ដទៃៗទៀតនោះគឺ កុំឱ្យសិស្សធ្វើការជាក្រុមជាមួយអ្នក ដែលមានជំនាញចំណេះដឹងដូចគ្នា ព្រោះវាអាចឱ្យពួកគេគិតថា ជំនាញរបស់ពួកគេវាសំខាន់ជាងការខិតខំប្រឹងប្រែងរបស់ពួកគេទៅវិញ។ ធ្វើឱ្យសិស្សសហការគ្នាជាជាងឱ្យពួកគេប្រកួតប្រជែងគ្នា។ ហើយគ្រូត្រូវធ្វើយ៉ាងណាឱ្យសិស្សមានចម្ងល់ចង់ចេះជាបន្តបន្ទាប់។ ដូច្នេះគ្រូត្រូវណែនាំប្រធានបទថ្មី ឬកិច្ចការថ្មីឱ្យសិស្សធ្វើជានិច្ចកាល។ ហើយកុំភ្លេចត្រូវរកលំហាត់ថ្មី ឬប្រធានបទថ្មីៗណាដែលត្រូវនឹងកម្រិតរបស់សិស្ស។ "ការរៀនបែបសកម្ម ជាការទទួលឥទ្ធិពលយ៉ាងខ្លាំង ពីការជំរុញទឹកចិត្តសិស្ស។ គ្រូអាចជួយសិស្សឱ្យមានកម្លាំងចិត្តក្នុងការរៀនតាមរយៈការកសាងសមត្ថភាពនិងឥរិយាបថរបស់ពួកគេ" (Vosniadou,2001,27)។

២- សេចក្តីសន្និដ្ឋាន

សរុបសេចក្តីមក គោលបំណងនៃគោលការណ៍ទាំង១២នេះ គឺ បង្កើតការបង្រៀនដែលគិតពីសមត្ថភាពជំនាញ និងប្រវត្តិរបស់អ្នកសិក្សាទាំងឡាយព្រមទាំងសម្របសម្រួលដំណើរការសិក្សា ឱ្យត្រូវទៅនឹងជីវិតពិតក្នុងជីវភាពប្រចាំថ្ងៃ ដើម្បីទាក់ទាញអ្នកសិក្សាឱ្យមានកម្លាំងចិត្តរៀនកាន់តែខ្លាំងឡើង។ ធ្វើបែបនេះទើបអ្នកសិក្សាមានលទ្ធផលល្អទាំងនៅក្នុងថ្នាក់ និងក្រៅថ្នាក់។ វាមានភាពចាំបាច់ណាស់ដែលអ្នកសិក្សាត្រូវមានជំនាញមួយចំនួន នៅសាលារៀនដែលអាចឱ្យពួកគេប្រើប្រាស់សម្រាប់ដោះស្រាយបញ្ហានៅក្នុងជីវិតការងារនាពេលបច្ចុប្បន្ន និងអនាគត។ ការរៀនសូត្រពីបទពិសោធនិងគំនិតអ្នកដទៃឱ្យបានច្រើន អាចយកមកប្រើជាផលប្រយោជន៍ផ្ទាល់ខ្លួនធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅប្រចាំថ្ងៃ ក៏ដូចជាអាចបញ្ចេញគំនិតរបស់ខ្លួនឯងដែលអ្នកដទៃអាចយល់បាន ហើយនឹងអាច

ចូលរួមនៅក្នុងស្ថានភាពផ្សេងៗ ដោយសកម្មច្បាស់លាស់ និងមានប្រសិទ្ធភាព។ នេះមានន័យថាគោលដៅចុងក្រោយបំផុតនោះគឺជាការផ្លាស់ប្តូរទស្សនៈដ៏ធំមួយពីការបង្រៀនតាមគោលវិធីគ្រូមជ្ឈមណ្ឌល ទៅសិស្សមជ្ឈមណ្ឌល។

រូបទី២៖ ចតុស្តម្ភនៃការអប់រំ[1]

៣- ចំណុចសំខាន់ៗ

ដើម្បីសម្របការសិក្សាទៅនឹងជីវិតពិតក្នុងពេលអនាគតរបស់អ្នកសិក្សាឱ្យកាន់តែមានប្រសិទ្ធភាពទៀតនោះ វាចាំបាច់ណាស់ដែលយើងត្រូវផ្លាស់ប្តូរការអប់រំពីគ្រូមជ្ឈមណ្ឌលទៅសិស្សមជ្ឈមណ្ឌល៖

- ការចូលរួមដោយសកម្មក្នុងថ្នាក់៖ ដំណើរការសិក្សាដែលទាមទារឱ្យមានការចូលរួមប្រកបដោយស្ថាបនា និងសកម្មពីអ្នកសិក្សាទាំងឡាយដើម្បីបង្កើតគំនិតផ្ទាល់ខ្លួននីមួយៗឱ្យគេបានឃើញនៅក្នុងថ្នាក់
- ការចូលរួមនៅក្នុងសង្គម៖ ការចូលរួមនៅក្នុងកិច្ចការសង្គម និងសហប្រតិបត្តិការនៅក្នុងថ្នាក់រៀនមានឥទ្ធិពលយ៉ាងខ្លាំងទៅនឹងការសិក្សារបស់សិស្សព្រមទាំងការលូតលាស់ផ្ទាល់ខ្លួនរបស់សិស្សផងដែរ
- លំហាត់អនុវត្តសកម្មភាពដែលមានអត្ថប្រយោជន៍៖ ដើម្បីឱ្យដំណើរការអ្នកសិក្សារបស់សិស្សម្នាក់ៗទទួលបានជោគជ័យ អ្នកសិក្សាទាំងឡាយ

[1] Taken from UNESCO (2014, p. 2). CC BY-SA.

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ត្រូវចាត់ទុកសកម្មភាពសិក្សាទាំងអស់ជាកត្តាសំខាន់ និងផ្តល់ប្រយោជន៍ដល់ការសិក្សាផ្ទាល់ខ្លួនរបស់ពួកគេ

- ភ្ជាប់ព័ត៌មានថ្មីៗទៅនឹងចំណេះដឹងមុន ៖ ការសិក្សាដែលជោគជ័យទៅបាននៅពេលដែលព័ត៌មានថ្មីត្រូវបានបូករួមជាមួយចំណេះដឹង ដែលរៀនពីមុនៗមក
- ការរៀនបែបយុទ្ធសាស្ត្រ៖ គ្រូមានតួនាទីជួយសិស្សក្នុងការបង្កើតយុទ្ធសាស្ត្រសិក្សាឱ្យបានទូលំទូលាយ ហើយប្រើប្រាស់ទៅលើកិច្ចការដែលកំពុងធ្វើ
- មានវិន័យផ្ទាល់ខ្លួន និងរៀនឆ្លុះបញ្ចាំង ៖ គ្រូមានតួនាទីជួយសិស្សបង្កើតចំណេះដឹងទៅតាមសមត្ថភាពនីមួយៗរបស់សិស្ស សេចក្តីត្រូវការ និងយុទ្ធសាស្ត្រកែតម្រូវ ដូច្នេះហើយទើបបង្កើតឱ្យមានលទ្ធផលសិក្សាល្អ
- ពិនិត្យរៀបចំចំណេះដឹងពីមុនឡើងវិញ ៖ គ្រូត្រូវប្រាកដថាចំណេះដឹងដែលទទួលបានកន្លងមកយកប្រើប្រាស់ជាមូលដ្ឋាន ដើម្បីចាប់យកចំណេះដឹងថ្មី
- ឆ្ពោះទៅការយល់មេរៀនជាជាងការទន្ទេញចាំមាត់ ៖ តម្រង់ទិសដៅសិស្សឱ្យយល់មេរៀនជាជាងទន្ទេញចាំមាត់។ សិស្សចូលចិត្តទន្ទេញព័ត៌មានឱ្យចាំ ជាងការពិតដែលពួកគេត្រូវឈ្វេងយល់។
- ជួយឱ្យសិស្សចេះរៀនផ្ទេរចំណេះដឹង ៖ គ្រូបង្រៀនអាចមានឥទ្ធិពលទៅលើដំណើរការសិក្សារបស់សិស្ស តាមរយៈបង្កើតឱ្យមានអ្នកសិក្សាប្រកបដោយកម្លាំងជំរុញទឹកចិត្ត
- ចំណាយពេលដើម្បីអនុវត្តផ្ទាល់ ៖ ការសិក្សានឹងមានន័យប្រសិនបើសិស្សអាចយកចំណេះដឹង ដែលពួកគេបានរៀនផ្សារភ្ជាប់ទៅនឹងការអនុវត្តនៅក្នុងជីវិតប្រចាំថ្ងៃ
- ភាពខុសគ្នារវាងការអភិវឌ្ឍនិងបុគ្គល ៖ ការសិក្សាគឺជាដំណើរការគិតដ៏ស្មុកស្មាញមួយជា បទពិសោធដែលទាក់ទងនឹងចិត្តចលនា ដែលត្រូវការពេលវេលា និងការអនុវត្តឱ្យបានច្រើន ដើម្បីទទួលបានជោគជ័យ។
- បង្កើតអ្នកសិក្សាប្រកបដោយកម្លាំងចិត្ត ៖ សិស្សម្នាក់ៗនៅក្នុងថ្នាក់មានសមត្ថភាព និងសេចក្តីត្រូវការផ្សេងៗពីគ្នា។ ដូច្នេះ នេះជាការកិច្ចរបស់គ្រូ និងសាលារៀន ក្នុងការផ្តល់បរិយាកាសដ៏សមរម្យមួយឱ្យពួកគេក្នុងការជួយផ្តល់សមត្ថភាព និងសេចក្តីត្រូវការទាំងនេះ និងជួយបង្កើនសមត្ថភាពសិស្សម្នាក់ៗតាមរបៀបរៀនរបស់ពួក។

ឯកសារយោង

Boekaerts, M., Pintrich, P., & Zeidner, M. (2000). *Handbook of Self-Regulation*. New York: Academic Press.

Collins, A., Brown, J.S., & Newman, S.F. (1989). Cognitive Apprenticeship: Teaching the Craft of Reading, Writing and Mathematics. In: L.B. Resnick, ed. *Knowing, Learning and Instruction: Essays in Honor of Robert Glaser* (pp. 453–84). Hillsdale, NJ.

Elmore, R.F., Peterson, P.L., & McCarthy, S.J. (1996). *Restructuring in the Classroom: Teaching, Learning and School Organization*. San Francisco, CA: Jossey-Bass.

Mehta, J. (2015). *Unlearning Is Critical for Deep Learning.* Retrieved from: https://www.edweek.org/teaching-learning/opinion-unlearning-is-critical-for-deep-learning [2021, Apr. 16].

Sileo, T. W., Prater, M. A., Luckner, J. L., Rhine, B., & Rude, H. A. (1998). Strategies to Facilitate Preservice Teachers' Active Involvement in Learning. *Teacher Education and Special Education*, 21(3), 187–204.

Ryan, R.M. & Deci, E.L. (2000). Intrinsic and Extrinsic Motivations: Classic Definitions and New Directions. *Contemporary Educational Psychology*, 25, 54-67.

The Glossary of Education Reform. (2014, May 7). *Student-Centered Learning*. Retrieved from: https://www.edglossary.org/student-centered-learning/ [2020, Apr. 27].

Thomas, S. & Anderson, E.L. (2013*). Socialization: Theories, Processes and Impact*. New York: Nova Science Publisher's.

Tuomarla, K. (2019). *Activating Methods in Classroom*. Retrieved from: https://learningscoop.fi/activating-methods-in-classroom/ [2021, Jan. 4].

UNESCO. (2014). *Learning to Live Together: Education Policies and Realities in the Asia-Pacific*. Retrieved from: https://unesdoc.unesco.org/ark:/48223/pf0000227208. ISBN 978-92-9223-473-7 (Electronic version). This publication is available in Open Access under the Attribution-ShareAlike 3.0 IGO (CC BY-SA 3.0 IGO) license (http://creativecommons.org/licenses/by-sa/3.0/igo/).

UNESCO. (2015). *Embracing Diversity: Toolkit for Creating Inclusive Learning Friendly Environments*. Retrieved from: https://unesdoc.unesco.org/ark:/48223/pf0000137522. ISBN 92-9223-032-8 (Electronic version).

Vosniadou, S. (2001). *How Children Learn*. Chicago, Illinois: IAE.

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ជំហានទី១៖ សំណួរពង្រឹងចំណេះដឹង

ក. សូមបញ្ជាក់បង្ហាញតើប្រយោគខាងក្រោមនេះត្រូវ ឬខុស៖

១.សកម្មភាពចូលរួមរបស់សិស្សទាមទារឱ្យមានការចូលរួមដែលប្រកបដោយការស្ថាបនានិងសកម្មពីសិស្សផ្ទាល់ខ្លួនដែលជាអ្នកសំយោគមេរៀននៅក្នុងថ្នាក់។ **ខុស / ត្រូវ**

២.ការចូលរួមសកម្មភាពផ្សេងៗនៅក្នុងសង្គម និងកិច្ចប្រតិបត្តិការរវាងគ្នានឹងគ្នា គ្មានឥទ្ធិពលទៅលើលទ្ធផលនៃការសិក្សារបស់សិស្សឡើយ។ **ខុស / ត្រូវ**

៣.ដើម្បីជោគជ័យ សិស្សត្រូវពិចារណាទៅលើសកម្មភាពរបស់ខ្លួនណាដែលសំខាន់ ហើយមានប្រយោជន៍ដល់ការសិក្សាផ្ទាល់ខ្លួនរបស់ពួកគេ។ **ខុស/ ត្រូវ**

៤.ការសិក្សាដែលជោគជ័យទៅបាន នៅពេលដែលអ្នកសិក្សាចេះតភ្ជាប់ចំណេះដឹងចាស់ៗទៅនឹងព័ត៌មានថ្មីៗ។ **ខុស / ត្រូវ**

៥.គ្រូមាននាទីជួយសិស្សបង្កើតយុទ្ធសាស្ត្រសិក្សាឱ្យបានទូលំទូលាយ ហើយឱ្យចេះប្រើវាបានត្រូវនឹងកិច្ចការដែលមាន។ **ខុស / ត្រូវ**

៦.គ្រូគ្មានឥទ្ធិពលទៅលើសិស្សក្នុងការអភិវឌ្ឍសមត្ថភាព និងសេចក្តីត្រូវការរបស់សិស្សម្នាក់ៗនោះទេ។ **ខុស / ត្រូវ**

៧.គ្រូអាចធ្វើសេចក្តីសន្និដ្ឋានដោយស្វ័យប្រវត្តិថាចំណេះដឹងពីមុនៗ របស់សិស្សសុទ្ធតែត្រឹមត្រូវដោយមិនចាំបាច់ពិនិត្យមើលឡើងវិញឡើយ។ **ខុស / ត្រូវ**

៨.សិស្សមានទំនោរទៅលើ ការទន្ទេញព័ត៌មាន បានរៀនច្រើនជាងព័ត៌មាន ដែលពួកគេបានឮ ឬយល់។ **ខុស / ត្រូវ**

៩.ការសិក្សាមានន័យបាន លុះត្រាតែអ្នកសិក្សាអាចតភ្ជាប់នូវអ្វីដែលពួកគេរៀនទៅអ្វីដែលមាននៅក្នុងជីវិតពិតប្រចាំថ្ងៃ។ **ខុស / ត្រូវ**

១០.ការសិក្សាជាបទពិសោធដ៏សាមញ្ញមួយដែលមិនត្រូវការពេលវេលា និងការអនុវត្តច្រើនឡើយ។ **ខុស / ត្រូវ**

១១.សិស្សទាំងអស់នៅក្នុងថ្នាក់រៀនមានស្ថានភាពប្រហាក់ប្រហែលគ្នា។ ដូច្នេះការជួយពួកគេម្នាក់ៗជាបុគ្គលគឺពុំចាំបាច់ឡើយ។ **ខុស / ត្រូវ**

១២.គ្រូអាចមានឥទ្ធិពលទៅលើការសិក្សារបស់សិស្ស ដោយបង្កើតឱ្យមានអ្នកសិក្សាប្រកបកម្លាំងជំរុញទឹកចិត្ត។ **ខុស / ត្រូវ**

ខ. ចូរដាក់ឧទាហរណ៍ខាងក្រោមទៅតាមប្រភេទឱ្យបានត្រឹមត្រូវនៅក្នុងតារាងខាងក្រោម៖

១. សួរសំណួរដែលជំរុញឱ្យសិស្សមានមតិត្រលប់

២. បញ្ចូលលំហាត់អនុវត្តន៍

៣. ផ្តល់ឱកាសឱ្យសិស្សទទួលបាន និងបញ្ចេញមតិណែនាំ

៤. បង្កើតទំនាក់ទំនងគ្នារវាងខ្លឹមសារមេរៀន ជីវិតពិត និងសហគមន៍

៥. បង្កើតឱ្យមានការសម្តែង

៦. សិស្សរៀបចំបទបង្ហាញប្រធានបទថ្មី

៧. ផ្តល់ឱកាសឱ្យសិស្សវាយតម្លៃកិច្ចការរបស់ខ្លួន

៨. រៀបចំឱ្យមានដំណើរកម្សាន្ត

៩. ទុកឱកាសឱ្យសិស្សចេះធ្វើការឆ្លុះបញ្ចាំងផ្ទាល់ខ្លួន

១០. ប្រើចំណុចខ្លាំងរបស់សិស្ស

១១. បង្កើតបរិយាកាសដែលអនុគ្រោះដល់ជំនឿផ្សេងៗរបស់សិស្ស

១២. ប្រើឧទាហរណ៍

១៣. ផ្តល់ឱកាសឱ្យសិស្សមានឥទ្ធិពលលើដំណើរការសិក្សា

១៤. ផ្តល់ពេលវេលាគ្រប់គ្រាន់ឱ្យសិស្ស

១៥. សិស្សពន្យល់ដំណើរការ និងច្បាប់ផ្សេងៗដោយមិនប្រើប្រាស់សៀវភៅសិក្សារបស់ពួកគេ

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

១៦. ដាក់លំហាត់ឱ្យសិស្សធ្វើត្រូវនឹងជំនាញសមត្ថភាព

១៧. ផ្តល់ឱកាសឱ្យសិស្សធ្វើការជាមួយគ្នា ការពិភាក្សា និងការងារជាក្រុម

១៨. ដាក់ការងារឱ្យសិស្សធ្វើដែលសមស្របទៅនឹងសមត្ថភាពដែលពួកគេបានរៀន

១៩. អញ្ជើញអ្នកវិទ្យាសាស្ត្រ ឬអ្នកជំនាញមកចែករំលែកក្នុងថ្នាក់

២០. បង្រៀនតែមួយ ឬពីរប្រធានបទតែប៉ុណ្ណោះក្នុងមួយពេលសិក្សា

២១. ធ្វើការពិភាក្សាមុនពេលបង្រៀនប្រធានបទថ្មី

២២. ទទួលស្គាល់សមិទ្ធផលរបស់សិស្ស

២៣. បង្កើតឱ្យសិស្សមានទំនុកចិត្តលើខ្លួនឯង

២៤. ឱ្យសិស្សសង្ខេបអត្ថបទបន្ទាប់ពីអានរួច

២៥. ឱ្យសិស្សមានជម្រើសក្នុងការរៀបចំផែនការ និងរចនាសម្ព័ន្ធលំហាត់អនុវត្ត

២៦. ជួយសិស្សស្វែងរកយុទ្ធសាស្ត្រសិក្សា

ការចូលរួមដោយសកម្មក្នុងថ្នាក់	ការចូលរួមចំណែកក្នុងសង្គម	លំហាត់សកម្មភាពដែលមានប្រយោជន៍	ភ្ជាប់ព័ត៌មានថ្មីៗទៅនឹងចំណេះដឹងពីមុន
ការរៀនបែបយុទ្ធសាស្ត្រ	មានវិន័យផ្ទាល់ខ្លួន និងរៀនឆ្លុះបញ្ចាំង	ពិនិត្យ រៀបចំចំណេះដឹង ឡើងវិញ	ឆ្ពោះទៅកាន់ការយល់មេរៀនជាជាងការទន្ទេញចាំមាត់
ជួយឱ្យសិស្សចេះរៀនផ្ទៃចំណេះដឹង	ចំណាយពេលដើម្បីអនុវត្តផ្ទាល់	ភាពខុសគ្នារវាងការអភិវឌ្ឍនិងបុគ្គល	បង្កើតអ្នកសិក្សាប្រកបដោយកម្លាំងចិត្ត

គ. ចូរដាក់គោលការណ៍ខាងក្រោមនេះចូលទៅក្នុងតារាងខាងក្រោមឱ្យបានត្រឹមត្រូវ៖

សម្គាល់៖ ក្នុងតារាងនីមួយៗអាចដាក់គោលការណ៍បានលើសពីមួយ។

១. ការចូលរួមដោយសកម្ម

២. ការចូលរួមចំណែកក្នុងសង្គម

៣. លំហាត់អនុវត្តសកម្មភាពដែលមានប្រយោជន៍

៤. ភ្ជាប់ព័ត៌មានថ្មីៗទៅនឹងចំណេះដឹងពីមុន

៥. ការរៀនបែបយុទ្ធសាស្ត្រ

៦. វិន័យផ្ទាល់ខ្លួននិងការឆ្លុះបញ្ចាំង

៧. ពិនិត្យរៀបចំចំណេះដឹងពីមុនឡើងវិញ

៨. ឆ្ពោះទៅកាន់ការយល់ ជាជាងការទន្ទេញចាំមាត់

៩. ជួយឱ្យសិស្សចេះរៀនផ្ទៃចំណេះដឹង

១០. ចំណាយពេលដើម្បីអនុវត្តផ្ទាល់

១១. ភាពខុសគ្នារវាងការអភិវឌ្ឍ និងបុគ្គល

១២. បង្កើតអ្នកសិក្សាប្រកបដោយកម្លាំងចិត្ត

ការចែករំលែក និងរួមសហការដ៏សកម្ម	
ការផ្សារភ្ជាប់រវាងសាលារៀន និងស្ថានភាពនៅក្នុងជីវិតពិត	
ការប្រាស្រ័យទាក់ទងក្នុងសង្គម	

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

វាយតម្លៃការងារផ្ទាល់ខ្លួន	
ការផ្សារភ្ជាប់រវាងចំណេះដឹងថ្មី និងចំណេះដឹងមានស្រាប់	
ការយល់ខ្លឹមសារ ជាជាងការ-ទន្ទេញចាំមាត់	

ឃ: ចូរសរសេរសំណេរខ្លី (ប្រហែល៥០០ពាក្យ) អំពីសំណួរស្វ័យឆ្លុះបញ្ចាំងដូចខាងក្រោម៖

១. តើអ្នកមានបទពិសោធអ្វីខ្លះអំពីការអប់រំតាមបែបគ្រូមជ្ឈមណ្ឌល និងសិស្សមជ្ឈមណ្ឌល? តើអ្នកទទួលបានបទពិសោធអ្វីខ្លះកាលអ្នកនៅជាសិស្ស? តើវាបានជួយអ្នកក្នុងការសិក្សាដែរ ឬទេ? ឬថាតើអ្នកត្រូវការអ្វីផ្សេងទៀតដែលគួរជួយដល់ដំណើរការសិក្សារបស់អ្នកឱ្យកាន់តែបានច្រើនជាអតិបរមា?

ចូរគិតអំពីវិធីបង្រៀនដែលគ្រូរបស់អ្នកធ្លាប់បានប្រើក្នុងការបង្រៀនអ្នកនៅក្នុងសាលា និងរបៀបដែលអ្នកត្រូវបានបង្រៀនពីវិធីសាស្ត្របង្រៀន។ ចូរសរសេរពីអារម្មណ៍របស់អ្នកអំពីវិធីសាស្ត្រទាំងពីរនេះ។[2]

	ឃ: ចូរសរសេរសំណេរខ្លី (ប្រហែល ៥០០ពាក្យ) អំពីសំណួរស្វ័យឆ្លុះបញ្ចាំងដូចខាងក្រោម៖	**ឃ:** ចូរសរសេរសំណេរខ្លី (ប្រហែល ៥០០ពាក្យ) អំពីសំណួរស្វ័យឆ្លុះបញ្ចាំងដូចខាងក្រោម៖
កាលអ្នកនៅជាសិស្ស		
អំឡុងពេលវគ្គបណ្តុះបណ្តាលគ្រូបង្រៀន		

[2] Taken from UNESCO (2014, p. 2). CC BY-SA.

ឯកសារពិគ្រោះ

UNESCO (2015). Booklet 4: Creating Inclusive, Learning-Friendly Classrooms. In: *Embracing Diversity: Toolkit for Creating Inclusive, Learning-Friendly Environments*. Retrieved from: https://unesdoc.unesco.org/ark:/48223/pf0000137522. ISBN 92-9223-032-8 (Electronic version).

ជំហានទី២៖ អនុវត្ត

ក.ចូរអានករណីសិក្សាខាងក្រោម។ តើមួយណាជាឧទាហរណ៍នៃថ្នាក់រៀនបែបសិស្សមជ្ឈមណ្ឌល ហើយមួយណាជាឧទាហរណ៍នៃថ្នាក់រៀនបែបគ្រូមជ្ឈមណ្ឌល? ចូរដាក់គោលការណ៍បង្រៀនដែលសមស្របចូលទៅក្នុងតារាងភ្ជាប់ខាងក្រោម៖

ករណីសិក្សាទី១

កុមារចំនួន៤០នាក់អង្គុយលើកៅអីឈើពីក្រោយតុវែង ដោយបើកសៀវភៅលំហាត់ និងកាន់ប៊ិកក្នុងដៃ។ គ្រូកំពុងតែកត់ចម្លងមេរៀនពីក្នុងសៀវភៅថ្នាក់ទី៣ នៅលើក្តារខៀនដោយប្រុងប្រយ័ត្ន។ សិស្សប្រុសៗដែលអង្គុយនៅផ្នែកខាងស្តាំកំពុងកត់ត្រាតាមគ្រូ និងសិស្សស្រីៗដែលអង្គុយនៅខាងឆ្វេងកំពុងរង់ចាំឱ្យគ្រូរំកិលចេញបន្តិច ដើម្បីអាចកត់ត្រាដែរ។ ពួកគេកត់ចម្លងដាក់ក្នុងសៀវភៅលំហាត់ពួកគេ។ នៅពេលកំពុងកត់លើក្តារខៀន គ្រូសួរសិស្សថា "តើកូនៗទាំងអស់គ្នាកំពុងកត់មេរៀនដែលគ្រូកំពុងសរសេរដែរ ឬទេ?" សិស្សឆ្លើយថា "ចាស/បាទ"។

ករណីសិក្សាទី២

សិស្សមួយក្រុមកំពុងអង្គុយនៅលើឥដ្ឋជា២វង្វង់។ ក្រុមទាំង២មានទាំងសិស្សស្រីនិងសិស្សប្រុស។ គ្រូថ្នាក់ទី៣កំពុងបង្រៀនអំពី "ទម្រង់រូបរាង" នៃវត្ថុទៅកាន់សិស្ស។ នៅក្រុមទី១សិស្សកំពុងពិភាក្សាគ្នាអំពីវង្វង់។ គ្រូកំពុងបង្ហាញសិស្សនូវវត្ថុរាងមូលជាច្រើនដែលគាត់បានឱ្យសិស្សយកពីផ្ទះមក។ បន្ទាប់មកសិស្សក៏ចាប់ផ្តើមធ្វើការជាក្រុម ដើម្បីជួយគ្នាប្រាប់ពីវត្ថុដែលមានរាងមូលផ្សេងៗទៀត។ នៅក្រុមទី២ សិស្សខ្លះកំពុងកាន់ក្រដាសកាសែតដែលមូរឱ្យដូចជាចង្កឹះវែង។ បន្ទាប់មកគ្រូចាប់ផ្តើមហៅលេខ ហើយសិស្សដែលមានលេខនោះ ត្រូវដាក់ចង្កឹះកាសែតនៅលើឥដ្ឋ កណ្តាលក្រុមដើម្បីចាប់ផ្តើមបង្កើតជារូបរាងការេ។ សិស្សម្នាក់នៅក្នុងក្រុមដែលមានបញ្ហាត្រចៀក ដាក់ដំបងក្រដាសរបស់គាត់ ដើម្បីបង្កើតជារាងត្រីកោណ ហើយញញឹមដាក់គ្រូ។ គ្រូញញឹមតបហើយនិយាយថា"ល្អណាស់" ហើយនិយាយដោយធ្វើម៉ែចឱ្យសិស្សនោះអាចមើលបបូរមាត់របស់គាត់ ឃើញថាគាត់កំពុងនិយាយអ្វីជាមួយ។ ឪពុកម្តាយម្នាក់ដែលបានស្ម័គ្រចិត្តធ្វើជាជំនួយការគ្រូមួយសប្តាហ៍នៅពេលនោះបានគោះដៃសិស្សនោះតិចៗ ហើយជួយពន្យល់សិស្សដែលបានដាក់ចង្កឹះកាសែតច្រឡំកន្លែង ដើម្បីបង្កើតជារូបរាងថ្មី។

១. ការចូលរួមសកម្ម

២. ការចូលរួមចំណែកក្នុងសង្គម

៣. លំហាត់អនុវត្ត/សកម្មភាពដែលមានប្រយោជន៍

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

៤. ភ្ជាប់ចំណេះដឹងថ្មីទៅនឹងចំណេះដឹងពីមុន

៥. ឆ្ពោះទៅការយល់មេរៀន ជាជាងការទន្ទេញចាំមាត់

៦. ជួយឱ្យសិស្សចេះរៀនផ្ទេរចំណេះដឹង

៧. ចំណាយពេលដើម្បីអនុវត្តផ្ទាល់

៨. ភាពខុសគ្នារវាងការអភិវឌ្ឍ និងបុគ្គល

ឧទាហរណ៍នៃថ្នាក់រៀនបែបសិស្សមជ្ឈមណ្ឌល	គោលការណ៍បង្រៀននៃថ្នាក់រៀនបែបសិស្សមជ្ឈមណ្ឌល	ឧទាហរណ៍
		សិស្សរៀនដោយផ្សារភ្ជាប់ទៅនឹងវត្ថុដែលគេធ្លាប់ស្គាល់ និងដែលបានយកមកពីផ្ទះ។
		សិស្សធ្វើការជាក្រុមដើម្បីរកវត្ថុដែលមានរាងមូលផ្សេងទៀត។
		សិស្សប្រើប្រាស់របៀបដែលគ្រូបានណែនាំរួចដើម្បីធ្វើតារាងវត្ថុដែលមានរាងមូល។
		សិស្សធ្វើការជាមួយវត្ថុនោះ
		សិស្សសង្កេតវត្ថុនោះដោយផ្ទាល់ ដូច្នេះពួកគេ បានយល់ដឹងពីវត្ថុទាំងនោះ។
		សិស្សដែលមានបញ្ហាស្តាប់បានទទួលការគាំទ្រពីគ្រូ។

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

		សិស្សមានពេលគ្រប់គ្រាន់ដើម្បីអនុវត្តសកម្មភាពនានាពីមួយទៅមួយ។
		សិស្សរៀនដោយភ្ជាប់ទៅនឹងវត្ថុដែលយកមកពីផ្ទះ។

១. សកម្មភាពមិនសូវមានប្រយោជន៍

២. គ្មានការបែងចែកភាពខុសគ្នារវាងសិស្សទាំងអស់ទេ។ សិស្សគ្រប់គ្នាត្រូវតែកត់ត្រាអត្ថបទដូចគ្នាតាមរបៀបដូចគ្នា

៣. គ្មានទំនាក់ទំនងរវាងអ្វីដែលសិស្សកំពុងរៀន និងចំណេះដឹងពីមុនទេ

៤. សិស្សមិនមានទំនាក់ទំនងអ្វីជាមួយសិស្សដទៃទៀតទេ

៥. សិស្សមិនមានភាពសកម្មក្នុងការចូលរួម

ឧទាហរណ៍នៃថ្នាក់រៀនបែបគ្រូមជ្ឈមណ្ឌល	ឧទារហណ៍	ដំណោះស្រាយ
		គ្រូយកវត្ថុផ្សេងៗមកឱ្យសិស្សអនុវត្តនៅក្នុងពេលរៀនក្នុងថ្នាក់
		សិស្សត្រូវបានដាក់ឱ្យធ្វើការជាក្រុម

		គ្រូបង្ហាញសិស្សថាហេតុអ្វីពួកគេត្រូវរៀន ឬហេតុអ្វីដែលពួកគេត្រូវធ្វើនូវអ្វីដែលកំពុងរៀន/កំពុងធ្វើ
		គ្រូធ្វើការសង្ខេបគំនិតអំពីអ្វីដែលសិស្សបានដឹងមុននឹងចាប់ផ្តើមមេរៀន។
		គ្រូទុកពេលឱ្យសិស្សមានពេលវេលារៀនតាមវិធីផ្សេងៗគ្នាទៅលើប្រធានបទមួយ ដូចជាគូរ ពន្យល់ និងកត់ត្រាជាដើម។

ខ.ចូរមើលរូបភាពខាងក្រោម រួចចូរដាក់ឧទាហរណ៍នៃជំនាញក្នុងការបង្រៀននៅសតវត្សទី២១ ឱ្យត្រូវទៅនឹងរូបភាព។ ឧទាហរណ៍មួយអាចប្រើក្នុងរូបភាពលើសពីមួយបាន។

១. លំហាត់សហការអនុវត្តផ្ទាល់

២. ធ្វើឱ្យមានទំនាក់ទំនងគ្នារវាងមេរៀនដែលបានបង្រៀនទៅនឹងសហគមន៍រស់នៅជាក់ស្តែង

៣. ការសម្តែង(រឿង)

៤. សិស្សរៀបចំធ្វើបទបង្ហាញអំពីប្រធានបទថ្មី

៥. រៀបគម្រោងដំណើរកម្សាន្ត

៦. ផ្តល់ឱកាសឱ្យសិស្សបានទទួលការគាំទ្រ ការសហការ ការពិភាក្សា និងធ្វើការងារជាក្រុម

៧. អញ្ជើញអ្នកវិទ្យាសាស្ត្រ ឬអ្នកជំនាញមកចែករំលែកក្នុងថ្នាក់រៀន

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

[3]		
[4]		
[3]		

Picture Source: Open Source from pixabay.com

[4] Picture Source: Own Pictures

3	
4	
4	
4	

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

Picture Sources: Open Source from pixabay.com; Own Pictures

គ.ចូរស្តាប់គ្រូបង្រៀនពីរនាក់នេះ និយាយអំពី វិធីដែលពួកគាត់អនុវត្តគោលការណ៍បង្រៀនសម្រាប់សតវត្សទី២១(Audio file 1.1.1-គ្រូ-A, 1.1.2-គ្រូ-B)។ ចូរឆ្លើយសំណួរជ្រើសរើសខាងក្រោម (អាចមានចម្លើយលើសពី១)

១.តើគ្រូ-Aបានផ្តល់ព័ត៌មាន ទៅឱ្យឪពុកម្តាយអំពីការវិវឌ្ឍរបស់កូនពួកគាត់ដោយរបៀបណា?

ក. តាម WhatsApp

ខ. សៀវភៅទំនាក់ទំនង

គ. ជំនួបរវាងគ្រូ និងឪពុកម្តាយ

ឃ. ក្តារបង្ហាញព័ត៌មាន

២.តើគ្រូ-Aបានផ្តល់ព័ត៌មាន ទៅឱ្យឪពុកម្តាយអំពីការវិឌ្ឍនរបស់កូនពួកគាត់ដោយរបៀបណា?

ក. តាម WhatsApp

ខ. សៀវភៅទំនាក់ទំនង

គ. ជំនួបរវាងគ្រូនិងឪពុកម្តាយ

ឃ. ក្តារបង្ហាញព័ត៌មាន

៣.តើគ្រូម្នាក់ណាដែលផ្តល់ព័ត៌មានត្រឡប់ដល់សិស្សជាបុគ្គល?

ក. គ្រូ-A

ខ. គ្រូ-B

គ. គ្រូ-A និង-B

៤.គ្រូ-B បានបង្ហាញពីបញ្ហាប្រឈមជាច្រើនក្នុងការរៀបចំផែនការបង្រៀន។ តើបញ្ហាប្រឈមទាំងនោះមានអ្វីខ្លះ?

ក. សមត្ថភាពសិស្សខុសៗគ្នា

ខ. ការរំពឹងទុករបស់ឪពុកម្តាយ

គ. ការកត់ត្រាពីការវិឌ្ឍរបស់សិស្សម្នាក់ៗ

ឃ. ការរៀបចំសម្ភារៈឧបទ្ទេស

៥. តើគ្រូ-B មានយុទ្ធសាស្ត្រអ្វីខ្លះ ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ?

ក. គាត់បានត្រៀមអ្វីៗទាំងអស់ទុកជាមុន

ខ. គាត់មិនបានដោះស្រាយបញ្ហាប្រឈមទាំងអស់នេះទេ

គ. គាត់ពិភាក្សាពីការវិឌ្ឍរបស់សិស្សជាមួយឪពុកម្តាយ

ឃ. គាត់ផ្តល់ព័ត៌មានត្រឡប់ទៅកាន់សិស្សជាបុគ្គលផ្ទាល់

ឃ. ចូរមើលសិស្សម្នាក់នេះនិយាយអំពីរបៀបដែលគ្រូរបស់នាងធ្វើការទាក់ទងជាមួយឪពុកម្តាយរបស់នាង។ (Video File 1.1.1; កំណត់ត្រាពីសំឡេងអាចរកបាននៅក្នុងឧបសម្ព័ន្ធនៃឯកសារនេះ)។

ចូរឆ្លើយសំណួរដែលមានពហុចម្លើយសម្រាប់ជ្រើសរើសនៅខាងក្រោម។ អាចនឹងមានចម្លើយដែលត្រឹមត្រូវច្រើន៖

១. តើអ្នកគ្រូនិយាយជាមួយឪពុកម្តាយអំពីអ្វី?

ក. គាត់និយាយពីចំណុចខ្លាំងរបស់សិស្សម្នាក់នេះ។

ខ. គាត់និយាយពីតម្រូវការសិក្សារបស់សិស្សម្នាក់នេះ។

គ. គាត់ផ្តល់ឱ្យឪពុកម្តាយនូវមតិយោបល់ និងយុទ្ធសាស្ត្រពីរបៀបជួយសិស្សនេះម្នាក់នៅផ្ទះ។

ឯកសារពិគ្រោះ

UNESCO (2015). Booklet 1: Becoming an Inclusive, Learning-Friendly environment (ILFE). In: *Embracing Diversity: Toolkit for Creating Inclusive, Learning-Friendly Environments*. Retrieved from: https://unesdoc.unesco.org/ark:/48223/pf0000137522. ISBN 92-9223-032-8 (Electronic version). This publication is available in Open Access under the Attribution-ShareAlike 3.0 IGO (CC-BY-SA 3.0 IGO) license (http://creativecommons.org/licenses/by-sa/3.0/igo/).

ជំហានទី១៖ ចម្លើយពន្លឺចំណេះដឹង

ក. សូមបញ្ជាក់បង្ហាញតើប្រយោគខាងក្រោមនេះត្រូវ ឬខុស៖

១.សកម្មភាពចូលរួមរបស់សិស្សទាមទារឱ្យមានការចូលរួមដែលប្រកបដោយការស្ថាបនា និងសកម្មពីសិស្សផ្ទាល់ខ្លួនដែលជាអ្នកសំយោគមេរៀននៅក្នុងថ្នាក់។ ខុស / ត្រូវ

២.ការចូលរួមសកម្មភាពផ្សេងៗនៅក្នុងសង្គម និងកិច្ចប្រតិបត្តិការរវាងគ្នានិងគ្នា គ្មានឥទ្ធិពលទៅលើលទ្ធផលនៃការសិក្សារបស់សិស្សឡើយ។ ខុស / ត្រូវ

(ចម្លើយត្រឹមត្រូវ៖ ការសិក្សាជាច្រើនបានបង្ហាញថាការចូលរួមសកម្មភាពផ្សេងៗនៅក្នុងសង្គម និងកិច្ចការប្រតិបត្តិការរវាងគ្នានិងគ្នាដែលទាក់ទងទៅនឹងការរៀនសូត្រមានឥទ្ធិពលជាវិជ្ជមានដ៏សំខាន់បំផុតទៅលើលទ្ធផលសិក្សារបស់សិស្ស។)

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

៣.ដើម្បីជោគជ័យ សិស្សត្រូវពិចារណាទៅលើសកម្មភាពរបស់ខ្លួនណាដែលសំខាន់ ហើយមានប្រយោជន៍ដល់ការសិក្សាផ្ទាល់ខ្លួនរបស់ពួកគេ។ ខុស/ ត្រូវ

៤.ការសិក្សាដែលជោគជ័យទៅបាន នៅពេលដែលអ្នកសិក្សាចេះតភ្ជាប់ចំណេះដឹងចាស់ៗទៅនឹងព័ត៌មានថ្មីៗ។ ខុស / ត្រូវ

៥.គ្រូមាននាទីជួយសិស្សបង្កើតយុទ្ធសាស្ត្រសិក្សាឱ្យបានទូលំទូលាយ ហើយឱ្យចេះប្រើវាបានត្រូវនឹងកិច្ចការដែលមាន។ ខុស / ត្រូវ

៦.គ្រូគ្មានឥទ្ធិពលទៅលើសិស្សក្នុងអភិវឌ្ឍសមត្ថភាព និងសេចក្តីត្រូវការរបស់សិស្សម្នាក់ៗនោះទេ។ ខុស / ត្រូវ

(ចម្លើយត្រឹមត្រូវ៖ តួនាទីរបស់គ្រូគឺត្រូវជួយសិស្សអភិវឌ្ឍន៍ការយល់ដឹងអំពីសមត្ថភាពនិងតម្រូវការផ្ទាល់ខ្លួនរបស់ពួកគេ និងយុទ្ធសាស្ត្រដើម្បីកែលម្អពួកគេ ហើយដែលកត្តាទាំងនេះមានឥទ្ធិពលខ្លាំងដល់លទ្ធផលនៃការរៀនសូត្រ។)

៧.គ្រូអាចធ្វើសេចក្តីសន្និដ្ឋានដោយស្វ័យប្រវត្តិថា ចំណេះដឹងពីមុនៗរបស់សិស្សសុទ្ធតែត្រឹមត្រូវដោយមិនចាំបាច់ពិនិត្យមើលឡើងវិញឡើយ។ ខុស / ត្រូវ

(ចម្លើយត្រឹមត្រូវ៖ វាជាការចាំបាច់ណាស់ដែលត្រូវប្រាកដថាចំណេះដឹងដែលទទួលបានពីមុនបានផ្តល់ជាគ្រឹះសមរម្យសម្រាប់ទទួលចំណេះដឹងថ្មី។ ដើម្បីទទួលលទ្ធផលបែបនេះចំណេះដឹង ពីមុនត្រូវតែប្រើប្រាស់និងរៀបចំឱ្យបានត្រឹមត្រូវ។)

៨.សិស្សមានទំនោរទៅលើការទន្ទេញព័ត៌មានដែលបានរៀនច្រើនជាងព័ត៌មានដែលពួកគេបានឮយល់។ ខុស / ត្រូវ

(ចម្លើយត្រឹមត្រូវ៖ សិស្សមានទំនោរទៅលើការចងចាំព័ត៌មានដែលពួកគេយល់ជាជាងការពិតដែលពួកគេបានរៀនដោយទន្ទេញ។)

៩.ការសិក្សាមានន័យបាន លុះត្រាតែអ្នកសិក្សាអាចតភ្ជាប់នូវអ្វីដែលពួកគេរៀនទៅអ្វីដែលមាននៅក្នុងជីវិតពិតប្រចាំថ្ងៃ។ ខុស / ត្រូវ

១០.ការសិក្សាជាបទពិសោធដ៏សាមញ្ញមួយដែលមិនត្រូវការពេលវេលា និងការអនុវត្តច្រើនឡើយ។ ខុស / ត្រូវ

(ចម្លើយត្រឹមត្រូវ៖ ការសិក្សាគឺជាបទពិសោធដ៏ស្មុគស្មាញដែលទាក់ទងទៅនឹងអារម្មណ៍និង អាកប្បកិរិយា ការគិត ការធ្វើដែលត្រូវការពេលវេលាដ៏សមស្របនឹងអនុវត្តដើម្បីបានទទួលជោគជ័យ។)

១១.សិស្សទាំងអស់នៅក្នុងថ្នាក់រៀនមានស្ថានភាពប្រហាក់ប្រហែលគ្នា ដូច្នេះការជួយពួកគេម្នាក់ៗជាបុគ្គលគឺពុំចាំបាច់ឡើយ។ ខុស / ត្រូវ

(ចម្លើយត្រឹមត្រូវ៖ កុមារមានភាពខុសគ្នាទាំងសមត្ថភាពនិងតម្រូវការគឺជាកាតព្វកិច្ចរបស់គ្រូ និងសាលារៀនក្នុងការផ្តល់នូវបរិយាកាសរៀនសូត្រមួយ ដែលជួយគាំទ្រដល់សមត្ថភាពនិងតម្រូវការទាំងនោះ ហើយអនុញ្ញាតឱ្យសិស្សគ្រប់រូបអាចអភិវឌ្ឍទៅតាមកម្រិតផ្ទាល់ខ្លួន។)

១២.គ្រូអាចមានឥទ្ធិពលទៅលើការសិក្សារបស់សិស្សដោយបង្កើតឱ្យមានអ្នកសិក្សាប្រកបដោយកម្លាំងជំរុញទឹកចិត្ត។ ខុស/ ត្រូវ

ខ. ចូរដាក់ឧទាហរណ៍ខាងក្រោមទៅតាមប្រភេទឱ្យបានត្រឹមត្រូវនៅក្នុងតារាងខាងក្រោម៖

១. សួរសំណួរដែលជំរុញឱ្យសិស្សមានមតិត្រលប់

២. បញ្ចូលលំហាត់អនុវត្តន៍

៣. ផ្តល់ឱកាសឱ្យសិស្សទទួលបាន និងបញ្ចេញមតិណែនាំ

៤. បង្កើតទំនាក់ទំនងគ្នារវាងខ្លឹមសារមេរៀន ជីវិតពិត និងសហគមន៍

៥. បង្កើតឱ្យមានការសម្តែង

៦. សិស្សរៀបចំបទបង្ហាញប្រធានបទថ្មី

៧. ផ្តល់ឱកាសឱ្យសិស្សវាយតម្លៃកិច្ចការរបស់ខ្លួន

៨. រៀបចំឱ្យមានដំណើរកម្សាន្ត

៩. ទុកឱកាសឱ្យសិស្សចេះធ្វើការឆ្លុះបញ្ចាំងផ្ទាល់ខ្លួន

១០. ប្រើចំណុចខ្លាំងរបស់សិស្ស

១១. បង្កើតបរិយាកាសដែលអនុគ្រោះដល់ជំនឿផ្សេងៗរបស់សិស្ស

t.me/moeysnews
www.moeys.gov.kh
youtube.com/moeyscambodia

១២. ប្រើឧទាហរណ៍

១៣. ផ្តល់ឱកាសឱ្យសិស្សមានឥទ្ធិពលលើដំណើរការសិក្សា

១៤. ផ្តល់ពេលវេលាគ្រប់គ្រាន់ឱ្យសិស្ស

១៥. សិស្សពន្យល់ដំណើរការ និងច្បាប់ផ្សេងៗដោយមិនប្រើប្រាស់សៀវភៅសិក្សារបស់ពួកគេ

១៦. ដាក់លំហាត់ឱ្យសិស្សធ្វើត្រូវនឹងជំនាញសមត្ថភាព

១៧. ផ្តល់ឱកាសឱ្យសិស្សធ្វើការជាមួយគ្នា ការពិភាក្សា និងការងារជាក្រុម

១៨. ដាក់ការងារឱ្យសិស្សធ្វើដែលសមស្របទៅនឹងសមត្ថភាពដែលពួកគេបានរៀន

១៩. អញ្ជើញអ្នកវិទ្យាសាស្ត្រ ឬអ្នកជំនាញមកចែករំលែកក្នុងថ្នាក់

២០. បង្រៀនតែមួយ ឬពីរប្រធានបទតែប៉ុណ្ណោះក្នុងមួយពេលសិក្សា

២១. ធ្វើការពិភាក្សាមុនពេលបង្រៀនប្រធានបទថ្មី

២២. ទទួលស្គាល់សមិទ្ធផលរបស់សិស្ស

២៣. បង្កើតឱ្យសិស្សមានទំនុកចិត្តលើខ្លួនឯង

២៤. ឱ្យសិស្សសង្ខេបអត្ថបទបន្ទាប់ពីអានរួច

២៥. ឱ្យសិស្សមានជម្រើសក្នុងការរៀបចំផែនការ និងរចនាសម្ព័ន្ធលំហាត់អនុវត្ត

២៦. ជួយសិស្សស្វែងរកយុទ្ធសាស្ត្រសិក្សា

ការចូលរួមដោយសកម្មក្នុងថ្នាក់	ការចូលរួមចំណែកក្នុងសង្គម	លំហាត់សកម្មភាពដែលមានប្រយោជន៍	ភ្ជាប់ព័ត៌មានថ្មីៗទៅនឹងចំណេះដឹងពីមុន
២	៣	៥	១
៨	៤	១៦	៦
១៣	១៧	១៩	២១

ការរៀនបែបយុទ្ធសាស្ត្រ	មានវិន័យផ្ទាល់ខ្លួន និងរៀនឆ្លុះបញ្ចាំង	ពិនិត្យ រៀបចំចំណេះដឹង ឡើងវិញ	ឆ្ពោះទៅកាន់ការយល់មេរៀនជាជាងការទន្ទេញចាំមាត់
១៧	៧	១១	១២
២៤	៩	១២	១៥
២៦	២៥	១៤	១៨
ជួយឱ្យសិស្សចេះរៀនផ្ទៅចំណេះដឹង	ចំណាយពេលដើម្បីអនុវត្តផ្ទាល់	ភាពខុសគ្នារវាងការអភិវឌ្ឍនិងបុគ្គល	បង្កើតអ្នកសិក្សាប្រកបដោយកម្លាំងចិត្ត
៣	១៤	១	៣
៤	១៨	៤	២២
១២	២០	១០	២៣

គ. ចូរដាក់គោលការណ៍ខាងក្រោមនេះចូលទៅក្នុងតារាងខាងក្រោមឱ្យបានត្រឹមត្រូវ៖

សម្គាល់៖ ក្នុងតារាងនីមួយៗអាចដាក់គោលការបានលើសពីមួយ។

១. ការចូលរួមដោយសកម្ម

២. ការចូលរួមចំណែកក្នុងសង្គម

៣. លំហាត់អនុវត្តសកម្មភាពដែលមានប្រយោជន៍

៤. ភ្ជាប់ព័ត៌មានថ្មីៗទៅនឹងចំណេះដឹងពីមុន

៥. ការរៀនបែបយុទ្ធសាស្ត្រ

៦. វិន័យផ្ទាល់ខ្លួននិងការឆ្លុះបញ្ចាំង

៧. ពិនិត្យរៀបចំចំណេះដឹងពីមុនឡើងវិញ

៨. ឆ្ពោះទៅកាន់ការយល់ ជាជាងការទន្ទេញចាំមាត់

៩. ជួយឱ្យសិស្សចេះរៀនផ្ទៅចំណេះដឹង

១០. ចំណាយពេលដើម្បីអនុវត្តផ្ទាល់

១១. ភាពខុសគ្នារវាងការអភិវឌ្ឍនិងបុគ្គល

១២. បង្កើតអ្នកសិក្សាប្រកបដោយកម្លាំងចិត្ត

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ការចែករំលែក និងរួមសហការដ៏សកម្ម	១, ២, ១២
ការផ្សារភ្ជាប់រវាងសាលារៀន និងស្ថានភាពនៅក្នុងជីវិតពិត	៣, ៨, ៩, ១១
ការប្រាស្រ័យទាក់ទងក្នុងសង្គម	២, ៤
វាយតម្លៃការងារផ្ទាល់ខ្លួន	៤, ៥, ៦
ការផ្សារភ្ជាប់រវាងចំណេះដឹងថ្មី និងចំណេះដឹងមានស្រាប់	៣, ៤, ៧, ៨
ការយល់ខ្ពឹមសារ ជាជាងការទន្ទេញចាំមាត់	៣, ៨, ៩, ១០

ឃ: ចូរសរសេរសំណេរខ្លី(ប្រហែល៥០០ពាក្យ) អំពីសំណួរស្វ័យឆ្លុះបញ្ចាំងដូចខាងក្រោម៖

១. តើអ្នកមានបទពិសោធអ្វីខ្លះអំពីការអប់រំតាមបែបគ្រូមជ្ឈមណ្ឌល និងសិស្សមជ្ឈមណ្ឌល? តើអ្នកទទួលបានបទពិសោធអ្វីខ្លះកាលអ្នកនៅជាសិស្ស? តើវាបានជួយអ្នកក្នុងការសិក្សាដែរ ឬទេ? ឬថាតើអ្នកត្រូវការអ្វីផ្សេងទៀតដែលគួរជួយដល់ដំណើរការសិក្សារបស់អ្នកឱ្យកាន់តែបានច្រើនជាអតិបរមា? ចូរគិតអំពីវិធីបង្រៀនដែលគ្រូរបស់អ្នកធ្លាប់បានប្រើក្នុងការបង្រៀនអ្នកនៅក្នុងសាលា និងរបៀបដែលអ្នកត្រូវបានបង្រៀនពីវិធីសាស្ត្របង្រៀន។ ចូរសរសេរពីអារម្មណ៍របស់អ្នកអំពីវិធីសាស្ត្រទាំងពីរនេះ។.[5]

[5] Adapted from UNESCO/Booklet 4 (2015, 4).

	យ: ចូរសរសេរសំណេរខ្លី (ប្រហែល ៥០០ពាក្យ) អំពីសំណួរស្វ័យឆ្លុះបញ្ចាំងដូចខាងក្រោម៖	យ: ចូរសរសេរសំណេរខ្លី (ប្រហែល ៥០០ពាក្យ) អំពីសំណួរស្វ័យឆ្លុះបញ្ចាំងដូចខាងក្រោម៖
កាលអ្នកនៅជាសិស្ស		
អំឡុងពេលវគ្គបណ្តុះបណ្តាលគ្រូបង្រៀន		

ឯកសារយោង

UNESCO (2015). Booklet 4: Creating Inclusive, Learning-Friendly Classrooms. In: *Embracing Diversity: Toolkit for Creating Inclusive, Learning-Friendly Environments*. Retrieved from: https://unesdoc.unesco.org/ark:/48223/pf0000137522. ISBN 92-9223-032-8 (Electronic version).

ជំហានទី២៖ ចម្លើយ

ក.ចូរអានករណីសិក្សាខាងក្រោម។ តើមួយណាជាឧទាហរណ៍នៃថ្នាក់រៀនបែបសិស្សមជ្ឈមណ្ឌល ហើយមួយណាជាឧទាហរណ៍នៃថ្នាក់រៀនបែបគ្រូមជ្ឈមណ្ឌល? ចូរដាក់គោលការណ៍បង្រៀនដែលសមស្របចូលទៅក្នុងតារាងភ្ជាប់ខាងក្រោម៖

ករណីសិក្សាទី១

កុមារចំនួន៤០នាក់អង្គុយលើកៅអីឈើពីក្រោយតុវែង ដោយបើកសៀវភៅលំហាត់ និងកាន់ប៊ិកក្នុងដៃ។ គ្រូកំពុងតែកត់ចម្លងមេរៀនពីក្នុងសៀវភៅថ្នាក់ទី៣ នៅលើក្តារខៀនដោយប្រុងប្រយ័ត្ន។ សិស្សប្រុសៗដែលអង្គុយនៅផ្នែកខាងស្តាំកំពុងកត់ត្រាតាមគ្រូ និងសិស្សស្រីៗដែលអង្គុយនៅខាងឆ្វេងកំពុងរង់ចាំឱ្យគ្រូរំកិលចេញបន្តិច ដើម្បីអាចកត់ត្រាដែរ។ ពួកគេកត់ចម្លងដាក់ក្នុងសៀវភៅលំហាត់ពួកគេ។ នៅពេលកំពុងកត់លើក្តារខៀន គ្រូសួរសិស្សថា "តើកូនៗទាំងអស់គ្នាកំពុងកត់មេរៀនដែលគ្រូកំពុងសរសេរដែរ ឬទេ?" សិស្សឆ្លើយថា "ចាស/បាទ"។

ករណីសិក្សាទី២

សិស្សមួយក្រុមកំពុងអង្គុយនៅលើឥដ្ឋជា២វង់។ ក្រុមទាំង២មានទាំងសិស្សស្រីនិងសិស្សប្រុស។ គ្រូថ្នាក់ទី៣កំពុងបង្រៀនអំពី "ទម្រង់រូបរាង" នៃវត្ថុទៅកាន់សិស្ស។ នៅក្រុមទី១សិស្សកំពុងពិភាក្សាគ្នា អំពីវង់។ គ្រូកំពុងបង្ហាញសិស្សនូវវត្ថុរាងមូលជាច្រើនដែលគាត់បានឱ្យសិស្សយកពីផ្ទះមក។ បន្ទាប់មកសិស្សក៏

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ចាប់ផ្តើមធ្វើការជាក្រុម ដើម្បីជួយគ្នាប្រាប់ពីវត្ថុដែលមានរាងមូលផ្សេងៗទៀត។ នៅក្រុមទី២ សិស្សខ្លះកំពុងកាន់ក្រដាសកាសែតដែលមូរឱ្យដូចជាចង្កឹះវែង។ បន្ទាប់មក គ្រូចាប់ផ្តើមហៅលេខ ហើយសិស្សដែលមានលេខនោះ ត្រូវដាក់ចង្កឹះកាសែតនៅលើឥដ្ឋ កណ្តាលក្រុមដើម្បីចាប់ផ្តើមបង្កើតជារូបរាងការេ។ សិស្សម្នាក់នៅក្នុងក្រុមដែលមានបញ្ហាត្រចៀក ដាក់ដំបងក្រដាសរបស់គាត់ ដើម្បីបង្កើតជារាងត្រីកោណ ហើយញញឹមដាក់គ្រូ។ គ្រូញញឹមតបហើយនិយាយថា"ល្អណាស់" ហើយនិយាយដោយធ្វើយ៉ាងណាឱ្យសិស្សនោះអាចមើលបបូរមាត់របស់គាត់ ឃើញថាគាត់កំពុងនិយាយអ្វីជាមួយ។ ឪពុក/ម្តាយម្នាក់ដែលបានស្ម័គ្រចិត្តធ្វើជាជំនួយការគ្រូមួយសប្តាហ៍នៅពេលនោះបានគោះដៃសិស្សនោះតិចៗ ហើយជួយពន្យល់សិស្សដែលបានដាក់ចង្កឹះកាសែតច្រឡំកន្លែង ដើម្បីបង្កើតជារូបរាងថ្មី។

១. ការចូលរួមសកម្ម

២. ការចូលរួមចំណែកក្នុងសង្គម

៣. លំហាត់អនុវត្ត/សកម្មភាពដែលមានប្រយោជន៍

៤. ភ្ជាប់ចំណេះដឹងថ្មីទៅនឹងចំណេះដឹងពីមុន

៥. ឆ្ពោះទៅ ការយល់មេរៀន ជាជាងការទន្ទេញចាំមាត់

៦. ជួយឱ្យសិស្សចេះរៀនផ្ទៃចំណេះដឹង

៧. ចំណាយពេលដើម្បីអនុវត្តផ្ទាល់

៨. ភាពខុសគ្នារវាងការអភិវឌ្ឍ និងបុគ្គល

ឧទាហរណ៍នៃថ្នាក់រៀនបែបសិស្សមជ្ឈមណ្ឌល	គោលការណ៍បង្រៀននៃថ្នាក់រៀនបែបសិស្សមជ្ឈមណ្ឌល	ឧទាហរណ៍
ករណីសិក្សាទី២	៤	សិស្សរៀនដោយផ្សារភ្ជាប់ទៅនឹងវត្ថុដែលគេធ្លាប់ស្គាល់ និងដែលបានយកមកពីផ្ទះ។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

	២	សិស្សធ្វើការជាក្រុមដើម្បីរកវត្ថុដែលមានរាងមូលផ្សេងទៀត។
	៦	សិស្សប្រើប្រាស់របៀបដែលគ្រូបានណែនាំរួចដើម្បីធ្វើតារាងវត្ថុដែលមានរាងមូល។
	១	សិស្សធ្វើការជាមួយវត្ថុនោះ
	៥	សិស្សសង្កេតវត្ថុនោះដោយផ្ទាល់ ដូច្នេះ ពួកគេ បានយល់ដឹងពីវត្ថុទាំងនោះ។
	៨	សិស្សដែលមានបញ្ហាស្តាប់បានទទួលការគាំទ្រពីគ្រូ។
	៧	សិស្សមានពេលគ្រប់គ្រាន់ដើម្បីអនុវត្តសកម្មភាពនានាពីមួយទៅមួយ។
	៣	សិស្សរៀនដោយភ្ជាប់ទៅនឹងវត្ថុដែលយកមកពីផ្ទះ។

១. សកម្មភាពមិនសូវមានប្រយោជន៍

២. គ្មានការបែងចែកភាពខុសគ្នារវាងសិស្សទាំងអស់ទេ។ សិស្សគ្រប់គ្នាត្រូវតែកត់ត្រាអត្ថបទដូចគ្នាតាមរបៀបដូចគ្នា

៣. គ្មានទំនាក់ទំនងរវាងអ្វីដែលសិស្សកំពុងរៀន និងចំណេះដឹងពីមុនទេ

៤. សិស្សមិនមានទំនាក់ទំនងអ្វីជាមួយសិស្សដ៏ទៃទៀតទេ

៥. សិស្សមិនមានភាពសកម្មក្នុងការចូលរួម

ឧទាហរណ៍នៃថ្នាក់រៀនបែបគ្រូមជ្ឈមណ្ឌល	ឧទារហណ៍	ដំណោះស្រាយ
ករណីសិក្សាទី១	៥	គ្រូយល់វត្តុផ្សេងៗមកឱ្យសិស្សអនុវត្តនៅក្នុងពេលរៀនក្នុងថ្នាក់
	៤	សិស្សត្រូវបានដាក់ឱ្យធ្វើការជាក្រុម
	១	គ្រូបង្ហាញសិស្សថាហេតុអ្វីពួកគេត្រូវរៀន ឬហេតុអ្វីដែលពួកគេត្រូវធ្វើនូវអ្វីដែលកំពុងរៀន/កំពុងធ្វើ
	៣	គ្រូធ្វើការសង្ខេបគំនិតអំពីអ្វីដែលសិស្សបានដឹងមុននឹងចាប់ផ្តើមមេរៀន។
	២	គ្រូទុកពេលឱ្យសិស្សមានពេលវេលារៀនតាមវិធីផ្សេងៗគ្នាទៅលើប្រធានបទមួយ ដូចជាគួរពន្យល់ និងកត់ត្រាជាដើម។

ខ.ចូរមើលរូបភាពខាងក្រោម រួចចូរដាក់ឧទាហរណ៍នៃដំនាញក្នុងការបង្រៀននៅសតវត្សទី២១ ឱ្យត្រូវទៅនឹងរូបភាព។ ឧទាហរណ៍មួយអាចប្រើក្នុងរូបភាពលើសពីមួយបាន។

១. លំហាត់សហការអនុវត្តផ្ទាល់

២. ធ្វើឱ្យមានទំនាក់ទំនងគ្នារវាងមេរៀនដែលបានបង្រៀនទៅនឹងសហគមន៍រស់នៅជាក់ស្តែង

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

៣. ការសម្តែង (រឿង)

៤. សិស្សរៀបចំធ្វើបទបង្ហាញអំពីប្រធាបបទថ្មី

៥. រៀបគម្រោង ដំណើរកម្សាន្ត

៦. ផ្តល់ឱកាសឱ្យសិស្សបានទទួលការគាំទ្រ ការសហការ ការពិភាក្សា និងធ្វើការងារជាក្រុម

៧. អញ្ជើញអ្នកវិទ្យាសាស្ត្រ ឬអ្នកជំនាញមកចែករំលែកក្នុងថ្នាក់រៀន

[6]	១
[7]	៤, ៦

[6] Picture Source: Open Source from pixabay.com

[7] Picture Source: Own Pictures

3	๕
3	๒
4	๓
4	๓

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

4	ជ
4	ញ
4	ជ

4	៤, ៦

Picture Sources: Open Source from pixabay.com; Own Pictures

គ.ចូរស្តាប់គ្រូបង្រៀនពីរនាក់នេះ និយាយអំពីវិធីដែលពួកគាត់អនុវត្តគោលការណ៍បង្រៀនសម្រាប់សតវត្សទី២១(Audio file 1.1.1-គ្រូ-A, 1.1.2-គ្រូ-B)។ ចូរឆ្លើយសំណួរជ្រើសរើសខាងក្រោម(អាចមានចម្លើយលើសពី១)

១.តើគ្រូ-Aបានផ្តល់ព័ត៌មាន ទៅឱ្យឪពុកម្តាយអំពីការវិវឌ្ឍរបស់កូនពួកគាត់ដោយរបៀបណា?

ក. តាម WhatsApp

ខ. សៀវភៅទំនាក់ទំនង

គ. ជំនួបរវាងគ្រូ និងឪពុកម្តាយ

ឃ. ក្តារបង្ហាញព័ត៌មាន

២.តើគ្រូ-Aបានផ្តល់ព័ត៌មាន ទៅឱ្យឪពុកម្តាយអំពីការវិវឌ្ឍរបស់កូនពួកគាត់ដោយរបៀបណា?

ក. តាម WhatsApp

ខ. សៀវភៅទំនាក់ទំនង

គ. ជំនួបរវាងគ្រូនិងឪពុកម្តាយ

ឃ. ក្តារបង្ហាញព័ត៌មាន

៣.តើគ្រូម្នាក់ណាដែលផ្តល់ព័ត៌មានត្រឡប់ដល់សិស្សជាបុគ្គល?

ក. គ្រូ-A

ខ. គ្រូ-B

គ. គ្រូ-A និង-B

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

៤.គ្រូ-B បានបង្ហាញពីបញ្ហាប្រឈមជាច្រើនក្នុងការរៀបចំផែនការបង្រៀន។ តើបញ្ហាប្រឈមទាំងនោះមានអ្វីខ្លះ?

ក. សមត្ថភាពសិស្សខុសៗគ្នា

ខ. ការរំពឹងទុករបស់ឪពុកម្តាយ

គ. ការកត់ត្រាពីការវិឌ្ឍរបស់សិស្សម្នាក់ៗ

ឃ. ការរៀបចំសម្ភារៈឧបទ្ទេស

៥. តើគ្រូ-B មានយុទ្ធសាស្ត្រអ្វីខ្លះ ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ?

ក. គាត់បានត្រៀមអ្វីៗទាំងអស់ទុកជាមុន

ខ. គាត់មិនបានដោះស្រាយបញ្ហាប្រឈមទាំងអស់នេះទេ

គ. គាត់ពិភាក្សាពីការវិឌ្ឍរបស់សិស្សជាមួយឪពុកម្តាយ

ឃ. គាត់ផ្តល់ព័ត៌មានត្រឡប់ទៅកាន់សិស្សជាបុគ្គលផ្ទាល់

ឃ. ចូរមើលសិស្សម្នាក់នេះនិយាយអំពីរបៀបដែលគ្រូរបស់នាងធ្វើការទាក់ទងជាមួយឪពុកម្តាយរបស់នាង។ (Video File 1.1.1; កំណត់ត្រាពីសំឡេងអាចរកបាននៅក្នុងឧបសម្ព័ន្ធនៃឯកសារនេះ)។

ចូរឆ្លើយសំណួរដែលមានពហុចម្លើយសម្រាប់ជ្រើសរើសនៅខាងក្រោម។ អាចនឹងមានចម្លើយដែលត្រឹមត្រូវច្រើន៖

១. តើអ្នកគ្រូនិយាយជាមួយឪពុកម្តាយអំពីអ្វី?

ក. គាត់និយាយពីចំណុចខ្លាំងរបស់សិស្សម្នាក់នេះ។

ខ. គាត់និយាយពីតម្រូវការសិក្សារបស់សិស្សម្នាក់នេះ។

គ. គាត់ផ្តល់ឱ្យឪពុកម្តាយនូវមតិយោបល់ និងយុទ្ធសាស្ត្រពីរបៀបជួយសិស្សម្នាក់នេះនៅផ្ទះ។

ឯកសារពិគ្រោះ

UNESCO (2015). Booklet 1: Becoming an Inclusive, Learning-Friendly environment (ILFE). In: *Embracing Diversity: Toolkit for Creating Inclusive, Learning-Friendly Environments*. Retrieved from: https://unesdoc.unesco.org/ark:/48223/pf0000137522. ISBN 92-9223-032-8 (Electronic version). This publication is available in Open Access under the Attribution-ShareAlike 3.0 IGO (CC-BY-SA 3.0 IGO) license (http://creativecommons.org/licenses/by-sa/3.0/igo/).

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ជំហានទី៣៖ កិច្ចការរៀបចំឯកសារជាសំណុំ (PORTFOLIO) – សំណួរបែប ឆ្លុះបញ្ចាំងផ្ទាល់ខ្លួន

ចូរសរសេរចម្លើយតាមបែបសំណេរតែងសេចក្តីចំពោះសំណួរបែបឆ្លុះបញ្ចាំងផ្ទាល់ខ្លួននីមួយៗ។ចម្លើយបែបសំណេរតែងសេចក្តីនីមួយៗគួរតែមានប្រវែងប្រហែលចាប់ពី៣០០ទៅ៥០០ពាក្យហើយត្រូវឆ្លើយជាអត្ថបទបែបសំណេរតែងសេចក្តីទាំងនេះ។ ចម្លើយសំណេរនេះត្រូវដាក់បញ្ចូលទៅក្នុងសំណុំឯកសារផ្ទាល់ខ្លួនរបស់អ្នក!

១. តើអ្វីជាបទពិសោធរបស់អ្នកជាមួយនឹងការអប់រំបែបគ្រូមជ្ឈមណ្ឌល និងសិស្សមជ្ឈមណ្ឌល? តើអ្នកបានឆ្លងកាត់បទពិសោធអ្វីខ្លះក្នុងរយៈពេលប៉ុន្មានឆ្នាំក្នុងនាមជាសិស្សម្នាក់? តើវាបានជួយជាប្រយោជន៍ដែរឬទេ ឬតើមានអ្វីផ្សេងទៀតដែលអ្នកអាចត្រូវការនៅពេលនោះដើម្បីឱ្យអ្នកមានអារម្មណ៍ថាត្រូវបានគេជួយពេញទំហឹងក្នុងដំណើរការរៀនសូត្ររបស់អ្នក?

២. ចូរគិតពីរបៀបដែលអ្នកត្រូវបានបង្រៀននៅសាលា និងពីរបៀបដែលអ្នកកំពុងត្រូវបានបង្រៀនពីរបៀបដែលត្រូវបង្រៀន។ ចូរសរសេរពីចំណាប់អារម្មណ៍របស់អ្នកនៅពេលនោះ/នៅពេលនេះអំពីវិធីសាស្ត្រទាំងនេះ។

ជំហានទី៤៖ កិច្ចការរៀបចំឯកសារជាសំណុំ (PORTFOLIO) – គម្រោងការបង្រៀន

ចូរបង្កើតគម្រោងបង្រៀនផ្ទាល់ខ្លួន។ ចូរជ្រើសរើសប្រធានបទមួយ និងថ្នាក់រៀនបែបសន្និដ្ឋានមួយដែលអ្នកចង់បង្រៀនមេរៀនរបស់អ្នក។ អ្នកនឹងប្រើថ្នាក់នេះ និងប្រធានបទសម្រាប់រាល់កិច្ចការរៀបចំសំណុំឯកសារនៅក្នុងលំហាត់ជំហានទី៤នេះ។ សំណុំឯកសារនេះអាចមានប្រវែងប្រហែល ៨០០ទៅ១០០០ពាក្យ។ គម្រោងនៃការបង្រៀននេះដាក់ចូលទៅក្នុងសំណុំឯកសារផ្ទាល់ខ្លួនរបស់អ្នក!

ចូរពណ៌នាពីប្រធានបទនេះ៖ តើមុខវិជ្ជាណាមួយដែលនឹងត្រូវបង្រៀន? តើនៅក្នុងថ្នាក់ទីប៉ុន្មាន? តើទំនាក់ទំនងរបស់ប្រធានបទភ្ជាប់ទៅនឹងកម្មវិធីសិក្សាគឺជាអ្វី? តើវានិយាយពីអ្វី? តើសិស្សចាំបាច់ត្រូវការចំណេះដឹងទុកមុនអ្វីខ្លះ? ចូរពណ៌នាពីសិស្សរបស់អ្នក៖ តើមានសិស្សប៉ុន្មាននាក់ក្នុងថ្នាក់របស់អ្នក? តើពួកគេមានអាយុប៉ុន្មានហើយ តើពួកគេរៀនក្នុងថ្នាក់ទីប៉ុន្មាន?

១. ឧបសម្ព័ន្ធ

កំណត់ត្រាពីសំឡេង៖ Audio File 1.1.1 – គ្រូបង្រៀនក

អ្នកសម្ភាសន៍ ៖ តើអ្នកផ្តល់មតិយោបល់ទៅដល់សិស្សរបស់អ្នកជាលក្ខណៈបុគ្គលដែរ ឬទេ?

គ្រូបង្រៀន ក ៖ បាទ/ចាសអ្នកស្រី។ ខ្ញុំនិយាយទៅកាន់ក្មេងម្នាក់ៗ ហើយផ្តល់មតិយោបល់ដល់ពួកគេជាលក្ខណៈបុគ្គល។

អ្នកសម្ភាសន៍ ៖ តើការប្រាស្រ័យទាក់ទងជាមួយឪពុកម្តាយមានលក្ខណៈយ៉ាងដូចម្តេចដែរ?

គ្រូបង្រៀន ក ៖ ពួកគាត់តែងតែអាចទាក់ទងជាមួយយើងបាន ព្រោះយើងមានលេខទូរស័ព្ទរបស់ពួកគាត់ ប្រសិនបើ ពួកគាត់មានបញ្ហាអ្វីមួយ ពួកគាត់អាចពិភាក្សាជាមួយយើងបាន ហើយយើងអាចដោះស្រាយគ្រប់រឿងបាន។ យើងក៏មានការប្រជុំជាមួយអាណាព្យាបាលដែលពួកគាត់ក៏អាចពិភាក្សាជាមួយយើង ប្រសិនបើមានបញ្ហាអ្វីមួយ។ ហើយម្យ៉ាងវិញទៀតពួកគាត់អាចទាក់ទងជាមួយយើងផ្ទាល់តាមរយៈលេខទូរស័ព្ទ។

អ្នកសម្ភាសន៍ ៖ ជាធម្មតាពួកគាត់មកកាន់ថ្នាក់រៀន ហើយពិភាក្សាជាមួយអ្នក ដែរ ឬទេ?

គ្រូបង្រៀន ក ៖ បាទ/ចាស។

អ្នកសម្ភាសន៍ ៖ ហើយអ្នកក៏អាចសរសេរសារដាក់លើក្តារប្រកាសព័ត៌មានបានដែរមែនទេ?

គ្រូបង្រៀន ក ៖ បាទ មែនហើយ យើងមានក្តារប្រកាសព័ត៌មានមួយ។

អ្នកសម្ភាសន៍ ៖ ត្រង់ចំណុចនេះ អ្នកប្រើប្រាស់ក្រុមទំនាក់ទំនងតាម WhatsApp មែនដែរ ឬទេ?

គ្រូបង្រៀន ក ៖ បាទ។ យើងមានប្រើវាតាំងពីដើមមក។

កំណត់ត្រាសំឡេង៖ Audio File 1.1.2 – គ្រូបង្រៀន ខ

គ្រូបង្រៀន ខ ៖ ការរៀបចំកិច្ចតែងការបង្រៀនគឺជាការលំបាក ព្រោះវាមានសមត្ថភាពផ្សេងៗគ្នា ហើយនៅពេលយើងអនុវត្ត យើងត្រូវគិតពីរឿងនោះ។ បញ្ហាដទៃទៀតគឺអាណាព្យាបាល។ ពួកគាត់

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

មានការរំពឹងខ្ពស់ ដូច្នេះហើយ ពួកគាត់តែងតែព្រួយបារម្ភណ៍ពីកូនៗរបស់ពួកគាត់។ បញ្ហាមួយផ្សេងទៀត គឺការរក្សាកំណត់ត្រាពីដំណើរការរីកចម្រើនរបស់សិស្សម្នាក់ៗ ហើយជួនកាលក៏មានការរៀបចំសម្ភារៈបង្រៀនផងដែរ។

អ្នកសម្ភាសន៍ ៖ តើអ្វីជាវិធីសាស្ត្ររបស់អ្នកក្នុងការជំនះលើបញ្ហាបែបហ្នឹង?

គ្រូបង្រៀន ខ ៖ តាមពិតទៅខ្ញុំរៀបចំគម្រោងគ្រប់បែបយ៉ាង ហើយពេលខ្លះខ្ញុំពិភាក្សាជាមួយអាណាព្យាបាលអំពីការរីកចម្រើនរបស់កូនៗពួកគាត់។

អ្នកសម្ភាសន៍ ៖ តើអ្នកតែងតែផ្តល់មតិយោបល់ទៅកាន់សិស្សរបស់អ្នកជាលក្ខណៈបុគ្គលឬ?

គ្រូបង្រៀន ខ ៖ បាទ/ចាសប្រាកដណាស់។ ខ្ញុំក៏ពិភាក្សាជាមួយអាណាព្យាបាលរបស់ពួកគេផងដែរ។ ជួនកាលយើងចាំបាច់ត្រូវធ្វើបែបហ្នឹង។

អ្នកសម្ភាសន៍ ៖ តើការប្រាស្រ័យទាក់ទងជាមួយអាណាព្យាបាលមានលក្ខណៈយ៉ាងដូចម្តេចដែរ?

គ្រូបង្រៀន ខ ៖ យើងមានវិធីសាស្ត្រពីរ។ ទីមួយ យើងមានសៀវភៅមួយក្បាលដែលហៅថាជាសៀវភៅទំនាក់ទំនង។ នៅពេលដែលយើងត្រូវផ្តល់សារទៅកាន់អាណាព្យាបាល យើងសរសេរនៅក្នុងសៀវភៅរបស់ពួកគេ។ ហើយវិធីមួយទៀតបច្ចុប្បន្ននេះ យើងកំពុងប្រើWhatsApp។ យើងបានបង្កើតក្រុម WhatsApp ដូច្នេះនៅពេលយើងចាំបាច់ត្រូវផ្ញើសារយើងប្រើក្រុមទំនាក់ទំនងនោះ ហើយបច្ចុប្បន្ននេះវាមានប្រសិទ្ធភាពណាស់។

កំណត់ត្រាពីសំឡេង ៖ Video File 1.1.1 (វីដេអូ)

អ្នកសម្ភាសន៍ ៖ តើគ្រូរបស់អ្នកមានទំនាក់ទំនងល្អជាមួយឪពុកម្តាយរបស់អ្នកដែរឬទេ? ហេតុអ្វី?

សិស្ស ៖ គ្រូរបស់ខ្ញុំមានទំនាក់ទំនងល្អជាមួយឪពុកម្តាយខ្ញុំ។ គាត់តែងតែនិយាយអំពីចំណុចខ្លាំងរបស់ខ្ញុំ និងតម្រូវការសិក្សារបស់ខ្ញុំ។ លើសពីនេះទៅទៀតគាត់ផ្តល់ឱ្យឪពុកម្តាយខ្ញុំនូវមតិយោបល់ និងយុទ្ធសាស្ត្រជាច្រើន ដើម្បីជួយខ្ញុំនៅផ្ទះ។

អ្នកអប់រំដែលជោគជ័យត្រូវចេះពីវិធីប្រើប្រាស់ធាតុសំខាន់ៗនៃការបង្រៀនដែលមានគុណភាពខ្ពស់សម្រាប់ថ្នាក់រៀនរបស់ខ្លួន។. ក្នុងម៉ូឌុលនេះ បង្ហាញពីមូលដ្ឋានមួយចំនួនសម្រាប់ការអនុវត្តការបង្រៀនប្រកបដោយប្រសិទ្ធភាព ដើម្បីជានាថាសមាសភាពសំខាន់នៃការបង្រៀននៅកម្រិតបឋមសិក្សាត្រូវបានពិចារណានៅពេលធ្វើផែនការបង្រៀន អនុវត្តការបង្រៀន វាយតម្លៃដំណើរការបង្រៀន និងរៀន។ តាមរយៈប្រធានបទផ្សេងៗ រួមបញ្ចូលការបង្រៀន និងរៀនសតវត្សទី២១ ការធ្វើកិច្ចតែងការបង្រៀន និងបរិស្ថានសិក្សា អ្នកនឹងតម្រូវឱ្យធ្វើការឆ្លុះបញ្ចាំងពីដំណើរការបង្រៀន និងរៀនដើម្បីសម្រេចលទ្ធផលសិក្សាដោយជោគជ័យ។

សូមសិក្សាដោយរីករាយ!

TECHNISCHE UNIVERSITÄT DRESDEN

UNI GRAZ

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

CONTESSA
Contemporary Teaching Skills for South Asia
Co-funded by the Erasmus+ Programme of the European Union

ម៉ូឌុល ១

ការកសាងការយល់ដឹងពីការរៀបរៀបចំមេរៀនសិក្សា

១.២- វិធីសាស្ត្របង្រៀន និងរៀបចំកិច្ចតែងការបង្រៀនៈ បញ្ញត្តិ ឧបករណ៍ និងការអនុវត្ត

ការកសាងការយល់ដឹងអំពីការអប់រំនៅបឋមសិក្សាមេរៀននេះត្រូវបានបង្កើតឡើងដោយដៃគូសហការពាក់ព័ន្ធនៅក្នុងគម្រោងនៅក្នុង វិធីសាស្ត្របង្រៀនសម័យថ្មីនៅអាស៊ីខាងត្បូង

(Contemporary Teaching Skill for South Asia) ហៅកាត់ថា CONTESSA

ក្រោមការចូលរួមឧបត្ថម្ភថវិកាដោយកម្មវិធី Eramus+ នៃសហភាពអឺរ៉ុបដែលមានលេខគម្រោង

598756-EPP-1-2018-1-AT-EPPKKA2-CBHE-JP-/CONTESSA

កាលបរិច្ឆេទបោះពុម្ព : 2021

បោះពុម្ពដោយ: CONTESSA

អ្នកសម្របសម្រួល :

Sandra Hummel, សាកលវិទ្យាល័យហ្គ្រាស UNIVERSITY OF GRAZ (អូទ្រីស(

ក្រោមការចូលរួមសហការពី :

សាកលវិទ្យាល័យបច្ចេកវិទ្យា ជ្រៃសឺន(អាលល្លឺម៉ង់)

(កម្ពុជា) សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា

(កម្ពុជា) សាកលវិទ្យាល័យកម្ពុជា

(ស្រីលង្កា) សាកលវិទ្យាល័យអូកេននៃប្រទេសស្រីលង្កា

(ស្រីលង្កា) សាកលវិទ្យាល័យកឡំបូ

អ្នកនិពន្ធ: BRIDGET Sheehan, Sandra Hummel, Mirjam Brodacz-Geier

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

សេចក្តីប្រកាស

គណៈកម្មការអឺរ៉ុបសូមធ្វើការគាំទ្រដល់ការបោះពុម្ពឯកសារនេះ ដែលមិនមែនឆ្លុះបញ្ចាំងតែពីទស្សនៈរបស់អ្នកនិពន្ធខាងលើទេ ហើយយើងក៏មិនទទួលខុសត្រូវចំពោះការប្រើប្រាស់ព័ត៌មានដែលដកស្រង់ចេញពីការបោះពុម្ពនេះដោយប្រការណាមួយដែរ។ ព័ត៌មានលម្អិតបន្ថែមនៃមេរៀននេះអាចរកបានដោយបើកចំហ និងឥតគិតថ្លៃនៅលើគេហទំព័រ CONTESSA:

https://contessa_project.eu/

រក្សាសិទ្ធិ

មេរៀននេះត្រូវបានផ្តល់អាជ្ញាប័ណ្ណឱ្យប្រើប្រាស់ក្រោមលក្ខខណ្ឌនៃ Creative Commons

Attribution_ShareAlike 4.0 Internatinal License

(https://creativecommons.org(licenses/by_sa/4.0/) ដែលអនុញ្ញាតឱ្យប្រើប្រាស់ ចែករំលែកសម្របសម្រួល ដើម្បីប្រើប្រាស់បន្ត ចែកចាយផលិតផលសារជាថ្មីក្នុងទ្រង់ទ្រាយណាមួយ ដរាបណាអ្នកប្រើប្រាស់ផ្តល់កិត្តិយសឱ្យបានសមរម្យដល់អ្នកនិពន្ធទាំងអស់។ សូមផ្តល់ជាតំណភ្ជាប់)link) ទៅកាន់ Creative Commons License និងសូមបញ្ជាក់ផងដែរ បើមានការផ្លាស់ប្តូរណាមួយ។ ប្រសិនបើអ្នកបញ្ចូលគំនិតកែសម្រួល ឬបន្ថែមអត្ថន័យលើមេរៀននេះអ្នកត្រូវតែធ្វើការសុំសិទ្ធិកែសម្រួលឯកសារតាមលក្ខខណ្ឌខាងលើ។ រូបភាព ខ្សែសំឡេង វីដេអូ ក៏ដូចជាឯកសារដទៃទៀត ដែលមាននៅក្នុងមេរៀនទាំងនេះមិនត្រូវបានបូបញ្ចូលទៅក្នុងឯកសារអាជ្ញាប័ណ្ណ Creative Commons ទេ លើកលែងតែមានការអនុញ្ញាតឱ្យប្រើប្រាស់។ ប្រសិនបើផ្នែកណាមួយនៃមេរៀននេះមិនត្រូវបានបញ្ចូលទៅក្នុងឯកសារអាជ្ញាប័ណ្ណ ហើយការប្រើប្រាស់មិនត្រូវបានអនុញ្ញាតដោយច្បាប់ ឬក៏ប្រើប្រាស់លើសពីច្បាប់ អនុញ្ញាតត្រូវតែសុំការអនុញ្ញាតដោយផ្ទាល់ពីម្ចាស់កម្មសិទ្ធិ។

Co-funded by the
Erasmus+ Programme
of the European Union

CONTESSA
Contemporary Teaching Skills for South Asia
Co-funded by the Erasmus+ Programme of the European Union

CC BY SA

youtube.com/moeyscambodia
sala.moeys.gov.kh
t.me/moeysnews

សេចក្តីផ្តើម

តើវគ្គសិក្សា CONTESSA គឺជាអ្វី?

វគ្គសិក្សា CONTESSA គឺជាលទ្ធផលមួយក្នុងចំណោម លទ្ធផលនៃគម្រោងស្តីអំពី "ជំនាញក្នុងការបង្រៀនសម័យថ្មីសម្រាប់អាស៊ីខាងត្បូង" ដែលផ្តល់មូលនិធិរួម ដោយកម្មវិធី Erasmus+ Program នៃសហភាពអឺរ៉ុប។ គោលបំណងរបស់វគ្គសិក្សានេះ ដើម្បីជាការរួមចំណែក ក្នុងការបង្កើតកម្មវិធីអប់រំគ្រូបង្រៀន ដោយជោគជ័យសម្រាប់គ្រូបឋមសិក្សា ជាពិសេសក្នុងប្រទេសកម្ពុជា និងស្រីលង្កាដែលនឹងនាំដល់ការបង្កើតបានផលវិជ្ជមាន ដែលមានរយៈពេលវែងឆ្ងាយទៅលើប្រព័ន្ធអប់រំទូទៅ។

វាមានសារៈសំខាន់កាន់តែខ្លាំងឡើង សម្រាប់អ្នកអប់រំដែលជោគជ័យក្នុងការតាមឱ្យទាន់សម័យជាមួយនឹងជំនាញ និងវិធីសាស្ត្រក្នុងសម័យថ្មីដើម្បីយកមកប្រើក្នុង និងក្រៅថ្នាក់រៀន។ ដូច្នេះវគ្គសិក្សា CONTESSA ផ្តល់ជូនមេរៀនដែលត្រូវបានជ្រើសរើសដោយប្រុងប្រយ័ត្នចំនួន៥ម៉ូឌុល ដែលម៉ូឌុលនីមួយៗមានការផ្តល់ការយកចិត្តទុកដាក់ទៅលើចំណុចចំនួនបីដែលតម្រង់ទៅរកការអភិវឌ្ឍលើជំនាញបង្រៀនបែបសម័យថ្មី។

ម៉ូឌុលទាំងឡាយ និងការផ្តោតការយកចិត្តទុកដាក់របស់វា គឺមានដូចខាងក្រោម៖

ម៉ូឌុល១៖ ការកសាងការយល់ដឹងអំពីការអប់រំនៅបឋមសិក្សា
១. ការបង្រៀន និងការរៀននៅសតវត្សទី២១
២. ការរៀបចំកិច្ចតែងការបង្រៀន និងជំនាញគរុកោសល្យ៖ គំនិត ឧបករណ៍ និងការអនុវត្ត
៣. ការរៀបចំបរិយាកាសសិក្សា

ម៉ូឌុល២៖ ភាពអស្ចារ្យក្នុងការបង្រៀន៖ សមត្ថភាពជាក់លាក់ប្រកបទៅដោយវិជ្ជាជីវៈរបស់គ្រូបង្រៀនបឋមសិក្សា
១. ការយល់ដឹងពីការបង្រៀន៖ តួនាទី កិច្ចការ និងមុខងារ
២. ការវាយតម្លៃទៅលើលទ្ធផលនៃការសិក្សា
៣. ជំនាញវិជ្ជាជីវៈគរុកោសល្យ

ម៉ូឌុល៣៖ ការអប់រំឈានមុខគេបែបវិធីសាស្ត្រ សិស្សមជ្ឈមណ្ឌល៖ ការលើកម្ពស់ដំណើរការសិក្សាដែលបានបង្កើតរួមគ្នា
១. ការអភិវឌ្ឍលក្ខណៈបុគ្គល និងជំនាញដោះស្រាយបញ្ហា
២. ការអះអាងពីពិភពជីវិតជាក់ស្តែង និងក្តីសង្ឃឹមទៅអនាគត
៣. ការប្តេជ្ញាចិត្តដោយខ្លួនឯង ការផ្តល់សិទ្ធិអំណាច និងប្រសិទ្ធភាពផ្ទាល់ខ្លួន

ម៉ូឌុល៤៖ ការរួមបញ្ចូលភាពខុសគ្នា៖ គោលវិធីគរុកោសល្យសម្រាប់ភាពចម្រុះគ្នា ភាពមិនស្មើគ្នា និងតម្រូវការពិសេស
១. គរុកោសល្យបរិយាបន្ន៖ គោលវិធី និងយុទ្ធសាស្ត្រ
២. ការបង្រៀន និងការរៀនក្នុងភាពចម្រុះគ្នា៖ ការរៀបចំការយល់ដឹង ការវាយតម្លៃ
៣. ការគ្រប់គ្រងថ្នាក់រៀនដែលមានភាពចម្រុះគ្នា

ម៉ូឌុល៥៖ ការបង្រៀន និងការរៀនតាមបែបឌីជីថល
១. គរុកោសល្យនៃការសិក្សាពីចម្ងាយ និងបរិយាកាសសិក្សាដែលបំពាក់ទៅដោយបច្ចេកវិទ្យា
២. ប្រព័ន្ធផ្សព្វផ្សាយ និងបច្ចេកទេសឌីជីថល៖ ឧបករណ៍ និងទម្រង់សម្រាប់គោលបំណងការអប់រំ
៣. ការរៀបចំមេរៀន និងដំណើរការបង្រៀនតាមអ៊ីនធឺណែតនៅពេលដែលបញ្ចប់វគ្គសិក្សានេះ អ្នកចូលរួមនឹងអាចអនុវត្តជំនាញបង្រៀនសម័យថ្មី ដែលទើបទទួលបានធ្វើឱ្យសិស្សទាំងអស់អាចចូលរួមសកម្មភាពក្នុងថ្នាក់ និងរៀនពីវិធីថ្មីៗដើម្បីជួយឱ្យសិស្សឈានទៅដល់ចំណុចសក្តានុពលពេញលេញរបស់ពួកគេ។

តើវគ្គសិក្សា CONTESSA សម្រាប់អ្នកណា?

គម្រោងស្តីពីជំនាញក្នុងការបង្រៀនសម័យថ្មីសម្រាប់អាស៊ីខាងត្បូងមានបំណងក្នុងការលើកតម្កើងជំនាញបង្រៀនសម័យថ្មីសម្រាប់គរុនិស្សិត និងគ្រូបង្រៀនដែលកំពុងបម្រើការក្នុងសាលាបឋមសិក្សានានា។ ឯកសារខាងក្រោមត្រូវបានសម្របសម្រួលជាពិសេសសម្រាប់គរុនិស្សិត។ លើសពីនេះទៅទៀត វគ្គសិក្សា CONTESSA ក៏សម្រាប់អ្នកដែលចាប់អារម្មណ៍ក្នុងការធ្វើខ្លួនឱ្យទាន់សម័យកាលជាមួយ និងជំនាញបង្រៀនសម័យថ្មី។

ឯកសារមានជាភាសាអង់គ្លេស ហើយក៏មានជាភាសាខ្មែរ ភាសាសិង្ហាលា (Sinhala) និងភាសាតាមីល (Tamil) ដែលប្រើប្រាស់នៅប្រទេសស្រីលង្កា។

តើរចនាសម្ព័ន្ធនៃវគ្គសិក្សា CONTESSA មានអ្វីខ្លះ?

ដូចដែលបានលើកឡើងពីមុនរួមហើយវគ្គសិក្សា CONTESSA នេះរួមមាន៥ម៉ូឌុល ដែលម៉ូឌុលនីមួយៗ មានតម្លៃស្មើនឹង ៣ ក្រេឌីតតាមប្រព័ន្ធផ្ទេរការសិក្សារបស់អឺរ៉ុប។ ជាការល្អ ម៉ូឌុលទាំងនេះត្រូវបានប្រើប្រាស់រួមគ្នា ព្រោះម៉ូឌុលនីមួយៗយោងឯកសារលើម៉ូឌុលដទៃទៀត។ ប៉ុន្តែក្នុងមេរៀនម៉ូឌុលទាំងនេះក៏ត្រូវបានបង្កើតឡើងក្នុងវិធីមួយដែលអាចប្រើបានដោយខ្លួនឯងផ្ទាល់ផងដែរ។

ម៉ូឌុលនីមួយៗមានការផ្តោតលើប្រធានបទចំនួនបី ហើយឯកសារទាំងឡាយក៏បង្កើតឡើង សម្រាប់ការផ្តោតនីមួយៗផងដែរ។ វាបង្កើតឱ្យមានឯកសារសរុបចំនួន១៥ផ្នែកសម្រាប់វគ្គសិក្សា CONTESSA ។ ឯកសារនីមួយៗរួមមានសេចក្តីផ្តើមបែបទ្រឹស្តីចំពោះចំណុចផ្តើម ហើយតាមពីក្រោយដោយលំហាត់អនុវត្ត ដោយផ្អែកលើទ្រឹស្តី។ **ជំហាន១ – ទ្រឹស្តី** – គឺជាការម្លឹកនូវអ្វី ដែលបានអាននៅក្នុងសេចក្តីផ្តើមនៃទ្រឹស្តីលំហាត់អនុវត្តទាំងនេះ ត្រួតពិនិត្យការយល់ដឹងនៃអត្ថបទដើម្បីប្រាកដថាទ្រឹស្តីជាមូលដ្ឋានដែលត្រូវបានយល់ដឹង។

ជំហាន២-បពិសោធ– ផ្តល់ជូននូវឧទាហរណ៍នៃគ្រូបង្រៀនពិតប្រាកដ និងពីវិធី ដែលពួកគាត់អនុវត្តទ្រឹស្តីផ្សារភ្ជាប់នឹងការអនុវត្តជាក់ស្តែង។ ឧទាហរណ៍ទាំងនេះបានភ្ជាប់លំហាត់អនុវត្តទៅនឹងទ្រឹស្តីដែលបានរៀនពីមុនរួចហើយ។ **ជំហាន៣ – ការឆ្លុះបញ្ចាំងដោយខ្លួនឯងផ្ទាល់** – វាប់បញ្ចូលសំណួរបែបឆ្លុះបញ្ចាំងដោយផ្អែកទៅលើចំណុចផ្តោតនីមួយៗ។ **ជំហាន៤ – ការអនុវត្ត** – គឺជាជំហានចុងក្រោយដែលមានគម្រោងគោលនៃការបង្រៀនមួយត្រូវបានបង្កើតឡើងផ្អែកទៅលើអ្វីដែលបានប្រទះឃើញពីមុននៅក្នុងជំហានទីមួយ និងទីពីរ។

លំហាត់អនុវត្តនៅក្នុងជំហានទីមួយ និងទីពីរអាចត្រូវបានបំពេញដោយផ្ទាល់ក្នុងឯកសារនេះ។ ជំហានទី៣ និងទីបួនជាផ្នែកនៃឯកសារដែលរៀបជាសំណុំដាច់ដោយឡែកដែលនឹងត្រូវបង្កើតដោយបុគ្គលម្នាក់ៗ។ គំរូសម្រាប់ការរៀបចំសំណុំឯកសារ (portfolio) មានជាឯកសារដាច់ដោយឡែកពីគ្នា។

CONTESSA
Contemporary Teaching Skills for South Asia
Co-funded by the Erasmus+ Programme of the European Union

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

មាតិកា

១- របៀបរៀនរបស់សិស្ស គំរូការរៀនសូត្រ 1

២- យុទ្ធសាស្ត្របង្រៀនដែលមានប្រសិទ្ធភាព 10

- ២.១- ការបង្រៀនដោយផ្ទាល់ 10
- ២.២- ការបង្រៀនមិនផ្ទាល់ 11
- ២.៣- ការបង្រៀនតាមរយៈបទពិសោធ 12
- ២.៤- ការបង្រៀនតាមបែបអន្តរកម្ម 13
- ២.៥- ស្វ័យសិក្សា 14

៣- ប្រភេទថ្នាក់រៀនផ្សេងៗ 15

- ៣.១- ការបង្រៀនថ្នាក់ដែលមានសិស្សច្រើន 15
- ៣.២- ការបង្រៀនថ្នាក់ដែលមានសិស្សតិច 17

៤- វិធីសាស្ត្របង្រៀន 19

៥- ការបង្រៀនប្រកបដោយប្រសិទ្ធភាព 22

- ៥.១- ការរៀបចំកិច្ចតែងការបង្រៀន 22
- ៥.២- ការធ្វើបទបង្ហាញ និងការពន្យល់ 28
- ៥.៣- ការសួរសំណួរ 29
- ៥.៤- ការពិនិត្យតាមដាន 31

៦- ចំណុចគន្លឹះ 36

ឯកសារពិគ្រោះ 38

លំហាត់អនុវត្ត 42

ជំហានទី១៖ ពង្រឹងចំណេះដឹង 42

ជំហានទី២៖ អនុវត្ត 48

ចម្លើយអនុវត្ត 54
ជំហានទី១៖ ពង្រឹងចំណេះដឹង 54
ជំហានទី២៖ ចម្លើយអនុវត្ត 60
ជំហានទី៣៖ កិច្ចការរៀបចំឯកសារជាសំណុំ សំណួរឆ្លុះបញ្ចាំងពីខ្លួនឯងផ្ទាល់ 66
ជំហានទី៤៖ កិច្ចការរៀបចំឯកសារសំណុំ – គម្រោងការបង្រៀន 66
ឧបសម្ព័ន្ធ 67
កំណត់ត្រាពីសំឡេង៖ Video File 1.2.1 67
កំណត់ត្រាពីសំឡេង៖ Video File 1.2.2 67

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

១- របៀបរៀនរបស់សិស្ស គំរូការរៀនសូត្រ

ការយល់ដឹងពីរបៀបរៀនរបស់សិស្សគឺសំខាន់ខ្លាំងណាស់ ដើម្បីឱ្យការបង្រៀនទទួលបានជោគជ័យ។ គ្រូបង្រៀនគួរចែកការរៀន២កម្រិតផ្សេងគ្នាគឺ ការរៀនបែបសើៗ និងការរៀនបែបស៊ីជម្រៅ។ ការរៀនទាំង២កម្រិតនេះមិនគ្រាន់តែចង់សំដៅលើទំនោរ ឬវិធីរៀនរបស់សិស្សប៉ុណ្ណោះទេ ប៉ុន្តែចង់សំដៅទៅលើកម្រិតនៃការយល់របស់សិស្សទៅលើមេរៀន ដែលបានបង្រៀនផងដែរ។ ការរៀនតាមបែបសើៗ គឺជាការរៀនដោយផ្តោតសំខាន់តែទៅលើចំណេះដឹងកម្រិតទាប ការទន្ទេញចាំមាត់ រម្លឹកការចងចាំ ដែលនឹងអាចភ្លេចទៅវិញនៅក្នុងរយៈពេលដ៏ខ្លី។ ផ្ទុយទៅវិញការរៀនតាមបែបស៊ីជម្រៅគឺជាការរៀនដែលសិស្សអាចយល់ វាយតម្លៃ វិភាគបញ្ញត្តិគន្លឹះនៃមេរៀន និងយកចំណេះទាំងនោះទៅប្រើដោះស្រាយបញ្ហា ឬរឿងរ៉ាវផ្សេងៗ (Keeble 2016)។ សិស្សកម្រិតបឋមសិក្សា ជាធម្មតាតែងតែចង់ចេះចង់ដឹងអំពីពិភពលោក ដែលពួកគេកំពុងរស់នៅ ឆ្លើយតបបានយ៉ាងល្អទៅសកម្មភាពរៀនរបស់គេ ប្រកបដោយការជំរុញ ទឹកចិត្តខ្ពស់។ គ្រូបង្រៀនដែលពូកែគឺអាចរៀបចំសកម្មភាពរៀនប្រកបដោយស៊ីជម្រៅសម្រាប់សិស្សនៅក្នុងថ្នាក់រៀន ដើម្បីលើកទឹកចិត្តសិស្ស ឱ្យក្លាយជាអ្នកពូកែគិតស៊ីជម្រៅ ទទួលបានជំនាញថ្មីតាមបរិបទផ្សេងៗគ្នា (Johnson et al. 2016)។

ដើម្បីអនុវត្តការរៀនតាមបែបស៊ីជម្រៅនៅក្នុងថ្នាក់រៀន គ្រូបង្រៀនត្រូវយល់ពីតម្រូវការ និងសមត្ថភាពផ្សេងៗគ្នារបស់សិស្សម្នាក់ៗ។ ការយល់ដឹងអំពីទ្រឹស្តីទូទៅនៃការរៀន អាចជួយគ្រូបង្រៀនឱ្យសម្រេចការងារនេះបាន។ **ទ្រឹស្តីនៃការរៀន** បានផ្តល់ជាមូលដ្ឋានគ្រឹះ សម្រាប់តម្រូវការរបស់សិស្ស និងអាចផ្តល់ជាយុទ្ធសាស្ត្របង្រៀនដែលត្រឹមត្រូវ ដើម្បីសម្រេចតម្រូវការនោះ។ នៅពេលដែលគ្រូបង្រៀនយល់កាន់តែច្បាស់អំពីទ្រឹស្តីនៃការរៀន ពួកគាត់អាចធ្វើការសម្រេចចិត្តបានកាន់តែប្រសើរ ក្នុងការជ្រើសរើសវិធីបង្រៀនសមស្រប។ មានទ្រឹស្តីនៃការរៀនជាច្រើន ប៉ុន្តែនៅក្នុងជំពូកនេះយើងនឹងលើកយកទ្រឹស្តីចំនួន៥ ដែលមានឥទ្ធិពលខ្លាំងដល់ការបង្រៀន ៖

ទ្រឹស្តីអាកប្បកិរិយានិយម ទ្រឹស្តីការគិតនិយម ទ្រឹស្តីស្ថាបនានិយម ទ្រឹស្តីផ្សារភ្ជាប់និយម និងទ្រឹស្តីផ្តោតលើសិស្ស (Johnson et al., 2016)។

ទ្រឹស្តីនៃការរៀន
ទ្រឹស្តីនៃការរៀន គឺជារចនាសម្ព័ន្ធបែបអរូបីដែលពណ៌នាអំពីសៀមដែលចំណេះដឹងត្រូវបានទទួលបានដំណើរការក្នុងកំឡុងពេលរៀន។ ទ្រឹស្តីនៃការរៀនបានផ្តល់ព័ត៌មានពីការប្រើប្រាស់ការបង្កើតបទពិសោធរៀន

ទ្រឹស្តីអាកប្បកិរិយានិយម(Behaviorism) សំដៅដល់ការរៀន ដែលសិស្សមានប្រតិកម្មតបសមស្រប ដោយសារតែមានការជំរុញពីកត្តាខាងក្រៅ។ ផ្អែកលើបញ្ញត្តិនេះ សិស្សរៀនដោយសារការជំរុញ(បង្ខំ) ដូចជាការផ្តល់ព័ត៌មានត្រលប់ជាប់ជាប្រចាំ ជាវិជ្ជមានក្តី ឬអវិជ្ជមានក្តីពីសំណាក់គ្រូបង្រៀន ប្រាប់ពួកគេថាធ្វើត្រូវ ឬខុស។ សម្រាប់ទ្រឹស្តីអាកប្បកិរិយានិយម គ្រូបង្រៀនមានតួនាទីជាអ្នកត្រួតពិនិត្យសកម្មភាពរៀន គឺថាគ្រូបង្រៀនបង្កើតឱ្យមានបរិយាកាសជំរុញផ្លូវចិត្តមួយចំនួន ដូចជាការដាក់ពិន័យ ឬការផ្តល់រង្វាន់ជាដើម។ សិស្សត្រូវបានគេគិតថាជាអ្នករៀនបែបអសកម្ម ជាជាងការផ្តល់ឱ្យពួកគេយល់ថា ពួកគេមានតួនាទីបង្កើតបរិយាកាសសិក្សាយ៉ាងសកម្មនៅក្នុងថ្នាក់រៀន។ ដោយហេតុនេះ ទ្រឹស្តីអាកប្បកិរិយានិយមសមស្របសម្រាប់តែបរិយាកាសសិក្សាដែលទាមទារការផ្តល់ព័ត៌មានត្រលប់ភ្លាមៗ ការបង្កើតទម្លាប់ដដែលៗ និងការជំរុញឱ្យសិស្សមានអាកប្បកិរិយាល្អ (Ertmer & Newby, 2013)។ ឧទាហរណ៍ខាងក្រោម បង្ហាញពីការអនុវត្តទ្រឹស្តីនេះទៅក្នុងបរិយាកាសសិក្សានៅកម្រិតបឋមសិក្សា៖

- នាំយកសំឡេងតន្ត្រីទៅក្នុងថ្នាក់រៀន ដើម្បីបង្កើតជាទម្លាប់មួយ ដោយប្រាប់សិស្សទាំងអស់ថា នៅពេលដែលឮសំឡេងតន្ត្រីចាប់ផ្តើមបន្លឺឡើង មានន័យថាសកម្មភាពដែលពួកគេកំពុងធ្វើត្រូវបានបញ្ចប់ ហើយពួកគេត្រូវធ្វើការសម្អាតនិងត្រៀមដើម្បីបន្តទៅសកម្មភាពបន្ទាប់។ ដើម្បីជាការលើកទឹកចិត្តសិស្សឱ្យចូលរួមបង្កើតទម្លាប់នេះ គ្រូអាចឱ្យសិស្សជាអ្នកជ្រើសរើសបទចម្រៀងណាដែលពួកគេចូលចិត្ត
- ផ្តល់ឱ្យសិស្សផ្ទាល់នូវយោបល់ណែនាំភ្លាមៗ បន្ទាប់ពីពួកគេបញ្ចប់កិច្ចការណាមួយរួច ដោយពន្យល់ពីអ្វីដែលគេធ្វើបានល្អ និងអ្វីដែលគួរកែលម្អបន្ថែមនៅលើកក្រោយ។ ការអូសបន្លាយពេលក្នុងការផ្តល់យោបល់ណែនាំទៅសិស្ស អាចធ្វើឱ្យពួកគេមិនអនុវត្តតាមយោបល់ដែលគ្រូបានផ្តល់ឱ្យ។
- បង្កើតឱ្យមានប្រព័ន្ធលើកទឹកចិត្ត ដូចជាការបន្ថែមពិន្ទុ ការទទួលបានក្រេឌីតសិក្សាបន្ថែមឬទទួលបានរូបស្នឹកគ័រ សម្រាប់សិស្សដែលមានអាកប្បកិរិយាល្អ ដូចជាលើកដៃឆ្លើយសំណួរ ឬ ខំប្រឹងធ្វើកិច្ចការសាលាជាដើម។

យោងទៅលើគរុកោសល្យនាសម័យទំនើបនេះ ការបង្រៀននៅក្នុងថ្នាក់រៀនដោយអនុវត្តទ្រឹស្តី អាកប្បកិរិយានិយមនេះ ត្រូវបានគេចាត់ទុកថា **«ហួសសម័យ»** និងមិនជោគជ័យក្នុងការជួយសិស្សឱ្យទទួលបានបំណិនកម្រិតខ្ពស់ ឬបំណិនដែលទាមទារដំណើរការស្មុគស្មាញបានទេ (Ertmer & Newby,2013)។

និងសម្ភារៈទ្វេសសម្រាប់រៀនទៅតាមគំរូផ្សេងៗ (*Learning Theory*, 2020, online).

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

<u>ទ្រឹស្តីការគិតនិយម(Cognitivism)</u> សំដៅទៅលើការរៀនតាមរយៈការធ្វើសកម្មភាព ការយល់ដឹងទូលំទូលាយ និងការឆ្លុះបញ្ចាំង។ ជាញឹកញាប់ វាត្រូវបានគេប្រៀបប្រដូចទៅនឹងគំរូការដំណើរការព័ត៌មានរបស់កុំព្យូទ័រដូច្នោះដែរ។ ចំណេះដឹងថ្មីៗត្រូវបានបង្កើត តាមរយៈការទទួលស្គាល់ព័ត៌មានមូលដ្ឋានមានស្រាប់ ឬដោយការសម្របទៅនឹងព័ត៌មានថ្មី។ អ្នកសិក្សាមានតួនាទីយ៉ាងសកម្មក្នុងដំណើរការរៀន ដោះស្រាយកិច្ចការដែលគ្រូដាក់ឱ្យ ដោយប្រើវិធីសាស្ត្ររៀនសមស្រប (Johnson et al.,2016)។ គ្រូបង្រៀនមានតួនាទីជាអ្នកហ្វឹកហ្វឺន ដោយផ្តើមគំនិត (បញ្ហា) ត្រួតពិនិត្យ គាំទ្រដល់ការរៀន ការរៀបចំសម្ភារៈបទ្វេស និងផ្តល់មតិយោបល់ណែនាំដល់សិស្សជាប់ជានិច្ច។ ប្រសិនបើចាំបាច់ គ្រូអាចធ្វើអន្តរាគមន៍យ៉ាងសកម្ម ក្នុងដំណើរការរៀនរបស់សិស្ស តាមរយៈការផ្តល់ការណែនាំគាំទ្រ។ សិស្សអាច អភិវឌ្ឍវិធីសាស្ត្រដោះស្រាយបញ្ហាដោយផ្ទាល់ខ្លួន គេជ្រើសរើសវិធីសាស្ត្រត្រឹមត្រូវ ប្រើវិធីទាំងនោះតាមកាលៈទេសៈសមស្រប វាយតម្លៃលទ្ធផល និងឆ្លុះបញ្ចាំងលើដំណើរការនៃការរៀនសូត្ររបស់ពួកគេ (Ertmer & Newby, 2013)។

ផ្ទុយទៅនឹងទ្រឹស្តីអាកប្បកិរិយានិយម ទ្រឹស្តីការគិតនិយមកសាងចំណេះដឹងដែលមានន័យ និងផ្សារភ្ជាប់ចំណេះដឹងមានស្រាប់ទៅនឹងចំណេះដឹងថ្មី។ ដំណើរនេះត្រូវបានគេមើលឃើញថាជាដំណើរផ្លាស់ប្តូរចំណេះដឹង ដែលបន្ទាប់មកត្រូវបានរក្សាទុកយ៉ាងជ្រៅក្នុងអង្គចងចាំ ជាជាងគ្រាន់តែផ្លាស់ប្តូរត្រឹមតែអាកប្បកិរិយា។ ដើម្បីអនុវត្តគោលការណ៍ការគិតនិយម គ្រូបង្រៀនត្រូវប្រាស្រ័យជាមួយសិស្សយ៉ាងសកម្ម ក្នុងដំណើរការរៀន ដោយផ្តោតលើដំណើររៀនជាជាងផ្តោតតែទៅលើលទ្ធផលសិក្សា និងសង្កត់ធ្ងន់ទៅលើរបៀបរៀបចំលំដាប់លំដោយ នៃព័ត៌មាន (Ertmer & Newby, 2013)។

ខាងក្រោមគឺជា ឧទាហរណ៍អំពីការអនុវត្តទ្រឹស្តីការគិតនិយមនៅក្នុងថ្នាក់រៀនកម្រិតបឋមសិក្សា៖

- ចាប់ផ្តើមមេរៀនថ្មី ដោយរម្លឹកឡើងវិញនូវចំណេះដឹងមានស្រាប់របស់សិស្ស។ ផ្សារភ្ជាប់ទំនាក់ទំនងរវាងចំណេះដឹងថ្មីទៅនឹងអ្វី ដែលបានរៀនពីមុនរួចហើយ ផ្តើមដោយការសួរសំណួរ ឬ រម្លឹកមេរៀនចាស់
- ប្រើឧបករណ៍ជំនួយ ដូចជាផែនទីគំនិតដើម្បីជួយសិស្សឱ្យចេះរៀបចំព័ត៌មានចំណេះដឹង ឬ រៀបតារាងក្រាហ្វិកគំនិត ដើម្បីជាជំនួយដល់សិស្សក្នុងការសរសេរជាឃ្លាប្រយោគ

- បង្កើតល្បែងសិក្សា និងល្បែងប្រជ្រាបែបអប់រំ នៅក្នុងថ្នាក់ ដែលជួយឱ្យសិស្សអាចប្រើប្រាស់ជំនាញ ដែលបានរៀនរួចហើយ ដើម្បីអនុវត្តឈ្វេងយល់រួមជាមួយមិត្តរួមថ្នាក់បាន
- បង្ហាញសិស្សពីរបៀបដែលឧបករណ៍មនោវិទ្យា (ការប្រើអក្សរតំណាងដើម្បីចងចាំអ្វីមួយ) អាចជួយពួកគេចងចាំលំដាប់ពាក្យសំខាន់ៗ
  (ឧទាហរណ៍ដូចជា My Very Educated Mother Just Served Us Noodles - Mercury Earth Mars Jupiter, Saturn, Uranus, Neptune)។

ទ្រឹស្តីស្ថាបនានិយម (Constructivism) ចែងថា សិស្សទទួលបានព័ត៌មាន និងគំនិតថ្មី ដោយផ្អែកលើបទពិសោធពីមុនដែលសិស្សធ្លាប់ឆ្លងកាត់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគេ។ ដោយសិស្សធ្លាប់ឆ្លងកាត់បទពិសោធក្នុងពិភពរស់នៅ ពួកគេអាចធ្វើការឆ្លុះបញ្ចាំង និងបង្កើតបានជាបទពិសោធ ព្រមទាំងចងក្រងព័ត៌មានជាចំណេះដឹង **ឬ គ្រោងការណ៍(Schemas)** មានស្រាប់របស់ពួកគេ (Johnson et al.,2016)។ ចំណុចសំខាន់នៃទ្រឹស្តីស្ថាបនានិយមនៅក្នុងថ្នាក់រៀនគឺមិនមែនផ្តល់ចំណេះដឹងទៅឱ្យសិស្សនោះទេ។ ប៉ុន្តែវាជាការផ្តល់បទពិសោធដែលជួយឱ្យពួកគេបង្កើតបានជាចំណេះដឹងដោយខ្លួនឯង។ ដោយហេតុថាសិស្ស និងគ្រូធ្វើការជាមួយគ្នាដើម្បីកសាងចំណេះដឹងថ្មី ស្ថាបនានិយមចាត់ទុកការរៀនជាដំណើរ សហប្រតិបត្តិការដោយបញ្ជ្រាបជាមួយនឹងបរិបទសង្គម។ តួនាទីរបស់គ្រូគឺជាដៃគូសិក្សារបស់សិស្ស ក្នុងការបង្កើតលក្ខខណ្ឌដែលសិស្សអាចសិក្សាដោយខ្លួនឯង ហើយដែលការណ៍នេះអាចនាំឱ្យបង្កើតបាននូវដំណើរការនៃការអភិវឌ្ឍចំណេះដឹងដោយឯករាជ្យ(Ertmer & Newby,2013)។

ដើម្បីអនុវត្តគោលការណ៍ស្ថាបនានិយមនៅក្នុងថ្នាក់រៀន គ្រូបង្រៀនត្រូវតែប្រាកដថា ចំណេះដឹងមិនមែនអរូបីទេ ប៉ុន្តែវាត្រូវតែផ្សារភ្ជាប់ទាំងបរិបទសង្គមមនុស្ស និងបុគ្គល។ នៅពេលដែលសិស្សភ្ជាប់ព័ត៌មានថ្មីទៅនឹងបទពិសោធជំនឿ និងឥរិយាបថរបស់គេផ្ទាល់ដើម្បីបង្កើតចំណេះដឹងថ្មី ពួកគេនឹងអាចដោះស្រាយបញ្ហានៅក្នុងជីវិតពិតរបស់គេបានកាន់តែប្រសើរឡើង ដោយក្លាយជាអ្នកគិតស៊ីជម្រៅគ្រប់ជ្រុងជ្រោយ និងជាអ្នកដោះស្រាយបញ្ហា (Johnson et al.,2016)។ ឧទាហរណ៍ នៃការអនុវត្តទ្រឹស្តីស្ថាបនានិយម នៅក្នុងថ្នាក់រៀនកម្រិតបឋមសិក្សារួមមាន៖

- ដោយប្រើ **ការរៀនផ្អែកលើបញ្ហា** ដើម្បីឱ្យសិស្សកំណត់បញ្ហាជាក់ស្តែងណាមួយនៅសាលារៀនឬ នៅកន្លែងដែលពួកគេរស់នៅ រួចផ្តល់ឱកាសឱ្យពួកគេបំផុស

គ្រោងការណ៍ (Schemas) អនុញ្ញាតឱ្យអ្នកសិក្សាផ្តល់ហេតុផលស្ថានភាពរៀនថ្មី និងបកស្រាយស្ថានភាពទាំងនេះ ជាចំណេះដឹងទូទៅ។ គ្រោងការណ៍អាចត្រូវសិក្សាដើម្បីលើកកម្ពស់ការទទួលបានចំណេះដឹង និង (Lee & Seel, 2012, online)

ការរៀនផ្អែកលើបញ្ហា (PBL) គឺជាវិធីសាស្ត្របង្រៀនដែល

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

គំនិតសាកល្បងរកដំហានដើម្បីដំណោះស្រាយ។ ពួកគេអាចធ្វើបទបង្ហាញពីដំណោះស្រាយរបស់គេតាមវិធីផ្សេងៗរាប់តាំងពីការសរសេរជាសំបុត្រ ដល់ការធ្វើបទបង្ហាញតាមប្រព័ន្ធផ្សព្វផ្សាយនានា(ពហុមេឌា)។

- រៀបចំសិស្សជាក្រុម រួចឱ្យពួកគេស្រាវជ្រាវលើប្រធានបទណាមួយ ធ្វើដូច្នេះ ពួកគេនឹងក្លាយជាអ្នកជំនាញលើប្រធានបទនោះនៅក្នុងថ្នាក់រៀន។ ពួកគេអាចបង្រៀនបញ្ញត្តិថ្មីនោះទៅមិត្តរួមថ្នាក់ផ្សេងទៀត
- ចូលរួមការរៀនតាមបែបស្រាវជ្រាវ ដោយធ្វើដំណើរទស្សនកិច្ចសិក្សាទៅកន្លែងផ្សេងៗ ដើម្បីឱ្យសិស្សអាចយកចំណេះដឹងដែលបានរៀនក្នុងថ្នាក់ទៅប្រើនៅក្នុងបរិបទជាក់ស្តែង។ ដំណើរទស្សនកិច្ចសិក្សា អាចមានលក្ខណៈសាមញ្ញដូចជាការដើរនៅខាងក្រៅថ្នាក់ប្រមូលស្លឹកឈើ ដើម្បីសិក្សាពីឫសរបស់វា ឬប្រើវាក្នុងការធ្វើគម្រោងសិល្បៈជាដើម។

ទ្រឹស្តីផ្សារភ្ជាប់និយមន័យ(Connectivism) បានជឿថាសិស្សអាចធ្វើឱ្យដំណើរការនៃការរៀនបានប្រសើរឡើងនៅពេលដែលពួកគេរៀនដោយផ្សារភ្ជាប់ទៅនឹងបណ្តាញផ្សេងៗ។ សិស្សមិនអាចស្វែងរកបទពិសោធពីអ្វីគ្រប់យ៉ាងដែលគេចង់រៀនដោយខ្លួនឯងនោះទេ ពួកគេត្រូវការបង្កើនមូលដ្ឋានចំណេះដឹង និងបទពិសោធជាមួយភាគីទី៣ដូចជា បច្ចេកវិទ្យា ឬបណ្តាញសង្គមផ្សេងៗ(Siemens,2017)។

ការសិក្សាវាមិនអាស្រ័យតែទៅលើខ្លួនឯងតែម្យ៉ាងទេ ប៉ុន្តែក៏អាស្រ័យនឹងបរិស្ថានជុំវិញផងដែរ។ សិស្សដែលអាចបង្កើតបណ្តាញទំនាក់ទំនងមូលដ្ឋានសម្រាប់បរិស្ថានជុំវិញរបស់គេ អាចធ្វើឱ្យពួកគេទទួលបានចំណេះដឹងថ្មីៗទាន់ពេលវេលា។ ក្នុងទស្សនៈរបស់ទ្រឹស្តីផ្សារភ្ជាប់និយម សមត្ថភាពទទួលបាននូវចំណេះដឹងថ្មីៗតាមរយៈការផ្លាស់ប្តូរគំនិតជាមួយអ្នកដទៃ និងព្យាយាមជម្នះរាល់ឧបសគ្គជាមួយគ្នា គឺពិតជាសំខាន់ជាងចំណេះដឹងរបស់ខ្លួនឯង តែម្នាក់។

> *ចំណុចចាប់ផ្តើមនៃទ្រឹស្តីផ្សារភ្ជាប់និយមគឺបុគ្គលសិស្សខ្លួនឯង។ ចំណេះដឹងផ្ទាល់ខ្លួនគឺត្រូវយកទៅប្រើប្រាស់នៅក្នុងប្រព័ន្ធបណ្តាញទំនាក់ទំនង ដែលសមស្របទៅនឹងស្ថាប័ន ឬគ្រឹះស្ថាន បន្ទាប់មកប្រព័ន្ធបណ្តាញនោះត្រូវបានបន្តប្រើដើម្បីអភិវឌ្ឍចំណេះដឹងបុគ្គលជាប្រចាំ។ វដ្តនៃការអភិវឌ្ឍចំណេះដឹង (ពីបុគ្គលទៅប្រព័ន្ធ ទៅកម្រិតស្ថាប័ន) ផ្តល់ឱ្យអ្នកសិក្សា រក្សាបាននូវបច្ចុប្បន្នភាពនៃជំនាញ របស់ពួកគេ តាមរយៈបណ្តាញទំនាក់ទំនងដែលគេបានបង្កើត* (Siemens,2017,online) ។

មានគោល- បំណងជួយសិស្សសម្រាប់ជីវភាពពិតនៅក្នុងជីវិត។ តាមរយៈឱ្យសិស្សរៀនដោះស្រាយបញ្ហា វិធីនេះក៏ជួយលើកកម្ពស់លទ្ធផលនៃការរៀនសូត្ររបស់សិស្សផងដែរ តាមរយៈការបង្កើនសមត្ថភាព និងជំនាញអនុវត្តចំណេះដឹង និងដោះស្រាយបញ្ហាអនុវត្តការគិតកម្រិតខ្ពស់ និងដឹកនាំការរៀនសូត្រដោយខ្លួនឯង (Jonassen & Hung, 2012, online)

នៅក្នុងបរិបទនេះ គ្រូបង្រៀនមានតួនាទីជាអ្នកប្រឹក្សា ដែលជួយគាំទ្រដល់សិស្សឱ្យកសាងចំណេះដឹង ដោយផ្អែកលើបទពិសោធតាមរយៈការផ្លាស់ប្តូរគ្នា ធ្វើការជាមួយគ្នា និងផ្សារភ្ជាប់ទំនាក់ទំនងជាមួយគ្នា។ សិស្សគួរយល់ថា ការដឹងពីវិធីទទួលបានចំណេះដឹង គឺវាមានភាពចាំបាច់ ដូចជាចំណេះដឹងដែរ។ ឧទាហរណ៍នៃទ្រឹស្តីផ្សារភ្ជាប់និយម ដែលប្រើនៅកម្រិតបឋមសិក្សារួមមាន៖

- បង្រៀនសិស្សពីរបៀបស្វែងរកព័ត៌មានដែលមានភាពច្បាស់លាស់ និងមានសុពលភាព ទាំងនៅលើប្រព័ន្ធអនឡាញ សៀវភៅ ឬនៅក្នុងសហគមន៍ដែលគេរស់នៅ។ វានៅតែមានសារៈសំខាន់ ដែលសិស្សត្រូវពិនិត្យឡើងវិញនូវអង្គហេតុជាក់ស្តែងក្នុងជីវភាពរស់នៅ។
- បើកបង្ហាញសិស្សឱ្យយល់អំពីវិសាលភាពនៃចំណេះដឹង និងគំនិតច្រើនចម្រុះគ្នា ដោយបង្ហាញពួកគេថា «បណ្តាញកាន់តែធំ ឱកាសសិក្សាកាន់តែច្រើន។ យើងអាចធ្វើបានតាមរយៈបង្កើតឱ្យមានវេទិកាអនឡាញ ឬបណ្តាញសង្គមនានា។ ប៉ុន្តែយើងក៏អាចធ្វើបានតាមរយៈការជួបទល់មុខគ្នាផ្ទាល់ជាមួយអ្នកផ្សេងៗក្នុងសហគមន៍ផងដែរ។ ឧទាហរណ៍ នៅតាមទីជនបទ គ្រូបង្រៀនអាចឱ្យសិស្សធ្វើការសង្កេត យកព័ត៌មានអំពីយុទ្ធសាស្ត្រគន្លឹះដាំដំណាំពីកសិករចំនួន១០នាក់ក្នុងសហគមន៍។ ការធ្វើបែបនេះ ពួកគេនឹងយល់ថា កាលណាកសិកររនិយាយកាន់តែច្រើន នោះគេក៏នឹងទទួលបាន ពីព័ត៌មានកាន់តែច្រើនដែរ។
- ចាត់តាំងឱ្យសិស្សរៀនពីគ្នាទៅវិញទៅមកក្នុងបណ្តាញ។ ឱ្យពួកគេបង្កើតជាសំណួរទៅមិត្តរួមថ្នាក់ដូចជា តើសៀវភៅអ្វី ដែលខ្ញុំគួរអាននៅពេលបន្ទាប់? ឬតើដំរីស៊ីអ្វី? សំណួរទាំងនេះអាចត្រូវបានសរសេរលើក្រដាសផ្ទាំងធំៗ ឬនៅលើបណ្តាញអនឡាញ។ ពួកគេទាំងអស់នឹងព្យាយាមឆ្លើយសំណួរគ្នាទៅវិញទៅមកឱ្យអស់ពីលទ្ធភាព ដើម្បីបង្ហាញពីផលប្រយោជន៍នៃការធ្វើការនៅក្នុងក្រុម។

<u>ទ្រឹស្តីផ្តោតលើសិស្ស (Subject-Oriented understanding of learning or individual learning)</u> កំណត់ការរៀន ជាដំណើរអភិវឌ្ឍបុគ្គល ផ្អែកលើហេតុផលផ្ទាល់ខ្លួនជាជាងឥទ្ធិពលពីខាងក្រៅ។ សិស្សត្រូវបានចាត់ទុកជាប្រធានបទចម្បងនៅក្នុងការសិក្សា។ ដូច្នេះ ជំនួសឱ្យការរៀនថាជាសកម្មភាពដែលកើតឡើងនៅពេលបង្រៀន ទ្រឹស្តីនេះលើកឡើងថា ការរៀនអាចកើតឡើងបានលុះត្រាតែ អ្នកសិក្សា (សិស្ស) មានហេតុផលត្រូវរៀន។ គ្រូបង្រៀនអាចប្រើវិធីសាស្ត្រគ្រប់បែបយ៉ាង

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ដើម្បីទាក់ទាញសិស្សឱ្យរៀន (ដូចជាប្រើឧបករណ៍ ឬឯកសារជំនួយនានា) ប៉ុន្តែសិស្សត្រូវតែមានការលើកទឹកចិត្តពីក្នុងខ្លួនឯងដោយផ្ទាល់ និងពីសង្គម ដែលពួកគេត្រូវធ្វើទំនាក់ទំនង និងធ្វើការផ្លាស់ប្តូរយោបល់ ពីគ្នាទៅវិញទៅមក(Grottiische, 2019)។ គ្រូបង្រៀនដើរតួជាកម្លាំងគាំទ្រ បង្កើតឱកាសឱ្យសិស្សគ្រប់គ្នាបានវិឌ្ឍន៍ឡើង ផ្តល់ពេលវេលាឱ្យសិស្សបង្កើនភាពជឿជាក់លើខ្លួនឯង និងទទួលបានបទពិសោធពីប្រសិទ្ធភាពខ្លួនឯង។ វាគឺជាទំនួលខុសត្រូវផ្នែកគរុកោសល្យរបស់គ្រូបង្រៀនក្នុងការជួយសម្រួលរកវិធីសាស្ត្ររៀនសូត្រ ដែលជាទីចាប់អារម្មណ៍ដល់សិស្ស ដែលនេះគឺជាមូលដ្ឋានដ៏រឹងមាំធ្វើឱ្យសិស្សយល់កាន់តែច្បាស់ពីពិភពលោកនេះ។ នៅក្នុងថ្នាក់បឋមសិក្សា គ្រូបង្រៀនអាចឈ្វេងយល់ពីមូលហេតុដែលសិស្សមករៀនដោយរួមបញ្ចូលចំណុចលើកទឹកចិត្តសិស្សទៅក្នុងកិច្ចតែងការរបស់ពួកគាត់។ ឧទាហរណ៍ អំពីទ្រឹស្តីផ្តោតលើសិស្ស ដែលប្រើនៅកម្រិតបឋមសិក្សារួមមាន៖

- ភ្ជាប់ទំនាក់ទំនងរវាងសកម្មភាពនៅក្នុងថ្នាក់រៀន ជាមួយស្ថានភាពរស់នៅជាក់ស្តែង។ ឧទាហរណ៍ ដូចជា បង្ហាញពីផលប្រយោជន៍ នៃភាសាអង់គ្លេសក្នុងការទទួលបានឱកាសផ្សេងៗ ដូចជាការទៅដើរលេង ឬទៅរៀននៅក្រៅប្រទេស ឬអាចពន្យល់ពីផលប្រយោជន៍នៃការចេះបូក និងដកលេខដែលអាចជួយក្នុងការទិញទំនិញផ្សេងៗនៅផ្សារជាដើម។
- រៀងរាល់សប្តាហ៍ ត្រូវទុកពេលវេលាឱ្យសិស្សជ្រើសរើសអ្វីដែលពួកគេចង់រៀន និងវិធីរៀន។ ការធ្វើរបៀបនេះអាចជួយសិស្សឱ្យស្វែងរកគោលដៅរបស់ខ្លួន ហើយយល់ថាសាលា មានតួនាទីជួយពួកគេ ដើម្បីសម្រេចគោលដៅ។

ទ្រឹស្តីនៃការរៀននីមួយៗបានផ្តល់ឱ្យគ្រូបង្រៀននូវវិធីសាស្ត្រផ្សេងៗក្នុងការបង្រៀនសិស្ស។ ទ្រឹស្តី អាកប្បកិរិយានិយមត្រូវបានបង្កើតឡើងនៅដើមទសវត្សរ៍ ១៩០០ ហើយទ្រឹស្តីការគិតនិយម ត្រូវបានបង្កើតឡើងនៅចុងទសវត្ស ១៩៥០ ប៉ុន្តែមិនត្រូវបានគេមើលឃើញថាជាទ្រឹស្តីគ្រឹះសម្រាប់សតវត្សទី២១ទេ។ ដូចបានលើកឡើងខាងលើ គោលការណ៍នៅក្នុងទ្រឹស្តីនៃការរៀនទាំងនេះមានប្រយោជន៍ណាស់ ប៉ុន្តែមិនត្រូវបានគេប្រើជាចម្បងឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងសតវត្សទី ២១នេះ ដំណើរការរៀននៅក្នុងវិស័យអប់រំនាពេលបច្ចុប្បន្នជាការរួមបញ្ចូលគ្នានៃសមាសភាពនានា ដូចជាចំណេះដឹងដែលមាននៅក្នុងបរិបទនីមួយៗ មនុស្សជុំវិញ និងការសហការគ្នា។ ហេតុនេះទ្រឹស្តីអប់រំរបបស្ថាបនានិយម ទ្រឹស្តីផ្សារភ្ជាប់និយម និងទ្រឹស្តីផ្តោតលើសិស្សត្រូវបានចាត់ទុកថាជាទ្រឹស្តីដ៏ចាំបាច់នៅក្នុងការអប់រំ ដោយទ្រឹស្តីទាំងនេះមានភាពស្របគ្នាទៅនឹង វិធីសាស្ត្របង្រៀននាពេលបច្ចុប្បន្នដែល

ផ្តោតទៅលើតម្រូវការរបស់សិស្ស (មានដូចជាការធ្វើការជាមួយមិត្តភក្តិ ការរៀនបែបសិស្សមជ្ឈមណ្ឌល និងការប្រើបច្ចេកវិទ្យានៅក្នុងថ្នាក់) ហើយនឹងផ្តោតទៅលើសង្គមបច្ចុប្បន្ន (ដូចជាការបញ្ចូលជំនាញការគិតឱ្យបានស៊ីជម្រៅ ជំនាញដោះស្រាយបញ្ហា និងការចេះច្នៃប្រឌិតជាដើម) (Ertmer & Newby,2013)។

តារាងលេខ១ខាងក្រោមជាសេចក្តីសង្ខេបរបស់ទ្រឹស្តីទាំង៥ ខាងលើ៖

តារាង១៖ ទ្រឹស្តីការរៀន

	តួនាទីសិស្ស	តួនាទីគ្រូបង្រៀន
ទ្រឹស្តីអាកប្បកិរិយានិយម	សិស្សរៀនតាមរយៈការជំរុញពីគ្រូបង្រៀន ទាំងមតិណែនាំទាំងវិជ្ជមាន និងអវិជ្ជមាន ទៅលើអ្វីដែលពួកគេបានធ្វើទោះត្រូវ ឬខុស។	គ្រូបង្រៀនជាអ្នកផ្តួចផ្តើមដោយការជំរុញទឹកចិត្តសិស្សតាមរយៈការសរសើរ ឬ ការផ្តល់រង្វាន់។ គ្រូបង្រៀនជាអ្នកគ្រប់គ្រងការរៀន។
ទ្រឹស្តីការគិតនិយម	សិស្សចូលរួមយ៉ាងសកម្មនៅក្នុងការរៀន សូត្រដោយត្រូវដោះស្រាយបញ្ហា លើកិច្ចការដែលគ្រូដាក់ឱ្យដោយប្រើយុទ្ធសាស្ត្ររៀនដ៏ត្រឹមត្រូវ។ សិស្សបង្កើតយុទ្ធសាស្ត្រដោះស្រាយបញ្ហាដោយខ្លួនឯង ជ្រើសរើសវិធីណាដែលត្រឹមត្រូវប្រើយុទ្ធសាស្ត្រនោះទៅលើបញ្ហាចំគោលដៅ វាយតម្លៃលទ្ធផល និងឆ្លុះបញ្ចាំងទៅលើដំណើរការរៀន។	គ្រូបង្រៀនដើរតួនាទីជាអ្នកបង្វឹកដោយផ្តួចផ្តើមគ្រប់គ្រង និងគាំទ្រដំណើរការរៀនសូត្រនេះដោយបានត្រៀមជាមុននូវសម្ភារៈសិក្សាផ្សេងៗ ហើយផ្តល់នូវមតិយោបល់ត្រលប់ទៅវិញដល់សិស្សជាបន្តបន្ទាប់។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ទ្រឹស្តីស្ថាបនានិយម	សិស្សរៀនពីចំណេះដឹងថ្មីៗ ដោយផ្អែកលើ បទពិសោធពីមុន។ ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ សិស្សអាចទទួលបានចំណេះដឹងថ្មីៗ តាមរយៈចំណេះដឹងដែលមានស្រាប់។	គ្រូបង្រៀនមិនបានផ្តល់ឱ្យសិស្សនូវចំណេះដឹងថ្មីៗដោយផ្ទាល់ទេ ប៉ុន្តែបានផ្តល់ឱកាសឱ្យសិស្សឈ្វេងយល់ពីចំណេះដឹងនោះដោយខ្លួនឯង។ គ្រូគ្រាន់តែជាដៃគូរៀនដោយបង្កើតលក្ខខណ្ឌឱ្យសិស្សរៀនដោយខ្លួនឯង។ ការធ្វើបែបនេះជួយជំរុញឱ្យសិស្សយល់ដឹងការអភិវឌ្ឍចំណេះដឹងថ្មីៗដោយឯករាជ្យ។
ទ្រឹស្តីផ្សារភ្ជាប់និយម	សិស្សពង្រឹងការរៀនសូត្រតាមរយៈការបង្កើតក្រុមដើម្បីទទួលបានព័ត៌មាន និងបទពិសោធពីគ្នាទៅវិញទៅមក។	គ្រូបង្រៀនមានតួនាទីជាអ្នកដឹកនាំដែលជួយសិស្សអាចកសាងចំណេះដឹងពីបទពិសោធតាម រយៈការផ្លាស់ប្តូរយោបល់ធ្វើការសហការគ្នា និងបង្កើតទំនាក់ទំនងជានិច្ច។
ទ្រឹស្តីផ្តោតលើសិស្ស	សិស្សរៀនតាមរយៈការលើកទឹកចិត្ត ដោយខ្លួនឯង ដោយយោងទៅលើកត្តាជំរុញទឹកចិត្តពីក្នុងខ្លួនឯង។	គ្រូបង្រៀនជួយជំរុញសិស្សឱ្យរៀនកាន់តែប្រសើរ ដោយការបញ្ចូលការលើកទឹកចិត្តពីខាងក្នុងទៅក្នុងការធ្វើផែនការបង្រៀន។

២- យុទ្ធសាស្ត្របង្រៀនដែលមានប្រសិទ្ធភាព

ការយល់ដឹងពីទ្រឹស្តីនៃការរៀន និងការបង្កើតបាននូវទស្សនៈអប់រំដ៏ល្អៗ នឹងជួយគ្រូបង្រៀនឱ្យអាចជ្រើសរើសវិធីបង្រៀនសមស្រប ទៅតាមវត្ថុបំណងដែលចង់បាន។ ចំណុចមួយដែលទាក់ទងទៅនឹងប្រសិទ្ធភាពនៃការបង្រៀនគឺ ចំនួន និងភាពចម្រុះគ្នានៃបច្ចេកទេសបង្រៀន ដែលគ្រូបង្រៀនបានយកមកប្រើ។ ការអប់រំនាពេលបច្ចុប្បន្នគឺ មានគោលដៅក្នុងការបណ្តុះការគិតប្រកបដោយហេតុផលដល់សិស្ស។ ទោះបីជាមានការស្រាវជ្រាវជាច្រើន ត្រូវបានធ្វើឡើងទាក់ទងនឹងយុទ្ធសាស្ត្របង្រៀន ដែលអាចប្រើបានជាសកល។ ប៉ុន្តែមិនមានយុទ្ធសាស្ត្រណាមួយដែលគេរកឃើញថា អាចនាំទៅសម្រេចលទ្ធផលជោគជ័យឥតខ្ចោះនោះទេ ផ្ទុយទៅវិញការស្រាវជ្រាវទាំងនោះបង្ហាញពីបច្ចេកទេសបង្រៀនជាច្រើនរបៀបផ្សេងគ្នា ដែលស្របទៅនឹងតម្រូវការសិស្ស ហើយលទ្ធផលសិក្សារបស់សិស្សហាក់ឈានទៅរកកម្រិតប្រសើរឡើង(ku el al,2014)។ លទ្ធផលទាំងនោះគឺល្អសម្រាប់តែបរិបទមួយៗប៉ុណ្ណោះ។ គោលដៅ ដើម្បីឈានទៅទទួលបានលទ្ធផល ដូចគ្នា នៅក្នុងគ្រប់បរិបទនៃការបង្រៀន(Stronge, 2018)។ ដោយហេតុថាវាគ្មានយុទ្ធសាស្ត្រជាក់លាក់ណាមួយ ដែលអាចនាំមកនូវលទ្ធផលល្អបំផុតដល់សិស្សនោះទេ ទើបភាពបត់បែនតាម កាលៈទេសៈនៅក្នុងការបង្រៀនគឺជាការចាំបាច់។ វាពិតជាគ្រោះថ្នាក់សម្រាប់សិស្ស ប្រសិនបើគ្រូប្រើគរុកោសល្យតែមួយប្រភេទ គ្រប់ពេលវេលា (Hoff, 2003, 8)។

មានយុទ្ធសាស្ត្របង្រៀនសំខាន់ៗចំនួន៥ និងភាពទំនាក់ទំនងគ្នារវាងយុទ្ធសាស្ត្រទាំងនោះ នឹងត្រូវលើកយកមកពិភាក្សាដូចខាងក្រោម៖

២.១- ការបង្រៀនដោយផ្ទាល់

នៅក្នុងការយុទ្ធសាស្ត្រនៃការបង្រៀនដោយផ្ទាល់ គ្រប់សកម្មភាព និងការកិច្ចនានាត្រូវ បានរៀបចំចាត់ចែងយ៉ាងល្អដោយគ្រូបង្រៀន (ដែលអាចហៅថា ជាអ្នកផ្តល់ព័ត៌មាន) ដោយមានបង្ហាញគោលបំណងមេរៀន ច្បាស់លាស់ និងជាប្រព័ន្ធ ការបង្រៀនបែបនេះគឺជាការបង្រៀនបែប**គ្រូមជ្ឈមណ្ឌល** ដែលរួមមានវិធីសាស្ត្រផ្សេងៗគ្នាដូចជា៖

គ្រូមជ្ឈមណ្ឌល សំដៅលើលំនាំបង្រៀនដែលគ្រូបង្រៀនជាអ្នកគ្រប់គ្រងសកម្មភាពរៀនរបស់សិស្ស ខណៈដែលសិស្សជាអ្នកទទួលដោយអសកម្ម ស្តាប់តាម

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- **ការធ្វើបទឧទ្ទេស៖** ជាការបង្រៀនតែមួយទិសពីគ្រូទៅសិស្ស តាមរយៈការធ្វើបទបង្ហាញលើប្រធានបទអ្វីមួយ
- **ការបង្រៀនលម្អិត៖** គឺជាការពន្យល់ និងការពណ៌នាលម្អិតអំពីប្រធានបទអ្វីមួយ ដោយលើកឧទាហរណ៍ច្បាស់លាស់ ដើម្បីជួយសិស្សឱ្យយល់ច្បាស់ពាក់ព័ន្ធនឹងប្រធានបទនោះ។
- **ការសួរសំណួរបែបយុទ្ធសាស្ត្រ៖** គឺជាវិធីដែលជជីកសួរសំណួរផ្សេងៗឱ្យសិស្សឆ្លើយ ដោយប្រើសំណួរដូចជាតើអ្នកណា? តើអ្វី? តើនៅទីណា? តើហេតុអ្វី? តើនៅពេលណា? និង តើដោយរបៀបណា? (5W+1H)
- **ការបង្រៀនបង្ហាញ៖** គ្រូបង្រៀនធ្វើបទបង្ហាញដល់សិស្ស នូវបំណិនណាមួយ ដូចជាបង្ហាញពីរបៀបធ្វើលេខបូកជាដំហានៗនៅលើក្តារខៀន
- **ការហ្វឹកហ្វាត់ និងការអនុវត្ត៖** សិស្សអនុវត្តលើប្រធានបទណាមួយ ឬបំណិនអ្វីមួយដដែលៗដែលទើបតែរៀនរួចដោយខ្លួនឯង (Johnson et al. 2016) ការបង្រៀនប្រភេទនេះច្រើនតែទាក់ទងទៅនឹងការបង្រៀននៅក្នុងថ្នាក់រៀនដែលមានសិស្សអសកម្មច្រើន។ អ្នកអប់រំជាច្រើនចាត់ទុកថា ការបង្រៀនប្រភេទនេះគ្មានប្រសិទ្ធភាពសម្រាប់តម្រូវការរៀននាពេលបច្ចុប្បន្នទេ។ ទោះបីជាយ៉ាងណាក៏ដោយ ការបង្រៀនដោយផ្ទាល់នេះមានផលអវិជ្ជមានជាច្រើនប្រសិនបើគ្រូមិនប្រើវិធីផ្សេងទៀតទេនោះ(Lombardi,2017)។ នៅក្នុងថ្នាក់បឋមសិក្សា ការបង្រៀនដោយផ្ទាល់ នេះគឺ សក្តិសមបំផុត ដើម្បីការពន្យល់គំនិតគោលសំខាន់ៗ មុនពេលឱ្យសិស្សចាប់ផ្តើមធ្វើកិច្ចការជាក្រុម ឬជាបុគ្គល។

តែអ្នកគ្រូបង្រៀន (Lombardi, 2017, online)

២.២- ការបង្រៀនមិនផ្ទាល់

នៅក្នុងការបង្រៀនមិនផ្ទាល់ សិស្សមានភាពទទួលខុសត្រូវខ្ពស់ក្នុងការសម្រេចចិត្ត ពីរបៀបរៀបចំ និងបញ្ចប់កិច្ចការអ្វីមួយដោយគ្មានការបង្រៀនណែនាំលើគ្រូបង្រៀនផ្ទាល់ឡើយ។ ទម្រង់បង្រៀន បែបនេះ គឺបែប**សិស្សមជ្ឈមណ្ឌល** ដោយហេតុថាវាបានលើកកម្ពស់ឱ្យសិស្សមានការ ចូលរួមបានច្រើន ហើយតួនាទីរបស់គ្រូគឺជាអ្នកសម្របសម្រួល។ យុទ្ធសាស្ត្រនៅក្នុងការបង្រៀនមិនផ្ទាល់រួមមាន៖

- **ការរិះរក៖** សិស្សបង្កើតសំណួរដើម្បីស្រាវជ្រាវលើប្រធានបទអ្វីមួយ
- **ការដោះស្រាយបញ្ហា៖** បញ្ហាជាក់លាក់នៅក្នុងជីវិតពិត ត្រូវបានលើកឡើងសម្រាប់សិស្ស ដើម្បីរកដំណោះស្រាយសមស្រប។

សិស្សមជ្ឈមណ្ឌល សំដៅលើទម្រង់នៃការបង្រៀនដែល [...] ផ្តល់ឱកាសឱ្យសិស្សដឹកនាំសកម្មភាពរៀន [...] ហើយជាទូទៅសិស្សជាអ្នកធ្វើផែនការសិក្សាដោយខ្លួនឯងផ្ទាល់

(The Glossary of Education Reform, 2014, online)

- **ករណីសិក្សា៖** សេណារីយ៉ូនៅក្នុងជីវិតពិតទាក់ទងទៅនឹងសិស្ស ត្រូវបានប្រើដើម្បីពិភាក្សា និងបំផុសរកដំណោះស្រាយបាន។
- **ការបង្កើតបញ្ញត្តិ៖** សិស្សបង្កើតគំនិតថ្មីៗដោយរៀបចំ និងប្រើប្រាស់ព័ត៌មានដោយប្រើវិធីថ្មីៗ។

នៅក្នុងថ្នាក់បឋមសិក្សា ការបង្រៀនមិនផ្តាល់នេះ បានបណ្តុះគំនិតចង់ចេះចង់ដឹងពីធម្មជាតិដល់សិស្ស ដោយលើកទឹកចិត្តឱ្យពួកគេស្វែងរកលទ្ធភាពផ្សេងៗ ព្យាយាមលុបបំបាត់នូវភាពភ័យខ្លាចក្នុងការ ផ្តល់ចម្លើយមិនត្រឹមត្រូវ។ យុទ្ធសាស្ត្រនេះអាចប្រើបាននៅគ្រប់មេរៀន ប៉ុន្តែវាមានប្រសិទ្ធភាព លុះត្រាតែសិស្សយល់គំនិតសំខាន់នៃមេរៀនជាមុនសិន (Regina, 1991)។

២.៣- ការបង្រៀនតាមរយៈបទពិសោធ

ការរៀនតាមរយៈបទពិសោធគឺចង់សំដៅថា សិស្សរៀនដោយទទួលលទ្ធផលល្អបាននៅពេល ដែលពួកគេត្រូវបានផ្សារភ្ជាប់យ៉ាងជិតស្និតទៅនឹងឧបករណ៍ ឬចំណេះដឹងដែលត្រូវរៀន ឬអាចនិយាយបានថាសិស្សយល់បានកាន់តែល្អប្រសើរនៅពេលដែលពួកគេទទួលបទពិសោធផ្ទាល់ជាជាងគ្រាន់តែបានអាន បានស្តាប់ ឬបាននិយាយអំពីចំណេះដឹង ឬមេរៀនថ្មីនោះ (Johnson etal.,2016)។ ឧទាហរណ៍បន្ទាប់ពីបញ្ចប់មេរៀនអំពីរុក្ខជាតិ និងការថែសួន គ្រូប្រាប់សិស្សថាពួកគេនឹងត្រូវបង្កើតសួនច្បារនៅក្នុងសាលា ហើយគ្រូអាចណែនាំដោយប្រាប់ពីដំណើរការនៃការរៀបចំគម្រោង ដោយចាប់ផ្តើមដាំ និងការថែទាំជាក្រុម។ ការរៀនតាមរយៈបទពិសោធគឺជាការរៀនបែបសិស្សមជ្ឈមណ្ឌល និងតាមបែបធ្វើសកម្មភាព។ វិធីសាស្ត្របង្រៀនសម្រាប់ការរៀនតាមរយៈបទពិសោធរួមមាន៖

- **ការអនុវត្តសាកល្បង៖** សិស្សត្រូវបានផ្តល់នូវស្ថានការណ៍ ឬបញ្ហាដែលគេ ប្រឌិតឡើងដោយផ្អែកលើស្ថានភាពពិតនៅក្នុងបរិបទណាមួយ រួចដាក់ឱ្យអនុវត្តដាក់ស្តែង និងលើកទឹកចិត្តឱ្យសិស្សមានទំនាក់ទំនងគ្នា បង្កើនការគិតបែបស៊ីជម្រៅ។
- **រូបភាពផ្តោតអារម្មណ៍៖** សិស្សតម្រូវឱ្យមើលរូបភាព ព្រឹត្តការណ៍ ឬហេតុការណ៍អ្វីមួយ ដើម្បីជំរុញទឹកចិត្តឱ្យសិស្សបញ្ចេញយោបល់ ចេះច្នៃប្រឌិត និងចេះស្រមើស្រមៃ។

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

- **គំរូ៖** សិស្សសាងសង់គំរូអ្វីមួយ ដោយផ្អែកលើខ្លឹមសារពិតណាមួយ (ដូចជាសាងសង់ស្ពាន សង់ទីក្រុងតូចមួយ ឡានប្រណាំង ឬនាវ៉ាកែត)។
- **ល្បែងសិក្សា៖** សិស្សលេងល្បែងសិក្សា ដើម្បីយល់ខ្លឹមសារមេរៀន ទាក់ទងនឹងបញ្ញត្តិ និងទំនាក់ទំនងអន្តរបុគ្គល (ឧទាហរណ៍ ល្បែងលើក្តារឆ្នួន ល្បែងអនឡាញ និងល្បែងរៀបរូប។ល។
- **ដំណើរចុះកម្មសិក្សា៖** គ្រូបង្រៀនរៀបចំកម្មវិធីធ្វើដំណើរទៅឆ្ងាយពីបរិស្ថានសិក្សារាល់ថ្ងៃ ដើម្បីដកបទពិសោធការសិក្សានៅខាងក្រៅដោយផ្ទាល់។
- **ការធ្វើពិសោធ៖** សិស្សធ្វើការជាក្រុមទៅលើសំណួរគន្លឹះ ដើម្បីអង្កេត និងប្រមូលយកព័ត៌មាន។ ការធ្វើពិសោធ អាចត្រូវបានប្រើដើម្បីបំផុសគំនិតថ្មី ឬប្រឆាំងបទដែលបានរៀនរួចហើយ (Beard & Wilson,2018; Regina,1991)។

ការបង្រៀនតាមរយៈបទពិសោធអាចត្រូវបានប្រើនៅក្នុងថ្នាក់បឋមសិក្សា ដើម្បីលើកទឹកចិត្តសិស្សតាមរយៈការចូលរួមយ៉ាងសកម្ម។ ធ្វើដូច្នេះគ្រូអាចលើកកម្ពស់ការយល់ដឹងរបស់សិស្ស លើសពីអ្វីដែលពួកគេគ្រាន់តែបានស្តាប់ ឬអាន។ ផលលំបាកនៃការប្រើប្រាស់វិធីសិក្សាបែបនេះមានដូចជា កង្វះពេលវេលា និងធនធានដូច្នេះហើយជាធម្មតា វាមិនឆ្លើយតបទៅនឹងគ្រប់មេរៀននៅក្នុងគ្រប់ស្ថានការណ៍ទាំងអស់នោះទេ។ ទោះបីជាយ៉ាងណា វាផ្តល់ផលប្រយោជន៍ច្រើន បើយើងព្យាយាមបញ្ចូលយុទ្ធសាស្ត្រនេះក្នុងការបង្រៀន(Regina,1991,16)។

២.៤- ការបង្រៀនតាមបែបអន្តរកម្ម

នៅក្នុងការបង្រៀនប្រភេទនេះសិស្សរៀនពីមិត្តភក្តិផងពីគ្រូផង តាមរយៈការពិភាក្សា និងការចែករំលែក។ ប្រភេទនៃការទំនាក់ទំនងផ្សេងៗគ្នានៅក្នុងចំណោមសិស្សទាំងអស់ត្រូវប្រើ ដើម្បីជំរុញដល់ការគិតបែបសុីជម្រៅដល់ការវិឌ្ឍផ្នែកទំនាក់ទំនងសង្គម និងការរៀបចំគំនិតផ្សេងៗ។ ការបង្រៀនរបៀបនេះពឹងផ្អែកយ៉ាងខ្លាំងទៅលើ**ការរៀនបែបសហការ** និង**ការរៀនបែបទំនាក់ទំនង** ដែលផ្តោតការយកចិត្តទុកដាក់ទៅលើការទំនាក់ទំនងក្នុងសង្គម ការសហការ និងសហគមន៍។ គ្រូបង្រៀនគួរជំរុញសិស្សឱ្យចែករំលែកគំនិត និងចំណង់ចំណូលចិត្ត ដើម្បីជាស្ពានក្នុងការ កសាងទំនាក់ទំនងរវាងគ្នានឹងគ្នា និងទទួលបានចំណេះដឹងទាំងអស់គ្នា (Serrat, 2017)។ វិធីសាស្ត្របង្រៀនបែបអន្តរកម្ម រួមមាន៖

- **ការតស៊ូមតិ៖** សិស្សប្រកាន់យកចំណុចណាមួយជាគោល ដើម្បីជជែកលម្អិត

ការរៀនតាមបែបសហការ
ការរៀបបែបសហការត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយថាជាការអនុវត្តគរុកោសល្យដែលលើកកម្ពស់ដល់ទំនាក់ទំនងសង្គមនិងការរៀនតាមរយៈការឱ្យសិស្សធ្វើការជារួមដើម្បីសម្រេចគោលដៅរួមឬបញ្ចប់កិច្ចការជាក្រុមគោលដៅ និងកិច្ចការដែលពួកគេមិនអាចធ្វើបានដោយខ្លួនឯងតែម្នាក់ (Gillies, 2016, p. 39)

- **ការពិភាក្សា៖** សិស្សជជែកគ្នាជាក្រុម ឬជាថ្នាក់ទាំងមូលដើម្បីបង្កើត និងចែករំលែកគំនិតទៅលើប្រធានបទអ្វីមួយ។ "ការពិភាក្សាអាចត្រូវបានធ្វើសេចក្តីសន្និដ្ឋានរួមដោយការព្រមព្រៀងគ្នា ដោយដំណោះស្រាយណាមួយ ដោយការបញ្ជាក់ពីចំណេះដឹងដែលបានទទួល ឬ ដោយសេចក្តីសង្ខេប (ជាធម្មតាផ្តល់ដោយសិស្ស)" (Gupta, 2017, 167)
- **ការដោះស្រាយបញ្ហា៖** បញ្ហាក្នុងជីវិតពិតត្រូវបានបង្ហាញដល់សិស្ស ដើម្បីឱ្យពួកគេរកវិធីសាស្ត្រដោះស្រាយ (ឧទាហរណ៍៖ ដូចជាស្វែងយល់ពីបញ្ហាបង្ហាញពីដំណោះស្រាយសមស្រប ហើយវាយតម្លៃទៅលើជម្រើសនៃដំណោះស្រាយសមស្របណាមួយ)
- **ការបំផុសគំនិត៖** សិស្សធ្វើការជាក្រុមដើម្បីបង្កើតគំនិត
- **ការសិក្សាពីមិត្តភក្តិ៖** សិស្សបង្រៀនគ្នាទៅវិញទៅមក ឬជួយគ្នាឱ្យទទួលបានចំណេះដឹងដោយការអនុវត្តរួមគ្នា។ ប្រើវិធីសាស្ត្រ "គិត-ធ្វើការជាមួយដៃគូ-ចែករំលែក Think-Pair-Share" ដើម្បីជំរុញឱ្យសិស្សមានទំនាក់ទំនងគ្នា និងចេះរក្សាព័ត៌មានថ្មីៗ ទុក។
- **ការផ្តល់មតិត្រលប់៖** សិស្សផ្តល់គំនិតយោបល់ទៅកាន់មេរៀនមួយ(ជាលក្ខណៈផ្ទាល់ខ្លួន ឬ ជាក្រុម) ដើម្បីអភិវឌ្ឍជំនាញនៃការគិតឱ្យមានហេតុផល និងវិភាគឱ្យបានស៊ីជម្រៅពីអ្វីដែលពួកគេបានរៀន។ (Johnson et al., 2016, Regina, 1991) នៅក្នុងថ្នាក់បឋមសិក្សា ការបង្រៀនតាមបែបអន្តរកម្មគឺនិយមអនុវត្តដើម្បីជួយសិស្សឱ្យមានជំនាញទំនាក់ទំនងចេះពិភាក្សា និងបង្កើតភាពជឿជាក់។

២.៥- ស្វ័យសិក្សា

ការបង្រៀនប្រភេទនេះ និយាយអំពីសកម្មភាពអប់រំទាំងឡាយណាដែលផ្តល់ដោយគ្រូបង្រៀនក្នុងការបង្កើតឱ្យសិស្សម្នាក់ៗមានគំនិត ដោយពួកគេត្រូវការណែនាំបន្តិចបន្តួច ឬក៏គ្មានការត្រួតពិនិត្យទាល់តែសោះ។ វិធីសាស្ត្របង្រៀនស្វ័យសិក្សាមានដូចខាងក្រោម៖

- **ការដាក់ការងារឱ្យធ្វើ៖** សិស្សធ្វើការងារដែលគ្រូផ្តល់ឱ្យ ដោយគ្មានការត្រួត ពិនិត្យផ្ទាល់ពីគ្រូ។
- **គម្រោងស្រាវជ្រាវ៖** សិស្សស្រាវជ្រាវលើប្រធានបទ ផ្សេងៗដែលគេអាចធ្វើបាន (នៅផ្ទះ នៅសាលា នៅបណ្ណាល័យ) ហើយធ្វើបទបង្ហាញពីការរកឃើញរបស់

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ពួកគេតាមរយៈសេចក្តីរាយការណ៍ ការធ្វើបទបង្ហាញ ការធ្វើជារូបភាពបង្ហាញ ឬ វិធីសាស្ត្រប្រកបដោយភាពច្នៃប្រឌិត ផ្សេងៗទៀត។

- **ការបង្រៀនដោយប្រើប្រាស់កុំព្យូទ័រៈ** សិស្សធ្វើស្វ័យសិក្សាតាមរយៈកុំព្យូទ័រ (E-Learning) (Johnson et al., 2016)។

ការប្រើប្រាស់វិធីសាស្ត្រស្វ័យសិក្សានៅបឋមសិក្សាពិតជាមានសារៈសំខាន់យ៉ាងខ្លាំងពីព្រោះវាជួយឱ្យសិស្សក្លាយជាអ្នកស្វ័យសិក្សាមួយរូប ទាំងក្នុង និងក្រៅសាលា។ ក្នុងខណៈពេលដែលគ្រូគ្រាន់តែជួយបន្តិចបន្តួចនៅក្នុងការសិក្សា គ្រូត្រូវប្រាកដថាសិស្សយល់ពីចំណេះដឹង និងដំណើរការសិក្សាទាំងឡាយ ដែលពាក់ព័ន្ធទៅនឹងវិធីសាស្ត្រទាំងអស់នេះជាមុនសិន។ គ្រូបង្រៀនទាំងឡាយណាដែលមានបំណងចង់ឱ្យសិស្សរបស់ខ្លួនក្លាយទៅជាអ្នកសិក្សាដោយឯករាជ្យ គ្រូត្រូវគាំទ្រនូវការអភិវឌ្ឍនូវសមត្ថភាពរបស់សិស្សទាំងអស់នោះ ដោយផ្តល់ឱ្យពួកគេនូវមធ្យោបាយសិក្សាឱ្យបានគ្រប់គ្រាន់ (Reginal, 1991)។

៣- ប្រភេទថ្នាក់រៀនផ្សេងៗ

ដើម្បីជ្រើសរើសយកយុទ្ធសាស្ត្របង្រៀនដែលប្រកបដោយប្រសិទ្ធភាព គ្រូត្រូវពិនិត្យមើលសិស្សនៅក្នុងថ្នាក់ និងប្រវត្តិរៀនរបស់សិស្សនៅក្នុងថ្នាក់។ យុទ្ធសាស្ត្រផ្សេងៗពីគ្នាត្រូវបានយកមកប្រើអាស្រ័យទៅលើទំហំថ្នាក់រៀន ចំនួនសិស្ស និងសមាសភាពទូទៅនៃថ្នាក់រៀននីមួយៗ។

៣.១- ការបង្រៀនថ្នាក់ដែលមានសិស្សច្រើន

[1]

[1] Picture source: Open source from pixabay.com

ថ្នាក់រៀនដែលមានសិស្សច្រើនជាង៣០ ទៅ៤០នាក់ចាត់ទុកថាជាថ្នាក់ធំ។ គ្រូច្រើនតែជ្រើសរើសយុទ្ធសាស្ត្របង្រៀនតាមបែបបុរាណ ទៅលើថ្នាក់ណាដែលមានសិស្សច្រើន ក៏ប៉ុន្តែការបង្រៀនតាមបែបគ្រូមជ្ឈមណ្ឌលមិនបានធ្វើឱ្យមានការចូលរួមយ៉ាងសកម្មពីសិស្សនោះទេ តែថែមទាំងជះឥទ្ធិពលមិនល្អក្នុងដំណើរការនៃការសិក្សាផងដែរ។ មិនតែប៉ុណ្ណោះវាថែមទាំងរារាំងគ្រូមិនឱ្យដឹងនូវអ្វី ដែលសិស្សចេះ ហើយនឹងយល់ថាតើត្រូវជួយសិស្សតាមរបៀបណា។ លើសពីនេះទៀតវាក៏ជះឥទ្ធិពលមិនល្អដល់សក្តានុពលសង្គមនៅក្នុងថ្នាក់រៀនដែរ។ វាក៏អាចមានឥទ្ធិពលដល់កម្រិតបរិយាបន្ននៅក្នុងថ្នាក់រៀនផងដែរ។ នៅពេលដែលមានសិស្សច្រើននៅក្នុងថ្នាក់គ្រូមានការពិបាកក្នុងការបង្រៀន និងផ្តល់គ្រប់តម្រូវការសម្រាប់សិស្សគ្រប់រូប (UNESCO/Booklet Three,2015)។ ជាទូទៅ នៅប្រទេសក្រីក្រច្រើនតែមានថ្នាក់ដែលមានសិស្សច្រើន ទោះជាយ៉ាងណា ទំហំនៃថ្នាក់រៀនមិនមែនជាឧបសគ្គក្នុងការបង្រៀនឱ្យមានតម្លាភាព ឬដំណើរការរៀនដោយដោគជ័យនោះទេ។ ការរៀនបានលទ្ធផលល្អគឺ វាស្ថិតនៅលើយុទ្ធសាស្ត្ររបស់គ្រូបង្រៀនថាតើគាត់យល់ថាទំហំនៃថ្នាក់រៀនគឺជាឧបសគ្គ ដែរឬទេ (UNESCO/Booklet Three,2015)។

ក្រៅពីការបង្រៀនដោយផ្ទាល់ ដែលគ្រូត្រូវចំណាយកម្លាំងច្រើន ហើយសិស្សមិនសូវចូលចិត្តនោះ នៅមានការបង្រៀនបែបអន្តរកម្មដែលបញ្ចូលឱ្យមានការធ្វើការជាក្រុម ដែលអាចធ្វើទៅបានសម្រាប់ថ្នាក់រៀន ដែលមានសិស្សច្រើនដូចជាវិធី "Think – Pair - Shares" ជាដើម។ ការអនុវត្ត "Think-Pair-Shares" គឺជាការបូកបញ្ចូលគំនិតផ្ទាល់ខ្លួន និងគំនិតដៃគូ។ គ្រូអាចផ្តល់ប្រធានបទ ឬលំហាត់មួយទៅសិស្សបន្ទាប់មកសិស្សត្រូវគិត ឬសរសេរដោយខ្លួនឯង មុនពេលត្រូវឱ្យចាប់ដៃគូពិភាក្សា។ វិធីនេះនឹងជួយសិស្សឱ្យចេះទំនាក់ទំនងជាមួយអ្នកដទៃ ក៏ដូចជាជួយសិស្សដែលមានការលំបាក ក្នុងការពិភាក្សាជាមួយគេឱ្យអាចសម្របនឹងបរិយាកាសពិភាក្សាជាក្រុមធំ (sanger, 2001)។

សម្រាប់ថ្នាក់សិស្សច្រើនវាពិតជាចាំបាច់ណាស់ ដែលត្រូវលើកទឹកចិត្តឱ្យសិស្សធ្វើតាំងពីកិច្ចការតូចតាចទៅ ជាពិសេសនៅពេលដែលពួកគេមានអារម្មណ៍ថាកំពុងស្ថិតនៅក្នុងបរិបទនៃថ្នាក់រៀនថ្មី ឬប្លែក។ វាជាការចាំបាច់ណាស់ដែលគ្រូត្រូវផ្តល់មតិណែនាំវិជ្ជមានដល់សិស្ស ហើយក៏ត្រូវស្តាប់ព័ត៌មានត្រលប់ពីសិស្សមកវិញដែរ។ សម្រាប់ថ្នាក់ដែលមានសិស្សច្រើន ការស្នង់មតិដើម្បីដឹងពីមតិត្រលប់ពីសិស្សវិញវាជាការល្អ។ គ្រូអាចធ្វើការស្នង់មតិពីសិស្សនៅដើមឆ្នាំសិក្សា ដើម្បីឱ្យបានដឹងពីការរំពឹងទុកនៅក្នុងថ្នាក់នេះ(Sanger, 2001)។

ការរៀនបែបទំនាក់ទំនង

បង្ហាញថាមនុស្សគឺជាបុគ្គលដែលចូលចិត្តស្វែងយល់ពីសង្គម ហើយរៀនតាមរយៈការទំនាក់-ទំនងជាមួយអ្នកដទៃនៅក្នុងសង្គម។ ការរៀនសូត្រមិនអាចកើតឡើងបាននៅក្នុងចិត្តរបស់មនុស្សទេ ការរៀនស្ថិតនៅក្នុងបរិបទដែលការចូលរួមរបស់សិស្សនៅក្នុងសហគមន៍មានភាពចាំបាច់ (Ataizi, 2012, online)

សកម្មភាពនៅក្នុងវិធីសាស្ត្រ "Think, Pair, Share" ជាដំបូងគឺស្នើឱ្យសិស្សគិតលើ សំណួរណាមួយដោយខ្លួនឯង បន្ទាប់មកត្រូវពិភាក្សាជាមួយដៃគូណាម្នាក់ ហើយចុងក្រោយបញ្ចប់ដោយការពិភាក្សាជារួមក្នុងថ្នាក់ទាំងមូល។ សកម្មភាពនេះដំណើរការដោយល្អ

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ជាទូទៅ ការភ្ជាប់ទំនាក់ទំនងជាប្រចាំជាមួយសិស្សគឺចាំបាច់ណាស់។ ប៉ុន្តែវាមានការលំបាកសម្រាប់ថ្នាក់រៀនដែលមានសិស្សច្រើន។ គ្រូអាចជាក់កាលវិភាគជួបសិស្សតាមក្រុម ដែលការធ្វើបែបនេះ អាចជាជម្រើសមួយសម្រាប់សិស្ស និងគ្រូមានទំនាក់ទំនងគ្នា (Sanger, 2001)។

៣.២- ការបង្រៀនថ្នាក់ដែលមានសិស្សតិច

នៅក្នុងការបង្រៀនថ្នាក់ដែលមានសិស្សតិច គ្រូអាចប្រើវិធីសាស្ត្របង្រៀនបែបអន្តរកម្មច្រើនប្រភេទ។ យោងទៅលើទំហំថ្នាក់រៀន និងតម្រូវការរបស់សិស្ស អ្នកអប់រំអាចសម្រេច ថាតើសិស្សត្រូវធ្វើការជាដៃគូរ ជាក្រុម ជាក្រុមតូច ឬក្រុមធំ។ វិធីសាស្ត្របង្រៀនថ្នាក់ដែលមានសិស្សតិចមានដូចខាងក្រោម ៖

[1]

- **សកម្មភាពជីកស (Jigsaw) ៖** សិស្សត្រូវធ្វើការជាក្រុមតូចៗហើយក្រុមនីមួយៗមានកិច្ចការរៀងខ្លួន។ បន្ទាប់មកក្រុមថ្មីត្រូវបានបង្កើតដោយមានសមាជិកមកពីក្រុមចាស់ផ្សេងៗគ្នា។ ពួកគេរាយការណ៍អំពីការរកឃើញនៅក្នុងក្រុមមុនរបស់ខ្លួនប្រាប់ទៅសមាជិកក្រុមថ្មីម្នាក់ម្តងៗ។ សកម្មភាពនេះអាចចំណាយពេលលើសពីមួយម៉ោងសិក្សា។
- **លំហាត់ស្រាវជ្រាវ៖** សិស្សចូលរួមក្នុងការងារស្រាវជ្រាវបន្ថែមទៀតជាមួយសិស្សដទៃ។ ការងារនេះអាចធ្វើជាមួយដៃគូ ឬជាក្រុមតូចៗក្នុងរយៈពេលមួយម៉ោងសិក្សា ឬវែងជាងនេះ។
- **ដំណើរចុះកម្មសិក្សា/ សកម្មភាពរៀនផ្អែកលើបទពិសោធ៖** រៀបចំដំណើរកម្សាន្តឬទៅទស្សនាសារៈមន្ទីរគឺជាការរៀនតាមបទពិសោធក្រៅថ្នាក់រៀន ដែលអាចជំរុញឱ្យមានការចូលរួមយ៉ាងសកម្មនិងមានការលើកទឹកចិត្តសិស្សគ្រប់ប្រភេទ។ ការធ្វើកម្មសិក្សាជាពេលដែលសិស្សអាចធ្វើការជាក្រុមដោយដាក់ឱ្យសិស្សដែលមានចំណេះដឹងផ្សេងៗគ្នានៅក្នុងក្រុមតែមួយ។ ការធ្វើបែបនេះអាចផ្តល់ឱកាសឱ្យសិស្សបានឃើញ និងយល់រឿងរ៉ាវផ្សេងៗពីទស្សនៈផ្សេងៗគ្នា។

តតខ្ពោះទៅលើសំណួរ ដែលលើកទឹកចិត្តដល់ការគិតឱ្យបានស៊ីជម្រៅ ការដោះស្រាយបញ្ហា និង/ឬការវិភាគដោយលម្អិត។ ការពិភាក្សាជាក្រុមគឺមានលក្ខណៈសំខាន់ណាស់ដោយហេតុថាបានធ្វើឱ្យសិស្សបញ្ជាក់ច្បាស់ពីដំណើរការនៃការគិតរបស់ពួកគេ ។

(Brown University, n.d., online)

- **ការរៀនដោយផ្តែកលើបញ្ហា៖** នៅក្នុងក្រុម សិស្សត្រូវស្វែងរកដំណោះស្រាយចំពោះបញ្ហាដែលគ្រូដាក់ឱ្យ ដោយគ្មានចម្លើយណាមួយច្បាស់លាស់ទេ។ សិស្សអាចធ្វើកិច្ចការជាមួយក្រុមច្រើនម៉ោងសិក្សា។ ការរៀនដោយផ្តែកលើបញ្ហាមិនអាចធ្វើតែម្តងបានទេ គឺសិស្សត្រូវធ្វើការជាមួយគ្នាក្នុងរយៈពេលយូរទើបគ្រប់គ្រាន់។
- **ការរៀនដោយផ្តែកលើក្រុម៖** វិធីនេះស្រដៀងនឹងវិធីមុនដែរ ប៉ុន្តែវិធីនេះគ្រូដាក់សិស្សជាក្រុមទៅតាមប្រភេទផ្សេងគ្នាដូចជាមានជំនាញ សាវតារ វប្បធ៌មផ្សេងគ្នា។ ទោះបីជាយ៉ាងណាក៏ដោយ គ្រូត្រូវប្រាកដថាគ្មានសិស្សណាម្នាក់នៅក្នុងក្រុមមានអារម្មណ៍ថាត្រូវធ្វើការខ្លាំងពេកនោះទេ។ នេះមានន័យថា ប្រសិនបើនៅក្នុងថ្នាក់មានសិស្សប្រុសតែពីរនាក់ ពួកគេគួរតែត្រូវបានដាក់ឱ្យនៅក្នុងក្រុមជាមួយគ្នា ដើម្បីចៀសវាងភាពឯកា។ ក្រុមនេះត្រូវនៅជាមួយគ្នា ពេញមួយឆមាស។ ការនៅក្នុងក្រុមជាមួយគ្នាក្នុងរយៈពេលយូរ នឹងជំរុញឱ្យមានភាពជឿជាក់ក៏ដូចជាការគាំទ្រការសហការ និងទំនាក់ទំនងសង្គមរវាងសិស្សក្នុងក្រុមទាំងមូល (Sanger, 2001)។

ការធ្វើការងារជាក្រុមត្រូវមានការលើកទឹកចិត្តជាច្រើនប្រភេទ។ ជាដំបូងត្រូវធានាថា សិស្សទាំងអស់បានរៀនធ្វើកិច្ចការជាក្រុម ដែលនាំឱ្យមានការប្រែប្រួលដល់លទ្ធផលនៃការសិក្សា។ លើសពីនេះទៅទៀតការធ្វើការជាក្រុមតូចៗនៅក្នុងថ្នាក់អាចនាំមកនូវលទ្ធផល ល្អជាងការធ្វើការទាំងអស់គ្នានៅក្នុងថ្នាក់ទាំងមូល។ ការធ្វើការជាក្រុមក៏ជំរុញឱ្យមានការសហការ និងការគាំទ្ររវាងសិស្សនិងសិស្សផងដែរ។ វាអាចជួយសិស្សឱ្យបង្កើនសមត្ថភាពនៃការគិតបែបអរូបីជួយឱ្យចេះស្វែងរកដំណោះ-ស្រាយថ្មីៗ ហើយនិងគិតដោយមានហេតុផល។ ការធ្វើការជាក្រុមក៏អាចលើកកម្ពស់ដល់ការចូលរួមរបស់សិស្សក្នុងការរៀនសូត្រផងដែរ។ មូលហេតុមួយដែលសិស្សបានចូលរួមច្រើនគឺដោយសារតែការទទួលបាននូវមតិត្រលប់ភ្លាមៗ ពីមិត្តរួមក្រុម។ ផលប្រយោជន៍មួយទៀតនៃការធ្វើការជាក្រុមគឺសិស្សចេះសហការគ្នា ដែលជាកត្តាចាំបាច់នៅក្នុងជីវិត។ ការចេះសហការនេះនឹងនាំឱ្យមានទំនាក់ទំនងល្អក្នុងសង្គម ហើយវានឹងកាន់តែប្រសើរឡើងប្រសិនបើសិស្សត្រូវបានផ្តល់ឱកាសឱ្យធ្វើការនៅក្នុងក្រុមដោយឯករាជ្យ(Ward,1987)។ ផលប្រយោជន៍មួយទៀតនៃ ការបង្រៀនថ្នាក់តូច គឺថាវាជំរុញឱ្យមានការវិវឌ្ឍនៃការផ្ទេរជំនាញដូចជាជំនាញទំនាក់ទំនង ការធ្វើការជាក្រុម និងការដោះស្រាយបញ្ហា។ ទោះបីជាយ៉ាងណាក៏ដោយ គ្រូត្រូវតែ ប្រាកដថាសិស្សទាំងអស់បានទទួលចំណេះដឹងដូចៗគ្នា។ បន្ថែមពីនេះទៀត នៅពេលប្រើយុទ្ធសាស្ត្រការងារជាក្រុមត្រូវចងចាំក្នុងចិត្តថា ៖

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

- ត្រូវធ្វើការផ្លាស់ប្តូរក្រុម។ ឧទាហរណ៍ ក្រុមខ្លះសុទ្ធតែស្រី ក្រុមខ្លះសុទ្ធតែប្រុស ក្រុមខ្លះមានប្រុសមានស្រី ក្រុមខ្លះមានសមត្ថភាពផ្សេងៗគ្នាជាដើម ហើយព្យាយាមប្តូរចំនួនសមាជិកនៃក្រុម ដូចជាអាចធ្វើការជាដៃគូជាក្រុមបីបួននាក់ ឬច្រើនជាងនេះជាដើម។
- ត្រូវចេះបត់បែនតាមកាល:ទេស នៅពេលដាក់សិស្សជាក្រុម ដោយហេតុថាការបានធ្វើការជាក្រុម ជាមួយមិត្តរួមថ្នាក់ផ្សេងៗគ្នាគឺមានសារៈសំខាន់ដែលអាចជួយឱ្យពួកគេ បានដឹងពីចំណេះដឹងផ្សេងៗគ្នា។ វាក៏បានបង្ហាញពីទេពកោសល្យរបស់ពួកគេ និងរបស់មិត្តភក្តិគេ។ វាក៏ជំរុញឱ្យមានភាពអត់ធ្មត់ផងដែរ។
- សិស្សម្នាក់គួរតែទទួលបានឱកាសធ្វើជាប្រធានក្រុម យ៉ាងហោចណាស់ក៏ម្តងដែរ ដើម្បីឱ្យពួកគេបានរៀន និងកែលម្អពីជំនាញភាពជាអ្នកដឹកនាំ (UNESCO/ Booklet Five,2015)។
- កុំដាក់ចំណាត់ថ្នាក់សិស្សនៅក្នុងក្រុមណាមួយ (ខ្លាំង ឬ ខ្សោយ)។

៤- ទិធីសាស្ត្របង្រៀន

ដូចគ្នាទៅនឹងទ្រឹស្តីនៃការរៀន ដែលគ្រូអាចជ្រើសរើសយុទ្ធសាស្ត្របង្រៀនជាច្រើន ដើម្បីបង្រៀនសិស្ស។ យុទ្ធសាស្ត្រ និងវិធីសាស្ត្រផ្សេងៗដែលគាំទ្រការរៀនគឺមិនអាចកាត់ផ្តាច់គ្នាបានទេ។

> *ការបង្រៀនដោយផ្ទាល់អាច បញ្ចូលគ្នាជាមួយវិធីសាស្ត្រផ្សេងៗទៀតដើម្បីបង្រៀន។ ជាឧទាហរណ៍គ្រូអាចប្រើវិធីសាស្ត្របង្រៀនដោយផ្ទាល់ ដើម្បីរៀបចំឱ្យសិស្សចូលរួមក្នុងសកម្មភាពការងារគម្រោងជាក្រុម ដែលមានការដឹកនាំពីគ្រូបង្រៀននៅពេលចាំបាច់ (សកម្មភាពជាក្រុមមិនត្រូវបានចាត់ទុកជាការបង្រៀនដោយផ្ទាល់ទេ) (Lombardi,2017,online)*

វិធីសាស្ត្រជាដំណើរការដែលត្រូវបានដាក់ឱ្យអនុវត្ត ដើម្បីសម្រេចគោលដៅដែលចង់បាន។ នៅក្នុងបរិបទនៃការបង្រៀន វាគឺជាផ្លូវដែលអ្នករៀនត្រូវដើរ ដើម្បីសម្រេចគោលដៅនៃការរៀនសូត្រ។ មានវិធីសាស្ត្ររៀនជាច្រើនប្រភេទ អ្នកខ្លះចូលចិត្ត ទស្សន:គ្រូមជ្ឈមណ្ឌល អ្នកខ្លះចូលចិត្តទស្សន:សិស្សមជ្ឈមណ្ឌល។ វិធីសាស្ត្រគ្រូមជ្ឈមណ្ឌលសំដៅលើគ្រូជ្រើសរើសវិធីរៀនសម្រាប់សិស្ស មានន័យថាគ្រូប្រើលំហាត់ គោលដៅជាក់លាក់ផ្សេងៗ នាំសិស្សទៅដល់គោលដៅ ដែលបានរៀបចំទុក។ នៅមានវិធីសាស្ត្របើកទូលាយជាច្រើនទៀតមិនសំដៅទៅលើគោលដៅដែល

បានត្រៀមទុកមុននោះទេ តែសំដៅលើការជួយសិស្សលើជំនាញផ្សេងៗទៅវិញ (Pluskow,2015)។ នៅពេលនិយាយអំពីវិធីសាស្ត្រក្នុងការបង្រៀន យើងគួរកត់សម្គាល់ថាការដឹងអាយុរបស់សិស្ស និងការជ្រើសរើសវិធីសាស្ត្របង្រៀនគឺមានសារៈសំខាន់ណាស់។ ទោះជាយ៉ាងណាក៏ដោយ ការដែលចេះប្រើវិធីសាស្ត្រផ្សេងៗបញ្ចូលគ្នាជារឿងដ៏ប្រសើរ (Tuomarla,2019)។ នៅក្នុងសាលារៀន វិធីសាស្ត្របង្រៀន និងលទ្ធផលនៃការរៀនគឺមានភាពចាំបាច់ដូចគ្នា។ ការបង្រៀនប្រកបដោយប្រសិទ្ធភាពគឺជា "ការបូកផ្សំគ្នារវាងវិធីសាស្ត្ររៀន និងបង្រៀនដែលការធ្វើបែបនេះអាចបំពេញដល់តម្រូវការរបស់សិស្ស និងធ្វើឱ្យថ្នាក់រៀនក្លាយជាកន្លែងរស់រវើក ដែលមានការប្រកួតប្រជែងនិងជាកន្លែងដែលរីករាយ" (UNESCO/Booklet Five,2015,p.18)។

វិធីសាស្ត្រសិស្សមជ្ឈមណ្ឌលតម្រូវឱ្យមានការបញ្ចូលលំហាត់ដែលនាំឱ្យមានការចូលរួមពីសិស្សយ៉ាងសកម្ម ក៏ដូចជាការលើកទឹកចិត្តសិស្សក្នុងការសិក្សា។ លំហាត់ប្រភេទនេះនឹងជួយសិស្សឱ្យផ្តោតការយកចិត្តទុកដាក់លើមុខវិជ្ជាដែលរៀន។ លើសពីនេះទៅទៀតវិធីសាស្ត្រសកម្មនានាអាចជួយសិស្សឱ្យមានជំនាញនៃការគិតដូចជាការវិភាគផ្សេងៗមានភាពប្រសើរឡើង។ វិធីសាស្ត្រ និងការរៀនដែលសកម្មផ្សេងៗមិនគ្រាន់តែអាចជួយឱ្យសិស្សមានការគិតប្រសើរឡើងប៉ុណ្ណោះទេ វាថែមទាំងជួយជំរុញឱ្យផ្នែកស្មារតីដូចជា មេត្តាធម៌ ការចេះជួយគ្នា មនុស្សធម៌ និងការយល់ចិត្តគ្នាជាដើមនិងជំនាញជាក់ស្តែងឱ្យមានភាពប្រសើរឡើង (Tuomarla,2019)។

វាជាការសំខាន់ណាស់ដែលត្រូវដឹងថាវិធីបង្រៀនបែបគ្រូមជ្ឈមណ្ឌល ឬក៏វិធីបង្រៀនបែបបុរាណគឺនៅតែជាផ្នែកមួយនៃដំណើរការនៃការបង្រៀន។ ប៉ុន្តែភាគច្រើននៃពេលវេលានៅក្នុងថ្នាក់រៀន គួរតែជាការប្រើវិធីសាស្ត្របែបសិស្សមជ្ឈមណ្ឌលដែលជំរុញឱ្យមានការចូលរួមពីសិស្ស លើកទឹកចិត្តសិស្សឱ្យរៀន ហើយលទ្ធផលចុងក្រោយគឺការទទួលបានភាពជោគជ័យក្នុងការរៀនសូត្រ។ ការធ្វើបែបនេះមិនមែនជាការបញ្ឈៀសចេញពីការបង្រៀនបែបគ្រូមជ្ឈមណ្ឌល ទាំងស្រុងនោះទេ ប៉ុន្តែយើងត្រូវបញ្ជ្រាបចូលនូវសកម្មភាពរៀនបែបសិស្សមជ្ឈមណ្ឌលបន្តិចម្តងៗ រួមមានដូចជាការសម្តែង ការលេងល្បែងផ្សេងៗ និងឱ្យមានការពិភាក្សាជាក្រុម។ ជាពិសេសតាមរយៈការសន្ទនា និងការពិភាក្សា សិស្សមានឱកាសទទួលបានព័ត៌មានថ្មីៗ ក៏ដូចជាវាយតម្លៃចំណេះដឹងពីមុន និងអាចសម្រេចកិច្ចការដែលគ្រូដាក់ឱ្យ (Tuomarla, 2019)។ គ្រូអាចជ្រើសរើសវិធីសាស្ត្រផ្សេងៗជាច្រើន ដើម្បីធ្វើឱ្យបរិយាកាសនៃការរៀនសូត្រមានភាពសមស្រប ក៏ដូចជាជួយសិស្សឱ្យចូលរួមយ៉ាងសកម្មនៅក្នុង

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ថ្នាក់រៀន។ នៅពេលដែលជ្រើសរើសវិធីសាស្ត្រសមស្របសម្រាប់ការបង្រៀន គ្រូត្រូវចងចាំនូវចំណុចសំខាន់ៗខាងក្រោម ៖

- ភ្ជាប់វិធីសាស្ត្រទៅនឹងលទ្ធផលរំពឹងទុកនៃការរៀន
- មានទំនាក់ទំនងគ្នាជាមួយកម្មវិធីសិក្សា
- គិតពីចំណេះដឹង និងបទពិសោធមានស្រាប់របស់សិស្ស
- វាយតម្លៃពីធនធានដែលមានដូចជា (ពេលវេលា ទីកន្លែង ថវិកា និងសម្ភារៈ)
- រួមបញ្ចូលចំណង់ចំណូលចិត្ត និងរបៀបរៀនរបស់សិស្ស (ឧ. អ្នករៀនតាមរយៈការមើល ការស្តាប់ និងការប៉ះ)
- ប្រើយុទ្ធសាស្ត្រផ្សេងៗក្នុងកំឡុងពេលរៀន
- វិធីសាស្ត្រដែលជ្រើសរើសត្រូវតែស៊ីគ្នាជាមួយអ្វីដែលត្រូវបង្រៀន គឺថាគ្រូត្រូវគិតពីចំណុចដែលត្រូវរៀនក៏ដូចជាប្រសិទ្ធភាពនៃវិធីសាស្ត្រនៅក្នុងបរិបទនោះ
- សង្កេតមើលថាវិធីសាស្ត្រណាមានប្រសិទ្ធភាពហើយព្យាយាមវិភាគថាតើហេតុអ្វីបានជាវាមានប្រសិទ្ធភាព តើអ្នកនឹងធ្វើអ្វីផ្សេងពីនេះនៅលើកក្រោយ
- ឆ្លុះបញ្ចាំងទៅលើវិធីសាស្ត្រនានាដែលបានរៀនរួចក្នុងកំឡុងពេលនៃការបណ្តុះបណ្តាល គិតអំពីយុទ្ធសាស្ត្រផ្សេងទៀតដែលអាចប្រើបានបន្ថែមហើយសួរខ្លួនឯងថា តើហេតុអ្វីបានជាចង់បន្ថែម ព្រមទាំងគិតពីអត្ថប្រយោជន៍ និងផលលំបាកនៃវិធីសាស្ត្រនីមួយៗផង (Tuomarla,2019)។

ចំណុចសំខាន់គឺចង់ទាក់ទាញនូវចំណង់ចំណូលចិត្តរបស់សិស្ស។ គ្រូគួរតែបង្កើតបរិយាកាសរៀនសូត្រដែលអាចជំរុញចំណង់ចំណូលចិត្តក្នុងការរៀន ដោយការសង្កេតលើការចូលរួមរបស់សិស្សនៅក្នុងថ្នាក់។ យោងតាមការសង្កេតរបស់អ្នកអប់រំ គ្រូគួរតែជ្រើសរើសវិធីសាស្ត្របែបបុរាណឬក៏សម័យ(បែបសិស្សមជ្ឈមណ្ឌល)។

- តើត្រូវសង្កេតលើអ្វី?
- តើសិស្សចាប់អារម្មណ៍លើមេរៀនដែលកំពុងរៀនដោយរបៀបណា? តើពួកគេចូលរួមរៀនក្នុងថ្នាក់ដោយរបៀបណា?
- គិតអំពីវិធីផ្សេងៗដែលអ្នកអាចជួយសិស្ស ដើម្បីសម្រេចគោលដៅរៀនសូត្ររបស់ពួកគេ
- រៀបគម្រោងផ្សេងទៀត ដើម្បីទាក់ទាញចំណាប់អារម្មណ៍របស់សិស្សចំពោះមេរៀនថ្មី

- រៀបគម្រោងអំពីរបៀប ដែលទាក់ទាញចំណាប់អារម្មណ៍របស់សិស្សទៅលើមេរៀនកំពុងរៀន។

៥- ការបង្រៀនប្រកបដោយប្រសិទ្ធភាព

ជំនាញបង្រៀន គឺត្រូវរៀន ត្រូវចេះសម្របខ្លួន និងចេះវិវឌ្ឍន៍ខ្លួនជាបន្តបន្ទាប់ក្នុងអាជីពជាគ្រូបង្រៀន ហើយដំណើរនេះត្រូវវិវឌ្ឍន៍ជាប្រចាំ។ កត្តាផ្សេងៗដែលមាន ឥទ្ធិពលដល់ជំនាញនេះរួមមានបរិស្ថានសាលារៀន តម្រូវការនៃកម្មវិធីសិក្សា និងតម្រូវការរបស់សិស្ស។ គ្រូអាចវិវឌ្ឍន៍ខ្លួនជាបណ្តើរៗជាប់ជានិច្ច ដើម្បីឱ្យការបង្រៀនមានប្រសិទ្ធភាព។ ជំពូកនេះនឹងធ្វើការពិភាក្សាលើជំនាញបង្រៀនចំនួនប្រាំដែលមានប្រសិទ្ធភាព(ការរៀបចំកិច្ចតែងការ ការពន្យល់ ការធ្វើបង្ហាញ ការសួរសំណួរ ការធ្វើបទបង្ហាញ ការគ្រប់គ្រង ការឆ្លុះបញ្ចាំង និងការវាយតម្លៃ)។

៥.១- ការរៀបចំកិច្ចតែងការបង្រៀន

សមត្ថភាពរបស់គ្រូក្នុងការរៀបចំកិច្ចតែងការបង្រៀន ដោយមានគោលដៅច្បាស់លាស់គឺជាចំណុចសំខាន់បំផុត ដែលនាំឱ្យមេរៀនមួយបានសម្រេចជោគជ័យ ព្រោះតែវាមានភាពច្បាស់លាស់ផ្តោតលើការរៀនសូត្ររបស់សិស្ស និងមានគោលបំណងជាក់លាក់។ នៅពេលរៀបចំកិច្ចតែងការបង្រៀន គ្រូត្រូវសួរខ្លួនឯងថា "តើសិស្សនឹងបានរៀនអ្វីនៅពេលចប់មេរៀន។

លំដាប់នៃការរៀបចំកិច្ចតែងការបង្រៀនមានដូចជា កត់សម្គាល់ពីគោលបំណងមេរៀន ជ្រើសរើសវិធីសាស្ត្របង្រៀន និងបញ្ជាក់ច្បាស់ពីរបៀបធ្វើតេស្តសិស្ស។ យោងទៅលើការសិក្សាស្រាវជ្រាវជាច្រើនបានបង្ហាញថា គ្រូបង្រៀនដែលមានបទពិសោធតែងតែប្រើវិធីសាស្ត្រផ្សេងៗគ្នាជាច្រើន។

ជាទូទៅ វិធីខាងលើជាវិធីដែលគរុនិស្សិតជាច្រើនបានរៀបចំកិច្ចតែងការបង្រៀន (ជាពិសេសនៅពេលត្រូវបង្ហាញកិច្ចតែងការបង្រៀនទៅគ្រូឧទេស)។ ការសិក្សាស្រាវជ្រាវទៅលើការរៀបចំកិច្ចតែងការបង្រៀនរបស់គ្រូ ដែរមានបទពិសោធជាច្រើនបានបង្ហាញថា ពួកគាត់បានផ្តោតការយកចិត្តទុកដាក់ទៅលើខ្លឹមសារមេរៀន សម្ភារៈ និងសកម្មភាពដែលត្រូវប្រើក្នុងការបង្រៀន និងរៀនដោយគ្មានបញ្ជាក់ច្បាស់លាស់ អំពីគោលបំណងនៃមេរៀនទេ។ ការធ្វើបែបនេះវាបង្ហាញការពិតថា គ្រូបង្រៀន ដែលមានបទពិសោធធ្លាប់រៀបចំកិច្ចតែងការបង្រៀនឱ្យស្របទៅនឹងអ្វី

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ដែលជាការងារប្រចាំថ្ងៃរបស់សិស្ស ដោយមិនចាំបាច់ប្រើឯកសារយោងនៃមេរៀននីមួយៗឡើយ (Kyriacou,2009,88)។

ក្នុងពេលដែលបទពិសោធ មានសារៈសំខាន់ក្នុងការរៀបចំកិច្ចតែងការបង្រៀន ការអនុវត្តតាមកិច្ចតែងការបង្រៀនដែលមានស្រាប់ (ជាពិសេសសម្រាប់គ្រូថ្មីៗ) អាចជួយឱ្យការបង្រៀន និងរៀនមានប្រសិទ្ធភាព។ **ទី១** គ្រូត្រូវកំណត់វត្ថុបំណងមេរៀន ហើយភ្ជាប់ទៅនឹងកម្មវិធីសិក្សារបស់រដ្ឋ។ វត្ថុបំណងនៃការសិក្សាត្រូវតែមានភាពជាក់ច្បាស់ ហើយអាចបញ្ជាក់ដោយពាក្យងាយៗដូចជា "នៅចុងបញ្ចប់នៃមេរៀនសិស្សនឹងអាច....." (Newman University,2018)។ **ទី២** គ្រូត្រូវពិចារណាទៅលើខ្លឹមសារមេរៀនដែលកំពុងបង្រៀន និងអ្វីដែលសិស្សបានដឹងរួចហើយ ទាក់ទងនឹងមេរៀននោះ។ មេរៀនដែលសិស្សនឹងត្រូវរៀនគួរតែបង្រៀនជាបណ្តើរៗ ហើយគ្រូគួរតែផ្តោតទៅលើមេរៀនទាំងនោះឱ្យបានពេញលេញនៅក្នុងឆ្នាំសិក្សា។ ការរៀបចំកិច្ចតែងការបង្រៀនក៏អាចធ្វើវិធីបញ្ជាសផងដែរដោយកំណត់លទ្ធផលសិក្សាដែលរំពឹងថាសិស្សអាចធ្វើបាននៅចុងឆ្នាំសិក្សា ហើយគ្រូត្រូវប្រាកដថា សិស្សមានចំណេះដឹងនិងជំនាញមូលដ្ឋានរួចរាល់ ដើម្បីទៅដល់គោលដៅដែលបានកំណត់ (Keeble,2016)។ វាក៏ជាការប្រសើរដែរ ប្រសិនបើគ្រូអាចពិនិត្យដោយផ្ទាល់ថាសិស្សបានយល់ច្បាស់ពីមេរៀន ជាមួយកស្តុតាងច្បាស់លាស់(មិនមែនចេះតែស្មានថាសិស្សយល់ទេ)។ ដើម្បីដឹងថាសិស្សយល់មេរៀនគ្រូអាចរម្លឹក មេរៀនចាស់ជាមុនសិនមុននឹងចាប់ផ្តើមមេរៀនថ្មីទៀត(Kyriacou,2009)។ **ទី៣** គ្រូអាចជ្រើសរើសយុទ្ធសាស្ត្របង្រៀនដូចជាការបង្រៀនដោយផ្ទាល់ ការបង្រៀនដោយមិនផ្ទាល់ ការបង្រៀនតាមបែបអន្តរកម្ម ការដកដៃពីក្រុក ករណីសិក្សា ល្បែងអប់រំ និងការឆ្លុះបញ្ចាំង ធ្វើយ៉ាងណាឱ្យយុទ្ធសាស្ត្របង្រៀនផ្សារភ្ជាប់ទៅនឹងគោលបំណងនៃមេរៀន។ វិធីសាស្ត្រទាំងនេះមិនត្រឹមតែអាចធ្វើឱ្យសិស្សផ្តោតលើ មេរៀនប៉ុណ្ណោះទេ ប៉ុន្តែ វាថែមទាំងអាចគាំទ្រដល់សិស្សឱ្យឈានទៅដល់ការរៀនបែបសិស្សមជ្ឈមណ្ឌល និងមានភាពស៊ប់រើក។ (Newman University,2018)

បន្ថែមពីនោះទៅទៀតគ្រូត្រូវមានភាពបត់បែនទៅតាមមេរៀន និងតម្រូវការសិស្ស។ គ្រូ និងសិស្សត្រូវតែសម្របតាមតម្រូវការជាក់ស្តែងណាមួយ ដើម្បីពួកគេអាចអនុវត្តប្រកបដោយភាពបត់បែនតាមកាល:ទេស: ខ្លឹមសារមេរៀន និង សមត្ថភាពសិស្ស។ នៅពេលដែលគ្រូអាចបង្កើតជាទម្លាប់នៅក្នុងថ្នាក់រៀនបានហើយ តាមរយៈបទពិសោធនិងការអនុវត្តជាប្រចាំ នឹងអាចជួយសម្រួលដល់ការបង្រៀនកាន់តែងាយស្រួល (Kyriacou,2009)។ ជាចុងក្រោយ នៅពេលរៀបចំកិច្ចតែងការ

បង្រៀន គ្រូត្រូវតែដឹង និងធ្វើការពិចារណាពីភាពខុសគ្នារវាងសិស្សទាំងអស់ដូចជា របៀបរៀន តម្រូវការចាំបាច់ ល្បឿននៃការរៀននិងការលើកទឹកចិត្តក្នុងការរៀនសូត្រ ទាក់ទងទៅនឹងភេទ សាសនា សញ្ជាតិ ។ល។

សំណួរគន្លឹះមួយចំនួនដែលអាចជួយដល់ការរៀបចំកិច្ចតែងការបង្រៀន ដែលដកស្រង់ចេញពី Kyriacou (2009) មានដូចខាងក្រោម ៖

- តើអ្វីខ្លះត្រូវការរៀបចំជាចាំបាច់មុនពេលបង្រៀន?
- តើបញ្ហាអ្វីដែលនឹងអាចកើតឡើង?
- តើសិស្សនៅក្នុងថ្នាក់មានសមត្ថភាពផ្សេងៗគ្នាយ៉ាងដូចម្តេចខ្លះ?
- តើខ្ញុំត្រូវធ្វើការលើកទឹកចិត្តដល់សិស្សដល់កម្រិតណា?
- តើមានសិស្សណាខ្លះមានតម្រូវការរៀនពិសេសដែរ ឬទេ?
- តើសិស្សបានដឹង យល់ពីមេរៀន ដែលរៀនបានដល់កម្រិតណា?
- តើខ្ញុំចង់ឱ្យសិស្សរៀនពីអ្វីនៅក្នុងមេរៀននេះ ការគិត និងយល់ (ចំណេះដឹង ប្រាជ្ញា) ចំណូលចិត្ត(ភាពជឿជាក់ ឥរិយាបទ) និងស្មារតី(ការគិត ការឆ្លើយតប ការសម្របខ្លួន)?
- តើមានទំនាក់ទំនងទៅនឹងអារម្មណ៍ ចំណង់ចំណូលចិត្ត និងតម្រូវការសិស្ស ដោយរបៀបណា ?
- តើមេរៀននេះមានទាក់ទងទៅនឹងមុខវិជ្ជា នេះទាំងមូល ឬទេ?
- តើបញ្ហាអ្វីខ្លះដែលគួរលើកយកមកពិចារណា (ដូចជាពេលវេលា ចំនួនសិស្ស ថ្នាក់រៀន ជំនាញរបស់គ្រូ និងធនធានសិក្សា)?
- តើមេរៀននេះបានទទួលជោគជ័យ ដូចថ្នាក់រៀនដទៃទៀតដែលរៀនមេរៀនដូចគ្នានេះ ឬទេ?
- តើវិធីសាស្ត្របង្រៀនមួយណាដែលត្រូវគ្នានឹងគោលបំណងនៃមេរៀន?
- តើមានការលំបាកកម្រិតណា និងគួរធ្វើយ៉ាងណាដើម្បីទទួលបាននូវការយកចិត្តទុកដាក់ពីសិស្ស តាមរយៈការលើកទឹកចិត្តដើម្បីឱ្យសិស្សបានសម្រេចដល់គោលដៅមេរៀន?
- តើត្រូវកំណត់ពីកម្រិតសម្រេចបានដោយរបៀបណា (ឧទាហរណ៍ ដូចជាការសួរសំណួរសិស្ស ដាក់ក្រុមពិភាក្សា ធ្វើសំណេរ និងការធ្វើតេស្តបន្ទាប់ពីរៀនរួច)?

គំរូដើមឈើ (Tree Model) គឺជាគោលការណ៍ណែនាំសម្រាប់រៀបចំបទពិសោធបង្រៀន និងរៀនឲមានប្រសិទ្ធភាព។ វាត្រូវបានបែងចែកជា២ គឺទស្សនៈរបស់គ្រូ (អ្វីដែលគ្រូត្រូវបានរៀបចំទុកជាមុន និងពិចារណានៅពេលរៀបចំកិច្ច

តែងការបង្រៀន) និងទស្សនៈរបស់សិស្ស (អ្វីដែលសិស្សត្រូវការក្នុងកំឡុងពេលដំណើរការរៀន។ គំរូនេះផ្តោតសំខាន់ទៅលើអន្តរកម្មរបស់គ្រូ និងសិស្ស។

តារាង២៖ គំរូដើមឈើ (Tree Model)

គ្រូ/ការបង្រៀន	សិស្ស/ការរៀន
<u>ការសិក្សាពីមូលដ្ឋាន</u> (Root) នៅក្នុងដំហានដំបូងនេះ អ្នកត្រូវមើលស្ថានភាពនៃបរិស្ថានរៀនសូត្រ។ វាជាការវិភាគទៅលើសមាសភាពទាំងអស់នៅក្នុងលក្ខខណ្ឌបច្ចុប្បន្ន។ *<u>ចូរសួរសំណួរខាងក្រោម៖</u>* +តើសិស្សរបស់ខ្ញុំជាអ្នកណា? តើអ្វីដែលជាចំណុចចាប់ផ្តើមនៃការរៀនផ្ទាល់ខ្លួនរបស់ពួកគេ? តើអ្វីដែលជាចំណេះដឹងពីមុន និងសមត្ថភាពរបស់ពួកគេ? +តើថ្នាក់រៀនរបស់ខ្ញុំមានលក្ខណៈយ៉ាងដូចម្តេច? តើតុ កៅអីត្រូវបានរៀបចំយ៉ាងដូចម្តេច? +តើមានធនធានអ្វីខ្លះដែលអាចប្រើប្រាស់បាន? តើមេរៀនមួយត្រូវចំណាយពេលប៉ុន្មាន? +តើមានការបង្ហាញពីភាពផ្សេងៗគ្នានៃមេរៀនដោយរបៀបណា? តើសិស្សត្រូវការការណែនាំបែបបទណាពីខ្ញុំគ្រូ?	**<u>ការសិក្សាពីមូលដ្ឋាន</u>** (Root) នៅក្នុងដំហានដំបូងនេះសិស្សបានដឹងពីបរិស្ថានរៀនសូត្រ។ ពួកគេត្រូវបានណែនាំដោយការគិតអំពីអ្វីដែលនឹងកើតឡើងនៅក្នុងមេរៀន។ ចំណុចចាប់ផ្តើមនៃការរៀនរបស់សិស្សម្នាក់ៗ និងចំណេះដឹងពីមុន ព្រមទាំងសមត្ថភាពរបស់សិស្សគួរតែត្រូវបានវាយតម្លៃ។ *<u>គោលគំនិត៖</u>* ☐ ការលេងល្បែងអប់រំនៅពេលចាប់ផ្តើមមេរៀន ការធ្វើពិធីសាសនា បង្ហាញពីគោលបំណងនៃការរៀន។ ☐ ការបំផុសគំនិត ការម្លឹកមេរៀនចាស់ ☐ ផ្សារភ្ជាប់មេរៀនទៅនឹងជីវិតផ្ទាល់ខ្លួនរបស់សិស្សដោយការបង្ហាញពីភាពពាក់ព័ន្ធគ្នានៃមេរៀន ការលើកឡើងពីបញ្ហា។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ការអភិវឌ្ឍ (Growth)	**ការអភិវឌ្ឍ (Growth)**
នៅជំហានទី២ អ្នកត្រូវពិចារណារកវិធីដើម្បីដំណើរបង្រៀន និងរៀន។ នេះជាការវិភាគនៃស្ថានភាពអនាគត។ *<u>ចូរសួរសំណួរខាងក្រោម</u>*៖ - តើអ្វីដែលជាលទ្ធផលចង់បាននៃមេរៀន? តើចំណេះដឹងមួយណាដែលសិស្សទទួលបាន? តើសមត្ថភាពអ្វីខ្លះដែលបានផ្តល់ឱ្យសិស្ស? -តើសិស្សត្រូវការអ្វីដើម្បីអភិវឌ្ឍសមត្ថភាពនោះ? តើវិធីសាស្ត្រណាមួយដែលនឹងជួយសិស្សឱ្យអភិវឌ្ឍសមត្ថភាពនោះ? តើសម្ភារឧបទេសណាមួយដែលនឹងគាំទ្រដល់ការអភិវឌ្ឍដល់សមត្ថភាពដ៏សំខាន់នោះ? -ក្នុងនាមជាគ្រូ តើខ្ញុំអាចជួយសិស្សម្នាក់ៗក្នុងដំណើរការរៀនសូត្រនេះឱ្យបានខ្លាំងក្លាដោយរបៀបណា? តើសិស្សត្រូវការណែនាំយ៉ាងដូចម្តេចពីខ្ញុំជាគ្រូ?	នៅក្នុងជំហានទី២ សិស្សទទួលចំណេះដឹងថ្មី ដោយការប្រើវិធីសាស្ត្រធ្វើបង្ហាញ និងវិធីសាស្ត្រចូលរួម។ *<u>គោលគំនិត</u>*៖ ☐ ការធ្វើបង្ហាញ ការធ្វើបទឧទ្ទេស ការធ្វើបាឋកថារបស់វាយគ្មិន ការធ្វើបទបង្ហាញ។ ☐ ការចុះកម្មសិក្សា ការសម្តែង ការធ្វើគម្រោង។
<u>បំផុសគំនិត</u> (BLOSSOMING) នៅជំហានទី៣នេះ មុនដំបូងត្រូវពិចារណាអំពី៖ • គោលបំណងនៃមេរៀន • ការបង្កើតខ្លឹមសារជាក់លាក់ • ការបង្កើតទម្រង់ខ្លឹមសារ	**<u>បំផុសគំនិត</u> (BLOSSOMING)** ដើម្បីឱ្យសិស្សទទួលបានចំណេះដឹងពេញលេញ ពួកគេត្រូវការពេលដើម្បីចូលរួមក្នុងដំណើរការរៀន។ នៅជំហានទី៣នេះ សមត្ថភាពចំណេះដឹងនឹងត្រូវពង្រឹង រម្លឹកឡើងវិញ និងអនុវត្ត។

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

• ការបញ្ចូលខ្លឹមសារមេរៀនទៅក្នុងកម្មវិធីសិក្សា • ការបង្កើតខ្លឹមសារយុទ្ធ/សាស្ត្រផ្សេងៗប្រកបដោយភាពបត់បែន • ការបង្កើតលក្ខណៈវិនិច្ឆ័យ និងយុទ្ធសាស្ត្រ ដើម្បីពិនិត្យ និងវាយតម្លៃពីលទ្ធផលសិក្សា និងវត្ថុបំណងមេរៀន។	មិនមានសមត្ថភាពថ្មីត្រូវបានផ្តល់ឱ្យនៅចំណុចនេះទេ។ *<u>គោលគំនិត</u>* ☐ ការពិភាក្សាក្នុងថ្នាក់រៀន ការសម្តែង ករណីសិក្សា ការធ្វើរបាយការណ៍ ☐ ការសង្កេប ការធ្វើតេស្ត ការប្រើប័ណ្ណ(Flash card) ការចងចាំ គិត-ដៃគូ-ចែករំលែក (Think-Pair-Share)
<u>ការឆ្លុះបញ្ចាំងត្រលប់</u>(Renewal) បន្ទាប់ពីបានបញ្ចប់ដំហានទាំង៣ខាងលើ គ្រូអាចឆ្លុះបញ្ចាំងត្រលប់ទៅលើជោគជ័យរបស់គាត់ និងអ្វីដែលត្រូវផ្លាស់ប្តូរ ឬសម្របតាមដើម្បីឱ្យសិស្សទទួលបានជោគជ័យក្នុងការរៀនសូត្រប្រសើរឡើង។	**<u>ការឆ្លុះបញ្ចាំងត្រលប់</u>**(Renewal) បន្ទាប់ពីបានបញ្ចប់ដំហានទាំង៣ សិស្សអាចឆ្លុះបញ្ចាំងត្រលប់ទៅលើអ្វីដែលបានរៀននៅក្នុងមេរៀន និងអ្វីដែលពួកគេត្រូវការបន្ថែមទៀត ដើម្បីធ្វើឱ្យការរៀនសូត្រមានការវិវឌ្ឍទៅមុខ។ *<u>គោលគំនិត</u>* ☐ ការធ្វើតេស្តទាំងផ្លូវការ និងមិនផ្លូវការ ☐ សិស្សធ្វើការសង្កេប

៥.២- ការធ្វើបទបង្ហាញ និងការពន្យល់

ជាទូទៅ គ្រូត្រូវចំណាយពេលច្រើននៅក្នុងថ្នាក់ដើម្បីធ្វើការបង្ហាញ ឬពន្យល់បញ្ញត្តិមេរៀននៅក្នុងថ្នាក់។ ដូច្នេះ វាចាំបាច់ណាស់ដែលត្រូវពង្រឹងសមត្ថភាពជំនាញទាំងនេះ។ វិធីសាស្ត្រទាំងពីរនេះគឺមានប្រយោជន៍ ពិសេសនៅពេលដែលសិស្សមានការលំបាកក្នុងការភ្ជាប់ការយល់ដឹងទៅនឹងការអនុវត្តជាក់ស្តែង ឬក៏នៅពេលដែលសិស្សមិនអាចយល់ពីការអនុវត្តអ្វីមួយ។ ដើម្បីផ្តល់នូវការពន្យល់ឱ្យបានល្អ ដែលអាចជួយសិស្សឱ្យយល់ស៊ីជម្រៅពីចំណេះដឹងអ្វីមួយ គ្រូត្រូវតែយល់ឱ្យបានច្បាស់លាស់ពីចំណុចមេរៀន ហើយផ្តល់ឱ្យសិស្សនូវព័ត៌មានជាក់ច្បាស់។ ការពន្យល់ពិតជាមានសារៈប្រយោជន៍ណាស់ក្នុងការជួយឱ្យគ្រូបង្ហាញពីមេរៀន និងគំនិតថ្មី ទំនាក់ទំនងហេតុនិងផលនិងដំណើរការនានា។ នៅពេលពន្យល់គំនិត ឬចំណេះដឹងថ្មី គ្រូគួរតែផ្តោតទៅលើចំណុចសំខាន់ៗមួយចំនួនដូចជា ការដាក់ឈ្មោះ ការបង្ហាញចំណុចគន្លឹះ ផ្តល់វិធាន និងលើកជាឧទាហរណ៍ (Regina,1991)។

តាមរយៈសមត្ថភាពរបស់គ្រូក្នុងការពន្យល់ដោយមានការធ្វើបង្ហាញ វាអាចផ្តល់នូវទំនាក់ទំនងរវាង ចំណេះដឹង និងការអនុវត្ត។ ការធ្វើបង្ហាញអាចបង្កើនចំណង់ចំណូលចិត្ត និងការយកចិត្តទុកដាក់ពីសិស្ស លើកកម្ពស់ការលើកទឹកចិត្តដល់សិស្ស និងបង្កើតស្ថានការណ៍រៀនពិតជាក់ស្តែងនៅក្នុងថ្នាក់រៀន។ ការធ្វើបង្ហាញនេះមានប្រសិទ្ធភាពបំផុតនៅពេលដែលបាននូវបង្ហាញពីគំនិតត្រឹមត្រូវ សិស្សអាចមើលឃើញ និងឮច្បាស់នូវអ្វីដែលកំពុងកើតឡើង និងនៅពេលដែលមានការពន្យល់សង្ខេបខ្លីៗ ក្នុងពេលកំពុងពិភាក្សា។ ដើម្បីឱ្យការធ្វើបង្ហាញទទួលបានជោគជ័យ គ្រូអាចប្រើរូបភាពជំនួយដូចជារូបថត ឬវីដេអូ មើលវត្ថុពិតជាក់ស្តែងដូចជា រុក្ខជាតិ និងសត្វផ្សេងៗ ឬក៏បង្កើតជាពិសោធផ្សេងៗ ជាក្រុម ឬជាថ្នាក់ទាំងមូល (Regina,1991)។

នៅពេលធ្វើការពន្យល់ដោយមានការបង្ហាញ ឬពន្យល់ចំណេះដឹងអ្វីមួយនៅក្នុងថ្នាក់គ្រូអាចតាមដានសិស្សជាបន្តបន្ទាប់នៅក្នុងដំណើរការបង្រៀន និងរៀន។ ការធ្វើការត្រួតពិនិត្យតាមដានពីការយល់ និងបានចូលរួមរបស់សិស្សនៅក្នុងដំណើរការរៀន អាចជួយឱ្យពួកគេទទួលជោគជ័យយ៉ាងធំធេង។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

៥.៣- ការសួរសំណួរ

ការចេះសួរសំណួរល្អគឺពិតជាជំនាញដ៏សំខាន់ខ្លាំងណាស់ ដែលគ្រូគួរតែមាន។ វាអាចជួយបង្កើនការចូលរួមពីសិស្ស លើកកម្ពស់ការយល់ដឹង ជំរុញការគិតបែបស៊ីជម្រៅ និងបង្កើនភាពច្នៃប្រឌិតខ្ពស់។ គ្រូបង្រៀនល្អគឺសួរសំណួរច្រើន ហើយគោរពតាមគោលការណ៍ជាក់លាក់៖

សំណួរដែលប្រើនៅក្នុងថ្នាក់ភាគច្រើនគឺស្រួលងាយៗ ឬជាសំណួរបិទ ដូចជាសួរថា "តើនេះជារូបការេឬ?" គ្រូបង្រៀនដែលល្អជ្រើសរើសសំណួរមកសួរដោយប្រុងប្រយ័ត្ន ដែលតម្រូវឱ្យសិស្សបានពន្យល់ និងគិតឱ្យបានស៊ីជម្រៅមុននឹងឆ្លើយ។ ឧទាហរណ៍ "តើប្អូនអាចប្រើពាក្យនេះទៅក្នុងបរិបទបាន ឬទេ?" និង "តើ X និង Y ខុសគ្នាដូចម្តេច?" ការជ្រើសរើសសំណួរប្រភេទផ្សេងៗគ្នាដោយមានគោលបំណងច្បាស់លាស់ដែលស៊ីគ្នាទៅនឹងខ្លឹមសារនៃមេរៀន និងបណ្តុះនូវជំនាញគិតបានល្អជាងមុន នាំដល់ការរៀនបានច្រើន។ វាក៏អាចជួយគ្រូឱ្យបានយល់ពីការវិឌ្ឍរបស់សិស្ស និងអាចផ្តល់ការណែនាំទៅដល់ពួកគាត់ប្រកបដោយប្រសិទ្ធភាព។ ការសួរសំណួរញឹកញាប់ក្នុងកំឡុងពេលពិភាក្សាក្នុងថ្នាក់អាចជួយសិស្សឱ្យបង្កើនការគិត ប៉ុន្តែការសួរសំណួរពិបាកពេកនៅពេលដែលសិស្សកំពុងរៀនមេរៀនថ្មី អាចធ្វើឱ្យគ្មានប្រសិទ្ធភាព ឬមិនបានជួយដល់ការយល់របស់សិស្សទេ (Keeble, 2016, 24)។

វិធីសាស្ត្រសួរសំណួរគួរត្រូវបានពិចារណា។ គ្រូបង្រៀនគួរជ្រើសរើសសំណួរដែលនាំឱ្យសិស្សមានឱកាសគិតដោយសេរី បង្កើតកំហុស(ការយល់ច្រឡំ) និងរកចម្លើយដោយខ្លួនឯង។ ដូចជាឱ្យសិស្សទាំងអស់សរសេរចម្លើយ។ គ្រូគួរតែជ្រើសរើសសំណួរដែលអាចឱ្យសិស្សគិតដោយសេរី អាចឆ្លើយខុសបានហើយអាចរកដំណោះស្រាយទៅលើបញ្ហាដោយខ្លួនឯង។

គ្រូបង្រៀនដែលជោគជ័យរិះរកវិធីផ្សេងៗដើម្បីជួយឱ្យសិស្សគិត ដូចជាឱ្យសិស្សសរសេរចម្លើយ ឬឱ្យសិស្សឆ្លើយសំណួរ ជាមួយមិត្តភក្តិជាដៃគូ មុនពេលជ្រើសរើសសិស្សឱ្យឆ្លើយនិងផ្តល់ការណែនាំត្រលប់។ គ្រូត្រូវផ្តល់ពេលគ្រប់គ្រាន់ឱ្យសិស្សគិតពីចម្លើយ ដោយបន្តការបំផុស លើកទឹកចិត្តក្នុងខណៈពេលជាមួយគ្នា (Keeble,2016,25)។

ដើម្បីជំរុញឱ្យមានការចូលរួមពីសិស្សកាន់តែច្រើន គ្រូគួរតែផ្តល់ពេល ៤ ទៅ ៥ វិនាទីដល់សិស្ស សម្រាប់សំណួរងាយៗ និងពេលយូរជាងនេះសម្រាប់សំណួរ

ពិបាក។ លើសពីនេះទៀត ការហៅឱ្យសិស្សស្ម័គ្រចិត្តឆ្លើយសំណួរបានបង្ហាញថា គ្មានប្រសិទ្ធភាពទេ ដោយហេតុថា ការធ្វើបែបនេះជំរុញឱ្យតែសិស្សណាដែលក្លាហានក្នុងការនិយាយប៉ុណ្ណោះ។ ចំណែកឯ សិស្សដែលមិនក្លាហាន ឬអៀនច្រើននឹងបាត់បង់ឱកាស ឬឈប់ចូលរួមតែម្តង (Walsh Sattes, 2016) ។

គ្រូត្រូវតែពិចារណាថាការសួរសំណួរ មិនមែនសុទ្ធតែនាំទៅដល់ការឆ្លើយត្រលប់វិញទាំងអស់នោះទេ។ ប្រសិនបើសិស្សមានការលំបាកក្នុងការឆ្លើយ គ្រូអាចសួរឡើងវិញ ឬអាចពន្យល់ន័យសំណួរឡើងវិញ។ ក្នុងន័យនេះគ្រូត្រូវតែរម្លឹកឡើងវិញពីចំណេះដឹងពីមុន ឬសួរសំណួរផ្សេងដែលអាចជួយឱ្យសិស្សស្វែងរកដំណោះស្រាយបាន (Sockalingam, 2011)។

សំណួរអាចត្រូវប្រើតាមវិធីផ្សេងៗគ្នាដើម្បីជួយណែនាំសិស្សនៅក្នុងដំណើរការនៃការរៀន។ វាអាចជាសំណួរងាយៗ ហើយអាចត្រួតពិនិត្យមើលភ្លាមៗ ថាតើប្រសិនកំពុងតែផ្តោតអារម្មណ៍លើសំណួរ ឬក៏ជាសំណួរដែលពិបាកដែលអាចឈានដល់ការដាក់ឱ្យពិភាក្សា។ មុនពេលសួរសំណួរនៅក្នុងថ្នាក់ គ្រូគួរតែពិចារណាទៅលើគោលបំណងនៃសំណួរ ថាតើសំណួរនោះមានភ្ជាប់ទំនាក់ទំនងរវាងគោលបំណងនៃមេរៀនដោយរបៀបណា និងថាតើគ្រូត្រូវធ្វើដូចម្តេចប្រសិនបើសិស្សមិនអាចឆ្លើយសំណួរបាន។ គ្រូគួរតែប្រើសំណួរបើកដែលនាំទៅដល់ការរៀនបែបសិស្សមជ្ឈមណ្ឌល និង ការរៀនបែបសកម្ម។ គ្រូល្អ គាំទ្រដល់ដំណើរការនៃការគិតរបស់សិស្សដោយណែនាំពួកគេតាមរយៈការពង្រឹងជំនាញចាំបាច់ដើម្បីដោះស្រាយបញ្ហា និងយល់ដោយមានហេតុផល (Keeble, 2016)។

តារាង៣៖ កម្រិតផ្សេងៗនៃសំណួរ (Costello 2020,online) [2]

កម្រិតនៃសំណួរ	ពាក្យគន្លឹះសម្រាប់សួរ
ដាក់ឈ្មោះ និងឱ្យនិយមន័យ	ចូរកំណត់អត្តសញ្ញាណ រម្លឹកឡើងវិញ ប្រាប់ឈ្មោះ រាប់ឡើងវិញ សង្ខេប
ពណ៌នា	ចូរពណ៌នា បង្ហាញ បែងចែក ចាត់ថ្នាក់
ពន្យល់	ចូរពន្យល់ ចាត់ថ្នាក់ ព្យាករណ៍ អនុវត្ត ធ្វើបង្ហាញ សង្ខេប

[2] Adapted from Costello (2020, online).

វិភាគ	ចូរអនុវត្ត គណនា ប្រៀបធៀប បែងចែក ពិនិត្យ
វិភាគបែបស៊ីជម្រៅ	ចូរប្រៀបធៀប ពិភាក្សា ណែនាំ
វាយតម្លៃ	ចូរវាយតម្លៃ កែតម្រូវ ព្យាករណ៍ ស្នើ ផ្តល់យោបល់

៥.៤- ការពិនិត្យតាមដាន

ការពិនិត្យតាមដានគឺជាជំនាញដ៏ចាំបាច់សម្រាប់គ្រូ ដើម្បីវាយតម្លៃទាំងមេរៀន និងការយល់មេរៀនរបស់សិស្ស។ តាមរយៈការតាមដានសមស្រប គ្រូអាចកំណត់បានថាតើសិស្សមានជាក់អារម្មណ៍ក្នុងការរៀន ថាតើមេរៀននេះពិបាកពេក ថាតើសិស្សមានសមត្ថភាពរៀនដូចគ្នាឬទេ មានសម្ភារៈគ្រប់គ្រាន់ឬទេ និងថាតើមេរៀននេះបានរៀបចំល្អឬទេជាដើម។ ដូចដែលបានរៀបរាប់ខាងលើរួចមកហើយការរៀបចំកិច្ចតែងការបង្រៀនបានល្អ និងការបង្កើតគោលបំណងនៃមេរៀនយ៉ាងហ្មត់ចត់ នឹងជួយឱ្យគ្រូមានភាពងាយស្រួលក្នុងការតាមដានសិស្ស (Kyriaeou,2009)។ Kyriaeou, 2009 បានលើកឡើងថាមានជំនាញសំខាន់ពីររួមបញ្ចូលគ្នាដែលអាចបង្ហាញថា គ្រូពិតជាមានសមត្ថភាពក្នុងការគ្រប់គ្រងសិស្សបានយ៉ាងមានប្រសិទ្ធភាព។ **ទី១** គ្រូត្រូវតែអាចវាយតម្លៃពីវឌ្ឍនភាពរបស់សិស្ស។ ដោយហេតុថានៅក្នុងថ្នាក់នីមួយៗគ្រូត្រូវវាយតម្លៃសិស្សម្នាក់ៗផ្សេងៗគ្នា។ ដូច្នេះ គ្រូចាំបាច់ត្រូវតែបង្កើតវិធីសាស្ត្រដើម្បីតាមដានសិស្សជាក្រុមធំៗ។ ឧទាហរណ៍ គ្រូអាចចូលរួមជាមួយសិស្សដោយផ្ទាល់ ការផ្លាស់ប្តូរពីក្រុមមួយទៅក្រុមមួយ (មិនមែនគ្រាន់តែឈរមើលទេ)។ គ្រូអាចប្រាប់សិស្សឱ្យសរសេរសំណួរទុកជាមុនបើមាន ហើយនៅពេលគ្រូទៅចូលរួមជាក្រុមណាមួយ ពួកគេអាចសួរសំណួរទៅកាន់គ្រូតែម្តង។ **ទីពីរ** គ្រូត្រូវមានសមត្ថភាពក្នុងការដោះស្រាយបញ្ហាផ្សេងៗ ក្នុងពេលដំណាលគ្នាបាន។ នេះមានន័យថាក្នុងខណៈដែលគ្រូ កំពុងស្តាប់សិស្សម្នាក់ និងអានឮៗ គាត់ក៏អាចត្រួតពិនិត្យកិច្ចការដែលសិស្សម្នាក់ទៀតបានធ្វើរួច ហើយក៏អាចណែនាំសិស្សទី៣អំពីធនធានបានដែរ។ លើសពីនេះទៅទៀតគ្រូត្រូវពិនិត្យដែរថា តើដល់ពេលដែលសិស្សត្រូវរៀបចំទៅផ្ទះ ឬ មើលថាតើពួកគេឡូឡាខ្លាំងពេក ឬត្រូវដើរមើលក្នុងថ្នាក់ថាតើអ្វីៗ

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

រៀបរយឬទេ។ល។ បញ្ហាអាចនឹងកើតមានឡើងប្រសិនបើ ការរៀបចំកិច្ចតែងការបង្រៀន និងសកម្មភាពនានា នៅក្នុងមេរៀនមានតម្រូវការខ្ពស់ពេកហើយគ្រូមិនអាចសម្រេចបាន។ បញ្ហានេះក៏នាំទៅដល់មិនយល់មេរៀនផងដែរ ដែលតម្រូវឱ្យគ្រូត្រូវជួយសិស្ស និងពិនិត្យមើលសិស្ស សូម្បីតែកិច្ចការតិចតួចក៏ដោយ។ ការបង្រៀនដែលមានប្រសិទ្ធភាពតម្រូវឱ្យមានការរៀបចំមេរៀនដែលអាចមានពេលគ្រប់គ្រាន់ដើម្បីត្រួតពិនិត្យកិច្ចការនានាក្នុងសកម្មភាពថ្នាក់រៀនទាំងមូ (Kyriacou,2009,93-94)។

ការរៀបចំកិច្ចតែងការបង្រៀនឱ្យបានល្អ និងជួយឱ្យការតាមដានសិស្សបានដំណើរការទៅដោយរលូន។ ផ្នែកមួយទៀតដ៏សំខាន់នៅក្នុងការតាមដានត្រួតពិនិត្យគឺការផ្តល់ព័ត៌មានត្រលប់ទៅឱ្យសិស្សវិញប្រកបដោយប្រសិទ្ធភាព។ ការផ្តល់ព័ត៌មានត្រលប់ទៅសិស្សអាចធ្វើជាលក្ខណៈផ្ទាល់ខ្លួន(ម្នាក់ម្តង) ធ្វើជារួមក្នុងថ្នាក់ ឬឱ្យសិស្សជាក់ពិន្ទុលើកិច្ចការរបស់គេទៅតាមចម្លើយដែលគ្រូផ្តល់ឱ្យស្រាប់។ វាក៏អាចធ្វើឡើងតាមរយៈការជាក់ពិន្ទុដោយផ្ទាល់មាត់ មិនផ្ទាល់មាត់ឬ រវាងមិត្តភក្តិក្នុងថ្នាក់។ ការផ្តល់មតិត្រលប់ដែលមានប្រសិទ្ធភាពផ្តោតទៅលើសកម្មភាព ឬកិច្ចការដែលកំពុងធ្វើ គួរតែធ្វើឱ្យបានទៀងទាត់នៅក្នុងដំណើរការនៃការរៀន ដើម្បីឱ្យបានដឹងថាតើសិស្សមានការលំបាក ឬងាយស្រួលយ៉ាងណា។ ប្រសិនបើសិស្សជួបការលំបាកក្នុងការរៀនសូត្រគ្រូគួរតែផ្តល់យោបល់ស្ថាបនាភ្លាមៗ។ បន្ថែមពីនោះ គ្រូគួរតែធ្វើឱ្យថ្នាក់រៀនជាកន្លែងដែលសិស្សអាចមើលឃើញថាការធ្វើខុស ឬឆ្លើយមិនត្រឹមត្រូវ ជាការរៀនមួយបែប។ ប្រសិនបើសិស្សមានការអៀនខ្មាស់ក្នុងការឆ្លើយខុស ពួកគេនឹងមិនមានឱកាសទទួលការកែលម្អ និងមិនសូវចង់ចូលរួមក្នុងកិច្ចការផ្សេងៗនៅពេលក្រោយទៀតផងដែរ (Kyriacou,2009)។

៥.៥- ការឆ្លុះបញ្ចាំង និងការវាយតម្លៃ

ការឆ្លុះបញ្ចាំង និងការវាយតម្លៃ ជាជំនាញបង្រៀនជាគោលដៃលនាំទៅដល់ការវិឌ្ឍបន្តនៃអ្នកអប់រំទាំងឡាយ។ គ្រូគួរតែធ្វើការឆ្លុះបញ្ចាំង និងវាយតម្លៃឱ្យបានញឹកញាប់ ពិសេសនៅបន្ទាប់ពីបញ្ចប់មេរៀន ឬនៅចុងបញ្ចប់នៃថ្ងៃរៀននីមួយៗដើម្បីដឹងថាតើបានសម្រេចគោលបំណងមេរៀនដោយជោគជ័យឬទេ និងដើម្បីកត់ត្រាពីការវិឌ្ឍរបស់សិស្ស។ គ្រូដែលចេះធ្វើការឆ្លុះបញ្ចាំង និងវាយតម្លៃទៅលើការបង្ហាញរបស់ខ្លួន និងទទួលបាននូវលទ្ធផលកាន់តែល្អប្រសើរក្នុងការបង្រៀនសិស្ស។ Hazel Pulley ជាប្រធានក្រុមបច្ចេកទេសបង្រៀន នៅសាលាបឋមសិក្សា

ParicfieldNCommunity នៃប្រទេសអង់គ្លេសបានដៃគូសបញ្ជាក់ថាប្រសិនបើចង់ឱ្យសិស្សមានការវិឌ្ឍបានរហ័ស គេត្រូវការគ្រូដែលមានចំណេះដឹងទាន់សម័យដ៏ពូកែនិង បានយល់ពីគុណភាពបង្រៀនដែលជាតម្រូវការ។ យើងបានដកឃ្លាចេញឆ្ងាយពីការធ្វើអង្កេតទៅលើមេរៀនជាផ្លូវការហើយ ដោយជំនួសវិញនូវភាពជាដៃគូនៃការរៀនបង្រៀន យើងបានការអភិវឌ្ឍដោយប្រើបច្ចេកវិទ្យា Video ការចូលពិនិត្យក្នុងថ្នាក់ឱ្យបានទៀងទាត់ និងការពិនិត្យវិនិយទៅលើការងារគោលក្នុងគោលបំណងអភិវឌ្ឍជំនាញវិជ្ជាជីវៈ។ ការវាយតម្លៃគឺជាចំណុចដ៏សំខាន់នៃ**ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ** (Continuous Professional Development, CPD)។ កាតព្វកិច្ចវិជ្ជាជីវៈរបស់គ្រូ និងសាលារៀនគឺអភិវឌ្ឍជំនាញវិជ្ជាជីវៈ ដើម្បីទទួលបានព័ត៌មាន ឬចំណេះដឹងបច្ចុប្បន្នភាពថ្មីនានានៅក្នុងវិស័យអប់រំ (Keeble,2016,14)។

ដូចដែលបានពណ៌នាពីខាងលើ ការវាយតម្លៃអាចទទួលបានពីភាគីខាងក្រៅ ប៉ុន្តែគ្រូអាចអនុវត្តការឆ្លុះបញ្ចាំង និងវាយតម្លៃដោយខ្លួនឯងដើម្បីស្វ័យអភិវឌ្ឍវិជ្ជាជីវៈរបស់ខ្លួន។ នៅក្នុងសៀវភៅ «ការបង្រៀនប្រកបដោយប្រសិទ្ធភាព» របស់ Ko et al,2016,21 មានគន្លឹះមួយចំនួន ដែលគ្រូអាចយកមកអនុវត្តជាយុទ្ធសាស្ត្រក្នុងការវាយតម្លៃខ្លួនឯង។ ដើម្បីចាប់ផ្តើមការវាយតម្លៃផ្ទាល់ខ្លួន គ្រូគួរតែសួរខ្លួនឯងថា ក្នុងនាមជាគ្រូ តើខ្ញុំ.....˝

- មានចំណេះដឹងទាន់សម័យ និងលម្អិតថ្មីៗទាក់ទងមុខវិជ្ជាដែលខ្ញុំបង្រៀនដែរឬទេ?
- បានរក្សាចំណូលចិត្ត និងការពេញចិត្តចំពោះមុខវិជ្ជាបង្រៀនដោយធ្វើខ្លួនឯងជាសិស្សផង ជាគ្រូផង ទាំងនៅក្នុងថ្នាក់ និងនៅក្រៅថ្នាក់ដែរ ឬទេ? ហើយតើខ្ញុំអាចប្រើចំណង់ចំណូលចិត្តចំពោះមុខវិជ្ជានោះ ដើម្បីលើកទឹកចិត្ត និងបំផុសគំនិតសិស្សឱ្យធ្វើអ្វីថ្មីដែរ ឬទេ?
- ផ្តល់គំរូការប្រព្រឹត្តល្អលើគ្រប់ជ្រុងនៃមុខវិជ្ជាដែលបង្រៀនដោយទៀងទាត់ ដើម្បីបញ្ជាក់ច្បាស់ពីការរំពឹងទុករបស់ខ្ញុំ និងលើកតម្កើងសេចក្តីប្រាថ្នារបស់គេដែរឬទេ?
- រៀបកិច្ចតែងការបង្រៀន និងកិច្ចការផ្សេងៗដើម្បីពង្រឹងការរៀន និងការវិឌ្ឍចំណេះដឹង ជំនាញចាំបាច់ និងការយល់របស់សិស្សដោយការផ្សារភ្ជាប់ចំណេះ

ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ
សំដៅទៅលើកាតព្វកិច្ចបែបអាជីពរបស់គ្រូបង្រៀន (និងសាលារៀន) ដើម្បីអភិវឌ្ឍជំនាញជាអាជីពរបស់ពួកគាត់ និងការទទួល បានព័ត៌មានថ្មីៗអំពីការវិឌ្ឍផ្សេងៗនៅក្នុងវិស័យអប់រំ (Keeble, 2016)

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ដឹងថ្មីទៅនឹងចំណេះដឹងពីមុន ហើយធ្វើឱ្យមានតុល្យភាពក្នុងការពង្រីកគំនិត ឬ ធនធានថ្មីដែរឬទេ?

- រៀបកិច្ចតែងការបង្រៀនដែលមានទម្រង់ផ្សេងៗគ្នា ដោយចាប់ផ្តើមពីការទាក់ទាញ ឱ្យសិស្សចូលរួមតាមរយៈចំណង់ចំណូលចិត្តសិស្ស ប្រាជ្ញា ឬភាពច្នៃប្រឌិត និង ប្រើវិធីដាក់សិស្សជាក្រុមការងារ តាមសកម្មភាពនានា និងធនធានដែលសមស្រប ដើម្បីលើកកម្ពស់ចំណង់ចំណូលចិត្តសិស្សដែរឬទេ?
- បញ្ជាក់ច្បាស់ពីការរំពឹងទុកនៃមេរៀននេះដែរឬទេ? តើខ្ញុំមានភ្ជាប់វាទៅនឹង សមត្ថភាពមានស្រាប់របស់សិស្ស ឥរិយាបថ និងបានពិនិត្យឡើងវិញគោលបំណង ទាំងអស់នេះដែរឬទេ?
- ផ្តល់ឱកាសឱ្យសិស្សធ្វើការស្រាវជ្រាវ ដោះស្រាយបញ្ហា ឬវិភាគ និងវាយតម្លៃ គំនិតអ្វីមួយនៅពេលណាមួយដែលសមស្របដែរឬទេ? តើខ្ញុំបានលើកទឹកចិត្ត សិស្សណាដែលមានទំនោរចង់ក្លាយជាអ្នកស្រាវជ្រាវ និងចេះវិភាគជាជាងជាអ្នក ចាំតែទទួលព័ត៌មានអសកម្មដែរឬទេ?
- ប្រើវិធីសួរសំណួរ ដើម្បីពង្រីកការគិតរបស់សិស្សដែលត្រូវគ្នានឹងកម្រិតនៃការទៅ ដល់គោលដៅនៃមេរៀនដែរឬទេ?
- ផ្តល់ពេលវេលាគ្រប់គ្រាន់ដល់សិស្សក្នុងការគិត ធ្វើការឆ្លុះបញ្ចាំង និងលំហាត់ ផ្សេងៗដែរឬទេ?
- កត់សម្គាល់ការអនុវត្តជាក់ស្តែង ថាជាមូលដ្ឋានគ្រឹះនៃការរៀនរបស់សិស្សគ្រប់ សមត្ថភាព ប៉ុន្តែបានប្រាកដថាកិច្ចការនោះផ្សារភ្ជាប់ទៅនឹងការវិភាគ និងការវាយ តម្លៃដែរឬទេ?
- ដាក់ពិន្ទុ និងធ្វើតេស្តលើកិច្ចការរបស់សិស្សទៅតាមស្ថានភាពជាក់ស្តែងដោយ មានផ្តល់ឱ្យសិស្ស ការណែនាំដ៏មានប្រយោជន៍ដែរឬទេតើខ្ញុំមានបានប្រើនូវតារាង វិនិច្ឆ័យពិន្ទុឬចំណាត់ថ្នាក់ដែលសិស្សធ្វើបានល្អ និងចំណុចត្រូវកែលម្អដែរ ឬទេ ?

ក្នុងខណៈដែលសំណួរទាំងអស់ខាងលើប្រើ ដើម្បីលើកកម្ពស់ការឆ្លុះបញ្ចាំង និងវាយតម្លៃពីខ្លួនឯងក្នុងន័យទូទៅ គ្រូអាចផ្តោតសំខាន់ជាពិសេសទៅលើមេរៀន

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

នីមួយៗ ដើម្បីឱ្យយល់ថាតើគោលបំណងនៃមេរៀនត្រូវធ្វើបានសម្រេចកម្រិតណា ហើយតើមេរៀននោះត្រូវបានរៀបចំ និងអនុវត្តដោយជោគជ័យ ឬទេ?

- តើមេរៀននោះដំណើរការទៅដោយរលូន ឬទេ?
- តើសកម្មភាពនានានៅក្នុងការរៀនត្រូវបានអនុវត្តដោយជោគជ័យ តាមកិច្ចតែងការបង្រៀនដែរឬទេ?
- តើសិស្សបានរៀនអ្វីខ្លះនៅក្នុងមេរៀននោះ ហើយតើខ្ញុំអាចដឹងបានដោយរបៀបណាថាសិស្សទទួលបានចំណេះដឹងថ្មីនោះ?
- តើមេរៀន និងការរៀនមានឆ្លុះបញ្ចាំងពីគោលដៅដែលបានកំណត់ ឬទេ?
- តើមានសិស្សណាម្នាក់ ឬមួយក្រុមណាមិនទទួលបានជោគជ័យនៅក្នុងមេរៀននេះ ឬទេ ប្រសិនបើមាន តើយើងអាចចៀ ?ឬទេ ?ដោយរបៀបណា ?
- ដើម្បីធ្វើឱ្យប្រសើរឡើង តើការផ្លាស់ប្តូរអ្វីដែលខ្ញុំអាចធ្វើបានមុនពេលបង្រៀនមេរៀនស្រដៀងគ្នានេះនៅក្នុងថ្នាក់នេះ ឬនៅថ្នាក់ដទៃទៀត?
- តើអ្វីដែលខ្ញុំបានរៀនពីការបង្រៀននៅក្នុងថ្នាក់នេះ ឬសិស្សណាម្នាក់ដែលអាចធ្វើឱ្យខ្ញុំកែប្រែនៅមេរៀនក្រោយៗទៀត?
- តើអ្វីដែលខ្ញុំបានរៀនពីការបង្រៀនមេរៀនចំណុចនេះ ដែលអាចធ្វើឱ្យខ្ញុំកែប្រែនៅមេរៀនក្រោយៗទៀត?
- តើខ្ញុំគួរចាត់វិធានការបន្ទាន់អ្វីខ្លះបន្ទាប់ពីបង្រៀនមេរៀននេះ?
- តើខ្ញុំមានការពេញចិត្តនឹងរបៀបដែលខ្ញុំរៀបមេរៀន បង្រៀនមេរៀននេះ និងគ្រប់គ្រងមេរៀននេះដែរឬទេ?
- តើមេរៀននេះមានគិតដល់ ការយកចិត្តទុកដាក់ និងចំណង់ចំណូលចិត្តសិស្សដែរឬទេ?
- តើមានបញ្ហាអ្វី ដែលបានកើតឡើងនៅក្នុងមេរៀន ដែលខ្ញុំគួរកត់សម្គាល់ដែរឬទេ?
- តើអាចបញ្ចូលខ្លឹមសារ ដែលខ្ញុំបានរៀនពីមេរៀននេះទៅមេរៀនក្រោយដោយរបៀបណា?
- តើមេរៀននេះត្រូវគ្នានឹងគោលដៅរបស់ក្រសួង សាលារៀន និងកម្មវិធីសិក្សាកម្រិតណា?(Kyriacou,2009, 96)

គ្រូដែលអនុវត្ត និងកែលម្អជំនាញនៃការឆ្លុះបញ្ចាំង និងវាយតម្លៃពីខ្លួនឯងជាទៀងទាត់អាច (ដោយប្រើសំណួរគោលខាងលើ)កំណត់បានពី ចំណុចខ្លាំង

ចំណុចខ្សោយ និងបញ្ហាប្រឈមបានល្អប្រសើរ។ បន្ទាប់មកគ្រូអាចបន្តដំណើរទៅមុខ ដោយកែលម្អការបង្រៀន សាកល្បងវិធីសាស្ត្របង្រៀនថ្មីៗ ឬអាចទទួលការជួយពីអ្នកដទៃដូចជាគ្រូបង្រៀនដូចគ្នា គ្រូបង្គោល ឬនាយកសាលាជាដើម។

រូប៣ ខាងក្រោមធ្វើការសង្ខេបពីទ្រឹស្តី យុទ្ធសាស្ត្រ និងជំនាញបង្រៀនដែលអាចអនុវត្តបានក្នុងការសិក្សានិងធ្វើឱ្យប្រសើរឡើងជាលំដាប់ និងផ្តល់ប្រយោជន៍បានទាំងគ្រូ និងសិស្ស។



រូបភាព៖ ទ្រឹស្តី យុទ្ធសាស្ត្រ និងជំនាញ

៦- ចំណុចគន្លឹះ

- ការយល់ពីរបៀបដែលសិស្សរៀនគឺ ពិតជាមានសារៈសំខាន់ដល់ការបង្រៀនឱ្យទទួលបានជោគជ័យ។
- គ្រូបង្រៀនដែលមានប្រសិទ្ធភាពមានជម្រើសច្រើនក្នុងការបង្រៀនបែបស៊ីជម្រៅនៅក្នុងថ្នាក់រៀនសិស្សអាចយល់ វាយតម្លៃ និងគិតវិភាគ ហើយអាចប្រើចំណេះដឹងនោះនៅពេលជួបបញ្ហាផ្សេងៗ។ ទ្រឹស្តីការរៀនបានផ្តល់មូលដ្ឋានគ្រឹះសម្រាប់តម្រូវការសិស្ស ហើយនាំទៅដល់ការរកយុទ្ធសាស្ត្របង្រៀនសមស្រប។
- នៅពេលដែលគ្រូយល់កាន់តែច្បាស់អំពីទ្រឹស្តីនៃការរៀន ពួកគាត់អាចធ្វើការសម្រេចចិត្តប្រកបដោយវិជ្ជាជីវៈអំពីរបៀបបង្រៀនសិស្ស។

- នៅក្នុងទ្រឹស្តីអាកប្បកិរិយានិយម សិស្សរៀនតាមរយៈការជំរុញណែនាំទាំងវិជ្ជមាន និងអវិជ្ជមានពីគ្រូ ថាតើអ្វីដែលពួកគេកំពុងតែធ្វើត្រូវ ឬខុស។
- នៅក្នុងទ្រឹស្តីការគិតនិយមការរៀន កើតឡើងតាមរយៈការធ្វើសកម្មភាពការយល់ដឹង និងការឆ្លុះបញ្ចាំងត្រលប់មកវិញ។ សិស្សមានតួនាទីយ៉ាងសកម្មដោយត្រូវធ្វើកិច្ចការដែលគ្រូដាក់ឱ្យដោយប្រើយុទ្ធសាស្ត្ររៀនសមស្រប ហើយគ្រូមានតួនាទីជាគ្រូបង្វឹក អ្នកផ្តួចផ្តើម ត្រួតពិនិត្យ និងគាំទ្រសិស្សក្នុងដំណើរការរៀន។
- ទ្រឹស្តីស្ថាបនានិយម បញ្ជាក់ថាសិស្សរៀនចំណេះដឹងថ្មីដោយផ្អែកលើចំណេះដឹងពីមុន។ គ្រូផ្តល់បទពិសោធ ដែលជំរុញឱ្យសិស្សកសាងចំណេះដឹងដោយខ្លួនឯង។
- ទ្រឹស្តីផ្សារភ្ជាប់និយម បង្ហាញថាសិស្សរៀនបានប្រសើរនៅពេលដែលពួកគេត្រូវបានដាក់ឱ្យធ្វើកិច្ចការជាក្រុមបណ្តាញ។ ពួកគេនឹងទទួលបានចំណេះដឹង និងបទពិសោធជាច្រើនពីការប្រាស្រ័យទាក់ទងជាមួយភាគីទី៣ ដូចជាបច្ចេកវិទ្យាក្រុមឬ បណ្តាញសង្គមនានា
- ការរៀនផ្តោតលើសិស្ស គឺការវិឌ្ឍនៃដំណើរការរៀនដោយផ្ទាល់ខ្លួនសិស្សដោយផ្អែកទៅលើមូលហេតុផ្ទាល់ខ្លួនសិស្សដែលមករៀន ជាជាងកត្តាខាងក្រៅ។ ដូច្នេះការរៀនកើតឡើងលុះត្រាតែសិស្សមានហេតុផលច្បាស់លាស់ក្នុងការរៀន
- ទ្រឹស្តីបែបស្ថាបនានិយម ទ្រឹស្តីផ្សារភ្ជាប់និយម និងទ្រឹស្តីផ្តោតលើសិស្សត្រូវបានចាត់ទុកថាជាទ្រឹស្តីដែលទាន់សម័យស៊ីគ្នាទៅនឹងវិធីសាស្ត្របង្រៀនដែលត្រូវនឹងតម្រូវការរបស់សិស្សនិងសង្គមពេលបច្ចុប្បន្ននេះ
- គ្រូគួរតែប្រើប្រាស់យុទ្ធសាស្ត្របង្រៀនផ្សេងៗគ្នាដែលត្រូវនឹងលទ្ធផលសិក្សាដែលចង់បាន រួមមានការបង្រៀនដោយផ្ទាល់ដូចជា ការធ្វើបទបង្ហាញ ការបង្រៀនដោយមិនផ្ទាល់ដូចជា ការដោះស្រាយបញ្ហា ករណីសិក្សាការបង្រៀន តាមរយៈបទពិសោធ ដូចជា ល្បែងសិក្សា ការសម្តែង ការរៀនបែបអន្តរកម្ម ដូចជា ការជជែកវែកញែក ការពិភាក្សានិងស្វ័យសិក្ស (ដូចជាគម្រោងស្រាវជ្រាវ លំហាត់ផ្សេងៗ
- នៅពេលរៀបកិច្ចតែងការបង្រៀន គ្រូត្រូវតែកំណត់វត្ថុបំណងមេរៀនឱ្យបានច្បាស់លាស់ ជ្រើសរើសយុទ្ធសាស្ត្របង្រៀនដែលមានប្រសិទ្ធភាព និងកំណត់វិធីវាយតម្លៃកម្រិតទទួលបានរបស់សិស្ស
- នៅពេលពន្យល់គំនិត និងចំណេះដឹងថ្មីដល់សិស្ស គ្រូគួរតែផ្តោតទៅលើការបញ្ចូលតារាង និងសន្លឹកប័ណ្ណដោយមានរាយឈ្មោះ ចំណុចគោលនានា ព្រមទាំងផ្តល់នូវរូបមន្ត វិធាន និងឧទាហរណ៍នានា។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- ការធ្វើបង្ហាញមានប្រសិទ្ធភាពផ្តល់ខ្លឹមសារយ៉ាងច្បាស់នៅពេលណាដែលសិស្ស អាចមើលឃើញ និងឮយ៉ាងច្បាស់នូវអ្វីដែលគ្រូបង្ហាញ ដោយមានការពន្យល់ និងការពិភាក្សាដោយផ្ទាល់
- មុនពេលប្រើយុទ្ធសាស្ត្រសួរសំណួរនៅក្នុងថ្នាក់រៀន គ្រូគួរតែពិចារណាអំពី គោលបំណងនៃសំណួរថាតើវាភ្ជាប់វត្ថុបំណងនៃមេរៀន និងអ្វីដែលសិស្សនឹង រៀនដោយរបៀបណា
- ប្រសិនបើសិស្សមិនអាចឆ្លើយសំណួរ ហើយនៅពេលមានឱកាសគ្រូគួរតែប្រើ សំណួរបើកដែលនាំដល់ការរៀនបែបសិស្សមជ្ឈមណ្ឌល និងបែបសកម្ម
- ការផ្តល់ការណែនាំដល់សិស្សដែលមានប្រសិទ្ធភាពគឺត្រូវដោយផ្តោតទៅលើកិច្ច ការពួកគេ និងធ្វើឱ្យបានទៀងទាត់ ក្នុងដំណើរការនៃការរៀន ដើម្បីឱ្យដឹងថា សិស្សមានជួបការលំបាកអ្វីខ្លះ
- គ្រូគួរតែធ្វើការឆ្លុះបញ្ចាំង និងវាយតម្លៃខ្លួនឯងឱ្យបានញឹកញាប់ ដូចជា បន្ទាប់ពី បញ្ចប់មេរៀន ឬនៅចុងបញ្ចប់នៃម៉ោងសិក្សានីមួយៗ ដើម្បីឱ្យដឹងថាតើមេរៀន នេះ បានទទួលជោគជ័យដោយសម្រេចគោលដៅនៃវត្ថុបំណងមេរៀន និងបាន កត់ត្រាពីការវិឌ្ឍរបស់សិស្ស

ឯកសារយោង

Ataizi, M. (2012). Situated Cognition. In: N.M. Seel, ed. *Encyclopedia of the Sciences of Learning*. Boston, MA: Springer.

Beard, C. & Wilson, J. P. (2018). *Experiential Learning: A Practical Guide for Training, Coaching and Education* (4th ed). Kogan Page Publishers.

Brown University. The Harriet W. Sheridan Center for Teaching and Learning. (n.d.) *Interactive Classroom Activities*. Retrieved from: https://www.brown.edu/sheridan/teaching-learning-resources/teaching-resources/classroom-practices/active-learning/interactive [2021, Jan. 04].

Costello, C. (2020). *ALARM - A Learning and Responding Matrix*. Retrieved from: https://www.virtuallibrary.info/alarm.html [2021, Mar. 18].

Ertmer, P. A. & Newby, T. J. (2013). Behaviorism, Cognitivism, Constructivism: Comparing Critical Features from an Instructional Design Perspective. *Performance Improvement Quarterly*, 26(2), 43-71.

Gillies, R. (2016). Cooperative Learning: Review of Research and Practice. *Australian Journal of Teacher Education*, 41(3), 39–51.

Grotlüschen, A. (2019). *Neo Subject-Scientific Learning Theory: A Reinterpretation 1*. Annual Review of Critical Psychology (ARCP) Vol 16.

Gupta, R. (2017). *Curriculum Design*. New Delhi: Friends Publications (India).

Hoff, D. J. (2003). Large-Scale Study Finds Poor Math, Science Instruction. *Education Week*, 23(1), 8.

Johnson, O. C. B., Documentation Team from Royal University of Law and Economics, & Royal University of Phnom Penh. (2016). *Quality Management of Educational Programmes in Cambodia*. ASEAN University Network.

Jonassen, D.H. & Hung, W. (2012). Problem-Based Learning. In: N.M. Seel, ed. *Encyclopedia of the Sciences of Learning*. Boston, MA: Springer.

Keeble, R. (2016). *Effective Primary Teaching Practice. 2016*. Teaching Schools Council. www.tscouncil.org.uk

Ko, J., Sammons, P., & Bakkum, L. (2016) *Effective Teaching*. Education Development Trust.

Ku, K., Ho, I., Hau, K., & Lai, E. (2014). Integrating Direct and Inquiry-Based Instruction in the Teaching of Critical Thinking: An Intervention Study. *Instructional Science*, 42, 251–269.

Kyriacou, C. (2009). *Effective Teaching in Schools: Theory and Practice* (3rd ed). Nelson Thornes.

Learning Theory (2020). Instructional Design Central. Retrieved from: https://www.instructionaldesigncentral.com/learning-theory [2021, Apr. 21].

Lee, J. & Seel N.M. (2012). Schema-Based Learning. In: N.M. Seel, ed. *Encyclopedia of the Sciences of Learning*. Boston, MA: Springer.

Lombardi, P. (2017). Direct Instruction: Chapter 4. In: *Instructional Methods, Strategies and Technologies to Meet the Needs of All Learners*. Retrieved from: https://granite.pressbooks.pub/teachingdiverselearners/chapter/direct-instruction/ [2021, May 31].

Newman University. (2018). *Primary School Experience Guidance Notes 1 Planning Lessons*. Retrieved from: https://www.newman.ac.uk/wp-

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

content/uploads/sites/10/2017/10/Primary-SE-GN1-Planning-1920.pdf [2021, Apr. 21].

Plüskow, A. P. (2015). *Methodenvielfalt im Unterricht – Wer die Wahl hat, hat die Qual!* Retrieved from: https://www.forrefs.de/grundschule/unterricht/unterricht-vorbereiten/ablaeufe-des-unterrichts/methodenvielfalt-im-unterricht-wer-die-wahl-hat-hat-die-qual.html [2021, Jan. 04].

Sanger, C.S. (2020). Inclusive Pedagogy and Universal Design Approaches of Diverse Learning Environments. In: C.S.Sanger & N. Gleason, eds. *Diversity and Inclusion in Global Higher Education* (pp. 31-71). Singapore: Palgrave Macmillan.

Saskatchewan Education. (1991). *Instructional Approaches: A Framework for Professional Practice*. Regina, SK: Saskatchewan Education.

Serrat, O. (2017). *Knowledge Solutions.* Singapore: Springer.

Siemens, G. (2017). Connectivism. In: *Foundations of Learning and Instructional Design Technology*. Retrieved from: https://lidtfoundations.pressbooks.com/chapter/connectivism-a-learning-theory-for-the-digital-age/ [2021, May 31].

Sockalingam, N. (2011). *Questioning Skills to Engage Students*. Retrieved from: https://www.facultyfocus.com/articles/teaching-and-learning/questioning-skills-to-engage-students/ [2021, Apr. 21].

Stronge, J. H. (2018). *Qualities of Effective Teachers* (3rd ed). Alexandria, Virginia: ASCD.

Tuomarla, K. (2019) *Activating Methods in Classroom.* Retrieved from: https://learningscoop.fi/activating-methods-in-classroom/ [2021, Jan. 04].

UNESCO. (2015). Booklet 3: Getting All Children in School and Learning. In: *Embracing Diversity: Toolkit for Creating Inclusive, Learning-Friendly Environments*. Retrieved from: https://unesdoc.unesco.org/ark:/48223/pf0000137522. ISBN 92-9223-032-8 (Electronic version).

UNESCO. (2015). Booklet 5: Managing Inclusive, Learning-Friendly Classrooms. In: *Embracing Diversity: Toolkit for Creating Inclusive, Learning-Friendly Environments*. Retrieved from: https://unesdoc.unesco.org/ark:/48223/pf0000137522. ISBN 92-9223-032-8 (Electronic version).

Walsh, J. A. & Sattes, B. D. (2016). *Quality Questioning: Research-Based Practice to Engage Every Learner*. Corwin Press.

Ward, B. A. (1987). *Instructional Grouping in the Classroom*. Retrieved from: https://educationnorthwest.org/sites/default/files/InstructionalGrouping.pdf [2021, Jan. 07].

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

លំហាត់អនុវត្ត

ជំហានទី១៖ ពង្រឹងចំណេះដឹង

ក.ចូរដាក់ទ្រឹស្តីនៃការរៀនទៅតាមនិយមន័យដែលត្រឹមត្រូវ៖

អាកប្បកិរិយានិយម ការគិតនិយម ផ្សារភ្ជាប់និយម ផ្តោតលើសិស្សនិយម ស្ថាបនានិយម

_____: ការរៀនកើតឡើងតាមរយៈធ្វើសកម្មភាព ការយល់ដឹង និងការឆ្លុះបញ្ចាំងត្រលប់វិញ។ សិស្សមានតួនាទីយ៉ាងសកម្មដោយត្រូវធ្វើកិច្ចការដែលគ្រូដាក់ឱ្យ ដោយប្រើយុទ្ធសាស្ត្ររៀនដែលសមស្រប ហើយគ្រូមានតួនាទីជាគ្រូបង្វឹក ដោយធ្វើជាអ្នកផ្តួចផ្តើម ត្រួតពិនិត្យនិងគាំទ្រសិស្សក្នុងដំណើរការរៀន។

_____: ការវិឌ្ឍនៃដំណើរការរៀនដោយផ្ទាល់ខ្លួន ដោយផ្អែកទៅលើមូលហេតុផ្ទាល់ខ្លួនដែលមករៀនជាជាងកត្តាខាងក្រៅ។ ដូច្នេះការរៀនកើតឡើងនៅពេលដែលសិស្សមានហេតុផលក្នុងការមករៀន។

_____: សិស្សរៀនបានប្រសើរនៅពេល ដែលពួកគេត្រូវបានដាក់នៅតាមក្រុមជំនាញ។ ពួកគេនឹងទទួលបានចំណេះដឹង និងបទពិសោធជាច្រើនពីការមានទំនាក់ទំនងជាមួយភាគីទី៣ ដូចជាបច្ចេកវិទ្យា ក្រុម ឬបណ្តាញសង្គមនានា។

_____: សិស្សរៀនតាមរយៈការពង្រឹងគំនិត ការណែនាំទាំងវិជ្ជមាន និងអវិជ្ជមានពីគ្រូថាតើអ្វីដែលពួកគេកំពុងតែធ្វើត្រូវ ឬខុស។

_____: សិស្សរៀនចំណេះដឹងថ្មី ដែលផ្អែកលើចំណេះដឹងពីមុន គ្រូផ្តល់បទពិសោធជំរុញឱ្យសិស្សបានកសាងចំណេះដឹងផ្ទាល់ខ្លួន។

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ចូរបំពេញតារាងខាងក្រោមដោយទាញយក អត្ថន័យសមស្រប ខាងក្រោមទៅជាក់ទៅតាមប្រភេទទ្រឹស្តីនីមួយៗ

១. យល់អំពីមូលហេតុនៃការរៀនរបស់សិស្ស	៦. ប្រើប្រាស់វិធីសាស្ត្រដោះស្រាយបញ្ហាដោយសកម្ម
២. ប្រើហេតុផល និងវង្វាន់	៧. ភ្ជាប់ទៅនឹងបទពិសោធន៍ពីមុនរបស់ខ្លួន
៣. ដើរតួនាទីជាគ្រូប្រឹក្សា/គ្រូណែនាំ	៨.ប្រើប្រាស់បណ្តាញសង្គមនានា
៤. ទទួលយកការជំរុញទឹកចិត្ត និងមតិណែនាំ	៩. មានការជំរុញទឹកចិត្តពីខ្លួនឯងផ្ទាល់
៥. ដើរតួជាដៃគូរៀន	១០. ដើរតួជាគ្រូបង្វឹក

	តួនាទីសិស្ស	តួនាទីគ្រូ
អាក្បកិរិយានិយម		
ការគិតនិយម		
ស្ថាបនានិយម		
ផ្សារភ្ជាប់និយម		
ផ្តោតលើសិស្សនិយម		

គ.យុទ្ធសាស្ត្រ និងវិធីសាស្ត្ររៀន និងបង្រៀន៖ ចូរបំពេញចន្លោះដោយប្រើវិធីសាស្ត្របង្រៀនខាងក្រោម៖

ការបង្រៀនដោយផ្ទាល់ ការបង្រៀនដោយមិនផ្ទាល់ ការបង្រៀនបែបអន្តរកម្ម

ការបង្រៀនដោយបទពិសោធ ស្វ័យសិក្សា

១ ._____: សិស្សរៀនពីមិត្តភក្តិ និងគ្រូរបស់គេតាមរយៈ ពិភាក្សានិងការចែករំលែក។

២ ._____: សកម្មភាពអប់រំនានា ត្រូវបានផ្តល់ឱ្យដោយគ្រូ ដើម្បីលើកកម្ពស់ការអភិវឌ្ឍគំនិតរបស់សិស្សម្នាក់ៗ ហើយដោយមានការដឹកនាំតិចតួច ឬគ្មានសោះពីគ្រូ។

៣._____: សិស្សមានការទទួលខុសត្រូវខ្ពស់ក្នុងការសម្រេចចិត្តពីការធ្វើ និងបំពេញកិច្ចការដោយគ្មានការបង្រៀនពីគ្រូ។

៤._____: កិច្ចការនានាត្រូវបានរៀបចំចាត់ចែងដោយគ្រូ ដែលជាអ្នកផ្តល់ព័ត៌មាន ដោយមានគោលដៅផ្តល់ព័ត៌មានដោយច្បាស់លាស់ និងមានលំដាប់លំដោយ។

៥._____: សិស្សរៀនបានល្អបំផុតនៅពេលដែលពួកគេបានឃើញ ឬប៉ះផ្ទាល់ជាមួយវត្ថុ ឬរបស់ដែលត្រូវរៀន មានន័យថាសិស្សទទួលបានចំណេះដឹងតាមរយៈបទពិសោធជាជាងការអាន ការស្តាប់ ឬការនិយាយ។

ឃ.ផ្គូផ្គងនិយមន័យនិងវិធីសាស្ត្រ៖ ចូរបំពេញតារាងដោយដាក់ពាក្យខាងក្រោមទៅក្នុងកន្លែងត្រឹមត្រូវ (ពាក្យខ្លះអាចប្រើបានច្រើនដង)

១.ការបង្កើតគំនិត	៩.ការបង្រៀនតាមរយៈបទពិសោធ
២.ការសម្តែង/ការធ្វើ	១០.គម្រោងស្រាវជ្រាវ
៣.ការបង្រៀនដោយផ្ទាល់	១១.រៀនជាមួយមិត្តភក្តិ
៤.កម្មសិក្សា	១២.សង្ខេបគំនិត
៥.ការបង្រៀនមិនផ្ទាល់	១៣.ស្វ័យសិក្សា
៦.ការបង្រើនតាមបែបអន្តរកម្ម	១៤.ការសាកសួរ
៧.ការដដែកវែកញែក	១៥.ការបង្រៀនដោយមានកុំព្យូទ័រជំនួយ
៨.ករណីសិក្សា	

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

#	និយមន័យ	វិធីសាស្ត្រ	យុទ្ធសាស្ត្រ
1	សិស្សបង្កើតសំណួរដើម្បីស្រាវជ្រាវ និងយកមកប្រើនៅក្នុងមេរៀន		
2	គ្រូរៀបចំធ្វើដំណើរទៅខាងក្រៅថ្នាក់ដើម្បី ផ្តល់បទពិសោធឱ្យសិស្សទទួលបានចំណេះដឹងផ្ទាល់ខ្លួនភ្លាមៗ		
3	សិស្សសិក្សាពីផ្នែកផ្សេងៗនៃប្រធានបទណាមួយដើម្បីស្វែងយល់ពីចំណេះដឹងផ្សេងៗនៃប្រធានបទនោះ		
4	បង្កើតសេណារីយ៉ូផ្សេងៗដែលមានពិតនៅក្នុងជីវិតឱ្យសមស្របទៅនឹងកម្រិតសិក្សារបស់សិស្ស ដើម្បីយកមកពិភាក្សានិងសង្ខេបគំនិតនៃដំណោះស្រាយនៃបញ្ហានោះ		
5	សិស្សរៀនដោយឯករាជ្យតាមរយៈកុំព្យូទ័រ)e-learning)		
6	សិស្សបង្រៀនគ្នា ឬជួយគ្នាទៅវិញទៅមកតាមរយៈ ការអនុវត្តទាំងអស់គ្នា។ ប្រើប្រាស់វិធី “Think,Pair, Share”(ធ្វើការជាដៃគូ)ដើម្បីជំរុញឱ្យសិស្សមានទំនាក់ទំនងគ្នា និងជួយគ្នាទទួលបានចំណេះដឹងថ្មីៗ។		
7	សិស្សភ្ជាប់ចំណុចផ្សេងៗដែលបានរៀនបញ្ចូលគ្នាដោយរៀបចំចាត់ចែងព័ត៌មានតាមរបៀបថ្មី។		
8	សិស្សត្រូវបានបង្ហាញបញ្ហា ឬស្ថានភាពប្រឌិតដែលផ្អែកលើរឿងពិត ហើយត្រូវបានដាក់ឱ្យដោះស្រាយជាពិសេសតាមរយៈការលេងល្បែងអប់រំដើម្បីលើកទឹកចិត្តឱ្យមានទំនាក់ទំនង និងជំរុញការគិតដោយមានហេតុផល។		

9	សិស្សស្រាវជ្រាវលើប្រធានបទណាមួយ(នៅផ្ទះ សាលា ឬបណ្ណាល័យ) ហើយធ្វើបទបង្ហាញពីលទ្ធផលស្រាវជ្រាវនោះតាមរយៈការសរសេររបាយការណ៍ ធ្វើបទបង្ហាញ ឬដៃគូ រូបគំនូរ ឬតាមវិធីច្នៃប្រឌិតផ្សេងៗ។		
10	សិស្សធ្វើការជាក្រុម ដើម្បីបង្កើតគំនិត		

ង. ចូរជ្រើសរើសចម្លើយមួយដែលត្រឹមត្រូវអំពីជំនាញបង្រៀនប្រកបដោយប្រសិទ្ធភាព។ មានចម្លើយត្រឹមត្រូវតែមួយគត់

១.តើចំណុចមួយណាដែលមិនមែនជាជំហានសំខាន់នៅពេលរៀបចំកិច្ចតែងការបង្រៀន?

ក.បង្កើតគោលបំណងមេរៀនផ្សារភ្ជាប់ទៅនឹងកម្មវិធីសិក្សា

ខ.ពិចារណាអំពីអ្វីដែលសិស្សបានដឹងអំពីមេរៀន

គ. រៀបចំកិច្ចតែងការបង្រៀន ដើម្បីឱ្យសិស្សមានកិច្ចការធ្វើជាបន្តបន្ទាប់

ឃ.គិតពីភាពខុសគ្នារវាងសិស្សទាំងអស់

២.នៅពេលពន្យល់មេរៀនថ្មី និងគំនិតថ្មីដល់សិស្សគ្រូគួរតែ

កុំប្រើវីដេអូ ឬបច្ចេកវិទ្យា.ក

ខ.តាមដានសិស្សក្នុងពេលពន្យល់ ដើម្បីឱ្យដឹងថាសិស្សបានយល់

គ.តែងតែធ្វើការពិសោធន៍

ឃ.សន្មត់ថាសិស្សយល់ បើសិនពួកគេគ្មានសំណួរ

៣.យោងទៅលើអត្ថបទខាងក្រោម តើមួយណាដែលជាឧទាហរណ៍នៃសំណួរដែលជំរុញឱ្យមានភាពច្នៃប្រឌិត និងការគិតប្រកបដោយហេតុផល?

ក.ត្រីបាឡែនគឺជាថនិកសត្វ ឬទេ?

ខ.តើ ៥ +១០=១៥មែនទេ?

គ.តើអ្នកគិតថាបុរសក្នុងរូបនេះសប្បាយចិត្ត ឬកើតទុក្ខ?

ឃ.តើចុងបញ្ចប់នៃរឿងធ្វើឱ្យអ្នកមានអារម្មណ៍យ៉ាងណា?

៤.ប្រសិនបើសិស្សមានការអៀនខ្មាសនៅពេលឆ្លើយ ឬធ្វើលំហាត់ខុស ពួកគេមានចំណង់ក្នុងការចូលរួមនៅពេលរៀនទៀតនៅក្រោយទៀត។

ក.ត្រូវ ខ.ខុស

៥.គ្រូដែលសួរខ្លួនឯងនូវសំណួរ «តើខ្ញុំពេញចិត្តនឹងវិធីដែលខ្ញុំបានរៀបចំធ្វើបទបង្ហាញ និងត្រួតពិនិត្យមេរៀននេះដែរឬទេ?» គឺជាឧទាហរណ៍នៃ៖

ក.ការធ្វើបង្ហាញ

ខ.ការពន្យល់

គ.ការត្រួតពិនិត្យ

ឃ.ការវាយតម្លៃ

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ជំហានទី២៖ អនុវត្ត

ក.ចូរអានឧទាហរណ៍នៃថ្នាក់រៀនខាងក្រោមរួចភ្ជាប់វាជាមួយនឹងទ្រឹស្តីនៃការរៀនដែលត្រឹមត្រូវ៖

អាកប្បកិរិយានិយម ការគិតនិយម ស្ថាបនានិយម ផ្សារភ្ជាប់និយម ផ្តោតលើសិស្សនិយម

១.សិស្សរបស់អ្នកគ្រូ-ខ កំពុងរៀនអំពីផែនទី និងការបង្ហាញផ្លូវ ហើយគាត់ចង់ ឱ្យសិស្សដាក់សញ្ញានៅលើផែនទីដោយខ្លួនឯង។ គាត់ដាក់ផែនទីលើក្តារខៀនដោយដាក់ទិសទាំងបួន ជើង(North) កើត(East) ត្បូង(South) និងលិច(West)។ គាត់ប្រាប់សិស្សរបស់គាត់ថាពេលខ្លះវាមានការលំបាកណាស់ក្នុងការចងចាំ។ ដូច្នេះគាត់បានបង្កើតឃ្លាមួយ ដើម្បីជួយសិស្សឱ្យងាយចងចាំ: Never Eat Sour Watermelon។ គាត់បានប្រាប់សិស្សឱ្យបង្កើតឃ្លាមួយដោយខ្លួនឯងដើម្បីងាយចងចាំទិសទាំង៤។ នេះគឺឧទាហរណ៍នៃ_____។

២.សិស្សរបស់អ្នកគ្រូ-ខ ទើបតែចាប់ផ្តើមរៀនមេរៀនអំពីសត្វល្អិត។ គាត់បានរូបភាពនៃសត្វទាំងនោះដែលពួកគេនឹងត្រូវនិយាយអំពីវា(ឧទាហរណ៍ : ស្រមោច អណ្តើកមាស ឃ្មុំ កន្ទុំរុយ) ហើយនិយាយថា "ខ្ញុំដឹងថាអ្នកទាំងអស់គ្នាបានដឹងច្រើនហើយអំពីសត្វទាំងអស់នេះ។" គាត់បែងចែកសិស្សជាក្រុម មានសមាជិកបីនាក់ ហើយឱ្យពួកគេសរសេរលើអ្វីដែលគេដឹងអំពីសត្វទាំងនោះ(ឧទាហរណ៍ដូចជា សត្វទាំង អស់នេះមានប្រមោយ ឬ ឃ្មុំផលិតទឹកឃ្មុំ ជាដើម)។ ១០នាទីក្រោយមក ពួកគេបញ្ចូលចម្លើយទាំងអស់ ចូលគ្នា។

នេះជាឧទាហរណ៍នៃ_____។

៣.នៅពេលសិស្សចូលថ្នាក់អ្នកគ្រូ-ខ ពួកគេដឹងពីអ្វីដែលត្រូវធ្វើ។ សិស្សម្នាក់ៗយកអាវទៅព្យួរទុក ដើរទៅកន្លែងដាក់ឯកសារផ្ទាល់ខ្លួន ហើយចាប់ផ្តើមធ្វើកិច្ចការ ដោយខ្លះធ្វើការជាដៃគូនៅលើឥដ្ឋក្នុងថ្នាក់ ខ្លះធ្វើម្នាក់ឯងនៅលើតុ។ នៅម៉ោង៨:១៥នាទី អ្នកគ្រូចាប់ផ្តើមចាក់ភ្លេង ហើយសិស្សទាំងអស់ដើរទៅកាន់តុរៀងៗខ្លួន និងឈរនៅទីនោះ។ នៅពេលដែលសិស្សគ្រប់គ្នាឈរនៅតុ អ្នកគ្រូ-B ចាប់ផ្តើមប្តូរចម្រៀង "អរុណសួស្តី" វិញ។ បន្ទាប់ពីច្រៀងចម្រៀងនេះទាំងអស់គ្នារួច សិស្សទាំងអស់ក៏អង្គុយចុះ។

នេះជាឧទាហរណ៍នៃ_____។

៤.បន្ទាប់ពីអាហារថ្ងៃត្រង់ អ្នកគ្រូ-ខ ដើរសំដៅទៅតុរបស់គាត់ ហើយយកប្រអប់មួយចេញមកដែលដាក់អក្សរថា "ប្រអប់ដំណោះស្រាយបញ្ហា"។ សិស្សត្រូវសរសេររៀបរាប់ពីបញ្ហាផ្ទាល់ខ្លួន (នៅសាលា ឬនៅផ្ទះ) ដាក់ក្នុងប្រអប់ ហើយក្នុងមួយសប្តាហ៍ ម្តងអ្នកគ្រូ-ខ អានបញ្ហាណាមួយឱ្យឮហើយឱ្យសិស្សក្នុងថ្នាក់ជួយដោះ

ស្រាយ។ ថ្ងៃនេះអ្នកគ្រូ-ខ អានរឿងមួយថា"បងប្រុសរបស់ខ្ញុំមិនចង់លេងជាមួយខ្ញុំទេនៅពេលគាត់មានមិត្តភក្តិលេងជាមួយ។ គាត់លេងជាមួយខ្ញុំ តែពេលដែលគាត់គ្មានមិត្តភក្តិហើយការធ្វើបែបនេះខ្ញុំមិនសប្បាយចិត្តទេ។" អ្នកគ្រូ -ខ បានបែងចែកសិស្សជាក្រុមតូចៗហើយឱ្យសិស្សរកដំណោះស្រាយ។១៥នាទីក្រោយមកពួកគេធ្វើបទបង្ហាញអំពីគំនិត/ដំណោះស្រាយរបស់ពួកគេ។

នេះជាឧទាហរណ៍នៃ_____។

៥.នៅក្នុងថ្នាក់គណិតវិទ្យា សិស្សរបស់អ្នកគ្រូ-ខ បានរៀនអំពីរបៀបប្រាប់ម៉ោង។ នៅចុងបញ្ចប់នៃមេរៀនអ្នកគ្រូបានឱ្យសិស្សមើលតារាងលេខ ដែលមានជម្រើសផ្សេងៗជាច្រើន។ គាត់ប្រាប់សិស្សថាពួកគេអាចជ្រើសរើសនូវជម្រើស២ពីក្នុងតារាង (ឧទាហរណ៍ បង្កើតនាឡិកាដោយខ្លួនឯង ហើយសួរមិត្តភក្តិៗឱ្យប្រាប់ម៉ោង ឬសរសេរពីកិច្ចការប្រចាំថ្ងៃ ដោយមានបញ្ជាក់ពីពេលវេលាដែលបានធ្វើសកម្មភាពនីមួយៗនោះ) ហើយចំណាយពេលនៅក្នុងថ្នាក់ដែលនៅសល់ធ្វើលំហាត់នេះ។

នេះជាឧទាហរណ៍នៃ_____។

ខ.ចូរមើលរូបភាពខាងក្រោម រួចផ្គូផ្គងរូបទៅនឹងវិធីសាស្ត្របង្រៀន

១. ការអនុវត្តផ្ទាល់ ២.ទស្សនកិច្ចសិក្សា ៣.ការធ្វើឧទ្ទេស ៤.គំរូ ៥.ការដាក់កិច្ចការឱ្យធ្វើ ៦.បំផុសគំនិត

3	6	6

[3] Picture Source: Own Pictures

t.me/moeysnews
sla.moeys.gov.kh
youtube.com/moeyscambodia

4	7	6

គ.ចូរមើលគំរូនៃកិច្ចតែងការបង្រៀនខាងក្រោម ហើយទាញយកឈ្មោះសកម្មភាពខាងក្រោមទៅដាក់នៅកន្លែងចន្លោះសមស្រប៖ ធ្វើការជាដៃគូ ត្រួតពិនិត្យ ភ្ជាប់ទៅនឹងកម្មវិធីសិក្សា មតិណែនាំរបស់គ្រូ ចំណេះដឹងពីមុន វត្ថុបំណងមេរៀន ការបង្រៀនដោយពន្យល់លម្អិត យុទ្ធសាស្ត្របង្រៀន សង្ខេបគំនិត កិច្ចការ សម្តែង មតិត្រលប់របស់សិស្ស ការសួរសំណួរ ការឆ្លុះបញ្ចាំងពីខ្លួនឯង។

<u>កិច្ចតែងការថ្នាក់វិទ្យាសាស្ត្រ</u>

ថ្នាក់ទី១

ប្រធានបទ៖ ជម្រកសត្វ

_____: នៅចុងបញ្ចប់នៃមេរៀនសិស្សអាចចាត់តារាង នៃជម្រកសត្វទាំង៥ សំខាន់ៗនិងអាចចាត់ថ្នាក់សត្វដែលរស់នៅតាមជម្រកនីមួយៗ។

_____: ដំណើរការនៃការរស់នៅ និងរបស់មានជីវិត

_____: នៅមេរៀនមុន សិស្សបានរៀនអំពីក្រុមនៃសត្វ ហើយនៅក្នុងថ្នាក់ភូមិវិទ្យាពួកគេ បានរៀនអំពីទីតាំងភូមិសាស្ត្រផ្សេងៗ នៃពិភពលោក។

[4] Picture Source: Open Source from pixabay.com

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ចាប់ផ្តើមមេរៀន

_____: សរសេរលើក្តារខៀន "តើមានអ្វីដែលសត្វទាំងអស់ត្រូវការដើម្បីរស់នៅ? "ហើយលើកទឹកចិត្តសិស្សឱ្យគិតពីភាពដូចគ្នារវាងមនុស្សនិងសត្វ។ សរសេរចម្លើយរបស់ពួកគេនៅលើក្តារខៀន។

_____: ឱ្យសិស្សចាប់ដៃគូហើយអង្គុយជាមួយគ្នានៅក្នុងថ្នាក់(កន្លែងណាក៏បាន)ពិភាក្សាពីសំណួរខាងលើ ហើយចែករំលែកជាមួយមិត្តរួមថ្នាក់ដទៃទៀត។ សរសេរចម្លើយទាំងអស់នៅលើក្តារខៀន។

_____: ពន្យល់សិស្សថាសត្វទាំងឡាយត្រូវការជម្រកដើម្បីរស់នៅដែលពួកគេអាចរកបាននូវអ្វីដែលពួកគេត្រូវការដើម្បីរស់។ សត្វប្រភេទផ្សេងគ្នាដែលមាន៥ប្រភេទសំខាន់ៗ ចូរអានអត្ថបទ "ជម្រក" របស់លោកWilliam B.B.Rice.

_____: នៅរៀងរាល់ពេល ដែលរកឃើញប្រភេទ "ជម្រក" ណាមួយបានពណ៌នាក្នុងសៀវភៅ សិស្សគួរតែលើកមេដៃឡើងជ្រើសរើសសិស្សម្នាក់ដើម្បីសរសេរនៅលើក្តារខៀន។

ការណែនាំអនុវត្ត

_____: ដាក់សិស្សជាក្រុមតូចៗ ហើយក្រុមមួយត្រូវទទួលខុសត្រូវ លើ "ជម្រក" មួយ។ ប្រាប់សិស្សថាពួកគេពេលនេះជាអ្នកវិទ្យាសាស្ត្រ ហើយពួកគេត្រូវបង្កើតជម្រកដែលជាកិច្ចការដាក់ឱ្យ។ ពួកគេត្រូវសរសេរឈ្មោះសត្វគ្រប់ប្រភេទដែលពួកគេគិតថានឹងត្រូវ រស់នៅក្នុងប្រភេទជម្រករបស់គេ។ ពួកគេគួរតែសរសេរឈ្មោះសត្វទាំងនោះនៅលើក្រដាសកត់ត្រា ហើយបិតវានៅពីក្រោមចំណងជើងជម្រករបស់ពួកគេនៅលើក្តារខៀន។ លើកទឹកចិត្តពួកគេទំនាក់ទំនងគ្នាដោយប្រើឃ្លាគោល "ខ្ញុំយល់ស្របថា_____អាចរស់នៅ_____ពីព្រោះថា_____។"

_____: ដើរមើលតាមក្រុម ហើយគ្រប់គ្រងសិស្ស ឱ្យធ្វើលើការងារនោះ។ តើពួកគេបានបញ្ចប់កិច្ចការនេះឬទេ? តើពួកគេទំនាក់ទំនងគ្នា

ដោយប្រើឃ្លាគោលដៅឬទេ? តោះពួកគេមានប្រើការគិតបែបស៊ីជម្រៅដែរឬទេ? តើពួកគេស្តាប់គ្នាទៅវិញទៅមកដែរឬទេ?

ការបញ្ចប់មេរៀន

_____: ដាក់សិស្សទាំងអស់ចូលគ្នាវិញហើយឱ្យពួកគេរម្លឹកពីកិច្ចការ ដែលបានធ្វើរួចលើក្រដាសកត់ត្រា។ ប្រាប់សិស្សថាពួកគេពិតជាធ្វើបានល្អណាស់ ដែលអាចរកឃើញប្រភេទសត្វជាច្រើនហើយសួរថា តើមានសិស្សណាចង់បន្ថែមចម្លើយ ឬរក្រុមរបស់សត្វទាំងនោះឡើងវិញ ឬទេ។

_____: ប្រសិនបើមានប្រភេទសត្វដែលត្រូវបានដាក់ខុស "ជម្រក"ហើយសិស្សមិនបានដឹងគ្រូអាចនិយាយថា "ខ្ញុំសម្គាល់ឃើញយើងបានដាក់ថាខ្លាឃ្មុំទឹកកករស់នៅតំបន់វាលខ្សាច់។ តើមាននរណាម្នាក់អាចគិត ដល់ជម្រកដ៏ប្រសើរជាងនេះ សម្រាប់ខ្លាឃ្មុំទឹកកកឬទេ?"។ ប្រសិនបើគ្មានសិស្សណាម្នាក់ឆ្លើយ ស្នើឱ្យសិស្សគិតជាមួយមិត្តភក្តិបន្តិចសិន។ ប្រសិនបើមានសិស្សឆ្លើយត្រូវគ្រូគួរតែសួរបន្តបន្ថែមថាហេតុអ្វីបានជាតំបន់ប៉ូលជា ជម្រកដ៏ប្រសើរបំផុតសម្រាប់ខ្លាឃ្មុំទឹកកក។

_____: ប្រាប់សិស្សថាពួកគេនឹងក្លាយទៅជាអ្នករុករក ស្រាវជ្រាវដោយដាក់ កិច្ចការឱ្យពួកគេរកសត្វ ដែលកំពុងរស់នៅក្នុងជម្រកនៅជិតសាលារៀនឬជិតផ្ទះរបស់ពួកគេ។ ពួកគេគួរតែដៃគូរូបសត្វនោះ ហើយធ្វើតារាងរាយឈ្មោះរបស់៥យ៉ាងដែលមាននៅក្នុងជម្រករបស់វា(ដូចជាស្មៅ ទឹក ដី រុក្ខជាតិ)។

_____: នៅពេលមេរៀនបានបញ្ចប់ គ្រូអាចសួរខ្លួនឯងថាតើសិស្សមានចំណាប់អារម្មណ៍ទៅលើមេរៀន បានចូលរួមអនុវត្ត កត់សម្គាល់ចំណុចអនុវត្តបានជោគជ័យ និងចំណុចដែលគួរកែលម្អពេលក្រោយ ឬអត់ប្រសិនបើប្រើកិច្ចតែងការនេះនៅឆ្នាំក្រោយតើត្រូវផ្លាស់ប្តូរចំណុចណាខ្លះ? ហើយហេតុអ្វី?[5]

[5] Adapted from education.com

ឃ. ចូរមើលគ្រូបង្រៀនម្នាក់និយាយអំពីការធ្វើកិច្ចតែងការបង្រៀន និងជំនាញគរុកោសល្យនានា។ (Video File 1.2.1; កំណត់ត្រាសំឡេងអាចរកបាននៅក្នុងឧបសម្ព័ន្ធនៃឯកសារនេះ)។ ចូរបង្ហាញថា ប្រយោគខាងក្រោមនេះត្រូវ(ត) ឬខុស (ខ)៖

១. គ្រូចាំបាច់ត្រូវពិចារណាពីប្រភេទ សិស្សនៅក្នុងថ្នាក់រៀននៅពេល ដែលធ្វើការជ្រើសរើសវិធីបង្រៀនឱ្យបានត្រឹមត្រូវ។ ត / ខ

២. ជាឧទាហរណ៍វិធីសាស្ត្រនៃការអង្កេត គឺដំបូងអនុញ្ញាតឱ្យសិស្សសង្កេតរូបភាព ហើយបន្ទាប់មកពណ៌នា ឬបញ្ចេញយោបល់លើរូបភាពនោះ។ ត / ខ

៣. វិធីសាស្ត្រអង្កេតមិនបានអភិវឌ្ឍនូវជំនាញគិតត្រិះរិះពិចារណាចំពោះសិស្សនោះទេ។ ត / ខ(ចម្លើយត្រឹមត្រូវ៖ វិធីសាស្ត្រសង្កេតពិតជាជួយអភិវឌ្ឍជំនាញត្រិះរិះពិចារណារបស់សិស្ស។)

ង. ចូរមើលលោកគ្រូបង្រៀនម្នាក់នេះគាត់និយាយអំពីការធ្វើកិច្ចតែងការបង្រៀន និងជំនាញគរុកោសល្យ។ (Video File 1.2.2; កំណត់ត្រាសំឡេងអាចរកបានក្នុងឧបសម្ព័ន្ធនៃឯកសារនេះ)។

ចូរឆ្លើយសំណួរពហុចម្លើយសម្រាប់ជ្រើសរើសខាងក្រោម។ អាចមានចម្លើយច្រើន៖

១. តើលោកគ្រូបង្រៀនម្នាក់នេះរៀបចំការបង្រៀនរបស់គាត់របៀបណា?

ក. គាត់មិនបានរៀបចំការបង្រៀនរបស់គាត់ទេ។

ខ. គាត់តែងតែរៀបចំធ្វើកិច្ចតែងការមេរៀនរបស់គាត់។

គ. គាត់រៀបចំគម្រោងត្រួសៗមួយពីអ្វីដែលគាត់នឹងបង្រៀន។

២. តើការធ្វើកិច្ចតែងការបង្រៀនរបស់គាត់រាប់បញ្ចូលធាតុអ្វីខ្លះ?

ក. គោលបំណងនៃមេរៀន

ខ. ការប្រើប្រាស់សម្ភារៈ (ដូចជា សៀវភៅពុម្ព)

គ. បរិបទរបស់មេរៀន

៣. តើគាត់ពិសោធការរៀបចំកិច្ចតែងការមេរៀនរបស់គាត់របៀបណា?

ក. ជាផែនទីនៃការបង្កើតលទ្ធផលសិក្សា

ខ. ជាផែនទីសម្រាប់ថ្នាក់រៀនដោយរាប់បញ្ចូលទាំងសិស្សម្នាក់ៗ

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

គ. ជាផែនទីសម្រាប់បរិយាកាសសិក្សា

៤. តើគាត់ប្រើវិធីសាស្ត្រប្រភេទអ្វីខ្លះ?

ក. វិធីសាស្ត្រ “គិត ធ្វើការជាដៃគូ ចែករំលែក”

ខ. វិធីសាស្ត្រ “តុមូល”

គ. វិធីសាស្ត្រ “ល្បែងផ្គុំរូបភាព”

ចម្លើយអនុវត្ត

ជំហានទី១៖ ពង្រឹងចំណេះដឹង

ក.ចូរដាក់ទ្រឹស្តីនៃការរៀនទៅតាមនិយមន័យដែលត្រឹមត្រូវ៖

អាកប្បកិរិយានិយម ការគិតនិយម ផ្សារភ្ជាប់និយម ផ្តោតលើសិស្សនិយម ស្ថាបនានិយម

ការគិតនិយម : ការរៀនកើតឡើងតាមរយៈធ្វើសកម្មភាព ការយល់ដឹង និងការឆ្លុះបញ្ចាំងត្រលប់វិញ។ សិស្សមានតួនាទីយ៉ាងសកម្មដោយត្រូវធ្វើកិច្ចការដែលគ្រូដាក់ឱ្យដោយប្រើយុទ្ធសាស្ត្ររៀនដែលសមស្រប ហើយគ្រូមានតួនាទីជាគ្រូបង្វឹកដោយធ្វើជាអ្នក ផ្តួចផ្តើម ត្រួតពិនិត្យ និងគាំទ្រសិស្សក្នុងដំណើរការរៀន។

ស្ថាបនានិយម : ការវិឌ្ឍនៃដំណើរការរៀនដោយផ្ទាល់ខ្លួន ដោយផ្អែកទៅលើមូលហេតុផ្ទាល់ខ្លួនដែលមករៀនជាជាងកត្តាខាងក្រៅ។ ដូច្នេះការរៀនកើតឡើងនៅពេលដែលសិស្សមានហេតុផលក្នុងការមករៀន។

ផ្តោតលើសិស្សនិយម : សិស្សរៀនបានប្រសើរនៅពេល ដែលពួកគេត្រូវបានដាក់នៅតាមក្រុមជំនាញ។ ពួកគេនឹងទទួលបានចំណេះដឹង និងបទពិសោធជាច្រើនពីការមានទំនាក់ទំនងជាមួយភាគីទី៣ ដូចជាបច្ចេកវិទ្យា ក្រុម ឬបណ្តាញសង្គមនានា។

អាកប្បកិរិយានិយម : សិស្សរៀនតាមរយៈការពង្រឹងគំនិត ការណែនាំទាំងវិជ្ជមាន និងអវិជ្ជមានពីគ្រូថាតើអ្វីដែលពួកគេកំពុងតែធ្វើត្រូវ ឬខុស។

<u>ផ្សារភ្ជាប់និយម</u> : សិស្សរៀនចំណេះដឹងថ្មីដែលផ្អែកលើចំណេះដឹងពីមុន គ្រូផ្តល់បទពិសោធ ជំរុញឱ្យសិស្សបានកសាងចំណេះដឹងផ្ទាល់ខ្លួន។

ចូរបំពេញតារាងខាងក្រោមដោយទាញយក អត្ថន័យសមស្រប ខាងក្រោមទៅជាក់ទៅតាមប្រភេទទ្រឹស្តីនីមួយៗ

១ យល់អំពីមូលហេតុនៃការរៀនរបស់សិស្ស.	៦ប្រើប្រាស់វិធីសាស្ត្រដោះស្រាយបញ្ហាដោយសកម្ម.
២ប្រើ.ហេតុផល និងរង្វាន់	៧ភ្ជាប់ទៅនឹងបទពិសោធពីមុនរបស់ខ្លួន.
៣ដើរតួនាទីជាគ្រូ.ប្រឹក្សា/អ្នកណែនាំ	៨ប្រើប្រាស់បណ្តាញសង្គមនានា.
៤ទទួលយកការ.ជំរុញទឹកចិត្ត និងមតិណែនាំ	៩មានការ.ជំរុញទឹកចិត្តពីខ្លួនឯងផ្ទាល់
៥ដើរតួជា.ដៃគូរៀន	១០ដើរតួជាគ្រូបង្វឹក.

	តួនាទីសិស្ស	តួនាទីគ្រូ
អាក្បកិរិយានិយម	៤	២
ការគិតនិយម	៦	១០
ស្ថាបនានិយម	៧	៥
ផ្សារភ្ជាប់និយម	៨	៣
ផ្តោតលើនិយាមសិស្ស	៩	១

គ.យុទ្ធសាស្ត្រ និងវិធីសាស្ត្ររៀន និងបង្រៀន៖ ចូរបំពេញចន្លោះដោយប្រើវិធីសាស្ត្របង្រៀនខាងក្រោម៖

ការបង្រៀនដោយផ្ទាល់ ការបង្រៀនដោយមិនផ្ទាល់ ការបង្រៀនបែបអន្តរកម្មការបង្រៀនដោយបទពិសោធ ស្វ័យសិក្សា

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

១. **<u>ការបង្រៀនបែបអន្តរកម្ម</u>** : សិស្សរៀនពីមិត្តភក្តិ និងគ្រូរបស់គេតាមរយៈ ពិភាក្សានិងការចែករំលែក។

២. **<u>ស្វ័យសិក្សា</u>** : សកម្មភាពអប់រំនានាត្រូវបានផ្តល់ឱ្យ ដោយគ្រូដើម្បីលើកកម្ពស់ការអភិវឌ្ឍគំនិតរបស់សិស្សម្នាក់ៗហើយដោយមានការដឹកនាំតិចតួច ឬគ្មានសោះពីគ្រូ។

៣. **<u>ការបង្រៀនដោយមិនផ្ទាល់</u>** : សិស្សមានការទទួលខុសត្រូវខ្ពស់ ក្នុងការសម្រេចចិត្តពីការធ្វើ និងបំពេញកិច្ចការដោយគ្មានការបង្រៀនពីគ្រូ។

៤. **<u>ការបង្រៀនដោយផ្ទាល់</u>** : កិច្ចការនានាត្រូវបានរៀបចំចាត់ចែងដោយគ្រូ ដែលជាអ្នកផ្ត)ល់ព័ត៌មាន ដោយមានគោលដៅផ្តល់ព័ត៌មានដោយច្បាស់លាស់ និងមានលំដាប់លំដោយ។

៥. **<u>ការបង្រៀនដោយបទពិសោធ</u>**: សិស្សរៀនបានល្អបំផុតនៅពេលដែលពួកគេបានឃើញ ឬប៉ះផ្ទាល់ជាមួយវត្ថុ ឬរបស់ដែលត្រូវរៀន មានន័យថាសិស្សទទួលបានចំណេះដឹងតាមរយៈបទពិសោធជាជាងការអាន ការស្តាប់ ឬការនិយាយ។

ឃ. ផ្គូផ្គងនិយមន័យនិងវិធីសាស្ត្រ៖ ចូរបំពេញតារាងដោយដាក់ពាក្យខាងក្រោមទៅក្នុងកន្លែងត្រឹមត្រូវ (ពាក្យខ្លះអាចប្រើបានច្រើនដង)

១ ការបង្កើតគំនិត.	៩ការបង្រៀនតាមរ.យៈបទពិសោធ
២ការ.សម្តែង/ការធ្វើ	១០.គម្រោងស្រាវជ្រាវ
៣ ការបង្រៀនដោយផ្ទាល់.	១១រៀនជាមួយមិត្តភក្តិ.
៤ កម្មសិក្សា.	១២សង្ខេបគំនិត.
៥ការបង្រៀន.មិនផ្ទាល់	១៣ស្វ័យសិក្សា.
៦ ការបង្រៀនតាមបែបអន្តរកម្ម.	១៤ការសាកសួរ.
៧ ការជជែកវែកញែក.	១៥.ការបង្រៀនដោយមានកុំព្យូទ័រជំនួយ
៨ករណីសិក្សា.	

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

#	និយមន័យ	វិធីសាស្ត្រ	យុទ្ធសាស្ត្រ
1	សិស្សបង្កើតសំណួរដើម្បីស្រាវជ្រាវ និងយកមកប្រើនៅក្នុងមេរៀន	១៣	៤
2	គ្រូរៀបចំធ្វើដំណើរទៅខាងក្រៅថ្នាក់ដើម្បី ផ្តល់បទពិសោធឱ្យសិស្សទទួលបានចំណេះដឹងផ្ទាល់ខ្លួន ភ្លាមៗ	៣	៨
3	សិស្សសិក្សាពីផ្នែកផ្សេងៗនៃប្រធាបបទណាមួយដើម្បីស្វែងយល់ពីចំណេះដឹងផ្សេងៗនៃប្រធានបទនោះ	៦	៥
4	បង្កើតសេណារីយ៉ូផ្សេងៗដែលមានពិតនៅក្នុងជីវិតឱ្យសមស្របទៅនឹងកម្រិតសិក្សារបស់សិស្ស ដើម្បីយកមកពិភាក្សានិងសង្ខេបគំនិតនៃដំណោះស្រាយនៃបញ្ហានោះ	៧	៤
5	សិស្សរៀនដោយឯករាជ្យតាមរយៈកំព្យូទ័រ)e-learning)	១៤	១២
6	សិស្សបង្រៀនគ្នា ឬជួយគ្នាទៅវិញទៅមកតាមរយៈ ការអនុវត្តទាំងអស់គ្នា។ ប្រើប្រាស់វិធី “Think,Pair, Share” (ធ្វើការជាដៃគូ)ដើម្បីជំរុញឱ្យសិស្សមានទំនាក់ទំនងគ្នា និងជួយគ្នាទទួលបានចំណេះដឹងថ្មីៗ។	១០	៥
7	សិស្សភ្ជាប់ចំណុចផ្សេងៗដែលបានរៀនបញ្ចូលគ្នាដោយរៀបចំចាត់ចែងព័ត៌មានតាមរបៀបថ្មី។	១	៤

8	សិស្សត្រូវបានបង្ហាញបញ្ហា ឬស្ថានភាពប្រឌិតដែលផ្អែកលើរឿងពិត ហើយត្រូវបានដាក់ឱ្យដោះស្រាយជាពិសេសតាមរយៈការលេងល្បែងអប់រំដើម្បីលើកទឹកចិត្តឱ្យមានទំនាក់ទំនង និងជំរុញការគិតដោយមានហេតុផល។	២	៨
9	សិស្សស្រាវជ្រាវលើប្រធានបទណាមួយ(នៅផ្ទះ សាលា ឬបណ្ណាល័យ) ហើយធ្វើបទបង្ហាញពីលទ្ធផលស្រាវជ្រាវនោះតាមរយៈការសរសេររបាយការណ៍ ធ្វើបទបង្ហាញ ឬដៃគូរួបគំនូរ ឬតាមវិធីច្នៃប្រឌិតផ្សេងៗ។	៩	១២
10	សិស្សធ្វើការជាក្រុម ដើម្បីបង្កើតគំនិត	១១	៥

ង. ចូរជ្រើសរើសចម្លើយមួយដែលត្រឹមត្រូវអំពីជំនាញបង្រៀនប្រកបដោយប្រសិទ្ធភាព។ មានចម្លើយត្រឹមត្រូវតែ១គត់

១តើ.ចំណុចមួយណាដែលមិនមែនជាជំហានសំខាន់នៅពេលរៀបចំកិច្ចតែងការបង្រៀន?

កបង្កើតគោលបំណងមេរៀន. ផ្សារភ្ជាប់ទៅនឹងកម្មវិធីសិក្សា

ខពិចារណាអំពីអ្វីដែលសិស្សបានដឹងអំពីមេរៀន.

គរៀបចំកិច្ចតែងការ.បង្រៀន ដើម្បីឱ្យសិស្សមានកិច្ចការធ្វើជាបន្តបន្ទាប់

ឃគិតពីភាពខុសគ្នារវាងសិស្សទាំងអស់.

២នៅពេលពន្យល់.មេរៀនថ្មី និងគំនិតថ្មីដល់សិស្សគ្រូគួរតែ

កុំប្រើវីដេអូ ឬបច្ចេកវិទ្យា.ក

ខតាមដានសិស្សក្នុងពេលពន្យល់. ដើម្បីឱ្យដឹងថាសិស្សបានយល់

គតែងតែធ.្វើការពិសោធ

ឃ.សន្មតថាសិស្សយល់. បើសិនពួកគេគ្មានសំណួរ

៣.យោងទៅលើអ.ត្ថបទខាងក្រោម តើមួយណាដែលជាឧទាហរណ៍នៃសំណួរដែលជំរុញឱ្យមានភាពច្នៃប្រឌិត និងការគិតប្រកបដោយហេតុផល?

ក.ត្រីបាឡែនគឺជាថនិកសត្វ. ឬទេ?

តើ៥.ខ +១០=១៥មែនទេ?

គ.តើអ្នកគិតថាបុរសក្នុងរូបនេះសប្បាយចិត្ត ឬកើតទុក្ខ?

ឃ.តើចុងបញ្ចប់នៃរឿងធ្វើឱ្យអ្នកមានអារម្មណ៍យ៉ាងណា?

៤.ប្រសិនបើសិស្សមានការអៀនខ្មាសនៅពេលឆ្លើយ ឬធ្វើលំហាត់ខុស ពួកគេមានចំណង់ក្នុងការចូលរួមនៅពេលរៀនទៀតនៅក្រោយទៀត។

ក.ត្រូវ **ខ.ខុស**

៥.គ្រូដែលសួរខ្លួនឯងនូវសំណួរ «តើខ្ញុំពេញចិត្តនឹងវិធីដែលខ្ញុំបានរៀបចំធ្វើបទបង្ហាញ និងត្រួតពិនិត្យមេរៀននេះដែរឬទេ?» គឺជាឧទាហរណ៍នៃ៖

ក.ការធ្វើបង្ហាញ

ខ.ការពន្យល់

គ.ការត្រួតពិនិត្យ

ឃ.ការវាយតម្លៃ

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ជំហានទី២៖ ចម្លើយអនុវត្ត

ក.ចូរអានឧទាហរណ៍នៃថ្នាក់រៀនខាងក្រោមរួចភ្ជាប់វាជាមួយនឹងទ្រឹស្តីនៃការរៀនដែលត្រឹមត្រូវ៖

អាកប្បកិរិយានិយម ការគិតនិយម ស្ថាបនានិយម ផ្សារភ្ជាប់និយម ផ្តោតលើសិស្សនិយម

១.សិស្សរបស់អ្នកគ្រូ-ខ កំពុងរៀនអំពីផែនទី និងការបង្ហាញផ្លូវ ហើយគាត់ចង់ ឱ្យសិស្សដាក់សញ្ញានៅលើផែនទីដោយខ្លួនឯង។ គាត់ដាក់ផែនទីលើក្តារខៀនដោយដាក់ទិសទាំងបួនជើង(North) កើត(East) ត្បូង(South) និងលិច(West)។ គាត់ប្រាប់សិស្សរបស់គាត់ថាពេលខ្លះវាមានការលំបាកណាស់ក្នុងការចងចាំ។ ដូច្នេះគាត់បានបង្កើតឃ្លាមួយ ដើម្បីជួយសិស្សឱ្យងាយចងចាំ: Never Eat Sour Watermelon។ គាត់បានប្រាប់សិស្សឱ្យបង្កើតឃ្លាមួយដោយខ្លួនឯងដើម្បីងាយចងចាំទិសទាំង៤។ នេះគឺឧទាហរណ៍នៃ **ការគិតនិយម** ។

២.សិស្សរបស់អ្នកគ្រូ-ខ ទើបតែចាប់ផ្តើមរៀនមេរៀនអំពីសត្វល្អិត។ គាត់បានរូបភាពនៃសត្វទាំងនោះដែលពួកគេនឹងត្រូវនិយាយអំពីវា(ឧទាហរណ៍ស្រមោច អណ្តើកមាស ឃ្មុំ កន្ទុំរុយ) ហើយនិយាយថា "ខ្ញុំដឹងថាអ្នកទាំងអស់គ្នាបានដឹងច្រើនហើយអំពីសត្វទាំងអស់នេះ។" គាត់បែងចែកសិស្សជាក្រុមមានសមាជិកបីនាក់ ហើយឱ្យពួកគេសរសេរលើអ្វីដែលគេដឹងអំពីសត្វទាំងនោះ(ឧទាហរណ៍ដូចជា សត្វទាំងអស់នេះមានប្រមោយ ឬ ឃ្មុំផលិតទឹកឃ្មុំ ជាដើម)។ ១០នាទីក្រោយមក ពួកគេបញ្ចូលចម្លើយទាំងអស់ចូលគ្នា។ នេះជាឧទាហរណ៍នៃ **ផ្សារភ្ជាប់និយម** ។

៣.នៅពេលសិស្សចូលថ្នាក់អ្នកគ្រូ-ខ ពួកគេដឹងពីអ្វីដែលត្រូវធ្វើ។ សិស្សម្នាក់ៗយកអាវទៅព្យួរទុក ដើរទៅកន្លែងដាក់ឯកសារផ្ទាល់ខ្លួន ហើយចាប់ផ្តើមធ្វើកិច្ចការ ដោយខ្លះធ្វើការជាដៃគូនៅលើឥដ្ឋក្នុងថ្នាក់ ខ្លះធ្វើម្នាក់ឯងនៅលើតុ។ នៅម៉ោង៨:១៥នាទីអ្នកគ្រូចាប់ផ្តើមចាក់ភ្លេង ហើយសិស្សទាំងអស់ដើរទៅកាន់តុរៀងៗខ្លួន និងឈរនៅទីនោះ។ នៅពេលដែលសិស្សគ្រប់គ្នាឈរនៅតុ អ្នកគ្រូ-B ចាប់ផ្តើមប្តូរចម្រៀង "អរុណសួស្តី" វិញ។ បន្ទាប់ពីច្រៀងចម្រៀងនេះទាំងអស់គ្នារួច សិស្សទាំងអស់ក៏អង្គុយចុះ។ នេះជា ឧទាហរណ៍នៃ **អាកប្បកិរិយានិយម** ។

៤.បន្ទាប់ពីអាហារថ្ងៃត្រង់ អ្នកគ្រូ-ខ ដើរសំដៅទៅតុរបស់គាត់ ហើយយកប្រអប់មួយចេញមកដែលដាក់អក្សរថា "ប្រអប់ដំណោះស្រាយបញ្ហា"។ សិស្សត្រូវសរសេររៀបរាប់ពីបញ្ហាផ្ទាល់ខ្លួន (នៅសាលា ឬនៅផ្ទះ) ដាក់ក្នុងប្រអប់ ហើយក្នុងមួយសប្តាហ៍ ម្តងអ្នកគ្រូ-ខ អានបញ្ហាណាមួយឱ្យឮ ហើយឱ្យសិស្សក្នុងថ្នាក់ជួយដោះស្រាយ។ ថ្ងៃនេះអ្នកគ្រូ-ខ អានរឿងមួយថា "បងប្រុសរបស់ខ្ញុំមិនចង់លេងជាមួយខ្ញុំទេនៅពេលគាត់មានមិត្តភក្តិលេងជាមួយ។ គាត់លេងជាមួយខ្ញុំ តែពេលដែលគាត់គ្មានមិត្តភក្តិហើយការធ្វើបែបនេះ

ខ្ញុំមិនសប្បាយចិត្តទេ។" អ្នកកគ្រូ-ខ បានបែងចែកសិស្សជាក្រុមតូចៗហើយឱ្យសិស្សរកដំណោះស្រាយ។ ១៥នាទីក្រោយមកពួកគេធ្វើ បទបង្ហាញអំពីគំនិត/ដំណោះស្រាយរបស់ពួកគេ។ នេះជាឧទាហរណ៍នៃ **<u>ស្ថាបនានិយម</u>** ។

៥.នៅក្នុងថ្នាក់គណិតវិទ្យា សិស្សរបស់អ្នកគ្រូ-ខ បានរៀនអំពីរបៀបប្រាប់ម៉ោង។ នៅចុងបញ្ចប់នៃមេរៀនអ្នកគ្រូបានឱ្យសិស្សមើលតារាងលេខ ដែលមានជម្រើសផ្សេងៗជាច្រើន។ គាត់ប្រាប់សិស្សថាពួកគេអាចជ្រើសរើសនូវជម្រើស២ពីក្នុងតារាង (ឧទាហរណ៍ បង្កើតនាឡិកាដោយខ្លួនឯង ហើយសួរមិត្តកក្តិឱ្យប្រាប់ម៉ោង ឬសរសេរពីកិច្ចការប្រចាំថ្ងៃដោយមានបញ្ជាក់ពីពេលវេលាដែលបានធ្វើសកម្មភាពនីមួយៗនោះ) ហើយចំណាយពេលនៅក្នុងថ្នាក់ដែលនៅសល់ធ្វើលំហាត់នេះ។ នេះជាឧទាហរណ៍នៃ**<u>ផ្តោតលើសិស្សនិយម</u>** ។

ខ.ចូរមើលរូបភាពខាងក្រោម រួចផ្គូផ្គងរូបទៅនឹងវិធីសាស្ត្របង្រៀន

១. ការអនុវត្តផ្ទាល់ ២.ទស្សនកិច្ចសិក្សា ៣.ការធ្វើឧទ្ទេស ៤.គំរូ ៥.ការដាក់កិច្ចការឱ្យធ្វើ ៦.បំផុសគំនិត

6	6	6
៣	៤	១

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

[6] Picture Source: Own Pictures

7	7	6
២	៦	៥

គ.ចូរមើលគំរូនៃកិច្ចតែងការបង្រៀនខាងក្រោម ហើយទាញយកឈ្មោះសកម្មភាពខាងក្រោមទៅដាក់នៅកន្លែងចន្លោះសមស្រប៖

ធ្វើការជាដៃគូ ត្រួតពិនិត្យ ភ្ជាប់ទៅនឹងកម្មវិធីសិក្សា មតិណែនាំរបស់គ្រូ ចំណេះដឹងពីមុន វគ្គបំណងមេរៀន ការបង្រៀនដោយពន្យល់លម្អិត យុទ្ធសាស្ត្របង្រៀន សង្ខេបគំនិតកិច្ចការ សម្តែង មតិត្រលប់របស់សិស្ស ការសួរសំណួរ ការឆ្លុះបញ្ចាំងពីខ្លួនឯង

<u>កិច្ចតែងការថ្នាក់វិទ្យាសាស្ត្រ</u>

ថ្នាក់ទី១

ប្រធានបទ៖ ជម្រកសត្វ

<u>វគ្គបំណងមេរៀន</u> ៖ នៅចុងបញ្ចប់នៃមេរៀនសិស្សអាចចាត់តាងនៃជម្រកសត្វទាំង៥សំខាន់ៗ និងអាចចាត់ថ្នាក់សត្វដែលរស់នៅតាមជម្រកនីមួយៗ។

<u>ភ្ជាប់ទៅនឹងកម្មវិធីសិក្សា</u> ៖ ដំណើរការនៃការរស់នៅ និងរបស់មានជីវិត

<u>ចំណេះដឹងពីមុន</u> ៖ នៅមេរៀនមុន សិស្សបានរៀនអំពីក្រុមនៃសត្វ ហើយនៅក្នុងថ្នាក់កូមិវិទ្យាពួកគេបានរៀនអំពីទីតាំងកូមិសាស្ត្រផ្សេងៗនៃពិភពលោក។

[7] Picture Source: Open Source from pixabay.com

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ចាប់ផ្តើមមេរៀន

សង្ខេបគំនិត : សរសេរលើក្តារខៀន "តើមានអ្វីដែលសត្វទាំងអស់ ត្រូវការ ដើម្បីរស់នៅ?" ហើយលើកទឹកចិត្តសិស្សឱ្យគិតពីភាពដូចគ្នារវាងមនុស្ស និងសត្វ។ សរសេរចម្លើយរបស់ពួកគេនៅលើក្តារខៀន។

ធ្វើការជាដៃគូ : ឱ្យសិស្សចាប់ដៃគូហើយអង្គុយជាមួយគ្នា នៅក្នុងថ្នាក់ (កន្លែងណាក៏បាន) ពិភាក្សាពីសំណួរខាងលើ ហើយចែករំលែកជាមួយមិត្តរួមថ្នាក់ដទៃទៀត។ សរសេរចម្លើយទាំងអស់នៅលើក្តារខៀន។

ការបង្រៀនដោយពន្យល់លម្អិត : ពន្យល់សិស្សថាសត្វទាំងឡាយត្រូវការជម្រក ដើម្បីរស់នៅដែលពួកគេអាចរកបាននូវអ្វីដែលពួកគេត្រូវការដើម្បីរស់។ សត្វប្រភេទផ្សេងគ្នាដែលមាន៥ប្រភេទសំខាន់ៗ ចូរអានអត្ថបទ "ជម្រក" របស់លោកWilliam B.B.Rice.

មតិត្រលប់របស់សិស្ស : នៅរៀងរាល់ពេលដែលរកឃើញប្រភេទ "ជម្រក"ណាមួយបានពណ៌នានាក្នុងសៀវភៅ សិស្សគួរតែលើកមេដៃឡើង។ ជ្រើសរើសសិស្សម្នាក់ដើម្បីសរសេរនៅលើក្តារខៀន។

ការណែនាំអនុវត្ត

សម្តែង : ដាក់សិស្សជាក្រុមតូចៗ ហើយក្រុមមួយត្រូវទទួលខុសត្រូវលើ "ជម្រក" មួយ។ ប្រាប់សិស្សថាពួកគេពេលនេះជាអ្នកវិទ្យាសាស្ត្រ ហើយពួកគេត្រូវបង្កើតជម្រកដែលជាកិច្ចការដាក់ឱ្យ។ ពួកគេត្រូវសរសេរឈ្មោះសត្វគ្រប់ប្រភេទ ដែលពួកគេគិតថានឹងត្រូវរស់នៅក្នុងប្រភេទជម្រករបស់គេ។ ពួកគេគួរតែសរសេរឈ្មោះសត្វទាំងនោះនៅលើក្រដាសកត់ត្រាហើយបិតវានៅពីក្រោមចំណងជើង ជម្រករបស់ពួកគេនៅលើក្តារខៀន។ លើកទឹកចិត្តឱ្យពួកគេទំនាក់ទំនងគ្នាដោយប្រើឃ្លាគោល "ខ្ញុំយល់ស្របថា_____អាចរស់នៅ_____ពីព្រោះថា_____។"

ត្រួតពិនិត្យ : ដើរមើលតាមក្រុមហើយគ្រប់គ្រងសិស្ស ឱ្យធ្វើលើការងារនោះ។ តើពួកគេបានបញ្ចប់កិច្ចការនេះឬទេ? តើពួកគេទំនាក់ទំនងគ្នា

ដោយប្រើឃ្លាគោលដៅឬទេ? តោះពួកគេមានប្រើការគិតបែបស៊ីជម្រៅដែរឬទេ? តើពួកគេស្តាប់គ្នាទៅវិញទៅមកដែរឬទេ?

ការបញ្ចប់មេរៀន

មតិណែនាំរបស់គ្រូ : ដាក់សិស្សទាំងអស់ចូលគ្នាវិញហើយឱ្យពួកគេរម្លឹកពីកិច្ចការដែលបានធ្វើរួចលើក្រដាសកត់ត្រា។ ប្រាប់សិស្សថាពួកគេពិតជាធ្វើបានល្អណាស់ដែលអាចរកឃើញប្រភេទសត្វជាច្រើន ហើយសួរថាតើមានសិស្សណាចង់បន្ថែមចម្លើយប្តូរក្រុម របស់សត្វទាំងនោះឡើងវិញ ឬទេ?

ការសួរសំណួរ : ប្រសិនបើមានប្រភេទសត្វដែលត្រូវបានដាក់ឧស "ជម្រក"ហើយសិស្សមិនបានដឹងគ្រូអាចនិយាយថា "ខ្ញុំសម្គាល់ឃើញយើងបានដាក់ថាខ្លាឃ្មុំទឹកកករស់នៅតំបន់វាលខ្សាច់។ តើមាននរណាម្នាក់អាចគិត ដល់ជម្រកដ៏ប្រសើរជាងនេះសម្រាប់ខ្លាឃ្មុំទឹកកកឬទេ?"។ ប្រសិនបើគ្មានសិស្សណាម្នាក់ឆ្លើយ ស្នើឱ្យសិស្សគិតជាមួយមិត្តភក្តិបន្តិចសិន។ ប្រសិនបើមានសិស្សឆ្លើយត្រូវគ្រូគួរតែសួរបន្តបន្ថែមថាហេតុអ្វីបានជាតំបន់ប៉ូលគឺជា ជម្រកដ៏ប្រសើរបំផុតសម្រាប់ខ្លាឃ្មុំទឹកកក។

សង្ខេបគំនិត : ប្រាប់សិស្សថាពួកគេនឹងក្លាយទៅជាអ្នករុករក ស្រាវជ្រាវដោយដាក់កិច្ចការឱ្យពួកគេរកសត្វ ដែលកំពុងរស់នៅក្នុងជម្រកនៅជិតសាលារៀន ឬជិតផ្ទះរបស់ពួកគេ។ ពួកគេគួរតែដៃគូរូបសត្វនោះ ហើយធ្វើតារាងរាយឈ្មោះរបស់៥យ៉ាងដែលមាននៅក្នុងជម្រករបស់វា(ដូចជាស្មៅ ទឹក ដី រុក្ខជាតិ)។

ការឆ្លុះបញ្ចាំងពីខ្លួនឯង : នៅពេលមេរៀនបានបញ្ចប់ គ្រូអាចសួរខ្លួនឯងថាតើសិស្ស មានចំណាប់អារម្មណ៍ទៅលើមេរៀន បានចូលរួមអនុវត្ត និងកត់សម្គាល់ចំណុចអនុវត្តបានដោគជ័យ និងចំណុចដែលគួរកែលម្អពេលក្រោយ ឬអត់ប្រសិនបើប្រើកិច្ចតែងការនេះនៅឆ្នាំក្រោយ តើត្រូវផ្លាស់ប្តូរចំណុចណាខ្លះ? ហើយហេតុអ្វី?[8]

[8] Adapted from education.com

ឃ. ចូរមើលគ្រូបង្រៀនម្នាក់និយាយអំពីការធ្វើកិច្ចតែងការបង្រៀន និងជំនាញគរុកោសល្យនានា។ (Video File 1.2.1; កំណត់ត្រាសំឡេងអាចរកបាននៅក្នុងឧបសម្ព័ន្ធនៃឯកសារនេះ)។ ចូរបង្ហាញថាប្រយោគខាងក្រោមនេះត្រូវ(ត) ឬខុស (ខ)៖

១. គ្រូចាំបាច់ត្រូវពិចារណាពីប្រភេទ សិស្សនៅក្នុងថ្នាក់រៀននៅពេលដែលធ្វើការជ្រើសរើសវិធីបង្រៀនឱ្យបានត្រឹមត្រូវ។ ត / ខ

២. ជាឧទាហរណ៍វិធីសាស្ត្រនៃការអង្កេត គឺដំបូងអនុញ្ញាតឱ្យសិស្សសង្កេតរូបភាព ហើយបន្ទាប់មកពណ៌នា ឬបញ្ចេញយោបល់លើរូបភាពនោះ។ ត / ខ

៣. វិធីសាស្ត្រអង្កេតមិនបានអភិវឌ្ឍនូវជំនាញគិតត្រិះរិះពិចារណាចំពោះសិស្សនោះទេ។ ត / ខ

(ចម្លើយត្រឹមត្រូវ៖ វិធីសាស្ត្រសង្កេតពិតជាជួយអភិវឌ្ឍជំនាញត្រិះរិះពិចារណារបស់សិស្ស។)

ង. ចូរមើលលោកគ្រូបង្រៀនម្នាក់នេះគាត់និយាយអំពីការធ្វើកិច្ចតែងការបង្រៀន និងជំនាញគរុកោសល្យ។ (Video File 1.2.2; កំណត់ត្រាសំឡេងអាចរកបានក្នុងឧបសម្ព័ន្ធនៃឯកសារនេះ)។ ចូរឆ្លើយសំណួរពហុចម្លើយសម្រាប់ជ្រើសរើសខាងក្រោម។ អាចមានចម្លើយច្រើន៖

១. តើលោកគ្រូបង្រៀនម្នាក់នេះរៀបចំការបង្រៀនរបស់គាត់របៀបណា?

ក. គាត់មិនបានរៀបចំការបង្រៀនរបស់គាត់ទេ។

ខ. គាត់តែងតែរៀបចំធ្វើកិច្ចតែងការមេរៀនរបស់គាត់។

គ. គាត់រៀបចំគម្រោងត្រួសៗមួយពីអ្វីដែលគាត់នឹងបង្រៀន។

២. តើការធ្វើកិច្ចតែងការបង្រៀនរបស់គាត់រាប់បញ្ចូលធាតុអ្វីខ្លះ?

ក. គោលបំណងនៃមេរៀន

ខ. ការប្រើប្រាស់សម្ភារៈ (ដូចជា សៀវភៅពុម្ព)

គ. បរិបទរបស់មេរៀន

៣. តើគាត់ពិសោធការរៀបចំកិច្ចតែងការមេរៀនរបស់គាត់របៀបណា?

ក. ជាផែនទីនៃការបង្កើតលទ្ធផលសិក្សា

t.me/moeysnews
sarr.ndeys.gov.kh
youtube.com/moeyscambodia

ខ. ជាផែនទីសម្រាប់ថ្នាក់រៀនដោយរាប់បញ្ចូលទាំងសិស្សម្នាក់ៗ

គ. ជាផែនទីសម្រាប់បរិយាកាសសិក្សា

៤. តើគាត់ប្រើវិធីសាស្ត្រប្រភេទអ្វីខ្លះ?

ក. វិធីសាស្ត្រ "គិត ធ្វើការជាដៃគូ ចែករំលែក"

ខ. វិធីសាស្ត្រ "តុមូល"

គ. វិធីសាស្ត្រ "ល្បែងផ្គុំរូបភាព"

ជំហានទី៣៖ កិច្ចការរៀបចំឯកសារជាសំណុំ សំណួរឆ្លុះបញ្ចាំងពីខ្លួនឯងផ្ទាល់

ចូរសរសេរចម្លើយបែបសំណេរតែងសេចក្តីចំពោះសំណួរបែបឆ្លុះបញ្ចាំងខាងក្រោម។ ចម្លើយរបស់អ្នកគួរមានប្រវែងប្រហែល ៣០០ទៅ៥០០ពាក្យហើយឆ្លើយជាអត្ថបទដែលទាក់ទងគ្នាងាយស្រួលយល់ជាមួយនឹងប្រយោគពេញលេញ។ ចម្លើយបែបសំណេរតែងសេចក្តីនេះដាក់ចូលក្នុងសំណុំឯកសារផ្ទាល់ខ្លួនរបស់អ្នក!

១. តើបទពិសោធរបស់អ្នកជាមួយនឹងយុទ្ធសាស្ត្របង្រៀនផ្សេងៗគ្នាដែលត្រូវបានពណ៌នានៅក្នុងម៉ូឌុលនេះមានអ្វីខ្លះ? តើអ្នកបានឆ្លងកាត់បទពិសោធអ្វីខ្លះក្នុងរយៈពេលជាច្រើនឆ្នាំកាលជាសិស្សម្នាក់?តើវាបានជួយជាប្រយោជន៍ដែរ ឬទេ? តើមានអ្វីផ្សេងទៀតដែលអ្នកប្រហែលជាត្រូវការនៅពេលនោះដើម្បីឱ្យអ្នកមានអារម្មណ៍ថាត្រូវបានគេជួយពេញទំហឹងក្នុងដំណើរការសិក្សារបស់អ្នក?

ជំហានទី៤៖ កិច្ចការរៀបចំឯកសារសំណុំ – គម្រោងការបង្រៀន

ចូរបង្កើតគម្រោងនៃការបង្រៀនផ្ទាល់ខ្លួនរបស់អ្នក។ ចូរកំណត់លទ្ធផលសិក្សាសម្រាប់មេរៀនដែលអ្នកបានជ្រើសរើសនៅក្នុងម៉ូឌុល 1.1។ កិច្ចការរៀបចំសំណុំឯកសារនេះគួរតែមានប្រវែងចាប់ពី ៨០០ទៅ១០០០ពាក្យ។ គម្រោងការបង្រៀននេះដាក់ចូលទៅក្នុងសំណុំឯកសារផ្ទាល់ខ្លួនរបស់អ្នក!

ផ្តោតលើមូលដ្ឋាននៃលទ្ធផលសិក្សាដែលត្រូវបានកំណត់កាលពីមុនរបស់អ្នក ចូរព្យាយាមបង្កើតយុទ្ធសាស្ត្រ វិធីសាស្ត្រ និងជំនាញសំខាន់ៗសម្រាប់ការបង្កើតទស្សនៈមួយដែលផ្តោតទៅលើសិស្សនៃការបង្កើតការអប់រំរបស់អ្នក។

ចូរប្រើផ្នែក "ការលូតលាស់" ពីការរៀបចំ*គម្រោងដើមឈើ* (ម៉ូឌុល ១.២)ដើម្បីជួយអ្នកក្នុងការពិចារណា។

ឧបសម្ព័ន្ធ

កំណត់ត្រាពីសំឡេង៖ Video File 1.2.1

គ្រូបង្រៀន ក៖ តើគ្រូបង្រៀនរៀបចំយ៉ាងណាសម្រាប់ថ្នាក់រៀនមួយ? មានវិធីជាច្រើនសម្រាប់គ្រូ ដើម្បីជ្រើសរើសសម្រាប់ថ្នាក់របស់ពួកគាត់។ វាអាស្រ័យទៅលើគ្រូ ហើយនិងសិស្សនៅក្នុងថ្នាក់នីមួយៗ។ តើពួកគេជាសិស្សប្រភេទណា។ ឧទាហរណ៍ ជាសិស្សដែលចូលចិត្តគិតតែឯង ឬជាសិស្សដែលចូលចិត្តគិតពីអ្វីជុំវិញខ្លួន? គ្រូចាំបាច់ត្រូវតែដឹងដើម្បីយល់ពីទង្វើនៃការប្រព្រឹត្តរបស់សិស្ស ហើយដើម្បីស្វែងរកវិធីត្រឹមត្រូវសម្រាប់សិស្ស។ ទាក់ទងទៅនឹងវិធីសាស្ត្រគ្រូ អាចជ្រើសរើសយកវិធីដែលសាកសមមួយ។ ខ្ញុំផ្ទាល់ចូលចិត្តវិធីសង្កេត។ វាមានន័យថាខ្ញុំអនុញ្ញាតឱ្យសិស្សសង្កេតមើលរូបភាពមួយហើយបន្ទាប់មកពួកគេពណ៌នាអំពីវា។ គ្រូចង់ឱ្យសិស្សសង្កេតមើលរូបភាពហើយបន្ទាប់មកសិស្សអាចផ្តល់ចម្លើយបាន។ គ្រូឱ្យពួកគេនិយាយពីអ្វីដែលគេឃើញ និងគិតដល់។ សិស្ស និងសង្កេតមើលអ្វីដែលគេមើលឃើញ ហើយនិយាយចេញមកឮៗ។ នេះគឺជាវិធីដែលខ្ញុំប្រើនៅពេលបង្រៀនពីរូបភាព។ ព្រោះវាងាយស្រួលសម្រាប់ពួកគេក្នុងការចងចាំហើយវាក៏អភិវឌ្ឍជំនាញគិតត្រិះរិះពិចារណាដែរ។ គ្រូអាចបន្ថែមវិធីសាស្ត្រផ្សេងថែមទៀតចំពោះមេរៀននីមួយៗ។

កំណត់ត្រាពីសំឡេង៖ Video File 1.2.2

អ្នកសម្ភាសន៍៖ តើអ្នករៀបចំការបង្រៀនរបស់អ្នករបៀបណា?

គ្រូបង្រៀន ខ៖ អ្វីដែលខ្ញុំតែងតែរៀបចំមុនពេលបង្រៀនគឺជាកិច្ចតែងការមេរៀនមួយ។ វាមានន័យថា គ្រូរៀបចំមេរៀន គោលបំណងនៃមេរៀន ការប្រើប្រាស់សៀវភៅ និងបរិបទនៃមេរៀន។ វាគឺជាផែនទីនៃការបង្កើតលទ្ធផលសិក្សា។ ប្រសិនបើអ្នកមិនបានរៀបចំកិច្ចតែងការបង្រៀននោះទេ អ្នកនឹងវង្វេងនៅពេលបង្រៀន។ ខ្ញុំកំណត់គោលដៅនៃការវាយតម្លៃសិស្ស៖ តើសិស្សទទួលបានអ្វីពីមេរៀននេះ? ប្រសិនបើអ្នកមិនបានកំណត់គោលដៅទេអ្នកនឹងបាត់បង់លទ្ធផលរបស់សិស្ស។ សៀវភៅ និងសម្ភារៈផ្សេងទៀតសំខាន់សម្រាប់គ្រូក្នុងការរៀបចំគោលបំណងនៃមេរៀន។ បន្ថែមលើនេះទៀត វាអាចជួយសិស្សក្នុងការអភិវឌ្ឍជំនាញត្រិះរិះពិចារណា និងការសង្កេតរបស់ពួកគេ។ អ្នកសម្ភាសន៍៖ អរគុណ។ អ្នកនិយាយជាច្រើនពីវិធីសាស្ត្រ។ តើអ្នកប្រើប្រាស់វិធីសាស្ត្រអ្វីខ្លះសម្រាប់ការបង្រៀនរបស់អ្នក?

គ្រូបង្រៀន ខ៖ ខ្ញុំផ្ទាល់ចូលចិត្តវិធីចំនួនពីរ ដើម្បីបង្រៀននៅក្នុងថ្នាក់ពិតប្រាកដ។ វិធីសាស្ត្រទីមួយហៅថា “តុមូល”។ វាមានបីជំហាន ជំហានទីមួយ សិស្សធ្វើការជាក្រុមហើយពិភាក្សាជាមួយគ្នា ដើម្បីស្វែងរកចម្លើយ។ ជំហានទី២ ពួកគេកំណត់គោលដៅមួយនិងតួនាទី។ ជំហានទីបី ពួកគេចែករំលែកជាមួយអ្នករួមថ្នាក់ពីអ្វីដែលពួកគេបានធ្វើ។ វិធីទីពីរ ហៅថា “ការផ្គុំរូបភាពឬអត្ថបទ”។ វាមានបួនជំហាន។ ជំហានទីមួយ

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

យបង្កើតក្រុមដោយឱ្យសិស្សរាប់ចំនួនលេខ (ក្រុមដែលមានមនុស្ស៤នាក់ = រាប់ពី១ដល់៤) ជំហានទីពីរ បង្កើតក្រុមថ្មីជាមួយនឹងលេខដូចគ្នា(១,១,១,១) ជំហានទីបី អាន និងគិតពីអត្ថបទដែលគ្រូផ្តល់ឱ្យ។ ជំហានទីបួន សិស្សត្រលប់ទៅកាន់ក្រុមដំបូងរបស់ពួកគេវិញ ហើយចែករំលែកពីអ្វីដែលពួកគេបានអានក្នុងអត្ថបទរបស់ពួកគេ។

អ្នកអប់រំដែលជោគជ័យត្រូវចេះពីវិធីប្រើប្រាស់ធាតុសំខាន់ៗនៃការបង្រៀនដែលមានគុណភាពខ្ពស់សម្រាប់ថ្នាក់រៀនរបស់ខ្លួន។ ក្នុងម៉ូឌុលនេះ បង្ហាញពីមូលដ្ឋានមួយចំនួនសម្រាប់ការអនុវត្តការបង្រៀនប្រកបដោយប្រសិទ្ធភាព ដើម្បីធានាថាសមាសភាពសំខាន់នៃការបង្រៀននៅកម្រិតបឋមសិក្សាត្រូវបានពិចារណានៅពេលធ្វើផែនការបង្រៀន អនុវត្តការបង្រៀន វាយតម្លៃដំណើរការបង្រៀន និងរៀន។ តាមរយៈប្រធានបទផ្សេងៗ រួមបញ្ចូលការបង្រៀន និងរៀនសតវត្សទី២១ ការធ្វើកិច្ចតែងការបង្រៀន និងបរិស្ថានសិក្សា អ្នកនឹងតម្រូវឱ្យធ្វើការឆ្លុះបញ្ចាំងពីដំណើរការបង្រៀន និងរៀនដើម្បី សម្រេចលទ្ធផលសិក្សាដោយជោគជ័យ។

សូមសិក្សាដោយរីករាយ!

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

CONTESSA
Contemporary Teaching Skills for South Asia
Co-funded by the Erasmus+ Programme of the European Union

ម៉ូឌុល ១

ការកសាងការយល់ដឹងពីការអប់រំនៅបឋមសិក្សា

១.៣- ការរៀបចំបរិយាកាសសិក្សា

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ការកសាងការយល់ដឹងអំពីការអប់រំនៅបឋមសិក្សា

មេរៀននេះត្រូវបានបង្កើតឡើងដោយដៃគូ សហការ ពាក់ព័ន្ធនៅក្នុងគម្រោង នៅក្នុងវិធីសាស្ត្របង្រៀនសម័យថ្មីនៅអាស៊ីខាងត្បូង (Contemporary Teaching Skill for South Assia) ហៅកាត់ថា **CONTESSA** ក្រោមការចូលរួមឧបត្ថម្ភថវិកាដោយកម្មវិធី **Eramus+** នៃសហភាពអឺរ៉ុបដែលមានលេខគម្រោង 598756-EPP-1-2018-1-AT-EPPKKA2-CBHE-JP-/CONTESSA

កាលបរិច្ឆេទបោះពុម្ព : 2021

បោះពុម្ពដោយ: CONTESSA

អ្នកសម្របសម្រួល: Sandra Hummel,សាកលវិទ្យាល័យហ្គ្រាស UNIVERSITY OF GRAZ (អូទ្រីស)

ក្រោមការចូលរួមសហការពី :

សាកលវិទ្យាល័យបច្ចេកវិទ្យា ជ្រៃសឺន(អាលល្លឺម៉ង់)

(កម្ពុជា) សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា

(កម្ពុជា) សាកលវិទ្យាល័យកម្ពុជា

(ស្រីលង្កា) សាកលវិទ្យាល័យអូកេននៃប្រទេសស្រីលង្កា

(ស្រីលង្កា) សាកលវិទ្យាល័យកឡំបូ

អ្នកនិពន្ធ: Bridget Sheehan, Sandra Hummel, Mirjam Brodacz-Geier

សេចក្តីប្រកាស

គណៈកម្មការអឺរ៉ុប សូមធ្វើការគាំទ្រដល់ការបោះពុម្ពឯកសារនេះដែរមិនមែន ឆ្លុះបញ្ចាំងតែពីទស្សនៈរបស់អ្នកនិពន្ធខាងលើទេ ហើយយើងក៏មិនទទួលខុសត្រូវ ចំពោះការប្រើប្រាស់ព័ត៌មានដែលដកស្រង់ចេញពីការបោះពុម្ពនេះដោយប្រការណាមួយដែរ។ ព័ត៌មានលម្អិតបន្ថែមនៃមេរៀននេះអាចរកបានដោយបើកចំហ និងឥតគិតថ្លៃនៅលើគេហទំព័រ CONTESSA:https://contessa_project.eu/

រក្សាសិទ្ធិ

មេរៀននេះត្រូវបានផ្តល់អាជ្ញាប័ណ្ណឱ្យប្រើប្រាស់ក្រោមលក្ខខណ្ឌនៃ Creative Commons Attribution_ShareAlike 4.0 Internatinal License (https://creativecommons.org(licenses/by_sa/4.0/) ដែលអនុញ្ញាតឱ្យប្រើប្រាស់ ចែករំលែក សម្របសម្រួល ដើម្បីប្រើប្រាស់បន្តចែកចាយផលិតផលសារជាថ្មីក្នុងទ្រង់ទ្រាយណាមួយ ដរាបណាអ្នកប្រើប្រាស់ផ្តល់កិត្តិយសឱ្យបានសមរម្យដល់អ្នកនិពន្ធទាំងអស់។ សូមផ្តល់ជាតំណភ្ជាប់ (link) ទៅកាន់ Creative Commons License និងសូមបញ្ជាក់ផងដែរ បើមានការផ្លាស់ប្តូរណាមួយ។ ប្រសិនបើអ្នកបញ្ចូលគំនិតកែសម្រួល ឬបន្ថែមអត្ថន័យលើមេរៀននេះអ្នកត្រូវតែធ្វើការសុំសិទ្ធិកែសម្រួលឯកសារតាមលក្ខខណ្ឌខាងលើ។ រូបភាព ខ្សែសំឡេង វីដេអូ ក៏ដូចជា ឯកសារដទៃទៀតដែលមាន នៅក្នុងមេរៀនទាំងនេះ មិនត្រូវបានបូកបញ្ចូលទៅក្នុងឯកសារអាជ្ញាប័ណ្ណ Creative Commons ទេ លើកលែងតែមានការអនុញ្ញាតឱ្យប្រើប្រាស់។ ប្រសិនបើផ្នែកណាមួយនៃមេរៀននេះមិនត្រូវបានបញ្ចូលទៅក្នុងឯកសារអាជ្ញាប័ណ្ណ ហើយការប្រើប្រាស់មិនត្រូវបានអនុញ្ញាតដោយច្បាប់ ឬក៏ប្រើប្រាស់លើសពីច្បាប់ អនុញ្ញាតត្រូវតែសុំការអនុញ្ញាតដោយផ្ទាល់ពីម្ចាស់កម្មសិទ្ធិ។

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

CC BY SA

សេចក្តីផ្តើម

តើវគ្គសិក្សា CONTESSA គឺជាអ្វី?

វគ្គសិក្សា CONTESSA គឺជាលទ្ធផលមួយក្នុងចំណោមលទ្ធផលនៃគម្រោងស្តីអំពី "ជំនាញក្នុងការបង្រៀនសម័យថ្មីសម្រាប់អាស៊ីខាងត្បូង" ដែលផ្តល់មូលនិធិរួម ដោយកម្មវិធី Erasmus+ Program នៃសហភាពអឺរ៉ុប។ គោលបំណងរបស់វគ្គសិក្សានេះគឺដើម្បីជាការរួមចំណែក ក្នុងការបង្កើតកម្មវិធីអប់រំគ្រូបង្រៀនដោយជោគជ័យ សម្រាប់គ្រូបឋមសិក្សា ជាពិសេសក្នុងប្រទេសកម្ពុជា និងស្រីលង្កាដែលនឹងនាំដល់ការបង្កើតបានផលវិជ្ជមានដែលមានរយៈពេលវែងឆ្ងាយទៅលើប្រព័ន្ធអប់រំទូទៅ។ វាមានសារៈសំខាន់កាន់តែខ្លាំងឡើងសម្រាប់អ្នកអប់រំដែលជោគជ័យ ក្នុងការតាមឱ្យទាន់សម័យជាមួយនឹងជំនាញនិងវិធីសាស្ត្រក្នុងសម័យថ្មីដើម្បីយកមកប្រើក្នុង និងក្រៅថ្នាក់រៀន។ ដូច្នេះ វគ្គសិក្សា CONTESSA ផ្តល់ជូនមេរៀនដែលត្រូវបានជ្រើសរើសដោយប្រុងប្រយ័ត្នចំនួន៥ម៉ូឌុល ដែលម៉ូឌុលនីមួយៗ មានការផ្តល់ការយកចិត្តទុកដាក់ទៅលើចំណុចចំនួនបីដែលតម្រង់ទៅរកការអភិវឌ្ឍលើជំនាញបង្រៀនបែបសម័យថ្មី។ ម៉ូឌុលទាំងឡាយ និងការផ្តោតការយកចិត្តទុកដាក់របស់វាគឺមានដូចខាងក្រោម៖

ម៉ូឌុល១៖ ការកសាងការយល់ដឹងអំពីការអប់រំនៅបឋមសិក្សា
១. ការបង្រៀន និងការរៀននៅសតវត្សទី២១
២. ការរៀបចំកិច្ចតែងការបង្រៀននិងជំនាញគរុកោសល្យ៖ គំនិត ឧបករណ៍ និងការអនុវត្ត
៣. ការរៀបចំបរិយាកាសសិក្សា

ម៉ូឌុល២៖ ភាពអស្ចារ្យក្នុងការបង្រៀន៖ សមត្ថភាពជាក់លាក់ប្រកបដោយវិជ្ជាជីវៈ របស់គ្រូបង្រៀនបឋមសិក្សា
១. ការយល់ដឹងពីការបង្រៀន៖ តួនាទី កិច្ចការ និងមុខងារ
២. ការវាយតម្លៃទៅលើលទ្ធផលនៃការសិក្សា
៣. ជំនាញវិជ្ជាជីវៈគរុកោសល្យ

ម៉ូឌុល៣៖ ការអប់រំឈានមុខគេបែបវិធីសាស្ត្រសិស្សមជ្ឈមណ្ឌល៖ ការលើកម្ពស់ ដំណើរការសិក្សាដែលបានបង្កើតរួមគ្នា
១.ការអភិវឌ្ឍលក្ខណៈបុគ្គលនិងជំនាញដោះស្រាយបញ្ហា
២. ការអះអាងពីពិភពជីវិតជាក់ស្តែង និងក្តីសង្ឃឹមទៅអនាគត
៣.ការប្តេជ្ញាចិត្តដោយខ្លួនឯង ការផ្តល់សិទ្ធិអំណាចនិងប្រសិទ្ធិភាពផ្ទាល់ខ្លួន

ម៉ូឌុល៤៖ ការរួមបញ្ចូលភាពខុសគ្នា៖ គោលវិធីគរុកោសល្យសម្រាប់ភាពចម្រុះគ្នា ភាពមិនស្មើគ្នា និងតម្រូវការពិសេស
១. គរុកោសល្យបរិយាបន្ន៖ គោលវិធី និងយុទ្ធសាស្ត្រ
២. ការបង្រៀន និងការរៀនក្នុងភាពចម្រុះគ្នា៖ ការរៀបចំ ការយល់ដឹង ការវាយតម្លៃ
៣. ការគ្រប់គ្រងថ្នាក់រៀនដែលមានភាពចម្រុះគ្នា

ម៉ូឌុល៥៖ ការបង្រៀន និងការរៀនតាមបែបឌីជីថល
១. គរុកោសល្យនៃការសិក្សាពីចម្ងាយ និងបរិយាកាសសិក្សាដែលបំពាក់ទៅដោយបច្ចេកវិទ្យា
២. ប្រព័ន្ធផ្សព្វផ្សាយ និងបច្ចេកទេសឌីជីថល៖ ឧបករណ៍ និងទម្រង់សម្រាប់គោលបំណងការអប់រំ។

៣. ការរៀបចំមេរៀន និងដំណើរការបង្រៀនតាមអ៊ិនធឺណែតនៅពេលដែលបញ្ចប់វគ្គសិក្សានេះ អ្នកចូលរួមនឹងអាចអនុវត្តជំនាញបង្រៀនសម័យថ្មី ដែលទើបទទួលបានធ្វើឱ្យសិស្សទាំងអស់អាចចូលរួមសកម្មភាពក្នុងថ្នាក់ និងរៀនពីវិធីថ្មីៗដើម្បីជួយឱ្យសិស្សឈានទៅដល់ចំណុចសក្តានុពលពេញលេញរបស់ពួកគេ។

តើវគ្គសិក្សា CONTESSA សម្រាប់អ្នកណា?

គម្រោងស្តីពីជំនាញ ក្នុងការបង្រៀនសម័យថ្មីសម្រាប់អាស៊ីខាងត្បូងមានបំណង ក្នុងការលើកតម្កើងជំនាញបង្រៀនសម័យថ្មីសម្រាប់គរុនិស្សិត និងគ្រូបង្រៀនដែលកំពុងបម្រើការ ក្នុងសាលាបឋមសិក្សានានា។ ឯកសារខាងក្រោម ត្រូវបានសម្របសម្រួលជាពិសេសសម្រាប់គរុនិស្សិត។ លើសពីនេះទៅទៀត វគ្គសិក្សា CONTESSA ក៏សម្រាប់អ្នកដែលចាប់អារម្មណ៍ក្នុងការធ្វើខ្លួនឱ្យទាន់សម័យកាល ជាមួយនឹងជំនាញបង្រៀនសម័យថ្មី។

ឯកសារមានជាភាសាអង់គ្លេស ហើយក៏មានជាភាសាខ្មែរ ភាសាសិង្ហាលា (Sinhala) និងភាសាតាមីល (Tamil) ដែលប្រើប្រាស់នៅប្រទេសស្រីលង្កា។

តើរចនាសម្ព័ន្ធនៃវគ្គសិក្សា CONTESSA មានអ្វីខ្លះ?

ដូចដែលបានលើកឡើងពីមុនរួមហើយ វគ្គសិក្សា CONTESSA នេះរួមមាន៥ម៉ូឌុល ដែលម៉ូឌុលនីមួយៗមានតម្លៃស្មើនឹង ៣ក្រេឌីតតាមប្រព័ន្ធផ្ទេរការសិក្សារបស់អឺរ៉ុប។ ជាការល្អម៉ូឌុលទាំងនេះត្រូវបានប្រើប្រាស់រួមគ្នាព្រោះម៉ូឌុលនីមួយៗ យោងឯកសារលើម៉ូឌុលដទៃទៀត។ ប៉ុន្តែក្នុងមេរៀនម៉ូឌុលទាំងនេះក៏ត្រូវបានបង្កើតឡើង ក្នុងវិធីមួយ ដែលអាចប្រើបានដោយខ្លួនឯងផ្ទាល់ផងដែរ។

ម៉ូឌុលនីមួយៗមានការផ្តោតលើប្រធានបទចំនួនបី ហើយឯកសារទាំងឡាយក៏បង្កើតឡើងសម្រាប់ ការផ្តោតនីមួយៗផងដែរ។ វាបង្កើតឱ្យមានឯកសារសរុបចំនួន ១៥ ផ្នែកសម្រាប់វគ្គសិក្សា CONTESSA ។ ឯកសារនីមួយៗ រួមមានសេចក្តីផ្តើមបែបទ្រឹស្តីចំពោះចំណុចផ្តើម ហើយតាមពីក្រោយដោយលំហាត់អនុវត្ត ដោយផ្អែកលើទ្រឹស្តី។

ជំហាន១ – ទ្រឹស្តី – គឺជាការរម្លឹកនូវអ្វីដែលបានអាននៅក្នុងសេចក្តីផ្តើមនៃទ្រឹស្តីលំហាត់អនុវត្ត ទាំងនេះត្រួតពិនិត្យការយល់ដឹងនៃអត្ថបទ ដើម្បីប្រាកដថាទ្រឹស្តីជាមូលដ្ឋានដែលត្រូវបានយល់ដឹង។

ជំហាន២ – បទពិសោធ– ផ្តល់ជូននូវឧទាហរណ៍នៃគ្រូបង្រៀនពិតប្រាកដ និងពីវិធីដែលពួកគាត់អនុវត្តទ្រឹស្តីផ្សារភ្ជាប់នឹង ការអនុវត្តជាក់ស្តែង។ ឧទាហរណ៍: ទាំងនេះ បានភ្ជាប់លំហាត់អនុវត្តទៅនឹងទ្រឹស្តីដែលបានរៀនពីមុនរួចហើយ។

ជំហាន៣ –ការឆ្លុះបញ្ចាំងដោយខ្លួនឯងផ្ទាល់ – រាប់បញ្ចូលសំណួរបែបឆ្លុះបញ្ចាំង ដោយផ្អែកទៅលើចំណុចផ្តោតនីមួយៗ។

ជំហាន៤ – ការអនុវត្តន៍ – គឺជំហានចុងក្រោយដែលមានគម្រោងគោលនៃការបង្រៀនមួយត្រូវបានបង្កើតឡើងផ្អែកទៅលើអ្វីដែលបានប្រទះឃើញពីមុននៅក្នុងជំហានទីមួយ និងទីពីរ។

លំហាត់អនុវត្តនៅក្នុងជំហានទីមួយ និងទីពីរអាចត្រូវបានបំពេញដោយផ្ទាល់ក្នុងឯកសារនេះ។ ជំហានទីបី និងទីបួនជាផ្នែក នៃឯកសារដែលរៀបជាសំណុំដាច់ដោយឡែកដែលនឹងត្រូវបង្កើតដោយបុគ្គលម្នាក់ៗ។ គំរូសម្រាប់ការរៀបចំសំណុំឯកសារ (portfolio) មានជាឯកសារដាច់ដោយឡែកពីគ្នា។

មាតិកា

១- តើអ្វីទៅជាបរិយាកាសសិក្សា? 1

២- សារៈសំខាន់នៃបរិយាកាសសិក្សាបែបវិជ្ជមាន 4

៣- តើគ្រូបង្រៀនអាចបង្កើតបរិយាកាសសិក្សាវិជ្ជមានបានដោយរបៀបណា? 6

៣.២- ការកំណត់លទ្ធផលរំពឹងទុកច្បាស់លាស់ 7

៣.៣- ការបង្កើតវប្បធម៌គាំទ្រគ្នា និងសុវត្ថិភាព 8

៣.៤- ការគ្រប់គ្រងថ្នាក់រៀន 9

៤- ចំណុចគន្លឹះ 11

ឯកសារពិគ្រោះ 12

ជំហានទី១- ពង្រឹងចំណេះដឹង 14

ជំហានទី២- អនុវត្ត 17

ជំហានទី១- ចម្លើយពង្រឹងចំណេះដឹង 24

ជំហានទី២- ចម្លើយអនុវត្ត 28

ជំហានទី៣៖ កិច្ចការរៀបចំសំណុំឯកសារ –សំណួរបែបឆ្លុះបញ្ចាំងផ្ទាល់ខ្លួន 35

ជំហានទី៤៖ កិច្ចការរៀបចំសំណុំឯកសារ – គម្រោងការបង្រៀន 36

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

១- តើអ្វីទៅជាបរិយាកាសសិក្សា?

ដើម្បីបង្កើតជាបរិយាកាសសិក្សាសមស្របសម្រាប់សិស្ស ចាំបាច់ត្រូវយល់ថាតើអ្វីទៅជាបរិយាកាសសិក្សា និងថាតើវាមានលក្ខណៈយ៉ាងដូចម្តេចះ

បរិយាកាសសិក្សាសំដៅទៅរកទីកន្លែងផ្សេងៗ បរិបទ និងវប្បធម៌ចម្រុះ ដែលសិស្សរៀន។ ដោយសារសិស្សអាចរៀនបានតាមមធ្យោបាយច្រើនយ៉ាងដូចជា ទីតាំងក្រៅសាលារៀន និងបរិយាកាសខាងក្រៅផ្សេងៗទៀតពាក្យនេះជាញឹកញាប់ត្រូវបានគេប្រើជំនួសឱ្យពាក្យថា «ថ្នាក់រៀន» ដែលមានន័យចង្អៀត និងបែបបុរាណ ជាទូទៅសំដៅទៅលើបន្ទប់មួយមានតុរៀបជាជួរ និងមានក្តារខៀនមួយជាដើម។ ពាក្យនេះក៏រួមបញ្ចូលផងដែរ នូវវប្បធម៌របស់សាលារៀន ឬថ្នាក់រៀន មួយដោយបង្កប់នូវគោលការណ៍សីលធម៌ និងលក្ខណៈរបស់វា ជាប់បញ្ចូល

ទាំងរបៀបដែលបុគ្គលម្នាក់ៗធ្វើការទំនាក់ទំនងគ្នាទៅវិញទៅមក រួមទាំងវិធីសាស្ត្រដែលគ្រូអាចនឹងរៀបចំបរិយាកាសសិក្សា ដើម្បីសម្រួលដល់ការរៀនសូត្ររបស់សិស្ស។ (The Glossary of Education Reform, 2013, online)

ដូច្នេះ បរិយាកាសសិក្សាមិនមែនសំដៅទៅរកតែទីតាំងជាក់លាក់មួយនោះទេ ប៉ុន្តែវាជាលំហមួយសម្រាប់ការបង្រៀន និងការរៀន។ ដើម្បីធានាឱ្យបាននូវគុណភាពខ្ពស់ គេត្រូវពិចារណាទៅលើកត្តាផ្សេងៗជាច្រើន។ ក្នុងចំណោមកត្តាទាំងនេះមានដូចជា ទំនាក់ទំនងក្នុងសង្គម ការរៀបចំថ្នាក់រៀន ការតុបតែងជញ្ជាំង ប្លង់ ធនធាន ឬគោលនយោបាយដែលមាន និងរឿងផ្សេងទៀត។

បរិយាកាសសិក្សាតែងតែមានការផ្លាស់ប្តូរជានិច្ច។ វាវិវឌ្ឍទៅតាមប្រព័ន្ធអប់រំ និងគោលដៅដែលគេផ្តល់អាទិភាព(Ifenthaler,2012)។ បរិយាកាសសិក្សាតាមបែបបុរាណ ឬ**គ្រូមជ្ឈមណ្ឌល** នៅតែមានឥទ្ធិពលភាគច្រើននៅតាមកន្លែងសិក្សានានា។ បរិយាកាសប្រភេទនេះផ្តោតទៅលើគ្រូជាផ្នែកសកម្ម ចំណែកឯសិស្សវិញជាអ្នកចាំតែទទួលនូវចំណេះដឹងប្រកបដោយភាពអសកម្ម ដែលត្រូវចាំតែទទួលការបង្ហាត់បង្ហាញពីគ្រូបង្រៀន(The Glossary of Education Reform, 2014)។ បរិយាកាសសិក្សាប្រភេទ

គ្រូមជ្ឈមណ្ឌល- សំដៅទៅរកស្ថានភាពសិក្សាទាំងឡាយណាដែលគ្រូគ្រប់គ្រងទៅលើសម្ភារសិក្សា ឬកិច្ចការដែលសិស្សរៀន ព្រមទាំងវិធីសាស្ត្រដែលសិស្សអនុវត្តក្នុងការសិក្សា មានដូចជា ពេលវេលា ទីកន្លែង វិធីសាស្ត្រដែលសិស្សរៀន។ ថ្នាក់ដែលចាត់ទុកថាជាគ្រូមជ្ឈមណ្ឌលគ្រូបង្រៀន គឺជាអ្នកសកម្មជាងគេនៅក្នុងថ្នាក់រៀន ហើយនិយាយច្រើនជាងសិស្ស។ ឧទាហរណ៍ ដូចជា ការបង្ហាញពីគំនិតទស្សនៈ ឬក៏ការពន្យល់ណែនាំ ចំណែកឯសិស្សវិញចំណាយពេលភាគច្រើនអង្គុយនៅតុស្តាប់គ្រូបង្រៀនកត់មេរៀន ផ្តល់ចម្លើយខ្លីៗទៅនឹងសំណួរដែលគ្រូសួរ ឬបំពេញកិច្ចការ ឬការប្រឡង តាមដែលគ្រូដាក់ឱ្យ។ (The Glossary of

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

នេះ វាលើកតម្កើងការផ្តោតតែទៅលើគ្រូបង្រៀនប៉ុណ្ណោះ ពុំបានជំរុញកិច្ចសហការ ឬ ស្ថានភាពសិក្សាតាមបែបអន្តរកម្មទេ។

បរិយាកាសសិក្សាតាមបែប**សិស្សមជ្ឈមណ្ឌល**គឺផ្តោតទៅលើអ្នកសិក្សា។ បរិយាកាសប្រភេទនេះគ្រូបង្រៀនដឹងថា សិស្សម្នាក់មាន របៀបរៀនខុសៗគ្នាទៅតាមដំណើររបស់ពួកគេ វិធីសាស្ត្រនេះគ្រូព្យាយាមដើរតួជាអ្នកសម្របសម្រួលដំណើរការរៀនរបស់សិស្សម្នាក់ៗ (Rieber,2001)។ គំនិតសំខាន់នៃបរិយាកាសសិក្សាបែបសិស្សមជ្ឈមណ្ឌល គឺត្រូវផ្តល់ឱកាសឱ្យសិស្សនាំផ្លូវនៃដំណើរការរៀនសូត្ររបស់ពួកគេ ព្រមទាំងមានការផ្សារភ្ជាប់ចំណាប់អារម្មណ៍របស់គេទៅនឹងអ្វីដែលគេរៀននៅឯសាលា។

ក្នុងបរិយាកាសសិក្សាបែបសិស្សមជ្ឈមណ្ឌល តួនាទី និងទំនួលខុសត្រូវរបស់សិស្សមានការប្រែប្រួល។ បរិយាកាសប្រភេទនេះ តម្រូវឱ្យមានការប្រឹងប្រែងច្រើនពីសំណាក់អ្នករៀនសូត្រដែលនឹងជួយពួកគេបង្កើតនូវជំនាញថ្មីៗនៅអនាគត (Doyle ,2008)។ គំរូគំនិតខាងក្រោមនេះអាចមានសារៈប្រយោជន៍ នៅពេលគ្រូបង្រៀនបង្កើតបរិយាកាសសិក្សា តាមបែបសិស្សមជ្ឈមណ្ឌលមួយ៖

- ✓ ការយល់ច្បាស់អំពីរបៀបដែលមនុស្សយើងរៀន៖ អ្នកសិក្សានឹងបង្កើនការចងចាំ បង្កើតគំនិត ឬព័ត៌មានផ្ទាល់ខ្លួនបានប្រសិនបើពួកគេបានចូលរួម ដោយសកម្មក្នុងដំណើរការនៃការរៀនសូត្រជំនួសឱ្យការចាំតែទទួលបានព័ត៌មានដោយអសកម្ម។
- ✓ ការត្រៀមខ្លួនសម្រាប់ជីវិតការងារ៖ បរិយាកាសក្នុងសិស្សមជ្ឈមណ្ឌលត្រូវការវិធីសាស្ត្រខុសៗគ្នា ដូចជាការងារជាក្រុម និងការធ្វើបទបង្ហាញរបស់សិស្ស។ សកម្មភាពទាំងនេះបានផ្តល់ឱ្យសិស្ស នូវជំនាញសំខាន់ៗដូចជា ការប្រាស្រ័យទាក់ទង ការផ្តល់ និងទទួលយកមតិយោបល់ ឬក៏ការបញ្ចេញមតិជាសាធារណៈជាដើម។
- ✓ ការត្រៀមខ្លួនដើម្បីក្លាយទៅជាអ្នករៀនពេញមួយជីវិត៖ គំនិតនេះ គឺត្រូវគាំទ្រអ្នកសិក្សាឱ្យចេះលើកទឹកចិត្តខ្លួនឯងហើយក្លាយជាអ្នកសិក្សាឯករាជ្យដែលចាំបាច់ក្នុងជីវិតការងារទៅអនាគតរបស់គេ។ ហេតុផលនៃរឿងនេះគឺបរិយាកាសសិក្សាបែបសិស្សមជ្ឈមណ្ឌលនឹងផ្តល់ឱកាសជាច្រើន ដើម្បីទទួលបាននូវជំនាញផ្សេងៗ ដូចជាការរៀបចំពេលវេលា និងការបញ្ជាក់ពីគំនិតរបស់សិស្ស ក្នុងវិធីដែលពួកគេអាចងាយយល់បាន។ រឿងនេះក៏នឹងជួយពួកគេឱ្យអាចបន្តការរៀនសូត្រពេញមួយជីវិត ទោះបីជាពួកគេបានបញ្ចប់ការសិក្សានៅសាលារៀនហើយក្តី។

Education Reform, 2014 online)។

សិស្សមជ្ឈមណ្ឌល- សំដៅទៅរកទម្រង់នៃការបង្រៀនដែលផ្តល់ឱ្យសិស្សនូវឱកាសដឹកនាំសកម្មភាពរៀនសូត្រ ចូលរួមយ៉ាងសកម្មក្នុងកិច្ចពិភាក្សា បង្កើតគម្រោងសិក្សាផ្ទាល់របស់ពួកគេ ស្រាវជ្រាវប្រធានបទដែលពួកគេចាប់អារម្មណ៍ ហើយជាទូទៅវានាំឱ្យមានការបង្កើតកម្មវិធីសិក្សាផ្ទាល់ខ្លួនរបស់ពួកគេ។ បន្ថែមពីលើនេះទៅទៀត ការបង្រៀនបែបសិស្សមជ្ឈមណ្ឌលជាញឹកញាប់ គឺជាប់ពាក់ព័ន្ធជាមួយថ្នាក់រៀនទាំងឡាយណាដែលមានតុកៅអីរៀបជារង្វង់ ឬរៀបជាក្រុមតូចៗ (ជាជាងរៀបតុជាជួរដែលបែរមុខទៅរកទៅគ្រូ) ដោយមានការណែនាំ ឬក៏ជំហានសិក្សាកំណត់ដោយខ្លួនឯង ឬដោយចែករំលែកបទពិសោធសិក្សាដែលកើត

- ✓ ការត្រៀមខ្លួនសម្រាប់ដំហានបន្ទាប់៖ ដើម្បីបង្កើតបាននូវបរិយាកាសសិក្សាបែបសិស្សមជ្ឈមណ្ឌល វាចាំបាច់ណាស់ត្រូវធ្វើឱ្យអ្នកសិក្សាយល់ពីភាពចាំបាច់ និងសារៈសំខាន់នៃមុខវិជ្ជាដែលពួកគេកំពុងរៀន។ រឿងនេះនឹងជួយលើកទឹកចិត្តពួកគេឱ្យចូលរួម ក្នុងដំណើរការរៀនសូត្រកាន់តែសកម្មជាងមុន។ (Bishop et al., 2014)

ឡើងនៅក្រៅថ្នាក់រៀន[.....] (The Glossary of Education Reform, 2014, online)

មានគុណសម្បត្តិជាច្រើនចំពោះបរិយាកាសសិក្សាបែបសិស្សមជ្ឈមណ្ឌលជាច្រើនទៀតក្រៅពីអ្វីដែលត្រូវបានលើកឡើងខាងលើ បរិយាកាសបែបនេះតម្រូវឱ្យមានកិច្ចប្រឹងប្រែងជាច្រើនពីសំណាក់អ្នកសិក្សា ក៏ប៉ុន្តែ វាបានផ្តល់នូវជំនាញគ្រប់គ្រងដំណើរការរៀនសូត្ររបស់ពួកគេ។ វិធីសាស្ត្របង្រៀនដែលប្រើចំពោះបរិយាកាសសិស្សមជ្ឈមណ្ឌលនឹងជំរុញឱ្យមានសមត្ថភាព ក្នុងការវាយតម្លៃខ្លួនឯងជំនាញទំនាក់ទំនង និងការគាំទ្រចំពោះការសិក្សាពេញមួយជីវិតរបស់ពួកគេផងដែរ(Bishop et al,2014)។ ទិដ្ឋភាពមួយផ្សេងទៀតនៃបរិយាកាសសិក្សាបែបសិស្សមជ្ឈមណ្ឌល គឺជួយតម្រង់គោលដៅជួយឱ្យសិស្សមានអារម្មណ៍ថាខ្លួនជាចំណែកមួយក្នុងក្រុម បង្កើនជំនឿចិត្តគ្នាទៅវិញទៅមក អនុវត្តការត្រិះរិះពិចារណានិងការសួរសំណួរ។ ដើម្បីសម្រេចបានគោលដៅទាំងនេះ គ្រូបង្រៀនគួរតែខិតខំអភិវឌ្ឍ និងអនុវត្តបរិយាកាសសិក្សាប្រកបដោយវិជ្ជមាន (Young,2014)។

បញ្ជីត្រួតពិនិត្យ ក្នុងតារាង១ ខាងក្រោម អាចត្រូវបានប្រើជាមូលដ្ឋាន ក្នុងការពិចារណា នៅពេលរៀបចំបរិយាកាសសិក្សា តាមបែបសិស្សមជ្ឈមណ្ឌល។

តារាង១៖ បញ្ជីត្រួតពិនិត្យ សម្រាប់បរិយាកាសសិក្សាតាមបែបសិស្សមជ្ឈមណ្ឌល[1]

☐ មានការទាក់ទាញសិស្សកម្រិតខ្ពស់	☐ សិស្សមានឱកាសធ្វើការរៀនសូត្រតាមដំណើររបស់ពួកគេ និងបង្ហាញចំណាប់អារម្មណ៍របស់គេផ្ទាល់
☐ សិស្សយល់អ្វីដែលពួកគេកំពុងរៀន និងដឹងពីមូលហេតុ និងរបៀបអនុវត្តក្នុងជីវិតពិត	☐ សិស្សធ្វើកិច្ចការ និងពិភាក្សាច្រើន

[1] Adapted from Liebtag (2017, online).

☐ មានបញ្ចូលគ្នារវាងការងារជាបុគ្គលម្នាក់ៗ និងជាក្រុម	☐ មានទម្រង់ផ្តល់យោបល់ត្រលប់ និងវាយតម្លៃច្រើនរបៀប
☐ កិច្ចការរបស់សិស្ស ត្រូវបានបង្ហាញនៅក្នុងថ្នាក់រៀន ឬនៅលើជញ្ជាំងតាមផ្លូវដើរនៃអាគារសិក្សា	☐ មានបញ្ចូលការណែនាំ វប្បធម៌ និងបរិយាកាសសិក្សា ឆ្លើយតបនឹងតម្រូវការផ្សេងៗគ្នារបស់សិស្ស
☐ មានការចូលរួមកម្រិតខ្ពស់ពីសំណាក់គ្រូបង្រៀន អាណាព្យាបាល សហគមន៍	☐ ការគាំទ្របរិស្ថាន សម្ភារៈ ឆ្លើយតបនឹងសកម្មភាពបង្រៀន និងរៀន

២- សារៈសំខាន់នៃបរិយាកាសសិក្សាបែបឥដ្ឋមាន

បរិយាកាសសិក្សា ជាផ្នែកមួយដ៏សំខាន់ក្នុងដំណើរសិក្សារបស់សិស្សឆ្ពោះទៅរកសមិទ្ធផលអប់រំ។ កត្តាសង្គម វប្បធម៌ រាងកាយ និងចិត្តសាស្ត្រអាចមានឥទ្ធិពលទៅលើសមត្ថភាពសិក្សារបស់សិស្ស។ ការបង្កើតឱ្យមានបរិយាកាសសិក្សាបែបអវិជ្ជមាន(ដូចជា សភាពតានតឹង ការផ្តល់មតិបែបអវិជ្ជមាន កង្វះខាតការទាក់ទងគ្នារវាងមិត្តភក្តិ និងគោលដៅដែលមិនបានកំណត់) អាចប៉ះពាល់ដល់ការសិក្សានិងរារាំងសិស្សពីការផ្តោតអារម្មណ៍ រារាំងដល់សមត្ថភាពក្នុងការរីកចម្រើនរបស់ពួកគេ។ ផ្ទុយទៅវិញបើសិស្សស្ថិតនៅក្នុងបរិយាកាសបែបវិជ្ជមាននោះ ពួកគេនឹងមានការរីកចម្រើនច្រើន (Young, 2014)។ ប៉ុន្តែគួរឱ្យស្តាយ មានកត្តាខាងក្រៅមួយចំនួន ដែលអាចគំរាមកំហែងដល់បរិយាកាសសិក្សាបែបវិជ្ជមាន។តាមទ្រឹស្តីប្រព័ន្ធអេកូឡូស៊ីរបស់លោក Bronfenbrenner (1997)បានណែនាំបញ្ញត្តិនៃបរិយាកាសចម្រុះ ដែលមានទំនាក់ទំនងទៅនឹងការអភិវឌ្ឍកុមារ។ តាមទស្សនៈប្រព័ន្ធអេកូឡូស៊ីរបស់លោក Bronfenbrenner មានជាស្រទាប់ៗដូចជាប្រព័ន្ធមីក្រូ(Microsystem) ប្រព័ន្ធមេសូ(Mesosystem) ប្រព័ន្ធអិចសូ(Exosystem) និងប្រព័ន្ធម៉ាក្រូ (Macrosystem)។ ប្រព័ន្ធមីក្រូ (Microsystem) ជាស្រទាប់ខាងក្នុងបំផុត និងជាបរិយាកាសដែលនៅកៀកបំផុតទៅនឹងកុមាររស់នៅ រួមមានផ្ទះសម្បែង សាលារៀន ទីរកដ្ឋាន ក្រុមគាំពារកុមារ និងសហគមន៍។ កុមារមានទំនាក់ទំនងផ្ទាល់ជាមួយ សមាជិកគ្រួសារ មិត្តរួមថ្នាក់ គ្រូបង្រៀន និងអ្នកមើលថែទាំ។ ចំណែកនៅក្នុងប្រព័ន្ធមេស៊ូ(Mesosystem) ជាអន្តរកម្មនិងទំនាក់ទំនងរវាងប្រព័ន្ធមីក្រូ(microsystems)នីមួយៗ។ ជាឧទាហរណ៍ ក្នុងប្រព័ន្ធមេសូ(Mesosystem) ទំនាក់ទំនងរវាងឪពុកម្តាយដែលតំណាងឱ្យផ្ទះ ដែលជាប្រព័ន្ធមីក្រូ(Microsystem)ជាមួយនឹងគ្រូបង្រៀនក្នុងករណីនេះជាតំណាងឱ្យសាលារៀនដែលជាប្រព័ន្ធមីក្រូ (Microsystem)

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

មួយផ្សេងទៀត។ ប្រព័ន្ធអិចសូ (Exosystem) ជាជីវិតរបស់មនុស្សដទៃទៀតដែលអាចមាន ឥទ្ធិពលលើកុមារ។ ស្រទាប់នេះមិនមានឥទ្ធិពលដោយផ្ទាល់ទៅលើការអភិវឌ្ឍរបស់កុមារទេ តែវាមានឥទ្ធិពលដោយប្រយោលតាមរយៈជីវិត និងបទពិសោធនានារបស់មនុស្សដែលនៅជុំវិញខ្លួន។ ឧទាហរណ៍: ឪពុកម្តាយដែលបានចូលរួមក្នុងសកម្មភាពក្រៅថ្នាក់រៀនមួយដែលជាកំលាក់នៅក្នុងកុមារភាពរបស់ពួកគេ អាចផ្តល់យោបល់ឱ្យកូនៗពួកគេធ្វើនូវសកម្មភាពដូចគ្នា។ ស្រទាប់ចុងក្រោយដែលហៅថាប្រព័ន្ធម៉ាក្រូ(Macrosystem) រួមមានតម្លៃ ជំនឿ បទដ្ឋាននានា ដែលមានផលប៉ះពាល់ទៅលើសង្គមដែលកុមារម្នាក់ៗចម្រើនវ័យដល់ធំដឹងក្តី (**Vest Ettekal និង Mahony,2017**)។ លទ្ធផលនៃទំនាក់ទំនងទាំងក្នុងប្រព័ន្ធ និងរវាងប្រព័ន្ធនិងប្រព័ន្ធ គឺពិតជាមានឥទ្ធិពលយ៉ាងខ្លាំងទៅលើ ការអភិវឌ្ឍរបស់កុមារម្នាក់ៗ សម្រាប់ប្រព័ន្ធមីក្រូ (microsystem) គ្រូបង្រៀនអាចមានឥទ្ធិពលដោយផ្ទាល់លើបរិយាកាសរៀនសូត្រនៅសាលារៀន។ ការផ្តល់នូវបទពិសោធសិក្សាជាវិជ្ជមានឱ្យបានគ្រប់គ្រា គ្រូបង្រៀនអាចជួយទប់ទល់បទ-ពិសោធន៍ អវិជ្ជមានដែលសិស្សបានឆ្លងកាត់ក្នុងផ្នែកផ្សេងៗនៃប្រព័ន្ធមីក្រូ (microsystem) របស់ពួកគេ (**Bucklerand Castle, 2014**)។ វិធីសាស្ត្ររបស់ Maria Montessori ក៏ជាក់ការចាប់អារម្មណ៍ទៅលើការបង្កើតបរិយាកាសសិក្សាបែបវិជ្ជមានផងដែរ ជាពិសេសសម្រាប់សិស្សក្មេងៗ។ វិធីសាស្ត្ររបស់ Montessori គឺផ្អែកលើគំនិតដែលថាក្មេងជាធម្មតាចង់បានចំណេះដឹងហើយអាចរៀនបាន។ សមត្ថភាពរៀននេះ អាចត្រូវបានលើកកម្ពស់តាមរយៈការផ្តល់នូវបរិយាកាសសិក្សាដែលរៀបចំបានល្អ សម្ភារសិក្សាសមស្របនឹងឱកាសសង្កេតមើលគំរូរៀមច្បង (**Tubaki, 2008**)។ ទិដ្ឋភាពមួយផ្សេងទៀតដ៏សំខាន់នៃយុទ្ធសាស្ត្រ Montessori គឺសម្ភារសិក្សា។ គាត់បានស្នើឱ្យរៀបចំសកម្មភាពឱ្យបានច្រើន និងសម្ភារសិក្សាគ្រប់គ្រាន់។

ដើម្បីធ្វើសកម្មភាពទាំងនេះបានចាំបាច់ត្រូវការការងារហត្ថកម្មនិងប្រាជ្ញា (**Marshall,2017**)។ យុទ្ធសាស្ត្ររបស់ Montessori មានគោលដៅផ្តួចផ្តើមនៃការស្វែងរកចំណេះដឹងយ៉ាងសកម្មរបស់សិស្សជាជាងការសិក្សាតាមបែបអសកម្ម។

> *គ្រូផ្តល់ជូនបរិយាកាសជាច្រើនបែបដែលសិស្សអាចមានសេរីភាពជ្រើសរើស និងឧបករណ៍ជំនួយដើម្បីសិស្សអាចឆ្លើយតបទៅនឹងសំណួរបាន។ ការពេញចិត្តដែលចេញពីក្នុងខ្លួនរបស់សិស្ស ជំរុញឱ្យពួកគេមានការចង់ចេះចង់ដឹង ចំណាប់អារម្មណ៍កាន់តែខ្លាំង ដែលជាលទ្ធផលធ្វើឱ្យពួកគេសប្បាយចិត្តក្នុងការសិក្សារហូតពេញមួយជីវិត (American Montessori Society, 2020, Online)។*

Maria Montessori- បានណែនាំនូវផ្ទះកុមារ ដែលត្រូវបានបង្កើតនូវបរិយាកាសមួយជំរុញ និងផ្តល់សេរីភាពដល់កុមារ រៀនដោយខ្លួនឯង។ ផ្ទះកុមារ គឺជាសួននៃប្បៃធម៌កុមារ។ គោលការណ៍ជាមូលដ្ឋាននៃបរិយាកាសសិក្សា

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

នៅពេលពិភាក្សាពីផលប្រយោជន៍នៃវិធីសាស្ត្រ Montessori ចាំបាច់ត្រូវចងចាំចំណុចសំខាន់ដូចបង្ហាញខាងលើនេះនៅក្នុងចិត្ត។ វិធីសាស្ត្របង្រៀនភាគច្រើនសព្វថ្ងៃគឺផ្តោតទៅលើជោគជ័យខាងការសិក្សា ចំណែកវិធីសាស្ត្រ Montessori វិញ គឺផ្តោតលើការអភិវឌ្ឍខាងផ្លូវចិត្ត អារម្មណ៍ និងប្រាជ្ញាស្មារតីរបស់កុមារម្នាក់ៗ(Marshall,2017)។ បរិយាកាសសិក្សាបែបវិជ្ជមាន ផ្តល់នូវមូលដ្ឋានគ្រឹះសម្រាប់ភាពជោគជ័យរបស់សិស្សម្នាក់ៗ ព្រោះវានឹងជំរុញឱ្យមានការចូលរួមយ៉ាងសកម្មក្នុងដំណើរការរៀនសូត្រនៅពេលសិស្សម្នាក់មានអារម្មណ៍រីករាយ និងមានថាមពលចូលរួមក្នុងបរិយាកាសសិក្សារបស់គេផ្ទាល់។ ពួកគេកាន់តែមានភាពទាក់ទាញចូលរួមក្នុងការរៀនសូត្រ ដែលនឹងនាំឆ្ពោះទៅរកការរីកចម្រើន(Young, 2014)។ មូលដ្ឋានគ្រឹះនៃទ្រឹស្តី Montessori ស្ថិតទៅលើទំនាក់ទំនងរវាងគ្រូបង្រៀន សិស្ស និងមជ្ឈដ្ឋានជុំវិញ (Marshall,2017)។

របស់វិធីសាស្ត្រ Montessori គឺមានបំពាក់នូវគ្រឿងសង្ហារឹម និងសម្ភារសិក្សាសមស្របសម្រាប់កុមារ (Montessori, 1912)។

៣- តើគ្រូបង្រៀនអាចបង្កើតបរិយាកាសសិក្សាវិជ្ជមានបានដោយរបៀបណា?

នៅពេលដែលចង់បង្កើតបរិយាកាសសិក្សាដែលមានសុវត្ថិភាព និងផ្តល់នូវលទ្ធផលល្អ គ្រូបង្រៀនត្រូវប្រឈមមុខជាមួយនឹងបញ្ហាលំបាកមួយចំនួន ដូចជាបញ្ហាឥរិយាបថរបស់សិស្ស កង្វះខាតធនធាន និងសម្ភារបង្រៀន ឬថ្នាក់រៀនដែលមានសិស្សច្រើន រួមទាំងមានកត្តាផ្សេងៗទៀតនៅខាងក្រៅសាលា។ ដើម្បីជម្នះនូវបញ្ហាទាំងនេះ និងដើម្បីបង្កើតបាននូវបរិយាកាសសិក្សាដែលវិជ្ជមាន និងជំរុញទឹកចិត្តសិស្ស គ្រូបង្រៀនគួរតែមានវិធីសាស្ត្រ និងធនធានចម្រុះជាច្រើន។ ពួកគាត់ត្រូវតែបង្ហាញនូវកត្តាពាក់ព័ន្ធទាំងឡាយ ដែលបង្អាក់ដំណើរការបង្កើតបរិយាកាសសិក្សាវិជ្ជមាន(Bank,2014)។ គ្រូបង្រៀនដែលបង្កើតបរិយាកាសសិក្សាវិជ្ជមានត្រូវចេះរៀបចំបរិបទទាំងឡាយ ដែលអាចជួយលើកទឹកចិត្តសិស្ស ឱ្យចូលរួមរៀនសូត្រ សួរសំណួរ យល់ពីអត្ថន័យ និងដោះស្រាយបញ្ហាដែលគ្រូដាក់ឱ្យ។ បរិយាកាសសិក្សាដែលក្មេងមានអារម្មណ៍ថាសុខស្រួល មានសុវត្ថិភាព និងដែលមិនប្រកាន់នូវកំហុសឆ្គង ពិតជាអាចជួយឱ្យគ្រូបង្រៀនអាចទាញយកបាននូវសក្តានុពលដ៏ពេញលេញរបស់ពួកគេមកប្រើប្រាស់បាន។

ខណៈដែលបរិយាកាសសិក្សាផ្សេងៗអាចមានភាពខុសប្លែកពីគ្នា ដោយយោងទៅតាមវប្បធម៌ និងបរិបទ ខាងក្រោមនេះមានសារៈសំខាន់ក្នុងការចូលរួមបង្កើតនូវបរិយាកាស

សិក្សាដែលផ្តល់ប្រសិទ្ធភាព ដែលអាចអនុញ្ញាតឱ្យសិស្សសម្រេចបាននូវសក្តានុពលដ៏ពេញលេញរបស់ពួកគេ។

៣.១- ការរៀបចំបរិយាកាសសិក្សាមានលក្ខណៈរីករាយក្នុងការសិក្សា

ការរៀបចំបរិយាកាសសិក្សា (មានដូចជា តុ កៅអី) អាចមានឥទ្ធិពលដោយផ្ទាល់ចំពោះការបង្រៀន និងទំនាក់ទំនងក្នុងថ្នាក់រៀន។ បរិយាកាសដែលរៀបចំបានល្អអាចបង្កើតនូវការស្វាគមន៍ និងការលើកទឹកចិត្តហើយវាអាចធ្វើឱ្យសិស្សមានអារម្មណ៍មានសេចក្តីសុខ មានសុវត្ថិភាព ជាកត្តាមូលដ្ឋានជំរុញឱ្យមានការរៀនសូត្រ។ ទោះជាយ៉ាងណាក៏ដោយ គ្មានវិធីណាមួយដែលសាកសមសម្រាប់សិស្សគ្រប់គ្នា ឬគ្រប់កាលៈទេសៈនោះទេ ហើយការរៀបចំថ្នាក់រៀនអាចនឹងសម្របសម្រួលទៅតាមប្រភេទនៃការបង្រៀនដែលកំពុងអនុវត្ត។ ឧទាហរណ៍ សម្រាប់ការងារជាក្រុមដែលលើកទឹកចិត្តឱ្យអ្នកសិក្សាមានទំនាក់ទំនងជាមួយគ្នាទៅវិញទៅមក ត្រូវការរៀបចំតុ កៅអីជារាងពាក់កណ្តាលរង្វង់។ សម្រាប់ការងារម្នាក់ឯង ឬការប្រលងគ្រូអាចត្រលប់ទៅរកការរៀបតុជាដូរវិញ។ ទោះជាយ៉ាងនេះក្តី វាមានសារៈសំខាន់ដែលត្រូវចងចាំថាសិស្សដែលអង្គុយនៅខាងក្រោយៗនៃថ្នាក់រៀន ជារឿយៗទទួលបាននូវការយកចិត្តទុកដាក់ និងបានទទួលផលតិចជាងសិស្សអង្គុយមុខ។ នេះជាមូលហេតុដែលការរៀបចំជាដួរបែបនេះគួរត្រូវធ្វើឡើងតែនៅពេលចាំបាច់ប៉ុណ្ណោះ។ វត្តមាននៃពណ៌ និងរូបភាពស្រស់ស្អាតនៅលើជញ្ជាំង ក៏មានសារៈសំខាន់ដូចជាការរៀបចំ តុ កៅអី ធនធាន និងសម្ភារៈដែរ។ គ្រូអាចបង្កើតទប់ឱ្យសិស្សទាំងអស់គ្នាចូលរួមក្នុងការរចនា រៀបចំ និងការសម្អាតថ្នាក់រៀន។ គ្រូបង្រៀនដែលចាំបាច់ត្រូវរៀបចំកន្លែងជាថ្មីញឹកញាប់ អាចពឹងសិស្សដែលស្ម័គ្រចិត្តជួយរៀបចំ។ ការបញ្ចូលសិស្សក្នុងការរចនារៀបចំថ្នាក់រៀននឹងជួយដល់ការបង្កើតគំនិតជាសហគមន៍ដល់ពួកគេ។ វានឹងជួយផ្តល់ឱ្យសិស្សនូវថាមពលនៅពេលដែលពួកគេចូលរួមជួយសម្របសម្រួលកំឡុងពេលគ្រូបង្រៀន(Banks,2014)។

៣.២- ការកំណត់លទ្ធផលរំពឹងទុកច្បាស់លាស់

ការកំណត់លទ្ធផលរំពឹងទុកច្បាស់លាស់ និងប្រាកដនិយមក្នុងបរិយាកាសសិក្សានឹងជួយសិស្សឱ្យយល់ពីវិធីទទួលបានភាពជោគជ័យនៅសាលារៀន។ គ្រូអាចកំណត់លទ្ធផលរំពឹងទុកលើផ្នែកផ្សេងៗនៃបរិយាកាសសិក្សា រាប់បញ្ចូលទាំងការកំណត់កាលវិភាគ និងវិន័យ។ ការកំណត់កាលវិភាគ ជាពិសេសសម្រាប់សិស្សក្មេងៗ នឹងជួយដល់សិស្សគ្រប់

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

គ្នា រួមទាំងគ្រូបង្រៀនផងដែរ ដើម្បីប្រមើមើលទុកមុននូវអ្វីដែលនឹងកើតមានឡើងនៅក្នុងថ្ងៃសិក្សា។ គ្រូគួរស្វែងរកមតិ ពីសិស្សផងដែរថាតើគេចង់បានកាលវិភាគបែបណា ដោយការសួរយោបល់ពួកគេអំពីសកម្មភាពត្រូវអនុវត្ត និងពេលវេលាដែលអាចបត់បែនបាន ដូចជាការសម្រាក ឬពេលវេលាសម្រាប់អំណានជាដើម។ល។គ្រូក៏គួរពិចារណាផងដែរទៅលើ **គោលការណ៍ Premack** នៅពេលបង្កើតកាលវិភាគ។

នៅពេលបង្កើតកាលវិភាគ ចំណុចដែលសិស្សយកចិត្តទុកដាក់ ឬចាប់អារម្មណ៍គួរត្រូវយកមកពិចារណា។ ដោយផ្អែកទៅលើកម្រិតនៃការសិក្សា អាយុ គេអាចសន្និដ្ឋានបានថា សិស្សអាចផ្ដង់អារម្មណ៍បានល្អក្នុងរយៈពេលតែ ២០ ទៅ ៣០នាទីប៉ុណ្ណោះ។ ការបង្កើតវិន័យក្នុងថ្នាក់រៀនជាក់លាក់ ជាដំហានដ៏មានសារៈសំខាន់ក្នុងការជំរុញឱ្យមានទំនាក់ទំនងបែបវិជ្ជមាន និងកំណត់ការពឹងទុក។ នៅដើមឆ្នាំសិក្សា គ្រូបង្រៀនគួរតែសម្រេចចិត្តចំពោះការកំណត់វិន័យថ្នាក់រៀន។ សិស្សគួរតែអាចចូលរួមបង្កើតវិន័យសម្រាប់ថ្នាក់រៀន និងផ្តល់ជាមតិយោបល់នៅពេលដែលវិន័យទាំងឡាយត្រូវបានសម្រេចយក។ សិស្ស គួរជួយគូសបញ្ជាក់ពីមូលហេតុ ដែលនាំឱ្យមានការកំណត់វិន័យមួយចំនួនដើម្បីអនុវត្តក្នុងថ្នាក់រៀនផងដែរ។ ឧទាហរណ៍ដូចជា ហេតុផលដែលត្រូវលើកដៃមុនពេលនិយាយ និងការពិភាក្សារកហេតុផល ក្នុងករណីធ្វើខុសវិន័យ (Banks,2014) ។

គោលការណ៍ Premack- ចែងថា សិស្សទំនងជាចង់ចូលរួមក្នុងសកម្មភាព ដែលគេមិនចូលចិត្តជាង ប្រសិនបើពួកគេដឹងថាពេលបន្ទាប់គឺសកម្មភាពដែលគេចូលចិត្ត (Banks,2014,p 521)

៣.៣- ការបង្កើតវប្បធម៌គាំទ្រគ្នា និងសុវត្ថិភាព

សិស្សនឹងឆ្លើយតបប្រកបដោយភាពវិជ្ជមាន និងមតិត្រលប់ប្រកបដោយការស្តាបនានៅពេលគេទទួលបានការសរសើរ ជាជាងការដាក់ទណ្ឌកម្ម។ វាជារឿងសំខាន់ក្នុងការបញ្ជាក់ និងពន្យល់បន្ថែមពីមូលហេតុច្បាស់លាស់នៃការសរសើរ ក៏ដូចជាការិះគន់។ រឿងនេះវាស្មើនឹងការសម្រួលឱ្យមានទំនាក់ទំនងត្រឹមត្រូវរវាងគ្រូបង្រៀន និងសិស្ស។ វាជាគន្លឹះធ្វើឱ្យសិស្សមានអារម្មណ៍ថាមានសុវត្ថិភា និងទទួលបានការគាំទ្រក្នុងបរិយាកាសរៀនសូត្ររបស់ពួកគេ។ គ្រូបង្រៀនត្រូវតែប្រាកដក្នុងចិត្តថា បានប្រើប្រាស់ពាក្យសម្តីត្រឹមត្រូវនៅពេលនិយាយជាមួយសិស្ស។លើសពីនេះទៅទៀតគ្រូអាចលើកកម្ពស់ទង្វើវិជ្ជមានដោយការជួយសិស្សដែលមានទង្វើមិនសមរម្យឱ្យទៅជាគំរូវិជ្ជមានវិញ។ តាមរយៈការផ្តល់ឱកាសឱ្យសិស្សចូលរួមអនុវត្តឥរិយាបថប្រកបដោយការលើកទឹកចិត្ត មានន័យថា គ្រូបានបង្កើតនូវបរិយាកាសសិក្សា ដែលនាំទៅរកលទ្ធផលវិជ្ជមាន (Banks, 2014)។ តារាង២ខាងក្រោម បង្ហាញពីឧទាហរណ៍ថ្នាក់រៀនបែបសិស្សមជ្ឈមណ្ឌល ដែលមានលក្ខណៈវិជ្ជមាន ធៀបនឹងថ្នាក់រៀនបែបគ្រូមជ្ឈមណ្ឌលដែលមានលក្ខណៈប្រពៃណី។

លក្ខណៈរបស់ថ្នាក់រៀនទាំងពីរនេះគឺមានភាពខុសគ្នាច្រើន។ បរិយាកាសសិក្សាបែបវិជ្ជមាន គឺយកចិត្តទុកដាក់លើសិស្ស។

៣.៤- ការគ្រប់គ្រងថ្នាក់រៀន

ដោយយោងទៅតាមការសិក្សាស្រាវជ្រាវ ការគ្រប់គ្រងថ្នាក់រៀន ជាបញ្ហាលំបាកសម្រាប់គ្រូបង្រៀនថ្មីភាគច្រើន ព្រោះពួកគាត់មិនបានត្រៀមលក្ខណៈឱ្យបានល្អជាមុនដើម្បីដោះស្រាយជាមួយនឹងសកម្មភាពរំខានរបស់សិស្ស។ ទោះជាយ៉ាងនេះក្តី ការដែលអាចរក្សាការគ្រប់គ្រងក្នុងថ្នាក់រៀនបាន គឺជាជំនាញមួយដ៏សំខាន់ ដែលគ្រូបង្រៀនចាំបាច់ត្រូវតែមានដើម្បីឱ្យការបង្រៀនមានប្រសិទ្ធភាព។ សមត្ថភាពគ្រូបង្រៀននេះគឺមានទំនាក់ទំនងផ្ទាល់ទៅនឹងលទ្ធផលសិក្សារបស់សិស្ស ព្រោះថា ថ្នាក់រៀនដែលមានការគ្រប់គ្រងបានល្អត្រឹមត្រូវនឹងធ្វើឱ្យការបង្រៀនមានភាពច្បាស់លាស់។ គ្រូបង្រៀនដែលប្រឈមនឹងបញ្ហានេះ ជាទូទៅគឺបណ្តាលមកពីពួកគាត់បានឆ្លងកាត់ការសិក្សាជំនាញនេះមិនមានប្រសិទ្ធភាព(Flower et al.2016)។ "ជាធម្មតា ការគ្រប់គ្រងថ្នាក់រៀនមិនបានល្អ ជាមូលហេតុចម្បងរបស់ថ្នាក់រៀនដែលអាក្រក់បំផុត។ គ្រូបង្រៀនដែលខ្សោយក្នុងការគ្រប់គ្រងថ្នាក់រៀន គឺតែងតែចំណាយពេលច្រើនតែទៅលើការគ្រប់គ្រងថ្នាក់រៀនហើយមិនមានពេលគ្រប់គ្រាន់សម្រាប់ការបង្រៀនទេ។ ថ្នាក់រៀនក្លាយទៅជាគ្មានចំណាប់អារម្មណ៍ និងគួរឱ្យរំខានសម្រាប់អ្នកចង់រៀន"។ (The New Teacher Project,2013,p.10)។ វិធីដ៏សំខាន់មួយ ដើម្បីធ្វើឱ្យការគ្រប់គ្រងថ្នាក់រៀនបានល្អប្រសើរ គឺត្រូវស្ង័យពិនិត្យតាមដាន។ ស្ង័យពិនិត្យតាមដាន ជាវិធីតាមដានត្រួតមើលនូវសកម្មភាពអាជីពរបស់ខ្លួនឯងផ្ទាល់។ ដើម្បីងាយស្រួល គេអាចប្រើបញ្ជីត្រួតពិនិត្យ (checklist) សម្រាប់ស្ង័យពិនិត្យតាមដាននេះ។ (Oliver et al.,2015) វាក៏មានប្រយោជន៍ផងដែរ ក្នុងការសង្កេតមើលសកម្មភាព និងការអភិវឌ្ឍរបស់សិស្ស។ គ្រូបង្រៀនអាចធ្វើ ដូច្នេះបានដោយឈរនៅទីតាំងដែលអាចមើលឃើញសកម្មភាពសិស្សច្បាស់ ផ្លាស់ទីនៅក្នុងថ្នាក់រៀន ផ្លាស់ប្តូរវិធីនិយាយ (ល្បឿន ការលើកដាក់សំឡេង) និងការធ្វើកាយវិការជាដើម (Stronge,2018)។

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

តារាង២៖ លក្ខណៈនៃបរិយាកាសសិក្សាបែបវិជ្ជមាន [2]

	បរិយាកាសថ្នាក់រៀន បែបគ្រូមជ្ឈមណ្ឌល	បរិយាកាសថ្នាក់រៀន បែបសិស្សមជ្ឈមណ្ឌល
ទំនាក់ទំនង	ឆ្ងាយគ្នា៖ គ្រូផ្តល់សារ ឬ និយាយពីខាងមុខថ្នាក់ដោយ បែរខ្នងទៅរកសិស្ស	កក់ក្តៅ និងរួសរាយ៖ គ្រូអង្គុយក្បែរ និង ញញឹមជាក់សិស្សដែលអង្គុយនៅកៅអី រៀបជារាងពាក់កណ្តាលរង្វង់
នរណាខ្លះនៅ ក្នុងថ្នាក់រៀន?	គ្រូ និងសិស្សមានសមត្ថភាព ស្រដៀងៗគ្នា	គ្រូ សិស្សមានប្រវត្តិសាវតារ និង សមត្ថភាពខុសៗគ្នា ទាំងការគាំទ្រពី អាណាព្យាបាល
ការរៀបចំកន្លែង អង្គុយ	ការរៀបចំកន្លែងអង្គុយដូចៗ គ្នាក្នុងគ្រប់ថ្នាក់រៀន(ក្មេងៗ អង្គុយទៅនឹងតុជាជួរ ស្រីៗនៅ ម្ខាង ប្រុសៗនៅម្ខាង)	ការរៀបចំកន្លែងអង្គុយខុសប្លែកគ្នាដូច ជាស្រី និងប្រុសអង្គុយជុំគ្នាលើកម្រាល ឥដ្ឋជារង្វង់ពីរជុំ ឬអង្គុយជុំគ្នានៅតាមតុ ជាក្រុម
សម្ភារសិក្សា	សៀវភៅពុម្ព សៀវភៅលំហាត់ ក្តារខៀន	សម្ភារៈផ្សេងៗសម្រាប់គ្រប់មុខវិជ្ជា ដូច ជាសម្ភារៈគណិតវិទ្យា ធ្វើឡើងពី ក្រដាសកាសែត ឬក្រដាសផ្ទាំងធំៗ និង តុក្តាសម្រាប់ថ្នាក់រៀនភាសា
ធនធានផ្សេងៗ	គ្រូឆ្លើយឆ្លង ឬធ្វើទំនាក់ ទំនងជាមួយសិស្សដោយគ្មាន ប្រើសម្ភារបង្រៀនបន្ថែមផ្សេង ទៀតទេ	គ្រូរៀបចំគម្រោងមួយថ្ងៃមុនបង្រៀន ឱ្យ សិស្សយកសម្ភារសិក្សាផ្សេងៗមកកាន់ ថ្នាក់រៀន ដោយមិនមានចំណាយប្រាក់
ការវាយតម្លៃ	សន្លឹកកិច្ចការប្រឡង ដែល សរសេរតាមបែបស្តង់ដារួម	វាយតម្លៃផ្អែកលើភាពជាក់ស្តែង ការសង្កេត ផ្អែកលើផលសម្រេចរបស់ សិស្សដូចជាសំណុំឯកសារសិក្សា (Portfolio)

[2] Adapted from UNESCO (2015, p. 24).

៤- ចំណុចគន្លឹះ

- ✓ បរិយាកាសសិក្សាមួយមិនសំដៅយកតែទីតាំងជាក់លាក់ណាមួយនោះទេ ក៏ប៉ុន្តែអាចជាកន្លែងណាក៏ដោយដែលការបង្រៀន និងការរៀនប្រព្រឹត្តទៅបាន
- ✓ បរិយាកាសសិក្សាសិស្សមជ្ឈមណ្ឌល(ផ្តោតទៅលើសិស្ស) ប្រសើរជាងបរិយាកាសសិក្សាបែបគ្រូមជ្ឈមណ្ឌល(ផ្តោតទៅលើគ្រូ)ព្រោះវាជំរុញឱ្យមាន ការគិតត្រិះរិះពិចារណា ការទាក់ទងគ្នាដោយប្រសិទ្ធភាព ហើយជួយទ្រទ្រង់ការសិក្សាពេញមួយជីវិត
- ✓ បរិយាកាសសិក្សាសិស្សមជ្ឈមណ្ឌលគឺអាស្រ័យដោយការរៀបចំ។ បរិយាកាសទាំងនេះអាចពាក់ព័ន្ធទៅនឹងការរៀបតុជារង្វង់ ឬជាក្រុមតូចៗ (ជាជាងរៀបជាជួរបែរទៅរកគ្រូ) សិក្សាតាមតម្រូវការសិស្ស ផ្សារភ្ជាប់បទពិសោធពីខាងក្រៅថ្នាក់រៀន
- ✓ សិស្សានុសិស្សនៅក្នុងបរិយាកាសសិក្សាសិស្សមជ្ឈមណ្ឌល មានឱកាសសិក្សាតាមសមត្ថភាពខ្លួន បង្ហាញនូវចំណាប់អារម្មណ៍ផ្ទាល់ខ្លួន និយាយពិភាក្សាគ្នាច្រើន យល់ពីអ្វីដែលគេកំពុងរៀន ពីមូលហេតុទំនាក់ទំនងជិតស្និតក្នុងកិច្ចការរបស់គេ
- ✓ បរិយាកាសសិក្សា ជាសមាសភាពសំខាន់ក្នុងវិធីទៅកាន់សមិទ្ធផលអប់រំរបស់សិស្ស ប៉ុន្តែនៅមានកត្តាខាងក្រៅជាច្រើន ដែលអាចគំរាមគំហែងដល់បរិយាកាសសិក្សាបែបវិជ្ជមាន
- ✓ ក្នុងទ្រឹស្តីប្រព័ន្ធអេកូលូស៊ីរបស់លោក Bronfenbrenner បានបង្ហាញ ពីបញ្ហត្តិ
- ✓ ពហុបរិយាកាសសិក្សាដែលជាប់ពាក់ព័ន្ធទៅនឹងការអភិវឌ្ឍរបស់កុមារ។ ទ្រឹស្តីនេះបានលើកឡើងពីប្រព័ន្ធទំនាក់ទំនងសំខាន់ៗដូចជា ប្រព័ន្ធមីក្រូ(Microsystem) ទំនាក់ទំនងរវាងផ្ទះ សាលារៀន គ្រួសារ មិត្តរួមថ្នាក់ ប្រព័ន្ធមេសូ (Mesosystem) ទំនាក់ទំនងរវាងប្រព័ន្ធមីក្រូ ប្រព័ន្ធអិចសូ (Exosystem កត្តាខាងក្រៅដូចជា ប្រព័ន្ធអប់រំ និងនយោបាយ) និងប្រព័ន្ធម៉ាក្រូ (Macrosystem តម្លៃ ជំនឿ និងបទដ្ឋាននានា)។ គ្រូមិនត្រឹមតែមានឥទ្ធិពលដោយផ្ទាល់ទៅលើបរិយាកាសសិក្សានៅសាលារៀន ប៉ុន្តែក៏បានផ្តល់បទពិសោធសិក្សាបែបវិជ្ជមានផងដែរ ដែលអាចជួយផ្លាស់ប្តូរបទពិសោធមិនល្អដែលសិស្សទទួលបានពី ប្រព័ន្ធមីក្រូ(microsystem) របស់ពួកគេ

- ✓ វិធីសាស្ត្ររបស់ Maria Montessori គឺផ្អែកលើគំនិតដែលថាក្មេងៗជាធម្មតាគឺចង់ចេះ ចង់ដឹង ហើយអាចរៀនបានតាមរយៈការបង្កើតបរិយាកាសសិក្សាបែបវិជ្ជមាន ដោយមានការរៀបចំសម្ភារសិក្សាបានល្អ គ្រប់គ្រាន់ បង្កើនចំណង់ក្នុងការរៀនសូត្ររបស់សិស្ស
- ✓ ក្នុងការបង្កើតបរិយាកាសសិក្សាបែបវិជ្ជមាន គ្រូគួរតែផ្តោតអារម្មណ៍ទៅលើការរៀបចំប្រកបដោយភាពច្នៃប្រឌិត (មានដូចជាការរៀបចំគ្រឿងសង្ហារឹម ពន្លឺ ធម្មជាតិ ការលម្អ ពណ៌) ការកំណត់លទ្ធផលរំពឹងទុកច្បាស់លាស់ (មានដូចជា កាលវិភាគ គោលដៅ ច្បាប់វិន័យផ្សេងៗ) និងការបង្កើតឱ្យមានវប្បធម៌គាំទ្រ និងសុវត្ថិភាព (មានដូចជា ការសរសើរ ការផ្តល់មតិកែលម្អ និងការប្រើភាសាជាពាក្យសមរម្យ។

ឯកសារយោង

American Montessori Society. (2020). *About Montessori*. Retrieved from: https://amshq.org/ [2020, Nov. 16].

Banks, T. (2014). Creating Positive Learning Environments: Antecedent Strategies for Managing the Classroom Environment & Student Behavior. *Creative Education*, 5, 519-524.

Bishop C. F., Caston, M. I., & King, C. A. (2014). Learner-Centered Environments: Creating Effective Strategies Based on Student Attitudes and Faculty Reflection. *Journal of the Scholarship of Teaching and Learning*, 14 (3), 46-63.

Bronfenbrenner, U. (1977). Toward an Experimental Ecology of Human Development. *American Psychologist*, 32(7), 513-531.

Buckler, S. & Castle, P. (2014). *Psychology for Teachers*. London: Sage.

Doyle, T. (2008). *Helping Students Learn in a Learner-Centered Environment: A Guide to Facilitating Learning in Higher Education*. Sterling, VA: Stylus Publishing.

Flower, A., McKenna, J. W., & Haring, C. D. (2016). Behavior and Classroom Management: Are Teacher Preparation Programs Really Preparing our Teachers? *Preventing School Failure: Alternative Education for Children and Youth*, *61*(2), 163–169.

Ifenthaler, D. (2012). Designing of Learning Environment. *Encyclopedia of the Sciences of Learning*. Springer.

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

Liebtag, E. (2017). *8 Things to Look for in a Student-Centered Learning Environment*. Retrieved from: https://www.gettingsmart.com/2017/08/8-things-look-student-centered-learning-environment/ [2021, Apr. 22].

Marshall, C. (2017). Montessori Education: A Review of the Evidence Base. *Science of Learning*, 11.

Montessori, M. (1912). *The Montessori Method. Scientific Pedagogy as Applied to Child Education in "The Children's Houses" with Additions and Revisions by the Author.* New York: Frederick A. Stokes Company.

Oliver, R. M., Wehby, J. H., & Nelson, J. R. (2015). Helping Teachers Maintain Classroom Management Practices Using a Self-Monitoring Checklist. *Teaching and Teacher Education*, 51, 113–120.

Rieber, L.P. (2001). *Designing Learning Environments that Excite Serious Play*. Paper presented at the annual meeting of the Australasian Society for Computers in Learning in Tertiary Education, Melbourne, Australia.

Stronge, J. H. (2018). *Qualities of Effective Teachers* (3rd ed). Alexandria, Virginia: ASCD.

The Glossary of Education Reform (2013, August 29). *Learning Environment*. Retrieved from: https://www.edglossary.org/learning-environment/ [2020, Nov. 9].

The Glossary of Education Reform (2014, May 7). *Student-Centered Learning*. Retrieved from: https://www.edglossary.org/student-centered-learning/ [2020, Apr. 27].

The New Teacher Project. (2013, August). *Perspectives of Irreplaceable Teachers: What America's Best Teachers Think About Teaching*. Retrieved from: https://tntp.org/publications/view/retention-and-school-culture/perspectives-of-irreplaceable-teachers-best-teachers-think-about-teaching [2021, Mar. 18].

Tubaki, M. & Matsuishi, M., (2019). *On the Pedagogical Theory of Maria Montessori*. Yokohama National University, Faculty of Education and Human Sciences, Department of Disability Studies.

UNESCO (2015). *Embracing Diversity: Toolkit for Creating Inclusive, Learning-Friendly Environments*. UNESCO Bangkok Office.

Vest Ettekal, A. & Mahoney, A. (2017). Ecological Systems Theory. In: K. Peppler, ed. *The SAGE Encyclopedia of Out-of-School Learning* (pp. 239-243). SAGE Publications.

Young, J. (2014). *Encouragement in the Classroom: How Do I Help Students Stay Positive and Focused?* ASCD Arias.

ជំហានទី១- ពង្រឹងចំណេះដឹង

ក.ចូរដាក់លក្ខណៈខាងក្រោម ចូលទៅក្នុងក្រុមដែលត្រឹមត្រូវក្នុងតារាងខាងក្រោមៈ

១.គ្រូបង្រៀនគ្រប់គ្រងទាំងស្រុងទៅលើសម្ភារសិក្សារបស់សិស្ស

២.សិស្សបង្ហាញពីចំណាប់អារម្មណ៍ផ្ទាល់ខ្លួនរបស់ពួកគេ

៣.គ្រូបង្រៀនណែនាំលើវិធីដែលសិស្សរៀន(ពេលវេលា ទីកន្លែង វិធីសាស្ត្រ និងល្បឿន)

៤.កៅអីត្រូវបានរៀបចំជារាងពាក់កណ្តាលរង្វង់តូច

៥.គ្រូជាមនុស្សសកម្មបំផុតនៅក្នុងថ្នាក់រៀន

៦.សិស្សធ្វើការជាក្រុម

៧.គ្រូនិយាយភាគច្រើនក្នុងថ្នាក់

៨.សិស្សធ្វើកិច្ចការតាមសមត្ថភាពខ្លួន

៩.មានដាក់តាំងបង្ហាញកិច្ចការសិស្សនៅតាមជញ្ជាំង

១០.សិស្សអង្គុយម្នាក់ឯងតាមតុរៀបជាជួរ

១១.កូនសិស្សស្តាប់កត់ត្រា បំពេញកិច្ចការដោយឡែកៗពីគ្នា

១២.សិស្សនិយាយភាគច្រើនក្នុងថ្នាក់

១៣.គ្រូឈរនៅខាងមុខថ្នាក់សរសេរលើក្តារខៀន

១៤.សិស្សទទួលបានបទពិសោធពីខាងក្រៅថ្នាក់រៀន

បរិយាកាសសិក្សាគ្រូមជ្ឈមណ្ឌល	បរិយាកាសសិក្សាសិស្សមជ្ឈមណ្ឌល

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ខ.ចូរបំពេញឈ្មោះប្រព័ន្ធអេកូឡូស៊ីរបស់លោក Bronfenbrenner ក្នុងរូបភាពខាងក្រោម រួចចូរដាក់សមាសភាពដូចជាមនុស្ស និងកន្លែងខាងក្រោមចូលក្នុងស្រទាប់នីមួយៗឱ្យបានត្រឹមត្រូវ៖

ផ្ទះ- សាលារៀន- ជំនឿក្នុងសង្គម- ប្រព័ន្ធអប់រំ -ការថែទាំពេលថ្ងៃ- តម្លៃក្នុងសង្គម -ប្រព័ន្ធផ្សព្វផ្សាយ- សហគមន៍- ប្រព័ន្ធសេដ្ឋកិច្ច- សមាជិកក្រុមគ្រួសារ- គ្រូបង្រៀន- ប្រព័ន្ធនយោបាយ- បទដ្ឋានសង្គម

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ក. ចូរឆ្លើយសំណួរពហុជ្រើសរើសខាងក្រោម។ មានចម្លើយត្រូវតែមួយគត់៖

១.បរិយាកាសសិក្សាសំដៅលើ

ក.ថ្នាក់រៀនដែលគ្រប់គ្រងដោយគ្រូ

ខ.ថ្នាក់រៀនមួយក្នុងសាលារៀន

គ.គ្រប់បន្ទប់ និងគ្រប់ទីកន្លែងក្នុងសាលារៀន

ឃ.ទីតាំងជាក់លាក់ជម្រុះបរិបទ វប្បធម៌ និងទម្លាប់ដែលសិស្សរៀន

២.ដោយយោងទៅតាមអត្ថបទមេរៀន តើគំនិតមួយណា ដែលមិនមែនជាប្រយោជន៍សម្រាប់បង្កើតបរិយាកាសសិស្សមជ្ឈមណ្ឌល?

ក.ការយល់ពីរបៀបរៀនរបស់មនុស្ស

ខ.ការយល់ពីរបៀបអនុវត្តបទបញ្ជា និងច្បាប់

គ.ការត្រៀមខ្លួនសម្រាប់ជីវិតការងារ

ឃ.ការត្រៀមខ្លួនដើម្បីក្លាយជាអ្នករៀនពេញមួយជីវិត

៣.ដោយយោងតាមវិធីសាស្ត្រ Montessori តើអ្វីជំរុញឱ្យមានការចង់ចេះចង់ដឹងរបស់កុមារម្នាក់ៗ?

ក.ការទទួលបានពិន្ទុចំណាត់ថ្នាក់ល្អ

ខ.ការធ្វើឱ្យឪពុកម្តាយសប្បាយចិត្ត
គ.ការពេញចិត្តពីខាងក្នុង
ឃ.ជោគជ័យមុខវិជ្ជាសិក្សាទាំងអស់

៤.មូលដ្ឋានគ្រឹះនៃវិធីសាស្ត្ររបស់ Montessori គឺស្ថិតនៅក្នុងទំនាក់ទំនងរវាង

ក.គ្រូ សិស្ស និងបរិយាកាស
ខ.សិស្ស សម្ភារៈ និងបរិយាកាស
គ.គ្រូ សម្ភារៈ និងសិស្ស
ឃ.គ្រូ ឪពុកម្តាយ និងបរិយាកាស

៥.តើចម្លើយមួយណាខាងក្រោមនេះ ជាបរិយាកាសសិក្សាដែលមានលក្ខណៈស្វាគមន៍?

ក.បរិយាកាសសិក្សាទាំងអស់គួរតែធ្វើតាមគំរូតែមួយដូចគ្នា គុ កៅអី គួរតែរៀបជាក្រុមតូចៗ ជញ្ជាំងគួរតែតុបតែងលម្អដោយមានពណ៌ស្រស់ស្អាត
ខ.តុ កៅអី គួរតែរៀបជាជួរ ដោយបែរមុខទៅរកគ្រូដែលនៅខាងមុខថ្នាក់
គ.តុ កៅអីគួរតែរៀបចំសារជាថ្មីជារៀងរាល់ថ្ងៃ ដើម្បីឱ្យសិស្សចាប់អារម្មណ៍
ឃ.តុ កៅអីគួរតែរៀបចំដោយផ្អែកលើប្រភេទនៃការបង្រៀនដែលត្រូវអនុវត្ត

៦.តើចម្លើយមួយណាក្នុងចំណោមខាងក្រោមនេះ ដែលចែងថា «សិស្សទំនងជាចូលរួមកាន់តែសកម្មក្នុងសកម្មភាពដែលគេមិនសូវចូលចិត្ត ប្រសិនបើពួកគេដឹងថានឹងមានសកម្មភាពបន្ទាប់ ដែលពួកគេពេញចិត្តធ្វើ»?

ក.គោលការណ៍ Premack
ខ.ទ្រឹស្តីប្រព័ន្ធអេកូឡូស៊ីរបស់លោក Bronfenbrenner
គ.វិធីសាស្ត្ររបស់ Maria Montessori
ឃ.វិធីសាស្ត្រសិស្សមជ្ឈមណ្ឌល

៧. នៅពេលបង្កើតវិន័យ និងកាលវិភាគសម្រាប់ថ្នាក់រៀន គ្រូគួរតែ៖

ក.ឱ្យសិស្សផ្តល់ធាតុចូល និងមតិយោបល់របស់ពួកគេ
ខ.ឱ្យសិស្សបំពេញ និងបង្ហាញនៅថ្នាក់រៀនថ្ងៃដំបូង
គ.ផ្សារភ្ជាប់ច្បាប់វិន័យនីមួយៗជាមួយនឹងទណ្ឌកម្មដែលត្រូវទទួល
ឃ.ប្រាកដច្បាស់ក្នុងចិត្តថា សកម្មភាពគួរជាទីពេញចិត្ត ត្រូវដាក់មុនសកម្មភាពដែលមិនសូវពេញចិត្ត

ជំហានទី២- អនុវត្ត

ក.ចូរអានការពណ៌នានៃថ្នាក់រៀន-ក និងថ្នាក់រៀន-ខ។

ចូរដាក់លក្ខណៈខាងក្រោមចូលទៅក្នុងក្រុមដែលត្រឹមត្រូវក្នុងតារាងខាងក្រោម។ លក្ខណៈមួយចំនួនអាច ដាក់ចូលក្នុងក្រុមលើសពីមួយ៖

១.មិនអាចអនុវត្តបាន ២.សម្ភារៈដែលសិស្សយកមក ៣.សៀវភៅពុម្ព ៤.តុកៅអីរៀបជាជួរ ៥.ឈរបង្រៀននៅផ្នែកខាងមុខ ៦.អ្នកស្ម័គ្រចិត្តខាងអាណាព្យាបាល ៧.ក្តារខៀន ៨.រង្វង់នៅលើកម្រាលឥដ្ឋ ៩.ការងារជាក្រុម ១០.ការចូលរួមរបស់សិស្ស ១១.ក្រុមតូចៗ ១២.សៀវភៅលំហាត់ ១៣.សម្ភារៈយកមកពីផ្ទះ ១៤.ការផ្តល់ពាក្យសម្តីវិជ្ជមាន និងផ្តល់ព័ត៌មានត្រលប់ជាក់ស្តែង ១៥.កម្រិតនៃការចូលរួមខ្ពស់ក្នុងចំណោមសិស្ស និងគ្រូ ១៦.ការរៀនបែបដដែលៗ ១៧.ក្រុមតូច ១៨.កាសែត ១៩.បែងចែកតាមភេទ ២០.ធ្វើកិច្ចការតាមសមត្ថភាពរបស់ខ្លួន ២១.សិស្សធ្វើកិច្ចការច្រើន ២២.ដីស ២៣.ការសួរសំណួរបិទ

ថ្នាក់រៀន-ក

កុមារចំនួន៤០នាក់អង្គុយលើកៅអីឈើពីក្រោយតុវែង ដោយបើកសៀវភៅលំហាត់ និងកាន់ប៊ិកក្នុងដៃ។ គ្រូកំពុងតែកត់ចម្លងមេរៀនពីក្នុងសៀវភៅថ្នាក់ទី៣ នៅលើក្តារខៀនដោយប្រុងប្រយ័ត្ន។ សិស្សប្រុសដែលអង្គុយនៅផ្នែកខាងស្តាំកំពុងកត់ត្រាតាមគ្រូ និងសិស្សស្រីៗដែលអង្គុយនៅខាងឆ្វេងកំពុងរង់ចាំឱ្យគ្រូរំកិលចេញបន្តិច ដើម្បីអាចកត់ត្រាដែរ។ ពួកគេកត់ចម្លងដាក់ក្នុងសៀវភៅលំហាត់ពួកគេ។ នៅពេលកំពុងកត់លើក្តារខៀន គ្រូសួរសិស្សថា "តើកូនៗទាំងអស់គ្នាកំពុងកត់មេរៀនដែលគ្រូកំពុងសរសេរដែរ ឬទេ?" សិស្សឆ្លើយថា "ចាស/បាទ"។

ថ្នាក់រៀន-ខ

សិស្សមួយក្រុមកំពុងអង្គុយនៅលើឥដ្ឋជា២រង្វង់។ ក្រុមទាំង២មានទាំងសិស្សស្រីនិងសិស្សប្រុស។ គ្រូថ្នាក់ទី៣កំពុងបង្រៀនអំពី "ទម្រង់រូបរាង" នៃវត្ថុទៅកាន់សិស្ស។ នៅក្រុមទី១សិស្ស កំពុងពិភាក្សាគ្នាអំពីរង្វង់។ គ្រូកំពុងបង្ហាញសិស្សនូវវត្ថុរាងមូលជាច្រើនដែលគាត់បានឱ្យសិស្សយកពីផ្ទះមក។ បន្ទាប់មកកូនសិស្សក៏ចាប់ផ្តើមធ្វើការជាក្រុម ដើម្បីជួយគ្នាប្រាប់ពីវត្ថុដែលមានរាងមូលផ្សេងៗទៀត។ នៅក្រុមទី២ សិស្សខ្លះកំពុងកាន់ក្រដាសកាសែតដែលមូរឱ្យដូចជាចង្កឹះវែង។ បន្ទាប់មកគ្រូចាប់ផ្តើមហៅលេខ ហើយសិស្សដែលមានលេខនោះ ត្រូវដាក់ចង្កឹះ កាសែតនៅលើឥដ្ឋ កណ្តាលក្រុមដើម្បីចាប់ផ្តើមបង្កើតជារូបរាងការេ។ សិស្សម្នាក់នៅក្នុងក្រុមដែលមានបញ្ហាត្រចៀក ដាក់ចង្កឹះក្រដាសរបស់គាត់ ដើម្បីបង្កើតជារាងត្រីកោណ ហើយញញឹមដាក់គ្រូ។ គ្រូញញឹមតបហើយនិយាយថា"ល្អណាស់" ហើយនិយាយដោយធ្វើម៉ែចឱ្យសិស្សនោះអាចមើលបបូរមាត់របស់គាត់ ឃើញថាគាត់កំពុងនិយាយអ្វីជាមួយ។ ឪពុក/ម្តាយម្នាក់ដែលបានស្ម័គ្រចិត្តធ្វើជា

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ជំនួយការគ្រូមួយសប្តាហ៍ នៅពេលនោះបានគោះដៃសិស្សនោះតិចៗ ហើយជួយពន្យល់សិស្សដែលបានដាក់ចង្កឹះកាសែតច្រឡំកន្លែង រួចបង្កើតជារូបរាងថ្មីៗ[3]

	ថ្នាក់រៀន-ក	ថ្នាក់រៀន-ខ
ធាតុនៃសិស្សមជ្ឈមណ្ឌល		
ធាតុនៃគ្រូមជ្ឈមណ្ឌល		
ការរៀបចំកន្លែងអង្គុយ		
សម្ភារសិក្សាដែលមាន		
ធនធានរបស់គ្រូបង្រៀន		
មតិយោបល់របស់គ្រូបង្រៀន		

ខ.ចូរមើលរូបភាពខាងក្រោម រួចដាក់លក្ខណៈទាំងឡាយខាងក្រោមចូលទៅតាមរូបភាពនៃបរិយាកាសសិក្សាសមស្របៈ

១.មានកន្លែងរៀបចំតុ និងកៅអី
២.មានកន្លែងគ្រប់គ្រាន់សម្រាប់សិស្សរំកិលចុះឡើងដោយមិនរំខានអ្នកដទៃ
៣.មានកន្លែងគ្រប់គ្រាន់សម្រាប់សិស្សពិការចូលរៀននិងអាចរំកិលចុះឡើងក្នុងថ្នាក់ដោយងាយស្រួល
៤.កង្វះខាតនៃពន្លឺធម្មជាតិ
៥.កិច្ចការរបស់សិស្សត្រូវបានដាក់បង្ហាញនៅលើជញ្ជាំង
៦.មានពន្លឺធម្មជាតិ
៧.ការតុបតែងលម្អដោយពណ៌
៨.ការរៀបចំកន្លែងអង្គុយដូចៗគ្នា
៩.ការរៀបចំកន្លែងអង្គុយខុសៗគ្នា
១០.ការបង្រៀននៅតែផ្នែកខាងមុខនៃថ្នាក់រៀន

បរិយាកាសសិក្សា	លក្ខណៈនានា

[3] Adapted from UNESCO/Booklet One (2015, p. 22).

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

Picture Source: Open Source from pixabay.com

គ.ចូរអានគន្លឹះខាងក្រោម ស្តីពីការបង្កើតបរិយាកាសថ្នាក់រៀនបែបវិជ្ជមាន រួចបំពេញតារាងខាងក្រោម អំពីថ្នាក់រៀនរបស់អ្នកបច្ចុប្បន្ន/ថ្នាក់រៀនអនាគត៖

ចំណុចគន្លឹះក្នុងការរៀបចំ

គ្រូបង្រៀនជាច្រើនអាចនឹងយល់ថា វាលំបាកសម្រាប់ការក្សាបាននូវថ្នាក់រៀន ដែលមានសណ្តាប់ធ្នាប់ និងមានការជំរុញទឹកចិត្ត។ សម្រាប់ហេតុផលនេះ គ្រូអាចធ្វើការជាមួយសិស្ស ឪពុកម្តាយ និងអ្នកដឹកនាំសហគមន៍ទាំងឡាយឱ្យជួយផ្តល់ និងការពារសម្ភារសិក្សា។ សម្ភារៈមួយចំនួនប្រហែលជាត្រូវរៀបចំទុកដាក់ឡើងវិញជារៀងរាល់ថ្ងៃក្នុងប្រអប់ ឬទូដែលមានសុវត្ថិភាព។ គ្រូអាចឱ្យសិស្សជួយទទួលខុសត្រូវក្នុងការទុកដាក់របស់របរ ឬយកវត្ថុទាំងនោះទៅផ្ទះ និងយកមកវិញនៅថ្ងៃបន្ទាប់។ ឪពុកម្តាយ និងសហគមន៍អាចត្រូវបានជំរុញលើកទឹកចិត្តឱ្យជួយបរិច្ចាកសម្ភារៈមួយចំនួន ទៅឱ្យសាលារៀនដែលអាចប្រើជាប្រយោជន៍សម្រាប់សម្ភារសិក្សា ឬជាវត្ថុសម្រាប់រៀបចំលម្អក្នុងថ្នាក់រៀន។ នៅពេលដែលឱ្យ

ឪពុកម្តាយ អ្នកអាណាព្យាបាល និងសហគមន៍ត្រូវបានលើកទឹកចិត្តឱ្យចូលរួមយ៉ាងសកម្ម ជួយគ្រូក្នុងដំណើរការសាលារៀន នឹងឱ្យសហគមន៍កាន់តែមានភាពរឹងមាំ។

បណ្ណាល័យ

បណ្ណាល័យនៅសាលារៀន គឺជាប្រភពធនធានដ៏សំខាន់ក្រៃលែងសម្រាប់សិស្ស និងសហគមន៍ទាំងមូល។ តែជាអកុសលនៅសហគមន៍ជនបទជាច្រើនខ្វះខាតបរិក្ខាបណ្ណាល័យ ដូច្នេះសិស្សគ្មានឱកាសនឹងបានអានសៀវភៅបានច្រើននោះទេ។ បណ្ណាល័យក្នុងថ្នាក់រៀនមួយ អាចនឹងត្រូវបានបង្កើតឡើងដោយប្រើប្រអប់កេសរឹង ដែលត្រូវបានតុបតែងលម្អ និងដាក់បំពេញដោយសៀវភៅដែលបង្កើតឡើងដោយសមាជិកក្នុងថ្នាក់។ នៅពេលក្មេងៗបង្កើតសៀវភៅផ្ទាល់ខ្លួនរបស់គេ ទោះបីជាវាជាសៀវភៅសាមញ្ញយ៉ាងណាក៏ដោយ ពួកគេមានមោទនភាពដោយឃើញរឿងរបស់គេបោះពុម្ព។ ពួកគេក៏បានរៀនពីរបៀបផលិតសៀវភៅ របៀបបែងចែក និងថែរក្សា។ គ្រូអាចឱ្យសិស្សបង្កើតជាសៀវភៅបត់ ដែលសៀវភៅទាំងនេះបង្កើតឡើងពីក្រដាសបត់ពីរ ឬបីផ្ទត់ដោយមានអត្ថបទនៅតាមទំព័រនីមួយ ដូចជាខិតប័ណ្ណដូច្នោះដែរ។ ក្មេងអាចអធិប្បាយដោយរូបភាពទៅលើសៀវភៅទាំងនេះ ហើយសៀវភៅទាំងនេះនឹងក្លាយជាសម្ភារសម្រាប់អានដ៏មានតម្លៃនៅពេលដែលមិនសូវមានសៀវភៅ។ សៀវភៅដែលបង្កើតឡើងដោយសិស្សក៏អាចជាជំនួយក្នុងការបង្រៀនដ៏មានប្រសិទ្ធភាពផងដែរ។ ការពន្យល់ ឬការបង្ហាញដែលក្មេងៗបានសរសេរបញ្ចូលក្នុងសៀវភៅរបស់ពួកគេ អាចជួយដល់ក្មេងដទៃឱ្យយល់ពីគំនិតសំខាន់មួយទាំងនោះ។ ក្មេងៗមើលឃើញបញ្ហាដោយវិធីខុសគ្នាពីមនុស្សពេញវ័យ។ ពួកគាត់ប្រើភាសាដែលងាយយល់ជាង ហើយពួកគេអាចចែករំលែកព័ត៌មានសំខាន់ៗដោយជោគជ័យ ដែលអាចនឹងលឿនជាងគ្រូក្នុងពេលខ្លះ។ ចូរក្រឡេកមើលសៀវភៅដែលធ្វើដោយសិស្សរបស់អ្នក។ លើសពីនេះ សៀវភៅអាចត្រូវបានប្រើដើម្បីបង្រៀនជំនាញផ្សេងៗ ជាពិសេសសម្រាប់សិស្សដែលមានបញ្ហាក្នុងការមើល។ ឧទាហរណ៍ សៀវភៅអាចត្រូវបានបង្កើតដោយប្រើជំរបិទសម្ភារៈ ឧបករណ៍ រូបភាពទាំងឡាយនៅលើទំព័រ។ សិស្សអាចរៀនពីរបស់ទាំងនេះដោយការស្ទាប ឧទាហរណ៍ ត្រីកោណមួយត្រូវបានបិទទៅលើទំព័រសៀវភៅដើម្បីឱ្យសិស្សមានបញ្ហាភ្នែក អាចរៀនពីរាងត្រីកោណ។ ទោះជាសិស្សដែលអាចមើលឃើញច្បាស់ ក៏អាចពេញចិត្តនឹងការបង្កើតសៀវភៅស្ទាបបែបហ្នឹងដែរ ហើយពួកគេអាចអនុវត្តប្រើពួកវាដោយការបិទភ្នែករបស់ពួកគេ។ ស្លាកសញ្ញាសម្រាប់ស្ទាប ជាជាងការមើល ក៏អាចត្រូវបានផលិត និងដាក់នៅកន្លែង សម្រាប់តាំងបង្ហាញនោះផងដែរ។

តំបន់សម្រាប់តាំងបង្ហាញ

តំបន់សម្រាប់តាំងបង្ហាញការបង្ហាញសម្ភារបង្រៀន និងកិច្ចការរបស់សិស្សក្នុងថ្នាក់រៀន នឹងជួយឱ្យសិស្សចាប់អារម្មណ៍ទៅលើការសិក្សារបស់ពួកគេ និងមានអារម្មណ៍ថាពួកគេជាសមាជិកក្នុងថ្នាក់រៀន។

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ឪពុកម្តាយក៏នឹងចាប់អារម្មណ៍ជាងមុន ព្រមទាំងយល់បានកាន់តែប្រសើរឡើងពីការងារដែលកំពុងកើតឡើងនៅក្នុងថ្នាក់រៀន។ កិច្ចការរបស់សិស្សទាំងអស់គួរតែត្រូវបានបង្ហាញយ៉ាងត្រឹមត្រូវ ដើម្បីបង្ហាញនូវសមត្ថភាពពិសេសៗរបស់ពួកគេ។ ក្មេងៗចូលចិត្តឃើញឈ្មោះរបស់គេនៅក្បែរកិច្ចការរបស់គេ ព្រោះវាធ្វើឱ្យគេមានមោទនភាព។ ធ្វើការផ្លាស់ប្តូរការតាំងបង្ហាញឱ្យបានញឹកញាប់ ដើម្បីរក្សាចំណាប់អារម្មណ៍របស់សិស្សនិងដើម្បីអនុញ្ញាតឱ្យសិស្សម្នាក់ៗដែលមានកិច្ចការល្អៗបង្ហាញក្នុងឆមាសនីមួយៗ។ កិច្ចការដែលបានដាក់បង្ហាញ ហើយអាចយកមកដើម្បីបង្កើតជាសំណុំកិច្ចការសម្រាប់ការវាយតម្លៃនិងការឆ្លុះបញ្ចាំងលទ្ធផលសិក្សាសិស្ស។ ក្តារខៀនសម្រាប់តាំងបង្ហាញដ៏គួរឱ្យចាប់អារម្មណ៍អាចជាសម្ភារៈជំនួយក្នុងការបង្រៀនដ៏ល្អមួយ ហើយវានឹងផ្តល់ជូននូវការផ្តោតការចាប់អារម្មណ៍ដ៏រស់រវើកមួយក្នុងថ្នាក់រៀន។ ក្តារខៀនសម្រាប់ដាក់តាំងបង្ហាញអាចធ្វើបានពីសម្ភារៈក្នុងសហគមន៍ដូចជាតម្បាញស្លឹកត្នោត ឬស្លឹកដូងដោយមានជំនួយពីសហគមន៍ក្នុងតំបន់។ ក្តារដាក់តាំងបង្ហាញគឺសំខាន់ណាស់ ព្រោះវាផ្តល់ឱ្យអ្នករៀននូវឱកាសប្រើប្រាស់សមត្ថភាពភាសា។ ឧទាហរណ៍ នៅប្រទេសទីម័រខាងកើត គ្រូបង្រៀនប្រើប្រាស់ធ័ត្រដែលខូចៗសម្រាប់ធ្វើជាគ្រោងចល័តដោយមានភ្ជាប់តួអក្សរ ឬរូបភាព។ល។ ខ្សែដែលចងព្យួរសម្ភារៈជំនួយជារូបភាព ធ្វើឡើងពីតម្បាញត្នោត ឬស្លឹកចេក។ ដំរបូរាណបានមកពីផ្លែឈើម៉ាំង។ ឪពុកម្តាយ និងអាណាព្យាបាលដទៃទៀតបានជួយផ្តល់សម្ភារៈទាំងនេះ ហើយពួកគេបានស្វែងយល់បន្ថែមពីដំណើរការបង្រៀន និងការរៀនសូត្រ។ ពួកគាត់ឥឡូវនេះអាចដឹងច្រើនជាងមុនក្នុងការនិយាយជាមួយកូនៗរបស់គាត់ពីការរៀនសូត្រនៅសាលារៀន។

កន្លែងសរសេរសរសេរ

នៅក្នុងប្រទេសបង់ក្លាដែស គេអាចឃើញក្តារខៀនសរសេរដីសនៅជុំវិញថ្នាក់រៀនសម្រាប់ក្មេងៗ ដើម្បីឱ្យពួកគេអាចអង្គុយជាក្រុម ហើយប្រើក្តារខៀនទាំងនោះសម្រាប់រៀបគម្រោង ពិភាក្សាគំនិត ការដោះស្រាយបញ្ហា។ល។ ក្នុងថ្នាក់រៀនមួយចំនួន ការខ្វះខាតគុ និងកៅអីអាចជារឿងមានប្រយោជន៍ ព្រោះវាអាចបង្កើតជាកន្លែងរៀនសូត្រធំមួយ ដែលក្រាលដោយព្រំ/កន្ទេល ធ្វើឡើងក្នុងស្រុក ហើយមានអនាម័យ និងអាចផ្លាស់ប្តូរជាកន្លែងសង្កេតវិទ្យាសាស្ត្រ កន្លែងសម្តែងសិល្បៈ និងអាចបង្កើតបានជាសកម្មភាពក្រុមជាច្រើន ដោយមិនរំខានថ្នាក់រៀនដទៃទៀត។ នៅក្នុងរដ្ឋដែលមានប្រជាជនច្រើន ដូចជានៅក្នុងប្រទេសឥណ្ឌា កន្លែងដែលមានជញ្ជាំងទាបត្រូវបានលាបពណ៌ខ្មៅ ហើយក្មេងៗអាចប្រើវាជាកន្លែងសរសេររបស់ពួកគេ ដោយគូស ឬសរសេរដោយប្រើដីស។

(តំបន់)ជ្រុង (សិក្សា)

ក្មេងៗជារឿយៗចង់ដឹងពីពិភពធម្មជាតិនៅជុំវិញខ្លួនរបស់គេ។ តំបន់សិក្សាអាចជួយជំរុញនូវការចង់ចេះចង់ដឹងរបស់ក្មេងៗ ហើយធ្វើឱ្យការសិក្សារបស់គេរីកចម្រើន។ ក្មេងៗអាចប្រមូល និងរៀបចំវត្ថុ

ទាំងអស់ដែលគេចាប់អារម្មណ៍ ដើម្បីអាចប្រើប្រាស់ជាប្រយោជន៍សម្រាប់ក្មេងៗទាំងអស់។ ក្មេងអាចដាំដុះគ្រាប់ពូជក្នុងតំបន់ទាំងនេះ ប្រមែលប្រមូលផលហើយ តាំងចិត្តបង្ហាញវត្ថុដែលគេរកបាន ដូចជាសម្បកគ្រំ ឬលៀស។ តំបន់សិក្សាទាំងនេះគួរតែស្ថិតនៅកន្លែង ដែលក្មេងៗទាំងអស់អាចធ្វើកិច្ចការបានដោយមិនរំខានដល់អ្នកដទៃ។ វត្ថុដែលរកបាន ដាក់ឈ្មោះ បង្ហាញ ដើម្បីជួយឱ្យពួកគេបង្កើតបាននូវទំនាក់ទំនងរវាងសាលា ជីវិតប្រចាំថ្ងៃ និងសហគមន៍ក្នុងតំបន់។ សិប្បករ និងតន្ត្រីករក្នុងស្រុកអាចមកលេងសាលារៀន ហើយសំណេះសំណាលជាមួយក្មេងៗ។ ពួកគេក៏អាចផ្តល់សម្ភារៈ ឧបករណ៍ទៅដល់ក្មេងៗដើម្បីរក្សាទុកក្នុងតំបន់សិក្សាផងដែរ ទោះក្នុងរយៈពេលខ្លីក៏ដោយ។ បន្ទប់រៀនមួយចំនួន គឺមិនធំល្មមសម្រាប់ជាតំបន់សិក្សានោះទេ។ នៅក្នុងប្រទេសទីម័រខាងកើត ឪពុកម្តាយសិស្សរវេចកន្ត្រកហើយដាក់លើកម្រាលឥដ្ឋ និងដាក់បំពេញដោយសម្បកគ្រំលៀស គ្រាប់គ្រួស គ្រាប់ពូជ និងវត្ថុផ្សេងៗទៀតដែលអាចប្រើបានក្នុងថ្នាក់វិទ្យាសាស្ត្រ ឬគណិតវិទ្យា។ ចំណុចសំខាន់នៃសម្ភារៈទាំងនេះគឺសិស្សទាំងឡាយអាចប្រើប្រាស់សម្រាប់ការសិក្សារបស់ពួកគេបាន។[4]

ធនធានថ្នាក់រៀន	តើត្រូវការធនធានអ្វីខ្លះ?	តើអាចទទួលបានធនធានទាំងនេះ ដោយរបៀបណា?	តើសិស្សអាចប្រើធនធានបានដោយរបៀបណា?
បណ្ណាល័យ			
កន្លែងសរសេរចម្រុះ			
ក្តារតាំងបង្ហាញកិច្ចការសិស្ស			
តំបន់(ជ្រុង)សិក្សា			
ក្រុមរៀបចំ			

ឯកសារពិគ្រោះ

UNESCO. (2015). Booklet 1: Becoming an Inclusive, Learning-Friendly environment (ILFE). In: *Embracing Diversity: Toolkit for Creating Inclusive, Learning-Friendly Environments*. Retrieved from: https://unesdoc.unesco.org/ark:/48223/pf0000137522. ISBN 92-9223-032-8 (Electronic version).

UNESCO. (2015). Booklet 5: Managing Inclusive, Learning-Friendly Classrooms. In: *Embracing*

[4] Adapted from UNESCO/Booklet Five (2015, 229ff.).

Diversity: Toolkit for Creating Inclusive, Learning-Friendly Environments. Retrieved from: https://unesdoc.unesco.org/ark:/48223/pf0000137522. ISBN 92-9223-032-8 (Electronic version).

ជំហានទី១- ចម្លើយពន្រឹងចំណេះដឹង

ក.ចូរដាក់លក្ខណៈខាងក្រោម ចូលទៅក្នុងក្រុមដែលត្រឹមត្រូវក្នុងតារាងខាងក្រោម៖

១.គ្រូបង្រៀនគ្រប់គ្រងទាំងស្រុងទៅលើសម្ភារសិក្សារបស់សិស្ស

២.សិស្សបង្ហាញពីចំណាប់អារម្មណ៍ផ្ទាល់ខ្លួនរបស់ពួកគេ

៣.គ្រូបង្រៀនណែនាំលើវិធីដែលសិស្សរៀន(ពេលវេលា ទីកន្លែង វិធីសាស្ត្រ និងល្បឿន)

៤.កៅអីត្រូវបានរៀបចំជារាងពាក់កណ្តាលរង្វង់តូច

៥.គ្រូជាមនុស្សសកម្មបំផុតនៅក្នុងថ្នាក់រៀន

៦.សិស្សធ្វើការជាក្រុម

៧.គ្រូនិយាយភាគច្រើនក្នុងថ្នាក់

៨.សិស្សធ្វើកិច្ចការតាមសមត្ថភាពខ្លួន

៩.មានដាក់តាំងបង្ហាញកិច្ចការសិស្សនៅតាមជញ្ជាំង

១០.សិស្សអង្គុយម្នាក់ឯងតាមតុរៀបជាជួរ

១១.កូនសិស្សស្តាប់កត់ត្រា បំពេញកិច្ចការដោយឡែកៗពីគ្នា

១២.សិស្សនិយាយភាគច្រើនក្នុងថ្នាក់

១៣.គ្រូឈរនៅខាងមុខថ្នាក់សរសេរលើក្តារខៀន

១៤.សិស្សទទួលបានបទពិសោធពីខាងក្រៅថ្នាក់រៀន

បរិយាកាសសិក្សាគ្រូមជ្ឈមណ្ឌល	បរិយាកាសសិក្សាសិស្សមជ្ឈមណ្ឌល
១	២

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

៣	៤
៥	៦
៧	៨
១០	៩
១១	១២
១៣	១៤

ខ.ចូរបំពេញឈ្មោះប្រព័ន្ធអេកូឡូស៊ីរបស់លោក Bronfenbrenner ក្នុងរូបភាពខាងក្រោម រួចចូរដាក់សមាសភាពដូចជាមនុស្ស និងកន្លែងខាងក្រោមចូលក្នុងស្រទាប់នីមួយៗឱ្យបានត្រឹមត្រូវ៖

ផ្ទះ- សាលារៀន- ជំនឿក្នុងសង្គម- ប្រព័ន្ធអប់រំ -ការថែទាំពេលថ្ងៃ- តម្លៃក្នុងសង្គម -ប្រព័ន្ធផ្សព្វផ្សាយ - សហគមន៍- ប្រព័ន្ធសេដ្ឋកិច្ច- សមាជិកក្រុមគ្រួសារ- គ្រូបង្រៀន- ប្រព័ន្ធនយោបាយ- បទដ្ឋានសង្គម



t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ក. ចូរឆ្លើយសំណួរពហុជ្រើសរើសខាងក្រោម។ មានចម្លើយត្រូវតែមួយគត់៖

១.បរិយាកាសសិក្សាសំដៅលើ

ក.ថ្នាក់រៀនដែលគ្រប់គ្រងដោយគ្រូ
ខ.ថ្នាក់រៀនមួយក្នុងសាលារៀន
គ.គ្រប់បន្ទប់ និងគ្រប់ទីកន្លែងក្នុងសាលារៀន
ឃ.ទីតាំងជាក់លាក់ដម្រុះបរិបទ វប្បធម៌ និងទម្លាប់ដែលសិស្សរៀន.

២.ដោយយោងទៅតាមអត្ថបទមេរៀន តើគំនិតមួយណា ដែលមិនមែនជាប្រយោជន៍សម្រាប់បង្កើតបរិយាកាសសិស្សមជ្ឈមណ្ឌល?

ក.ការយល់ពីរបៀបរៀនរបស់មនុស្ស
ខ.ការយល់ពីរបៀបអនុវត្តបទបញ្ជា និងច្បាប់
គ.ការត្រៀមខ្លួនសម្រាប់ជីវិតការងារ
ឃ.ការត្រៀមខ្លួនដើម្បីក្លាយជាអ្នករៀនពេញមួយជីវិត

៣.ដោយយោងតាមវិធីសាស្ត្រ Montessori តើអ្វីជំរុញឱ្យមានការចង់ចេះចង់ដឹងរបស់កុមារម្នាក់ៗ?

ក.ការទទួលបានពិន្ទុចំណាត់ថ្នាក់ល្អ

ខ.ការធ្វើឱ្យឪពុកម្តាយសប្បាយចិត្ត

គ.ការពេញចិត្តពីខាងក្នុង

ឃ.ជោគជ័យមុខវិជ្ជាសិក្សាទាំងអស់

៤.មូលដ្ឋានគ្រឹះនៃវិធីសាស្ត្ររបស់ Montessori គឺស្ថិតនៅក្នុងទំនាក់ទំនងរវាង

ក.គ្រូ សិស្ស និងបរិយាកាស

ខ.សិស្ស សម្ភារៈ និងបរិយាកាស

គ.គ្រូ សម្ភារៈ និងសិស្ស

ឃ.គ្រូ ឪពុកម្តាយ និងបរិយាកាស

៥.តើចម្លើយមួយណាខាងក្រោមនេះ ជាបរិយាកាសសិក្សាដែលមានលក្ខណៈស្វាគមន៍?

ក.បរិយាកាសសិក្សាទាំងអស់គួរតែធ្វើតាមគំរូតែមួយដូចគ្នា គុ កៅអី គួរតែរៀបជាក្រុមតូចៗ ជញ្ជាំងគួរតែតុបតែងលម្អដោយមានពណ៌ស្រស់ស្អាត

ខ.គុ កៅអី គួរតែរៀបជាជួរ ដោយបែរមុខទៅរកគ្រូដែលនៅខាងមុខថ្នាក់

គ.គុ កៅអីគួរតែរៀបចំសារជាថ្មីជារៀងរាល់ថ្ងៃ ដើម្បីឱ្យសិស្សចាប់អារម្មណ៍

ឃ.គុ កៅអីគួរតែរៀបចំដោយផ្អែកលើប្រភេទនៃការបង្រៀនដែលត្រូវអនុវត្ត

៦.តើចម្លើយមួយណាក្នុងចំណោមខាងក្រោមនេះ ដែលចែងថា «សិស្សទំនងជាចូលរួមកាន់តែសកម្មក្នុងសកម្មភាពដែលគេមិនសូវចូលចិត្ត ប្រសិនបើពួកគេដឹងថានឹងមានសកម្មភាពបន្ទាប់ដែលពួកគេពេញចិត្តធ្វើ»?

ក.គោលការណ៍ Premack

ខ.ទ្រឹស្តីប្រព័ន្ធអេកូឡូស៊ីរបស់លោក Bronfenbrenner

គ.វិធីសាស្ត្ររបស់ Maria Montessori

ឃ.វិធីសាស្ត្រសិស្សមជ្ឈមណ្ឌល

៧. នៅពេលបង្កើតវិន័យ និងកាលវិភាគសម្រាប់ថ្នាក់រៀន គ្រូគួរតែ៖

ក.ឱ្យសិស្សផ្តល់ធាតុចូល និងមតិយោបល់របស់ពួកគេ

ខ.ឱ្យសិស្សបំពេញ និងបង្ហាញនៅថ្នាក់រៀនថ្ងៃដំបូង

គ.ផ្សារភ្ជាប់ច្បាប់វិន័យនីមួយៗជាមួយនឹងទណ្ឌកម្មដែលត្រូវទទួល

ឃ.ប្រាកដច្បាស់ក្នុងចិត្តថា សកម្មភាពគួរជាទីពេញចិត្ត ត្រូវដាក់មុនសកម្មភាពដែលមិនសូវពេញចិត្ត

ជំហានទី២- ចម្លើយអនុវត្ត

ក.ចូរអានការពណ៌នានៃថ្នាក់រៀន-ក និងថ្នាក់រៀន-ខ។

ចូរដាក់លក្ខណៈខាងក្រោមចូលទៅក្នុងក្រុមដែលត្រឹមត្រូវក្នុងតារាងខាងក្រោម។ លក្ខណៈមួយចំនួនអាច ដាក់ចូលក្នុងក្រុមលើសពីមួយ៖

១. មិនអាចអនុវត្តបាន
២. សម្ភារៈដែលសិស្សយកមក
៣. សៀវភៅពុម្ព
៤. តុកៅអីរៀបជាជួរ
៥. ឈរបង្រៀននៅផ្នែកខាងមុខ
៦. អ្នកស្ម័គ្រចិត្តខាងអាណាព្យាបាល
៧.ក្តារខៀន
៨.រង្វង់នៅលើកម្រាលឥដ្ឋ
៩.ការងារជាក្រុម
១០.ការចូលរួមរបស់សិស្ស
១១.ក្រុមតូចៗ
១២.សៀវភៅលំហាត់
១៣.សម្ភារៈយកមកពីផ្ទះ
១៤.ការផ្តល់ពាក្យសម្តីវិជ្ជមាន និងផ្តល់ព័ត៌មានត្រលប់ជាក់ស្តែង
១៥.កម្រិតនៃការចូលរួមខ្ពស់ក្នុងចំណោមសិស្ស និងគ្រូ
១៦.ការរៀនបែបដដែលៗ
១៧.ក្រុមតូច
១៨.កាសែត
១៩.បែងចែកតាមកេទ
២០.ធ្វើកិច្ចការតាមសមត្ថភាពរបស់ខ្លួន
២១.សិស្សធ្វើកិច្ចការច្រើន
២២.ដីស
២៣.ការសួរសំណួរបិទ

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ថ្នាក់រៀន-ក

កុមារចំនួន៤០នាក់អង្គុយលើកៅអីឈើពីក្រោយតុវែង ដោយបើកសៀវភៅលំហាត់ និងកាន់ប៊ិកក្នុងដៃ។ គ្រូកំពុងតែកត់ចម្លងមេរៀនពីក្នុងសៀវភៅថ្នាក់ទី៣ នៅលើក្តារខៀនដោយប្រុងប្រយ័ត្ន។ សិស្សប្រុសៗដែលអង្គុយនៅផ្នែកខាងស្តាំកំពុងកត់ត្រាតាមគ្រូ និងសិស្សស្រីៗដែលអង្គុយនៅខាងឆ្វេងកំពុងរង់ចាំឱ្យគ្រូរំកិលចេញបន្តិច ដើម្បីអាចកត់ត្រាដែរ។ ពួកគេកត់ចម្លងដាក់ក្នុងសៀវភៅលំហាត់ពួកគេ។ នៅពេលកំពុងកត់លើក្តារខៀន គ្រូសួរសិស្សថា "តើកូនៗទាំងអស់គ្នាកំពុងកត់មេរៀនដែលគ្រូកំពុងសរសេរដែរ ឬទេ?" សិស្សឆ្លើយថា "ចាស/បាទ"។

ថ្នាក់រៀន-ខ

សិស្សមួយក្រុមកំពុងអង្គុយនៅលើឥដ្ឋជា២វង់ង។ ក្រុមទាំង២មានទាំងសិស្សស្រីនិងសិស្សប្រុស។ គ្រូថ្នាក់ទី៣កំពុងបង្រៀនអំពី "ទម្រង់រូបរាង" នៃវត្ថុទៅកាន់សិស្ស។ នៅក្រុមទី១សិស្សកំពុងពិភាក្សាគ្នាអំពីវង្វង់។ គ្រូកំពុងបង្ហាញសិស្សនូវវត្ថុរាងមូលជាច្រើនដែលគាត់បានឱ្យសិស្សយកពីផ្ទះមក។ បន្ទាប់មកកូនសិស្សក៏ចាប់ផ្តើមធ្វើការជាក្រុម ដើម្បីជួយគ្នាប្រាប់ពីវត្ថុដែលមានរាងមូលផ្សេងៗទៀត។ នៅក្រុមទី២ សិស្សខ្លះកំពុងកាន់ក្រដាសកាសែតដែលមូរឱ្យដូចជាចង្កឹះវែង។ បន្ទាប់មកគ្រូចាប់ផ្តើមហៅលេខ ហើយសិស្សដែលមានលេខនោះ ត្រូវដាក់ចង្កឹះ កាសែតនៅលើឥដ្ឋ កណ្តាលក្រុមដើម្បីចាប់ផ្តើមបង្កើតជារូបរាងការេ។ សិស្សម្នាក់នៅក្នុងក្រុមដែលមានបញ្ហាត្រចៀក ដាក់ចង្កឹះក្រដាសរបស់គាត់ ដើម្បីបង្កើតជារាងត្រីកោណ ហើយញញឹមដាក់គ្រូ។ គ្រូញញឹមតបហើយនិយាយថា"ល្អណាស់" ហើយនិយាយដោយធ្វើម៉េចឱ្យសិស្សនោះអាចមើលបបូរមាត់របស់គាត់ ឃើញថាគាត់កំពុងនិយាយអ្វីជាមួយ។ ឪពុក/ម្តាយម្នាក់ដែលបានស្ម័គ្រចិត្តធ្វើជាជំនួយការគ្រូមួយសប្តាហ៍នៅពេលនោះបានគោះដៃសិស្សនោះតិចៗ ហើយជួយពន្យល់សិស្សដែលបានដាក់ចង្កឹះកាសែតច្រឡំកន្លែង ដើម្បីបង្កើតជារូបរាងថ្មី។[5]

	ថ្នាក់រៀន-ក	ថ្នាក់រៀន-ខ
ធាតុនៃសិស្សមជ្ឈមណ្ឌល	១	៩,១០,១៤,១៥,១៩,២០
ធាតុនៃគ្រូមជ្ឈមណ្ឌល	៥,១៦	១
ការរៀបចំកន្លែងអង្គុយ	៤,១៨	៨,១១
សម្ភារសិក្សាដែលមាន	១២	១៣,១៧

[5] Adapted from UNESCO/Booklet One (2015, p. 22).

ធនធានរបស់គ្រូបង្រៀន	៣,៧,២១	២,៦
មតិយោបល់របស់គ្រូបង្រៀន	២២	១៤

ខ.ចូរមើលរូបភាពខាងក្រោម រួចដាក់លក្ខណៈទាំងឡាយខាងក្រោមចូលទៅតាមរូបភាពនៃបរិយាកាសសិក្សាសមស្របៈ

១.មានកន្លែងរៀបចំតុ និងកៅអី
២.មានកន្លែងគ្រប់គ្រាន់សម្រាប់សិស្សរំកិលចុះឡើងដោយមិនរំខានអ្នកដទៃ
៣.មានកន្លែងគ្រប់គ្រាន់សម្រាប់សិស្សពិការចូលរៀន
និងអាចរំកិលចុះឡើងក្នុងថ្នាក់ដោយងាយស្រួល
៤.កង្វះខាតនៃពន្លឺធម្មជាតិ
៥.កិច្ចការរបស់សិស្សត្រូវបានដាក់បង្ហាញនៅលើជញ្ជាំង
៦.មានពន្លឺធម្មជាតិ
៧.ការតុបតែងលម្អដោយពណ៌
៨.ការរៀបចំកន្លែងអង្គុយដូចៗគ្នា
៩.ការរៀបចំកន្លែងអង្គុយខុសៗគ្នា
១០.ការបង្រៀននៅតែផ្នែកខាងមុខនៃថ្នាក់រៀន

បរិយាកាសសិក្សា	លក្ខណៈនានា
	១,២,៣,៥,៦,៧,៩

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

	៤,៨,១០

Picture Source: Open Source from pixabay.com

គ.ចូរអានគន្លឹះខាងក្រោម ស្តីពីការបង្កើតបរិយាកាសថ្នាក់រៀនបែបវិជ្ជមាន រួចបំពេញតារាងខាងក្រោម អំពីថ្នាក់រៀនរបស់អ្នកបច្ចុប្បន្ន/ថ្នាក់រៀនអនាគត៖

ចំណុចគន្លឹះក្នុងការរៀបចំ

គ្រូបង្រៀនជាច្រើនអាចនឹងយល់ថា វាលំបាកសម្រាប់ការក្សាបាននូវថ្នាក់រៀន ដែលមានសណ្តាប់ធ្នាប់ និងមានការជំរុញទឹកចិត្ត។ សម្រាប់ហេតុផលនេះ គ្រូអាចធ្វើការជាមួយសិស្ស ឪពុកម្តាយ និងអ្នកដឹកនាំសហគមន៍ទាំងឡាយឱ្យជួយផ្តល់ និងការពារសម្ភារៈសិក្សា។ សម្ភារៈមួយចំនួនប្រហែលជាត្រូវរៀបចំទុកដាក់ឡើងវិញជារៀងរាល់ថ្ងៃក្នុងប្រអប់ ឬទូដែលមានសុវត្ថិភាព។ គ្រូអាចឱ្យសិស្សជួយទទួលខុសត្រូវក្នុងការទុកដាក់របស់របរ ឬយកវត្ថុទាំងនោះទៅផ្ទះ និងយកមកវិញនៅថ្ងៃបន្ទាប់។ ឪពុកម្តាយ និងសហគមន៍អាចត្រូវបានជំរុញលើកទឹកចិត្តឱ្យជួយបរិច្ចាកសម្ភារៈមួយចំនួន ទៅឱ្យសាលារៀនដែលអាចប្រើជាប្រយោជន៍សម្រាប់សម្ភារសិក្សា ឬជាវត្ថុសម្រាប់រៀបចំលម្អក្នុងថ្នាក់រៀន។ នៅពេលដែលឱ្យឪពុកម្តាយ និងសហគមន៍ត្រូវបានលើកទឹកចិត្តឱ្យចូលរួមយ៉ាងសកម្ម ជួយគ្រូក្នុងដំណើរការសាលារៀន នឹងឱ្យសហគមន៍កាន់តែមានភាពរឹងមាំ។

បណ្ណាល័យ

បណ្ណាល័យនៅសាលារៀន គឺជាប្រភពធនធានដ៏សំខាន់ក្រៃលែងសម្រាប់សិស្ស និងសហគមន៍ទាំងមូល។ តែជាអកុសលនៅសហគមន៍ជនបទជាច្រើនខ្វះខាតបរិក្ខាបណ្ណាល័យ ដូច្នេះសិស្សគ្មានឱកាសនឹងបានអានសៀវភៅបានច្រើននោះទេ។ បណ្ណាល័យក្នុងថ្នាក់រៀនមួយ អាចនឹងត្រូវបានបង្កើតឡើងដោយប្រើប្រអប់កេសរឹង ដែលត្រូវបានតុបតែងលម្អ និងដាក់បំពេញដោយសៀវភៅដែលបង្កើតឡើងដោយសមាជិកក្នុងថ្នាក់។ នៅពេលក្មេងៗបង្កើតសៀវភៅផ្ទាល់ខ្លួនរបស់គេ ទោះបីជាវាជាសៀវភៅសាមញ្ញយ៉ាងណាក៏ដោយ ពួកគេមានមោទនភាពដោយឃើញរឿងរបស់គេបោះពុម្ព។ ពួកគេក៏បានរៀនពី

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

របៀបផលិតសៀវភៅ របៀបបែងចែក និងថែរក្សា។ គ្រូអាចឱ្យសិស្សបង្កើតជាសៀវភៅបត់ ដែលសៀវភៅទាំងនេះបង្កើតឡើងពីក្រដាសបត់ពីរ ឬបីផ្ញត់ដោយមានអត្ថបទនៅតាមទំព័រនីមួយ ដូចជាខិតប័ណ្ណដូច្នោះដែរ។ ក្មេងអាចអធិប្បាយដោយរូបភាពទៅលើសៀវភៅទាំងនេះ ហើយសៀវភៅទាំងនេះនឹងក្លាយជាសម្ភារៈសម្រាប់អានដ៏មានតម្លៃនៅពេលដែលមិនសូវមានសៀវភៅ។ សៀវភៅដែលបង្កើតឡើងដោយសិស្សក៏អាចជាជំនួយក្នុងការបង្រៀនដ៏មានប្រសិទ្ធភាពផងដែរ។ ការពន្យល់ ឬការបង្ហាញដែលក្មេងៗបានសរសេរបញ្ចូលក្នុងសៀវភៅរបស់ពួកគេ អាចជួយដល់ក្មេងដទៃឱ្យយល់ពីគំនិតសំខាន់មួយទាំងនោះ។ ក្មេងៗមើលឃើញបញ្ហាដោយវិធីខុសគ្នាពីមនុស្សពេញវ័យ។ ពួកគាត់ប្រើភាសាដែលងាយយល់ជាង ហើយពួកគេអាចចែករំលែកព័ត៌មានសំខាន់ៗដោយជោគជ័យ ដែលអាចនឹងលឿនជាងគ្រូក្នុងពេលខ្លះ។ ចូរក្រឡេកមើលសៀវភៅដែលធ្វើដោយសិស្សរបស់អ្នក។ លើសពីនេះ សៀវភៅអាចត្រូវបានប្រើដើម្បីបង្រៀនជំនាញផ្សេងៗ ជាពិសេសសម្រាប់សិស្សដែលមានបញ្ហាក្នុងការមើល។ ឧទាហរណ៍ សៀវភៅអាចត្រូវបានបង្កើតដោយប្រើដំរបិទសម្ភារៈ ឧបករណ៍ រូបភាពទាំងឡាយនៅលើទំព័រ។ សិស្សអាចរៀនពីរបស់ទាំងនេះដោយការស្ទាប ឧទាហរណ៍ ត្រីកោណមួយត្រូវបានបិទទៅលើទំព័រសៀវភៅដើម្បីឱ្យសិស្សមានបញ្ហាភ្នែក អាចរៀនពីរាងត្រីកោណ។ ទោះជាសិស្សដែលអាចមើលឃើញច្បាស់ ក៏អាចពេញចិត្តនឹងការបង្កើតសៀវភៅស្ទាបបែបហ្នឹងដែរ ហើយពួកគេអាចអនុវត្តប្រើពួកវាដោយការបិទភ្នែករបស់ពួកគេ។ ស្លាកសញ្ញាសម្រាប់ស្ទាប ជាជាងការមើល ក៏អាចត្រូវបាន ផលិតនិងដាក់នៅកន្លែង សម្រាប់តាំងបង្ហាញនោះផងដែរ។

តំបន់សម្រាប់តាំងបង្ហាញ

តំបន់សម្រាប់តាំងបង្ហាញការបង្ហាញសម្ភារបង្រៀន និងកិច្ចការរបស់សិស្សក្នុងថ្នាក់រៀន នឹងជួយឱ្យសិស្សចាប់អារម្មណ៍ទៅលើការសិក្សារបស់ពួកគេ និងមានអារម្មណ៍ថាពួកគេជាសមាជិកក្នុងថ្នាក់រៀន។ ឪពុកម្តាយក៏នឹងចាប់អារម្មណ៍ជាងមុន ព្រមទាំងយល់បានកាន់តែប្រសើរឡើងពីការងារដែលកំពុងកើតឡើងនៅក្នុងថ្នាក់រៀន។ កិច្ចការរបស់សិស្សទាំងអស់គួរតែត្រូវបានបង្ហាញយ៉ាងត្រឹមត្រូវ ដើម្បីបង្ហាញនូវសមត្ថភាពពិសេសៗរបស់ពួកគេ។ ក្មេងៗចូលចិត្តឃើញឈ្មោះរបស់គេនៅក្បែរកិច្ចការរបស់គេ ព្រោះវាធ្វើឱ្យគេមានមោទនភាព។ ធ្វើការផ្លាស់ប្តូរការតាំងបង្ហាញឱ្យបានញឹកញាប់ ដើម្បីរក្សាចំណាប់អារម្មណ៍របស់សិស្ស និងដើម្បីអនុញ្ញាតឱ្យសិស្សម្នាក់ៗដែលមានកិច្ចការល្អៗបង្ហាញក្នុងធមាសនីមួយៗ។ កិច្ចការដែលបានដាក់បង្ហាញ ហើយអាចយកមកដើម្បីបង្កើតជាសំណុំកិច្ចការសម្រាប់ការវាយតម្លៃនិងការឆ្លុះបញ្ចាំងលទ្ធផលសិក្សាសិស្ស។ ក្តារខៀនសម្រាប់តាំងបង្ហាញដ៏គួរឱ្យចាប់អារម្មណ៍អាចជាសម្ភារៈជំនួយក្នុងការបង្រៀនដ៏ល្អមួយ ហើយវានឹងផ្តល់ជូននូវការផ្តោតការចាប់អារម្មណ៍ដ៏រស់រវើកមួយក្នុងថ្នាក់រៀន។ ក្តារខៀនសម្រាប់ដាក់តាំងបង្ហាញអាចធ្វើបានពីសម្ភារៈក្នុងសហគមន៍ដូចជា តម្បាញស្លឹកត្នោត ឬស្លឹកដូងដោយមានជំនួយពីសហគមន៍ក្នុងតំបន់។ ក្តារដាក់តាំង

បង្ហាញគឺសំខាន់ណាស់ ព្រោះវាផ្តល់ឱ្យអ្នករៀននូវឱកាសប្រើប្រាស់សមត្ថភាពភាសា។ ឧទាហរណ៍ នៅប្រទេសទីម័រខាងកើត គ្រូបង្រៀនប្រើប្រាស់ឆ័ត្រដែលខូចៗសម្រាប់ធ្វើជាគ្រោងចល័តដោយមានភ្ជាប់តួអក្សរ ឬរូបភាព។ល។ ខ្សែដែលចងព្យួរសម្ភារៈជំនួយជារូបភាព ធ្វើឡើងពីតម្បាញត្នោត ឬស្លឹកចេក។ ដំបូរាណបានមកពីផ្លែឈើម៉ាង។ ឪពុកម្តាយ និងអាណាព្យាបាលដទៃទៀតបានជួយផ្តល់សម្ភារៈទាំងនេះ ហើយពួកគេបានស្វែងយល់បន្ថែមពីដំណើរការបង្រៀន និងការរៀនសូត្រ។ ពួកគាត់ឥឡូវនេះអាចដឹងច្រើនជាងមុនក្នុងការនិយាយជាមួយកូនៗរបស់គាត់ពីការរៀនសូត្រនៅសាលារៀន។

កន្លែងសរសេរសរសេរ

នៅក្នុងប្រទេសបង់ក្លាដែស គេអាចឃើញក្តារខៀនសរសេរដើសនៅជុំវិញថ្នាក់រៀនសម្រាប់ក្មេងៗ ដើម្បីឱ្យពួកគេអាចអង្គុយជាក្រុម ហើយប្រើក្តារខៀនទាំងនោះសម្រាប់រៀបគម្រោង ពិភាក្សាគំនិត ការដោះស្រាយបញ្ហា។ល។ ក្នុងថ្នាក់រៀនមួយចំនួន ការខ្វះខាតតុ និងកៅអីអាចជារឿងមានប្រយោជន៍ ព្រោះវាអាចបង្កើតជាកន្លែងរៀនសូត្រធំមួយ ដែលក្រាលដោយព្រំកន្ទេល/ធ្វើឡើងក្នុងស្រុក ហើយមានអនាម័យ និងអាចផ្លាស់ប្តូរជាកន្លែងសង្កេតវិទ្យាសាស្ត្រ កន្លែងសម្តែងសិល្បៈ និងអាចបង្កើតបានជាសកម្មភាពក្រុមជាច្រើន ដោយមិនរំខានថ្នាក់រៀនដទៃទៀត។ នៅក្នុងរដ្ឋដែលមានប្រជាជនច្រើន ដូចជានៅក្នុងប្រទេសឥណ្ឌា កន្លែងដែលមានជញ្ជាំងទាបត្រូវបានលាបពណ៌ខ្មៅ ហើយក្មេងៗអាចប្រើវាជាកន្លែងសរសេររបស់ពួកគេ ដោយគូស ឬសរសេរដោយប្រើដីស។

(តំបន់)ជ្រុង (សិក្សា)

ក្មេងៗជារឿយៗចង់ដឹងពីពិភពធម្មជាតិនៅជុំវិញខ្លួនរបស់គេ។ តំបន់សិក្សាអាចជួយជំរុញនូវការចង់ចេះចង់ដឹងរបស់ក្មេងៗ ហើយធ្វើឱ្យការសិក្សារបស់គេរីកចម្រើន។ ក្មេងៗអាចប្រមូល និងរៀបចំវត្ថុទាំងអស់ដែលគេចាប់អារម្មណ៍ ដើម្បីអាចប្រើប្រាស់ជាប្រយោជន៍សម្រាប់ក្មេងៗទាំងអស់។ ក្មេងអាចដាំដុះគ្រាប់ពូជក្នុងតំបន់ទាំងនេះ ប្រមែលប្រមូលផលហើយ តាំងចិត្តបង្ហាញវត្ថុដែលគេរកបាន ដូចជាសម្បកគ្រំ ឬលៀស។ តំបន់សិក្សាទាំងនេះគួរតែស្ថិតនៅកន្លែង ដែលក្មេងៗទាំងអស់អាចធ្វើកិច្ចការបានដោយមិនរំខានដល់អ្នកដទៃ។ វត្ថុដែលរកបាន ដាក់ឈ្មោះ បង្ហាញ ដើម្បីជួយឱ្យពួកគេបង្កើតបាននូវទំនាក់ទំនងរវាងសាលា ជីវិតប្រចាំថ្ងៃ និងសហគមន៍ក្នុងតំបន់។ សិប្បករ និងតន្ត្រីករក្នុងស្រុកអាចមកលេងសាលារៀន ហើយសំណេះសំណាលជាមួយក្មេងៗ។ ពួកគេក៏អាចផ្តល់សម្ភារៈ ឧបករណ៍ទៅដល់ក្មេងៗដើម្បីរក្សាទុកក្នុងតំបន់សិក្សាផងដែរ ទោះក្នុងរយៈពេលខ្លីក៏ដោយ។ បន្ទប់រៀនមួយចំនួន គឺមិនធំល្មមសម្រាប់ជាតំបន់សិក្សានោះទេ។ នៅក្នុងប្រទេសទីម័រខាងកើត ឪពុកម្តាយសិស្សរៀបចំកន្ត្រកហើយដាក់លើកម្រាលឥដ្ឋ និងដាក់បំពេញដោយសម្បកគ្រំលៀស គ្រាប់គ្រួស គ្រាប់ពូជ និងវត្ថុផ្សេងៗ

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ទៀតដែលអាចប្រើបានក្នុងថ្នាក់វិទ្យាសាស្ត្រ ឬគណិតវិទ្យា។ ចំណុចសំខាន់នៃសម្ភារៈទាំងនេះគឺសិស្សទាំងឡាយអាចប្រើប្រាស់សម្រាប់ការសិក្សារបស់ពួកគេបាន។[6]

ធនធានថ្នាក់រៀន	តើត្រូវការធនធានអ្វីខ្លះ?	តើអាចទទួលបានធនធានទាំងនេះ ដោយរបៀបណា?	តើសិស្សអាចប្រើធនធានបានដោយរបៀបណា?
បណ្ណាល័យ	សៀវភៅ, កន្លែងអង្គុយ	ពួកគេនឹងចេះទំនាក់ទំនងជាមួយសមាជិកក្នុងសហគមន៍ដែល ក្មេងៗអាចបង្កើតសៀវភៅដោយបានជួយបង្រៀនពួកគេ។ ខ្លួនឯងហើយយើងស្នើសុំអ្នកទៅសហគមន៍ឲ្យជួយបរិច្ចាកសៀវភៅ។	ក្មេងៗអាចនឹងរៀនអំពីការបង្កើតសៀវភៅ ការរៀបចំ និងការថែរក្សាសៀវភៅ។ ពួកគេនឹងចេះទំនាក់ទំនងជាមួយសមាជិកក្នុងសហគមន៍ដែល ក្មេងៗអាចបង្កើតសៀវភៅដោយបានជួយបង្រៀនពួកគេ។
កន្លែងសរសេរចម្រុះ	ថ្នាំលាបក្តារខៀន និងដីស	ថវិកាសាលា	លាបជញ្ជាំងក្រោមដែលត្រូវនឹងកំពស់របស់សិស្ស ហើយឲ្យពួកគេគូស ឬធ្វើការផ្សេងៗ។
ក្តារតាំងបង្ហាញកិច្ចការសិស្ស	ខ្សែ	ទទួលការបរិច្ចាកពីរោងចក្រ	ព្យួរកិច្ចការសិស្សរបស់សិស្សនៅជ្រុងណាមួយ ដោយប្រើខ្សែប្រវែងផ្សេងៗ ដើម្បីជាការតាំងពិពណ៌ ហើយអញ្ជើញឪពុកម្តាយ

[6] Adapted from UNESCO/Booklet Five (2015, 229ff.).

			ឲ្យចូលរួម ក្នុងការមើលសាលពិពណ៌នោះ។
តំបន់(ជ្រុង)សិក្សា	របស់ពីធម្មជាតិដូចជា ស្លឹកឈើ គ្រាប់, ដី, មែកឈើ	នៅក្រៅសាលារៀន និងនៅផ្ទះ	បង្កើតពេលរៀនគណិតវិទ្យាដោយប្រើរបស់ទាំងនោះ។
ក្រុមរៀបចំ	សមាជិកសំអាត	អ្នកស្ម័គ្រចិត្តជាប្រចាំដែលផ្លាស់ប្តូរវេនគ្នារៀងរាល់សប្តាហ៍	សិស្សទាំងនេះនឹងដើរមើលបន្ទប់នៅពេលចប់ម៉ោងសិក្សាហើយ ត្រូវមើលថាតើអ្វីៗទាំងអស់ត្រូវបានទុកដាក់ដោយមានរបៀប និងរួចរាល់សំរាប់ថ្នាក់នៅថ្ងៃស្អែក។

ជំហានទី៣៖ កិច្ចការរៀបចំសំណុំឯកសារ –សំណួរបែបឆ្លុះបញ្ចាំងផ្ទាល់ខ្លួន

ចូរសរសេរចម្លើយបែបតែងសេចក្តីចំពោះសំណួរបែបឆ្លុះបញ្ចាំងផ្ទាល់ខ្លួនខាងក្រោម។ ចម្លើយនីមួយៗគួរមានប្រវែងប្រហែលពី ៣០០ទៅ៥០០ពាក្យ ហើយឆ្លើយជាអត្ថបទដែលទាក់ទងគ្នាងាយស្រួលយល់ជាមួយនឹងប្រយោគពេញលេញ។ ចម្លើយបែបសំណេរតែងសេចក្តីទាំងនេះដាក់ចូលទៅក្នុងសំណុំឯកសារផ្ទាល់ខ្លួនរបស់អ្នក!

១. តើអ្នកនឹងពណ៌នាបរិយាកាសសិក្សា ដែលល្អបំផុតរបស់អ្នកដោយរបៀបណា?

២. តើអ្នកគិតថាបរិយាកាសសិក្សាសំខាន់យ៉ាងណាសម្រាប់ដំណើរការសិក្សារបស់សិស្ស?

ជំហានទី៤៖ កិច្ចការរៀបចំសំណុំឯកសារ – គម្រោងការបង្រៀន

ចូរបង្កើតគម្រោងការបង្រៀនផ្ទាល់ខ្លួនរបស់អ្នក។ ចូរពិពណ៌នាពីរបៀបរៀបចំជារូបភាពជាក់ស្តែងនៃបរិយាកាសសិក្សារបស់អ្នក ដូចដែលបានជ្រើសរើសនៅក្នុងម៉ូឌុល១.១។ កិច្ចការរៀបចំឯកសារនេះគួរតែមានប្រវែងប្រហែលពី៨០០ទៅ១០០០ពាក្យ។ គម្រោងការបង្រៀននេះដាក់ចូលទៅក្នុងសំណុំឯកសារផ្ទាល់ខ្លួនរបស់អ្នក!

ចូរធ្វើការលម្អិតទៅលើកន្លែងដែល ការសិក្សាអាចកើតមានឡើងក្នុងគំនិតរបស់អ្នក។ តើកត្តាលក្ខខណ្ឌដែលមានស្រាប់អ្វីខ្លះត្រូវបានផ្តល់ជូន? តើកត្តាលក្ខខណ្ឌទាំងនេះអាចនឹងធ្វើឱ្យបានប្រសើរបំផុតដោយរបៀបណា? តើអ្វីដែលមិនអាចផ្លាស់ប្តូរបាន? ថាតើសិស្សអាចចូលរួមក្នុងការបង្កើតបរិយាកាសសិក្សាដែរឬទេ? ហើយមានទិដ្ឋភាពខុសប្លែកគ្នាអ្វីខ្លះនៃបរិយាកាសសិក្សា (ខាងសង្គម ជាឧទាហរណ៍....) ដែលចាំបាច់ត្រូវពិចារណា? តើបរិយាកាសសិក្សាត្រូវការអ្វីខ្លះដើម្បីធ្វើឱ្យអ្នកអាចជំរុញឱ្យសិស្សសកម្មបំផុតក្នុងមធ្យោបាយមួយ ដែលល្អបំផុត ដើម្បីឱ្យពួកគេអាចសម្រេចបាននូវគោលបំណងនៃការសិក្សា? ចូរប្រើផ្នែក “ឫស” ពីការរៀបចំគម្រោងបែបដើមឈើម៉ូឌុល១.២- ដើម្បីជួយអ្នកក្នុងការពិចារណា។

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

អ្នកអប់រំដែលជោគជ័យត្រូវចេះពីវិធីប្រើប្រាស់ធាតុសំខាន់ៗនៃការបង្រៀនដែលមានគុណភាពខ្ពស់សម្រាប់ថ្នាក់រៀនរបស់ខ្លួន។. ក្នុងម៉ូឌុលនេះ បង្ហាញពីមូលដ្ឋានមួយចំនួនសម្រាប់ការអនុវត្តការបង្រៀនប្រកបដោយប្រសិទ្ធភាព ដើម្បីធានាថាសមាសភាពសំខាន់នៃការបង្រៀននៅកម្រិតបឋមសិក្សាត្រូវបានពិចារណានៅពេលធ្វើផែនការបង្រៀន អនុវត្តការបង្រៀន វាយតម្លៃដំណើរការបង្រៀន និងរៀន។ តាមរយៈប្រធានបទផ្សេងៗ រួមបញ្ចូលការបង្រៀន និងរៀនសតវត្សទី២១ ការធ្វើកិច្ចតែងការបង្រៀន និងបរិស្ថាន សិក្សា អ្នកនឹងតម្រូវឱ្យធ្វើការឆ្លុះបញ្ចាំងពីដំណើរការបង្រៀន និងរៀនដើម្បីសម្រេចលទ្ធផលសិក្សាដោយជោគជ័យ។

សូមសិក្សាដោយរីករាយ!

TECHNISCHE UNIVERSITÄT DRESDEN

UNI GRAZ

CONTESSA
Contemporary Teaching Skills for South Asia
Co-funded by the Erasmus+ Programme of the European Union

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ម៉ូឌុល ២

ឧត្តមភាពក្នុងការបង្រៀន: សមត្ថភាពជាក់ណាក់ប្រកបដោយវិជ្ជាជីវៈរបស់គ្រូបង្រៀនបឋមសិក្សា

២.១- ការយល់ដឹងពីការបង្រៀន : តួនាទី តារកិច្ច និងមុខងារ

OER នេះត្រូវបានបង្កើតឡើងដោយជំនាញបង្រៀនសហសម័យសម្រាប់អាស៊ីខាងត្បូង / CONTESSA Consortium ដែលឧបត្ថម្ភថវិកាដោយកម្មវិធី Erasmus + នៃសហភាពអឺរ៉ុបក្រោមគម្រោងលេខ598756-EPP-1-2018-1-AT-EPPKA2-CBHE-JP–/CONTESSA.

កាលបរិច្ឆេទនៃការបោះពុម្ពផ្សាយ៖ ២០២១

បោះពុម្ពចេញផ្សាយដោយ:CONTESSA

អ្នកសម្របសម្រួលលទ្ធផល៖

Sandra Hummel, University of Graz (AT)

ដោយមានការចូលរួមវិភាគទានពី៖

សាកលវិទ្យាល័យហ្គ្រេស (AT): Mirjam Brodacz-Geier, Sarah Reichenstein, Sandra Hummel, Bridget Sheehan

សាកលវិទ្យាល័យកម្ពុជា (CM): Angus Munro, Siem Or

សាកលវិទ្យាល័យកូឡុំបូ (SR): H.M. Lalitha Kumari, Lakshman Weddikkarage, Jeevani Herath, Tiromi Indigahawela

ការបកប្រែជាភាសាខ្មែរ / ស៊ីនហាឡា / តាមិល:

ការបដិសេធ: គណៈកម្មការអឺរ៉ុបគាំទ្រផលិតកម្មក្នុងការបោះពុម្ពផ្សាយនេះមិនបង្កើតការយល់ព្រមលើខ្លឹមសារដែលឆ្លុះបញ្ចាំងពីទស្សនៈរបស់អ្នកនិពន្ធតែម្នាក់ឯងទេ ហើយគណៈកម្មការមិនអាចទទួលខុសត្រូវចំពោះការប្រើប្រាស់ណាមួយ ដែលអាចត្រូវបានធ្វើឡើងពីព័ត៌មានដែលមាននៅក្នុងនោះទេ។ វាអាចរកបានដោយបើកចំហ និងឥតគិតថ្លៃនៅលើគេហទំព័រ CONTESSA រួមជាមួយព័ត៌មានលំអិតបន្ថែមទៀត៖ https://contessa-project.eu/

ការរក្សាសិទ្ធិ៖ អត្ថបទនេះត្រូវបានផ្តល់សិទ្ធិស្របតាមលក្ខន្តិក: Creative Commons Attribution-ShareAlike ៤.0 អាជ្ញាប័ណ្ណអន្តរជាតិ (https://creativecommons.org/licenses/by-sa/4.0/) ដែលអនុញ្ញាតឱ្យប្រើប្រាស់ ចែករំលែក កែសម្រួល ចែកចាយ និងបង្កើតឡើងវិញនៅក្នុង ឧបករណ៍ផ្ទុក ឬទ្រង់ទ្រាយណាមួយ។ ជារាបណាអ្នកផ្តល់កិត្តិយសសមស្របដល់អ្នកនិពន្ធដើម និងប្រភពផ្តល់នូវតំណភ្ជាប់ទៅនឹងអាជ្ញាប័ណ្ណ Creative Commons និងចង្អុលបង្ហាញ ប្រសិនបើមានការផ្លាស់ប្តូរ។ ប្រសិនបើអ្នកបញ្ចូល កែសម្រួល រឹកសាងសំភារៈ អ្នកត្រូវផ្តល់អាជ្ញាប័ណ្ណសម្ភារៈដែលបានកែប្រែក្រោមលក្ខខ័ណ្ឌដូចគ្នា។

Co-funded by the
Erasmus+ Programme
of the European Union

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

CONTESSA
Contemporary Teaching Skills for South Asia
Co-funded by the Erasmus+ Programme of the European Union

CC BY SA

សេចក្តីផ្តើម

តើវគ្គសិក្សា CONTESSA ជាអ្វី?

វគ្គសិក្សា CONTESSA ជាលទ្ធផលមួយ ក្នុងចំណោមលទ្ធផលនៃគម្រោងស្តីអំពី "ជំនាញក្នុងការបង្រៀនសម័យថ្មី សម្រាប់អាស៊ីខាងត្បូង" ដែលផ្តល់មូលនិធិរួមដោយ Erasmus+ Program នៃសហភាពអឺរ៉ុប។ គោលបំណងរបស់វគ្គសិក្សានេះគឺការរួមចំណែកក្នុងការបង្កើតកម្មវិធីអប់រំគ្រូបង្រៀនដោយជោគជ័យ សម្រាប់គ្រូបឋមសិក្សា ជាពិសេសក្នុងប្រទេសកម្ពុជា និងស្រីលង្កាដែល នឹកនាំដល់ ការបង្កើតបានផលវិជ្ជមានដែលមានរយៈពេលវែងទៅលើប្រព័ន្ធអប់រំទូទៅ។

វាមានសារៈសំខាន់កាន់តែខ្លាំងឡើងសម្រាប់អ្នកអប់រំ ជាពិសេសជំនាញ និងវិធីសាស្ត្របង្រៀន ក្នុងសម័យថ្មីដើម្បី យកមកប្រើក្នុង និងក្រៅថ្នាក់រៀន។ ដូច្នេះវគ្គសិក្សា CONTESSA ផ្តល់ជូនមេរៀន ៥ម៉ូឌុល ដែលម៉ូឌុលនីមួយៗមានការផ្តល់ការយកចិត្តទុកដាក់ទៅលើចំណុចចំនួនបីដែលតម្រង់ទៅរកការអភិវឌ្ឍលើការបង្រៀនបែបសម័យថ្មី។ ម៉ូឌុលទាំងអស់ផ្តោតលើចំណុចសំខាន់ដូចខាងក្រោម៖

ម៉ូឌុល១៖ ការយល់ដឹងអំពីការអប់រំនៅបឋមសិក្សា
១. ការបង្រៀន និងការរៀននៅសតវត្សទី២១
២.ការរៀបចំកិច្ចតែងការបង្រៀន និងជំនាញគរុកោសល្យ៖ គំនិត ឧបករណ៍ និងការអនុវត្ត
៣. ការរៀបចំបរិយាកាសសិក្សា

ម៉ូឌុល២៖ ឧត្តមភាពក្នុងការបង្រៀន ៖ សមត្ថភាពជាក់លាក់ប្រកបទៅដោយវិជ្ជាជីវៈរបស់គ្រូបង្រៀនបឋមសិក្សា
១. ការយល់ដឹងពីការបង្រៀន៖ តួនាទី ភារកិច្ច និងមុខងារ
២. ការវាយតម្លៃលទ្ធផលនៃការសិក្សា
៣. ជំនាញវិជ្ជាជីវៈគរុកោសល្យ

ម៉ូឌុល៣៖ការអប់រំបែបគោលវិធីសិស្សមជ្ឈមណ្ឌល៖ ការលើកកម្ពស់ដំណើរសិក្សាដែលបានបង្កើតរួមគ្នា
១. ការអភិវឌ្ឍបុគ្គលលក្ខណៈ និងជំនាញដោះស្រាយបញ្ហា
២. ការអះអាងពីពិភពជីវិតដាក់ស្តែង និងក្តីសង្ឃឹមទៅអនាគត
៣.ការប្តេជ្ញាចិត្តដោយខ្លួនឯង ការផ្តល់សិទ្ធិអំណាច និងប្រសិទ្ធភាព ភាពផ្ទាល់ខ្លួន

ម៉ូឌុល៤៖ ការរួមបញ្ចូលភាពខុសគ្នា៖ គោលវិធីគរុកោសល្យសម្រាប់ភាពចម្រុះគ្នា ភាពមិនស្មើគ្នា និងតម្រូវការពិសេស
១. គរុកោសល្យបរិយាបន្ន៖ គោលវិធី និងយុទ្ធសាស្ត្រ
២. ការបង្រៀន និងការរៀនក្នុងភាពចម្រុះគ្នា៖ ការរៀបចំការយល់ដឹង ការវាយតម្លៃ
៣. ការគ្រប់គ្រងថ្នាក់រៀនដែលមានភាពចម្រុះគ្នា

ម៉ូឌុល៥៖ ការបង្រៀន និងការរៀនតាមបែបឌីជីថល
១. គរុកោសល្យនៃការសិក្សាពីចម្ងាយ និងបរិយាកាសសិក្សាដែលបំពាក់ទៅដោយបច្ចេកវិទ្យា
២. ប្រព័ន្ធផ្សព្វផ្សាយ និងបច្ចេកទេសឌីជីថល៖ ឧបករណ៍ និងទម្រង់សម្រាប់គោលបំណងការអប់រំ
៣. ការរៀបចំមេរៀន និងដំណើរការបង្រៀនតាមអ៊ិនធឺណែត

នៅពេលដែលបញ្ចប់វគ្គសិក្សានេះ អ្នកចូលរួម អាចអនុវត្តវិធីសាស្ត្របង្រៀនសម័យថ្មីធ្វើឱ្យសិស្សទាំងអស់ អាចចូលរួមសកម្មភាពក្នុងថ្នាក់ និងរៀនពីវិធីថ្មីៗ ដើម្បីជួយឱ្យសិស្សឈានទៅដល់ចំណុចសក្តានុពលពេញលេញរបស់ពួកគេ។

តើវគ្គសិក្សា CONTESSA សម្រាប់អ្នកណា?

គម្រោងស្តីពីជំនាញក្នុងការបង្រៀនសម័យថ្មីសម្រាប់អាស៊ីខាងត្បូងមានបំណងលើកកម្ពស់ជំនាញបង្រៀនសម័យថ្មីសម្រាប់គរុនិស្សិត និងគ្រូបង្រៀន ដែលកំពុងបម្រើការក្នុងសាលាបឋមសិក្សានានា។ ឯកសារខាងក្រោមត្រូវ បានប្រែសម្រួល ជាពិសេសសម្រាប់គរុសិស្ស។ លើសពីនេះទៅទៀត CONTESSA ក៏មានសារៈសំខាន់សម្រាប់ អ្នកដែលចាប់អារម្មណ៍ក្នុងការអភិវឌ្ឍសមត្ថភាពខ្លួន ឲ្យស្របតាម សម័យកាលជាមួយនឹងវិធីសាស្ត្របង្រៀនសម័យថ្មី។

ឯកសារមានជាភាសាអង់គ្លេស ហើយក៏មានប្រែសម្រួល ជាភាសាខ្មែរ ភាសាសិង្ហាលា (Sinhala) និងភាសាតាមីល (Tamil) ដែលប្រើប្រាស់នៅប្រទេសស្រីលង្កា។

តើរចនាសម្ព័ន្ធនៃវគ្គសិក្សា CONTESSA មានអ្វីខ្លះ?

ដូចបានលើកឡើងពីមុនរួមហើយCONTESSA មាន៥ម៉ូឌុល ដែលម៉ូឌុលនីមួយៗមានតម្លៃស្មើនឹង៣ក្រេឌីត តាមប្រព័ន្ធសិក្សារបស់អឺរ៉ុប។ ម៉ូឌុលទាំងនេះត្រូវបានប្រើប្រាស់

រួមគ្នា ព្រោះម៉ូឌុលនីមួយៗមានទំនាក់ទំនងរៀងគ្នាជាមួយ ម៉ូឌុលដទៃទៀត ក្នុងមេរៀនម៉ូឌុលទាំងនេះ បានបង្កើត ឡើងក្នុងវិធីមួយដែលអាចប្រើបាន ដោយខ្លួនឯងផ្ទាល់ ផងដែរ។

ម៉ូឌុលនីមួយៗមានការផ្តោតលើចំណុចសំខាន់ចំនួន។ វាបង្កើតឱ្យមានជាមេរៀនសរុបចំនួន១៥ផ្នែកសម្រាប់វគ្គសិក្សា CONTESSA ។

ឯកសារនីមួយៗរួមមាន សេចក្តីផ្តើមបែបទ្រឹស្តី នឹងមានលំហាត់អនុវត្ត ដោយផ្អែកតាមទ្រឹស្តីខាងលើ។

ជំហាន១ ទ្រឹស្តី៖ គឺជាការរំលឹកនូវអ្វីដែល បានអាន ទ្រឹស្តីក្នុងសេចក្តីផ្តើមលំហាត់អនុវត្តទាំងនេះ ត្រួតពិនិត្យការយល់ដឹង នៃអត្ថបទដើម្បីប្រាកដថាទ្រឹស្តីជាមូលដ្ឋានដែលត្រូវបានយល់ដឹង។

ជំហានទី២ បទពិសោធ៖ គ្រូបង្រៀនបានផ្តល់នូវ ឧទាហរណ៍ដែលផ្សារភ្ជាប់ទ្រឹស្តីនឹងការអនុវត្តជាក់ស្តែង។ ឧទាហរណ៍៖គ្រូអនុវត្តលំហាត់ភ្ជាប់ជាមួយនឹងទ្រឹស្តីដែលបានរៀនរួចហើយ។

ជំហានទី៣ ការឆ្លុះបញ្ចាំងដោយខ្លួនឯងផ្ទាល់៖ ពាប់បញ្ចូលសំណួរបែបឆ្លុះបញ្ចាំង ដោយផ្អែកទៅលើចំណុចនីមួយៗ។

ជំហាន៤ ការអនុវត្ត៖ គឺជាជំហានចុងក្រោយការបង្រៀនផ្អែកទៅលើអ្វីដែលបានរៀបរាប់នៅក្នុងជំហានទីមួយ និងទីពីរ។

លំហាត់អនុវត្តនៅក្នុងជំហានទីមួយ និងទីពីរ អាចត្រូវបានបំពេញក្នុងឯកសារនេះ។ ជំហានទី៣ និងទីបួនជាផ្នែក នៃឯកសារដែលរៀបជាសំណុំដាច់ដោយឡែកដែលនឹងត្រូវបង្កើតដោយបុគ្គលម្នាក់ៗ។ គំរូសម្រាប់ការរៀបចំសំណុំឯកសារ (portfolio) មានជាឯកសារដាច់ដោយឡែកពីគ្នា។

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

មាតិកា

១-ការយល់ដឹងពីការបង្រៀន ១

១.១-តួនាទីរបស់គ្រូបង្រៀន ២

១.២-ភារកិច្ចបង្រៀន ៦

១.២.១-ជំនាញលើមុខវិជ្ជា ៨

១.២.២-ជំនាញលើការចែករំលែកចំណេះដឹងទូទៅ ៩

១.២.៣-ជំនាញលើការគ្រប់គ្រងថ្នាក់រៀនទូទៅ ១០

១.២.៤-ជំនាញឆ្លើយតបបែបលក្ខណៈបុគ្គល ១១

១.២.៥-អាកប្បកិរិយាទូទៅ ១២

២-ស្ថានភាពក្នុងប្រទេសកម្ពុជា ១៣

៣-ស្ថានភាពក្នុងប្រទេសស្រីលង្កា ១៤

៤-សេចក្តីសន្និដ្ឋាន ១៥

៥-ចំណុចសំខាន់ៗ ១៥

៦-ឯកសារពិគ្រោះ ១៦

ជំហាន១: លំហាត់អនុវត្ត ១៩

ជំហាន១: លំហាត់អនុវត្ត ដំណោះស្រាយ ២៣

ជំហាន២: ដំណោះស្រាយ ២៧

ជំហាន២: ដំណោះស្រាយ ៣១

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

១-ការយល់ដឹងពីការបង្រៀន

ចំពោះអ្នកចូលចិត្តតន្ត្រី ការមើលការប្រគុំតន្ត្រីពីទស្សនិកជន វាងាយស្រួល និងជឿជាក់ថា អ្នកដឹកនាំបញ្ជាតន្ត្រីមានការងារមួយ ដែលងាយស្រួលបំផុតនៅក្នុងពិភពលោក។ គាត់ឈរនៅទីនោះ ហើយគ្រាន់តែគ្រវីដៃរបស់គាត់តាមចង្វាក់ភ្លេង ហើយវង់ភ្លេងបន្លឺសំឡេងរោទ៍ដល់ការបង្ហាញខ្លួនទាំងអស់។ លាក់បាំងពីទស្សនិកជនជាពិសេសពីតន្ត្រីថ្មីថ្មោង គឺជាសមត្ថភាពរបស់អ្នកដឹកនាំក្នុងការអាន និងបកស្រាយផ្នែកទាំងអស់ក្នុងពេលតែមួយក្នុងការលេងឧបករណ៍ជាច្រើន និងយល់ពីសមត្ថភាពរបស់អ្នកដឹកនាំបញ្ជាតន្ត្រីក្នុងការរៀបចំ និងសម្របសម្រួលផ្នែកខុសគ្នាដើម្បីជួយជំរុញ និងបង្កើតឱ្យមានទំនាក់ទំនងជាមួយសមាជិកវង់តន្ត្រីទាំងអស់។ តាមរបៀបដែលការប្រព្រឹត្តមើលទៅដូចជាដៃគ្រវីទៅនឹងមនុស្សដែលមិនចេះនិយាយ ការបង្រៀនមើលទៅសាមញ្ញពីទស្សនៈរបស់សិស្សដែលឃើញមនុស្សម្នាក់កំពុងនិយាយ និងស្តាប់ចែកក្រដាស និងផ្តល់ការងារ។ មើលមិនឃើញនៅក្នុងការសម្តែងទាំងពីរនេះមានចំណេះដឹងជាច្រើនប្រភេទ ផែនការដែលមើលមិនឃើញ និងការធ្វើចលនានៅខាងក្រោយដែលជាស្នាដៃដ៏ស្ទឹមស្មៃ ប្រសិនបើអ្នកចង់ធ្វើឱ្យគ្រូអាចផ្លាស់ប្តូរក្រុមសិស្សដោយចេតនាពីមួយសំណុំនៃការយល់ដឹង និងជំនាញមួយទៅមួយទៀតចន្លោះជាច្រើនខែ។(Darling-Hammond & Bransford, 2005, p. 1f)

ការដកស្រង់ខាងលើបង្ហាញពីភាពស្មុគស្មាញនៃតួនាទី ភារកិច្ច និងមុខងាររបស់គ្រូក្នុងការបង្កើតលទ្ធផលចុងក្រោយនៅក្នុងជីវិតសិស្ស។ ក្នុងមេរៀនដូចដែលបានរៀបរាប់ខាងលើមនុស្សម្នាក់ទំនងជាឃើញ និងពេញចិត្តចំពោះលទ្ធផលដែលភ្លេចពីកម្លាំងពលកម្មដែលបានចំណាយក្នុងការផលិតវា។ នៅក្នុងលទ្ធផលណាមួយមានកម្លាំងពលកម្មដែលមើលមិនឃើញនៅក្នុងផ្ទៃខាងក្រោយ។ សូមឱ្យយើងក្រឡេកមើលការងារ ដែលមិនមានការកត់សម្គាល់របស់គ្រូម្នាក់ដោយពិចារណាលើតួនាទី ភារកិច្ច និងទំនួលខុសត្រូវរបស់គ្រូ។

១.១- តួនាទីរបស់គ្រូបង្រៀន

ប្រាកដណាស់ថា តួនាទីរបស់គ្រូបង្រៀនម្នាក់ៗរងឥទ្ធិពលពីកត្តាខាងក្នុង និងកត្តាខាងក្រៅ។ ម៉្យាងវិញទៀត គ្រប់ការរំពឹងទុកគឺកើតចេញពីមជ្ឈដ្ឋានខាងក្រៅ។ នេះគឺជាតម្រូវការរបស់ស្ថាប័ន សង្គម និងកម្មវិធីសិក្សា ដែលកើតចេញពីអ្នករួមការងារ ថ្នាក់ដឹកនាំ សិស្សានុសិស្ស ឬអ្នកអាណាព្យាបាល។ រាជរដ្ឋាភិបាល ដែលជាអ្នកចេញនូវកម្មវិធីសិក្សា

តួនាទី៖ គំរូនៃឥរិយាបទដែលរំពឹងទុកក្នុងសង្គមជាធម្មតាត្រូវបានកំណត់ដោយហានៈរបស់បុគ្គលម្នាក់ៗនៅក្នុងសង្គមជាក់លាក់មួយ។ (វចនានុក្រម Merriam-Webster តាមអ៊ីនធឺណិត)

និមិត្តសញ្ញាគ្រូ ១ -" អ្នកត្រូវ..." ឬ" អ្នកត្រូវ..." ២ - សិស្សត្រូវបានគេវាយតម្លៃជាមួយនឹងចំណាត់ថ្នាក់លេខលើរាល់កិច្ចការ ៣-អង្គការទី ៤ សិស្សអាចជ្រើសរើសក្រុមរបស់ពួកគេនិងលំដាប់នៃភារកិច្ច ៥ -" អ្នកអាច..." ឬ" ប្រហែលជាអ្នកព្យាយាម ... " ៦ - ប្រតិកម្មរបស់គ្រូ ៧

ឥរិយាបទ	គាំទ្រស្ថ័យភាព	ការត្រួតពិនិត្យ
	អ្នកបានសរសេររឿងរ៉ាវគួរឱ្យចាប់អារម្មណ៍មួយដែលមានរចនាសម្ព័ន្ធល្អ។	អ្នកបានបញ្ចប់លំហាត់ដូចដែលអ្នកត្រូវបានគេប្រាប់។
ជំរើសរបស់សិស្ស		គ្រូជ្រើសរើសក្រុមនិងលំដាប់នៃភារកិច្ច។
	គ្រូបង្រៀនកែតម្រូវកិច្ចការដែលមានបិចពណ៌បៃតង ឬខៀវ។	គ្រូកែដោយប្រើបិចក្រហម។
ភាសា		
ថ្នាក់	សិស្សត្រូវបានវាយតម្លៃតាមវិធីផ្សេងៗពេញមួយឆ្នាំ។	

	និស្សិតអាចជ្រើសរើសពេលវេលាដែលពួកគេចំណាយលើការងារជាក់លាក់ក្នុងរយៈពេលដែលបានកំណត់។	សិស្សត្រូវបំពេញភារកិច្ចនៅពេលគ្រូប្រាប់។

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ក. ទាញ និងទម្លាក់លក្ខណៈទៅក្នុងប្រភេទសមស្របនៅក្នុងតារាងខាងក្រោម៖
រៀនតាមរយៈស្ថានភាពជាក់ស្តែងឬក្លែងធ្វើ ១ ការពឹងពាក់គ្នាទៅវិញទៅមកវិជ្ជមាន ២ - អភិវឌ្ឍនិងកែលំអការទំនាក់ទំនងការកសាងទំនុកចិត្តនិងភាពជាអ្នកដឹកនាំ ៣ - រចនាម៉ូដគ្រូបង្រៀនរចនាសម្ព័ន្ធការសិក្សា ៤ - គ្រូបង្រៀនជាអ្នកសម្របសម្រួល ៥ - មិនមានលទ្ធផលស្តង់ដារ ៦ - សិស្សធ្វើការរួមគ្នាជាក្រុមតូចៗលើកិច្ចការដែលបានផ្តល់ឱ្យ ៧ - ការរៀនសូត្រគឺ រយៈពេលវែងនិងអន្តរសិក្សាជាង ៨ - សមាជិកក្រុមទាំងអស់ទទួលខុសត្រូវចំពោះភាពជោគជ័យ ៩ ការកិច្ចមានអត្ថន័យចំពោះសិស្សខ្លួនឯង ១០- គ្រូគ្រប់គ្រងលើរចនាសម្ព័ន្ធសិក្សា ១១ - ក្រុមទាំងមូលសម្រេចចិត្តថាតើអ្វីទៅល្អហើយត្រូវផ្លាស់ប្តូរឬកែលម្អកន្លែងណា អ្វីមួយ ១២

ការសិក្សារួមគ្នា	ការរៀនសូត្រផ្តែកលើបញ្ហា	ការរៀនសូត្រសហប្រតិបត្តិការ

ក. ការផ្គូផ្គងជំនាញ (១-៦) ជាមួយការអនុវត្តនៃការរៀនសូត្រដែលផ្តោតលើបញ្ហា

១. ភាពបត់បែន

២. ការរៀបចំ

៣. ការគ្រប់គ្រងខ្លួនឯង

៤. ការចាប់ផ្តើមការកិច្ច

៥. ការគ្រប់គ្រងពេលវេលា

៦. បណ្តុំនៃបញ្ញា

ក. ផ្តល់ឱ្យនិស្សិតនូវឧបករណ៍ដើម្បីគ្រប់គ្រងគម្រោងរបស់ពួកគេ

ខ. ធ្វើជាគំរូនៃអាកប្បកិរិយាគោរព និងបង្កើតពិធីការប្រកបដោយការគោរព

គ. បង្កើតព្រឹត្តិការណ៍បណ្តោះអាសន្នដែលដំណើរការឆ្ពោះទៅរកផលិតផលចុងក្រោយ។

ឃ. ការរៀបចំគម្រោងដែលបានបញ្ចប់ ដោយមានដំណោះស្រាយច្រើនជាងមួយ។

ង. សុំឱ្យនិស្សិតឆ្លុះបញ្ចាំងពីការរីកចម្រើនរបស់ពួកគេ។

ច. ស្នើឱ្យនិស្សិតតាមដានគោលដៅនិងវឌ្ឍនភាពរបស់ពួកគេនៅក្នុងទិនានុប្បវត្តិ

ត្រូវគ្នានឹងបទដ្ឋាននៃការសហការពីផ្នាំងរូបភាពទៅនឹងនិយមន័យដែលត្រូវគ្នារបស់ពួកគេ៖

_____អនុញ្ញាតឱ្យមានពេលវេលាសម្រាប់ការគិត និងបង្កើនការសន្ទនាការពិភាក្សា និងការសម្រេចចិត្ត
_____បង្កើតការសន្ទនាប្រកបដោយអត្ថន័យ
_____ជួយឱ្យសិស្សស្វែងរកការយល់ដឹងជាមុន
_____បង្កើនភាពច្បាស់លាស់ និងភាពជាក់លាក់នៃការគិតរបស់សិស្ស
_____ជួយសិស្សឱ្យដឹងថាតើពាក្យសម្តី និងសកម្មភាពរបស់ពួកគេជះឥទ្ធិពលដល់ក្រុមយ៉ាងដូចម្តេច
_____អនុញ្ញាតឱ្យសិស្សស្តាប់និងយល់គ្

_____ជំរុញការសន្ទនាប្រកបដោយផលិតភាព និងលុបបំបាត់ការអាក់អន់ចិត្តដោយអចេតនា

ជំហានទី១ លំហាត់អនុវត្ត - ដំណោះស្រាយ

ក. ចង្អុលបង្ហាញប្រសិនបើសេចក្តីថ្លែងការណ៍ខាងក្រោមមានពិត ឬមិនពិត៖

១. ការផ្លាស់ប្តូរបច្ចុប្បន្នទៅបរិបទបង្រៀនផ្តោតលើអ្នកសិក្សាមានន័យថា គ្រូត្រូវបានគេចាត់ទុកថាជា" អ្នកជំនាញ" ។ **ពិត/មិនពិត**

២. ទីបំផុតគ្រូដែលមានថាមពលតិចចែករំលែកសិស្សនឹងពឹងផ្អែកកាន់តែច្រើន។ **ពិត/មិនពិត**

៣. នៅក្នុងថ្នាក់រៀនដែលគ្រូគាំទ្រស្វ័យភាពសិស្សធ្វើឱ្យប្រសើរឡើងនូវការសិក្សារបស់ពួកគេមានភាពច្នៃប្រឌិតនិងកែសំរួលបានល្អចូលរួមនៅក្នុងសាលានិងមានអារម្មណ៍តានតឹងតិច។ **ពិត/មិនពិត**

៤. ការរៀនសូត្ររួមគ្នាមិនអនុញ្ញាតឱ្យសិស្សសម្រេចចិត្តលើរបៀបដែលពួកគេរៀបចំរចនាសម្ព័ន្ធអន្តរកម្ម និងការរៀនសូត្ររបស់ពួកគេ។ គ្រូសំរេចចិត្ត។ **ពិត/មិនពិត**

៥. ការរៀនសូត្រផ្អែកលើបញ្ហាគឺជាប្រភេទនៃការរៀនសូត្រផ្អែកលើការសាកសួរដែលមានលក្ខណៈយូរអង្វែងនិងមានមុខវិជ្ជាសិក្សាច្រើនតែ មិនមានចម្លើយច្បាស់លាស់នៅចុងបញ្ចប់។ **ពិត/មិនពិត**

៦. ដំណើរការមុខងារប្រតិបត្តិដូចជាការសំរបសំរួលផ្ទាល់មាត់ការធ្វើនិយ័តកម្មខ្លួនឯងការធ្វើផែនការការ-វិនិច្ឆ័យនិងការតាមដានខ្លួនឯងគឺជា ឧទាហរណ៍នៃជំនាញមេត្តា។ **ពិត/មិនពិត**

៧. ការផ្តោតអារម្មណ៍នៃការរៀនសូត្រផ្អែកលើបញ្ហាគឺការអភិវឌ្ឍនិងពង្រឹងជំនាញមួយក្នុងពេលតែមួយ។ **ពិត/មិនពិត**

៨. ការស្តាប់គឺជាជំនាញដ៏សំខាន់ក្នុងការងារួមគ្នា។ **ពិត/មិនពិត**

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ខ. បំពេញក្នុងដៃនលទ្ធផលរំពឹងទុកនីមួយៗយោងទៅតាមក្របខ័ណ្ឌរបស់យូណេស្កូសម្រាប់ផ្តល់សិទ្ធិអំណាចដល់និស្សិត៖

ការយល់ដឹង – មនោសញ្ចេតនាសង្គម – ឥរិយាបទ

__**ការយល់ដឹង** __និស្សិតទទួលបានចំណេះដឹងនិងការយល់ដឹងអំពីបញ្ហាក្នុងតំបន់ជាតិ និងពិភពលោក។
_____**ឥរិយាបទ**__ និស្សិតអភិវឌ្ឍការលើកទឹកចិត្ត និងឆន្ទៈក្នុងការធ្វើសកម្មភាពចាំបាច់។
__**ការយល់ដឹង** __ សិស្សអភិវឌ្ឍជំនាញគិត និងវិភាគ។
មនោសញ្ចេតនាសង្គមនិស្សិតមានអារម្មណ៍ថាជាកម្មសិទ្ធិរបស់មនុស្សសាមញ្ញការចែករំលែកគុណតម្លៃនិងទំនួលខុសត្រូវដោយផ្អែកលើសិទ្ធិមនុស្ស។
__**ការយល់ដឹង** __និស្សិតទទួលបានចំណេះដឹង និងការយល់ដឹងអំពីអន្តរទំនាក់ទំនង និងភាពអាស្រ័យគ្នាទៅវិញទៅមកនៃប្រទេស និង ប្រជាជនផ្សេងៗគ្នា។
មនោសញ្ចេតនាសង្គម និស្សិតបង្កើតឥរិយាបថនៃការយល់ចិត្ត សាមគ្គីភាព និងការគោរពចំពោះភាពខុសគ្នា និងភាពចម្រុះ។
_**ឥរិយាបទ**____ សិស្សធ្វើសកម្មភាពប្រកបដោយប្រសិទ្ធភាព និងទំនួលខុសត្រូវនៅថ្នាក់មូលដ្ឋានជាតិ និងពិភពលោកដើម្បីពិភពលោកមួយ ប្រកបដោយនិរន្តរភាព និងសន្តិភាព។

ក. បំពេញតារាងដោយបំពេញបំណែកដែលបាត់៖

និមិត្តសញ្ញាគ្រូ ១ -" អ្នកត្រូវ..." ឬ" អ្នកត្រូវ..." ២ - សិស្សត្រូវបានគេវាយតម្លៃជាមួយនឹងចំណាត់ថ្នាក់លេខលើរាល់កិច្ចការ ៣ - អង្គការ ទី ៤ សិស្សអាចជ្រើសរើសក្រុមរបស់ពួកគេនិងលំដាប់នៃភារកិច្ច ៥ -" អ្នកអាច..." ឬ" ប្រហែលជាអ្នកព្យាយាម ... " ៦ - ប្រតិកម្មរបស់គ្រូ ៧

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

តវិយោបទ	គាំទ្រស្វ័យភាព	ការត្រួតពិនិត្យ
7	អ្នកបានសរសេររឿងរ៉ាវគួរឱ្យចាប់អារម្មណ៍មួយដែលមានរចនាសម្ព័ន្ធល្អ។	នកបានបញ្ចប់លំហាត់ដូចដែលអ្នកត្រូវបានគេប្រាប់។
ជំរើសរបស់សិស្ស	5	គ្រូជ្រើសរើសក្រុមនិងលំដាប់នៃការកិច្ច។
1	គ្រូបង្រៀនកែតម្រូវកិច្ចការដែលមានបិចពណ៌បៃតង ឬខៀវ។	គ្រូកែដោយប្រើបិចក្រហម។
ភាសា	6	2
ថ្នាក់	សិស្សត្រូវបានវាយតម្លៃតាមវិធីផ្សេងៗពេញមួយឆ្នាំ។	3
4	និស្សិតអាចជ្រើសរើសពេលវេលាដែលពួកគេចំណាយលើការងារជាក់លាក់ក្នុងរយៈពេលដែលបានកំណត់។	សិស្សត្រូវបំពេញការកិច្ចនៅពេលគ្រូប្រាប់។

ក. ទាញ និងទម្លាក់លក្ខណៈទៅក្នុងប្រភេទសមស្របនៅក្នុងតារាងខាងក្រោម៖
រៀនតាមរយៈស្ថានភាពជាក់ស្តែងឬក្លែងធ្វើ ១ ការពឹងពាក់គ្នាទៅវិញទៅមកវិជ្ជមាន ២ - អភិវឌ្ឍនិងកែលំអការទំនាក់ទំនងការកសាងទំនុកចិត្តនិងភាពជាអ្នកដឹកនាំ ៣ - រចនាម៉ូដគ្រូបង្រៀនរចនាសម្ព័ន្ធការសិក្សា ៤ - គ្រូបង្រៀនជាអ្នកសម្របសម្រួល ៥ - មិនមានលទ្ធផលស្តង់ដារ ៦ - សិស្សធ្វើការរួមគ្នាជាក្រុមតូចៗលើកិច្ចការដែលបានផ្តល់ឱ្យ ៧ - ការរៀនសូត្រគឺ រយៈពេលវែងនិងអន្តរសិក្សាជាង ៨ - សមាជិកក្រុមទាំងអស់ទទួលខុសត្រូវចំពោះភាពជោគជ័យ ៩ ការកិច្ចមានអត្ថន័យចំពោះសិស្សខ្លួនឯង ១០- គ្រូគ្រប់គ្រងលើរចនាសម្ព័ន្ធសិក្សា ១១ - ក្រុមទាំងមូលសម្រេចចិត្តថាតើអ្វីទៅល្អហើយត្រូវផ្លាស់ប្តូរឬកែលម្អកន្លែងណា អ្វីមួយ ១២

ការសិក្សារួមគ្នា	ការរៀនសូត្រផ្តែកលើបញ្ហា	ការរៀនសូត្រសហប្រតិបត្តិការ
2	1	4
3	6	7
5	8	11
9	10	12

ក. ការផ្គូផ្គងជំនាញ (១-៦) ជាមួយការអនុវត្តនៃការរៀនសូត្រដែលផ្តោតលើបញ្ហា

១. ភាពបត់បែន

២. ការរៀបចំ

៣. ការគ្រប់គ្រងខ្លួនឯង

៤. ការចាប់ផ្តើមការកិច្ច

៥. ការគ្រប់គ្រងពេលវេលា

៦. បណ្តុំនៃបញ្ញា

ក. ផ្តល់ឱ្យនិស្សិតនូវឧបករណ៍ដើម្បីគ្រប់គ្រងគម្រោងរបស់ពួកគេ

ខ. ធ្វើជាគំរូនៃអាកប្បកិរិយាគោរព និងបង្កើតពិធីការប្រកបដោយការគោរព

គ. បង្កើតព្រឹត្តិការណ៍បណ្តោះអាសន្នដែលដំណើរការឆ្ពោះទៅរកផលិតផលចុងក្រោយ។

ឃ. ការរៀបចំគម្រោងដែលបានបញ្ចប់ ដោយមានដំណោះស្រាយច្រើនជាងមួយ។

ង. សុំឱ្យនិស្សិតឆ្លុះបញ្ចាំងពីការរីកចម្រើនរបស់ពួកគេ។

ច. ស្នើឱ្យនិស្សិតតាមដានគោលដៅ និងវឌ្ឍនភាពរបស់ពួកគេនៅក្នុងទិនានុប្បវត្តិ

២ក – ៣ខ – ៥គ – ១ឃ – ៦ង – ៤ច

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ក. ចូរផ្គូផ្គងបទដ្ឋាននៃការសហការពីផ្នាំងរូបភាពទៅនឹងនិយមន័យដែលត្រូវគ្នារបស់ពួកគេ៖

២	អនុញ្ញាតឱ្យមានពេលវេលាសម្រាប់ការគិត និងបង្កើនការសន្ទនាការពិភាក្សា និងការសម្រេចចិត្ត
៥	បង្កើតការសន្ទនាប្រកបដោយអត្ថន័យ
១	ជួយឱ្យសិស្សស្វែងរកការយល់ដឹងជាមុន
៤	បង្កើនភាពច្បាស់លាស់ និងភាពជាក់លាក់នៃការគិតរបស់សិស្ស
៦	ជួយសិស្សឱ្យដឹងថាតើពាក្យសម្តី និងសកម្មភាពរបស់ពួកគេជះឥទ្ធិពលដល់ក្រុមយ៉ាងដូចម្តេច
៣	អនុញ្ញាតឱ្យសិស្សស្តាប់ និងយល់គ្នា
៧	ជំរុញការសន្ទនាប្រកបដោយផលិតភាព និងលុបបំបាត់ការអាក់អន់ចិត្តដោយអចេតនា

ជំហានទី២

ក. សូមអានករណីសិក្សាខាងក្រោម។ សម្រេចចិត្តថាការពិពណ៌នាមួយណាតំណាងឱ្យការរៀនសូត្រដែលមានបញ្ហាតើការរៀនសូត្របែបសហការមួយនិងការរៀនសូត្របែបណាដែលសហការគ្នា៖

ករណីសិក្សា១

លោកនីវ័ត្នប្រគល់អត្ថបទស្តីពីការបែងចែកសំរាមនៅក្នុងថ្នាក់របស់គាត់ហើយសរសេរសំណួរចំនួនបីនៅលើក្តារ។ សិស្សគួរតែអានអត្ថបទដោយខ្លួនឯងជាមុនសិនហើយសរសេរពាក្យសំខាន់ៗ។ និស្សិតត្រូវបានគេសន្មត់ថាធ្វើការជាមួយគ្នាជាក្រុមដែលមានគ្នាបីនាក់ដើម្បីពិភាក្សាអត្ថបទនិងឆ្លើយសំនួរ។ លោកនីវ័ត្នដើរជុំវិញថ្នាក់ហើយផ្តល់ឱ្យក្រុមជួយនៅពេលដែលពួកគេត្រូវការ។ បន្ទាប់មកក្រុមទាំងអស់គួរតែបង្ហាញលទ្ធផល និងការរកឃើញរបស់ពួកគេនៅមុខថ្នាក់។_____ _____

ករណីសិក្សា២

ថ្នាក់ទី ៤ បច្ចុប្បន្នកំពុងរៀនរូបមន្តសម្រាប់ផ្ទៃការ៉េនិងចតុកោណ។ លោកស្រី Munro បាននាំយកសម្ភារៈធ្វើដោយដៃផ្សេងៗរបស់និស្សិត (ឧទាហរណ៍ការបិទក្រដាសខ្សែអក្សរ) ហើយក្នុងក្រុមសិស្សបួននាក់ត្រូវបានស្នើឱ្យរចនាម៉ូដគំរូសរុបទាំងអស់នៃការ៉េ និងចតុកោណបួន។ បន្ទាប់មកគ្រូចង់បន្តធ្វើការជាមួយតួលេខទាំងនេះ។_____ _____

ករណីសិក្សា៣

សិស្សថ្នាក់ទី ២ មានការរំភើបយ៉ាងខ្លាំងនៅពេលដែលកញ្ញាវិចិណាផាតថាណា៉ាចូលថ្នាក់រៀនដោយមានប័ណ្ណប្រកាសនិងបិច។ ថ្ងៃនេះនាងចាប់ផ្តើមមុខវិជ្ជាថ្មីមួយនៅក្នុងថ្នាក់ជីវវិទ្យាគឺសុខភាព។ នាងរុញតុជាមួយគ្នាហើយកុមារត្រូវបានគេសន្មត់ថាធ្វើការជាក្រុមបួនដើម្បីបង្កើតផែនទីគំនិតលើប្រធានបទសុខភាព។ ពួកគេគួរតែសរសេរអ្វីគ្រប់យ៉ាងដែលពួកគេអាចគិតអំពីពាក្យសុខភាព។ តាមរយៈការងារបើកចំហនិស្សិតគួរតែកែលម្អនិងអភិវឌ្ឍជំនាញសង្គម (ឧទាហរណ៍ការប្រាស្រ័យទាក់ទង) បន្ថែមលើទិដ្ឋភាពដែលទាក់ទងនឹងខ្លឹមសារ។_____ _____

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ក. ខាងក្រោមនេះអ្នកអាចឃើញបញ្ជីនៃសេចក្តីថ្លែងផ្សេងគ្នានៃឥរិយាបទគាំទ្រស្វ័យភាពរបស់គ្រូនិងអាកប្បកិរិយាគ្រប់គ្រងគ្រូ។ ទាញនិងទម្លាក់ឧទាហរណ៍ទៅក្នុងប្រភេទសមស្របក្នុងតារាងខាងក្រោម៖

ខ្ញុំតែងតែប្រើបិចពណ៌ក្រហមដើម្បីកែកំហុសក្នុងអត្ថបទឬការធ្វើតេស្ត ១។ ខ្ញុំតែងតែប្រាប់សិស្សរបស់ខ្ញុំថាពួកគេអាចធ្វើការជាក្រុមរឺធ្វើដោយខ្លួនឯងបាន ២។ ខ្ញុំមានផែនការធ្វើការសម្រាប់រាល់សប្តាហ៍ និស្សិតអាចជ្រើសរើសនៅពេលដែលពួកគេចង់ធ្វើការងារណាមួយ។ ការបញ្ជាក់តែមួយគត់គឺថាអ្វីៗត្រូវធ្វើនៅថ្ងៃសុក្រទី ៣ ។ ខ្ញុំតែងតែសរសើរសិស្សរបស់ខ្ញុំនៅពេលដែលពួកគេដោះស្រាយបញ្ហាគណិតវិទ្យាទាំងអស់ដូចដែលពួកគេត្រូវបានប្រាប់៤។ មនុស្សបួននាក់ដោយខ្លួនឯង។ ៥ - ខ្ញុំប្រើពណ៌ផ្សេងៗគ្នាដើម្បីកែហើយមិនមែនពណ៌ក្រហមទេ។ - នៅពេលសរសេរខ្ញុំតែងតែប្រាប់សិស្សរបស់ខ្ញុំថាតើពួកគេត្រូវសរសេរប៉ុន្មាន ៧។៨ - នៅពេលនិយាយពីការងារជាគូ ខ្ញុំសូមរំលឹកសិស្សម្តងហើយម្តងទៀតថា ពួកគេនឹងទទួលបានពិន្ទុលើការងាររបស់ពួកគេ។ ៩ ខ្ញុំសូមកោតសរសើរចំពោះការខិតខំរបស់សិស្សខ្ញុំហើយប្រាប់ពួកគេនៅពេលខ្ញុំគិតថាវាអស្ចារ្យ។ ឧទាហរណ៍ពួកគេបានគូសបញ្ជាក់ដំណោះស្រាយចំពោះបញ្ហាគណិតវិទ្យាដោយបិចពណ៌និងបន្ទាត់មួយ ១០។ - ប្រសិនបើយើងមានពេលនៅសល់ប៉ុន្មាននាទីនៅក្នុងមេរៀនសិស្សរបស់ខ្ញុំអាចអានសៀវភៅដែលពួកគេបានជ្រើសរើស ១១។

ឥរិយាបថគាំទ្រស្វ័យភាព	ការគ្រប់គ្រងឥរិយាបថ

ក. សម្របនិយមន័យនៃស្តង់ដារសហការពីផ្នាំងរូបភាពទៅជាឧទាហរណ៍ជាក់ស្តែងដែលត្រូវគ្នា។ ដើម្បីធ្វើដូចនេះ សូមភ្ជាប់ឧទាហរណ៍ដែលសមស្របជាមួយគ្នា៖

(១)ជួយសិស្សឱ្យស្វែងរកការយល់ដឹងជាមុន:

(២) ទុកពេលសម្រាប់ការគិតនិងបង្កើនការសន្ទនាការពិភាក្សានិងការសម្រេចចិត្ត៖

(៣) អនុញ្ញាតឱ្យសិស្សស្តាប់និងស្វែងយល់ពីគ្នាទៅវិញទៅមក៖

(៤) បង្កើនភាពច្បាស់លាស់និងភាពជាក់លាក់នៃការគិតរបស់សិស្ស៖

(៥) បង្កើតការសន្ទនាប្រកបដោយអត្ថន័យ៖

(៦) ជួយសិស្សឱ្យដឹងថាតើពាក្យនិងសកម្មភាពរបស់ពួកគេមានឥទ្ធិពលយ៉ាងណាទៅលើក្រុម៖

(៧) ជម្រុញកិច្ចពិភាក្សាប្រកបដោយផលិតភាពនិងលុបបំបាត់ការអាក់អន់ចិត្តដោយអចេតនា៖

(ក)" ដូច្នេះអ្នកអាចនិយាយបានថាគុណភាពនៃការគេងជះឥទ្ធិពលដល់ការបំពេញការងាររបស់អ្នកនៅក្នុងជីវិតប្រចាំថ្ងៃហើយវាក៏ជះឥទ្ធិពលដល់ការយល់ឃើញនៃភាពតានតឹងរបស់អ្នកផងដែរ។ នោះជាទិដ្ឋភាពល្អ។

(ខ)" ខ្ញុំគិតថាលើសាចង់និយាយថាវាមិនអាស្រ័យលើប្រភេទកីឡាដែលអ្នកធ្វើនោះទេប៉ុន្តែអ្នកពិតជាសកម្ម" ។

(គ) ខ្ញុំចង់ដឹងកាន់តែច្បាស់អំពីការគេងអាចជះឥទ្ធិពលដល់សុខភាពរបស់ខ្ញុំ។
(ឃ)" តើអ្នកយល់ព្រមទេប្រសិនបើយើងសរសេរកីឡានៅលើក្តារនោះ? តើការធ្វើលំហាត់ប្រាណអាចជះឥទ្ធិពលដល់សុខភាពរបស់យើងយ៉ាងដូចម្តេច?
(ង)" តើអ្នកគិតថាការគេងប៉ះពាល់ដល់ការយល់ឃើញនៃភាពតានតឹងកម្រិតណា?"
(ច)" តើអ្នកគិតយ៉ាងណា?ខ្ញុំរងចាំបន្តិចដើម្បីទុកពេលគិតមុន។ ប្រហែលជាអ្នកមានគំនិតខ្លះហើយ។
(ឆ)" ខ្ញុំនឹងសរសេរពាក្យគេង និងស្ត្រេសនៅលើផែនទីគំនិតរបស់យ

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ជំហានទី២ - ដំណោះស្រាយ

ក. សូមអានករណីសិក្សាខាងក្រោម។ សម្រេចចិត្តថាការពិពណ៌នាមួយណាតំណាងឱ្យការរៀនសូត្រដែលមានបញ្ហាតើការរៀនសូត្របែបសហការមួយនិងការរៀនសូត្របែបណាដែលសហការគ្នា៖

ករណីសិក្សា១

លោកនីវ័ត្នប្រគល់អត្ថបទស្តីពីការបែងចែកសំរាមនៅក្នុងថ្នាក់របស់គាត់ហើយសរសេរសំណួរចំនួនបីនៅលើក្តារ។ សិស្សគួរតែអានអត្ថបទដោយខ្លួនឯងជាមុនសិនហើយសរសេរពាក្យសំខាន់ៗ។ និស្សិតត្រូវបានគេសន្មត់ថាធ្វើការជាមួយគ្នាជាក្រុមដែលមានគ្នាបីនាក់ដើម្បីពិភាក្សាអត្ថបទនិងឆ្លើយសំនួរ។ លោកនីវ័ត្នដើរជុំវិញថ្នាក់ហើយផ្តល់ឱ្យក្រុមជួយនៅពេលដែលពួកគេត្រូវការ។ បន្ទាប់មកក្រុមទាំងអស់គួរតែបង្ហាញលទ្ធផល និងការរកឃើញរបស់ពួកគេនៅមុខថ្នាក់។ __**សិក្សាបែបសហប្រតិបត្តិការ**__

ករណីសិក្សា២

ថ្នាក់ទី ៤ បច្ចុប្បន្នកំពុងរៀនរូបមន្តសម្រាប់ផ្ទៃការ៉េនិងចតុកោណ។ លោកស្រី Munro បាននាំយកសម្ភារៈធ្វើដោយដៃផ្សេងៗរបស់និស្សិត (ឧទាហរណ៍ការបិទក្រដាសខ្សែអក្សរ) ហើយក្នុងក្រុមសិស្សបួននាក់ត្រូវបានស្នើឱ្យរចនាម៉ូដគំរូសរុបទាំងអស់នៃការ៉េនិងចតុកោណបួន។ បន្ទាប់មកគ្រូចង់បន្តធ្វើការជាមួយតួលេខទាំងនេះ។_____**ការសិក្សាផ្តោតលើបញ្ហា**_____

ករណីសិក្សា៣

សិស្សថ្នាក់ទី ២ មានការរំភើបយ៉ាងខ្លាំងនៅពេលដែលកញ្ញាវិចិណាផាតថាណាក៏ចូលថ្នាក់រៀនដោយមានប័ណ្ណប្រកាសនិងប៊ិច។ ថ្ងៃនេះនាងចាប់ផ្តើមមុខវិជ្ជាថ្មីមួយនៅក្នុងថ្នាក់ជីវវិទ្យាគឺសុខភាព។ នាងរុញតុជាមួយគ្នាហើយកុមារត្រូវបានគេសន្មត់ថាធ្វើការជាក្រុមបួនដើម្បីបង្កើតផែនទីគំនិតលើប្រធានបទសុខភាព។ពួកគេគួរតែសរសេរអ្វីគ្រប់យ៉ាងដែលពួកគេអាចគិតអំពីពាក្យសុខភាព។ តាមរយៈការងារបើកចំហនិស្សិតគួរតែកែលម្អនិងអភិវឌ្ឍជំនាញសង្គម (ឧទាហរណ៍ការប្រាស្រ័យទាក់ទង) បន្ថែមលើទិដ្ឋភាពដែលទាក់ទងនឹងខ្លឹមសារ។_____**ការសិក្សារួមគ្នា**_____

ក. ខាងក្រោមនេះអ្នកអាចឃើញបញ្ជីនៃសេចក្តីថ្លែងផ្សេងគ្នានៃឥរិយាបទគាំទ្រស្វ័យភាពរបស់គ្រូនិងអាកប្បកិរិយាគ្រប់គ្រងគ្រូ។ទាញ និងទម្លាក់ឧទាហរណ៍ទៅក្នុងប្រភេទសមស្របក្នុងតារាងខាងក្រោម៖

ខ្ញុំតែងតែប្រើបិចពណ៌ក្រហមដើម្បីកែកំហុសក្នុងអត្ថបទឬការធ្វើតេស្ត ១។ ខ្ញុំតែងតែប្រាប់សិស្សរបស់ខ្ញុំថាពួកគេអាចធ្វើការជាក្រុមរឺធ្វើដោយខ្លួនឯងបាន ២។ ខ្ញុំមានផែនការធ្វើការសម្រាប់រាល់សប្តាហ៍

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

និស្សិតអាចជ្រើសរើសនៅពេលដែលពួកគេចង់ធ្វើការងារណាមួយ។ ការបញ្ជាក់តែមួយគត់គឺថាអ្វីៗត្រូវធ្វើនៅថ្ងៃសុក្រទី ៣ ។ ខ្ញុំតែងតែសរសើរសិស្សរបស់ខ្ញុំនៅពេលដែលពួកគេដោះស្រាយបញ្ហាគណិតវិទ្យាទាំងអស់ដូចដែលពួកគេត្រូវបានប្រាប់៤។ មនុស្សបួននាក់ដោយខ្លួនឯង។ ៥ - ខ្ញុំប្រើពណ៌ផ្សេងៗគ្នាដើម្បីកែហើយមិនមែនពណ៌ក្រហមទេ។ - នៅពេលសរសេរខ្ញុំតែងតែប្រាប់សិស្សរបស់ខ្ញុំថាតើពួកគេត្រូវសរសេរប៉ុន្មាន ៧។៨ - នៅពេលនិយាយពីការងារជាគូ ខ្ញុំសូមរំលឹកសិស្សម្តងហើយម្តងទៀតថាពួកគេនឹងទទួលបានពិន្ទុលើការងាររបស់ពួកគេ។ ៩ ខ្ញុំសូមកោតសរសើរចំពោះការខិតខំរបស់សិស្សខ្ញុំហើយប្រាប់ពួកគេនៅពេលខ្ញុំគិតថាវាអស្ចារ្យ។ ឧទាហរណ៍ពួកគេបានគូសបញ្ជាក់ដំណោះស្រាយចំពោះបញ្ហាគណិតវិទ្យាដោយប៊ិចពណ៌និងបន្ទាត់មួយ ១០។ - ប្រសិនបើយើងមានពេលនៅសល់ប៉ុន្មាននាទីនៅក្នុងមេរៀនសិស្សរបស់ខ្ញុំអាចអានសៀវភៅដែលពួកគេបានជ្រើសរើស ១១។

ឥរិយាបថគាំទ្រស្វ័យភាព	ការគ្រប់គ្រងឥរិយាបថ
2	1
3	4
5	7
6	8
10	9
11	

ក. សម្របនិយមន័យនៃស្តង់ដារសហការពីផ្នាំងរូបភាពទៅជាឧទាហរណ៍ជាក់ស្តែងដែលត្រូវគ្នា។ ដើម្បីធ្វើដូចនេះ សូមភ្ជាប់ឧទាហរណ៍ដែលសមស្របជាមួយគ្នា៖

(១)ជួយសិស្សឱ្យស្វែងរកការយល់ដឹងជាមុន:
(២) ទុកពេលសម្រាប់ការគិត និងបង្កើនការសន្ទនាការពិភាក្សា និងការសម្រេចចិត្ត៖
(៣) អនុញ្ញាតឱ្យសិស្សស្តាប់និងស្វែងយល់ពីគ្នាទៅវិញទៅមក៖
(៤) បង្កើនភាពច្បាស់លាស់និងភាពជាក់លាក់នៃការគិតរបស់សិស្ស៖
(៥) បង្កើតការសន្ទនាប្រកបដោយអត្ថន័យ៖
(៦) ជួយសិស្សឱ្យដឹងថាតើពាក្យនិងសកម្មភាពរបស់ពួកគេមានឥទ្ធិពលយ៉ាងណាទៅលើក្រុម៖
(៧) ជម្រុញកិច្ចពិភាក្សាប្រកបដោយផលិតភាពនិងលុបបំបាត់ការអាក់អន់ចិត្តដោយអចេតនា៖

(ក)" ដូច្នេះអ្នកអាចនិយាយបានថាគុណភាពនៃការគេងជះឥទ្ធិពលដល់ការបំពេញការងាររបស់អ្នកនៅក្នុងជីវិតប្រចាំថ្ងៃហើយវាក៏ជះឥទ្ធិពលដល់ការយល់ឃើញនៃភាពតានតឹងរបស់អ្នកផងដែរ។ នោះជាទិដ្ឋភាពល្អ។

(ខ)" ខ្ញុំគិតថាលើសាចង់និយាយថាវាមិនអាស្រ័យលើប្រភេទកីឡា ដែលអ្នកធ្វើនោះទេប៉ុន្តែអ្នកពិតជាសកម្ម" ។
(គ) ខ្ញុំចង់ដឹងកាន់តែច្បាស់អំពីការគេងអាចជះឥទ្ធិពលដល់សុខភាពរបស់ខ្ញុំ។
(ឃ)" តើអ្នកយល់ព្រមទេប្រសិនបើយើងសរសេរកីឡានៅលើក្តារនោះ? តើការធ្វើលំហាត់ប្រាណអាចជះឥទ្ធិពលដល់សុខភាពរបស់ យើងយ៉ាងដូចម្តេច?
(ង)" តើអ្នកគិតថាការគេងប៉ះពាល់ដល់ការយល់ឃើញនៃភាពតានតឹងកម្រិតណា?"
(ច)" តើអ្នកគិតយ៉ាងណា?ខ្ញុំរង់ចាំបន្តិចដើម្បីទុកពេលគិតមុន។ ប្រហែលជាអ្នកមានគំនិតខ្លះហើយ។
(ឆ)" ខ្ញុំនឹងសរសេរពាក្យគេង និងស្ត្រេសនៅលើផែនទីគំនិតរបស់យើង"

១គ – ២ច – ៣ក – ៤ង – ៥ឆ – ៦ឃ – ៧ខ

ជំហានទី៣៖ កិច្ចការរៀបចំសំណុំឯកសារ –សំនួរបែបឆ្លុះបញ្ចាំងផ្ទាល់ខ្លួន

ចូរសរសេរចម្លើយបែបសំនេរនៃតែងសេចក្តីចំពោះសំនួរបែបឆ្លុះបញ្ចាំងផ្ទាល់ខ្លួនខាងក្រោម។ ចម្លើយបែបសំនេរតែងសេចក្តីនីមួយៗគួរតែមានប្រវែងចាប់ពី ៣០០ទៅ៥០០ពាក្យ ហើយឆ្លើយជា អត្ថបទដែលទាក់ទងគ្នាងាយស្រួលយល់ជាមួយនឹងប្រយោគពេញលេញ។ ចម្លើយបែបសំនេរតែង សេចក្តីទាំងនេះជាក់ចូលទៅក្នុងសំណុំឯកសារផ្ទាល់ខ្លួនរបស់អ្នក!

១. តើគ្រូម្នាក់អាចគាំទ្រសិស្សបានយ៉ាងដូចម្តេចដើម្បីជាបទពិសោធន៍ឆ្លងកាត់ការមានសិទ្ធិផ្ទាល់ខ្លួននៅពេលសិក្សា នៅសាលា ហើយនិងស្ថានភាពទាំងឡាយនៅក្នុងថ្នាក់រៀន?

ជំហានទី៤៖ កិច្ចការរៀបចំសំណុំឯកសារ – គំរោងការបង្រៀន

ចូរបង្កើតគំរោងបង្រៀនផ្ទាល់ខ្លួនរបស់អ្នក។ បង្កើតជាគ្រោងការណ៍មួយសំរាប់ការសិក្សាដែលផ្តែកលើគំរោងឬក៏ការសិក្សាតាមបែបសហការ នៅក្នុងថ្នាក់របស់អ្នកហើយ និងសម្រាប់ប្រធានបទរបស់អ្នកដែលបានជ្រើសរើសនៅក្នុងម៉ូឌុល១.១។ កិច្ចការរៀបចំសំណុំឯកសារនេះគួរតែមានប្រវែងប្រហែលចាប់ពី ៨០០ទៅ១០០០ពាក្យ។ គំរោងការបង្រៀនជាក់ចូលទៅក្នុងសំណុំឯកសារផ្ទាល់ខ្លួនរបស់អ្នក!ចូរពិចារណាដល់សំនួរខាងក្រោមនេះ តើអ្នកត្រូវតែពិចារណាដល់ទិដ្ឋភាពណាខ្លះសំរាប់ទម្រង់នៃការបង្រៀននេះ? វិធីសាស្ត្រណាខ្លះអាចជួយជាប្រយោជន៍? តើអ្នកត្រូវសំរេចចិត្តរៀបចំបែបណាខ្លះ? តើអ្នកមានពេលវេលាប៉ុន្មាននៅក្នុងដៃ?

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

អ្នកអប់រំដែលជោគជ័យត្រូវចេះពីវិធីប្រើប្រាស់ធាតុសំខាន់ៗនៃការបង្រៀនដែលមានគុណភាពខ្ពស់សម្រាប់ថ្នាក់រៀនរបស់ខ្លួន។. ក្នុងម៉ូឌុលនេះ បង្ហាញពីមូលដ្ឋានមួយចំនួនសម្រាប់ការអនុវត្តការបង្រៀនប្រកបដោយប្រសិទ្ធភាព ដើម្បីធានាថាសមាសភាពសំខាន់នៃការបង្រៀននៅកម្រិតបឋមសិក្សាត្រូវបានពិចារណានៅពេលធ្វើផែនការបង្រៀន អនុវត្តការបង្រៀន វាយតម្លៃដំណើរការបង្រៀន និងរៀន។ តាមរយៈប្រធានបទផ្សេងៗ រួមបញ្ចូលការបង្រៀន និងរៀនសតវត្សទី២១ ការធ្វើកិច្ចតែងការបង្រៀន និងបរិស្ថានសិក្សា អ្នកនឹងតម្រូវឱ្យធ្វើការឆ្លុះបញ្ចាំងពីដំណើរការបង្រៀន និងរៀនដើម្បីសម្រេចលទ្ធផលសិក្សាដោយជោគជ័យ។

សូមសិក្សាដោយរីករាយ!

CONTESSA
Contemporary Teaching Skills for South Asia
Co-funded by the Erasmus+ Programme of the European Union

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ម៉ូឌុល ៤

ការរួមបញ្ចូលភាពខុសគ្នា៖ គោលវិធីគរុកោសល្យសម្រាប់ភាពចម្រុះគ្នា ភាពមិនស្មើគ្នា និងតម្រូវការពិសេស

៤.១ គរុកោសល្យបរិយាបន្ន៖ គោលវិធី និងយុទ្ធសាស្ត្រ

Co-funded by the
Erasmus+ Programme
of the European Union

ការរួមបញ្ចូលភាពខុសគ្នា-គោលវិធីគរុកោសល្យសម្រាប់ភាពចម្រុះគ្នា ភាពមិនស្មើគ្នា និងតម្រូវការពិសេស៖ គរុកោសល្យបរិយាបន្ន-គោលវិធី និងយុទ្ធសាស្ត្រ

មេរៀននេះត្រូវបានបង្កើតឡើងដោយដៃគូសហការនៅក្នុងគម្រោងនៅ វិធីសាស្ត្របង្រៀនសម័យថ្មីនៅអាស៊ីខាងត្បូង (Contemporary Teaching Skill for South Asia) ហៅកាត់ថា CONTESSA ក្រោមការចូលរួមឧបត្ថម្ភថវិកាដោយកម្មវិធី Eramus+ នៃសហភាពអឺរ៉ុបដែលមានលេខគម្រោង598756-EPP-1-2018-1-AT-EPPKKA2-CBHE-JP-/CONTESSA

អ្នកសម្របសម្រួល :

Sandra Hummel, សាកលវិទ្យាល័យហ្គ្រាស UNIVERSITY OF GRAZ (អូទ្រីស)

ក្រោមការចូលរួមសហការពី :

សាកលវិទ្យាល័យបច្ចេកវិទ្យា ជ្រៃសឺល (អាល្លឺម៉ង់)

សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា (កម្ពុជា)

សាកលវិទ្យាល័យកម្ពុជា (កម្ពុជា)

សាកលវិទ្យាល័យអូអកេននៃប្រទេសស្រីលង្កា (ស្រីលង្កា)

សាកលវិទ្យាល័យយូកំឡូប (ស្រីលង្កា)

អ្នកនិពន្ធ: Regina Elias, Sandra Hummel, Mirjam Brodacz-Geier, Bridget Sheehan

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

សេចក្តីប្រកាស

គណៈកម្មការអឺរ៉ុបសូមធ្វើការគាំទ្រដល់ការបោះពុម្ពឯកសារនេះ ដែលមិនមែនឆ្លុះបញ្ចាំងតែពីទស្សនៈរបស់អ្នកនិពន្ធខាងលើទេ ហើយយើងក៏មិនទទួលខុសត្រូវចំពោះការប្រើប្រាស់ព័ត៌មានដែលដកស្រង់ចេញពីការបោះពុម្ពនេះដោយប្រការណាមួយដែរ។ ព័ត៌មានលម្អិតបន្ថែមនៃមេរៀននេះអាចរកបានដោយបើកចំហ និងឥតគិតថ្លៃនៅលើគេហទំព័រ CONTESSA :

https://contessa_project.eu/

រក្សាសិទ្ធិ

មេរៀននេះត្រូវបានផ្តល់អាជ្ញាប័ណ្ណឱ្យប្រើប្រាស់ក្រោមលក្ខខណ្ឌនៃ Creative Commons

Attribution_ShareAlike 4.0 Internatinal License

(https://creativecommons.org(licenses/by_sa/4.0/)

ដែលអនុញ្ញាតឱ្យប្រើប្រាស់ ចែករំលែក សម្របសម្រួលដើម្បីប្រើប្រាស់បន្ត ចែកចាយផលិតផលសារជាថ្មី ក្នុងទ្រង់ទ្រាយណាមួយ ដរាបណាអ្នកប្រើប្រាស់ផ្តល់កិត្តិយសឱ្យបានសមរម្យដល់អ្នកនិពន្ធទាំងអស់។ សូមផ្តល់ជាតំណភ្ជាប់ (link) ទៅកាន់ Creative Commons License និងសូមបញ្ជាក់ផងដែរ បើមានការផ្លាស់ប្តូរណាមួយ។ ប្រសិនបើអ្នកបញ្ចូលគំនិតកែសម្រួល ឬបន្ថែមអត្ថន័យលើមេរៀននេះអ្នកត្រូវតែធ្វើការសុំសិទ្ធិកែសម្រួលឯកសារតាមលក្ខខណ្ឌខាងលើ។ រូបភាព ខ្សែសំឡេង វីដេអូ ក៏ដូចជាឯកសារដទៃទៀតដែលមាននៅក្នុងមេរៀនទាំងនេះមិនត្រូវបានបូកបញ្ចូលទៅក្នុងឯកសារអាជ្ញាប័ណ្ណ Creative Commons ទេ លើកលែងតែមានការអនុញ្ញាតឱ្យប្រើប្រាស់។ ប្រសិនបើផ្នែកណាមួយនៃមេរៀននេះមិនត្រូវបានបញ្ចូលទៅក្នុងឯកសារអាជ្ញាប័ណ្ណ ហើយការប្រើប្រាស់មិនត្រូវបានអនុញ្ញាតដោយច្បាប់ ឬក៏ប្រើប្រាស់លើសពីច្បាប់អនុញ្ញាត ត្រូវតែសុំការអនុញ្ញាតដោយផ្ទាល់ពីម្ចាស់កម្មសិទ្ធិ។

CC BY SA

សេចក្តីផ្តើម

តើវគ្គសិក្សា CONTESSA គឺជាអ្វី?

វគ្គសិក្សា CONTESSA គឺជាលទ្ធផលមួយក្នុងចំណោមលទ្ធផលនៃគម្រោង ដែលស្តីអំពី "ជំនាញក្នុងការបង្រៀន សម័យថ្មីសម្រាប់អាស៊ីខាងត្បូង" ដែលផ្តល់មូលនិធិរួម ដោយកម្មវិធី Erasmus+ Program នៃសហភាពអឺរ៉ុប។ គោលបំណងរបស់វគ្គសិក្សានេះគឺដើម្បីជាការរួមចំណែកក្នុងការបង្កើតកម្មវិធីអប់រំគ្រូបង្រៀនដោយជោគជ័យ សម្រាប់គ្រូបឋមសិក្សា ជាពិសេសក្នុងប្រទេសកម្ពុជានិង ស្រីលង្កា។ វានឹងនាំដល់ការបង្កើតបាននូវផែលវិជ្ជមាន ដែលមានរយៈពេលវែងឆ្ងាយទៅលើប្រព័ន្ធអប់រំទូទៅ។ វាមានសារៈសំខាន់កាន់តែខ្លាំងឡើងសម្រាប់អ្នកអប់រំ ដែលជោគជ័យក្នុងការតាមឱ្យទាន់សម័យជាមួយនឹងជំនាញ និងវិធីសាស្ត្រក្នុងសម័យថ្មី ដើម្បីយកមក ប្រើទាំងក្នុង និងក្រៅថ្នាក់រៀន។ ដូច្នេះវគ្គសិក្សា CONTESSA ផ្តល់ជូនមេរៀនដែលត្រូវបានជ្រើសរើសដោយប្រុងប្រយ័ត្នចំនួន៥ម៉ូឌុល។ ម៉ូឌុលនីមួយៗមានការផ្តល់ការយកចិត្តទុកដាក់ទៅលើចំណុចចំនួនបី ដើម្បីតម្រង់ទៅរកការអភិវឌ្ឍលើជំនាញបង្រៀនបែបសម័យថ្មី។ ម៉ូឌុលទាំងឡាយ និងការផ្តោតការយកចិត្ត ទុកដាក់ របស់វាមានដូចខាងក្រោម៖

ម៉ូឌុល១៖ ការកសាងការយល់ដឹងអំពីការអប់រំនៅបឋមសិក្សា

១. ការបង្រៀន និងការរៀននៅសតវត្សទី២១

២.ការរៀបចំកិច្ចតែងការបង្រៀន និងជំនាញគរុកោសល្យផ្អែកលើ គំនិត ឧបករណ៍ និងការអនុវត្ត

៣. ការរៀបចំបរិយាកាសសិក្សា

ម៉ូឌុល២៖ ភាពអស្ចារ្យក្នុងការបង្រៀន៖ សមត្ថភាពជាក់លាក់ប្រកបទៅដោយវិជ្ជាជីវៈរបស់គ្រូបង្រៀននៅបឋមសិក្សា

១. ការយល់ដឹងពីការបង្រៀនផ្អែកលើ តួនាទី កិច្ចការ និង មុខងារ

២. ការវាយតម្លៃទៅលើលទ្ធផលនៃការសិក្សាសិស្ស

៣. ជំនាញវិជ្ជាជីវៈគរុកោសល្យ

ម៉ូឌុល៣៖ ការអប់រំឈានមុខគេបែបវិធីសាស្ត្រសិស្សមជ្ឈមណ្ឌល៖ ការលើកម្ពស់ដំណើរការសិក្សាដែលបានបង្កើតរួមគ្នា

១. ការអភិវឌ្ឍលក្ខណៈបុគ្គល និងជំនាញដោះស្រាយបញ្ហា

២. ការអះអាងពីពិភពជីវិតជាក់ស្តែង និងក្តីសង្ឃឹមទៅអនាគត

៣. ការប្តេជ្ញាចិត្តដោយខ្លួនឯង ការផ្តល់សិទ្ធិអំណាច និងប្រសិទ្ធិភាពផ្ទាល់ខ្លួន

ម៉ូឌុល៤៖ ការរួមបញ្ចូលភាពខុសគ្នា៖ គោលវិធីគរុកោសល្យសម្រាប់ភាពចម្រុះគ្នា ភាពមិនស្មើគ្នា និងតម្រូវការពិសេសរបស់សិស្ស

១. គរុកោសល្យបរិយាបន្ន៖ គោលវិធី និងយុទ្ធសាស្ត្រ

២. ការបង្រៀន និងការរៀនក្នុងភាពចម្រុះគ្នា៖ ការរៀបចំ ការយល់ដឹង ការវាយតម្លៃ

៣. ការគ្រប់គ្រងថ្នាក់រៀនដែលមានភាពចម្រុះគ្នា

ម៉ូឌុល៥៖ ការបង្រៀន និងការរៀនតាមបែបឌីជីថល

១. គរុកោសល្យនៃការសិក្សាពីចម្ងាយ និងបរិយាកាសសិក្សា ដែលបំពាក់ទៅដោយបច្ចេកវិទ្យា

២. ប្រព័ន្ធផ្សព្វផ្សាយ និងបច្ចេកទេសឌីជីថល៖ ឧបករណ៍ និងទម្រង់សម្រាប់គោលបំណងការអប់រំ

៣. ការរៀបចំមេរៀន និងដំណើរការបង្រៀនតាមអ៊ិនធឺណែតនៅពេល ដែលបញ្ចប់វគ្គសិក្សានេះ អ្នកចូលរួមនឹងអាចអនុវត្តជំនាញបង្រៀនសម័យថ្មី ដែលទើបទទួលបានធ្វើឲ្យសិស្សទាំងអស់អាចចូលរួមសកម្មភាពក្នុងថ្នាក់ និងរៀនពីវិធីថ្មីៗ ដើម្បីជួយឱ្យសិស្សឈានទៅដល់ចំណុចសក្តានុពលពេញលេញរបស់ពួកគេ។

CONTESSA Contemporary Teaching Skills for South Asia
Co-funded by the Erasmus+ Programme of the European Union

តើវគ្គសិក្សា CONTESSA សម្រាប់អ្នកណា?

គម្រោងស្តីពីជំនាញក្នុងការបង្រៀនសម័យថ្មីសម្រាប់អាស៊ីខាងត្បូងមានបំណងក្នុងការលើកតម្កើងជំនាញបង្រៀន សម័យថ្មីសម្រាប់គរុនិស្សិត និងគ្រូបង្រៀនដែល កំពុងបម្រើការក្នុងសាលាបឋមសិក្សានានា។ ឯកសារខាងក្រោមត្រូវបានសម្របសម្រួលជា ពិសេសសម្រាប់គរុនិស្សិត។

លើសពីនេះទៅទៀត វគ្គសិក្សា CONTESSA ក៏សម្រាប់អ្នកដែលចាប់អារម្មណ៍ក្នុងការធ្វើខ្លួនឱ្យទាន់សម័យកាលជាមួយ និងជំនាញបង្រៀនសម័យថ្មី។

ឯកសារមានជាភាសាអង់គ្លេស ហើយក៏មាន ជាភាសាខ្មែរ ភាសាសិង្ហាលា (Sinhala) និងភាសាតាមីល (Tamil) ដែលប្រើប្រាស់នៅប្រទេសស្រីលង្កា។

តើរចនាសម្ព័ន្ធនៃវគ្គសិក្សា CONTESSA មានអ្វីខ្លះ?

ដូចដែលបានលើកឡើងពីមុនរួមហើយ វគ្គសិក្សា CONTESSA នេះរួមមាន៥ម៉ូឌុល ដែលម៉ូឌុលនីមួយៗមានតម្លៃស្មើនឹង៣ក្រេឌីតតាមប្រព័ន្ធផ្ទេរការសិក្សារបស់អឺរ៉ុប។ ជាការល្អ ម៉ូឌុលទាំងនេះត្រូវបានប្រើប្រាស់រួមគ្នា ព្រោះម៉ូឌុលនីមួយៗ យោងឯកសារលើម៉ូឌុលដទៃទៀត។ ប៉ុន្តែក្នុងមេរៀនម៉ូឌុលទាំងនេះក៏ត្រូវបានបង្កើតឡើងក្នុងវិធីមួយដែលអាចប្រើបានដោយខ្លួនឯងផ្ទាល់ផងដែរ។

ម៉ូឌុលនីមួយៗមានការផ្តោតលើប្រធានបទចំនួនបី ហើយឯកសារទាំងឡាយក៏បង្កើតឡើងសម្រាប់ការ-ផ្តោតនីមួយៗផងដែរ។ វាបង្កើតឱ្យមានឯកសារសរុបចំនួន ១៥ផ្នែកសម្រាប់វគ្គសិក្សា CONTESSA ។

ឯកសារនីមួយៗរួមមានសេចក្តីផ្តើមបែបទ្រឹស្តីចំពោះចំណុចផ្តើម ហើយតាមពីក្រោយដោយលំហាត់អនុវត្តដោយផ្អែកលើទ្រឹស្តី។

ជំហាន១ – ទ្រឹស្តី គឺជាការរំឭក នូវអ្វីដែលបានអាននៅក្នុងសេចក្តីផ្តើមនៃទ្រឹស្តីលំហាត់ អនុវត្តទាំងនេះ ត្រួតពិនិត្យការយល់ដឹង នៃអត្ថបទ ដើម្បី ប្រាកដថាទ្រឹស្តីជាមូលដ្ឋានដែលត្រូវបានយល់ដឹង។

ជំហាន២ – បទពិសោធ – ផ្តល់ជូននូវ ឧទាហរណ៍របស់គ្រូបង្រៀនពិតប្រាកដ និងពីវិធី ដែល ពួកគាត់អនុវត្តទ្រឹស្តីផ្សារភ្ជាប់ នឹងការអនុវត្ត ជាក់ស្តែង។ ឧទាហរណ៍ទាំងនេះ បានភ្ជាប់ លំហាត់ អនុវត្តទៅនឹងទ្រឹស្តីដែលបានរៀន ពីមុនរួចហើយ។

ជំហាន៣ – ការឆ្លុះបញ្ចាំងដោយខ្លួនឯងផ្ទាល់ – រាប់បញ្ចូលសំណួរបែបឆ្លុះបញ្ចាំង ដោយផ្អែក ទៅលើចំណុចផ្តោតនីមួយៗ។

ជំហាន៤ – ការអនុវត្ត – គឺជាជំហានចុងក្រោយដែលមានគម្រោងគោល នៃការ បង្រៀនមួយត្រូវបានបង្កើតឡើងផ្អែកទៅលើអ្វីដែល បានប្រទះឃើញពីមុននៅក្នុងជំហានទី១ និងទី២។

លំហាត់អនុវត្តនៅក្នុងជំហានទី១ និងទី២អាចត្រូវបានបំពេញដោយផ្ទាល់ក្នុងឯកសារនេះ។ ជំហានទី៣ និងទី៤ ជាផ្នែក នៃឯកសារដែលរៀបជាសំណុំដាច់ដោយឡែក ដែលនឹងត្រូវបង្កើតដោយបុគ្គលម្នាក់ៗគំរូសម្រាប់ការរៀបចំសំណុំឯកសារ (portfolio) មានជា ឯកសារ ដាច់ដោយឡែកពីគ្នា។

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

មាតិកា

១. គោលវិធីសម្រាប់គរុកោសល្យបរិយាបន្ន 1

១.១ តម្រូវការអប់រំពិសេស (Special Educational Need, SEN) 2

១.២ សាលារៀនអប់រំពិសេស ការបញ្ជ្រាប និងបរិយាបន្ន 6

១.៣ ការរៀបចំជាសាកលសម្រាប់ការសិក្សា (UDL) 9

២.ស្ថានភាពនៅក្នុងប្រទេសកម្ពុជា 12

៣. ស្ថានភាពនៅក្នុងប្រទេសស្រីលង្កា 12

៤. យុទ្ធសាស្ត្រសម្រាប់គរុកោសល្យបរិយាបន្ន 13

៤.១ សិក្សាពីសិស្សរបស់អ្នក 13

៤.២ ជំរុញប្រសិទ្ធភាពខ្លួនឯងបែបវិជ្ជមាន 14

៤.៣ ការពិចារណាពីភាពខុសគ្នាខាងវប្បធម៌ និងប្រពៃណីក្នុង តំបន់ 15

៤.៤ ការជ្រើសរើសសកម្មភាពដែលមានអត្ថន័យ 16

៤.៥ ការធ្វើជាគំរូនៃភាពចម្រុះគ្នា 17

៤.៦ ការបញ្ចូលគ្រួសាររបស់សិស្ស 19

៥. ចំណុចគន្លឹះ 20

៦. ឯកសារពិគ្រោះ 22

ជំហានទី១. លំហាត់អនុវត្ត 25

ជំហានទី១. ដំណោះស្រាយ 33

ជំហានទី២៖ លំហាត់អនុវត្ត 41

ជំហានទី២៖ ចម្លើយលំហាត់អនុវត្ត 43

ជំហានទី៣៖ ការរៀបចំសំណុំឯកសារ –សំណួរឆ្លុះបញ្ចាំងផ្ទាល់ខ្លួន 46

ជំហានទី៤៖ ការរៀបចំសំណុំឯកសារ – គម្រោងការបង្រៀន 46

កំណត់ត្រាពីសំឡេង៖ Audio File 4.1.1 47

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

កំណត់ត្រាពីសំឡេងៈ Video File 4.1.1 47

១. គោលវិធីសម្រាប់ការរុករកសិក្សាបរិយាបន្ន

គោលការណ៍គ្រឹះនៃសាលារៀនបរិយាបន្នគឺ សិស្សទាំងអស់ត្រូវទទួលបានការសិក្សាជាមួយគ្នានៅគ្រប់ទីកន្លែង ដោយមិនគិតពីការលំបាក ឬភាពខុសគ្នា ដែលពួកគេមាននោះឡើយ។ សាលារៀនបរិយាបន្នត្រូវតែ ទទួលស្គាល់ និងឆ្លើយតបចំពោះតម្រូវការផ្សេង ពីគ្នារបស់សិស្សដោយផ្តល់ទាំង របៀបរៀន និងល្បឿនរៀនប្លែកៗពីគ្នា និងការធានាគុណភាពអប់រំដល់សិស្សទាំងអស់គ្នាតាមរយៈកម្មវិធីសិក្សាត្រឹមត្រូវ។ ការរៀបចំរចនាសម្ព័ន្ធ យុទ្ធសាស្ត្របង្រៀន ធនធានសមស្របនានា និងភាពជាដៃគូល្អជាមួយសហគមន៍។ (UNESCO, 1994)នៅក្នុងសង្គមរបស់យើង ក៍ដូចជានៅក្នុងសាលារៀនដែរ គឺមានភាពខុសៗគ្នាចម្រុះគ្នាជាច្រើន។ ដើម្បីបំពេញតម្រូវការនៃភាពខុសៗគ្នារបស់សិស្ស គ្រូបង្រៀនចាំបាច់ត្រូវផ្តល់ឱកាសសិក្សាពាក់ព័ន្ធ និងរៀបចំឱ្យមានបទពិសោធជាក់ស្តែងស្របតាមតម្រូវការទាំងនេះ។ ពណ៌សម្បុរ ជនជាតិ ពិការភាព ខាងផ្លូវកាយ និងផ្លូវចិត្ត ភេទ អាយុ គឺជាការបែងចែកក្រុមក្នុងសង្គមមួយចំនួនដែល ជីវិតក្នុងការសិក្សាប្រចាំថ្ងៃអាចនាំឱ្យមានវិសមភាព ឬការរើសអើង។ ដើម្បីយកឈ្នះលើការអនុវត្តបែបមិនស្មើគ្នាក្នុងប្រព័ន្ធសាលារៀន អ្នកពាក់ព័ន្ធរួមទាំងគ្រូ និងសិស្សចាំបាច់ ត្រូវទទួលស្គាល់គ្រប់យ៉ាងចំពោះភាពខុសគ្នារបស់ ពួកគេទៅវិញទៅមកដោយការបង្ហាញពីទស្សនៈទាក់ទងនឹងប្រក្រតីភាព និងការអនុវត្តក្នុងការប្រាស្រ័យទាក់ទងគ្នាដោយការគោរព។ (Stainback & Smith, 2005)

ភាពចម្រុះគ្នា៖
គឺជាភាពខុសគ្នាក្នុងចំណោមក្រុមមនុស្ស និងបុគ្គលម្នាក់ៗ ដោយអាស្រ័យលើជនជាតិ ពូជសាសន៍ ស្ថានភាពសង្គមសេដ្ឋកិច្ច ភេទ ការគិត ភាសា សាសនា អត្តសញ្ញាណ ភេទ ហើយនិងតំបន់ភូមិសាស្ត្រ។ (NCATE, 2008, p. 3)

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia



រូប១. កង់នៃភាពចម្រុះ

១.១ តម្រូវការអប់រំពិសេស (Special Educational Need, SEN)

សិស្សម្នាក់ៗ អាចប្រឈមនឹងការពិបាកនៅចំណុចណាមួយ ក្នុងបទពិសោធ សិក្សារបស់គេ។ កាតព្វកិច្ចរបស់គ្រូ គឺជួយគាំទ្រនិងជំរុញសិស្សឱ្យយកឈ្នះលើការលំបាកទាំងនេះ។ ទោះជាយ៉ាងនេះក្តី សម្រាប់សិស្សដែលមានតម្រូវការអប់រំពិសេស មានន័យថាពួកគេត្រូវការការគាំទ្របន្ថែម ឬក៏ទម្រង់ការគាំទ្រប្លែកពីសិស្សដទៃដែលមានអាយុដំណាលគ្នា ឬរៀននៅថ្នាក់ជាមួយគ្នា។ តម្រូវការអប់រំពិសេស(SEN) ជាពាក្យដែលពណ៌នាពីការលំបាកនៃការសិក្សា ភាពខុសប្លែកគ្នា ឬ ភាពអសមត្ថភាព ធ្វើឱ្យការសិក្សា រឹតតែលំបាកសម្រាប់សិស្សមួយចំនួន។ ច្បាប់ស្តីពីការអប់រំដ៏នពិការ (Individuals with Disabilities Education Act, IDEA)បានបែងចែកប្រភេទនៃតម្រូវការអប់រំពិសេសមានដូចជា៖"ពិការភាពខាងបញ្ញាស្មារតី ការចុះខ្សោយខាងការស្តាប់(រាប់បញ្ចូលពិការត្រចៀក) ការចុះខ្សោយខាងការនិយាយ ការចុះខ្សោយខាងគំហើញ(រាប់បញ្ចូលពិការភ្នែក) ការរំខានខាងផ្លូវអារម្មណ៍យ៉ាងធ្ងន់ធ្ងរ[...]ការចុះខ្សោយឆ្អឹង អូទីហ្សឹម របួសសរសៃឈាមក្នុងខួរក្បាល ពិការភាពផ្នែកសិក្សាជាក់លាក់ណាមួយ អាចជាគថ្លង់-ខ្វាក់ ឬពិការភាពផ្នែកផ្សេងទៀត (Section 300.8 (a) (1))។

កង់ភាពចម្រុះគ្នា[7]
ក្រុមដែលចេញពីទិដ្ឋភាពខាងក្នុងគឺមានជាប់ជាមួយខ្លួនពីកំណើតដែលជាមូលហេតុក្រុមនេះមិនអាចផ្លាស់ប្តូរបានឬបើបានក៏ដោយមានភាពលំបាកដែរ។ ក្រុមដែលចេញពីទិដ្ឋភាពខាងក្រៅអាចផ្លាស់ប្តូរបានដោយបុគ្គលម្នាក់ៗផ្ទាល់ឬក៏បានដោយការទំនាក់ទំនងជាមួយនឹងបរិយាកាសរបស់បុគ្គលម្នាក់ៗ។

[7] Adapted from Gardenswartz & Rowe (online).

ពិការភាពទាំងនេះប៉ះពាល់ដល់ដំណើរការរៀនសូត្ររបស់កុមារ។ ជាលទ្ធផលកុមារត្រូវការឧបករណ៍ជំនួយនៃការសិក្សាប្រភេទខុសៗគ្នា។

- **ពិការភាពបញ្ញាស្មារតី**

  ជាភាពមិនប្រក្រតី ដែលកើតឡើងមុនពេលពេញវ័យ។ គេកំណត់បានដោយការចុះខ្សោយខ្លាំងលើមុខងាររបស់ពុទ្ធិបញ្ញា និងការចុះខ្សោយទង្វើសម្របខ្លួនចំនួនពីរ ឬច្រើនជាងនេះ(ដូចជាការជួយខ្លួនឯង ការប្រាស្រ័យទាក់ទងគ្នា ឬក៏ជំនាញទាក់ទងអន្តរបុគ្គល) (Boundless.com Textbooks *Learning Disabilities and Special Education*, online) ។

- **ពិការភាពការស្តាប់**

  សំដៅទៅលើសិស្ស ដែលខូចប្រព័ន្ធការស្តាប់ឮ។ នៅពេលដែលកុមារម្នាក់មានពិការភាពធ្ងន់ធ្ងរខ្លាំងគេមិនអាចទទួលយក "ព័ត៌មានផ្សេងៗតាមរយៈការស្តាប់ទោះជាមានឬក៏គ្មានឧបករណ៍បំពងសំឡេងក៏ដោយ " (IDEA, Section 300.8 (c) (3)) ។

- **ការចុះខ្សោយខាងការនិយាយ/ភាសា**

  សំដៅលើសិស្ស ដែលមានភាពមិនប្រក្រតី ខាងការទំនាក់ទំនង(ឧទាហរណ៍ ដូចជានិយាយឮតិចទៅៗ ឬសំឡេងងងយចុះបន្តិចម្តងៗ)។ (IDEA, 300.8 (c) (11))

- **ការចុះខ្សោយគំហើញ(រាប់បញ្ចូលទាំងពិការភ្នែក)**

  សំដៅលើសិស្ស ដែលការមើលឃើញរបស់គាត់មានបញ្ហា។ (IDEA, 300.8 (c) (13))

- **ភាពរំខានអារម្មណ៍**

  ជាជំងឺផ្លង់អារម្មណ៍ ដែលការយកចិត្តទុកដាក់បានធ្លាក់ចុះ(ADHD)។ គេសម្គាល់បានតាមរយៈការលំបាកក្នុងការផ្តោតការយកចិត្តទុកដាក់ និងការគ្រប់គ្រងស្ថានភាពចិត្ត។ សិស្សដែលមានជំងឺ ADHD អាចនឹងមានបញ្ហាទាក់ទងនឹងកន្លែងអង្គុយ និងមេរៀនដែលត្រូវរៀន ឬការបែកអារម្មណ៍ ដែលជាឧបសគ្គក្នុងការរៀនបានពេញលេញនិងការយល់មេរៀនបានល្អ (Boundless.com*Learning Disabilities and Special Education*, online)។

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

- **ការចុះខ្សោយខាងឆ្អឹង**

  សំដៅលើសិស្ស ដែលមានឆ្អឹងចុះខ្សោយធ្ងន់ធ្ងរ ឬពិការភាពសាច់ដុំដែលជះឥទ្ធិពលអាក្រក់ដល់ការសិក្សា។ (IDEA, 300.8 (c) (8))

- **ជំងឺអូទីហ្សឹម (Autism spectrum disorder, ASD)**

  ជាភាពមិនប្រក្រតីនៃប្រព័ន្ធប្រសាទ ធ្វើឱ្យមានបញ្ហាក្នុងការប្រើប្រាសភាសា និងទំនាក់ទំនងសង្គម[...]។ ការលំបាកផ្នែកភាសាដែលបណ្តាលមកពីជំងឺ ASD(អូទីហ្សឹម)ជួនកាលវាធ្វើឱ្យកុមារមានការលំបាកក្នុងការទាក់ទងជាមួយគ្រូមិត្តភក្តិក្នុងថ្នាក់រៀន។ ការខ្វះទំនាក់ទំនងក្នុងសង្គម អាចរំខានក្នុងការចងមិត្តភាព ហើយ ទង្វើច្រំដែលៗ អាចរំខានដល់សកម្មភាពប្រចាំថ្ងៃរបស់កុមារ។ ទោះបីជាសិស្សភាគច្រើនដែលមានជំងឺ ASDបង្ហាញនូវភាពឆ្លាតវៃធម្មតា តែពួកគេអាចនឹងត្រូវការការគាំទ្រជាពិសេស តាមរយៈរោគសញ្ញានៃជំងឺនេះ។[1]

ខាងក្រោមនេះជាឧទាហរណ៍មួយចំនួនស្តីពីពិការសិក្សាជាក់លាក់៖

Dyslexia ជាជំងឺឬបញ្ហាខាងការអាន និងការសរសេរមិនបានត្រឹមត្រូវ ទោះបីជាមានសតិបញ្ញាធម្មតាក៏ដោយ។ ជំងឺនេះរួមមានការលំបាកក្នុងការស្គាល់សូរ ការកំណត់សូរ ល្បឿនរបស់សូរ ការចងចាំសំឡេងរយៈពេលខ្លី និង ការយល់ដឹងពីពាក្យសម្តី។ Dyslexia ត្រូវបានទទួលស្គាល់ជាទូទៅថា ជាជំងឺនៃការអាន។ ទោះជាយ៉ាងនេះក្តី មិនមែនរាល់ជំងឺដែលពាក់ព័ន្ធនឹងការអានទាំងអស់សុទ្ធតែជា
Dyslexia នោះទេ។

ពាក្យថា "Dysgraphia" ត្រូវបានប្រើជាញឹកញាប់ទៅលើអ្នកដែលមានបញ្ហាទាក់ទងនឹងការសរសេរ។ បុគ្គលដែលមានបញ្ហា Dysgraphia ជាធម្មតាបង្ហាញនូវការខ្វះខាតដែលទាក់ទងនឹងការសរសេរ។ ដូចជាករណី កំហុសផ្នែកវេយ្យករណ៍ ឬវណ្ណយុត្តិនៅក្នុងប្រយោគ។ ការរៀបចំកថាខណ្ឌនៅមានកម្រិត កំហុសឆ្គងក្នុងការប្រកបពាក្យ និងមានកំហុសជាច្រើនក្នុងការសរសេរអក្ស[2]។ Dysgraphia ជាទម្រង់នៃភាពទន់ខ្សោយខាងគណិតវិទ្យា ដែល

[1] Taken from Boundless.com Textbooks *Learning Disabilities and Special Education* (n.d., online). CC BY-SA 4.0. Changes made to all CC BY texts used in this document are indicated in italics or square brackets.

[2] Taken from Boundless.com Textbooks *Specific Learning Disorder* (n.d., online). CC BY-SA 4.0.

ទាក់ទងនឹងកំណត់បញ្ញត្តិដូចជា បរិមាណ តម្លៃលេខ វិធីគុណ និងការទន្ទេញវិធានគណិតវិទ្យាជាដើម។ Dyscalculics គឺសំដៅលើការចងចាំលេខមិនបានល្អ ។

- **របួសសរសៃប្រសាទក្នុងខួរក្បាល**

  សំដៅលើសិស្ស ដែលបានរងរបួសខួរក្បាលបណ្តាលឱ្យ "មានពិការភាពមុខងារណាមួយឬ ពិការភាពមុខងារទាំងអស់ ឬអាចជាការចុះខ្សោយខាងចិត្តសាស្ត្រសង្គម ឬក៏អាចមានបញ្ហាទាំងពីរប្រភេទ" (IDEA, 300.8 (c) (12)) ។

- **ការចុះខ្សោយសុខភាពផ្នែកដទៃៗទៀត**

  សំដៅដល់ការចុះខ្សោយដែលប៉ះពាល់ដល់ "កម្លាំង ភាពភ្លៀវភ្លា ការប្រុងប្រយ័ត្ន ដោយរាប់បញ្ចូលទាំងភាពវាងវៃកម្រិតខ្ពស់ ដែលមានប្រតិកម្មនឹងបរិស្ថានជុំវិញ" (IDEA, 300.8 (c) (9))។

- **ពិការភាពភ្នែក-ត្រចៀក**

  ជាការផ្សំបញ្ចូលគ្នារវាងការចុះខ្សោយខាងការស្តាប់ឮ និងការមើលឃើញ។ "ការរួមបញ្ចូលគ្នានេះបណ្តាលឱ្យមានបញ្ហាធ្ងន់ធ្ងរផ្នែកទំនាក់ទំនង និងតម្រូវការលើការអភិវឌ្ឍដទៃទៀត" (IDEA, 300.8 (c) (2))។ អសមត្ថភាពផ្សេងទៀត ជាការរួមបញ្ចូលគ្នានៃការចុះខ្សោយច្រើនយ៉ាងទាំងនេះនឹងប៉ះពាល់ដល់ដំណើរការរៀនសូត្រ របស់កុមារ (IDEA, 300.8 (c) (7))។

រូបទ៖ តម្រូវការអប់រំពិសេស

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

១.២ សាលារៀនអប់រំពិសេស ការបញ្ចូល និងបរិយាបន្ន

ជាច្រើនទសវត្សមកហើយ ការអប់រំពិសេស-ឬការអប់រំកុមារដែលមានពិការភាព ខាងរាងកាយនិងការសិក្សា រួមទាំងតម្រូវការពិសេស ត្រូវបានលើកមកពិភាក្សាដេញដោលយ៉ាងចម្រូងចម្រាស ជាពិសេសសំណួរ ដែលចោទថាតើសិស្សដែលមានតម្រូវការការអប់រំពិសេស (SEN) គួរតែត្រូវបានដាក់ក្នុងថ្នាក់ធម្មតា(រួមបញ្ចូលចម្រុះ) ឬថ្នាក់ដាច់ដោយឡែកពីគ្នា? ក្នុងអតីតកាល អ្នកជំនាញបានគាំទ្រ ចំពោះការបែងចែក សាលារៀនទូទៅសម្រាប់សិស្សធម្មតា និងសាលារៀនពិសេសសម្រាប់សិស្សដែលមានតម្រូវការពិសេសតាមក្រុមនីមួយៗ ក្នុងគោលបំណងទទួលបានផលប្រយោជន៍ ពីការបង្រៀនស្របតាមតម្រូវការរបស់សិស្ស។ ទោះជាយ៉ាងនេះក្តី គុណភាព នៃការបែងចែកសិស្សតាមប្រព័ន្ធខាងលើ ត្រូវបានគេទទួលស្គាល់ថា សិស្សដែលមិនសាកសមចូលរួមក្នុងក្រុមធម្មតា ត្រូវបានបំបែកចេញពីមិត្តភក្តិរបស់ពួកគេ។ ជាលទ្ធផល ប្រព័ន្ធអប់រំនេះត្រូវបានគេសាកល្បងបញ្ជ្រាបបញ្ចូល ដោយផ្នែកខ្លះចំពោះសិស្សដែលមានតម្រូវការពិសេសចូលទៅក្នុងសាលា/ថ្នាក់រៀនធម្មតា។ នៅពេលនោះគេសង្កេតឃើញថា សមត្ថ-ភាពសិស្សដែលមានតម្រូវការពិសេស មានភាពល្អគ្រប់គ្រាន់សម្រាប់ការរួមបញ្ចូលបែបនេះ។ ម៉្យាងទៀត វិធីសាស្ត្រនេះបង្ហាញហេតុផលថាមានសិស្សភាគច្រើននៅតែមានសភាពធម្មតា ទោះជាពួកគេត្រូវបានដាក់បញ្ចូលរួមជាមួយសិស្សភាគតិចដែលមិនប្រក្រតីក៏ដោយ។ (Sharma and Dunay, 2018; Prengel, 2013; Moore, Gilbreath & Maiuri, 1998) គរុកោសល្យបែបបរិយាបន្នមានន័យលើសពីការបញ្ចូលគ្នាបែបធម្មតាដែលយកសិស្សភាគតិចទៅរួមបញ្ចូលជាមួយសិស្សភាគច្រើន។

គេពិនិត្យឃើញថា មានភាពខុសគ្នាជាច្រើនចំពោះបុគ្គលម្នាក់ៗ ដែលមានតម្រូវការផ្សេងៗ និងពិសេសរៀងៗខ្លួន។ ប៉ុន្តែនៅពេលជាមួយគ្នានេះដែរ សាលារៀនបរិយាបន្នបានបដិសេធ មិនបែងចែក ឬដាក់បញ្ចូលសិស្សទៅតាមក្រុមដែលបានកំណត់ទុកនោះទេ។ “ការអប់រំបរិយាបន្ន គឺជាការផ្សារភ្ជាប់មនុស្សគ្រប់គ្នា ហើយធ្វើការប្តេជ្ញាក្នុងការផ្តល់ចំណេះដឹងឱ្យសិស្សក្នុងសហគមន៍។ ពលរដ្ឋម្នាក់ៗក្នុងប្រទេសប្រជា-ធិបតេយ្យទទួលបានសិទ្ធិ ដែលមិនអាចផ្លាស់ប្តូរបានក្នុងភាពជាសមាជិកក្រុម។” (Falvey & Givner, 2005, p. 5) សិទ្ធិដែលទទួលបានជាសមាជិកភាពនេះ រាប់បញ្ចូលទាំងការឱ្យតម្លៃទៅលើភាពខ្លាំងរបស់បុគ្គលនីមួយៗ រួមទាំងតម្រូវការរបស់ពួកគេ។ “សន្និដ្ឋានថាការរស់នៅ និង

រៀនជាមួយគ្នា ធ្វើឱ្យអ្នកគ្រប់គ្នាទទួលបានផលប្រយោជន៍ពីគ្នាទៅវិញទៅមក មិនមែនសម្រាប់តែសិស្ស ដែលត្រូវបានគេចាត់តាមក្រុមថាមានភាពខុសគ្នាប៉ុណ្ណោះទេ” ។ (Falvey & Givner, 2005, p. 5). ដូច្នេះហើយ ទើបតម្រូវឱ្យមានការផ្លាស់ប្តូរការបង្រៀន និងការរៀន ពីវិធីសាស្ត្រមួយដែលដំណើរការសម្រាប់អ្នករៀនភាគច្រើនដែលមានស្រាប់ រួមបញ្ចូលជាមួយអ្វីមួយ “ដែលជាវិធីបន្ថែម” ឬ “វិធីខុសប្លែកពីគេ” សម្រាប់អ្នកដែលពិការជួបប្រទះការលំបាក ដើម្បីបោះជំហានទៅរកការអភិវឌ្ឍសហគមន៍។ ការសិក្សាដ៏សម្បូរបែប ផ្តល់ឱកាសរៀនសូត្រសម្រាប់ទាំងអស់គ្នា ហេតុ-នេះអ្នកសិក្សាទាំងអស់អាចចូលរួមរៀនក្នុងថ្នាក់បាន។ (Florian & Black-Hawkins, 2011, p. 814)។ ទិដ្ឋភាពដែលគេហៅថា “ការធ្វើឱ្យមាន**ភាពសាមញ្ញ (normalization)** នេះជួយសិស្សដែលមានតម្រូវការពិសេសខាងការសិក្សា ឱ្យរៀនពីឥរិយាបថដែលសង្គមទទួលស្គាល់ឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន។ ការជំរុញឱ្យមានការផ្លាស់ប្តូរ បុគ្គលម្នាក់ៗត្រូវអភិវឌ្ឍនូវជំនាញនិងទម្លាប់ ដែលសង្គមទទួលស្គាល់។ ដូចគ្នានេះដែរ ការធ្វើឱ្យមានសភាពធម្មតា តម្រូវឱ្យមានការទទួលយកពីសង្គម ចំពោះបុគ្គលដែលមានតម្រូវការពិសេសដោយឡែក។ ភាពសាមញ្ញ បង្ហាញយ៉ាងច្បាស់ថាការរួមបញ្ចូលចម្រុះគ្នាអាស្រ័យទាំងស្រុងលើសង្គម និងមនុស្សដែលមានពិការភាព (Wolfensberger, 1977) ។

ទោះជាយ៉ាងនេះក៏ដោយ បរិយាបន្នលែងត្រូវបានគេកាត់បន្ថយសម្រាប់ការអប់រំសិស្សានុសិស្ស ដែលពិការភាពខាងផ្លូវកាយ ដែលអសមត្ថភាពខាងការសិក្សា និងសិស្សដែលមានតម្រូវការពិសេស(Sanger, 2020) ចំពោះមនុស្សគ្រប់ប្រភេទនៅគ្រប់កម្រិត ស្ថាប័ន អប់រំ សង្គម និងសេដ្ឋកិច្ច ដើម្បីធ្វើឱ្យមនុស្សគ្រប់គ្នាមានលទ្ធភាពស្មើគ្នា (Sanger, 2020)។

សាលារៀន ជាស្ថាប័នតំណាងឱ្យប្រទេសមួយ ដើរតួជាគំរូឆ្លុះបញ្ចាំងពីតម្លៃសង្គម។ ដូចនេះគួរតែជាក់បញ្ចូលសមាជិករបស់ខ្លួនទៅតាមវិធីសាស្ត្រណាមួយអាចជាៈ វិធីសាស្ត្រ សម្រាប់ទាំងអស់គ្នា ឬផ្ទុយគ្នា វិធីសាស្ត្ររៀបតាមលំដាប់ និងញែកចេញពីគ្នាតាមប្រភេទសមាជិករបស់ខ្លួន (Falvey & Givner, 2005) ។

សាលារៀនបរិយាបន្ន គឺដើរតាមវិធីសាស្ត្រទីមួយដែលទទួលស្គាល់ថា ទាំងអស់គ្នាអាចរៀនចេះ ជួយគាំទ្រសិស្សគ្រប់គ្នាក្នុងការសិក្សា ទើបធានាបានថាអ្នកគ្រប់គ្នានឹងជោគ- ជ័យ។ដើម្បីធ្វើកិច្ចការនេះបាន សាលារៀនបរិយាបន្នពឹងផ្អែកទៅលើការសហការ និងកិច្ចសហប្រតិបត្តិការពីអ្នកដែលជាប់ពាក់ព័ន្ធ។ នេះមាន

ភាពសាមញ្ញ

មានន័យថាជាការធ្វើឱ្យកាន់តែមានលក្ខណៈធម្មតា តាមដែលអាចធ្វើទៅបាន ដើម្បីបង្កើតបាន ឬរក្សាបាននូវបុគ្គលិកលក្ខណៈ និងអាកប្បកិរិយាបែបធម្មតា។ (Wolfensberger, 1977, p. 28)

ការគាក់តែងជាសកលសម្រាប់ការសិក្សា (Universal Design for Learning, UDL) ជាការគាក់តែងមិនសម្រាប់តែសិស្សមានសមត្ថភាពកម្រិតមធ្យមនោះទេ តែសម្រាប់សិស្សដែលមានសមត្ថភាពខ្ពស់ ឱ្យតម្លៃសមត្ថភាព

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ន័យថា ការគាំទ្រមិនគួរផ្តោតតែលើបរិបទដែលជាក់លាក់ដូចជាថ្នាក់រៀនពិសេស ឬសាលារៀនពិសេសប៉ុណ្ណោះទេ តែសិស្សានុសិស្សអាចរៀនជាមួយគ្នាក្នុងបរិយាកាសមួយដែលអាចផ្តល់នូវជំនួយដល់អ្នកដែលមានតម្រូវការ (Falvey & Givner, 2005) ។

អ្នកជំនាញអប់រំជនជាតិអាល្លឺម៉ង់ឈ្មោះ Annedore Prengel (2013) បានបង្ហាញមូលដ្ឋានគ្រឹះ នៃសាលារៀនបរិយាបន្នដោយផ្អែកលើលក្ខណៈសម្បត្តិបួនយ៉ាងគឺ៖

1. សាលារៀនបរិយាបន្ន មានន័យថាសិស្សទាំងអស់ដោយមិនរាប់បញ្ចូលពីតម្រូវការផ្ទាល់ខ្លួន បានចូលរៀននៅសាលាមួយជាមួយគ្នាជាច្រើនឆ្នាំនៅថ្នាក់បឋមសិក្សា ហើយអាចរៀនជាមួយគ្នាទៀតនៅឆ្នាំសិក្សាបន្ទាប់។
2. សាលារៀនបរិយាបន្នមានន័យថា គ្រូបង្រៀនទូទៅ គ្រូបង្រៀនអប់រំពិសេស និងអ្នកជំនាញអប់រំដទៃទៀត ធ្វើការរួមគ្នាក្នុងក្រុមពហុជំនាញឬពហុអាជីព ដើម្បីបង្រៀន អប់រំ គាំទ្រ ហើយនិងមើលថែសិស្សានុសិស្ស។
3. សាលារៀនបរិយាបន្នមានន័យថា ការបង្រៀនរបស់គ្រូម្នាក់ដល់សិស្សគ្រប់គ្នា ដើម្បីលើកកម្ពស់ការសិក្សារបស់ពួកគេនៅគ្រប់កម្រិតស្របតាមសមត្ថភាព និងចំណាប់អារម្មណ៍។ ការធ្វើសម្បទានវិស័យអប់រំត្រូវបានធ្វើទៅតាមចំណេះដឹង ដែលមានពីមុនមករបស់សិស្សម្នាក់ៗ ដោយមានជំនួយពីអ្នកអប់រំ និងជំនួយពីសប្បុរសជនផងដែរ។ ជាឧទាហរណ៍ ការបែងចែកភាពខុសគ្នារបស់សិស្សក្នុងថ្នាក់អាចធ្វើទៅបានត្រឹមត្រូវ លុះត្រាតែការសម្រេចបានឆ្ពុះបញ្ចាំងពីការឯកភាពគ្នានៅក្នុងថ្នាក់ត្រូវបានធានា។
4. សាលារៀនបរិយាបន្នមានន័យថា ការសិក្សាប្រចាំថ្ងៃរបស់សិស្សម្នាក់ៗ ទទួលបានការគោរពស្រឡាញ់គ្រប់គ្រាន់ ទទួលបានការអបអរសាទរ និងចាត់ទុកថាជាផ្នែកមួយនៃសហគមន៍។ សិស្សម្នាក់ៗអាចស្វែងរកការគាំទ្រនៅក្នុងថ្នាក់រៀន ក្នុងទម្រង់នៃអាណាព្យាបាលខាងចិត្តវិទ្យាម្នាក់ៗ (p. 16f.)

ពិការភាព អាយុ វិធី រៀន ភាសាដើមជនជាតិ។ល។ (Burgstahler, n.d., online)

អ្នកសិក្សាខាងភាសា ចូលចិត្តអាន សរសេរ និទានរឿង និងពូកែចងចាំព័ត៌មាន។ អ្នកសិក្សាផ្នែកឡូស៊ិក ចូលចិត្តធ្វើការជាមួយលេខ និងពូកែខាងដោះស្រាយបញ្ហា និងលំនាំឡូស៊ិក។

អ្នកសិក្សាខាងរូបី ចូលចិត្តគូរ និងធ្វើការជាមួយម៉ាស៊ីន និងពូកែខាងផ្លូផ្តង វិភាគផែនទី និងក្រាហ្វ។ អ្នកសិក្សាដែលសកម្មខាងរាងកាយ ចូលចិត្តរំកឹលជុំវិញថ្នាក់ហើយពូកែខាងកីឡា រាំនិងការសម្តែង។

អ្នកសិក្សាខាងតន្ត្រី គឺពួកគេចូលចិត្តច្រៀងហើយលេងឧបករណ៍ហើយពូកែចងចាំទំនុកភ្លេង ពូកែខាងកត់សម្គាល់សំឡេងឡើងខ្ពស់និងចង្វាក់ភ្លេង។ អ្នកសិក្សាដែលមានទំនាក់ទំនងអន្តរបុគ្គល ចូលចិត្តមានមិត្តភក្តិច្រើនហើយ



រូប៣. បរិយាកាសសិក្សាមេត្រីបរិយាបន្ន[3]

ភាពជោគជ័យនៃសាលារៀនបរិយាបន្ន ទទួលបានការគាំទ្រពីការសិក្សាមួយចំនួនដែលបង្ហាញពីការរីកចម្រើននៃការសិក្សារបស់សិស្សដែលមានពិការភាពកម្រិតស្រាល ហើយកំពុងត្រូវបានបង្រៀនក្នុងបរិយាកាសបែបបរិយាបន្ន។ ចំពោះសិស្សដែលមានពិការភាពធ្ងន់ធ្ងរ ការរីកចម្រើនខាងការសិក្សាមានតិចតួច ប៉ុន្តែការរីកចម្រើនខាងសង្គមរបស់ពួកគេគួឱ្យកត់សម្គាល់។ ទន្ទឹមគ្នានេះដែរ សិស្សធម្មតាមិនមានបញ្ហាខាង ការសិក្សាទេ តែផ្ទុយទៅវិញពួកគេអភិវឌ្ឍវិរិយាបថវិជ្ជមាន ចំពោះមិត្តរួមថ្នាក់ដែលមានតម្រូវការពិសេស។ (Prengel, 2013; Moore, Gilbreath & Maiuri, 1998)

ពូកែយល់ពីមនុស្សម្នារ ដឹកនាំអ្នកដទៃ ហើយនិងពូកែខាងសម្រុះសម្រួលទំនាស់។

អ្នកសិក្សាជាបុគ្គលស្ងប់ស្ងាត់ផ្នែកខាងក្នុងចូលចិត្តធ្វើការតែឯង យល់លើពីខ្លួនរបស់គេបានច្បាស់ ហើយជាអ្នកដែលមានគំនិតដើមមិនយកពីគេ។

អ្នកសិក្សាបែបធម្ម-ជាតិចូលចិត្តចេញទៅខាងក្រៅហើយពូកែខាងថែរក្សាអភិរក្ស ហើយរៀបចំកន្លែងសម្រាប់រស់នៅ។ (Gardner et al., 2011, p. 67)

១.៣ ការរៀបចំជាសកលសម្រាប់ការសិក្សា (UDL)

គោលវិធីសាស្ត្រនេះ នឹងផ្តល់នូវវិធីក្នុងការបង្កើតថ្នាក់រៀនបែបបរិយាបន្ន ដោយចាប់ផ្តើមពីការរៀបចំកម្មវិធីសិក្សា។ **UDL**ជំរុញអ្នកអប់រំឱ្យផ្តល់៖ (១) មធ្យោបាយទំនាក់ទំនង -"ហេតុផល"នៃការសិក្សា (២)មធ្យោបាយតំណាង -"កម្មវត្ថុ" ដែលត្រូវការសិក្សា និង(៣)សកម្មភាព និងការសម្តែងមតិ -"របៀប"នៃការសិក្សា។[...] ជាជាង ការរងចាំ ដើម្បីដឹងថាសិស្សណាម្នាក់ត្រូវការការគាំទ្របន្ថែម ឬការគាំទ្រដែលមានលក្ខណៈពិសេស។ គោលវិធីសាស្ត្រ**UDL**ជំរុញឱ្យអ្នកអប់រំរៀបចំផែនការកម្មវិធីសិក្សា និងគរុកោសល្យ ដើម្បីប៉ាន់ស្មានពីភាពចម្រុះគ្នាក្នុងតម្រូវការសិក្សា និងនិន្នាការរបស់សិស្ស។ គោលវិធីសាស្ត្រ**UDL**ផ្តោ

[3] Taken from UNESCO/Booklet One (2015, p. 11). CC BY-SA 3.0 IGO.

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

តការយកកចិត្តទុកដាក់តិចតួចទៅលើពិការភាពនិងអត្តសញ្ញាណជាក់លាក់ ហើយផ្តោតយ៉ាងសំខាន់លើវិធីសាស្ត្ររួម ដើម្បីជំរុញការសិក្សា។ [...] មានកស្តុតាងគួរឱ្យចាប់អារម្មណ៍ដែលអះអាងថា ការចាប់យកគោលវិធី-សាស្ត្ររួមនៃ **UDL** ចំពោះការសិក្សារបស់សិស្ស ហើយនិងការបញ្ចូលវិធីសាស្ត្របង្រៀនច្រើនប្រភេទ ធ្វើឱ្យការសិក្សារបស់សិស្សមានភាពរីកចម្រើន។ លើសពីការរំពឹងទុករបស់គ្រូបង្រៀនក្នុងការរៀបចំមេរៀនបង្រៀនសិស្សម្នាក់ៗ និងរបៀបរៀនដែលគេបានដឹងគឺ ការសិក្សាស្រាវជ្រាវថ្មីបានផ្តោតទៅលើសារៈសំខាន់ នៃការឱ្យសិស្សទាំងអស់ស្វែងយល់ពីទម្រង់ និងដំណើរការសិក្សាដែលខុសប្លែកពីគ្នា។ សិស្សអាចជឿថាពួកគេអាចរៀនបានប្រសើរបំផុតដោយការស្តាប់ ឬដោយការប្រើប្រាស់វត្ថុជំនួយជារូបភាព។ ប៉ុន្តែកស្តុតាងបានបញ្ជាក់ថា សិស្សភាគច្រើនមិនមែនមានរបៀបរៀនតែមួយប្រភេទនោះទេ តាមពិតទៅគេរៀនបានប្រសើរបំផុតនៅពេលដែលមានគំរូ និងមានតំណាងច្រើនប្រភេទ។[4]

ទ្រឹស្តីពហុបញ្ញា របស់ Howards Gardner (1983/2011) បញ្ជាក់ថាមនុស្សលោកទាំងអស់កើតមកខុសគ្នា តែមានភាពឆ្លាតវៃស្មើគ្នា ដែលគាត់បែងចែកជា ៨ប្រភេទ។ គាត់ជំទាស់ទៅនឹងអត្ថន័យនៃពាក្យ“ភាពឆ្លាតវៃ” ដែលត្រូវបានគេយល់តាមបែបបុរាណថា ជា“សមត្ថភាពក្នុងការគិតបែបអរូបី ដោយវាស់ស្ទង់តាមរយៈលក្ខណៈវិនិច្ឆ័យ ដែលផ្តោតលើគោលបំណង (ដូចជាការប្រឡងធ្វើតេស្ត)” (Merriam-Webster, n.d., online) ការយល់ទៅលើពាក្យ “ឆ្លាតវៃ” របស់គាត់ឆ្លើយតបទៅនឹងគំនិតដែលគេយល់ជាទូទៅថា ជាសមត្ថភាព ឬជាសម្បទារបស់បុគ្គលម្នាក់ៗ។ មនុស្សគ្រប់គ្នាមានភាពខុសគ្នានៃសមត្ថភាពទាំងនេះ ហើយពួកគេអភិវឌ្ឍបន្ថែមទៀតក្នុងជីវិតរបស់ពួកគេ។ លើសពីនេះទៀតការអប់រំកាន់តែមានប្រសិទ្ធភាពជាងមុនប្រសិនបើចំណុចខ្លាំងរបស់សិស្សម្នាក់ៗ ត្រូវបានកំណត់ និងជួយអភិវឌ្ឍ។ ដំណើរការអភិវឌ្ឍ ដែលបានគ្រោងទុកទៅតាមចំណុចខ្លាំងរបស់សិស្សម្នាក់ៗ ប្រសើរជាងការផ្តោតទៅលើតែការបិនប្រសប់ដែលល្អឥតខ្ចោះរបស់សិស្សតែមួយចំនួន។ (Gouws & Dicker, 2011) គ្រូបង្រៀនគួរតែដឹងពីសមត្ថភាពរបស់សិស្សម្នាក់ៗ ហើយព្យាយាម "បង្រៀននិងវាយតម្លៃតាមវិធីដែលធ្វើឱ្យពួកគេបានយល់ដឹង" (Gardner, 1983/2011, xvi)។ និយាយចំពោះសាលារៀនបរិយាបន្ន អាចមានន័យថាការទទួលយកនូវចំណុចខ្លាំងរបស់សិស្សម្នាក់ៗ និងជំនាន់របស់ពួកគេ ដែលត្រូវបានប្រើប្រាស់ប្តូ

ប្រសិទ្ធភាពខ្លួនឯង
ការជឿជាក់លើសមត្ថភាពខ្លួន ក្នុងការរៀបចំ និងប្រតិបត្តិសកម្មភាពដើម្បី

[4] Taken from Sanger (2020, p. 34ff.). CC BY 4.0.

រវែនគ្នា ដើម្បីគាំទ្រសិស្សដទៃទៀត។ ជាមួយគ្នានេះដែរ គ្រូបង្រៀនគួរតែប្រើវិធីផ្សេងៗគ្នាក្នុងការបង្ហាញនូវខ្លឹមសារមេរៀន ដែលមិនត្រឹមតែឈានទៅដល់កម្រិតអតិបរមារបស់សិស្សតែប៉ុណ្ណោះទេ តែថែមទាំងបញ្ជូននូវអត្ថន័យឱ្យសិស្សបានយល់ច្បាស់ទៀតផង (Gardner , 1983/2011, xvi) ជាគោលវិធីមួយដែលបានរៀបចំឡើងដោយ UDL។

សេចក្តីថ្លែងការណ៍របស់Salamanca និងគម្រោងសកម្មភាពផ្តោតទៅលើការអប់រំពិសេស(UNESCO, 1994) ក៏ទទួលស្គាល់ថា “សិស្សម្នាក់ៗ មានបុគ្គលិកលក្ខណៈ ចំណាប់អារម្មណ៍ សមត្ថភាព និងតម្រូវការសិក្សារៀងខ្លួន”។ ទោះជាយ៉ាងនេះក៏ដោយ សេចក្តីថ្លែងនេះបានចាប់អារម្មណ៍ជាពិសេសទៅលើការរួមបញ្ចូលសិស្ស ដែលមានតម្រូវការអប់រំពិសេសក្នុងបរិបទសាលារៀនទូទៅ ដែលចាំបាច់ត្រូវរក្សាកន្លែងសម្រាប់សិស្ស ដែលមានតម្រូវការប្លែកៗពីគ្នានៅក្នុងចំណោមសិស្សរបស់ខ្លួន។ មានតែការរួមបញ្ចូលគ្នានៃសិស្សទាំងអស់នេះទេទើបអាចកាត់បន្ថយឥរិយាបទនៃការរើសអើងបានដែលអាចបង្កើតបាននូវសហគមន៍ដ៏កក់ក្តៅមួយ អាចទទួលយកសមាជិករបស់ខ្លួន និងផ្តល់ជូននូវស្តង់ដានៃការអប់រំដូចគ្នាសម្រាប់ទាំងអស់គ្នា ដែលស្របទៅនឹងវិធីសាស្ត្រសិស្សមជ្ឈមណ្ឌល។ សេចក្តីថ្លែងការណ៍នេះបានបន្ថែមទៀតថា មិនមែនត្រឹមតែសិស្សប៉ុណ្ណោះទេដែលត្រូវប្រកាន់ភ្ជាប់តាមគំនិតគោលនៃជំហាន និងដំណើរនៃការសិក្សា ប៉ុន្តែដំណើរការសិក្សាដែលគេត្រូវធ្វើការសម្របក្នុងមធ្យោបាយមួយ វាអាចបម្រើដល់អ្នកសិក្សារៀនសូត្រជាច្រើននាក់។ វិធីសាស្ត្រសិស្សមជ្ឈមណ្ឌល មានសារៈសំខាន់សម្រាប់សិស្សទាំងអស់ និងដល់សង្គមជាតិទាំងមូល។ បទពិសោធបានបង្ហាញថា វិធីនេះបានកាត់បន្ថយការបោះបង់ការសិក្សា និងការរៀនត្រួតថ្នាក់ច្រើន។ វាជាផ្នែកមួយនៅក្នុងប្រព័ន្ធអប់រំ ដែលធានាឱ្យលទ្ធផលការសិក្សាមានមធ្យមភាគកម្រិតខ្ពស់។ វិធីនេះអាចជួយបញ្ចៀសការខ្ជះខ្ជាយធនធានទាំងឡាយ និងការបំផ្លាញក្តីសង្ឃឹម ដែលនាំមកនូវផលវិបាកសម្រាប់ការបង្រៀន មានគុណភាពកម្រិតទាប និងជាវិធីសាស្ត្រ “អប់រំដ៏ត្រឹមត្រូវសម្រាប់គ្រប់គ្នា”។ ជាងនេះទៀត សាលារៀនដែលប្រើប្រាស់វិធីសិស្សមជ្ឈមណ្ឌល ជាថ្នាលបណ្តុះបណ្តាលសង្គមមនុស្ស នាំទៅរកការគោរពទាំងភាពខុសគ្នា និងសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិទាំងអស់) (UNESCO, 1994)។

សម្រេចបានលទ្ធផល (Bandura, 1997, p. 3)

សូមមើល ម៉ូឌុល ៣ ចំណុច ៣.៣ «ការកំណត់អំណាច និងប្រសិទ្ធភាពខ្លួនឯង»

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

២.ស្ថានភាពនៅក្នុងប្រទេសកម្ពុជា

របាយការណ៍មួយក្នុងឆ្នាំ២០១៨ របស់គម្រោង All Children Reading – Asia (ACR-Asia) បានសន្និដ្ឋានថា កម្ពុជាបានប្រឹងប្រែង ដើម្បីអនុវត្តសាលារៀនបរិយាបន្ន។ ទោះជាយ៉ាងនេះក្តី ការអប់រំតាមបែបបញ្ជ្រាប នៅតែជាជម្រើសដែលគេពេញនិយម ពិសេសអង្គការក្រៅរដ្ឋាភិបាលជាច្រើន(p. 31) ព្រមទាំងពីសំណាក់រដ្ឋាភិបាលផងដែរ។ លើសពីនេះទៀត សិស្សដែលមានពិការភាពនៅក្នុងសាលារៀនមិនបានទទួលនូវការ- គាំទ្រចាំបាច់ ដែលពួកគេត្រូវការដើម្បីទទួលបានជោគជ័យ។ ដូចគ្នានេះដែរគ្រូបង្រៀនមិនបានទទួលការបណ្តុះបណ្តាលបន្ថែម ពីរបៀបរៀបចំកម្មវិធីសិក្សាដើម្បីគាំទ្រការ-សិក្សារបស់សិស្ស ដែលមានលក្ខណៈពិសេសទាំងនោះទេ”។(p. 31) ទោះបីជារាជរដ្ឋា-ភិបាលកម្ពុជាបានប្តេជ្ញាចំពោះការបង្កើតប្រព័ន្ធអប់រំបែបបរិយាបន្ន “កម្មវិធីសិក្សាបច្ចុប្បន្ន មិនត្រូវបានតាក់តែងឡើងក្នុងវិធីមួយដែលអាចផ្លាស់ប្តូរបានដោយងាយស្រួលឡើយ” (p. 31) ហើយគោលបំណងរបស់រដ្ឋាភិបាល លើរបៀបយល់ដឹងពីការបង្កើតប្រព័ន្ធអប់រំនេះ ក៏នៅមិនទាន់ត្រូវបានរៀបចំគម្រោងឱ្យបានច្បាស់ឬលម្អិតនៅឡើយ។ របាយការណ៍ នេះបានសន្និដ្ឋានថា កម្ពុជាបានរៀបចំគម្រោងមូលដ្ឋានសម្រាប់ការអប់រំបែបបរិយាបន្ន ក៏ប៉ុន្តែនៅមានរយៈពេលវែងទៀតដើម្បីអនុវត្តគម្រោងនេះឱ្យបានពេញ-លេញ នៅក្នុងសាលារៀនទាំងអស់។

៣. ស្ថានភាពនៅក្នុងប្រទេសស្រីលង្កា

ការសិក្សាមួយដែលធ្វើឡើងដោយ Muttiah, Drager និងO’Connor (2016) ទៅលើការអប់រំពិសេសក្នុងប្រទេសស្រីលង្កាថា ការឆ្លុះបញ្ចាំងក្នុងខេត្តចំនួនបីបានរកឃើញថា សិស្សភាគច្រើនមានតម្រូវការពិសេស ក្នុងខេត្តភាគខាងលិច ភាគខាងជើង និងភាគខាងត្បូង ដែលកំពុងត្រូវបានបង្រៀនក្នុងផ្នែកពិសេសនេះ។ ចំណែកពាក្យ “សាលារៀនបរិយាបន្ន” ត្រូវបានប្រើក្នុងបរិបទទាំងនេះ។ តាមពិតទៅវាជាការបញ្ចូលគ្នានូវសិស្សដែលមានតម្រូវការពិសេសក្នុងសាលារៀនទូទៅ ជាកន្លែងដែលពួកគេត្រូវចំណាយពេលពេលសិក្សា១០០% នៃថ្ងៃ

សិក្សារបស់គេជាមួយសិស្សដែលមានពិការភាព ហើយនៅជាប់ដោយឡែកពីមិត្តភក្តិ ដែលកំពុងអភិវឌ្ឍតាមបែបធម្មតា”(online)។ ផ្នែកពិសេសទាំងនេះមិនបានបែងចែក អាយុ ឬសមត្ថភាព ហើយជាញឹកញាប់មិនមានការគាំទ្រចាំបាច់សម្រាប់សិស្សម្នាក់ៗដែលខុសគ្នាទេ។ ការខ្វះចន្លោះក្នុងការបណ្តុះ បណ្តាលគ្រូបន្ថែម ជាបញ្ហាមួយ និងបញ្ហាមួយទៀតគឺកង្វះខាតគ្រូបង្រៀន ដែលមានសមត្ថភាព។ សិស្សដែលមានតម្រូវការពិសេស នៅក្នុងសាលារៀនឯកជនភាគច្រើន អាចចូលរៀនក្នុងថ្នាក់រួមបញ្ចូលគ្នា ដែលជាកន្លែងពួកគេត្រូវបានទទួលការជួយគាំទ្រពីសំណាក់គ្រូជំនួយដោយផ្ទាល់ លើសមិទ្ធិផលការសិក្សារបស់ពួកគេ។ ទោះជាយ៉ាងនេះក្តីសាលារដ្ឋមិនមានធនធានសម្រាប់គ្រូ និងសិស្សក្នុងថ្នាក់រួមបញ្ចូលគ្នានោះទេ ហើយសាលាពឹងផ្អែកទាំងស្រុងទៅលើគ្រូបង្រៀនប្រចាំថ្នាក់។ ការសិក្សានេះសន្និដ្ឋានថាទោះបីជា ប្រទេសស្រីលង្កាបានអភិវឌ្ឍផ្នែកអប់រំពិសេសក៏ដោយ ក៏នៅតែមានការធ្វើឱ្យរីកចម្រើន លើសេវាកម្មត្រូវការចាំបាច់ ដើម្បីឱ្យសិស្សគ្រប់គ្នាទទួលបានផលប្រយោជន៍ពីប្រព័ន្ធអប់រំនេះ។ ការសិក្សានេះក៏បានបង្ហាញច្បាស់ថា ទោះបីជាខ្លួនបានសង្កេតពីស្ថានភាពនៅក្នុងខេត្ត ចំនួនបីក្នុងចំណោមខេត្តទាំងប្រាំបួន។ លទ្ធផលទាំងនេះអាចជាមូលដ្ឋាននាំទៅដល់ការសន្និដ្ឋាន ស្ថានភាពនៅក្នុងខេត្តដែលនៅសល់ក្នុងប្រទេសថាមានលក្ខណៈស្រដៀងគ្នា។

៤. យុទ្ធសាស្ត្រសម្រាប់គរុកោសល្យបរិយាបន្ន

៤.១ សិក្សាពីសិស្សរបស់អ្នក

មានហេតុផលខុសៗគ្នា ដែលគំរូបង្រៀនត្រូវសិក្សាពីសិស្សរបស់ខ្លួន។ ទី១ វានឹងជួយអ្នកឱ្យទទួលស្គាល់សមត្ថភាពរបស់សិស្ស និងអាចឱ្យអ្នកជួយពង្រឹងសមត្ថភាពរបស់ពួកគេ និងគាំទ្រពួកគេដោះស្រាយបញ្ហាលំបាក ដែលអាចកើតមានឡើង(UNESCO/Booklet Four, 2015)។ ទី២ “ការសិក្សាស្រាវជ្រាវពីគរុកោសល្យបរិយាបន្នបានបង្ហាញថា សិស្សរីករាយនឹងការមានអត្តសញ្ញាណផ្ទាល់ខ្លួន និងបទពិសោធជីវិតទាំងឡាយដែលទទួលស្គាល់ពីគ្រូបង្រៀន”

(Sanger, 2020, p. 37)។ រឿងនេះនឹងធ្វើឱ្យពួកគេមានអារម្មណ៍ថា ពួកគេត្រូវបានគេរាប់បញ្ចូលហើយបង្ហាញជាសញ្ញាដល់សិស្សថា អ្នកបានដឹងពីប្រវត្តិដែលប្លែកៗចម្រុះរបស់គេ។ ហើយនេះក៏ជាសញ្ញាថាអ្នកកំពុងទន្ទឹងរងចាំធ្វើការជាមួយពួកគេ ដើម្បីទទួលបានជោគជ័យក្នុងថ្នាក់របស់អ្នក” (Sanger, 2020, p. 38)។

៤.២ ជំរុញប្រសិទ្ធភាពខ្លួនឯងបែបឌិជូមាន

មុនពេលពួកគេចូលរួមក្នុងការរៀនសូត្រ សិស្សត្រូវជឿថាពួកគេអាចរៀនចេះ។ សិស្សកំពុងអភិវឌ្ឍការជឿជាក់លើខ្លួនឯង និងអត្តសញ្ញាណរបស់ពួកគេ។ មនុស្សពេញវ័យមានតួនាទីសំខាន់ ក្នុងការលូតលាស់នេះ។ សិស្សអាចនឹងត្រូវបានបំផ្លិចបំផ្លាញនៅពេលដែល ភេទ សាវតារ ជនជាតិ ឬសមត្ថភាពរបស់ពួកគេមិនត្រូវបានគេឱ្យតម្លៃ ឬនៅពេលដែលលក្ខណៈទាំងនេះត្រូវបានប្រើដើម្បីធ្វើឱ្យពួកគេមានអារម្មណ៍ថាតូចទាបជាងគេ។ (UNESCO/Booklet Four, 2015, p. 10f.) សាលាបរិយាបន្នកំណត់ថាសិស្សទាំងនេះអាចនឹងរៀនបានដោយជោគជ័យ។ ទោះបីជាយ៉ាងនេះក្តី ការជឿជាក់លើសមត្ថ-ភាពរបស់ខ្លួនអាចនឹងធ្វើឱ្យ ពួកគេមានមន្ទិលសង្ស័យអំពី ភាពជោគជ័យរបស់ពួកគេ។ តួនាទីរបស់គ្រូគឺត្រូវជួយគាំទ្រសិស្ស ឱ្យមានភាពជឿជាក់លើខ្លួនឯងច្រើនជាងមុន និងលើកកម្ពស់ស្មារតីជ័យជម្នះរបស់គេ។ មានន័យថា ពួកគេអាចធ្វើជាម្ចាស់លើកិច្ចការ និងស្វែងរកដំណោះស្រាយដោយផ្ទាល់ខ្លួន។ នៅក្នុងសាលារៀនបរិយាបន្នសិស្សមានមោទនភាព និងសមិទ្ធិផលរបស់ខ្លួនគេ។ គេរៀនពីរបៀបរៀនទាំងនៅក្នុង និងក្រៅសាលារៀនដោយខ្លួនឯង។ឧទាហរណ៍ ពួកគេរៀនពីរបៀបសួរសំណួរល្អៗ។ ពួកគេរៀនស្វែងយល់ និងអនុវត្តនូវអ្វី ដែលគេបានរៀនក្នុងសាលា និងប្រើប្រាស់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់គេ ដូចជាការលេង និងនៅក្នុងផ្ទះរបស់ពួកគេ។ ពួកគេក៏រៀន ពីរបៀបទាក់ទងគ្នាយ៉ាងសកម្ម និងរីករាយជាមួយមិត្តរួមថ្នាក់ និងគ្រូបង្រៀន។ (UNESCO/Booklet One, 2015, p. 14)

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ចូរពិចារណាឧទាហរណ៍ខាងក្រោម ដើម្បីជំរុញប្រសិទ្ធភាពវិជ្ជមានរបស់សិស្ស

- ចៀសវាងបែងចែកសិស្សទៅតាមសមត្ថភាព
- លុបបំបាត់សម្ពាធនៃការប្រកួតប្រជែង និងការចាត់ចំណាត់ថ្នាក់
- ផ្តល់ឱ្យសិស្សនូវការទទួលខុសត្រូវការងារផ្ទាល់ខ្លួនរបស់គេ ដោយទុកឱ្យគេកំណត់គោលដៅផ្ទាល់ខ្លួន និងត្រួតពិនិត្យវាយតម្លៃគោលដៅទាំងនោះដោយខ្លួនឯង
- ផ្តល់មតិយោបល់ដែលច្បាស់លាស់ និងល្អិតល្អន់សម្រាប់ការលូតលាស់នៃ ការសិក្សារបស់ពួកគេ។(Sanger, 2020; Moore, Gilbreath & Maiuri, 1998)
- ផ្តល់តម្លៃដល់សិស្ស និងការចូលរួមទៅតាមលក្ខណៈពិសេសរបស់ពួកគេ (UNESCO/Booklet Four, 2015)
- ផ្តល់មតិលើការចូលរួមរបស់សិស្សតាមបែបវិជ្ជមាន "ឧទាហរណ៍ មតិយោបល់វិជ្ជមាន" ចូរមើលចម្លើយប៉ុន្មានដែលកូន ឆ្លើយ ខុស!" អាចប្តូរទៅជា "ចូរមើលចម្លើយប៉ុន្មាន ដែលកូនឆ្លើយត្រូវ!គោះយើងស្វែងរកវិធីមួយសម្រាប់ជួយឱ្យកូនឆ្លើយត្រូវបានច្រើនជាងមុននៅពេលក្រោយ។ តើអ្វីបានជួយកូនឱ្យចងចាំចម្លើយទាំងឡាយដែលកូនឆ្លើយត្រូវ?" (UNESCO/Booklet Four, 2015, p. 10)
- ត្រូវប្រាកដក្នុងចិត្តថា អ្នកប្រាប់សិស្សម្នាក់ៗយ៉ាងហោចណាស់នូវរឿងអ្វីមួយដែលពួកគេធ្វើបានយ៉ាងល្អ។" (UNESCO/Booklet Four, 2015, p. 14)

៤.៣ ការពិចារណាពីភាពខុសគ្នាខាងវប្បធម៌ និងប្រពៃណីក្នុងតំបន់

សាលារៀនបរិយាបន្នផ្សារភ្ជាប់ភាពចម្រុះគ្នា និងត្រូវឱ្យតម្លៃភាពខុសគ្នាទាំងនោះ។ ចំពោះសិស្សដែលនិយាយភាសាមួយផ្សេងគ្នា ឬក៏សិស្សដែលចេញមកពីវប្បធម៌ដទៃទៀត យើងចាំបាច់សង្កេតទៅលើចំណុចដូចខាងក្រោម៖

- ធ្វើការជាមួយឪពុកម្តាយ និងសមាជិកសហគមន៍ ដើម្បីសម្របសម្រួលមេរៀនក្នុងថ្នាក់ និងសម្ភារៈដទៃទៀត ដែលតំណាងឱ្យវប្បធម៌ចម្រុះនិងភាសារបស់សហគមន៍។ ទង្វើនេះនឹងជួយធានាសហគមន៍ និងស្វែងរក

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

សម្ភារៈជាក់ស្តែង និងមានផលប្រយោជន៍ ហើយវានឹងជួយជំរុញឱ្យអាណាព្យាបាលបញ្ជូនកូនរបស់ពួកគាត់ទៅសាលារៀន។[...]

- ចូរប្រើប្រាស់ប្រវត្តិសាស្ត្រក្នុងតំបន់ និទានផ្ទាល់មាត់ រឿងបុរាណ បទចម្រៀង និងកំណាព្យក្នុងការបង្កើតមេរៀនក្នុងថ្នាក់។
- ចំពោះសិស្សដែលមិនចេះនិយាយភាសា សម្រាប់ការបង្រៀនក្នុងថ្នាក់រៀន សូមសហការជាមួយគ្រូដែលនិយាយ ពីរភាសា ឬអ្នកជំទៃទៀតដែលចេះនិយាយភាសារបស់សិស្សទាំងនេះ(ទោះបីជាពួកគាត់ជាសមាជិកគ្រួសារ និងសហគមន៍ក៏ដោយ) ដើម្បីបង្កើតកម្មវិធីបង្រៀនភាសាមួយដែលត្រឹមត្រូវសម្រាប់ថ្នាក់រៀន។
- ចូរប្រើឧទាហរណ៍ជាក់ស្តែងតាមតំបន់ ដែលបង្ហាញអត្ថន័យសម្រាប់សិស្សទាំងអស់គ្នាទាំងប្រុសទាំងស្រី ដែលមានប្រវត្តិ និងសមត្ថភាពចម្រុះគ្នា។[5]

៤.៤ ការជ្រើសរើសសកម្មភាពដែលមានអត្ថន័យ

សកម្មភាពមួយ ដែលចាត់ទុកថាមានអត្ថន័យក្នុងបរិបទនេះគឺ នៅពេលដែលអ្នកសិក្សាមើលឃើញថា មានប្រយោជន៍ ឬមានសារៈសំខាន់ចំពោះដំណើរការសិក្សារបស់ពួកគេ។ គ្រូបង្រៀនអាចបង្កើតសកម្មភាព ដែលមានអត្ថន័យដោយប្រកាន់ខ្ជាប់ក្នុងចិត្តនូវប្រវត្តិវប្បធម៌នៃអ្នកសិក្សា រួមទាំងផលប្រយោជន៍ក្នុងជីវិតជាក់ស្តែង ផ្សារភ្ជាប់សាលារៀនចំពោះពួកគេ។ ហេតុផលដែលគ្រូបង្រៀនត្រូវចាំគឺភាពខុសគ្នាខាងវប្បធម៌ ព្រោះវប្បធ៌មអាចមានឥទ្ធិពលទៅលើទស្សនៈរបស់សិស្ស ព្រោះមានអត្ថន័យជាប់ពាក់ព័ន្ធទៅនឹងសកម្មភាពមួយចំនួន។ ប្រវត្តិខាងផ្នែកវប្បធម៌អាចខុសគ្នា ហើយវាសំខាន់សម្រាប់អ្នកអប់រំម្នាក់ស្គាល់ច្បាស់ពីសិស្ស ដែលមិនទាន់យល់ដឹងពីប្រព័ន្ធសាលារៀន និងវប្បធម៌របស់ខ្លួន។ រឿងនេះមានន័យថាសកម្មភាព និងលំហាត់មួយចំនួនសក្តិសមសម្រាប់ សិស្សមួយចំនួនហើយមិនត្រូវជាមួយសិស្សដទៃទៀត។ ដើម្បីធ្វើឱ្យសកម្មភាពមានអត្ថន័យ វាផ្តោតសំខាន់ក្នុងការសម្របសម្រួលទៅនឹងស្ថានភាពជីវិត និងកាលៈទេសៈពិតៗ។ កិច្ចការនេះនឹងជួយអ្នកសិក្សាឱ្យមើលឃើញនូវសារៈ-សំខាន់លើអ្វីដែលគេកំពុងសិក្សា។ វិធីនេះធ្វើឱ្យការសិក្សាមានអត្ថន័យជាងមុនចំពោះពួកគេ (Vosniadou,2001) សកម្មភាពទាំងនេះ នឹងផ្តល់នូវការយល់ដឹងរបស់សិស្ស

[5] Taken from UNESCO/Booklet Three (2015, p. 36) + Booklet Four (2015, p. 61). CC BY-SA 3.0 IGO.

នូវអ្វី ដែលកំពុងត្រូវបានគេបង្រៀន ហើយវានឹងជំរុញឱ្យមានការគិតវិភាគរបស់ពួកគេ។(Sileo et al.,1998) គំនិតខាងក្រោមអាចមានប្រយោជន៍នៅពេលដែលកំពុងរៀបចំគម្រោងសកម្មភាព៖

- ផ្តួផ្តងជំនាញមួយ និងលំហាត់មួយដែលមានអត្ថន័យចំពោះអ្នកសិក្សា។ ឧទាហរណ៍ឱ្យសិស្សធ្វើបទបង្ហាញ ឬចូលរួមក្នុងការដេញដោលមតិ ដើម្បីអភិវឌ្ឍសមត្ថភាពនិយាយរបស់ពួកគេ ឬក៏ណែនាំការសែតដល់សិស្សក្នុងថ្នាក់រៀន និងជំរុញឱ្យគេអាន និងលើកទឹកចិត្តឱ្យសរសេរអត្ថបទ ដើម្បីបង្កើនសមត្ថភាពសរសេររបស់ពួកគេ។(Vosniadou, 2001)
- អញ្ជើញអ្នកវិទ្យាសាស្ត្រ ឬអ្នកជំនាញបង្រៀនអំពីបទពិសោធក្នុងជីវិតការងារពិត ដើម្បីបង្កើនបន្ថែមនូវការយល់ដឹងរបស់សិស្សក្នុងទំនាក់ទំនងរវាងសាលារៀននិងការងារ។(Collins et al., 1989)
- ការសម្តែងតួធ្វើត្រាប់តាមឱ្យដូច ដើម្បីបញ្ចូលក្នុងដំណើរការសិក្សាជាមួយ តថភាព និងបង្កើនការគិតវិភាគស៊ីជម្រៅ។(Sileo et al., 1998)

៤.៥ ការធ្វើជាគំរូនៃភាពចម្រុះគ្នា

បើនិយាយអំពីខ្លឹមសារ និងការធ្វើសកម្មភាព រួមបញ្ចូលទាំងឧទាហរណ៍ដែលបង្ហាញភាពចម្រុះគ្នា។ ចូរកុំប្រើតែសព្វនាមជាបុរស ឬតួអង្គដែលចេញតែពីប្រវត្តិជនជាតិ ឬភូមិសាស្ត្រជាក់លាក់តែមួយមុខ។ ចូរបំបែកចេញជាលក្ខណៈតួយ៉ាងខាងយេនឌ័រ ដោយភ្ជាប់ជាមួយសកម្មភាពផ្សេងៗដូចជាចំអិនអាហារ ឬការថែទាំកូនជាមួយនឹង តួអង្គបុរស។ នៅពេលជាមួយគ្នានេះដែរ ចូរបញ្ជាក់ពីការអនុវត្តដែលមិនស្មើភាពគ្នាទាំងការមើលឃើញក្នុងសម្ភារសិក្សា ឬនៅក្នុងតថភាពជាក់ស្តែងរបស់សិស្ស។ សិស្សគួរតែបានដឹងពីភាពមិនស្មើគ្នាទាំងនេះ ហើយធ្វើការឆ្លុះបញ្ចាំងទៅលើរឿងទាំងនេះ ដើម្បីអាចផ្លាស់ប្តូរនូវតំរិយាបទមួយចំនួន។(Sanger, 2020) នៅពេលរៀបចំសម្ភារៈបង្រៀន ចូរពិចារណាទៅលើទិដ្ឋភាពខាងក្រោម៖

- ត្រួតពិនិត្យលើការស្រាយបំភ្លឺ៖ ស្វែងរកលក្ខណៈរួមដូចជា រូបភាព ឬគំនិតយោបល់និយាយអំពីមនុស្ស ដែលគេទទួលយកយ៉ាងទូលំទូលាយ ទោះបីជារូបភាពទាំងនោះមិនមែនជាការពិតក៏ដោយ(ដូចជា បុរសជា “មេគ្រួសារ” ហើយស្ត្រីជា “អ្នកមើលថែទាំកុមារ”)។ ការបង្ហាញនេះបានចោទជាសំណួរថា តើមនុស្សនៅក្នុងវប្បធម៌មួយ ឬក៏បុរសជាតួអង្គ

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ដៃលលេចធ្លោជាងគេ?តើនរណាកំពុងធ្វើអ្វី?តើកុមារដៃលមានពិការភាពជាអ្នកមើលអសកម្ម ឬក៏ពួកគេមានការចូលរួមដូចជាការ លេងបាល់ជាមួយអ្នកដទៃ? តើពួកគេមើលទៅមានភាពសប្បាយរីករាយឬទេ?

- ត្រួតពិនិត្យមើលដំណើររឿង៖ តើបញ្ហាត្រូវបានបង្ហាញ ច្នៃប្រឌិត និងដោះស្រាយនៅក្នុងសាច់រឿងដោយរបៀបណា? តើសាច់រឿងជំរុញឱ្យមានការទទួលយកដោយអសកម្ម ឬការតស៊ូយ៉ាងស្វិតស្វាញពីសំណាក់តួអង្គភាគតិច(ដូចជាមនុស្សក្នុងកុលលសម្ពន្ធ ឬក៏មនុស្សដៃលមានពិការភាព)? តើភាពជោគជ័យរបស់កុមារ ឬស្ត្រីផ្អែកលើការផ្តួចផ្តើមគំនិត និងភាពឆ្លាតវៃរបស់គេ ឬក៏បានមកដោយសាររូបរាងដ៏ស្រស់ស្អាតរបស់ពួកគេ? តើរឿងតែមួយដូចគ្នា អាចត្រូវបានលើកមកនិទានដៃរឬទេ ប្រសិនបើការសម្តែងរបស់បុរស និងស្ត្រីក្នុងសាច់រឿងត្រូវបានគេធ្វើបញ្ច្រាសគ្នា?
- ក្រឡេកមើលទៅរបៀរស់នៅ៖ ប្រសិនបើការបកស្រាយ និងអត្ថបទមានបំណងបង្ហាញពីវប្បធម៌មួយដទៃទៀត តើពួកគេបានបង្ហាញពីភាពសាមញ្ញ ឬផ្តល់នូវគំនិតវៃឆ្លាតនៅក្នុងរបៀបរស់នៅរបស់អ្នកដទៃដៃរឬទេ?
- សង្កេតមើលទំនាក់ទំនង៖ នរណាមានអំណាច?នរណាជាអ្នកសម្រេចចិត្ត? តើស្ត្រីមានតួនាទីសំខាន់ក្នុងការគាំទ្រ តៃមានមុខងារជាអ្នកនៅក្រោមបង្គាប់ឬ?
- កត់សម្គាល់ពីវិភាព៖ ជាទូទៅ តើវិជនមានប្រភពចេញពីវប្បធម៌ជាក់លាក់ណាមួយឬ? តើមនុស្សដៃលមានពិការភាពធ្លាប់ជាវិជនឬទេ? តើស្ត្រីធ្លាប់ជាវិនារីឬទេ? តើអ្នកក្រធ្លាប់ជាវិជនដៃរឬទេ?
- ពិចារណាទៅលើផលប៉ះពាល់ដល់រូបភាពរបស់កុមារ។ តើមានការផ្តល់ជាមតិយោបល់ ដៃលអាចកំណត់ព្រំដៃននៃការប៉ងប្រាថ្នារបស់កុមារដៃរឬទេ? រឿងនេះអាចប៉ះពាល់លើការគិតរបស់សិស្សម្នាក់ៗ។ តើមានអ្វីកើតឡើងចំពោះរូបកុមារីម្នាក់ នៅពេលគាត់អានអត្ថបទមួយដៃលកុមារាសម្តែងតួជាអ្នកក្លាហាន ហើយធ្វើការងារសំខាន់ៗ តៃកុមារីមិនអាចធ្វើបាន? (UNESCO/Booklet 4 2015: 30ff.)

៤.៦ ការបញ្ចូលគ្រួសាររបស់សិស្ស

ទំនួលខុសត្រូវមួយដ៏សំខាន់ ក្នុងចំណោមទំនួលខុសត្រូវរបស់យើងដែលជាគ្រូបង្រៀន គឺត្រូវបើកចំហរប្រព័ន្ធទំនាក់ទំនងជាច្រើនប្រភេទ ចំពោះគ្រួសារនិងសមាជិកដទៃទៀតក្នុងសហគមន៍។សិស្សរៀនបានប្រសើរជាងមុន នៅពេល ដែលឪពុកម្តាយ និងសមាជិកគ្រួសាររបស់ពួកគេចាប់អារម្មណ៍ និងមានទំនាក់ទំនងជាមួយសាលារៀន និងការអប់រំ។ នៅពេលដែលយើងបញ្ចូលគ្រួសារក្នុងការរៀនសូត្រ យើងបង្កើននូវសក្តានុពលសម្រាប់ការសិក្សាក្នុងថ្នាក់រៀនរបស់យើង។ យើងបង្កើតការគាំទ្រសម្រាប់ការបង្រៀនតាមមធ្យោបាយជាច្រើនយ៉ាង។ ជាលទ្ធផល ការធ្វើទំនាក់ទំនងជាមួយគ្រួសាររបស់សិស្ស និងសមាជិកសំខាន់ៗនៅក្នុងសហគម វាសំខាន់ខ្លាំងណាស់ ក្នុងការបង្កើតបរិយាកាសមេត្រីសិក្សា។[...]មានវិធីសាស្ត្រដែលមានប្រសិទ្ធភាពជាច្រើន ក្នុងការចាប់ផ្តើមធ្វើការទំនាក់ទំនងជាមួយគ្រួសារ។

ខាងក្រោមនេះជាបញ្ជីនៃវិធីសាស្ត្រមួយចំនួន។ សាកល្បង ប្រើវិធីសាស្ត្រដែលអ្នកចូលចិត្តបំផុត និងជាវិធីដែលងាយស្រួលបំផុត។ បន្ទាប់មកបន្តសាកល្បងវិធីសាស្ត្រដទៃទៀត៖

- ជួបប្រជុំជាមួយគ្រួសារសិស្ស និងសហគមន៍នៅទីណា ដែលអ្នកណែនាំពីខ្លួនអ្នកផ្ទាល់ ពណ៌នាពីគោលបំណងរបស់អ្នកសម្រាប់ការបង្រៀននិងការរៀនរបស់សិស្ស។ តម្លៃនៃភាពចម្រុះគ្នានៅក្នុងថ្នាក់រៀនមេត្រីសិក្សាបរិយាបន្ន។ពិភាក្សាពីវិធីដែលគ្រួសារនិងសមាជិកសហគមន៍អាចចូលរួមក្នុងសកម្មភាពក្នុងថ្នាក់រៀនរបស់អ្នក។
- កំណត់ពេលជួបពិភាក្សាបែបក្រៅផ្លូវការម្តង ឬពីរដងក្នុងមួយឆ្នាំ ជាមួយឪពុកម្តាយសិស្ស ដើម្បីវាយតម្លៃការសិក្សាកូនគាត់។ បង្ហាញពួកគាត់ពីឧទាហរណ៍ ដែលជាស្នាដៃកូនៗរបស់គាត់។ សង្កត់ធ្ងន់ទៅលើទេពកោសល្យនិងសមិទ្ធផលបែបវិជ្ជមានរបស់សិស្សម្នាក់ៗ ហើយរៀបរាប់ពីរបៀបដែលសិស្សរៀន កាន់តែប្រសើរជាងមុន ប្រសិនបើពួកគេអាចជម្នះបាននូវឧបសគ្គមួយចំនួន។
- ផ្ញើកិច្ចការសិស្សរបស់អ្នកទៅតាមផ្ទះរបស់ពួកគេ ដើម្បីបង្ហាញដល់ឪពុកម្តាយថាកូនរបស់ពួកគាត់កំពុងធ្វើបានល្អ ឬយ៉ាងណា។ សុំមតិ

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

យោបល់ឪពុក ម្តាយសិស្ស អំពីកិច្ចការកូនៗរបស់ពគាត់ ហើយសួរពីអ្វីដែលកូនៗរបស់គាត់គួរឱ្យរៀនបន្ទាប់។

- ជំរុញលើកទឹកចិត្តសិស្សឱ្យនិយាយពីអ្វីដែលពួកគេរៀននៅផ្ទះ។ ប្រើព័ត៌មាននេះក្នុងមេរៀនរបស់អ្នក។ ជជែកជាមួយឪពុកម្តាយអំពីរបៀបរៀន និងអ្វីដែលកូនៗរបស់ពួកគាត់កំពុងរៀននៅក្នុងថ្នាក់ ដែលជាប់ពាក់ព័ន្ធទៅនឹងជីវិតនៅផ្ទះរបស់ពួកគេ។ ម៉្យាងទៀតបង្ហាញពីរបៀបដែលចំណេះដឹងនៅក្នុងថ្នាក់រៀនរបស់ពួកគេ ដែលត្រូវបានប្រើ ឬកំពុងប្រើនៅផ្ទះ។
- ធ្វើទស្សនកិច្ចសិក្សាតាមសហគមន៍ ឬសុំឱ្យសិស្សសម្ភាសន៍ឪពុកម្តាយ ឬជីដូនជីតាអំពីកុមារភាពផ្ទាល់ខ្លួនរបស់ពួកគាត់ក្នុងសហគមន៍ ហើយបន្ទាប់មកឱ្យសិស្សរៀបរាប់ពីរឿង ឬសំណេរតែងសេចក្តីអំពី “ជីវិតក្នុងសហគមន៍នៅក្នុងអតីតកាល”។
- លើកទឹកចិត្តឱ្យសមាជិកគ្រួសារចូលរួមក្នុងសកម្មភាពក្នុងថ្នាក់រៀន ហើយអញ្ជើញអ្នកជំនាញក្នុងសហគមន៍ ឱ្យចែករំលែកចំណេះដឹងរបស់ពួកគេជាមួយនឹងថ្នាក់រៀនរបស់អ្នក។[6]

៥. ចំណុចគន្លឹះ

- ✓ សង្គមនីមួយៗត្រូវបានកំណត់លក្ខណៈ នៃភាពចម្រុះក្នុងទម្រង់ខុសៗគ្នានៃពណ៌សម្បុរ ស្បែក ភាសា ភេទ អាយុ អត្តសញ្ញាណ ស្ថានភាពសង្គម សេដ្ឋកិច្ច ឬក៏សមត្ថភាពខាងផ្លូវកាយ និងផ្លូវចិត្តនៃសមាជិករបស់ខ្លួន។ ភាពចម្រុះគ្នានេះ ក៏ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងសាលារៀនផងដែរ។
- ✓ សាលារៀនបរិយាបន្ននីមួយៗទទួលយក និងផ្តល់តម្លៃសិស្សទាំងអស់គ្នា រួម-ទាំងចំណុចខ្លាំងរបស់គេម្នាក់ៗ ហើយផ្តោតទៅរកតម្រូវការរបស់សិស្សម្នាក់ៗ។
- ✓ សាលារៀនបរិយាបន្ន មិនបានបែងចែកក្រុម ឬដាក់ឈ្មោះឱ្យបុគ្គលទាំងឡាយចូលទៅក្នុងក្រុម ដែលត្រូវបានកំណត់ទុកជាមុននោះទេ។

[6] Taken from UNESCO/Booklet Two (2015, p. 11f.). CC BY-SA 3.0 IGO.

- ✓ សាលារៀនបរិយាបន្នទទួលស្គាល់ថា អ្នកគ្រប់គ្នាអាចរៀនចេះ គាំទ្រសិស្សគ្រប់គ្នាក្នុងការសិក្សានេះ ហើយធានាបានថាអ្នកគ្រប់គ្នាបានជោគជ័យ។
- ✓ សិស្សដែលមានតម្រូវការពិសេសខាងការអប់រំ(SEN) មានទម្រង់ជាបញ្ហា ឬជំងឺ Dyslexia, Dysgraphia, Dyscalculia, ADHD ឬក៏ ASD ក្នុងចំណោមអ្នកដទៃទៀត ប្រហែលជាត្រូវការទម្រង់បន្ថែម ឬផ្សេងគ្នានៃការគាំទ្រ ជាងសិស្សដទៃទៀតដែលមានអាយុដំណាលគ្នា ឬរៀនក្នុងថ្នាក់ដូចគ្នា។
- ✓ គោលវិធីការរៀបចំជាសកលសម្រាប់ការសិក្សា(UDL) ជំរុញឱ្យអ្នកអប់រំរៀបចំគម្រោងនៃកម្មវិធីសិក្សា និងគរុកោសល្យ ដើម្បីរំពឹងទុកជាមុននូវភាពចម្រុះជាច្រើនករណីនៅក្នុងតម្រូវការការសិក្សានៃសិស្សរបស់គេ។
- ✓ មធ្យោបាយជាច្រើននៃទំនាក់ទំនង និងការបញ្ជាក់ពីគំនិត គឺជាវិធីដែលធ្វើឱ្យសិស្សឈានដល់កម្រិតខ្ពស់។
- ✓ តាមរយៈការសិក្សាពីសមត្ថភាពរបស់សិស្សម្នាក់ គ្រូដឹងពីវិធីជួយពង្រឹងសមត្ថភាពរបស់សិស្សទាំងឡាយ និងជួយគាំទ្រពួកគេនៅពេលការលំបាកអាចកើតឡើង។
- ✓ តាមរយៈការជំរុញឱ្យមានផលវិជ្ជមានចំពោះការជឿជាក់លើសមត្ថភាពផ្ទាល់ខ្លួន គ្រូអាចគាំទ្រសិស្សដោយទទួលស្គាល់ពីចំណុចខ្លាំងរបស់បុគ្គលម្នាក់ៗផ្ទាល់។
- ✓ គ្រូគួរតែពិចារណាពីភាពខុសគ្នាខាងវប្បធម៌ និងប្រពៃណីក្នុងតំបន់ដែលមានវត្តមាននៅក្នុងថ្នាក់រៀនរបស់ពួកគាត់។
- ✓ គ្រូគួរតែជ្រើសរើសសកម្មភាពទាំងឡាយណា ដែលមានអត្ថន័យសម្រាប់សិស្សម្នាក់ៗ។
- ✓ គ្រូបង្រៀនគួរតែធ្វើជាគំរូនៃភាពចម្រុះរបស់ខ្លួនផ្ទាល់។
- ✓ នៅក្នុងបរិបទបែបរួមបញ្ចូលគ្រួសារទាំងឡាយរបស់សិស្សគួរតែត្រូវបានរួមបញ្ចូលទៅក្នុងដំណើរការរៀនសូត្រ។

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

๖. ឯកសារពិគ្រោះ

All Children Reading – Asia (ACR-Asia). (2018). *Cambodia Situational Analysis of the Education of Children with Disabilities in Cambodia Report*. Washington, DC: ACR-Asia.

Bandura, A. (1997). *Self-Efficacy: The Exercise of Control*. New York: Freeman.

Boundless.com Textbooks. (n.d.). *Learning Disabilities and Special Education*. [Online]. Retrieved from: http://oer2go.org/mods/en-boundless/www.boundless.com/psychology/textbooks/boundless-psychology-textbook/learning-7/psychology-in-education-50/learning-disabilities-and-special-education-206-12741/index.html [2021, Jan. 04]. This publication is licensed under CC BY-SA 4.0 (http://oer2go.org/mods/en-boundless/creativecommons.org/licenses/by-sa/4.0/index.html).

Boundless.com Textbooks. (n.d.). *Specific Learning Disorder*. [Online]. Retrieved from: http://oer2go.org/mods/en-boundless/www.boundless.com/psychology/textbooks/boundless-psychology-textbook/psychological-disorders-18/neurodevelopmental-disorders-416/specific-learning-disorder-516-16770/index.html [2021, Jan. 04]. This publication is licensed under CC BY-SA 4.0 (http://oer2go.org/mods/en-boundless/creativecommons.org/licenses/by-sa/4.0/index.html).

Burgstahler, S. (n.d.). *Equal Access: Universal Design of Instruction*. Retrieved from https://www.washington.edu/doit/equal-access-universal-design-instruction [2021, Jan. 04].

Collins, A., Brown, J.S., & Newman, S.F. (1989). Cognitive Apprenticeship: Teaching the Craft of Reading, Writing, and Mathematics. In: Resnick, L.B., ed. *Knowing, Learning and Instruction: "Essays in Honor of Robert Glaser"* (pp. 453-484). Hillsdale, NJ: Lawrence Erlbaum Associates, Inc.

Falvey, M.A. & Givner, C.C. (2005). What Is an Inclusive School? In: R.A. Villa & J.S. Thousand, eds. *Creating an Inclusive School* (pp. 1-11). Alexandria: ASCD publications.

Florian, L. & Black-Hawkins K. (2011). Exploring Inclusive Pedagogy. *British Educational Research Journal*, 37(5), 813-828.

Gardenswartz, L. & Rowe, A. (n.d.). *Why Gardenswartz & Rowe*. Retrieved from https://www.gardenswartzrowe.com/why-g-r [2021, Apr. 07].

Gardner, H. (2011). *Frames of Mind: The Theory of Multiple Intelligences* [1983]. New York: Basic Books.

Gardner, J. N., Jewler, A. J., & Barefoot, B. O. (2011). *PACE Yourself* (9th ed). Boston, MA: Bedford/St. Martin's.

Gouws, E. & Dicker, A. M. (2011). Teaching Mathematics that Addresses Learners' Multiple Intelligences. *Africa Education Review*, 8(3), 568-587.

Individuals with Disabilities Education Act IDEA. (n.d.). Retrieved from: https://sites.ed.gov/idea/regs/b/a/300.8 [2021, Apr. 07].

Merriam-Webster. (n.d.). *Intelligence*. https://www.merriam-webster.com/dictionary/intelligence [2020, Dec. 10].

Moore, C., Gilbreath, D., & Maiuri, F. (1998). *Educating Students with Disabilities in General Education Classrooms: A Summary of the Research*. Retrieved from https://files.eric.ed.gov/fulltext/ED419329.pdf [2021, Apr. 07].

Muttiah, N., Drager, K.D.R. & O'Connor, L. (2016). Special Education in Sri Lanka: A Snapshot of Three Provinces. *Disability Studies Quarterly*. 36(2). Retrieved from: https://dsq-sds.org/article/view/4388/4310 [2021, Apr. 07].

NCATE National Council for Accreditation of Teacher Education. (2008). *Professional Standards for the Accreditation of Teacher Preparation Institutions*. Washington, DC: NCATE.

Prengel, A. (2013). *Inklusive Bildung in der Primarstufe. Eine Wissenschaftliche Expertise des Grundschulverbandes*. Frankfurt am Main: Grundschulverband e.V.

Sharma, A. & Dunay, A. (2018). Special Education Versus Inclusive Education: Examining Concerns and Attitudes of Teaching Professionals Toward Children with Disabilities. *Forum Scientiae Oeconomia*, 6(1), 83-101.

Sanger, C.S. (2020). Inclusive Pedagogy and Universal Design Approaches of Diverse Learning Environments. In: C.S. Sanger & N. Gleason, eds. *Diversity and Inclusion in Global Higher Education* (pp. 31-71). Singapore: Palgrave Macmillan. Licensed under the terms of the Creative Commons Attribution 4.0 International License (https://creativecommons.org/licenses/by/4.0/)

Sileo, T.W., Prater, M.A., Luckner, J.L., Rhine, B., & Rude, H.A. (1998). Strategies to Facilitate Preservice Teachers' Active Involvement in Learning. *Teacher Education and Special Education*, 21(3), 187-204.

Stainback, S.B. & Smith, J. (2005). Inclusive Education: Historical Perspective. In: R.A. Villa & J.S. Thousand, eds. *Creating an Inclusive School* (pp. 12-26). Alexandria: ASCD publications.

Tichá, R., et al. (2018). Instructional Strategies for Inclusive Classrooms: PALS, Cooperative Learning, Direct Instruction and Play-Based Strategies. In: R. Tichá, et al., eds. *Inclusive Education Strategies: A Textbook* (pp. 105–124). Minneapolis, MN: University of Minnesota.

UNESCO. (1994). *The Salamanca Statement and Framework for Action on Special Needs Education*. Retrieved from https://www.european-agency.org/sites/default/files/salamanca-statement-and-framework.pdf [2021, Apr. 07].

UNESCO. (2015). Booklet 1: Becoming an Inclusive Learning-Friendly Environment (ILFE). In: *Embracing Diversity: Toolkit for Creating Inclusive, Learning-Friendly Environments*. UNESCO Bangkok Office. This publication is available in Open Access under the Attribution-ShareAlike 3.0 IGO (CC BY-SA 3.0 IGO) license (http://creativecommons.org/licenses/by-sa/3.0/igo/).

UNESCO. (2015). Booklet 2: Working with Families and communities to Create an ILFE. In: *Embracing Diversity: Toolkit for Creating Inclusive, Learning-Friendly Environments*. UNESCO Bangkok Office. This publication is available in Open Access under the Attribution-ShareAlike 3.0 IGO (CC BY-SA 3.0 IGO) license (http://creativecommons.org/licenses/by-sa/3.0/igo/).

UNESCO. (2015). Booklet 3: Getting All Children in School and Learning. In: *Embracing Diversity: Toolkit for Creating Inclusive, Learning-Friendly Environments*. UNESCO Bangkok Office. This publication is available in Open Access under the Attribution-ShareAlike 3.0 IGO (CC BY-SA 3.0 IGO) license (http://creativecommons.org/licenses/by-sa/3.0/igo/).

UNESCO. (2015). Booklet 4: Creating Inclusive, Learning-Friendly Classrooms. In: *Embracing Diversity: Toolkit for Creating Inclusive, Learning-Friendly Environments*. UNESCO Bangkok Office. This publication is available in Open Access under the Attribution-ShareAlike 3.0 IGO (CC BY-SA 3.0 IGO) license (http://creativecommons.org/licenses/by-sa/3.0/igo/).

Vosniadou, S. (2001). *How Children Learn*. Chicago: IAE.

Wolfensberger, W. (1977). *The Principle of Normalization in Human Services* [1972]. Toronto: National Institute on Mental Retardation.

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ជំហានទី១. ជំហាត់អនុវត្ត

ក. ចូរដាក់លក្ខណៈខាងក្រោមទៅក្នុងក្រុមដែលត្រឹមត្រូវនៃកង់ភាពចម្រុះ៖

-សង្គមសេដ្ឋកិច្ច -ភេទ -វណ្ណៈសង្គម -ប្រវត្តិអប់រំ -សមត្ថភាពផ្លូវចិត្ត -ទម្លាប់ផ្ទាល់ខ្លួន -ទម្លាប់កម្សាន្ត -អត្តសញ្ញាណភេទ -ទីតាំងភូមិសាស្ត្រ -ជនជាតិ -គ្រួសារ -ពូជសាសន៍ -អាយុ -សាសនា/ទស្សនពិភពលោក -ភាសាទំនាក់ទំនង -សមត្ថភាពខាងផ្លូវកាយ



ខ. ចូរឆ្លើយទៅនឹងសំណួរពហុជ្រើសរើសខាងក្រោម។ ចម្លើយដែលត្រូវអាចមានច្រើនជាងមួយ៖

១. តើអ្វីជាភាពខុសគ្នារវាងលក្ខណៈខាងក្រៅ និងលក្ខណៈខាងក្នុងនៃកង់ភាពចម្រុះ?

ក. គ្មានភាពខុសគ្នាទេ

ខ. ក្រុមដែលចេញពីលក្ខណៈខាងក្នុងមានពីកំណើត ហើយដូច្នេះមិនអាចផ្លាស់ប្តូរបាន ឬបើដូរបានក៏បានដោយលំបាកដែរ។ ក្រុមដែលចេញពីលក្ខណៈខាងក្រៅអាចផ្លាស់ប្តូរបានដោយបុគ្គលម្នាក់ៗ ឬដោយការមានទំនាក់ទំនងជាមួយមជ្ឈដ្ឋានជុំវិញបុគ្គល។

គ. ក្រុមដែលចេញពីលក្ខណៈខាងក្នុងអាចត្រូវបានផ្លាស់ប្តូរបានដោយបុគ្គលផ្ទាល់ ឬក៏ដោយការមានទំនាក់ទំនងជាមួយមជ្ឈដ្ឋានជុំវិញនៃបុគ្គលទាំងនោះ។ ក្រុមដែលចេញពីលក្ខណៈខាងក្រៅ មានមកពីកំណើត ហើយមិនអាចផ្លាស់ប្តូរបានទេ ឬបើបានក៏បានដោយភាពលំបាក។

២. តើអ្វីជាគោលវិធីរបស់សាលារៀនបរិយាបន្នចំពោះភាពចម្រុះ?

ក. សាលារៀនបរិយាបន្នឱ្យតម្លៃភាពខុសគ្នាជាផ្នែកដ៏សំខាន់របស់សង្គមយើង។

ខ. សាលារៀនបរិយាបន្នគាំទ្រនូវតម្រូវការចម្រុះគ្នារបស់សិស្សទាំងអស់។

គ. សាលារៀនបរិយាបន្នលើកកម្ពស់ភាពចម្រុះគ្នា ដោយការគិតពិចារណាដល់ ភាពខុសគ្នាខាងវប្បធម៌ និងប្រពៃណីក្នុងតំបន់។

គ. ចូរដាក់លក្ខណៈខាងក្រោមទៅក្នុងក្រុមឱ្យបានត្រឹមត្រូវ៖

១.ការលំបាកខាងវេយ្យាករណ៍ និងការបញ្ចេញសំឡេងនៅក្នុងប្រយោគ

២. ការរៀបចំកថាខណ្ឌនៅមិនទាន់បានល្អ

៣. ការលំបាកជាមួយនឹងជំនាញសង្គម

៤. ការលំបាកខាងភាសា

៥. ការលំបាកខាងការតម្រៀបលេខ

៦. ការលំបាកខាងការកំណត់សូរ

៧. កំហុសច្រើនក្នុងការប្រកបពាក្យ

៨. ការលំបាកក្នុងការផ្តោតអារម្មណ៍

៩. ការលំបាកក្នុងការគ្រប់គ្រងសភាពការណ៍

១០. ការលំបាកក្នុងការកំណត់ល្បឿនដំណើរការ

១១. ការលំបាកក្នុងការរៀនបញ្ញត្តិគណិតវិទ្យាដូចជាបរិមាណ តម្លៃ វិធីគុណ

១២. ការលំបាកក្នុងការចងចាំសម្លេងរយៈពេលខ្លី

១៣. ភាពខ្សោយខ្លាំងខាងការសរសេរ

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

១៤. ការលំបាកខាងជំនាញភាសា

១៥. ការលំបាកក្នុងការទន្ទេញវិធានគណិតវិទ្យា

១៦. ការលំបាកក្នុងការឆ្លើយឆ្លង

១៧. ការលំបាកក្នុងការផ្ចង់ស្មារតី

១៨. ការលំបាកក្នុងការក្នុងការស្វែងយល់ពីវិធីដោះស្រាយបញ្ហា

១៩. អាកប្បកិរិយាច្រំដែល

បញ្ហាខាងការអាន	បញ្ហាខាងការសរសេរ	បញ្ហាខាងគណិតវិទ្យា	បញ្ហាខាងការផ្ចង់ស្មារតី	ជំងឺខាងការអភិវឌ្ឍប្រព័ន្ធកោសិកាប្រសាទ

ឃ. ចូរដាក់លក្ខណៈខាងក្រោមទៅក្នុងក្រុមឱ្យបានត្រឹមត្រូវ៖ លក្ខណៈខ្លះអាចប្រើបានច្រើនជាងមួយ៖

១. គ្មានការបែងចែក ឬការដាក់ស្លាកនៃបុគ្គលម្នាក់ៗ ចូលទៅក្នុងក្រុមដែលកំណត់ទុកជាមុននោះទេ

២. ការបែងចែក និងការដាក់ស្លាកនៃបុគ្គលម្នាក់ៗ ចូលទៅក្នុងក្រុមដែលកំណត់ទុកជាមុន

៣. ការបែងចែករវាងសិស្សធម្មតានិងសិស្ស ដែលមានតម្រូវការអប់រំពិសេស

៤. សិស្សដែលមានតម្រូវការអប់រំពិសេស អាចចូលរួមជាមួយថ្នាក់រៀនធម្មតាបើគេមានសមត្ថភាព

៥. បរិយាកាសសិក្សាមួយសម្រាប់សិស្សទាំងអស់ ដែលអាចផ្តល់ជំនួយដល់អ្នកដែលត្រូវការ

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

៦. ការទទួលថាបុគ្គលម្នាក់ៗខុសប្លែកពីគ្នា ជាមួយនឹងចំណុចខ្លាំង និងតម្រូវការរៀងៗខ្លួន

៧. ការផ្តោតទៅលើចំណុចខ្សោយរបស់សិស្ស

៨. ក្រុមភាគតិចត្រូវបានដាក់បញ្ចូលទៅក្នុងក្រុមភាគច្រើន

១០. សិស្សដែលមានបញ្ហាស្រដៀងគ្នាគួរតែរៀនជាមួយគ្នា

១១. អ្នកគ្រប់គ្នាធ្វើការជាមួយគ្នា ដើម្បីបង្កើតបរិយាកាសសិក្សាមួយ ដែលផ្តល់ឱកាសសិក្សាដល់អ្នកគ្រប់គ្នា

១២. ការទទួលស្គាល់ថាអ្នកគ្រប់គ្នាអាចរៀនចេះ

១៣. សិស្សដែលមានតម្រូវការអប់រំពិសេស ដកចេញពីការចូលរៀនក្នុងសាលារៀនទូទៅ

១៤. សិស្សទាំងអស់គ្នាទទួលបានការគោរព និងការពារយកចិត្តទុកដាក់ថាជាផ្នែកនៃសហគមន៍សិក្សា

សាលារៀនពិសេស(បែងចែក)	ការបញ្ជ្រាប	បរិយាបន្ន

ង. ចូរបង្ហាញថាអំណះអំណាងខាងក្រោមសំដៅទៅរកសាលារៀនពិសេស(បែងចែក) ការបញ្ជ្រាប ឬបរិយាបន្ន៖

	គ្រប់ប្រទេសក្នុងពិភពលោក តែងតែមានសិស្សដែលមានតម្រូវការពិសេស។ សិស្សទាំងនេះជួបប្រទះបញ្ហា ដែលជាការរារាំងដល់ការពីការរៀនសូត្រ និងអភិវឌ្ឍដូចសិស្សដទៃទៀតដែលមានអាយុតំណាលគ្នា។ ដូច្នេះហើយសិស្សទាំងនេះត្រូវការទម្រង់ខុសប្លែកគ្នានៃការជួយគាំទ្រ ដើម្បីឆ្លើយតបចំពោះបញ្ហា

	របស់ពួកគេ។ វាអាចផ្តល់លទ្ធផលយ៉ាងល្អបំផុតដោយការដាក់សិស្ស ដែលមានបញ្ហាស្រដៀងគ្នាក្នុងក្រុមតែមួយ ដើម្បីធានាថា សិស្សទាំងនេះអាចទាក់ទងជាមួយមិត្តភក្តិ ដែលមិនមានបញ្ហាខាងការសិក្សាដូចគ្នា។ សិស្សដែលមានតម្រូវការពិសេស មិនគួរគេបង្រៀននៅក្នុងសាលាពិសេសនោះទេ តែគួរតែរៀននៅក្នុងថ្នាក់ពិសេសដែលមានបញ្ហាស្រដៀងគ្នា។ ក្នុងករណីដែលសិស្សទាំងនេះមានសមត្ថភាពគ្រប់គ្រាន់ ពួកគេអាចមានលទ្ធភាពចូលរួមក្នុងថ្នាក់ធម្មតានៃសាលារបស់ពួកគេ។
	កុមារទាំងអស់ មានតម្រូវការសិក្សាផ្សេងៗគ្នា ហើយអាចប្រឈមទៅការលំបាកនៅចំណុចណាមួយ ក្នុងបទពិសោធសិក្សារបស់ពួកគេ។ បញ្ហាបែបហ្នឹងអាចចង្អុលបង្ហាញពីវិធីសាស្ត្រក្នុងការកែលម្អការបង្រៀន ដែលនាំទៅដល់បរិយាកាសសិក្សាកាន់តែប្រសើរឡើងតាមតម្រូវការសិស្ស។ មិនមែនតែកុមារដែលជាបញ្ហាទេ តែវាជាបញ្ហាប្រព័ន្ធអប់រំ។ សិស្សទាំងអស់ជាបុគ្គល ដែលមានចំណុចខ្លាំង និងតម្រូវការរៀងៗខ្លួន។ គ្រូបង្រៀនចាំបាច់ត្រូវមានការបត់បែន ដើម្បីអាចឈានទៅដល់ចំណុចខ្លាំង និងតម្រូវការពិសេសនៃសិស្សម្នាក់ៗក្នុងថ្នាក់រៀនបាន។
	ក្នុងសង្គមទាំងអស់ក្នុងពិភពលោកនេះ សិស្សតែងតែមានតម្រូវការពិសេសរបស់ខ្លួន។ សិស្សទាំងនេះមានបញ្ហាជាក់លាក់ដែលរារាំងដល់ការរៀនសូត្រ និងការអភិវឌ្ឍរបស់ខ្លួនធៀបនឹងកុមារដទៃទៀតដែលមានអាយុដូចគ្នា។ ដូច្នេះ សិស្សទាំងនេះត្រូវការទម្រង់នៃការគាំទ្រខុសៗគ្នាដើម្បីឆ្លើយតបទៅនឹងបញ្ហារបស់ពួកគេ ហើយដែលអាចសម្រេចបានជាលទ្ធផលល្អបំផុតដោយការដាក់សិស្សៗដែលមានបញ្ហាស្រដៀងគ្នាឱ្យនៅជាមួយគ្នាក្នុងក្រុម។ សាលាដែលមានតម្រូវការពិសេស គឺជាកន្លែងដែលល្អបំផុតដើម្បីបំពេញតម្រូវការពិសេសរបស់សិស្សទាំងនេះ។ គ្រូបង្រៀនត្រូវការហ្វឹកហាត់បន្ថែមដើម្បីអាចបង្រៀនសិស្សទាំងនេះបាន។[8]

[8] Adapted from Disability Action Council Cambodia (n.d., p. 24).

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ច. ចូរបង្ហាញថា តើរូបណាមួយតំណាងឱ្យសាលាពិសេស(ផ្តាច់ចេញពីគេ) បញ្ហាប និង បរិយាបន្ន៖

		

ឆ. ចូរយកពាក្យក្នុងប្រអប់ទៅបំពេញចន្លោះ៖

ជាគំរូនៃភាពចម្រុះគ្នា សិក្សាពីសិស្សរបស់អ្នក ជ្រើសរើសសកម្មភាពទាំងឡាយដែលមាន អត្ថន័យ រាប់បញ្ចូលគ្រួសារសិស្ស លើកកម្ពស់ប្រសិទ្ធភាពបែបវិជ្ជមានផ្ទាល់ខ្លួន

១. វាមានសារៈសំខាន់ក្នុងការ _____ ដើម្បីទទួលស្គាល់ពីចំណុចខ្លាំង និងតម្រូវការទាំងឡាយសិស្ស។

២. វាសំខាន់ក្នុងការ _____ ដូច្នេះសិស្សដឹងពីសមត្ថភាពរបស់ពួកគេ ហើយអាចគ្រប់គ្រងការងារ និងស្វែងរកដំណោះស្រាយដោយខ្លួនឯងបាន។

៣. វាសំខាន់ក្នុងការ _____ ដើម្បីឱ្យសិស្សអាចមើលឃើញពីសារៈសំខាន់នៃហេតុផលដែលត្រូវរៀន។

៤. គ្រូបង្រៀនគួរតែ _____ ដោយការបញ្ចូលឧទាហរណ៍ដែលមកពីប្រភពផ្សេងៗដែលខុសៗគ្នា។

៥. ដោយ _____ យើងមើលឃើញសញ្ញាថាអ្នកគ្រប់គ្នានៅក្នុងជីវិតរបស់កុមារ គឺចាប់អារម្មណ៍ និងចូលរួមក្នុងការរៀនសូត្ររបស់គាត់។

ជ. ចូរដាក់លក្ខណៈវិនិច្ឆ័យទាំងនេះចូលទៅក្នុងក្រុមដែលត្រឹមត្រូវក្នុងតារាងខាងក្រោម៖

១. តើតួនាទីរបស់បុរស និងស្ត្រី(ដូចជា វេជ្ជបណ្ឌិត គ្រូបង្រៀន កម្មករ ពានិជ្ជករ) មានភាពស្មើគ្នាឬទេ?

២. តើតួនាទីនៃជនជាតិខុសគ្នា(ដូចជា វេជ្ជបណ្ឌិត គ្រូបង្រៀន កម្មករ ពានិជ្ជករ) មានភាពស្មើគ្នាឬទេ?

៣. តើសកម្មភាពសិស្សប្រុស និងសិស្សស្រី (ដូចជាសកម្មភាពកីឡា ការអានសៀវភៅ ការពិភាក្សា ការធ្វើការងារ)ស្មើភាពគ្នាឬទេ?

៤. តើទាំងកុមារា និងកុមារីមានឥរិយាបទ (សកម្មភាព ការចេះជួយគ្នា ភាពខ្លាំង ការបង្កើនផល)ស្រដៀងគ្នាដែរឬទេ?

៥. តើកុមារី និងកុមារាដើរតួនាទីជាអ្នកដឹកនាំស្មើគ្នាដែរឬទេ?

៦. តើជនជាតិខុសគ្នាដើរតួនាទីដឹកនាំបានស្មើគ្នាដែរឬទេ?

៧. តើកុមារី និងកុមារាកំពុងដោះស្រាយបញ្ហានៅក្នុងអត្ថបទនានាដែរឬទេ?

៨. តើក្រុមជនជាតិផ្សេងៗគ្នាកំពុងដោះស្រាយបញ្ហាក្នុងអត្ថបទដែរឬទេ?

៩. តើកុមារី និងកុមារាកំពុងធ្វើការរួមគ្នាក្នុងកម្មវិធីមួយដែលត្រឹមត្រូវចំពោះវប្បធម៌ដែរឬទេ?

១០. តើប្រធានបទទាំងឡាយគួរឱ្យចាប់អារម្មណ៍ចំពោះកុមារី និងកុមារាដែរឬទេ?

១១. តើប្រធានបទគួរឱ្យចាប់អារម្មណ៍ចំពោះសិស្សដែលមានសញ្ជាតិខុសគ្នាដែរឬទេ?

១២. តើមានតុល្យភាពភេទនៅក្នុងរឿងនិទានស្តីអំពីសត្វដែរឬទេ?

១៣. តើមានតុល្យភាពពូជសាសន៍នៅក្នុងរឿងនិទានស្តីអំពីសត្វដែរឬទេ?

១៤. តើស្ត្រីត្រូវបានពណ៌នាក្នុងប្រវត្តិសាស្ត្រ អក្សរសាស្ត្រ និងសិល្បៈដែរឬទេ?

១៥. តើប្រជាជាតិជំទែត្រូវបានពណ៌នាក្នុងប្រវត្តិសាស្ត្រ អក្សរសាស្ត្រ និងសិល្បៈដែរឬទេ?

១៦. តើភាសាមានរាប់បញ្ចូលស្ត្រី(ឬក៏ពាក្យដូចជា “បុរស” ឬ “របស់បុរស” ត្រូវបានប្រើប្រាស់ជាធម្មតា)ដែរឬទេ?

១៧. តើភាសាមានភាពសមរម្យសម្រាប់ការប្រើប្រាស់នៅក្នុងសហគមន៍ ក្នុងតំបន់(ដូចជាវត្ថុ ឬ សកម្មភាពត្រូវបានគេស្គាល់រួចជាស្រេច)ដែរឬទេ?

១៨. តើភាសាបានជំរុញឱ្យប្រជាជាតិខុសគ្នាចាប់អារម្មណ៍ទៅលើអត្ថបទដែរឬទេ?

១៩. តើពាក្យទាំងឡាយមិនបានរើសអើងទៅនឹងប្រជាជនភាគតិចដែរឬទេ?

ជនជាតិ	កេទ

ឈ. ចូរសរសេរតែងសេចក្តី(ប្រហែល៥០០ពាក្យ) នូវសំណួរឆ្លុះបញ្ចាំងផ្ទាល់ខ្លួនដូចខាងក្រោម៖

១. តើភាពចម្រុះគ្នាមានអត្ថន័យយ៉ាងដូចម្តេចសម្រាប់ការអប់រំថ្នាក់បឋមសិក្សា?

២. តើតម្លៃមួយណាដែលអ្នកមានជំនឿជាបុគ្គលខ្លួនឯង? ហើយថាតើគំនិតរបស់អ្នកនេះអាចមានឥទ្ធិពលទៅលើ ទស្សនៈរបស់សិស្ស និងអ្នករួមការងាររបស់អ្នកបានកម្រិតណា?

៣. តើទស្សនៈរបស់អ្នកមានការផ្លាស់ប្តូរបែបណា នៅបន្ទាប់ពីបានអានទ្រឹស្តីទាក់ទងនឹងគរុកោសល្យដែលផ្អែកលើតម្រូវការសិស្ស ភាពចម្រុះគ្នានិងបរិយាបន្ន?

៤. ចំពោះរូបអ្នក តើអ្វីទៅជាលក្ខណៈសំខាន់បំផុតនៃការអប់រំបែបបរិយាបន្ន?

៥. តើអ្នកនឹងផ្តល់នូវការជំទាស់បែបណាខ្លះចំពោះការដាក់សិស្ស ដែលមានតម្រូវការពិសេសចូលទៅក្នុងថ្នាក់ បរិយាបន្ន? តើមានភាពពិបាក ឬការប្រថុយប្រថានអ្វីខ្លះដែលត្រូវពិចារណា?

ឯកសារពិគ្រោះ

Disability Action Council Cambodia. (n.d.). *Children with Special Needs in the Classroom: In-Service Teacher Training Course*.

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ជំហានទី១. ដំណោះស្រាយ

ក. ចូរដាក់លក្ខណៈខាងក្រោមទៅក្នុងក្រុមដែលត្រឹមត្រូវនៃកង់ភាពចម្រុះគ្នា៖

សង្គមសេដ្ឋកិច្ច – កេទ – វណ្ណៈសង្គម – ប្រវត្តិអប់រំ – សមត្ថភាពផ្លូវចិត្ត – ទម្លាប់ផ្ទាល់ខ្លួន - ទម្លាប់កម្សាន្ត – អត្តសញ្ញាណកេទ – ទីតាំងភូមិសាស្ត្រ – ជនជាតិ – គ្រួសារ – ពូជសាសន៍ – អាយុ – សាសនា/ទស្សនពិភពលោក – ភាសាទំនាក់ទំនង – សមត្ថភាពខាងផ្លូវកាយ



ខ. ចូរឆ្លើយទៅនឹងសំណួរពហុជ្រើសរើសខាងក្រោម។ ចម្លើយដែលត្រូវអាចមានច្រើនជាងមួយ៖

១. តើអ្វីជាភាពខុសគ្នារវាងលក្ខណៈខាងក្រៅ និងលក្ខណៈខាងក្នុងនៃកង់ភាពចម្រុះគ្នា?

ក. គ្មានភាពខុសគ្នាទេ

ខ. ក្រុមដែលចេញពីលក្ខណៈខាងក្នុងមានពីកំណើត ហើយដូច្នេះមិនអាចផ្លាស់ប្តូរបាន ឬបើប្តូរបានក៏បានដោយលំបាកដែរ។ ក្រុមដែលចេញពីលក្ខណៈខាងក្រៅអាចផ្លាស់ប្តូរបានដោយបុគ្គលម្នាក់ៗ ឬដោយការមានទំនាក់ទំនងជាមួយមជ្ឈដ្ឋានជុំវិញបុគ្គល។

គ. ក្រុមដែលចេញពីលក្ខណៈខាងក្នុងអាចត្រូវបានផ្លាស់ប្តូរបានដោយបុគ្គលផ្ទាល់ ឬក៏ដោយការមានទំនាក់ទំនងជាមួយមជ្ឈដ្ឋានជុំវិញនៃបុគ្គលទាំងនោះ។ ក្រុមដែលចេញពីលក្ខណៈខាងក្រៅ មានមកពីកំណើត ហើយមិនអាចផ្លាស់ប្តូរបានទេ ឬបើបានក៏បានដោយភាពលំបាក។

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

២. តើអ្វីជាគោលវិធីរបស់សាលារៀនបរិយាបន្នចំពោះភាពចម្រុះគ្នា?

ក. សាលារៀនបរិយាបន្នឱ្យតម្លៃភាពខុសគ្នា ជាផ្នែកដ៏សំខាន់របស់សង្គមយើង។

ខ. សាលារៀនបរិយាបន្នគាំទ្រនូវតម្រូវការចម្រុះគ្នា របស់សិស្សទាំងអស់។

គ. សាលារៀនបរិយាបន្នលើកកម្ពស់ភាពចម្រុះគ្នា ដោយការគិតពិចារណាដល់ភាពខុសគ្នាខាងវប្ប ធម៌ និងប្រពៃណីក្នុងតំបន់។

គ. ចូរដាក់លក្ខណៈខាងក្រោមទៅក្នុងក្រុមឱ្យបានត្រឹមត្រូវ៖

១.ការលំបាកខាងវេយ្យាករណ៍ និងការបញ្ចេញសំឡេងនៅក្នុងប្រយោគ

២. ការរៀបចំកថាខណ្ឌនៅមិនទាន់បានល្អ

៣. ការលំបាកជាមួយនឹងជំនាញសង្គម

៤. ការលំបាកខាងភាសា

៥. ការលំបាកខាងការតម្រៀបលេខ

៦. ការលំបាកខាងការកំណត់សូរ

៧. កំហុសច្រើនក្នុងការប្រកបពាក្យ

៨. ការលំបាកក្នុងការផ្តោតអារម្មណ៍

៩. ការលំបាកក្នុងការគ្រប់គ្រងសភាពការណ៍

១០. ការលំបាកក្នុងការកំណត់ល្បឿនដំណើរការ

១១. ការលំបាកក្នុងការរៀនបញ្ញត្តិគណិតវិទ្យាដូចជាបរិមាណ តម្លៃ វិធីគុណ

១២. ការលំបាកក្នុងការចងចាំសម្លេងរយៈពេលខ្លី

១៣. ភាពខ្សោយខ្លាំងខាងការសរសេរ

១៤. ការលំបាកខាងជំនាញភាសា

១៥. ការលំបាកក្នុងការទន្ទេញវិធានគណិតវិទ្យា

១៦. ការលំបាកក្នុងការឆ្លើយឆ្លង

១៧. ការលំបាកក្នុងការផ្ទង់ស្មារតី

១៨. ការលំបាកក្នុងការក្នុងការស្វែងយល់ពីវិធីដោះស្រាយបញ្ហា

១៩. អាកប្បកិរិយាច្រំដែល

បញ្ហាខាងការអាន	បញ្ហាខាងការសរសេរ	បញ្ហាខាងគណិតវិទ្យា	បញ្ហាខាងការផ្ទង់ស្មារតី	ជំងឺខាងការអភិវឌ្ឍប្រព័ន្ធកោសិកាប្រសាទ
៦	១	៥	៨	៣
១០	២	១១	៩	៤
១២	៧	១៥	១៧	១៩
១៦	១៣	១៨		
១៤				

ឃ. ចូរដាក់លក្ខណៈខាងក្រោមទៅក្នុងក្រុមឱ្យបានត្រឹមត្រូវ៖ លក្ខណៈខ្លះអាចប្រើបានច្រើនជាងមួយ៖

១. គ្មានការបែងចែក ឬការដាក់ស្លាកនៃបុគ្គលម្នាក់ៗ ចូលទៅក្នុងក្រុមដែលកំណត់ទុកជាមុននោះទេ

២. ការបែងចែក និងការដាក់ស្លាកនៃបុគ្គលម្នាក់ៗ ចូលទៅក្នុងក្រុមដែលកំណត់ទុកជាមុន

៣. ការបែងចែករវាងសិស្សធម្មតា និងសិស្សដែលមានតម្រូវការអប់រំពិសេស

៤. សិស្សដែលមានតម្រូវការអប់រំពិសេស អាចចូលរួមជាមួយថ្នាក់រៀនធម្មតាបើគេមានសមត្ថភាព

៥. បរិយាកាសសិក្សាមួយសម្រាប់សិស្សទាំងអស់ ដែលអាចផ្តល់ជំនួយដល់អ្នកដែលត្រូវការ

៦. ការទទួលថាបុគ្គលម្នាក់ៗគឺខុសប្លែកពីគ្នាជាមួយនឹងចំណុចខ្លាំង និងតម្រូវការរៀងៗខ្លួន

៧. ការផ្តោតទៅលើចំណុចខ្សោយរបស់សិស្ស

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

៨. ក្រុមភាគតិចត្រូវបានដាក់បញ្ចូលទៅក្នុងក្រុមភាគច្រើន

១០. សិស្សដែលមានបញ្ហាស្រដៀងគ្នាគួរតែរៀនជាមួយគ្នា

១១. អ្នកគ្រប់គ្នាធ្វើការជាមួយគ្នា ដើម្បីបង្កើតបរិយាកាសសិក្សាមួយ ដែលផ្តល់ឱកាសសិក្សាដល់អ្នកគ្រប់គ្នា

១២. ការទទួលស្គាល់ថាអ្នកគ្រប់គ្នាអាចរៀនចេះ

១៣. សិស្សដែលមានតម្រូវការអប់រំពិសេស ដកចេញពីការចូលរៀនក្នុងសាលារៀនទូទៅ

១៤. សិស្សទាំងអស់គ្នាទទួលបានការគោរព និងការពារយកចិត្តទុកដាក់ជាផ្នែកនៃសហគមន៍សិក្សា

សាលារៀនពិសេស(បែងចែក)	ការបញ្ជ្រាបចូល	ការបញ្ចូលចម្រុះគ្នា
២	២	១
៣	៣	៥
៧	៤	៦
១០	៧	៩
១៣	៨	១១
	១០	១២
		១៤

ង. ចូរបង្ហាញថាអំណះអំណាងខាងក្រោមសំដៅទៅរកសាលារៀនពិសេស(បែងចែក) ការបញ្ជ្រាប ឬបរិយាបន្ន៖

ការបញ្ជ្រាបចូល	គ្រប់ប្រទេសក្នុងពិភពលោក តែងតែមានសិស្សដែលមានតម្រូវការពិសេស។ សិស្សទាំងនេះជួបប្រទះបញ្ហាជាដែលរារាំងដល់ការពីការរៀនសូត្រ និងអភិវឌ្ឍដូចសិស្សដទៃទៀតដែលមានអាយុតំណាលគ្នា។ ដូច្នេះហើយសិស្សទាំងនេះត្រូវការទម្រង់ខុសប្លែកគ្នានៃការជួយគាំទ្រ ដើម្បីឆ្លើយតបចំពោះបញ្ហារបស់ពួកគេ។ វាអាចផ្តល់លទ្ធផលយ៉ាងល្អបំផុតដោយការដាក់សិស្សដែលមានបញ្ហាស្រដៀងគ្នាក្នុងក្រុមតែមួយ។ ដើម្បីធានាឱ្យបានថា សិស្សទាំងនេះអាចទាក់ទងជាមួយមិត្តភក្តិ ដែលមិនមានបញ្ហាខាងការសិក្សាដូចគ្នាបាន សិស្សដែលមាន

	តម្រូវការពិសេសមិនគួរត្រូវបានគេបង្រៀននៅក្នុងសាលាពិសេសនោះទេ តែគួរតែរៀននៅក្នុងថ្នាក់ពិសេសដែលមានបញ្ហាស្រដៀងគ្នា។ ក្នុងករណីដែលសិស្សទាំងនេះមានសមត្ថភាពគ្រប់គ្រាន់ ពួកគេអាចមានលទ្ធភាពចូលរួមក្នុងថ្នាក់ធម្មតានៃសាលារបស់ពួកគេ។
ការបញ្ចូលចម្រុះគ្នា	កុមារទាំងអស់ មានតម្រូវការសិក្សាផ្សេងគ្នាហើយអាចប្រឈមទៅការលំបាកនៅចំណុចណាមួយ ក្នុងបទពិសោធសិក្សារបស់ពួកគេ។ បញ្ហាបែបហ្នឹង អាចចង្អុលបង្ហាញពីវិធីសាស្ត្រក្នុងការកែលម្អការបង្រៀន ដែលនាំទៅដល់បរិយាកាសសិក្សាកាន់តែប្រសើរឡើងតាមតម្រូវការសិស្ស។ មិនមែនតែកុមារទេដែលជាបញ្ហា តែវាជាបញ្ហាប្រព័ន្ធអប់រំ។ សិស្សទាំងអស់ជាបុគ្គល ដែលមានចំណុចខ្លាំង និងតម្រូវការរៀងៗខ្លួន។ គ្រូបង្រៀនចាំបាច់ត្រូវធ្វើការបត់បែនដើម្បីអាចឈានទៅដល់ចំណុចខ្លាំង និងតម្រូវការពិសេសនៃសិស្សម្នាក់ៗក្នុងថ្នាក់រៀន។
សាលារៀនពិសេស(បែងចែក)	ក្នុងសង្គមទាំងអស់ក្នុងពិភពលោកនេះ សិស្សតែងតែមានតម្រូវការពិសេសរបស់ខ្លួន។ សិស្សទាំងនេះមានបញ្ហាជាក់លាក់ដែលរារាំងដល់ការរៀនសូត្រ និងការអភិវឌ្ឍរបស់ខ្លួនធៀបនឹងកុមារដទៃទៀតដែលមានអាយុដូចគ្នា។ ដូច្នេះសិស្សទាំងនេះត្រូវការទម្រង់នៃការគាំទ្រខុសៗគ្នា ដើម្បីឆ្លើយតបទៅនឹងបញ្ហារបស់ពួកគេ ហើយដែលអាចសម្រេចបានជាលទ្ធផលល្អបំផុត ដោយការដាក់សិស្សដែលមានបញ្ហាស្រដៀងគ្នាឱ្យនៅក្នុងក្រុមជាមួយគ្នា ។ សាលាដែលមានតម្រូវការពិសេស គឺជាកន្លែងដែលល្អបំផុតដើម្បីបំពេញតម្រូវការពិសេសរបស់សិស្សទាំងនេះ។ គ្រូបង្រៀនត្រូវការហ្វឹកហាត់បន្ថែមដើម្បីអាចបង្រៀនសិស្សទាំងនេះបាន។[9]

[9] Adapted from Disability Action Council Cambodia (n.d., p. 24).

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ច. ចូរបង្ហាញថារូបណាមួយតំណាងឱ្យសាលាពិសេស(ផ្តាច់ចេញពីគេ) ការបញ្ជ្រាបចូលនិង ការលាយចម្រុះគ្នា៖

ការបញ្ចូលចម្រុះគ្នា	ការបញ្ជ្រាបចូល	សាលារៀនពិសេស(បែងចែក)
		

ឆ. ចូរបំពេញចន្លោះជាមួយពាក្យដែលត្រឹមត្រូវ យកចេញពីប្រអប់៖

ជាគំរូនៃភាពចម្រុះគ្នា	សិក្សាពីសិស្សរបស់អ្នក	ជ្រើសរើសសកម្មភាពទាំងឡាយ
ដែលមានអត្ថន័យ		
ការរាប់បញ្ចូលគ្រួសារសិស្ស		លើកឡើងពីប្រសិទ្ធភាពផ្ទាល់ខ្លួនបែបវិជ្ជមាន

១. វាមានសារៈសំខាន់ក្នុងការសិក្សាពីសិស្សរបស់អ្នកដើម្បីអាចដឹងពីចំណុចខ្លាំង និងតំរូវការទាំងឡាយរបស់ពួកគេ។

២. វាសំខាន់ក្នុងការលើកឡើងពីប្រសិទ្ធភាពផ្ទាល់ខ្លួនបែបវិជ្ជមាន ដើម្បីឲ្យសិស្សដឹងពីសមត្ថភាពរបស់ពួកគេហើយអាចយល់ពីកិច្ចការទាំងឡាយ និងស្វែងរកដំណោះស្រាយដោយខ្លួនឯងបាន។

៣.វាសំខាន់ក្នុងការជ្រើសរើសសកម្មភាពទាំងឡាយដែលមានអត្ថន័យ ដើម្បីឱ្យសិស្សអាចមើលឃើញពីសារៈសំខាន់នៃមូលហេតុដែលពួកគេកំពុងរៀន។

៤. គ្រូបង្រៀនគួរតែជាគំរូនៃភាពចម្រុះគ្នា ដោយការបញ្ចូលឧទាហរណ៍ប្រភពផ្សេងៗចម្រុះគ្នា។

៥. ដោយការរាប់បញ្ចូលគ្រួសារសិស្ស យើងមើលឃើញសញ្ញាថាអ្នកគ្រប់គ្នានៅក្នុងជីវិតរបស់កុមារ គឺចាប់អារម្មណ៍ និងពាក់ព័ន្ធក្នុងការរៀនសូត្រគេ។

ជ. ចូរដាក់លក្ខណៈវិនិច្ឆ័យទាំងនេះចូលទៅក្នុងក្រុមដែលត្រឹមត្រូវក្នុងតារាងខាងក្រោម៖

១. តើតួនាទីរបស់បុរស និងស្ត្រី(ដូចជា វេជ្ជបណ្ឌិត គ្រូបង្រៀន កម្មករ ពានិជ្ជករ) មានភាពស្មើគ្នាឬទេ?

២. តើតួនាទីនៃជនជាតិខុសគ្នា(ដូចជា វេជ្ជបណ្ឌិត គ្រូបង្រៀន កម្មករ ពានិជ្ជករ) មានភាពស្មើគ្នាឬទេ?

៣. តើសកម្មភាពសិស្សប្រុស និងសិស្សស្រី (ដូចជាសកម្មភាពកីឡា ការអានសៀវភៅ ការពិភាក្សា ការធ្វើការងារ)ស្មើភាពគ្នាឬទេ?

៤. តើទាំងកុមារា និងកុមារីមានឥរិយាបទ(សកម្មភាព ការចេះជួយគ្នា ភាពខ្លាំង ការបង្កបង្កើនផល) ស្រដៀងគ្នាដែរឬទេ?

៥. តើកុមារី និងកុមារាដើរតួនាទីជាអ្នកដឹកនាំស្មើគ្នាដែរឬទេ?

៦. តើជនជាតិខុសគ្នាដើរតួនាទីដឹកនាំបានស្មើគ្នាដែរឬទេ?

៧. តើកុមារី និងកុមារាកំពុងដោះស្រាយបញ្ហានៅក្នុងអត្ថបទនានាដែរឬទេ?

៨. តើក្រុមជនជាតិផ្សេងៗគ្នាកំពុងដោះស្រាយបញ្ហាក្នុងអត្ថបទដែរឬទេ?

៩. តើកុមារី និងកុមារាកំពុងធ្វើការរួមគ្នា ក្នុងកម្មវិធីមួយដែលត្រឹមត្រូវចំពោះវប្បធម៌ដែរឬទេ?

១០. តើប្រធានបទទាំងឡាយគួរឱ្យចាប់អារម្មណ៍ ចំពោះកុមារី និងកុមារាដែរឬទេ?

១១. តើប្រធានបទគួរឱ្យចាប់អារម្មណ៍ ចំពោះសិស្សដែលមានសញ្ជាតិខុសគ្នាដែរឬទេ?

១២. តើមានតុល្យភាពភេទនៅក្នុងរឿងនិទានស្តីអំពីសត្វដែរឬទេ?

១៣. តើមានតុល្យភាពខាងពូជសាន៍នៅក្នុងរឿងនិទានស្តីអំពីសត្វដែរឬទេ?

១៤. តើស្ត្រីត្រូវបានពិពណ៌នាក្នុងប្រវត្តិសាស្ត្រ អក្សរសាស្ត្រ និងសិល្បៈដែរឬទេ?

១៥. តើប្រជាជាតិដទៃត្រូវបានពិពណ៌នាក្នុងប្រវត្តិសាស្ត្រ អក្សរសាស្ត្រ និងសិល្បៈដែរឬទេ?

១៦. តើភាសាមានរាប់បញ្ចូលស្ត្រី(ឬក៏ពាក្យដូចជា "បុរស" ឬ "របស់បុរស" ត្រូវបានប្រើប្រាស់ជាធម្មតា)ដែរឬទេ?

១៧. តើភាសាមានភាពសមរម្យសម្រាប់ការប្រើប្រាស់នៅក្នុងសហគមន៍ ក្នុងតំបន់(ដូចជាវត្ថុ ឬសកម្មភាពត្រូវបានគេស្គាល់រួចជាស្រេច)ដែរឬទេ?

១៨. តើភាសាបានជំរុញឱ្យប្រជាជាតិខុសគ្នាចាប់អារម្មណ៍ទៅលើអត្ថបទដែរឬទេ?

១៩. តើពាក្យទាំងឡាយមិនបានរើសអើងទៅនឹងប្រជាជនភាគតិចដែរឬទេ?

ជនជាតិ	កេទ
២	១
៦	៣
៨	៤
៩	៥
១១	៧
១៣	១០
១៥	១២
១៧	១៤
១៨	១៦
១៩	

ឈ. ចូរសរសេរតែងសេចក្តី(ប្រហែល៥០០ពាក្យ) នូវសំណួរឆ្លុះបញ្ចាំងផ្ទាល់ខ្លួនដូចខាងក្រោម៖

១. តើភាពចម្រុះគ្នាមានអត្ថន័យយ៉ាងដូចម្តេច សម្រាប់ការអប់រំថ្នាក់បឋមសិក្សា?

២. តើតម្លៃមួយណាដែលអ្នកមានជំនឿជាបុគ្គលខ្លួនឯង? ហើយថាតើគំនិតរបស់អ្នកនេះអាចមានឥទ្ធិពលទៅលើទស្សនៈរបស់សិស្ស និងអ្នករួមការងាររបស់អ្នកបានកម្រិតណា?

៣. តើទស្សនៈរបស់អ្នកមានការផ្លាស់ប្តូរបែបណា នៅបន្ទាប់ពីបានអានទ្រឹស្តីទាក់ទងនឹងគរុកោសល្យដែលផ្អែកលើតម្រូវ

ការសិស្ស ភាពចម្រុះគ្នានិងបរិយាបន្ន?

៤. ចំពោះរូបអ្នក តើអ្វីទៅជាលក្ខណៈសំខាន់បំផុតនៃការអប់រំបែបបរិយាបន្ន?

៥. តើអ្នកនឹងផ្តល់នូវការជំទាស់បែបណាខ្លះចំពោះការដាក់សិស្សដែលមានតម្រូវការពិសេសចូលទៅក្នុងថ្នាក់ បរិយាបន្ន? តើមានភាពពិបាក ឬការប្រជុំយប្រថានអ្វីខ្លះដែលត្រូវពិចារណា?

ឯកសារពិគ្រោះ

Disability Action Council Cambodia. (n.d.). *Children with Special Needs in the Classroom: In-Service Teacher Training Course*.

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ជំហានទី២៖ លំហាត់អនុវត្ត

ក. ចូរអានករណីសិក្សា រួចបំពេញតារាងខាងក្រោម៖

ករណីសិក្សាទី១

ចាន់មានអាយុ៧ឆ្នាំ។ គាត់ពូកែខាងគណិតវិទ្យា និងគំនូរ ប៉ុន្តែគាត់មានការលំបាកក្នុងការអាន និងការសរសេរ។ គាត់សរសេរអក្សរខ្លះបញ្ច្រាសពីក្រោយទៅមុខហើយការប្រកបពាក្យរបស់គាត់មានកំហុសជាច្រើន។ នៅពេលដែលអ្នកគ្រូកត់សម្គាល់ឃើញថា ចាន់មានការលំបាកក្នុងការសរសេរ អ្នកគ្រូបានសួរគាត់ថាមានការលំបាកទៅលើអ្វី និងមានភាពងាយស្រួលទៅលើអ្វី? គ្រូក៏បានពិភាក្សាជាមួយឪពុកម្តាយរបស់ចាន់ និងគ្រូៗដទៃទៀត ដើម្បីជួយគាំទ្រចាន់ក្នុងដំណើរការរៀនសូត្ររបស់គាត់។ គ្រូរបស់ចាន់តែងតែលើកឡើងពីចំណុចវិជ្ជមានជាច្រើនរបស់ចាន់ជំនួសឱ្យការខ្វះខាតរបស់គាត់។ អ្នកគ្រូសរសើរចាន់ ពេលគាត់សរសេរបានល្អ និងពន្យល់ពីអ្វីដែលគាត់បានធ្វើល្អ។ គ្រូរបស់ចាន់ផ្តល់នូវការគាំទ្រ និងវិធីសាស្ត្រផ្សេងៗទៅលើផ្នែកដែលគាត់ត្រូវការជាចាំបាច់ជំនួយ។ លើសពីនេះទៀត គ្រូរបស់ចាន់ជំរុញឱ្យគាត់កំណត់គោលដៅសម្រាប់កិច្ចការរបស់គាត់ ហើយត្រួតពិនិត្យការរីកចម្រើនផ្ទាល់ខ្លួន ដើម្បីឱ្យគាត់អាចអភិវឌ្ឍការយល់ដឹងពីចំណុចខ្លាំង និងតម្រូវការរបស់គាត់។

ករណីសិក្សាទី២

ទីហុងមានអាយុ៧ឆ្នាំ ហើយគាត់រស់នៅជាមួយឪពុកម្តាយក្នុងតំបន់ស្វាយប៉ាក ជាយក្រុងនៅភាគខាងជើងនៃទីក្រុងភ្នំពេញ។ គ្រួសារបស់គាត់គឺជាជនជាតិវៀតណាម ប៉ុន្តែពួកគាត់រស់នៅក្នុងប្រទេសកម្ពុជាបានបីជំនាន់មកហើយ។ នៅផ្ទះ ឪពុកម្តាយរបស់ហុង ភាគច្រើននិយាយភាសាវៀតណាម ទោះបីជាទីហុងនិយាយភាសាខ្មែរក៏ដោយ។ នៅសាលារៀន ទីហុងមានការលំបាកខ្លាំង។ គ្រប់ពេលដែលគាត់ហាមាត់និយាយ សិស្សដទៃទៀតសើចចំអកចំពោះតុងសំឡេង និងសមត្ថភាពក្នុងការនិយាយភាសាខ្មែររបស់គាត់។ ពួកគេមិនលេងជាមួយហុងទេ ហើយសិស្សធំៗ វាយធ្វើបាបគាត់ទៀតផងដែរ។ ជាងនេះទៅទៀត គាត់មានការលំបាក និងរៀនមិនទាន់គេ។ គ្រូបង្រៀនរបស់ទីហុងបានដឹងពីទុក្ខលំបាកទាំងឡាយរបស់ហុង អ្នកគ្រូចាប់ផ្តើមបង្កើនការយល់ដឹងពីវប្បធម៌ និងជនជាតិខុសគ្នានៅក្នុងថ្នាក់រៀន។ អ្នកគ្រូបានចាប់ផ្តើមប្រើប្រាស់ឧទាហរណ៍ដែលបញ្ចូលនូវចំណេះដឹងខាងវប្បធម៌ចម្រុះគ្នាជាច្រើន។ ជាងនេះទៀត អ្នកគ្រូបានសុំឱ្យទីហុង និងមិត្តរួមថ្នាក់ទាំងអស់ និយាយប្រាប់គ្នាពីអ្វីដែលគេរៀននៅផ្ទះ។

ចំណេះដឹងទាំងនេះបានជួយគ្រូរបស់ទីហុង ឲ្យយល់ដឹងបានប្រសើរជាងមុនអំពីសិស្សរបស់គាត់ ហើយអ្នកគ្រូបានបញ្ចូលខ្លឹមសារមេរៀនដ៏មានន័យនេះចូលក្នុងការបង្រៀនរបស់គាត់។ អ្នកគ្រូក៏បានអញ្ជើញឪពុកម្តាយរបស់ទីហុងឱ្យនិយាយពីវប្បធម៌ និងជនជាតិរបស់ពួកគេនៅក្នុងថ្នាក់រៀនផងដែរ។

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ករណីសិក្សាទី៣

អានវី កើតមកមានជើងកែកមួយចំហៀង ហើយដៃស្តាំរបស់នាងខ្សោយ។ កុមារីរូបនេះរៀននៅក្នុងថ្នាក់ទី២ នៅប្រទេសស្រីលង្កា។ គាត់តែងតែចង់ទៅរៀនដូចមិត្តភក្តិដទៃទៀតដែរ។ តែពីដំបូង សិស្សមួយចំនួនបានសើចចំអកឱ្យអានវី។ គ្រូរបស់អានវីបានធ្វើជាគំរូមុនគេ។ គាត់និយាយជាមួយសិស្សរបស់គាត់អំពីភាពខុសគ្នារបស់មនុស្សម្នាក់ៗ។ គាត់ពន្យល់ថា ភាពមិនប្រក្រតីនៃអវយវៈរបស់អានវី មិនមែនជាមូលហេតុដែលគាត់មិនអាចរៀនបានដូចអ្នកដទៃនោះទេ ប៉ុន្តែគាត់ត្រូវការការគាំទ្រខុសប្លែកផ្សេងពីអ្នកដទៃ។ អ្នគ្រូក៏បានបញ្ជាក់យ៉ាងច្បាស់ទៀតថា អ្នកគ្រប់គ្នាគួរតែជួយអានវីនៅពេលចាំបាច់។ ដើម្បីធ្វើឱ្យសិស្សដទៃយល់ពីស្ថានភាពអានវី អ្នកគ្រូគ្រូបាននាំសិស្សសម្តែងតួផ្សេងៗគ្នា ដែលពួកគេ ទាំងនោះមានប្រវត្តិ និងសមត្ថភាពខុសគ្នា។[10]

	ការលំបាក	មូលហេតុនៃការលំបាក	ការគាំទ្រផ្នែកគរុកោសល្យ
ចាន់			
ទីហុង			
អានវី			

ខ. ចូរស្តាប់គ្រូម្នាក់និយាយអំពីរបៀបបង្រៀនក្នុងបរិយាកាសសិក្សាបរិយាបន្ន រួចឆ្លើយសំណួរខាងក្រោម៖

១. តើគ្រូបង្រៀនរូបនេះគិតដូចម្តេចចំពោះភាពខុសគ្នាខាងវប្បធម៌ និងប្រពៃណីក្នុងតំបន់?

២. តើគ្រូបង្រៀនបានយល់ដឹងពីសិស្សរបស់គាត់ដោយរបៀបណា?

គ. ចូរមើលគ្រូបង្រៀនម្នាក់នេះនិយាយអំពីការបង្រៀននៅក្នុងថ្នាក់រៀនបែបចម្រុះគ្នាមួយ។ (Video File 4.1.1; កំណត់ត្រាចេញពីសំឡេងអាចរកបាននៅក្នុងឧបសម្ព័ន្ធនៃឯកសារនេះ។) ចូរឆ្លើយសំណួរដែលមានពហុចម្លើយសម្រាប់ជ្រើសរើសនៅខាងក្រោមនេះ។ មានចម្លើយត្រឹមត្រូវលើសពីមួយ៖

១. តើគ្រូបង្រៀនម្នាក់នេះជួយគាំទ្រសិស្សដែលមានពិការភាពក្នុងការសិក្សាដោយរបៀបណា?

[10] Adapted from Disability Action Council Cambodia (n.d., p. 6)

ក. គាត់តាមដានមើលគ្រប់សកម្មភាពទាំងអស់។
ខ. គាត់មិនផ្តល់ការគាំទ្របន្ថែមទៅដល់សិស្សដែលមានពិការភាពក្នុងការសិក្សានោះទេ។
គ. គាត់រាយការណ៍ទៅឱ្យនាយកសាលាពីការរីកចម្រើនក្នុងថ្នាក់រៀនរបស់គាត់។

២. តើគាត់ប្រើយុទ្ធសាស្ត្រអ្វីខ្លះដើម្បីគាំទ្រសិស្សម្នាក់ៗ ដែលមានតម្រូវការ និងចំនុចខ្លាំងមិនដូចគ្នា?
ក. គាត់ជំរុញលើកទឹកចិត្តសិស្សគ្រប់គ្នា។
ខ. គាត់ព្យាយាមលើកទឹកចិត្តសិស្សគ្រប់គ្នា។
គ. គាត់កំណត់អត្តសញ្ញាណពីតម្រូវការនៃការសិក្សារបស់សិស្សម្នាក់ៗ។

ឯកសារពិគ្រោះ

Disability Action Council Cambodia. (n.d.). *Children with Special Needs in the Classroom: In-Service Teacher Training Course*.

ជំហានទី២៖ ចម្លើយលំហាត់អនុវត្ត

ក. ចូរអានករណីសិក្សា រួចបំពេញតារាងខាងក្រោម៖

ករណីសិក្សាទី១

ចាន់មានអាយុ៧ឆ្នាំ។ គាត់ពូកែខាងគណិតវិទ្យា និងគំនូរ ប៉ុន្តែគាត់មានការលំបាកក្នុងការអាន និងការសរសេរ។ គាត់សរសេរអក្សរខ្លះបញ្ច្រាសពីក្រោយទៅមុខហើយការប្រកបពាក្យរបស់គាត់មានកំហុសជាច្រើន។ នៅពេលដែលអ្នកគ្រូកត់សម្គាល់ឃើញថា ចាន់មានការលំបាកក្នុងការសរសេរ អ្នកគ្រូបានសួរគាត់ថាមានការលំបាកទៅលើអ្វី និងមានភាពងាយស្រួលទៅលើអ្វី? គ្រូក៏បានពិភាក្សាជាមួយឪពុកម្តាយរបស់ចាន់ និងគ្រូៗដទៃទៀត ដើម្បីជួយគាំទ្រចាន់ក្នុងដំណើរការរៀនសូត្ររបស់គាត់។ គ្រូរបស់ចាន់តែងតែលើកឡើងពីចំណុចវិជ្ជមានជាច្រើនរបស់គាត់ជំនួសឱ្យការខ្វះខាតរបស់គាត់។ អ្នកគ្រូសរសើរគាត់ពេលគាត់សរសេរបានល្អ និងពន្យល់ពីអ្វីដែលគាត់បានធ្វើល្អ។ គ្រូរបស់ចាន់ផ្តល់នូវការគាំទ្រ និងវិធីសាស្ត្រផ្សេងៗទៅលើផ្នែកដែលគាត់ត្រូវការជាចាំបាច់ជំនួយ។ លើសពីនេះទៀត គ្រូរបស់ចាន់ជំរុញឱ្យគាត់កំណត់គោលដៅសម្រាប់កិច្ចការរបស់គាត់ ហើយត្រួតពិនិត្យការរីកចម្រើនផ្ទាល់ខ្លួន ដើម្បីឱ្យគាត់អាចអភិវឌ្ឍការយល់ដឹងពីចំណុចខ្លាំង និងតម្រូវការរបស់គាត់។

ករណីសិក្សាទី២

ទីហុងមានអាយុ៧ឆ្នាំ ហើយគាត់រស់នៅជាមួយឪពុកម្តាយក្នុងតំបន់ស្វាយប៉ាក ជាយក្រុងនៅភាគខាងជើងនៃទីក្រុង
ភ្នំពេញ។ គ្រួសារបស់គាត់គឺជាជនជាតិវៀតណាម ប៉ុន្តែពួកគាត់រស់នៅក្នុងប្រទេសកម្ពុជាបានបីជំនាន់មក

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ហើយ។ នៅផ្ទះ ឪពុកម្តាយរបស់ហុង ភាគច្រើននិយាយភាសាវៀតណាម ទោះបីជាទីហុងនិយាយភាសាខ្មែរក៏ដោយ។ នៅសាលារៀន ទីហុងមានការលំបាកខ្លាំង។ គ្រប់ពេលដែលគាត់ហាមាត់និយាយ សិស្សដទៃទៀតសើចចំអកចំពោះតុងសំឡេង និងសមត្ថភាពក្នុងការនិយាយភាសាខ្មែររបស់គាត់។ ពួកគេមិនលេងជាមួយហុងទេ ហើយសិស្សធំៗ វាយធ្វើបាបគាត់ទៀតផងដែរ។ ជាងនេះទៅទៀត គាត់មានការលំបាក និងរៀនមិនទាន់គេ។ គ្រូបង្រៀនរបស់ទីហុងបានដឹងពីទុក្ខលំបាកទាំងឡាយរបស់ហុង អ្នកគ្រូចាប់ផ្តើមបង្កើនការយល់ដឹងពីវប្បធម៌ និងជនជាតិខុសគ្នានៅក្នុងថ្នាក់រៀន។ អ្នកគ្រូបានចាប់ផ្តើមប្រើប្រាស់ឧទាហរណ៍ដែលបញ្ចូលនូវចំណេះដឹងខាងវប្បធម៌ចម្រុះគ្នាជាច្រើន។ ជាងនេះទៀត អ្នកគ្រូបានសុំឱ្យទីហុង និងមិត្តរួមថ្នាក់ទាំងអស់ និយាយប្រាប់គ្នាពីអ្វីដែលគេរៀននៅផ្ទះ។

ចំណេះដឹងទាំងនេះបានជួយគ្រូរបស់ទីហុង ឱ្យយល់ដឹងបានប្រសើរជាងមុនអំពីសិស្សរបស់គាត់ ហើយអ្នកគ្រូបានបញ្ចូលខ្លឹមសារមេរៀនដ៏មានន័យនេះចូលក្នុងការបង្រៀនរបស់គាត់។ អ្នកគ្រូក៏បានអញ្ជើញឪពុកម្តាយរបស់ទីហុងឱ្យនិយាយពីវប្បធម៌ និងជនជាតិរបស់ពួកគេនៅក្នុងថ្នាក់រៀនផងដែរ។

ករណីសិក្សាទី៣

អានវី កើតមកមានជើងកែកមួយចំហៀង ហើយដៃស្តាំរបស់នាងខ្សោយ។ កុមារីរូបនេះរៀននៅក្នុងថ្នាក់ទី២ នៅប្រទេសស្រីលង្កា។ គាត់តែងតែចង់ទៅរៀនដូចមិត្តភក្តិដទៃទៀតដែរ។ តែពីដំបូង សិស្សមួយចំនួនបានសើចចំអកឱ្យអានវី។ គ្រូរបស់អានវីបានធ្វើជាគំរូមុនគេ។ គាត់និយាយជាមួយសិស្សរបស់គាត់អំពីភាពខុសគ្នារបស់មនុស្សម្នាក់ៗ។ គាត់ពន្យល់ថា ភាពមិនប្រក្រតីនៃអវយវៈរបស់អានវី មិនមែនជាមូលហេតុដែលគាត់មិនអាចរៀនបានដូចអ្នកដទៃនោះទេ ប៉ុន្តែគាត់ត្រូវការការគាំទ្រខុសប្លែកផ្សេងពីអ្នកដទៃ។ អ្នគ្រូក៏បានបញ្ជាក់យ៉ាងច្បាស់ទៀតថា អ្នកគ្រប់គ្នាគួរតែជួយអានវីនៅពេលចាំបាច់។ ដើម្បីធ្វើឱ្យសិស្សដទៃយល់ពីស្ថានភាពសម្រាប់អានវីអ្នកគ្រូបាននាំសិស្សសម្តែងតួផ្សេងៗគ្នាដែលពួកគេទាំងនោះមានប្រវត្តិ និងសមត្ថភាពខុសគ្នា។

	ភាពលំបាក	បុព្វហេតុលំបាក	ការគាំទ្រផ្នែកគរុកោសល្យ
ចាន់	ការអាន និងការសរសេរ	បញ្ហាខាងការអាន ឬការសរសេរ	សុំឱ្យគាត់ឆ្លុះបញ្ចាំងពីកាលំបាករបស់គាត់ រួមទាំងឪពុកម្តាយ និងគ្រូបង្រៀន គួសបញ្ជាក់ពីការចូលរួមបែបវិជ្ជមាន ផ្តល់ព័ត៌មានត្រឡប់បែបស្ថាបនា ជួយគាំទ្រគាត់ក្នុង ការកំណត់គោលដៅផ្ទាល់ខ្លួន។

ទីហុង	យល់ខ្លឹមសារមេរៀន ហើយមិត្ត រួមថ្នាក់ទទួលស្គាល់	មានសញ្ជាតិ និងភាសាកំណើតខុសពីមិត្តរួមថ្នាក់	លើកឡើងពីស្មារតីយល់ដឹងទាក់ទងនឹងជនជាតិដែលនិងវប្បធម៌ផ្សេងៗគ្នានៅក្នុងថ្នាក់។ ចាប់ផ្តើមប្រើប្រាស់ឧទាហរណ៍ជាច្រើនដែលរាប់បញ្ចូលទាំងប្រវត្តិវប្បធម៌ជាក់បញ្ចូលនូវរឿងទាំងឡាយដែលក្មេងៗរៀននៅផ្ទះ អញ្ជើញឱ្យអ្នកចាស់ទុំ និយាយពីវប្បធម៌និងជនជាតិរបស់ពួកគេ
អានវី	ការលំបាកក្នុងការសរសេរដោយប្រើដៃស្តាំ	ជើងកែក និងដៃស្តាំខ្សោយ	ទទួលយកមិនបានចំពោះការលេងពីសិស្សដ៏ទៃ ការជំរុញឲ្យសិស្សដទៃជួយគាត់ ការគួសបញ្ជាក់ថាគាត់អាចរៀនបានដូចជាក្មេងដទៃដែរ ប៉ុន្តែត្រូវការការគាំទ្រតាមទម្រង់ផ្សេងៗការដើរតួ

ខ. ចូរស្តាប់គ្រូម្នាក់និយាយអំពីរបៀដែលគាត់បង្រៀនក្នុងបរិយាកាសសិក្សាបរិយាបន្ន (Audio File 5.1.1; audio transcription មាននៅក្នុងឧបសម្ពន្ធនៃឯកសារនេះ) រួចឆ្លើយសំណួរខាងក្រោម៖

១. តើគ្រូបង្រៀនរូបនេះគិតដូចម្តេចចំពោះភាពខុសគ្នាខាងវប្បធម៌ និងប្រពៃណីក្នុងតំបន់?

២. តើអ្នកគ្រូបានរៀនពីសិស្សរបស់គាត់ដោយរបៀបណា?

គ. ចូរមើលគ្រូបង្រៀនម្នាក់នេះនិយាយអំពីការបង្រៀននៅក្នុងថ្នាក់បែបចម្រុះគ្នាមួយ។ (Video File 4.1.1; កំណត់ត្រាចេញពីសំឡេង មាននៅក្នុងឧបសម្ព័ន្ធនៃឯកសារនេះ។) ចូរឆ្លើយសំណួរពហុជ្រើសរើសនៅខាងក្រោមនេះ។ ចម្លើយត្រឹមត្រូវមានច្រើនជាងមួយ៖

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

១. តើគ្រូបង្រៀនម្នាក់នេះជួយគាំទ្រសិស្ស ដែលមានពិការភាពក្នុងការសិក្សាដោយរបៀបណា?
   ក. គាត់តាមដានមើលគ្រប់សកម្មភាពទាំងអស់។
   ខ. គាត់មិនផ្តល់ការគាំទ្របន្ថែមទៅដល់សិស្សដែលមានពិការភាពក្នុងការសិក្សានោះទេ។
   គ. គាត់រាយការណ៍ទៅឱ្យនាយកសាលា ពីការរីកចម្រើនក្នុងថ្នាក់រៀនរបស់ពួកគេ។
២. តើគាត់ប្រើយុទ្ធសាស្ត្រអ្វីខ្លះដើម្បីគាំទ្រសិស្សម្នាក់ៗ ដែលមានតម្រូវការ និងចំណុចខ្លាំងផ្សេងៗគ្នា?
   ក. គាត់ជំរុញលើកទឹកចិត្តសិស្សគ្រប់គ្នា។
   ខ. គាត់ព្យាយាមលើកទឹកចិត្តសិស្សគ្រប់គ្នា។
   គ. គាត់កំណត់អត្តសញ្ញាណពីតម្រូវការនៃការសិក្សារបស់សិស្សម្នាក់ៗ។

ឯកសារពិគ្រោះ

Disability Action Council Cambodia. (n.d.). *Children with Special Needs in the Classroom: In-Service Teacher Training Course*.

ជំហានទី៣៖ ការរៀបចំសំណុំឯកសារ –សំណួរឆ្លុះបញ្ចាំងផ្ទាល់ខ្លួន

ចូរសរសេរតែងសេចក្តីចំពោះសំណួរឆ្លុះបញ្ចាំងផ្ទាល់ខ្លួនខាងក្រោម។ សំណេរនីមួយៗអាចប្រើពាក្យចាប់ពី ៣០០ទៅ៥០០ពាក្យ ហើយចម្លើយត្រូវប្រើឃ្លាក្បាប់សេចក្តីជាប្រយោគពេញលេញ។ សំណេរទាំងនេះរក្សាទុកនៅក្នុងសំណុំឯកសារផ្ទាល់ខ្លួនរបស់អ្នក!

១. តើអ្នកផ្ទាល់ជឿលើតម្លៃមួយណា? ហើយតើអាកប្បកិរិយារបស់អ្នកមានឥទ្ធិពលលើទស្សនៈរបស់អ្នកលើសិស្ស និងអ្នករួមការងារដល់កម្រិតណា?
២. តើទស្សនៈរបស់អ្នកដែលទាក់ទងទៅនឹងគរុកោសល្យដែលផ្អែកលើតម្រូវការភាពចម្រុះគ្នា និងការរួមបញ្ចូលគ្នាបានផ្លាស់ប្តូរដែរឬទេ បន្ទាប់ពីបានអានសេចក្តីផ្តើមដែលទាក់ទងនឹងទ្រឹស្តី?
៣. តើអ្វីខ្លះជាលក្ខណៈសម្បត្តិសំខាន់បំផុតនៃការអប់រំបែបបរិយាបន្នចំពោះរូបអ្នក?
៤. តើអ្នកនឹងផ្តល់មតិ(ដំទាស់)ណាខ្លះចំពោះការដាក់ក្មេងៗដែលមានតម្រូវការអប់រំពិសេស(SEN) ចូលទៅក្នុងថ្នាក់បែបរួមបញ្ចូលគ្នា? តាមយោបល់របស់អ្នក តើអ្វីខ្លះជាបញ្ហាប្រឈម ឬជាការប្រជុំយដែលត្រូវយកមកពិចារណា?

ជំហានទី៤៖ ការរៀបចំសំណុំឯកសារ – គម្រោងការបង្រៀន

ចូរបង្កើតគម្រោងបង្រៀនផ្ទាល់ខ្លួនរបស់អ្នក ដោយស្របទៅតាមថ្នាក់ និងប្រធានបទរបស់អ្នកដែល បានជ្រើសរើសនៅក្នុងម៉ូឌុល១.១, ចូរបង្កើតវិធីសាស្ត្រ ការិះគ្រិះពិចារណា និងវិធានការទាំងឡាយសម្រាប់គំនិតអប់រំរបស់អ្នក ដើម្បីជំរុញអ្នកចូលរួម (អ្នកសិក្សា) ដែលមានតម្រូវការ ចំណុចខ្លាំង និងភាពចុះខ្សោយផ្សេងៗគ្នា

ដើម្បីរៀនចេះដោយមានប្រសិទ្ធិភាពខ្ពស់។ ការរៀបចំសំណុំឯកសារនេះអាចប្រើពី៨០០ទៅ១០០០ពាក្យ។ គម្រោងការបង្រៀននេះរក្សាទុកនៅក្នុងសំណុំឯកសារផ្ទាល់ខ្លួនរបស់អ្នក!

ឧបសម្ព័ន្ធ

កំណត់ត្រាពីសំឡេងៈ AUDIO FILE 4.1.1

គ្រូបង្រៀនៈ ឧទាហរណ៍ ក្នុងថ្ងៃឈប់សម្រាកបុណ្យណូអែល យើងពិភាក្សាអំពីថ្ងៃឈប់សម្រាកដែលគេប្រារព្ធក្នុងរយៈពេលនេះ។ ឥឡូវនេះ ខ្ញុំមិនគួរនិយាយថាបុណ្យណូអែលទេពីព្រោះយើងឃើញថាក្មេងៗបានប្រារព្ធពិធីបុណ្យជាច្រើន។ ដូចជាក្មេងខ្លះប្រារព្ធពិធីបុណ្យណូអែល ចំណែកអ្នកខ្លះទៀតក្នុងខែធ្នូ ប្រារព្ធពិធីបុណ្យហាណុកកា(Hanukah) ហើយអ្នកខ្លះក្រោយមកនិយាយពីពិធី Bowing Day ហើយសម្រាប់ក្មេងៗដ ប៉ុននិយាយពីព្រឹត្តិការណ៍ដែលគេហៅថា អូមីសូកា(Omisoka)។ ហើយបន្ទាប់មកក្មេងៗនៅអាហ្វ្រិកចូលរួមពិធីក្វានហ្សា(Kwanzaa)។ មានក្មេងម្នាក់រស់នៅអាហ្វ្រិក គាត់មិនមែនជាជនជាតិអាហ្វ្រិកទេ។ ប៉ុន្តែក្រោយមកកិច្ចការទាំងឡាយតម្រូវឱ្យកុមាររូបនោះសម្របតាម។ ការយល់ដឹងពីព្រឹត្តិការណ៍ ឬការប្រារព្ធពិធីផ្សេងៗមានលក្ខណៈអស្ចារ្យ។ ខ្ញុំចង់មានន័យថា វាធ្វើឱ្យខ្ញុំភ្ញាក់ផ្អើលដោយបានដឹងពីរឿងរ៉ាវទាំងឡាយដែលក្មេងៗធ្លាប់ដឹង ហើយវាបានជួយនាំមកនូវចំណុចខ្លាំង និងគំនិតរបស់ពួកគេ និងជួយឱ្យពួកគេមានទំនុកចិត្តក្នុងបរិយាកាសចម្រុះមួយ។

អ្នកសម្ភាសន៍ៈ តើអ្នកដោះស្រាយយ៉ាងដូចម្តេចចំពោះភាពចម្រុះគ្នានៅក្នុងថ្នាក់រៀនរបស់អ្នក? សូមអ្នកប្រាប់ពីបទពិសោធផ្ទាល់ខ្លួនរបស់អ្នកបានដែរឬទេ?

គ្រូបង្រៀនៈ បាទបាន នៅដើមឆ្នាំ កិច្ចការដែលខ្ញុំតែងតែឱ្យសិស្សធ្វើគឺខ្ញុំឱ្យក្រដាសពួកគេម្នាក់មួយសន្លឹក ដើម្បីស្វែងយល់ពីជីវប្រវត្តិ ហើយដឹងពីអ្វីដែលគេចាប់អារម្មណ៍ ដែលក្រដាសនេះប្រៀនបានទៅនឹង"សន្លឹកកិច្ចការស្គាល់ខ្ញុំ" យើងធ្វើដូចនេះ។ ខ្ញុំបានធ្វើរឿងនោះនៅដើមឆ្នាំ គឺដើម្បីស្វែងយល់ពីសិស្សហើយក៏ផ្តល់ឱកាសឱ្យពួកគេសួរខ្ញុំពីសំណួរទាំងឡាយដែលពួកគេចង់ដឹងអំពីខ្ញុំ។ ដូច្នេះ នេះជាជំហានដំបូងរបស់ខ្ញុំដែលឆ្ពោះទៅរកការយល់ដឹងពីភាពចម្រុះគ្នា និងជាវិធីដែលខ្ញុំដែលខ្ញុំដោះស្រាយបញ្ហា។

កំណត់ត្រាពីសំឡេងៈ Video File 4.1.1

គ្រូបង្រៀន កៈ ខ្ញុំយកចិត្តទុកដាក់ចំពោះអ្នករៀនយឺត ពីព្រោះសមត្ថភាពរបស់សិស្សតែងតែមិនដូចគ្នានោះទេ។ សិស្សខ្លះជាអ្នកដែលរៀនលឿន។ ចំពោះសិស្សដែលមានពិការភាពខាងការសិក្សា ខ្ញុំតាមដានគ្រប់សកម្មភាព។ ជាពិសេសជាមួយក្មេងៗ ដែលមានបញ្ហាខាងផ្លូវអារម្មណ៍ខ្ញុំធ្វើរបាយការណ៍ទៅកាន់នាយកសាលា អំពីការរីកចម្រើននៅក្នុងរៀនរបស់ពួកគេ។

អ្នកសម្ភាសន៍៖ ដូចដែលអ្នកបាននិយាយរួចមកហើយ សិស្សមានសមត្ថភា និងល្បឿននៃការរៀនខុសគ្នា។

តើអ្នកដោះស្រាយជាមួយរឿងទាំងនេះដោយរបៀបណា? តើអ្នកប្រើវិធីសាស្ត្រប្រភេទណា?

គ្រូបង្រៀន ក៖ ដំហានដំបូងគឺត្រូវដំរុញ និងលើកទឹកចិត្តដល់ពួកគេ។ បន្ទាប់មកត្រូវកំណត់អត្តសញ្ញាណនៃតម្រូវការសិក្សារបស់ពួកគេដើម្បីគាំទ្រតាមតម្រូវការទាំងនោះ។

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

អ្នកអប់រំដែលជោគជ័យត្រូវចេះពីវិធីប្រើប្រាស់ធាតុសំខាន់ៗនៃការបង្រៀនដែលមានគុណភាពខ្ពស់សម្រាប់ថ្នាក់រៀនរបស់ខ្លួន។. ក្នុងម៉ូឌុលនេះ បង្ហាញពីមូលដ្ឋានមួយចំនួនសម្រាប់ការអនុវត្តការបង្រៀនប្រកបដោយប្រសិទ្ធភាព ដើម្បីធានាថាសមាសភាពសំខាន់ នៃការបង្រៀននៅកម្រិតបឋមសិក្សាត្រូវបានពិចារណានៅពេលធ្វើផែនការបង្រៀន អនុវត្តការបង្រៀន វាយតម្លៃដំណើរការបង្រៀន និងរៀន។ តាមរយៈប្រធានបទផ្សេងៗ រួមបញ្ចូលការបង្រៀន និងរៀនសតវត្សទី២១ ការធ្វើកិច្ចតែងការបង្រៀន និងបរិស្ថានសិក្សា អ្នកនឹងតម្រូវឱ្យធ្វើការឆ្លុះបញ្ចាំងពីដំណើរការបង្រៀន និងរៀនដើម្បីសម្រេចលទ្ធផលសិក្សាដោយជោគជ័យ។

សូមសិក្សាដោយរីករាយ!

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

CONTESSA
Contemporary Teaching Skills for South Asia
Co-funded by the Erasmus+ Programme of the European Union

ម៉ូឌុល ៤

ការរួមបញ្ចូលភាពខុសគ្នា៖ គោលវិធីគរុកោលស្យសម្រាប់ភាពចម្រុះគ្នា ភាពមិនស្មើគ្នា និងតម្រូវការពិសេស

៤.២ ការបង្រៀននិងការរៀនក្នុងភាពចម្រុះគ្នា៖ ការរៀបចំ ការយល់ដឹង ការវាយតម្លៃ

ការរួមបញ្ចូលភាពខុសគ្នា-គោលវិធីគរុកោលស្យសម្រាប់ភាពចម្រុះគ្នា ភាពមិនស្មើគ្នា និងតម្រូវការពិសេស៖ ការបង្រៀននិងការរៀនក្នុងភាពចម្រុះគ្នា ការរៀបចំ ការយល់ដឹង ការខាយតម្លៃ

មេរៀននេះត្រូវបានបង្កើតឡើងដោយដៃគូសហការនៅក្នុងគម្រោងនៅ វិធីសាស្ត្របង្រៀនសម័យថ្មីនៅអាស៊ីខាងត្បូង (Contemporary Teaching Skill for South Asia) ហៅកាត់ថា CONTESSA ក្រោមការចូលរួមឧបត្ថម្ភថវិកាដោយកម្មវិធី Eramus+ នៃសហភាពអឺរ៉ុបដែលមានលេខគម្រោង598756-EPP-1-2018-1-AT-EPPKKA2-CBHE-JP-/CONTESSA

អ្នកសម្របសម្រួល :

Sandra Hummel, សាកលវិទ្យាល័យហ្គ្រាស UNIVERSITY OF GRAZ (អូទ្រីស)

ក្រោមការចូលរួមសហការពី :

សាកលវិទ្យាល័យបច្ចេកវិទ្យា ជ្រៃសឺល (អាល្លឺម៉ង់)

សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា (កម្ពុជា)

សាកលវិទ្យាល័យកម្ពុជា (កម្ពុជា)

សាកលវិទ្យាល័យអូអកេននៃប្រទេសស្រីលង្កា (ស្រីលង្កា)

សាកលវិទ្យាល័យយូកំឡូប (ស្រីលង្កា)

អ្នកនិពន្ធ: Regina Elias, Sandra Hummel, Mirjam Brodacz-Geier, Bridget Sheehan

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

សេចក្តីប្រកាស

គណៈកម្មការអឺរ៉ុបសូមធ្វើការគាំទ្រដល់ការបោះពុម្ពឯកសារនេះ ដែលមិនមែនឆ្លុះបញ្ចាំងតែពីទស្សនៈរបស់អ្នកនិពន្ធខាងលើទេ ហើយយើងក៏មិនទទួលខុសត្រូវចំពោះការប្រើប្រាស់ព័ត៌មានដែលដកស្រង់ចេញពីការបោះពុម្ពនេះដោយប្រការណាមួយដែរ។ ព័ត៌មានលម្អិតបន្ថែមនៃមេរៀននេះអាចរកបានដោយបើកចំហ និងឥតគិតថ្លៃនៅលើគេហទំព័រ CONTESSA :

https://contessa_project.eu/

រក្សាសិទ្ធិ

មេរៀននេះត្រូវបានផ្តល់អាជ្ញាប័ណ្ណឱ្យប្រើប្រាស់ក្រោមលក្ខខណ្ឌនៃ Creative Commons

Attribution_ShareAlike 4.0 Internatinal License

(https://creativecommons.org(licenses/by_sa/4.0/)

ដែលអនុញ្ញាតឱ្យប្រើប្រាស់ ចែករំលែក សម្របសម្រួលដើម្បីប្រើប្រាស់បន្ត ចែកចាយផលិតផលសារជាថ្មីក្នុងទ្រង់ទ្រាយណាមួយ ដរាបណាអ្នកប្រើប្រាស់ផ្តល់កិត្តិយសឱ្យបានសមរម្យដល់អ្នកនិពន្ធទាំងអស់។ សូមផ្តល់ជាតំណភ្ជាប់ (link) ទៅកាន់ Creative Commons License និងសូមបញ្ជាក់ផងដែរ បើមានការផ្លាស់ប្តូរណាមួយ។ ប្រសិនបើអ្នកបញ្ចូលគំនិតកែសម្រួល ឬបន្ថែមអត្ថន័យលើមេរៀននេះអ្នកត្រូវតែធ្វើការសុំសិទ្ធិកែសម្រួលឯកសារតាមលក្ខខណ្ឌខាងលើ។ រូបភាព ខ្សែសំឡេង វីដេអូ ក៏ដូចជាឯកសារដទៃទៀតដែលមាននៅក្នុងមេរៀនទាំងនេះមិនត្រូវបានបូកបញ្ចូលទៅក្នុងឯកសារអាជ្ញាប័ណ្ណ Creative Commons ទេ លើកលែងតែមានការអនុញ្ញាតឱ្យប្រើប្រាស់។ ប្រសិនបើផ្នែកណាមួយនៃមេរៀននេះមិនត្រូវបានបញ្ចូលទៅក្នុងឯកសារអាជ្ញាប័ណ្ណ ហើយការប្រើប្រាស់មិនត្រូវបានអនុញ្ញាតដោយច្បាប់ ឬក៏ប្រើប្រាស់លើសពីច្បាប់អនុញ្ញាត ត្រូវតែសុំការអនុញ្ញាតដោយផ្ទាល់ពីម្ចាស់កម្មសិទ្ធិ។

CC BY SA

សេចក្តីផ្តើម

តើវគ្គសិក្សា CONTESSA ជាអ្វី?

វគ្គសិក្សា CONTESSA ជាលទ្ធផលមួយក្នុងចំណោម លទ្ធផលនៃគម្រោងស្តីអំពី "ជំនាញក្នុងការបង្រៀនសម័យថ្មីសម្រាប់អាស៊ីខាងត្បូង" ដែលផ្តល់មូលនិធិរួម ដោយកម្មវិធី Erasmus+ Program នៃសហភាពអឺរ៉ុប។ គោលបំណងរបស់វគ្គសិក្សានេះគឺ ដើម្បីជាការរួមចំណែកក្នុងការបង្កើតកម្មវិធីអប់រំគ្រូបង្រៀនដោយជោគជ័យសម្រាប់គ្រូបឋមសិក្សា ជាពិសេសក្នុងប្រទេសកម្ពុជា និងស្រីលង្កាដែលនឹងនាំដល់ការបង្កើតបានផលវិជ្ជមានរយៈពេលវែងទៅលើប្រព័ន្ធអប់រំទូទៅ។ វាមានសារៈសំខាន់កាន់តែខ្លាំងឡើង សម្រាប់អ្នកអប់រំដែលជោគជ័យក្នុងការតាមឱ្យទាន់សម័យជាមួយនឹងជំនាញ និងវិធីសាស្ត្រក្នុងសម័យថ្មីដើម្បីយកមកប្រើក្នុង និងក្រៅថ្នាក់រៀន។ ដូច្នេះ វគ្គសិក្សា CONTESSA ផ្តល់ជូនមេរៀន ដែលត្រូវបានជ្រើសរើសដោយប្រុងប្រយ័ត្នចំនួន៥ម៉ូឌុល ដែលម៉ូឌុលនីមួយៗមានការផ្តោតការយកចិត្តទុកដាក់ទៅលើចំណុចចំនួនបី ដែលតម្រង់ទៅរកការអភិវឌ្ឍលើជំនាញបង្រៀនបែបសម័យថ្មី។ ម៉ូឌុលទាំងឡាយនិងការផ្តោតការយកចិត្តទុកដាក់របស់វាគឺមានដូចខាងក្រោម៖

ម៉ូឌុល១៖ ការកសាងការយល់ដឹងអំពីការអប់រំនៅបឋមសិក្សា
១.ការបង្រៀន និងការរៀននៅសតវត្សទី២១
២.ការរៀបចំកិច្ចតែងការបង្រៀន និងជំនាញគរុកោសល្យ ៖ គំនិត ឧបករណ៍ និងការអនុវត្ត
៣.ការរៀបចំបរិយាកាសសិក្សា

ម៉ូឌុល២៖ ភាពអស្ចារ្យក្នុងការបង្រៀន៖ សមត្ថភាពជាក់លាក់ប្រកបដោយវិជ្ជាជីវៈរបស់គ្រូបង្រៀនបឋមសិក្សា
១. ការយល់ដឹងពីការបង្រៀន៖ តួនាទី ភារកិច្ច និងមុខងារ
២. ការវាយតម្លៃលទ្ធផលនៃការសិក្សា
៣. ជំនាញវិជ្ជាជីវៈគរុកោសល្យ

ម៉ូឌុល៣៖ការអប់រំឈានមុខគេបែបវិធីសាស្ត្រសិស្ស
មជ្ឈមណ្ឌល៖ ការលើកកម្ពស់ដំណើរការសិក្សាដែលបានបង្កើតរួមគ្នា
១. ការអភិវឌ្ឍលក្ខណៈបុគ្គល និងជំនាញដោះស្រាយបញ្ហា
២. ការអះអាងពីពិភពជីវិតជាក់ស្តែង និងក្តីសង្ឃឹមទៅអនាគត
៣. ការប្តេជ្ញាចិត្តដោយខ្លួនឯង ការផ្តល់សិទ្ធិអំណាច និងប្រសិទ្ធភាពផ្ទាល់ខ្លួន

ម៉ូឌុល៤៖ ការរួមបញ្ចូលភាពខុសគ្នា៖ គោលវិធីគរុកោសល្យសម្រាប់ភាពចម្រុះគ្នា ភាពមិនស្មើគ្នា និងតម្រូវការពិសេស
១. គរុកោសល្យបរិយាបន្ន ៖ គោលវិធី និងយុទ្ធសាស្ត្រ
២. ការបង្រៀន និងរៀនក្នុងភាពចម្រុះគ្នា ៖ ការរៀបចំ ការយល់ដឹងការវាយតម្លៃ
៣. ការគ្រប់គ្រងថ្នាក់រៀនដែលមានភាពចម្រុះគ្នា

ម៉ូឌុល៥៖ ការបង្រៀន និងរៀនតាមបែបឌីជីថល
១. គរុកោសល្យ នៃការសិក្សាពីចម្ងាយ និងបរិយាកាសសិក្សាដែលបំពាក់ទៅដោយបច្ចេកវិទ្យា
២. ប្រព័ន្ធផ្សព្វផ្សាយ និងបច្ចេកទេសឌីជីថល៖ ឧបករណ៍ និងទម្រង់សម្រាប់គោលបំណងនៃការអប់រំ
៣. ការរៀបចំមេរៀន និងដំណើរការបង្រៀនតាមអ៊ីនធឺណែត

នៅពេលដែលបញ្ចប់វគ្គសិក្សានេះ អ្នកចូលរួមនឹងអាចអនុវត្តជំនាញបង្រៀនសម័យថ្មី ដែលទើបទទួលបានធ្វើឱ្យសិស្សទាំងអស់អាចចូលរួមសកម្មភាពក្នុងថ្នាក់ និងរៀនពីវិធីថ្មីៗដើម្បីជួយឱ្យសិស្សឈានទៅដល់ចំណុចសក្តានុពលពេញលេញរបស់ពួកគេ។

តើវគ្គសិក្សា CONTESSA សម្រាប់អ្នកណា?

គម្រោងស្តីពីជំនាញក្នុងការបង្រៀនសម័យថ្មីសម្រាប់អាស៊ីខាងត្បូង មានបំណងក្នុងការលើកតម្កើងជំនាញបង្រៀនសម័យថ្មីសម្រាប់គរុសិស្ស/និស្សិត និងគ្រូបង្រៀនដែលកំពុងបម្រើការក្នុងសាលាបឋមសិក្សានានា។ ឯកសារខាងក្រោមត្រូវបានសម្របសម្រួលជាពិសេសសម្រាប់គរុសិស្ស/និស្សិត។ លើសពីនេះទៅទៀត វគ្គសិក្សា CONTESSA ក៏សម្រាប់អ្នកដែលមានចំណាប់អារម្មណ៍ក្នុងការធ្វើខ្លួនឱ្យទាន់សម័យកាលជាមួយនិងជំនាញបង្រៀនសម័យថ្មី។ ឯកសារមានជាភាសាអង់គ្លេស ហើយក៏មានជាភាសាខ្មែរ ភាសាសិង្ហាលា (Sinhala) និងភាសាតាមីល (Tamil) ដែលប្រើប្រាស់នៅប្រទេសស្រីលង្កា។

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

តើរចនាសម្ព័ន្ធនៃវគ្គសិក្សា CONTESSA មានអ្វីខ្លះ?

ដូចដែលបានលើកឡើងពីមុនរួចហើយ វគ្គសិក្សា CONTESSA នេះរួមមាន៥ម៉ូឌុល ដែលម៉ូឌុលនីមួយៗមានតម្លៃស្មើនឹង៣ ក្រេឌីតតាមប្រព័ន្ធផ្ទេរការសិក្សារបស់អឺរ៉ុប។ ជាការល្អ ម៉ូឌុលទាំងនេះត្រូវបានប្រើប្រាស់រួមគ្នា ពីព្រោះម៉ូឌុលនីមួយៗយោងឯកសារលើម៉ូឌុលដទៃទៀត។ ប៉ុន្តែក្នុងមេរៀន ម៉ូឌុលទាំងនេះក៏ត្រូវបានបង្កើតឡើងក្នុងវិធីមួយ ដែលអាចប្រើបានដោយខ្លួនឯងឯងផ្ទាល់ផងដែរ។ ម៉ូឌុលនីមួយៗមានការផ្តោតលើប្រធានបទចំនួនបី ហើយឯកសារទាំងឡាយក៏បង្កើតឡើងសម្រាប់ការផ្តោតនីមួយៗផងដែរ។ វាបង្កើតឱ្យមានឯកសារសរុបចំនួន១៥ផ្នែកសម្រាប់វគ្គសិក្សា CONTESSA ។ ឯកសារនីមួយៗរួមមានសេចក្តីផ្តើមបែបទ្រឹស្តីចំពោះចំណុចផ្តើម ហើយតាមពីក្រោយដោយលំហាត់អនុវត្ត ដោយផ្អែកលើទ្រឹស្តី។

ជំហាន១ – ទ្រឹស្តី – គឺជាការរំឭកនូវអ្វីដែលបានអាននៅក្នុងសេចក្តីផ្តើមនៃទ្រឹស្តីលំហាត់អនុវត្តទាំងនេះ ត្រួតពិនិត្យការយល់ដឹងនៃអត្ថបទ ដើម្បីប្រាកដថាទ្រឹស្តីជាមូលដ្ឋានដែលត្រូវបានយល់ដឹង។

ជំហាន២ – បទពិសោធ – ផ្តល់ជូននូវឧទាហរណ៍នៃគ្រូបង្រៀនពិតប្រាកដ និងវិធីដែលពួកគាត់អនុវត្តទ្រឹស្តីផ្សារភ្ជាប់នឹងការអនុវត្តជាក់ស្តែង។ ឧទាហរណ៍ទាំងនេះបានភ្ជាប់លំហាត់អនុវត្តទៅនឹងទ្រឹស្តីដែលបានរៀនពីមុនរួចហើយ។ **ជំហាន៣ – ការឆ្លុះបញ្ចាំងដោយខ្លួនឯងផ្ទាល់** – រាប់បញ្ចូលសំណួរបែបឆ្លុះបញ្ចាំងដោយផ្អែកទៅលើចំណុចផ្តោតនីមួយៗ។

ជំហាន៤ – ការអនុវត្ត – គឺជាជំហានចុងក្រោយដែលមានគម្រោងគោលនៃការបង្រៀនមួយត្រូវបានបង្កើតឡើងផ្អែកទៅលើអ្វីដែលបានប្រទះឃើញពីមុននៅក្នុងជំហានទីមួយ និងទីពីរ។

លំហាត់អនុវត្តនៅក្នុងជំហានទីមួយ និងទីពីរអាចត្រូវបានបំពេញដោយផ្ទាល់ក្នុងឯកសារនេះ។ ជំហានទី៣ និងទីបួនជាផ្នែកនៃឯកសារដែលរៀបជាសំណុំដាច់ដោយឡែកដែលនឹងត្រូវបង្កើតដោយបុគ្គលម្នាក់ៗ។ គំរូសម្រាប់ការរៀបចំសំណុំឯកសារ (portfolio) មានជាឯកសារដាច់ដោយឡែកពីគ្នា។

មាតិកា

១. ការរៀបចំមេរៀនបែបបរិយាបន្ន 1

១.១ ការរៀបចំផែនការបែបពីរ៉ាមីត 2

១.២ ជំហានរៀបចំកិច្ចតែងការមេរៀនបែបបរិយាបន្ន 4

២. ការបង្រៀននៅក្នុងថ្នាក់រៀនដែលមានភាពចម្រុះ 6

២.១ រៀបចំទម្រង់ និងបច្ចេកទេសបង្រៀនឱ្យមានភាពចម្រុះ 7

២.២ ជំរុញការរៀនបែបសហការ 11

២.៣ ការបង្រៀនពីសំណាក់មិត្តភក្តិ(សិស្សជួយសិស្ស) 12

២.៤. យុទ្ធសាស្ត្រសម្រាប់សិស្សមានតម្រូវការអប់រំពិសេស 13

៣. ការវាយតម្លៃនៅក្នុងថ្នាក់រៀនបែបចម្រុះ 15

៣.១ ឧបករណ៍វាយតម្លៃ 17

៣.២ ទម្រង់វាយតម្លៃផ្សេងៗ 17

៣.៣ ការវាយតម្លៃលើការអនុវត្តជាក់ស្តែង 18

៣.៤ ការពិចារណាលើការប្រឡងដែលមិនកំណត់ពេលវេលា 18

៣.៥ ការផ្តល់ឱកាសឱ្យសិស្សធ្វើកិច្ចការសារជាថ្មី 19

៣.៦ បញ្ជីត្រួតពិនិត្យការវាយតម្លៃសម្រាប់ថ្នាក់រៀនបរិយាបន្ន 20

៤ ចំណុចគន្លឹះ 21

ឯកសារពិគ្រោះ 23

ជំហានទី១. លំហាត់ពង្រឹងចំណេះដឹង 26

ជំហានទី១.លំហាត់អនុវត្ត ដំណោះស្រាយ 32

ជំហានទី២៖ លំហាត់អនុវត្ត 38

ជំហានទី២ ដំណោះស្រាយ 40
ជំហានទី៣៖ ការរៀបចំសំណុំឯកសារ –សំណួរបែបឆ្លុះបញ្ចាំងផ្ទាល់ខ្លួន 42
ជំហានទី៤៖ ការរៀបចំសំណុំឯកសារ – គម្រោងការបង្រៀន 43
ឧបសម្ព័ន្ធ 43
កំណត់ត្រាពីសំឡេង៖ Audio File 4.2.1 43

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

១. ការរៀបចំមេរៀនបែបបរិយាបន្ន

គ្រូបង្រៀនប្រើពេលច្រើន ចាប់តាំងពីមុនពេលចូលទៅក្នុងថ្នាក់រៀន ហើយត្រូវបន្តជាច្រើនម៉ោងទៀតបន្ទាប់ពីចេញពីថ្នាក់រៀន។ ការបង្រៀនពិតប្រាកដជាផ្នែកតូចមួយនៃការងាររបស់គ្រូតែប៉ុណ្ណោះ។ ដើម្បីឱ្យការបង្រៀនជោគជ័យ ពេលវេលា និងកិច្ចប្រឹងប្រែងត្រូវផ្តោតទៅលើការរៀបចំគម្រោងបង្រៀនដោយប្រុងប្រយ័ត្ន។ នៅក្នុងថ្នាក់រៀនបរិយាបន្ននេះ មានន័យថាការរៀបចំគម្រោងមេរៀនត្រូវតែធ្វើនៅក្នុងវិធីមួយដែលអនុញ្ញាតឱ្យមានបរិយាកាសសិក្សាគាំទ្រ និងជំរុញលើកទឹកចិត្តដល់ការសិក្សារបស់សិស្សគ្រប់រូបជំនួសឱ្យសិស្សភាគច្រើន ព្រោះថាសាលារៀនបរិយាបន្នចែងថា សិស្សគ្រប់រូបមានសមត្ថភាពត្រឹមកម្រិតរបស់ពួកគេ។ ការសន្មតនេះក៏ជួយបង្ហាញពីចំណុចចាប់ផ្តើមនៃការសិក្សារបស់សិស្សម្នាក់ៗនាពេលបច្ចុប្បន្នផងដែរ។

សម្រាប់សិស្សទាំងអស់ ដែលមាននៅក្រុមសិក្សាបែបបរិយាបន្នមេត្រីសិក្សា និងក្រុមមានភាពចម្រុះខុសប្លែកគ្នាច្រើន សមត្ថភាពនៃកម្មវិធីសិក្សាស្នូលដែលមនុស្សពេញវ័យត្រូវទទួលខុសត្រូវ គឺអាស្រ័យនឹងមូលដ្ឋាននៃការអាន ការសរសេរ លេខនព្វន្ត និងធរណីមាត្រ ព្រមទាំងការសិក្សាសង្គម វិទ្យាសាស្ត្រសង្គម បច្ចេកវិទ្យា វិទ្យាសាស្ត្រធម្មជាតិ កីឡា តន្ត្រី និងសិល្បៈ។ ទោះជាយ៉ាងនេះក៏ដោយ វាជារឿងសំខាន់ក្នុងការផ្តោតលើខ្លឹមសារមូលដ្ឋាននៅក្នុងផ្នែកដែលលើកឡើងទាំងនេះ ត្រូវបានរៀបចំជាតំណាក់កាល។ មុខវិជ្ជានីមួយៗគួរតែត្រូវបានបង្កើតឡើងតាមរបៀបមួយ ដែលចាប់ផ្តើមជាមួយនឹងសមត្ថភាពកម្រិតមូលដ្ឋាន។ បន្ទាប់មកត្រូវបង្កើនសមត្ថភាពជាលំដាប់រហូតដល់កម្រិតខ្ពស់។ បណ្តុំសមត្ថភាពដែលកំណត់នៅពេលបញ្ចប់ការសិក្សា មិនបានពណ៌នាពីរបៀបសិក្សារបស់សិស្សតាមវិធីធម្មតានោះទេ ព្រោះសិស្សអាចទទួលបានចំណេះដឹង និងជំនាញតាមវិធីខុសគ្នា រយៈពេល និងរបៀបក៏ផ្សេងៗដែរ។ បណ្តុំទាំងនេះជួយឱ្យគ្រូបង្រៀនអាចរៀបចំសម្ភារសិក្សាសម្រាប់ក្រុមសិស្ស ដែលមាន សមត្ថភាពមិនដូច ឬមិនស្មើគ្នាយ៉ាងមានប្រសិទ្ធភាព។ ត្រង់ចំណុចនេះវាបញ្ជាក់យ៉ាងច្បាស់ថាគំរូស្តង់ដានៃការអប់រំសម្រាប់បរិយាបន្នជាមូលដ្ឋានគ្រឹះសំខាន់ ដែលមានឈ្មោះជាគំរូនៃស្តង់ដារីកចម្រើន និងរៀបចំតាមលំដាប់លំដោយ ផ្តល់ឱ្យអ្នកសិក្សាគ្រប់រូបអាចចូលរួមសិក្សាសមស្របតាមមុខវិជ្ជា ដោយផ្អែកលើចំណុចផ្តើមរបស់អ្នកសិក្សាម្នាក់ៗ។ (Prengel, 2013)

មេត្រីសិក្សា៖

សិស្សមានសិទ្ធិក្នុងការរៀនសូត្រដោយប្រើប្រាស់សក្តានុពលដ៏ពេញលេញរបស់ពួកគេក្នុងបរិយាកាសមួយដែលមានសុវត្ថិភាព និងរួសរាយរាក់ទាក់។ គោលបំណងគឺត្រូវបង្កើនការចូលរួម និងការសិក្សារបស់ក្មេងក្នុងសាលារៀនជាជាងការផ្តោតទៅលើមុខវិជ្ជា និងការប្រឡងទាំងឡាយ។(UNESCO/Booklet One, 2015, p. 4)

សមត្ថភាព:

គុណសភាព ឬកម្រិតនៃចំណេះដឹងគ្រប់គ្រាន់ ការវិនិច្ឆ័យ ជំនាញ ឬភាពខ្លាំង (សម្រាប់កិច្ចការ ឬក្នុងតម្លៃជាក់លាក់ណាមួយ)។ (Merriam-Webster Dictionary, Online)

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

១.១ ការរៀបចំផែនការបែបពីរ៉ាមីត

បណ្តុំសមត្ថភាពដែលអាចអនុវត្តបានគឺ ***ការរៀបផែនការបែបពីរ៉ាមីត*** (Schumm, Vaughn, & Leavell, 1994)។ ពីរ៉ាមីតត្រូវបានបែងចែកជាបីស្រទាប់ដែលស្រទាប់ ក្រោមបង្អស់ជាសមត្ថភាពមូលដ្ឋានចាំបាច់សម្រាប់សិស្សទាំងអស់គ្នាទទួលយក។ ដូច្នេះហើយ"វាមានទំហំធំជាងគេ"(Gould & Vaughn, 2000, p. 365)។ ស្រទាប់ កណ្តាលជាប្រភេទសមត្ថភាពសម្រាប់សិស្សភាគច្រើន ប៉ុន្តែមិនមែនសម្រាប់សិស្សទាំងអស់នោះទេ។ ស្រទាប់លើគេដែលតូចជាងគេបំផុតជាប្រភេទសមត្ថភាពសម្រាប់ សិស្សមួយចំនួនតូចតែប៉ុណ្ណោះ។



រូបភាព១៖ ការរៀបផែនការបែបពីរ៉ាមីត [1]

សៀវភៅសិក្សា និងកម្មវិធីសិក្សារបស់សាលារៀនភាគច្រើន ត្រូវបានរៀបចំឡើងដោយគ្របដណ្តប់លើព័ត៌មានមួយចំនួន ដែលមិនអាចបង្រៀនបានគ្រប់គ្រាន់។ នៅក្នុងដំហាននៃការរៀបចំផែនការ គ្រូបង្រៀនត្រូវធ្វើការសម្រេចចិត្តថាតើសមត្ថភាពណាខ្លះដែលសំខាន់សម្រាប់សិស្សគ្រប់គ្នា ដើម្បីអភិវឌ្ឍការរៀនសូត្រឱ្យបានជោគជ័យ។ "គោលដៅគឺសម្រាប់គ្រូបង្រៀនគិតអំពីគំនិត ឬបញ្ញត្តិសំខាន់ៗបំផុត ដើម្បីអភិវឌ្ឍដំណើរការបង្រៀន ដែលផ្តល់ឱកាសដល់សិស្សទាំងអស់គ្នាពង្រីកចំណេះដឹងរបស់ពួកគេទៅលើគំនិតសំខាន់ថ្មីៗទាំងនេះ " (Schumm, Vaughn, & Leavell, 1994, p. 611) ។ **បញ្ញត្តិ**ទាំងនេះត្រូវបានបង្ហាញជាទូទៅ និងទូលំទូលាយ។ លើសពីនេះទៀតព័ត៌មានលម្អិតជាងនេះជាផ្នែកនៃស្រទាប់កណ្តាល។ ផ្នែកកណ្តាលនៃពីរ៉ាមីត

បញ្ញត្តិ

អ្វីដែលគិតនៅក្នុងចិត្ត[...]ជាគំនិតអរូបី ឬទូទៅដែលសន្និដ្ឋានចេញពីហេតុការណ៍នានា។
(Merriam-Webster Dictionary, Online)

តំណាងឱ្យព័ត៌មានដែលគេចាត់ទុកថាមានភាពសំខាន់បន្ទាប់សម្រាប់ការយល់ខ្លឹមសារ/បញ្ញត្តិ មេរៀន។ វារួមបញ្ចូលនូវគំនិតសំខាន់ៗ ពង្រីកបន្ថែមលើបញ្ញត្តិមូលដ្ឋាន បញ្ញត្តិពាក់ព័ន្ធ ឬបញ្ញត្តិស្មុគស្មាញ" (Schumm, Vaughn, & Leavell, 1994, p. 611)។ គ្រូបង្រៀនសន្មតថាបញ្ញត្តិទាំងនេះនៅតែអាចយល់បានពីសិស្សភាគច្រើនក្នុងថ្នាក់។ មានតែនៅក្នុងស្រទាប់កំពូលលើគេទេដែលគ្រូបង្រៀនដឹងថា សិស្សនៅក្នុងកម្រិតណាមួយនឹងត្រូវបង្រៀនអ្វីនោះ។ ដូច្នេះវាមិនសំខាន់ក្នុងការអភិវឌ្ឍ សមត្ថភាពមូលដ្ឋានទេ ប៉ុន្តែវាអាចបង្កើតនូវព័ត៌មានបន្ថែមបន្ទាប់បន្សំ (Schumm, Vaughn, & Leavell, 1994)។

ចូរចាំទុកថា គោលវិធីសាស្ត្របែបបរិយាបន្នសម្រាប់ការបង្រៀន និងរៀនស្រទាប់ទាំងបីនៃ *ពីរ៉ាមីតរៀបចំផែនការ* មិនត្រូវច្រលំជាមួយនឹង **សមត្ថភាព** សិស្សម្នាក់ៗឡើយ៖ សិស្សគ្រប់គ្នាមានសិទ្ធិទទួលបានសមត្ថភាពនៅក្នុងស្រទាប់ទាំងបី។ ដោយអាស្រ័យទៅលើចំណេះដឹង និងចំណាប់អារម្មណ៍ដែលមានពីមុនមក សិស្សម្នាក់ៗអាចអភិវឌ្ឍសមត្ថភាពបានដល់ស្រទាប់ខាងលើនៃពីរ៉ាមីដក្នុងផ្នែកសមត្ថភាពណាមួយ (Schumm, Vaughn, & Leavell, 1994)។ ផែនការបែបពីរ៉ាមីតមានន័យថាជាឧបករណ៍ ដែលបង្ហាញពីសមត្ថភាពមូលដ្ឋានសំខាន់សម្រាប់អ្នកគ្រប់គ្នា ក្នុងការអភិវឌ្ឍតាមរូបភាពផ្សេងៗ មានន័យថាវាជាគំរូចនាសម្ពន្ធមួយដើម្បីគាំទ្រ ដំណើរការរៀនសូត្រ ដោយមិនបែងចែកសិស្សណាទេ ក៏ប៉ុន្តែអាស្រ័យលើសមត្ថភាពចាំបាច់ដែលពួកគេអាចទទួលយកបាន។ វិធីនេះជួយឱ្យគ្រូបង្រៀនអាចកំណត់ថាតើកន្លែងណាត្រូវសង្កត់ធ្ងន់ និងរកវិធីបង្រៀនសមស្រប ដើម្បីជួយសិស្សសម្រេចបានសមត្ថភាពមូលដ្ឋានសំខាន់ទាំងនេះ។ "ខ្ញុំនិយាយពន្យល់ច្បាស់ៗ ហើយបង្ហាញពួកគេនូវវិធីផ្សេងទៀត ដែលអាចជួយសិស្សរៀនពីវិជ្ជាចាំបាច់បំផុត[...] កិច្ចការនេះបានរុញច្រកខ្ញុំពីអ្វីដែលសំខាន់ ហើយដំរុញឱ្យខ្ញុំប្រឹងប្រែង និងវាយតម្លៃលើអាទិភាពនោះ" (Schumm, Vaughn, & Leavell, 1994, p. 614)។

សមត្ថភាព

កម្លាំងកាយ ឬ ចិត្ត ឬជាជំនាញចាំបាច់ដើម្បីធ្វើរឿងអ្វីមួយ។
(Cambridge Dictionary, online)

មានជម្រើសមួយទៀត ដែលអាចជំនួសការរៀបចំផែនការបែបពីរ៉ាមីត គ្រូបង្រៀនអាចប្រើតារាងមួយដែលមានបីក្រឡាន។ តារាងនេះមានបញ្ចូលឈ្មោះរបស់សិស្សម្នាក់ៗ កិច្ចការ និងសមត្ថភាពចាំបាច់សម្រាប់សិស្សនោះ ដើម្បីឱ្យពួកគេបំពេញកិច្ចការរៀនសូត្របានដោយជោគជ័យ។ តារាងដែលមាន

[1] Adapted from Schumm, Vaughn, & Leavell (1994, p. 610).

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

បីក្រឡេាននេះក៏អាចត្រូបានគេប្រើបន្ថែមទៅលើការរៀបចំផែនការបែបពីរ៉ាមីតផងដែរ (Conderman, 2011) ។

គុណសម្បត្តិសម្រាប់សិស្សគឺ គ្រូបង្រៀនរបស់ពួកគេ ត្រូវពន្យល់ឱ្យច្បាស់នូវអ្វីដែលពួកគេចាំបាច់ត្រូវរៀន ដែលជាទិដ្ឋភាពសំខាន់នៅពេលរៀបចំផែនការបង្រៀនណាមួយ ពីព្រោះវាច្បាស់លាស់ចំពោះអ្នកថា តើហេតុអ្វីបានជាអ្នកផ្តល់ឱ្យសិស្សនូវសកម្មភាព ឬកិច្ចការណាមួយនោះ និងថាតើត្រូវវាយតម្លៃដូចម្តេច។ ប៉ុន្តែសម្រាប់សិស្សមួយចំនួនទៀត មិនចាំបាច់ច្បាស់លាស់ទេ។ ដើម្បី ធ្វើឱ្យថ្នាក់រៀនរបស់អ្នកមានលក្ខណៈបរិយាបន្នសម្រាប់សិស្សទាំងអស់ [...] ចូរព្យាយាមធ្វើឱ្យមានតម្លាភាពតាមដែលអាចធ្វើទៅបានជាមួយសិស្សរបស់អ្នក លើអ្វីដែលពួកគេបានធ្វើ និងពីមូលហេតុដែលត្រូវឱ្យពួកគេធ្វើ (ឧទាហរណ៍ តើពួកគេនឹងរៀនអ្វី?) និងពីរបៀបវាយតម្លៃកិច្ច-ការរបស់ពួកគេ (Sanger, 2020, p. 44) ។

១.២ ដំហានរៀបចំកិច្ចតែងការមេរៀនបែបបរិយាបន្ន

- ចូរគិតពីមេរៀនជាក់លាក់ និងសមត្ថភាពចាំបាច់។ ចូរប្រើផែនការបែបពីរ៉ាមីតដើម្បីសម្រេចចិត្តថាសមត្ថភាពមួយណាដែលចាំបាច់សម្រាប់សិស្សទាំងអស់នៅក្នុងថ្នាក់។ សមត្ថភាពណាខ្លះអាចសម្រេចបានសម្រាប់តែសិស្សភាគច្រើន និងសមត្ថភាពណាខ្លះសម្រាប់សិស្សពីរ ឬបីនាក់។ ចូរបង្កើតវត្ថុបំណងសិក្សាសម្រាប់ស្រទាប់ពីរ៉ាមីតនីមួយៗ។
- ចូរគិតដល់សិស្សម្នាក់ៗ និងបញ្ហាណាខ្លះដែលអាចកើតមានឡើងនៅពេលបង្រៀន។ សម្រាប់សិស្សម្នាក់ៗ អ្នកគួរតែពិចារណាទៅលើលក្ខខណ្ឌសិក្សានិងតម្រូវការរបស់គាត់ៈ តើខ្ញុំត្រូវផ្តល់ដល់សិស្ស “ក” នូវសម្ភារៈ/វិធីសាស្ត្រ ប្រភេទណាដើម្បីឱ្យគាត់អាចអភិវឌ្ឍសមត្ថភាពបាន? សិស្ស “ខ” មានចំណេះដឹងមានស្រាប់លើខ្លឹមសារមេរៀន។ តើខ្ញុំអាចជួយសិស្ស “ខ” ឱ្យប្រើប្រាស់ចំណេះដឹងរបស់គាត់តាមវិធីគរុកោសល្យមានប្រសិទ្ធិភាពបានយ៉ាងណា? តើសិស្សរបស់ខ្ញុំទាំងអស់ ចេះពាក្យដែលពួកគេចាំបាច់ដើម្បីយល់ពីបញ្ញត្តិ ដែលនឹងត្រូវបង្រៀនដែរឬទេ? និងសួរខ្លួនឯងថាតើសម្ភារឧបទ្ទេសអាចត្រូវបានប្រើប្រាស់សម្រាប់សិស្សគ្រប់គ្នាឬទេ? ។ ឧទាហរណ៍ៈ កន្ត្រែសម្រាប់សិស្សដែលប្រើដៃស្តាំ គឺពិបាកសម្រាប់សិស្ស

ក្នុងការអប់រំ វត្ថុបំណងសិក្សា គឺជាប្រយោគសង្ខេប ដែលពិពណ៌នានូវអ្វីដែលគេរំពឹងថាសិស្សនឹងអាចរៀនចេះនៅចុងឆ្នាំសិក្សា ពេលបញ្ចប់មុខវិជ្ជា មេរៀន គម្រោង វគ្គសិក្សា ឬនៅពេលបញ្ចប់ការសិក្សាក្នុងរយៈពេលណាមួយ។ (The Glossary of Education Reform, 2014, online)

ដែលប្រើដៃឆ្វេង(Carey, 2016) ។ សរុបរួមទៅ ចូរបង្កើតបរិយាកាសសិក្សាមួយដែលមានការសហការនិងគួរជាទីចាប់អារម្មណ៍សម្រាប់សិស្សគ្រប់គ្នា។

- ចូរកំណត់សម្ភារៈឧបទ្ទេស ដែលអាចប្រើក្នុងស្រទាប់ពីរ៉ាមីតនីមួយៗ ដើម្បីបង្កើនសមត្ថភាពពីផ្នែកបាត នៃពីរ៉ាមីតបានពីសំណាក់សិស្សគ្រប់គ្នា។ ចូរសួរខ្លួនអ្នកផ្ទាល់ថា៖ តើសិស្ស “គ” ដែលមានបញ្ហាក្នុងការអាន អាចនឹងរៀនបញ្ញត្តិដោយឯករាជ្យខ្លួនឯងបានដែរឬទេ បើគេផ្តល់តែអត្ថបទអានមួយឱ្យ? តើខ្ញុំចាំបាច់ត្រូវផ្តល់សម្ភារៈក្រៅពីអត្ថបទបន្ថែមឱ្យសិស្ស “គ” ដើម្បីទទួលបានសមត្ថភាពដែលចាំបាច់ដែរឬទេ? តើខ្ញុំអាចយកសម្ភារៈដែលអាចអនុវត្តជាក់ស្តែងបានដូចជា ដុំថ្ម ឬដំបង/ចង្កឹះដើម្បីរៀនពីរូបរាងតាមគណិតវិទ្យា សំបកខ្យង ឬគ្រំ ឬស្បែកសម្រាប់គម្រោងសិល្បៈ ឬគ្រប់ពូជដែលយកពីរុក្ខជាតិ ដើម្បីសិក្សាពីការលូតលាស់របស់វាបានទេ? ចូរ “ប្រើសម្ភារៈច្រើនមុខប្លែកៗពីគ្នា សម្រាប់មុខវិជ្ជាទាំងអស់ដូចជា សម្ភារឧបទ្ទេសសម្រាប់មុខវិជ្ជាគណិតវិទ្យា ធ្វើពីក្រដាសកាសែត ឬស្លាក បាដា និងតុក្កតាសម្រាប់ថ្នាក់រៀនភាសា” (UNESCO /Booklet One, 2015, p. 7) ។
- មេរៀនត្រូវរៀបចំឱ្យទាក់ទងទៅនិងគំនិតសំខាន់ៗ ជាជាងបង្កើតផ្នែកព័ត៌មាន ដែលមិនទាក់ទងគ្នា។ តាមវិធីនេះ សិស្សមានគំនិតរួមមួយ ដែលពួកគេអាចដាក់ចូលនូវព័ត៌មានថ្មីៗជាមួយនឹងអ្វី ដែលគេបានចេះដឹងស្រាប់។ គំនិតសំខាន់អាចជាអ្វីមួយដូចជា “ទឹកសំខាន់ចំពោះជីវិត” ហើយប្រធានបទអាចជា “ថ្ងៃនេះយើងនឹងរៀនអំពីរបៀបរក្សាទឹកឱ្យបានស្អាត”។ (UNESCO/Booklet Four, 2015, p. 15) ស្របទៅនឹងទម្រង់ពីរ៉ាមីត ចូររៀបចំមេរៀនរបស់អ្នកជាបណ្តើរៗ ចេញពីភាពសាមញ្ញទៅរកភាពស្មុគស្មាញបន្តិច ចេញពីគំនិតទស្សនៈដែលធំទូលាយ ទូទៅប្រែទៅជាគំនិតជាក់លាក់ និងពីឧទាហរណ៍បែបរូបីទៅជាឧទហរណ៍អរូបី។ ចូរបង្ហាញសកម្មភាពទាំងឡាយ ដែលជាផ្នែកៗ ឱ្យមានលំដាប់លំដោយនឹងគ្នា។
- ចូរសម្រេចចិត្តពីវិធីបង្កើនសមត្ថភាពសិស្សរបស់អ្នក ឱ្យឈានទៅចំណុចជោគជ័យ និងត្រួតពិនិត្យតាមដានការរៀនដោយឯករាជ្យរបស់ពួកគេ។ (Schumm, Vaughn, & Leavell, 1994; Gould & Vaughn, 2000)

រូបភាព២៖ ទម្រង់រៀបចំផែនការ

២. ការបង្រៀនៅក្នុងថ្នាក់រៀនដែលមានភាពចម្រុះ

ដូចដែលបានឃើញពីមុន ការអប់រំបរិយាបន្នមានន័យថាតម្រូវការរបស់សិស្សម្នាក់ៗត្រូវបានពិចារណា។ សាវតាចម្រុះត្រូវបានចាត់ទុកជាភាពសម្បូរបែប ព្រោះសិស្សម្នាក់ៗចូលមកដល់ក្នុងថ្នាក់រៀនដោយមានចំណុចខ្លាំងរៀងៗខ្លួនដែលអាចផ្តល់ជាផលប្រយោជន៍ដល់អ្នកសិក្សាដទៃទៀត។ សិស្សម្នាក់អាចនឹងមានចំណេះដឹង ដែលមានស្រាប់លើខ្លឹមសារណាមួយ ដែលអាចប្រើបាននៅក្នុងថ្នាក់ ដោយដាក់សិស្សម្នាក់នេះអង្គុយ ជាមួយសិស្សម្នាក់ផ្សេងទៀតដែលមានចំណេះដឹងស្រាប់តិចជាងទៅ លើខ្លឹមសារត្រូវសិក្សា។ គ្រូបង្រៀនត្រូវធ្វើការឆ្លុះបញ្ចាំងទៅលើសិស្សម្នាក់ៗ ដើម្បីឱ្យរបៀបបង្រៀនរបស់គាត់អាចបំពេញតម្រូវការរបស់សិស្សម្នាក់ៗបាន។ "កម្រិតនៃការត្រៀមខ្លួនរបស់សិស្ស ចំណាប់អារម្មណ៍ និងវិធីសិក្សារបស់ពួកគេ" (Tichá et al., 2018, p. 107) ជាទិដ្ឋភាពដែលត្រូវពិចារណា នៅពេលជ្រើសរើសយុទ្ធសាស្ត្របង្រៀនស្របតាមគរុកោសល្យ។

ខាងក្រោមនេះ ជាការបង្ហាញពីយុទ្ធសាស្ត្រសម្រាប់ការបង្រៀន និងការរៀននៅក្នុងថ្នាក់រៀនបែបចម្រុះ។

ការបង្ហាញដែលមានអត្ថន័យច្រើន៖ បង្ហាញរូបភាព គូសរូបលើក្តារខៀន បង្ហាញ ឬបញ្ចាំងវីឌីអូ បង្ហាញវត្ថុជាគំរូ ចែករំលែកបទពិសោធផ្ទាល់ខ្លួនអ្នកនិងបទពិសោធរបស់សិស្ស អនុញ្ញាតឱ្យសិស្សទាយ ផ្តល់ជូនការសង្ខេបជាទម្រង់សរសេរ ផ្តល់ជូនពាក្យដែលចាំបាច់ សំណង់ប្រយោគការនិទានរឿងផ្ទាល់មាត់ អញ្ជើញភ្ញៀវជាវាគ្មិន (Johnstone, Avagyan & Marutyan, 2018)

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

២.១ រៀបចំទម្រង់ និងបច្ចេកទេសបង្រៀនឱ្យមានភាពច្រុះ

ស្របជាមួយយុទ្ធសាស្ត្រនៃការរៀបចំជាសកលសម្រាប់ការរៀនសូត្រ (UDL) ដែលបង្ហាញក្នុងអត្ថបទ៥.១គ្រូបង្រៀនគួរតែពិចារណាមធ្យោបាយជាច្រើននៃការភ្ជាប់ទំនាក់ទំនង ការបង្ហាញ និងសម្មភាព/មតិយោបល់៖

នៅពេលដែលរៀបចំមេរៀន ចូរពិចារណាទៅលើបញ្ហាអ្វីខ្លះដែលអាចកើតឡើងចំពោះប្រភេទខុសគ្នានៃអ្នកសិក្សា ក្នុងការទទួលបាននិងប្រើប្រាស់ព័ត៌មាននៅក្នុងថ្នាក់របស់អ្នក។ តើសិស្សដែលមិនសូវយល់ភាសាដែលទាក់ទងនឹងវប្បធម៌ ឬគរុកោសល្យអាចចូលរួមបានដោយរបៀបណា? តើសិស្សដែលមានបញ្ហាភ្នែក ឬខ្វះខាតការយកចិត្តទុកដាក់អាចនឹងប្រឈមជាមួយនឹងថ្នាក់រៀនរបស់អ្នកដោយរបៀបណា? (Sanger, 2020,p. 46)

ឧទាហណ៍ខាងក្រោម នឹងផ្តល់នូវយុទ្ធសាស្ត្រសម្រាប់ការបង្ហាញដែលមានប្រយោជន៍ច្រើន៖

- ប្រសិនបើការបង្រៀនរបស់អ្នកប្រើរូបភាព គ្រូត្រូវពន្យល់បន្ថែមដោយប្រើពាក្យសម្តី។ ពន្យល់បណ្តើរបង្ហាញរូបភាពបណ្តើរ។ ឱ្យសិស្សពណ៌នាជាពាក្យសម្តី ឬសរសេរពីអ្វីដែលពួកគេបានឃើញ ហើយមានន័យដូចម្តេច។ ទង្វើនេះនឹងសម្រួចការយល់ដឹងរបស់សិស្សទៅលើគំនិតដែលគេព្យាយាមផ្តល់ឱ្យ ហើយប្រើប្រាស់ព័ត៌មានតាមរយៈរូបភាព។ សម្រាប់សិស្សដែលមានបញ្ហាភ្នែក[...] ការស្តាប់មិត្តភក្តិពិពណ៌នាសម្ភារៈជារូបភាពនឹងជួយឱ្យពួកគេយល់ពីអត្ថន័យ ទោះជាពួកគេមិនអាចមើលឃើញរូបភាពដូច ដែលមិត្តភក្តិរបស់ពួកគេក៏ដោយ។ (Sanger, 2020, p. 46)
- ចូរពិចារណាលើការរួមបញ្ចូលគ្នារវាងអត្ថបទនឹងរូបភាព។ សិស្សដែលអសមត្ថភាពខាងផ្លូវស្មារតី ជារឿយៗអាចធ្វើកិច្ចការធម្មតាបាន តែកិច្ចការទាំងនេះត្រូវបានដាក់បង្កប់ជាមួយនឹងវត្ថុគេធ្លាប់ស្គាល់ និងប្រកពពិត។ ប៉ុន្តែនៅក្នុងពេលកាត់ផ្តាច់ចេញពីតថភាព ពួកគេមានបញ្ហាក្នុងការបកស្រាយការងារទាំងនោះជាទម្រង់បែបសញ្ញា។ ពួកគេប្រហែលជាត្រូវត្រឡប់ទៅរកឧទាហរណ៍ជាក់ស្តែងវិញ ឬពួកគេអាចសុំឱ្យ គ្រូបង្រៀនបកស្រាយទៅវិញទៅមកពីស្ថានភាពធម្មជាតិ ដែលជានិមិត្តសញ្ញាទាំងនេះ។ ដោយយោងទៅតាម Schmit et al. (2000) ការរួមបញ្ចូលគ្នារវាងរូបភាពជាមួយនឹងការណែនាំជាពាក្យសម្តីធ្វើឱ្យការបង្ហាញមានថាមពលជាងមុន។

ការទាក់ទាញដែលមានន័យច្រើន៖ សិស្សធ្វើការជាក្រុម ឬជាមួយដៃគូរសិស្សចែលរំលែករឿងផ្ទាល់ខ្លួន សិស្សធ្វើការលើសកម្មភាពផ្គុំរូប សិស្សសាកល្បងទៅលើគំនិតដែលបានរៀន សិស្សវាយតម្លៃខ្លួនឯងទៅលើការចូលរួមរបស់ពួកគេ សិស្សអាចសម្រេចចិត្តលើទម្រង់នៃការចូលរួមផ្ទាល់ខ្លួនរបស់ពួកគេ។ (Johnstone, Avagyan & Marutyan, 2018)

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

Healy, Aram, Horwitz និង Kessler (1982) បានរកឃើញលទ្ធផលដើមដំបូងស្របទៅតាម Schmit et al. (2000) ដែលអះអាងថាសិស្សបានជោគជ័យចំពោះការយល់ពីល្អះ នៅពេលដែលមានរូបភាពបង្ហាញជាគន្លឹះ។ សិស្សជាច្រើនដែលអសមត្ថភាពខាងស្មារតី ទាមទារឱ្យមានសម្ភារៈ និងការគាំទ្របន្ថែមដើម្បីធ្វើឱ្យការសិក្សាជាបន្តបន្ទាប់ របស់ពួកគេទទួលបានជោគជ័យ។

- អនុញ្ញាតឱ្យសិស្សជ្រើសរើសសម្ភារសិក្សា ដែលខុសប្លែកគ្នាជាទម្រង់បែបបទ (ដូចជា អត្ថបទ រូបភាព សំឡេង រូបភាពតាមកញ្ចក់ស្ត្រីន) និងកម្រិត។ (Jordan & McGhie-Richmond, 2014)
- "ចូរប្រើគំរូម៉ូដែល និងវត្ថុដទៃទៀតដើម្បីបង្រៀនគណិតវិទ្យា ដែលអាចធ្វើឱ្យមានលទ្ធផលល្អដល់ជំនាញខាងចលនារបស់សិស្ស និងការយល់ដឹងតាមរយៈរូបភាពរបស់ពួកគេ។" (UNESCO/Booklet Four, 2015, p. 20)
- "វត្ថុដែលមានរូបរាងខុសៗគ្នាជួយឱ្យសិស្សយល់ពីមាឌ ចំណុះ ទំហំ និងរាងបែបធរណីមាត្រ។ វត្ថុទាំងនេះអាចរួមបញ្ចូលជារាងគូប សាជីជ្រុង(ពីរ៉ាមីត) ចតុកោណកែង ស៊ីឡាំង និងរូបរាងដទៃទៀត ដែលធ្លាក់ចេញពីឈើ ឬធ្វើឡើងដោយក្រដាសរឹងៗ។ ចូរឱ្យសិស្សធ្វើការជាក្រុម ដើម្បីរកមើលវត្ថុក្នុងសាលា ឬបរិស្ថានជុំវិញ ដើម្បីស្វែងរកប្រភេទរូបរាងវត្ថុផ្សេងៗ ដែលប្រើប្រាស់ក្នុងជីវិតប្រចាំថ្ងៃ។" (UNESCO/Booklet Four, 2015, p. 62)

ឧទាហរណ៍ខាងក្រោមផ្តល់នូវយុទ្ធសាស្ត្រសម្រាប់ការទាក់ទាញដែលមានន័យច្រើន៖

- ចូរប្រើប្រាស់វិធីបង្រៀនគ្រូមជ្ឈមណ្ឌលឱ្យតិច។ (Moore, Gilbreath & Maiuri, 1998)
- មុននឹងចាប់ផ្តើមប្រធានបទថ្មី អ្នកចាំបាច់ត្រូវសួរសិស្សថាពួកគេចេះអ្វីរួចហើយ អំពីប្រធានបទនេះ។ ការសួរសំណួរនេះ ជួយសិស្សឱ្យភ្ជាប់ចំណេះដឹងទៅនឹងប្រធានបទ ដែលធ្លាប់បានដឹង និងជួយឱ្យពួកគេយល់ និងរៀនបានឆាប់រហ័សជាងមុន។ ចំណេះដឹងភាគច្រើនរបស់ពួកគេប្រហែលជាបានរៀននៅក្រៅថ្នាក់ និងក្នុងសហគមន៍។ ព័ត៌មាននេះនឹងជួយសិស្សភ្ជាប់ពីអ្វីដែលពួកគេចេះដឹងរួចស្រេចពីជីវិតប្រចាំថ្ងៃទៅនឹងចំណេះដឹងថ្មី ដែលយើងកំពុងតែព្យាយាមបង្រៀនពួកគេ។ លើសពីនេះទៅទៀត សិស្សមួយចំនួនអាចមានជំនាញលើប្រធានបទមួយចំនួនដូចជាការនេសាទ ឬការដាំ

សកម្មភាព/ការសម្តែងមតិដែលមានន័យច្រើនការរាយការណ៍ដោយផ្ទាល់មាត់ ជាទម្រង់នៃការសរសេរ (សំណេរតែងសេចក្តីកំណាព្យ បទចំរៀង..) ការកត់ត្រាការសន្ទនាជាក្រុមតូច ការសន្ទនារវាងសិស្សនិងគ្រូបង្រៀនការធ្វើបទបង្ហាញទៅកាន់ថ្នាក់រៀន (Johnstone,Avagyan & Marutyan, 2018)

បន្លែ ហើយសិស្សទាំងនេះគួរតែត្រូវបានផ្តល់ឱកាសឱ្យបង្ហាញពីចំណេះដឹងរបស់ពួកគេ សម្រាប់ជាផលប្រយោជន៍អ្នកដទៃនៅក្នុងថ្នាក់។ (UNESCO /Booklet Four, 2015, p. 126)

- អនុញ្ញាតឱ្យសិស្សរៀនដោយ "ការធ្វើសកម្មភាពជាក់ស្តែង និងទទួលបានបទពិសោធ" (UNESCO/Booklet Four, 2015, p. 126)។ សកម្មភាពទាំងឡាយដែលសិស្សចូលរួមពិតជាពាក់ព័ន្ធទៅនឹង បទពិសោធជីវិតប្រចាំថ្ងៃ ដែលអនុវត្តផ្ទាល់។ តាមរយៈការបង្កើតទំនាក់ទំនងរវាង គំនិតបែបអរូបីទៅនឹងបទពិសោធជីវិតពិត គេអាចធានាបាននូវការយល់បានស៊ីជម្រៅដែលជាការប្តូរវេនគ្នា ដែលទទួលបានគំនិតប្រសើរដើម្បីប្រើប្រាស់ក្នុងជីវភាពនៅពេលបន្ទាប់(UNESCO/Booklet Four, 2015, p. 126) "ក្នុងករណីទាំងអស់អត្ថន័យខ្លឹមសារគឺនៅតែដូចគ្នាដដែល ប៉ុន្តែសិស្សអាចធ្វើកិច្ចការក្នុងវិធីផ្សេងខុសប្លែកពីគ្នា" (Johnstone, Avagyan & Marutyan, 2018, p. 17)។
- សម្រាប់សិស្សនៅថ្នាក់បឋមសិក្សា ការលេងបានផ្តល់ឱកាសជាច្រើនក្នុងការសិក្សាលើពុទ្ធិបញ្ញា និងសង្គម។ ការលេងល្បែងសិក្សាជារង្វង់ ល្បែងអន្តរសកម្ម ល្បែងអប់រំ ល្បែងសហការ ល្បែងប្រកួតប្រជែងដោយយុត្តិធម៌ ល្បែងដែលធ្វើចលនា ការសម្តែងដោយសេរី និងល្បែងបែបដើរតួ អាចត្រូវបានបញ្ចូលទៅក្នុងមេរៀនបែបរួមបញ្ចូលគ្នា។ (Prengel, 2013)
- ចូរសរសេរពាក្យចេញពីបទចម្រៀងមួយដែលសិស្សចេះរួចជាស្រេច ឬក៏ទើបបានរៀនរួច។

ចូរសង្កេតមើលថាតើនរណាអាចទាយបាន ថាពាក្យណាមានន័យយ៉ាងដូចម្តេច? ពាក្យថ្មីៗក្នុងបទចម្រៀងត្រូវណែនាំសិស្សឱ្យចេះច្បាស់រួចជាស្រេច។ ការច្រៀងគឺជាផ្នែកមួយនៃការសិក្សា ព្រោះវាជួយដល់ការដកដង្ហើមរបស់សិស្ស បង្កើនពាក្យថ្មីៗ បង្កើតបានជាចង្វាក់ ពាក្យចួន និងបង្កើតសាមគ្គីភាពក្នុងថ្នាក់។

- សម្រាប់សិស្សតូចៗ បិទស្លាកឈ្មោះវត្ថុនៅក្នុងបន្ទប់ (ជាភាសាមួយ ឬច្រើនភាសាដែលសិស្សប្រើ)ឧទាហរណ៍ តុ កៅអី ជញ្ជាំង ឈ្មោះរបស់សិស្សនៅលើតុ កៅអី... ។ បង់លេខតាមក្រុមនីមួយៗទៅតាមវត្ថុៗល។ តើសិស្សណាខ្លះអាចដាក់វត្ថុទាំងនោះ ត្រូវតាមពាក្យដែលតំណាងឱ្យ?

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

(UNESCO/Booklet Four, 2015, p. 14) ឧទាហរណ៍ខាងក្រោមផ្តល់ជូននូវយុទ្ធសាស្ត្រសម្រាប់សកម្មភាព/ការសម្តែងមតិដែលមានន័យច្រើន៖

- នៅពេលឈានទៅដល់ការសួរ និងការឆ្លើយសំណួរ ចូរផ្តល់ឱកាសឱ្យសិស្សឆ្លើយតបតាមវិធីផ្សេងៗពីគ្នា។ ពួកគេអាចឆ្លើយតបតាមរយៈទម្រង់នៃការនិយាយឬការសរសេរ។ ភាសាសញ្ញា ឬការប្រើរូបភាពក្នុងទម្រង់ជារូបគំនូរ ក៏បាន។ សិស្សមួយចំនួនអាចមានអារម្មណ៍ថា ងាយស្រួលជាងក្នុងការបង្ហាញពីគំនិតរបស់ពួកគេជាបុគ្គល។ សិស្សដទៃទៀតប្រហែលជាពេញចិត្តនឹងការសន្ទនាជាមួយគ្រូបង្រៀន ឬមិត្តរួមថ្នាក់។ "គំនិតសំខាន់នៃការឆ្លើយតបប្រកបដោយភាពបត់បែន ធ្វើឱ្យ សិស្សអាចបង្ហាញចំណេះដឹងតាមវិធី ដែលល្អបំផុតសម្រាប់គេ"។(Johnstone, Avagyan, & Marutyan, 2018, p. 18)
- "យើងចាំបាច់ត្រូវសួរសំណួរល្អៗ ដើម្បីឱ្យសិស្សពន្យល់ពីគំនិតរបស់ពួកគេជាជាងការសួរសំណួរដែលមានចម្លើយត្រឹមតែ "បាទ/ចាស" ឬ "ទេ"។ យើងចាំបាច់សួរសំណួរបើកដើម្បីឱ្យសិស្សបញ្ជាក់ពីទស្សនៈ គំនិតមតិយោបល់។ ឧទាហរណ៍ យើងអាចសួរថា "តើអ្នកគិតដូចម្តេច?" (UNESCO/Booklet Four, 2015, p. 15)
- ហៅសិស្សឱ្យនិយាយ ឬសរសេរ អំពីគំនិតលើមុខវិជ្ជាគណិតវិទ្យាដែលភ្ជាប់ការគិតបែបនិយាយទៅជាការយល់ពីគំនិតមេរៀនគណិតវិទ្យា។ ឱ្យសិស្សគូររូបភាពដែលដកស្រង់ចេញពីរឿងដែលបានអាន។ ពួកគេអាចភ្ជាប់ការគិតតាមបែបរូបភាពទៅជាពាក្យសម្តី ឬព្រឹត្តិការណ៍នៅក្នុងសាច់រឿង។ ដឹកនាំសិស្សបង្កើតជាផែនទីគំបន់ជុំវិញសាលារៀន ភ្ជាប់បទពិសោធទៅជាគំនិតបែបរូបភាព និងបែបគណិតវិទ្យា។ នៅពេលសិស្សរៀនពីសហគមន៍របស់ពួកគេ ចូរគូសបញ្ជាក់ពីបញ្ហាដែលមាន និងប្រើជំនាញរបស់ពួកគេដោយសហការគ្នា ដើម្បីផ្តល់ជាដំណោះស្រាយចំពោះបញ្ហាទាំងនេះ សិស្សអនុវត្តពីអ្វីដែលពួកគេរៀនក្នុងសាលា។ ក្រៅពីការអប់រំដ៏ល្អ ដំណើរការនេះជួយឱ្យសហគមន៍យល់ពីកិច្ចការរបស់សាលារៀន ហើយពួកគេអាចនឹងមានការលើកទឹកចិត្តច្រើនជាងមុនដើម្បី ជួយគាំទ្រការងាររបស់គ្រូបង្រៀន […](UNESCO/Booklet Four, 2015, p. 20)

២.២ ដំណើរការរៀនបែបសហការ

ការរៀនបែបសហការកើតឡើង នៅពេលដែលសិស្សចែករំលែកទំនួលខុសត្រូវនិងធនធានដែលមានស្រាប់ នៅពេលពួកគេធ្វើការ ដើម្បីឆ្ពោះទៅកាន់គោលដៅរួម។ ការអភិវឌ្ឍជំនាញក្រុមសហការ ទាក់ទងពេលវេលា ការអនុវត្ត ហើយនិងការពង្រឹងឥរិយាបទ។ គ្រូបង្រៀនដើរតួសំខាន់ក្នុងការបង្កើតបរិយាកាសគាំទ្រនៅពេលសិស្សមានអារម្មណ៍ថាជួបបញ្ហា និងបរិយាកាសមួយដែលគំនិតសិស្សទាំងអស់ត្រូវបានគេឱ្យតម្លៃ។ ការងារជាក្រុមបែបសហការអាចជួយអ្នកសិក្សាតាមរយៈការបង្កើនការយល់ដឹង ភាពសប្បាយរីករាយ និងឥរិយាបទបែបវិជ្ជមានចំពោះការងារ និងខ្លួនគេផ្ទាល់។ ប៉ុន្តែដើម្បីឱ្យសិស្សទទួលផលប្រយោជន៍ពីសកម្មភាពក្រុម ពួកគេត្រូវការឱកាសដើម្បីអភិវឌ្ឍជំនាញនិងតួនាទី។ បើសិស្សខ្លះចំណាយពេលក្នុងការពិភាក្សាគ្នាយូរ នោះវាអាចនឹងធ្វើឱ្យអ្នកដទៃទៀតខកឱកាសក្នុងការបញ្ចេញគំនិតយោបល់។ ក្នុងបរិបទអប់រំបែបបរិយាបន្ន ការជូនព័ត៌មានដល់ឪពុកម្តាយ ពីការផ្លាស់ប្តូរវិធីសាស្ត្រក្នុងការបង្រៀននិងការរៀនជាការចាំបាច់ណាស់។ ឧទាហរណ៍ពួកគាត់ក៏អាចជួយបង្កើតសម្ភារៈជំនួយក្នុងការរៀន ឬក៏ល្បែងផ្សេងៗជាដើម។ ដូច្នេះពួកគាត់យល់ពីអ្វីដែលគ្រូបង្រៀនកំពុងព្យាយាមធ្វើ និងគាំទ្រដល់កូនៗរបស់គាត់។ជំនាញបែបសហការ ត្រូវបានគេអភិវឌ្ឍយ៉ាងមានប្រសិទ្ធិភាពបំផុតក្នុងបរិបទអប់រំសំខាន់ៗ។ សកម្មភាពដែលមានលក្ខណៈបើកចំហ ហើយតម្រូវឱ្យមានការគិតទូលំទូលាយ(ដូចជាការដោះស្រាយបញ្ហា) គឺមានលក្ខណៈសមស្របក្នុងការអភិវឌ្ឍជំនាញក្នុងក្រុមបែបសហការ[...]

- ការសហការ ជួយអ្នកសិក្សាឱ្យធ្វើការរួមគ្នាបាន ព្រមទាំងចែករំលែកទំនួលខុសត្រូវ សម្ភារៈ តួនាទី និងឱកាសការសិក្សា។
- គេអាចបែងចែកតួនាទី និងការទំនួលខុសត្រូវឱ្យសិស្សតាមក្រុមតូចៗ ក្នុងសកម្មភាពថ្នាក់រៀនវិទ្យាសាស្ត្រ។ សិស្សម្នាក់អាចនឹងថ្លឹងសម្ភារៈផ្សេងៗ ចំណែកឯម្នាក់ផ្សេងទៀតអាចនឹងកត់ត្រាលទ្ធផល។ ដល់ពាក់កណ្តាលដំណើរការសកម្មភាព សិស្សអាចដូរតួនាទីគ្នាបាន។ កិច្ចសហការចាំបាច់ត្រូវអនុវត្តប្រសិនបើក្រុមទាំងឡាយធ្វើកិច្ចការដោយឯករាជ្យ។
- ការដោះស្រាយបញ្ហា និងការចរចាជួយឱ្យសិស្សចេះដោះស្រាយទំនាស់និងធ្វើការសម្រេចចិត្តបាន។ សិស្សត្រូវរៀន និងអនុវត្តជំនាញចាត់ចែង

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

គ្រប់គ្រងទំនាស់ដែលផ្អែកទៅលើជំនាញទំនាក់ទំនងល្អៗ និងឥរិយាបទដែលចេះអត់ធ្មត់។

- គេចាំបាច់ជំរុញឱ្យសិស្សយល់ស្របទៅលើគោលបំណង ស្វះស្វែងប្រើប្រាស់ជម្រើសផ្សេងៗ ធ្វើការសម្រេចចិត្តនិងគាំទ្រពួកគេ និងបន្តតាមដានដើម្បីយល់ដឹងពីលទ្ធផលនៃជម្រើស។ ដំណើរការទាំងអស់នេះ អាស្រ័យទៅលើស្មារតីក្រុម ទំនាក់ទំនង និងការសហការគ្នា។[2]

២.៣ ការបង្រៀនពីសំណាក់មិត្តភក្តិ (សិស្សជួយសិស្ស)

ការបង្រៀនពីមិត្តភក្តិ (Peer Tutoring) ធ្វើបាននៅពេលដែលក្មេងម្នាក់ចេះជាង ឬចាស់ជាងបានបញ្ចប់ការងាររបស់ខ្លួនរួចហើយ។ ពួកគេបានបន្តជួយអ្នកដែលក្មេងជាង ឬអ្នកសិក្សាដទៃទៀត ដើម្បីបញ្ចប់កិច្ចការរបស់ពួកគេដែរ។ អ្នកជួយបង្រៀនបែបនេះគឺ ជួយឱ្យសិស្សធ្វើការងាររបស់ពួកគេដោយខ្លួនឯង។ វាទាមទារឱ្យមានពេលវេលាពិសេសណាមួយជារៀងរាល់ថ្ងៃ សម្រាប់ឱ្យសិស្សជួយគ្នាទៅវិញទៅមក ដើម្បីរៀនគណិតវិទ្យា ភាសាតាមរយៈការបង្រៀនមួយទល់នឹងមួយ ឬជាក្រុមតូចៗ។

ការបង្រៀនពីមិត្តភក្តិ គឺជាបច្ចេកទេសអប់រំដ៏មានតម្លៃ ព្រោះវាជួយបំពេញតម្រូវការរបស់សិស្សម្នាក់ៗ។ វាក៏បង្កើននូវវិធីសាស្ត្រសហការមួយជាជាងការប្រកួតប្រជែងចំពោះការសិក្សា។ ការគោរព និងការយោគយល់គ្នាទៅវិញទៅមកត្រូវបានបង្កើតឡើងក្នុងចំណោមសិស្សដែលធ្វើការជាមួយគ្នា។ សិស្សពិនិត្យមើលបញ្ហា តាមវិធីសាស្ត្រដែលខុសពីមនុស្សពេញវ័យ។[...] ក្នុងការអានការបង្រៀនពីមិត្តភក្តិត្រូវបានប្រើ ដើម្បីជួយអ្នកអានយឺត ឬក៏ដើម្បីផ្តល់ការអានបន្ថែមសម្រាប់សិស្សក្មេងជាងនៅក្នុងថ្នាក់រៀន។

- វាអាចមានផលជាវិជ្ជមាន ទាំងខាងផ្នែកអប់រំ និងសង្គម ទាំងអ្នកបង្រៀននិងអ្នករៀនផងដែរ។
- វាជាមធ្យោបាយសកម្មដែលជួយឱ្យសិស្សម្នាក់ៗអានបាន
- វាធ្វើឱ្យកម្រិតនៃការអានរបស់គ្រូកាន់តែរីកចម្រើនជាបន្តបន្ទាប់។
- ដោយប្រើបច្ចេកទេសនេះ ចំនួនម៉ោងដែលកុមារអានបានកើនឡើង។ ក្មេងដែលមានអាយុតិចជាង អាចទទួលបានប្រយោជន៍ពីការអានដោយយក

ការដាក់តាមលំដាប់លំដោយ៖ គឺជាការបង្ហាញទិសដៅដែលមានគោលបំណងនៃដំណើរការរៀនសូត្រ។

ការផ្តល់មតិយោបល់៖ ផ្តល់ជូននូវព័ត៌មានដែលអនុញ្ញាតិឱ្យអ្នកសិក្សាបន្ថយចន្លោះខ្វះខាតរវាងអ្វីដែលជាកស្តុតាងបច្ចុប្បន្ននិងអ្វី

[2] Taken from UNESCO/Booklet Five (2015, p. 20ff.). CC BY-SA 3.0 IGO. Changes made to all CC BY texts in this document are indicated in italics or square brackets.

ចិត្តទុកដាក់ពីអ្នកដទៃ។ គ្រូបង្រៀនភាគច្រើន មិនមានពេលគ្រប់គ្រាន់ដើម្បីផ្តល់ជំនួយដល់សិស្សម្នាក់ៗបែបនេះទេ។

ទោះយ៉ាងនេះក៏ដោយ វាជារឿងចាំបាច់ដែលត្រូវពន្យល់ឱ្យបានច្បាស់ ទៅដល់ ក្រុមសិស្សដែលបង្រៀនគ្នាឯងអំពីអ្វីដែលគ្រូចង់បាន។ ក្មេងដែលជាអ្នកបង្រៀនត្រូវតែយល់ពីអ្វីដែលខ្លួនចង់បានពីអ្នកដែលខ្លួនបង្រៀន។ ពួកគេគួរតែធ្វើការជាមួយសិស្សដទៃទៀតតាមវិធីមួយដែលស្ងៀមស្ងាត់ រួសរាយរាក់ទាក់ និងដែលផ្តល់ការគាំទ្រ។ ភាពដែលមិនចេះអត់ធ្មត់គួរតែត្រូវបានជៀសវាង។ នេះគឺជាឧទាហរណ៍នៃវិធីសាស្ត្រការបង្រៀនពីមិត្តភក្តិក្នុងការអាន។

វិធីសាស្ត្រអានជាដៃគូជាវិធីផ្អែកលើការអានដែល៖

ក. ការអានឮៗរួមគ្នាទាំងអ្នកបង្រៀន និងអ្នករៀន និងការអានជាបុគ្គលពីសំណាក់អ្នករៀន

ខ. ប្រើប្រាស់យោបល់វិជ្ជមាន ដើម្បីបង្កើនការអានដោយខ្លួនឯងឱ្យបានត្រឹមត្រូវ។

អ្នកបង្រៀនត្រូវបានបង្ហាត់ឱ្យ៖

- ណែនាំពីសៀវភៅ ឬអត្ថបទតាមវិធីដែលមានការជំរុញលើកទឹកចិត្ត
- ពន្យារពេលការកែកំហុសរហូតដល់អ្នករៀនដែលបានព្យាយាមកែខ្លួនឯង
- ពិភាក្សាអត្ថបទបន្ទាប់ពីបានអានចប់ និងពិនិត្យមើលលើការបង្រៀនរបស់ខ្លួនផ្ទាល់ក្នុងឯងនាមជាគ្រូបង្រៀន និងលើការរីកចំរើនរបស់អ្នករៀនដោយការបំពេញបណ្ណរបាយការណ៍ និងបញ្ជីត្រួតពិនិត្យ។[3]

២.៤. យុទ្ធសាស្ត្រសម្រាប់សិស្សមានតម្រូវការអប់រំពិសេស

នៅពេលដែលយើងបង្កើតថ្នាក់រៀនបែបបរិយាបន្ន ហើយកំពុងព្យាយាមដាក់បញ្ចូលសិស្ស ដែលមានសមត្ថភាពផ្សេងៗគ្នា។ យើងត្រូវការយុទ្ធសាស្ត្រដើម្បីជួយសិស្សទាំងនេះរៀនបានពេញលេញ។ យុទ្ធសាស្ត្រទាំងនោះមានដូចខាងក្រោម៖

- ការរៀបចំតាមលំដាប់លំដោយ៖ បែងចែកការងារ ឬដាក់កិច្ចការជាផ្នែកតូចៗហើយផ្តល់រូបភាពនិងពាក្យគន្លឹះ ឬការបង្រៀនណែនាំពីដំហានមួយទៅដំហានមួយតាមលំដាប់។

ដែលអាចឬគួរតែជាករណី។ (Hattie & Yates, 2014, p. 46)

ចាប់ផ្តើមពីតូច និងផ្តុំឡើង៖ មានន័យថាចាប់ចេញពីស្រួលទៅលំបាក ហើយពីសកម្មភាពតូចទៅធំក្នុងថ្នាក់រៀន។

កាត់បន្ថយភាពលំបាក៖ ក្នុងថ្នាក់រៀនបែបបរិយាបន្នមានន័យថាបង្កើតកិច្ចការដែលអាចបត់បែនបានហើយដែលអាចយកទៅប្រើប្រាស់បានចមពោះតម្រូវការរបស់សិស្សដែលចម្រុះគ្នា។

ការសួរសំណួរ៖ អាចជួយបញ្ជាក់ថាតើគោលបំណងសិក្សានៃមេរៀនកំពុងត្រូវបានបំពេញបានកម្រិតណា។

រូបភាពក្រាហ្វិច៖ ជួយសិស្សតាមរយៈការផ្តល់ព័ត៌មានបន្ថែមពីមេរៀន។

ការបង្រៀនជាក្រុម៖ ជាការគាំទ្រការសិក្សារបស់មិត្តភក្តិ និងបង្កើតបរិយាកាសដែលងាយស្រួលនិងរួសរាយរាក់ទាក់។

គ្រូបង្រៀនជំនួស៖ គឺជាអ្នកជំនាញម្នាក់ដែលជួយគាំទ្រសិស្សតម្រូវការពិសេសនៅក្នុងថ្នាក់។

👉 សូមមើលម៉ូឌុល៣ ចំណុច ៣ "ការផ្តល់អំណាច ការកំណត់ដឹង និងប្រសិទ្ធភាពខ្លួនឯង។

[3] Taken from UNESCO/Booklet Five (2015, p. 24ff.). CC BY-SA 3.0 IGO.

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

- ការធ្វើច្រំដែលៗ និងការផ្តល់ព័ត៌មានត្រឡប់៖ ធ្វើតេស្តប្រចាំថ្ងៃ ការអនុវត្តដដែលៗ និងការផ្តល់ព័ត៌មានត្រឡប់ប្រចាំថ្ងៃ។
- ចាប់ផ្តើមពីចំណុចតូច និងផ្តុំឡើង៖ បំបែកជំនាញគោលដៅទៅជាផ្នែកតូចៗហើយបន្ទាប់មកផ្តុំផ្នែកទាំងនេះឡើងទៅជាវត្ថុ ឬរបស់ទាំងមូល។
- កាត់បន្ថយការលំបាក៖ រៀបកិច្ចការតាមលំដាប់ពីស្រួលទៅលំបាក ហើយផ្តល់តែគន្លឹះចាំបាច់ប៉ុណ្ណោះ។
- ការសួរសំណួរ៖ សួរសំណួរដែលជាប់ពាក់ព័ន្ធនឹងដំណើរការ (“របៀបណា”) ឬសំណួរដែលជាប់ពាក់ព័ន្ធខ្លឹមសារ (“តើជាអ្វី...”)។
- រូបក្រាហ្វិច៖ គូសបញ្ជាក់រូបភាព ឬការធ្វើបទបង្ហាញជារូបភាពដទៃៗទៀត។
- ការបង្រៀនជាក្រុម៖ផ្តល់ការបង្រៀនណែនាំសម្រាប់ក្រុមសិស្សតូចៗ។
- គ្រូបង្រៀនជំនួស និងការចូលរួមពីសំណាក់មិត្តភក្តិ៖ ជំរុញ ឪពុកម្តាយ ឬអ្នកដទៃឱ្យជួយណែនាំកិច្ចការផ្ទះ។

See also Module 2, Text 2 “Assessing Learning Results”

លើសពីនេះទៅទៀត អ្នកអាចជំរុញលើកទឹកចិត្តដល់សិស្សដទៃទៀត ឱ្យចេះទទួលខុសត្រូវចំពោះមិត្តរួមថ្នាក់ ដែលអសមត្ថភាព ឬពិការដោយដាក់ឱ្យធ្វើកិច្ចការជាដៃគូជាមួយនឹងសិស្សធម្មតា។ សុំឱ្យដៃគូជួយលើសកម្មភាពសំខាន់ៗ។ ឧទាហរណ៍ ជួយសិស្សដែលមានពិការភាពទៅកន្លែងគេចង់ទៅ ដូចជា បណ្ណាល័យ បន្ទប់ទឹក ព្រមទាំងជួយពួកគេពេលធ្វើដំណើរកម្មសិក្សា ឬពេលលេងល្បែងជាក្រុម។ ពន្យល់ទៅដល់ដៃគូរបស់គេថា ពួកគេចាំបាច់ត្រូវការពារកុមារដែលមានពិការភាពពីការប៉ះពាល់ដល់រាងកាយ និងការនិយាយប្រាប់ពួកគេពីវិធីល្អបំផុតដើម្បីធ្វើរឿងនេះ។

ចូរពិភាក្សាជាមួយសិស្សអំពីពិការភាព ដែលសិស្សអាចប្រទះឃើញនៅតាមសាលា ឬនៅក្នុងសហគមន៍។ វិធីមួយក្នុងការធ្វើកិច្ចការនេះ គឺត្រូវឱ្យមនុស្សពេញវ័យ ដែលមានពិការភាពមួយប្រភេទចូលមកក្នុងថ្នាក់ ដើម្បីជជែកជាមួយសិស្សរបស់អ្នក។[4] ទោះជាយ៉ាងនេះក្តី អ្នកគួរតែបញ្ជាក់ឱ្យបានច្បាស់ពីសមត្ថភាពរបស់សិស្សដែលមានតម្រូវការពិសេស និងអនុញ្ញាតឱ្យគេបង្ហាញ

[4] Taken from UNESCO/Booklet Four (2015, p. 37f.). CC BY-SA 3.0 IGO.

សមត្ថភាពទាំងនោះក្នុងបរិបទបរិយាបន្ននេះ។ ការទទួលយកនូវគុណសម្បត្តិដែលប្លែកៗគ្នារបស់សិស្ស នឹងធ្វើឱ្យពួកគេមានទំនុកចិត្តលើខ្លួនឯងច្រើនជាងមុន និងអភិវឌ្ឍនូវប្រសិទ្ធិភាពខ្លួនឯងបែបវិជ្ជមានបានច្រើន។

៣. ការវាយតម្លៃនៅក្នុងថ្នាក់រៀនបែបចម្រុះ

ដូចបានឃើញពីមុនរួចមកហើយ ដំបូងគ្រូបង្រៀនត្រូវសម្រេចលើសមត្ថភាពមួយណាដែលសិស្សត្រូវទទួលយក។ ផ្អែកលើសមត្ថភាពនេះ យើងអាចកំណត់បានគោលបំណងនៃការសិក្សាបាន។ គោលបំណងនៃការសិក្សាទាំងនេះបញ្ជាក់ពីអ្វីដែលរំពឹងថា "សិស្សនឹងរៀនចេះនៅចុងឆ្នាំសិក្សា នៅពេលបញ្ចប់មុខវិជ្ជា គម្រោងមេរៀន ឬពេលរៀននៅក្នុងថ្នាក់" (The Glossary of Education Reform, 2014, online)។ គោលបំណងនៃការសិក្សាទាំងនេះក៏សំខាន់សម្រាប់ការវាយតម្លៃផងដែរ ព្រោះថាការវាយតម្លៃគឺមានន័យថាការវាស់វែងពីកម្រិតគោលបំណង ដែលត្រូវសម្រេចបាន។ រឿងនេះអាចធ្វើឱ្យគ្រូបង្រៀនអាចកំណត់បានពីចំណុចខ្លាំង និងខ្សោយរបស់សិស្សម្នាក់ៗថា "តើពួកគេយល់ពីមុខវិជ្ជាកំពុងរៀនបានច្បាស់កម្រិតណា? តើពួកគេទទួលបានសមត្ថភាពក្នុងជំនាញដែលពាក់ព័ន្ធដែរឬទេ?" (Sanger, 2020, p. 50) ដើម្បី គាំទ្រដល់ដំណើរការរៀនសូត្ររបស់សិស្សឱ្យបានច្រើនជាអតិបរិមា។

វាជារឿងលំបាកសម្រាប់គ្រូបង្រៀនក្នុងការស្វែងរកវិធី ដើម្បីកំណត់ពីជំនាញ ខុសៗគ្នា និងការជួយគាំទ្រសិស្ស នៅពេលដែលពួកគេប្រឈមនឹងសិស្សដែលមានសមត្ថភាពមិនស្មើគ្នា និងគុណវិបត្តិ ឬពិការភាពផ្សេងទៀត។ ការចូលរួមចំណែកដ៏សំខាន់ខាងផ្នែកសង្គម នៃគរុកោសល្យបែបបរិយាបន្ននេះ គឺត្រូវជួយកែលម្អដល់សិស្ស "សិស្សមិនល្អ" និងការពារមិនឱ្យមានការរើសអើង។ (Prengel, 2013)។

ដូចបានឃើញពីមុនហើយ នៅពេលធ្វើកិច្ចតែងការបង្រៀន គ្រូបង្រៀនត្រូវកំណត់ខ្លឹមសារទៅតាមចំណុចសកម្មភាពនីមួយៗទៅតាមជំហាន។ ការធ្វើដូច្នេះ ជួយឱ្យអ្នកសិក្សាអាចយល់ពីមុខវិជ្ជារៀនអាស្រ័យលើចំណុចចាប់ផ្តើម។ ដូច្នេះការអប់រំបរិយាបន្នត្រូវសាកសួរពីសមត្ថភាពភាពរបស់កុមារម្នាក់ៗ ដោយរាប់បញ្ចូលទាំងសក្តានុពលមានស្រាប់របស់ពួកគេ ជំនួសឱ្យការមិនយកចិត្ត

គោលបំណងនៃការវាយតម្លៃការសិក្សាក្នុងអំឡុងពេលរៀនគឺត្រូវវាយតម្លៃយ៉ាងទៀងទាត់លើដំណើរការរៀនសូត្ររបស់សិស្សក្នុងរយៈពេលជាក់លាក់ៗជាធម្មតាគេមិនដាក់ពិន្ទុ ឬចំណាត់ថ្នាក់លើការវាយតម្លៃនេះទេ។ វាអាចមានរបៀបផ្សេងៗគ្នាជាច្រើន ពីការធ្វើតេស្តជាផ្លូវការបែបខ្លីៗ និងកិច្ចការស្រាវជ្រាវ ទៅដល់ការសួរសំណួរក្រៅផ្លូវការ និងការពិភាក្សាជាមួយសិស្សនៅក្នុងថ្នាក់រៀនជាដើម។

(The Glossary of Education Reform, 2015, online) ការវាយតម្លៃក្នុងកំឡុងពេលសិក្សាទាំងនេះអនុញ្ញាតិឱ្យទាំងគ្រូបង្រៀនទាំងសិស្សកំណត់បានពីចំណុចខ្លាំងនិងខ្សោយរបស់អ្នករៀនយឺតហើយអនុញ្ញាតិឱ្យមានការផ្លាស់ប្តូរយុទ្ធសាស្ត្រនៃការបង្រៀននិងការរៀនប្រសិនបើចាំបាច់។

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ទុកដាក់។ ការធ្វើរបៀបនេះ អាចឈានទៅដល់ការសម្រេចបាននូវគោលដៅដែលបានកំណត់រវាងកុមារដែលមានសមត្ថភាពនិងកុមារដែលអសមត្ថភាព ដើម្បីជំរុញដំណើរការរៀន និងបង្រៀននៅពេលក្រោយ (Prengel, 2013)។ ក្នុងដំណើរការបន្ថែមនេះ ការអភិវឌ្ឍរបស់កុមារត្រូវបានប្រៀបធៀបជាបន្តបន្ទាប់ជាមួយពួកគេផ្ទាល់ ជាមួយនឹងការគាំទ្រពីគោលបំណងសិក្សាជាក់លាក់ដូចបានកំណត់នៅក្នុង ***ការរៀបចំផែនការបែបពីរ៉ាមីដ*** ឬនៅក្នុងបណ្តុំសមត្ថភាពខុសៗគ្នា។ មានតែតាមវិធីនេះទេដែលអាចបង្កើតបាននូវរបៀបអប់រំសម្រាប់បុគ្គលម្នាក់ៗ ដែលចាំបាច់ត្រូវតាក់តែងឡើង ដើម្បីឱ្យសិស្សអាចឈានទៅដល់កម្រិតបន្ទាប់។ (Prengel, 2013) ដូចនេះសាលារៀនបែបបរិយាបន្ធ្វើការវាយតម្លៃតាមដំណាក់ ដើម្បីទទួលបាននូវរូបភាពជាក់លាក់ក្នុងបង្កើនសមត្ថភាពរបស់សិស្សព្រោះនេះជាឧបករណ៍ ដែលមានថាមពលដើម្បីវាយតម្លៃចំណុចចាប់ផ្តើម និងបច្ចុប្បន្នភាពរបស់អ្នករៀន ក្នុងដំណើរការសិក្សាព្រមទាំងជំនួយជាចាំបាច់នានានៅពេលបន្តាប់។ ការវាយតម្លៃគឺជាវិធីនៃការអង្កេតការប្រមូលព័ត៌មាន ហើយបន្ទាប់មកធ្វើការសម្រេចចិត្តដោយផ្អែកលើព័ត៌មាននោះ។ ការវាយតម្លៃជាបន្តបន្ទាប់មានន័យថា ជាការសង្កេតមើលជាហូរហែរដើម្បីបញ្ជាក់ថាកុមារម្នាក់ៗចេះអ្វីខ្លះ? យល់អ្វីខ្លះ? ហើយគាត់អាចធ្វើអ្វីបានខ្លះ? ការសង្កេតមើលទាំងនេះត្រូវបានធ្វើជាច្រើនដងក្នុងមួយឆ្នាំសិក្សា ជាឧទាហរណ៍នៅពេលចាប់ផ្តើម នៅពាក់កណ្តាល ឬនៅចុងឆមាស ឬអាចញឹកញាប់ជាងនេះទៀត។ ការវាយតម្លៃជាបន្តបន្ទាប់អាចសម្រេចទៅបានតាមរយៈ: នៃការសង្កេត សំណុំឯកសារ បញ្ជីត្រួតពិនិត្យលើសមត្ថភាព ការប្រឡងធ្វើតេស្តវែង និងខ្លី ការវាយតម្លៃលើខ្លួនឯង និងការសរសេរអត្ថបទដើម្បីឆ្លុះបញ្ចាំង។ ការវាយតម្លៃជាបន្តបន្ទាប់ធានាថា កុមារទាំងអស់មានឱកាសជោគជ័យនៅក្នុងសាលារៀន។ តាមរយៈការប្រើប្រាស់ការវាយតម្លៃជាបន្តបន្ទាប់ គ្រូបង្រៀនអាចសម្របសម្រួលការរៀបចំគម្រោង និងការបង្រៀនរបស់គាត់ទៅតាមតម្រូវការរបស់អ្នកសិក្សា ដើម្បីឱ្យទាំងអស់គ្នាមានឱកាសរៀននិងទទួលបានជោគជ័យ។

ក្នុងការវាយតម្លៃជាបន្តបន្ទាប់ អ្នកសិក្សាទាំងអស់មានឱកាសបង្ហាញពីអ្វីដែលពួកគេចេះ។ពួកគេអាចធ្វើបានតាមវិធីជាច្រើន ដោយយោងទៅតាមប្រភេទវិធីសិក្សា។ ការវាយតម្លៃជាបន្តបន្ទាប់អាចប្រាប់បានថា កុមារណារៀនយឺតឬមិនសូវយល់ពីប្រធានបទ ។ បន្ទាប់មកគ្រូបង្រៀន អាចបង្កើតឱកាសសិក្សាថ្មីៗដល់សិស្សទាំងនោះ។ ការផ្តល់ព័ត៌មានត្រឡប់បន្តបន្ទាប់ ដើម្បីឱ្យសិស្សទទួល

និទ្ទេសបទ៖ បែងចែកកិច្ចការដែលជាក់ឱ្យទៅសិស្សជាផ្នែកផ្សេងៗ និងធ្វើការពិពណ៌នាយ៉ាងច្បាស់លាស់លើកម្រិតខុសៗគ្នា ត្រូវនឹងផ្នែកនីមួយៗ។
(Ambrose et al., 2010, p. 231)

បញ្ជីត្រួតពិនិត្យ៖ ជាឧបករណ៍វាយតម្លៃដែលកំណត់លក្ខណៈនិច្ឆ័យជាក់លាក់ដែលអ្នកអប់រំ និងសិស្សអាចប្រើប្រាស់ ដើម្បីវាស់ស្ទង់ការអភិវឌ្ឍជំនាញឬការរីកចម្រើន។
(Lauzon, online)

បានថាតើពួកគេរៀនបានត្រឹមត្រូវឬទេ? ព្រមទាំងវិធានការដែលត្រូវធ្វើ ដើម្បីធ្វើឱ្យរីកចម្រើន។ ការវាយតម្លៃជាបន្តបន្ទាប់អាចជួយសិស្សបានដោយការពិភាក្សាជាមួយឪពុកម្តាយនិងអ្នកអាណាព្យាបាលអំពីចំណុចខ្លាំង និងខ្សោយរបស់កុមារ ដើម្បីឱ្យពួកគេអាចចូលរួមក្នុងកម្មវិធីបញ្ចូលគ្នាមួយ ដូចជាកម្មវិធីមួយដែលភ្ជាប់សកម្មភាពក្នុងថ្នាក់ជាមួយសមាជិកក្នុងផ្ទះ។[5] ខាងក្រោមជារបៀបជួយគាំទ្រសិស្សដែលមានកម្រិតជំនាញខុសៗគ្នា៖

៣.១ ឧបករណ៍វាយតម្លៃ

ចូរប្រើឧបករណ៍វាយតម្លៃដូចជា និទ្ទេសបទ ឬបញ្ជីត្រួតពិនិត្យ។ វិធីទាំងនេះជួយឱ្យគ្រូបង្រៀនកំណត់លក្ខណៈវិនិច្ឆ័យ ដែលត្រូវបំពេញឱ្យបានជោគជ័យ។ ឧបករណ៍ និងលក្ខណៈវិនិច្ឆ័យទាំងនេះគួរតែបង្កើតឡើងរួមគ្នា ឱ្យសមស្របទៅតាមសមត្ថភាពរបស់សិស្សដែលអាចធ្វើបាន។ នៅពេលដែលគ្រូបង្រៀនបានរៀបចំការវាយតម្លៃកម្រិតខ្ពស់ហើយ សិស្សអាចកំណត់បន្ថែមនូវលក្ខណៈវិនិច្ឆ័យគុណភាពល្អនៅកម្រិតផ្សេងៗទៀត។ ហេតុនេះ ការវាយតម្លៃនឹងមានតម្លាភាព និងយុត្តិធម៌ ពីព្រោះសិស្សមិនគ្រាន់តែដឹងពីអ្វីដែលគេសួរប៉ុណ្ណោះទេ ប៉ុន្តែពួកគេក៏បានចូលរួមបង្កើតលក្ខណៈវិនិច្ឆ័យទាំងនេះផងដែរ។ ជាលទ្ធផលសិស្សអាចប្រៀបធៀបកិច្ចការរបស់ខ្លួន ជាមួយលក្ខណៈសម្បត្តិទាំងនេះ។ ដូច្នេះហើយគេអាចបញ្ជាក់ពីចំណុចខ្លាំង និងខ្សោយរៀងៗខ្លួនបាន។ ក្រោយមកទាំងគ្រូបង្រៀន និងសិស្សអាចឆ្លើយតបទៅនឹងតម្រូវការស្របគ្នា។ ជាពិសេស សិស្សដែលមានតម្រូវការអប់រំពិសេស ត្រូវពឹងផ្អែកលើឧបករណ៍វាយតម្លៃ ដែលរៀបជារចនាសម្ព័ន្ធដែលមានស្រាប់ ក្នុងការកំណត់ទិសដៅកិច្ចការសាលារៀនឱ្យទទួលបានជោគជ័យ។ (Lauzon, n.d.)

៣.២ ទម្រង់វាយតម្លៃផ្សេងៗ

ចូរប្រើទម្រង់បែបបទវាយតម្លៃផ្សេងៗពីគ្នាដើម្បីឱ្យសិស្សអាចបង្ហាញពីសមត្ថភាពពិសេសបាន។ ជាទូទៅ ចូរទុកឱកាសឱ្យសិស្សផ្តល់ចម្លើយតាមវិធីរៀងខ្លួន តាមរយៈការសរសេរ ការនិយាយ ឬការជ្រើសរើសចម្លើយ។ ជម្រើសមួយទៀតគឺទុកឱកាសឱ្យសិស្សជ្រើសរើសវិធី ដែលគេចង់បង្ហាញលទ្ធផល

[5] Taken from UNESCO/Booklet Five (2015, p. 40f.). CC BY-SA 3.0 IGO.

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

សិក្សារបស់គេដោយខ្លួនឯង ដោយប្រើទម្រង់ដែលគេគិតថាមានភាពងាយស្រួលបំផុត។ (Sanger, 2020)

- អាចឱ្យឆ្លើយជាពាក្យសម្តី ជំនួសឱ្យការសរសេរ
- បង្ហាញការណែនាំដោយផ្ទាល់មាត់
- ផ្តល់សម្ភារៈបោះពុម្ពជាអក្សរធំៗ
- កាត់បន្ថយចំនួនសំណួរក្នុង១ទំព័រ
  (ElSaheli-Elhage & Sawilowsky, 2016)

៣.៣ ការវាយតម្លៃលើការអនុវត្តជាក់ស្តែង

"ការវាស់ស្ទង់តាមបែបបុរាណពីការរៀនសូត្ររបស់សិស្ស ផ្តោតសំខាន់ទៅលើចំណេះដឹង និងផ្តល់ជាទស្សនៈទានដែលមិនប្រើបរិបទយល់ដឹងរបស់សិស្ស ហើយការអនុវត្តទាំអស់នេះផ្ទុយស្រឡះពីគោលវិធីសិស្សមជ្ឈមណ្ឌល" (Udvari-Solner et al., 2005, p. 105) ទិដ្ឋភាពនេះបានធ្វើឱ្យលំបាកដល់សិស្ស ដែលមានតម្រូវការពិសេសដើម្បីឈានដល់កម្រិតនៃការរៀនសូត្រដូចគ្នាជាមួយមិត្តភក្តិរបស់គេ។ ដូចដែលបានដឹងពីមុនរួចហើយ សិស្សដែលមានពិការភាពខាងសតិស្មារតី តែងតែមានការលំបាកក្នុងការភ្ជាប់កិច្ចការសាលា ដែលមានលក្ខណៈអរូបី មិនឆ្លើយតបទៅនឹងតថភាព។ ដូច្នេះវាមានសារៈសំខាន់ខ្លាំងក្នុងការផ្តល់ ឱ្យសិស្សនូវកិច្ចការដែលមានលក្ខណៈជាក់ស្តែងដែលសិស្សត្រូវបង្ហាញពីសមត្ថភាពសម្រាប់បរិបទជីវិតពិត។ កិច-ការដែលមានលក្ខណៈច្បាស់លាស់ទាំងនេះ នឹងត្រូវបានប្រមូលយកមកជាឯកសារថ្មីជាបន្តបន្ទាប់ និងត្រូវបានវាយតម្លៃ ដើម្បីបង្ហាញពីដំណើរការរៀនសូត្ររបស់សិស្ស និងជានាឱ្យមានការអភិវឌ្ឍដល់សិស្សម្នាក់ៗ។ (Udvari-Solner et al., 2005)

៣.៤ ការពិចារណាលើការប្រឡងដែលមិនកំណត់ពេលវេលា

វិធីសាស្ត្រមួយទៀតនៃបរិយាបន្នក្នុងការវាយតម្លៃគឺ ត្រូវពិចារណាលើការប្រឡងដែលមិនកំណត់ពេលវេលា។ ការប្រឡងមិនមែនគ្រាន់តែជាឱកាសបង្ហាញចំណេះដឹងនោះទេ តែវាក៏ជំរុញដល់ការរៀនសូត្រផងដែរ។ ចំពោះហេតុផលនេះ ការប្រឡងគួរតែត្រូវមានលក្ខណៈបរិយាបន្ន ឱ្យបានច្រើនតាមដែលអាចធ្វើបាន។ ការរៀនចំនួនពីរក្នុងចំណោមការរៀនដែលមានលក្ខណៈសាមញ្ញ

បំផុតដែលសិស្សទទួលបាននោះគឺ ម៉ោងបន្ថែមទៅលើការប្រឡង និងសមត្ថភាពប្រឡងក្នុងបន្ទប់ឯកជន។ ការផ្តល់ជូនទាំងនេះ ជាអនុសាសន៍សម្រាប់សិស្សដែលមានបញ្ហាក្នុងការប្រឡងមួយចំនួនដោយរាប់បញ្ចូលទាំងអ្នកមានបញ្ហាលើការអាន ការលំបាកក្នុងការផ្តោតអារម្មណ៍ និងការ-ព្រួយបារម្ភ។ លើសពីនេះទៅទៀត សិស្សអាចរៀនបានកាន់តែប្រសើរ ប្រសិនបើការ-ប្រឡងមិនត្រូវបានកំណត់ពេលវេលា។ ចូរពិចារណា ថាតើពេលវេលាជាកត្តាសំខាន់ដែលអ្នកព្យាយាមបង្រៀនសិស្សមែនឬទេ? ប្រសិនបើដូច្នេះមែន តើអ្នកបានចំណាយពេល ដើម្បីបង្រៀនសិស្សពីរបៀបធ្វើឱ្យសម្រេចនូវការរំពឹងទុក បានឆាប់រហ័សដែរឬទេ? ប្រសិនបើធ្វើមិនបានទេ ចូរពិចារណាឱ្យសិស្សប្រឡង ដោយប្រើពេលផ្ទាល់ខ្លួនគេ។ ជាការពិត ការប្រឡងដែលកំណត់ពេលវេលាមានភាពងាយស្រួល ព្រោះគេមិនចាំបាច់ធ្វើការប្រឡងដែលមានរយៈពេលយូរ ឬក៏រកពេលវេលាមួយដែលសិស្សទាំងអស់គ្នា អាចអង្គុយក្នុងបន្ទប់មួយរួមគ្នា ប្រើរយៈពេលមួយយូរនោះទេ។ ធ្វើបែបនេះជារឿងល្អក្នុងការពិចារណា ថាតើសិស្សអាចប្រឡងតែម្នាក់ឯងដោយកំណត់ពេលវេលាខ្លួនឯងនៅកន្លែងផ្ទាល់ខ្លួនបានឬយ៉ាងណា? វិធីសាស្ត្រនេះមានផលប្រយោជន៍ណាស់ ព្រោះមិនបានប្រើប្រាស់ពេលវេលា ក្នុងថ្នាក់រៀនទៅលើការប្រឡងឡើយ។[6]

- ផ្តល់ពេលវេលាបន្ថែមលើកិច្ចការស្រាវជ្រាវ
- ធ្វើតេស្តញឹកញាប់ បីឬបួនថ្ងៃម្តង
- ផ្តល់ការសម្រាកដោយទៀងទាត់
- ផ្តល់ទីតាំងដែលមានការរំខានតិចតួចបំផុត
- ធ្វើការប្រឡងក្នុងបន្ទប់ឯកជនមួយ ឬកន្លែងបម្រុងទុកជាស្រេច
- ផ្តល់សម្ភារៈដែលបោះពុម្ពជាអក្សរធំៗ
- ផ្តល់ជូនការរៀបចំធ្វើតេស្តជាពិសេស។

(ElSaheli-Elhage & Sawilowsky, 2016)

៣.៥ ការផ្តល់ឱកាសឱ្យសិស្សធ្វើកិច្ចការសារជាថ្មី

ចូរពិចារណាដល់ការផ្តល់ឱកាសឱ្យសិស្ស អាចធ្វើសេចក្តីព្រាងកិច្ចការសម្រាប់ការត្រួតពិនិត្យ ឬធ្វើកិច្ចការដំបូងរបស់ពួកគេឡើងវិញ ប្រសិនបើវាមិនទាន់ត្រឹមត្រូវ។ នេះជាវិធីលើកទឹកចិត្តសិស្ស ឱ្យគិតដល់ការផ្តល់យោបល់ឱ្យ

[6] Taken from Sanger (2020, p. 54). CC BY 4.0.

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

បានហ្មត់ចត់ ហើយបង្ហាញពីការប្តេជ្ញាចិត្តរបស់គ្រូ ដើម្បីជួយគាំទ្រសិស្សដែលខំប្រឹងប្រែងរៀនសូត្រ។ បើសិនបើអ្នកវាយតម្លៃការរៀនសូត្ររបស់សិស្ស តាមរយៈការប្រឡង ចូរពិចារណាទៅដល់ការប្រឡងលើកទី២ ដល់សិស្សដែលចង់ប្រឡងសារជាថ្មី ហើយប្រាប់សិស្សថាអ្នកនឹងផ្តល់ពិន្ទុជាមធ្យមភាគនៃការប្រឡងទាំងពីរលើកនេះ។ ជម្រើសមួយទៀតគឺ អនុញ្ញាតឱ្យសិស្សសរសេរកំណត់ហេតុ បែបឆ្លុះបញ្ចាំងមួយ បន្ទាប់ពីទទួលបានការផ្តល់ព័ត៌មានត្រឡប់ទៅលើកិច្ចការរបស់គេ។ ផ្តល់ឱ្យគេនូវអ្វីដែលគេសម្រេចបានក្នុងកិច្ចការរបស់គេ និងកន្លែងដែលពួកគេនៅខ្វះចន្លោះ។ ជាការពិតណាស់ការផ្តល់ឱកាស ឱ្យមានការប្រឡងសារជាថ្មីនេះ គឺជាការខាតពេលវេលាសម្រាប់គ្រូបង្រៀន ព្រោះថាវាតម្រូវឱ្យមានការសរសេរកិច្ចការប្រឡងជាថ្មី ឬការដាក់ពិន្ទុលើកិច្ចការថ្មីជាដើម។ អាចនិយាយបានថា នេះមិនមែនជាជម្រើសល្អសម្រាប់គ្រូបង្រៀន ដែលមានសិស្សច្រើន និងមានកិច្ចការបង្រៀនច្រើននោះទេ។ ប៉ុន្តែជាការស្វែងរកមធ្យោបាយ ដើម្បីលើកទឹកចិត្តសិស្ស ឱ្យដាក់បញ្ចូលគ្នានូវការផ្តល់ព័ត៌មានត្រឡប់ ដូចជាការបន្ថែមពិន្ទុបន្តិចបន្តួច សម្រាប់ការប្រគល់នូវកិច្ចការ ដែលយកទៅកែតម្រូវសារជាថ្មី អាចនឹងមានប្រយោជន៍ច្រើន ទោះបីជានៅក្នុងថ្នាក់ដែលមានសិស្សច្រើនក៏ដោយ។[7]

៣.៦ បញ្ជីត្រួតពិនិត្យការវាយតម្លៃសម្រាប់ថ្នាក់រៀនបរិយាបន្ន

- ☐ កត់ត្រាចំណុចចាប់ផ្តើមនៃការសិក្សារបស់សិស្សម្នាក់ៗ
- ☐ តាមដានដំណើរការសិក្សារបស់សិស្សម្នាក់ៗ
- ☐ ប្រើឧបករណ៍វាយតម្លៃដូចជា និទ្ទេសបទ ឬបញ្ជីត្រួតពិនិត្យ
- ☐ សម្របសម្រួលទម្រង់បែបបទ នៃការវាយតម្លៃទៅនឹងគោលបំណងការសិក្សា
- ☐ លើកទឹកចិត្តសិស្សឱ្យប្រើប្រាស់ បញ្ជីត្រួតពិនិត្យផ្ទាល់ខ្លួនរបស់ពួកគេ ដើម្បីឱ្យពួកគេអាចវាយតម្លៃខ្លួនឯងបាន និងកំណត់គោលដៅសិក្សាសម្រាប់ខ្លួនគេ
- ☐ ធ្វើការវាយតម្លៃជាបន្តបន្ទាប់ ដើម្បីប្រៀបធៀបសិស្សជាមួយខ្លួនគេផ្ទាល់
- ☐ បង្កើតទម្រង់វាយតម្លៃខុសៗគ្នា(ទាហរណ៍៖ផលបត្រសិក្សារបស់សិស្ស ការធ្វើការងារគម្រោងជាក្រុម ឬបុគ្គលម្នាក់ៗ ការធ្វើបទបង្ហាញផ្ទាល់មាត់)

[7] Taken from Sanger (2020, p. 54). CC BY 4.0.

- ☐ បង្កើតទម្រង់ធ្វើតេស្តបែបបុរាណផ្សេងៗគ្នា (ឧទាហរណ៍៖ សំណួរដែលមានចម្លើយពហុជ្រើសរើស ចម្លើយខ្លី ការផ្គូផ្គង ការបំពេញល្អះ)
- ☐ ប្រើកិច្ចការសាលាដែលមានលក្ខណៈជាក់ស្តែង
- ☐ ចែករំលែកលទ្ធផលដែលបានពីការវាយតម្លៃ ជាមួយឪពុកម្តាយសិស្ស
- ☐ សម្របសម្រួលកិច្ចការឱ្យត្រូវទៅនឹងកម្រិតរបស់សិស្សម្នាក់ៗ
- ☐ ផ្តល់ការណែនាំដែលសិស្សគ្រប់គ្នាងាយយល់ (ដូចជា៖ ធ្វើឡើងដោយផ្ទាល់មាត់ ឬដោយបោះពុម្ពជាអក្សរធំៗ)
- ☐ ឱ្យសិស្សឆ្លើយជាពាក្យសម្តីជំនួសឱ្យការសរសេរបន្ថែមពេលវេលាទៅលើកិច្ចការសាលា
- ☐ ផ្តល់កន្លែងមួយដែលមានការរំខានតិចតួចបំផុត

(ElSaheli-Elhage & Sawilowsky, 2016; Lauzon, n.d.)

៤ ចំណុចគន្លឹះ

- ✓ នៅក្នុងថ្នាក់រៀនមេត្រីសិក្សា (Learning-Friendly Classroom) សិស្សទទួលបានការគាំទ្រក្នុងដំណើរការសិក្សារបស់ពួកគេ ដោយការបង្កើតបរិយាកាសដែលមានសុវត្ថិភាព និងរួសរាយរាក់ទាក់។
- ✓ សមត្ថភាពទាំងឡាយ ដែលកំណត់ក្នុងកម្មវិធីសិក្សាស្នូល ត្រូវសមស្របជាមួយសិស្សទាំងអស់។ ទោះជាយ៉ាងនេះក្តីសិស្សទទួលបានចំណេះដឹងនិងជំនាញតាមវិធីផ្សេងៗគ្នា និងក្នុងល្បឿនមិនដូចគ្នាផងដែរ។
- ✓ ការរៀបចំផែនការបែបពីរ៉ាមីដ *(Planning Pyramid)* និងតារាង៣កូឡោន *(Three-Column Table)* គឺជាបណ្តុំសមត្ថភាពដែលអាចធ្វើទៅបាន ដើម្បីបែងចែកកម្រិតខុសៗគ្នានៃសមត្ថភាពសិស្ស និងផ្តល់នូវការសម្របសម្រួលដែលចាំបាច់សម្រាប់សិស្សម្នាក់ៗ។
- ✓ ស្របទៅតាមវិធីសាស្ត្រនៃការរៀបចំការសិក្សាជាសាកលសម្រាប់ការសិក្សា (Universal Design of Learning) គ្រូបង្រៀនគួរតែពិចារណាទៅលើមធ្យោបាយជាច្រើននៃការចូលរួមធ្វើបទបង្ហាញ និងការបញ្ចេញគំនិតយោបល់។

- ✓ ឧទាហរណ៍នៃការបង្ហាញដែលមានន័យច្រើន (Multiple means of representation)៖ បង្ហាញអត្ថបទភ្ជាប់ជាមួយរូបភាព ការប្រើវត្ថុដើម្បីបង្ហាញពីរូបរាងក្នុងគណិតវិទ្យា។
- ✓ ឧទាហរណ៍នៃការចូលរួម ដែលមានន័យច្រើន (Mltiple means of engagement)៖ ទុកឱកាសឱ្យសិស្សរៀនដោយការអនុវត្តជាក់ស្តែង ដោយរួមបញ្ចូលការលេងល្បែងសិក្សាទៅក្នុងបទពិសោធនៃការរៀនសូត្រ។
- ✓ ឧទាហរណ៍នៃការបញ្ចេញគំនិតយោបល់ដែលមានន័យច្រើន (Multiple means of expression)៖ ការផ្តល់ឱកាសដល់សិស្ស ដើម្បីឆ្លើយតបតាមវិធីផ្សេងៗគ្នា ការសួរសំណួរបើក ដែលសិស្សអាចបញ្ចេញទស្សនៈផ្ទាល់ខ្លួនបាន។
- ✓ ការរៀនបែបសហការជំរុញលើកទឹកចិត្តឱ្យសិស្សចែករំលែកទំនួលខុសត្រូវ ហើយធ្វើការឆ្ពោះទៅរកគោលដៅរួមមួយជាមួយគ្នា។
- ✓ យុទ្ធសាស្ត្របង្រៀនសម្រាប់សិស្សមានតម្រូវការពិសេស៖ ការរៀបកិច្ចការតាមលំដាប់លំដោយ ការផ្តល់មតិយោបល់ប្រចាំថ្ងៃ ការចាប់ផ្តើមពីចំណុចតូចៗ និងផ្តុំឱ្យធំឡើង ការកាត់បន្ថយការលំបាកក្នុងកិច្ចការ ការសួរសំណួរដែលទាក់ទងនឹងដំណើរការ ការបង្ហាញរូបភាពជាក្រាហ្វិច ការបង្រៀន ការណែនាំជាក្រុម និងការប្រើគ្រូបង្រៀនជំនួស។
- ✓ គរុកោសល្យបែបបរិយាបន្នអាចជួយកែលម្អ "សិស្សមិនល្អ" និងអាចលុបបំបាត់ការរើសអើងទាំងឡាយ។
- ✓ សាលារៀនបរិយាបន្ន តម្រូវឱ្យមានការយល់ដឹងពីសមត្ថភាពរបស់កុមារម្នាក់ ជំនួសឱ្យការទុកពួកគេចោល ព្រោះតែគេមានសមត្ថភាពមិនគ្រាប់គ្រាន់។
- ✓ សាលារៀនបរិយាបន្ន ចូលចិត្តធ្វើការវាយតម្លៃការសិក្សាសិស្សក្នុងអំឡុងពេលរៀនសូត្រ ដើម្បីបង្ហាញពីការរីកចម្រើនសមត្ថភាពរបស់សិស្ស។
- ✓ ការវាយតម្លៃតាមបែបពិតជាក់ស្តែង ការប្រឡងដែលមិនកំណត់ពេល និងឱកាសសម្រាប់ការធ្វើសារជាថ្មី គួរតែត្រូវបានពិចារណា របស់គ្រូបង្រៀននៅក្នុងថ្នាក់រៀនបរិយាបន្ន។

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ឯកសារយោង

Ambrose, S. A., Bridges, M.W., DiPietro, M., Lovett, M.C., & Norman, M.K. (2010). ***How Learning Works: Seven Research-Based Principles for Smart Teaching*****. San Francisco, CA: Jossey Bass.**

Cambridge Dictionary (n.d.). ***Ability*****. Retrieved from: https://dictionary.cambridge.org/de/worterbuch/englisch/ability [2020, Dec. 16].**

Carey, L. (2016). ***Considering Learning Spaces: How Do We Design Inclusive Classrooms?*** **Retrieved from: https://www.kennedykrieger.org/stories/linking-research-classrooms-blog/considering-learning-spaces-how-do-we-design-inclusive-classrooms [2021, Apr. 07].**

Conderman, G. (2011, March). Middle School Co-Teaching: Effective Practices and Student Reflections. ***Middle School Journal*****, 42(4), 24-31.**

ElSaheli-Elhage, R. & Sawilowsky, S. (2016). Assessment Practices for Students with Learning Disabilities in Lebanese Private Schools: A National Survey. ***Cogent Education*****, 3(1), 1-20.**

Gould, A. & Vaughn, S. (2000). Planning for the Inclusive Classroom: Meeting the Needs of Diverse Learners. ***Catholic Education: A Journal of Inquiry & Practice*****, 3(3), 363-374.**

Hattie, J.A.C. & Yates, G.C.R. (2014). Using Feedback to Promote Learning. In: V.A. Benassi, C.E. Overson & C.M. Hakala, eds. ***Applying Science of Learning in Education: Infusing Psychological Science into the Curriculum*****. Retrieved from the Society for the Teaching of Psychology web site: http://teachpsych.org/ebooks/asle2014/index.php**

Healy, J. M., Aram, D. M., Horwitz, S. J., & Kessler, J. W. (1982). A Study of Hyperlexia. ***Brain and Language*****, 7, 1–23.**

Johnstone, C., Avagyan, A., & Marutyan, M. (2018). Universal Design for Learning. In: R. Tichá, et al., eds. ***Inclusive Education Strategies: A Textbook*** **(pp. 7-20). Minneapolis, MN: University of Minnesota.**

Jordan, A. & McGhie-Richmond, D. (2014). Identifying Effective Teaching Practices in Inclusive Classrooms. In: C. Forlin & T.

Loreman, eds. *International Perspectives on Inclusive Education, Volume 3: Measuring Inclusive Education* (pp. 133-157). Bingley, UK: Emerald Group Publishing.

Lauzon, N. (n.d.). *Checklists and Achievement Charts*. Retrieved from https://www.ldatschool.ca/checklists-achievement-charts/ [2021, Apr. 07].

Merriam-Webster Dictionary (n.d.). *Competence*. Retrieved from: https://www.merriam-webster.com/dictionary/competence [2020, Nov. 30].

Merriam-Webster Dictionary (n.d.). *Concept*. Retrieved from: https://www.merriam-webster.com/dictionary/concept [2020, Nov. 30].

Moore, C., Gilbreath, D., & Maiuri, F. (1998). *Educating Students with Disabilities in General Education Classrooms: A Summary of the Research*. Retrieved from https://files.eric.ed.gov/fulltext/ED419329.pdf [2021, Apr. 07].

Prengel, A. (2013). *Inklusive Bildung in der Primarstufe. Eine Wissenschaftliche Expertise des Grundschulverbandes*. Frankfurt am Main: Grundschulverband e.V.

Sanger, C.S. (2020). Inclusive Pedagogy and Universal Design Approaches of Diverse Learning Environments. In: C. Sanger & N. Gleason, eds. *Diversity and Inclusion in Global Higher Education* (pp. 31-71). Singapore: Palgrave Macmillan. Licensed under the terms of the Creative Commons Attribution 4.0 International License (https://creativecommons.org/licenses/by/4.0/).

Schmit, J., Alper, S., Raschke, D., & Ryndak, D. (2000). Effects of Using a Photographic Cueing Package During Routine School Transitions with a Child Who Has Autism. *Mental Retardation*, 38(2), 131-137.

Schumm, J. S., Vaughn, S., & Leavell, A. G. (1994). Planning Pyramid: A Framework for Planning for Diverse Student Needs During Content Area Instruction. *The Reading Teacher*, 47(8), 608-615.

The Glossary of Education Reform (2014, May 15). *Learning Objectives*. Retrieved from: https://www.edglossary.org/learning-objectives [2020, Nov. 19].

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

The Glossary of Education Reform (2015, October 11). *Assessment.* Retrieved from: https://www.edglossary.org/assessment/ [2020, Dec. 11].

Tichá, R., et al. (2018). Instructional Strategies for Inclusive Classrooms: PALS, Cooperative Learning, Direct Instruction and Play-Based Strategies. In: R. Tichá, et al., eds. *Inclusive Education Strategies: A Textbook* (pp. 105-124). Minneapolis, MN: University of Minnesota.

Udvari-Solner, A., Thousand, J.S., Villa, R.A., Quiocho, A., & Kelly, M.G. (2005). Promising Practices That Foster Inclusive Education. In: R.A. Villa & J.S. Thousand, eds. *Creating an Inclusive School* (pp. 97-123). Alexandria: ASCD publications.

UNESCO. (2015). Booklet 1: Becoming an Inclusive Learning-Friendly Environment (ILFE). In: *Embracing Diversity: Toolkit for Creating Inclusive, Learning-Friendly Environments*. UNESCO Bangkok Office. This publication is available in Open Access under the Attribution-ShareAlike 3.0 IGO (CC-BY-SA 3.0 IGO) license (http://creativecommons.org/licenses/by-sa/3.0/igo/).

UNESCO. (2015). Booklet 4: Creating Inclusive, Learning-Friendly Classrooms. In: *Embracing Diversity: Toolkit for Creating Inclusive, Learning-Friendly Environments*. UNESCO Bangkok Office. This publication is available in Open Access under the Attribution-ShareAlike 3.0 IGO (CC-BY-SA 3.0 IGO) license (http://creativecommons.org/licenses/by-sa/3.0/igo/).

UNESCO. (2015). Booklet 5: Managing Inclusive, Learning-Friendly Classrooms. In: *Embracing Diversity: Toolkit for Creating Inclusive, Learning-Friendly Environments*. UNESCO Bangkok Office. This publication is available in Open Access under the Attribution-ShareAlike 3.0 IGO (CC-BY-SA 3.0 IGO) license (http://creativecommons.org/licenses/by-sa/3.0/igo/).

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ជំហានទី១. លំហាត់ពង្រឹងចំណេះដឹង

ក. ចូរជ្រើសរើសលក្ខណៈដែលពណ៌នាពីបរិយាកាសសិក្សាបរិយាបន្ន/មេត្រីសិក្សាពីបញ្ជីខាងក្រោម៖

១. បរិយាកាសដែលមានសុវត្ថិភាព និងស្វាគមន៍

២. បង្កើនការចូលរួមនិងការរៀនសូត្ររបស់សិស្សម្នាក់ៗ

៣. វិធីសាស្ត្រតែមួយសម្រាប់សិស្សគ្រប់គ្នា ដើម្បីទទួលបានចំណេះដឹង និងជំនាញ

៤. ការប្រឡងមានសារៈសំខាន់ក្នុងលំដាប់លេខ២

៥. ផ្តោតជាចម្បងទៅលើមុខវិជ្ជា និងការប្រឡង

៦. ធានាថាសិស្សទទួលបានចំណេះដឹង និងជំនាញផ្សេងៗរួមទាំងវិធីសាស្ត្រ

៧. គ្រូបង្រៀនកំណត់ពីវិធីសាស្ត្រ និងរបៀបដែលសិស្សគួររៀន

៨. ចំណុចចាប់ផ្តើមមេរៀនមួយសម្រាប់សិស្សគ្រប់គ្នា

៩. ពិចារណាលើចំណុចចាប់ផ្តើមមេរៀនដោយផ្តោតលើសិស្សម្នាក់ៗ

១០. ចាប់ផ្តើមពីសមត្ថភាពមូលដ្ឋានបំផុត ដើម្បីកសាងសមត្ថភាពកម្រិតខ្ពស់

១១. ផ្តោតទៅលើសក្តានុពលរបស់សិស្សម្នាក់ៗ

បរិយាកាសសិក្សាបែបបរិយាបន្ន/មេត្រីសិក្សា

ខ. ចូរដាក់ការពណ៌នាខាងក្រោមទៅក្នុងកម្រិត ដែលត្រឹមត្រូវនៃការរៀបចំផែនការបែបពីរ៉ាមីត៖

១. សមត្ថភាពដែលសិស្សភាគច្រើនគួរទទួលយកបាន

២.សមត្ថភាពដែលសិស្សទាំងអស់គួរទទួលបាន

៣. សមត្ថភាពដែលសិស្សមួយចំនួនគួរទទួលយកបាន



គ. ចូរជ្រើសរើសចម្លើយត្រឹមត្រូវតែមួយគត់៖

១. ស្រទាប់នៃការរៀបចំផែនការបែបពីរ៉ាមីត

ក. ក្រុមដែលស្ថិតនៅបាតខាងក្រោម នៃការរៀបចំផែនការបែបពីរ៉ាមីត មិនប្រើសម្ភារៈអ្វីទេ។

ខ. ក្រុមដែលស្ថិតនៅបាតខាងក្រោម នៃការរៀបចំផែនការបែបពីរ៉ាមីត ប្រើសម្ភារៈតិចតួចបំផុត។

គ. ក្រុមដែលស្ថិតនៅបាតខាងក្រោម នៃការរៀបចំផែនការបែបពីរ៉ាមីត ប្រើសម្ភារៈច្រើនបំផុត។

២. តើអំណះអំណាងណាដែលត្រឹមត្រូវ?

ក. បញ្ញត្តិដែលបានបង្ហាញនៅក្នុងក្រុម ដែលស្ថិតនៅបាតក្រោម នៃការរៀបចំផែនការបែបពីរ៉ាមីត គឺជាអង្គហេតុបន្ថែមនៃការពង្រីកបញ្ញត្តិមូលដ្ឋាន បញ្ញត្តិពាក់ព័ន្ធ ឬបញ្ញត្តិដែលស្មុគ្រស្មាញជាង

ខ. បញ្ញត្តិដែលបានបង្ហាញនៅក្នុងក្រុម ដែលស្ថិតនៅបាតក្រោម នៃការរៀបចំផែនការបែបពីរ៉ាមីត ត្រូវបានគេដាក់បង្ហាញជូនដាទូទៅ និងទូលំទូលាយ។

គ. បញ្ញត្តិដែលបានបង្ហាញនៅក្នុងក្រុម ដែលស្ថិតនៅបាតក្រោម នៃការរៀបចំផែនការបែបពីរ៉ាមីត មិនត្រូវបានគេចាត់ទុកថាមានសារៈសំខាន់ជាចម្បងនោះទេ ប៉ុន្តែជាព័ត៌មានបន្ថែមបន្ទាប់បន្សំប៉ុណ្ណោះ។

៣. តើអំណះអំណាងណាដែលនិយាយអំពី ដំណើរចូលទៅរកបញ្ញត្តិដែលត្រឹមត្រូវ?

ក. គ្រប់ស្រទាប់នៃការរៀបចំផែនការបែបពីរ៉ាមីត ស្មើនឹងកម្រិតសមត្ថភាពរបស់សិស្ស

ខ. សិស្សម្នាក់ៗត្រូវតែមានច្រកចូលទៅរកស្រទាប់ទាំងបី នៃការរៀបចំផែនការបែបពីរ៉ាមីត។

គ. សិស្សអាចអភិវឌ្ឍតែសមត្ថភាពក្នុងស្រទាប់ណាមួយ នៃការរៀបចំផែនការបែបពីរ៉ាមីតប៉ុណ្ណោះ។

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

៤. តើអ្វីទៅគោលបំណងនៃការរៀបផែនការបែបពីរ៉ាមីត?

ក. ការរៀបចំផែនការបែបពីរ៉ាមីត បែងចែកគ្រូបង្រៀនទៅតាមក្រុម។

ខ. ការរៀបចំផែនការបែបពីរ៉ាមីត បែងចែកសិស្សទៅតាមក្រុម។

គ. ការរៀបចំផែនការបែបពីរ៉ាមីត បែងចែកសមត្ថភាពដែលសិស្សគួរទទួលបាន។

ឃ. ចូរដាក់លក្ខណៈទាំងនេះចូលទៅតាមក្រុមឱ្យបានត្រឹមត្រូវតាមតារាង៖

១. ភាសាសញ្ញា

២. ពិចារណាដល់ចំណេះដឹង ដែលមានស្រាប់របស់សិស្ស

៣. ព័ត៌មានតាមរយៈរូបភាពត្រូវបានដាក់ជាគូ ជាមួយព័ត៌មានតាមពាក្យសម្តី

៤. ពាក្យគន្លឹះត្រូវបានដាក់ឱ្យសិស្ស

៥. ការបង្ហាញចំណេះដឹង និងសមត្ថភាពតាមវិធីមួយ ដែលល្អបំផុតសម្រាប់សិស្សម្នាក់ៗ

៦. ការរាយការណ៍ដោយផ្ទាល់មាត់

៧. សកម្មភាពផ្គុំរូបភាព

៨. វាគ្មិន

៩. សិស្សសាកល្បងប្រើគំនិត

១០. ការនិទានរឿងដោយផ្ទាល់មាត់

១១. រូបភាពវីដេអូ

១២. ការបង្រៀនបែបសិស្សមជ្ឈមណ្ឌល

១៣. ការគូររូបភាព

១៤. ការរាយការណ៍ជាលាយលក្ខណ៍អក្សរ

១៥. វត្ថុដែលមានរាងខុសៗគ្នា

១៦. សិស្សជ្រើសរើសសម្ភារៈសិក្សាដែលខុសគ្នាទាំងទ្រង់ទ្រាយ និងកម្រិត

១៧. សិស្សមានលទ្ធភាពឆ្លើយតាមរបៀបដែលខុសគ្នា

១៨. សំណួរបើក

១៩. ការចូលរួមរបស់សិស្សយ៉ាងសកម្ម

២០. ការសម្តែងល្ខោន

២១. ការសន្ទនាជាក្រុមតូច

អត្ថន័យនៃការបង្ហាញ	**អត្ថន័យនៃការចូលរួម**	**អត្ថន័យនៃសកម្មភាព/ការបញ្ចេញយោបល់**

ង. ចូរបំពេញចន្លោះដោយប្រើឃ្លាក្នុងប្រអប់ឱ្យបានត្រឹមត្រូវ៖

អនុវត្តជំនាញគ្រប់គ្រងទំនាស់	សម្ភារៈ តួនាទី និងឱកាសសិក្សា	ជំនាញប្រាស្រ័យទាក់ទងល្អ

១.ការរៀនបែបសហការ ជំរុញឱ្យសិស្សចែករំលែកទំនួលខុសត្រូវ _____

២. ការរៀនបែបសហការ ជួយឱ្យសិស្សដោះស្រាយបញ្ហាមួយរួមគ្នា ហើយជួយពួកគេឱ្យ _____

៣.ការរៀនបែបសហការ ជួយឱ្យសិស្សអនុវត្តលើ _____និងឥរិយាបថអត់ធ្មត់។

ច. ចូរជ្រើសរើសយុទ្ធសាស្ត្របង្រៀនសមស្របសម្រាប់សិស្សមានតម្រូវការពិសេសពីបញ្ជីខាងក្រោម៖

១. រៀបបញ្ជាតិតាមលំដាប់លំដោយ

២. គ្មានសំណួរដែលពាក់ព័ន្ធនឹងដំណើរការ ឬខ្លឹមសារទេ

៣. លើកឡើងនូវគំនិតដដែលៗ

៤. ផ្តល់ព័ត៌មានត្រឡប់ជារៀងរាល់ថ្ងៃ

៥. ចាប់ផ្តើមពីផ្នែកតូចៗ បន្ទាប់មកកសាងជាខ្លឹមសារ

៦. គ្មានការចូលរួមពីឪពុកម្តាយសិស្សទេ

៧. រៀបចំកិច្ចការតាមលំដាប់លំដោយពីស្រួលទៅលំបាក

៨. សួរសំណួរដែលទាក់ទងទៅនឹងដំណើរការ និងខ្លឹមសារពាក់ព័ន្ធ

៩. គ្មានការបែងចែកកិច្ចការទេ

១០. ភ្ជាប់ការនិយាយជាពាក្យសម្តី ទៅនឹងរូបភាពជាក់ស្តែង

១១. ចាប់ផ្តើមចេញពីគំនិតដែលស្មុគស្មាញទៅរកគំនិតដែលងាយយល់

១២. បំពេញបន្ថែមចំណុចខ្វះខាតដែលគ្រូបង្រៀនមាន

១៣. ការគាំទ្រពីសំណាក់មិត្តភក្តិ

១៤. ផ្តល់តែការពន្យល់ជាពាក្យសម្តី ឬរូបភាពតែប៉ុណ្ណោះ

យុទ្ធសាស្ត្របង្រៀនសមស្របសម្រាប់សិស្សមានតម្រូវការពិសេស

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ឆ. ចូរបង្ហាញថាអំណះអំណាងខាងក្រោមត្រូវ (ត) ឬ ខុស (ខ)

១. សាលារៀនបរិយាបន្នគាំទ្រលើការវាយតម្លៃសរុប។ ត / ខ

២. ការវាយតម្លៃជាបន្តបន្ទាប់ជាប់រហូត អាចសម្រេចបានតាមរយៈ ការសង្កេតមើល ផលបត្រសិក្សា ការវាយតម្លៃលើខ្លួនឯង រួមទាំងតាមរយៈការប្រឡង និងការធ្វើសំណួរខ្លី។ ត / ខ

៣. ការវាយតម្លៃជាបន្តបន្ទាប់ជាប់រហូត មិនបង្ហាញឱ្យសិស្សបានឃើញថាតើពួកគេកំពុងរៀនបានល្អ និងវិធានការអ្វីដែលពួកគេត្រូវចាត់ចែងដើម្បីឱ្យមានការរីកចម្រើននោះទេ។ ត / ខ

៤. ការប្រឡងចុងឆ្នាំនាំឱ្យមានការយឺតយ៉ាវ សម្រាប់ឪពុកម្តាយក្នុងការជួយកុមារ ដែលត្រូវការគាំទ្រនៅក្នុងដំណើរការរៀនសូត្រ។ ត / ខ

៥. ឧបករណ៍វាយតម្លៃដែលរៀបចំបានត្រឹមត្រូវដូចជា និទ្ទេសបទ ឬបញ្ជីត្រួតពិនិត្យ ធ្វើឱ្យសិស្សដែលមានតម្រូវការពិសេសយល់ច្រឡំ ដូច្នេះវាមិនបានជួយពួកគេដោយជោគជ័យក្នុងការយល់ពីកិច្ចការរបស់គ្រូបង្រៀនដែលបានដាក់ឱ្យឡើយ។ ត / ខ

៦. ការវាយតម្លៃលទ្ធផលសិស្ស ដែលផ្តោតលើការពិតជាក់ស្តែង ពឹងផ្អែកជាចម្បងទៅលើការចងចាំចំណេះដឹងមិនសមស្របនឹងបរិបទ។ ត / ខ

ជ. ចូរសរសេរសំណេរបែបខ្លី (ប្រហែលជា៥០០ពាក្យ) សម្រាប់សំណួរការឆ្លុះបញ្ចាំងខាងក្រោម៖

១. ចំពោះអ្នក តើអ្វីទៅជាបរិយាកាសមេត្រីសិក្សា?

២. តើអ្នកមានបទពិសោធអ្វីខ្លះពាក់ព័ន្ធនឹង ការបង្ហាញដែលមានអត្ថន័យច្រើន ការចូលរួមដែលមានអត្ថន័យ ច្រើន និង សកម្មភាព/ការបញ្ចេញគំនិតយោបល់ដែលមានអត្ថន័យច្រើន? តើការធ្វើឱ្យមានភាពចម្រុះគ្នាអ្វីខ្លះដែលអ្នកធ្លាប់បានឆ្លងកាត់ក្នុងរយៈពេលជាច្រើនឆ្នាំដែលអ្នកនៅជាសិស្ស? តើមានការគិតគូរពីភាពចម្រុះគ្នានេះគ្រប់គ្រាន់ឬទេ? តើវាអាចជួយបានដែរឬទេ? តើមានអ្វីទៀតដែលកាលនោះអ្នកត្រូវការចាំបាច់ ដើម្បីជួយឱ្យអ្នកមានអារម្មណ៍ថាត្រូវបានគេជួយគាំទ្រយ៉ាងពេញទំហឹងក្នុងដំណើរការរៀនសូត្ររបស់អ្នក?

ជំហានទី១.លំហាត់អនុវត្ត ដំណោះស្រាយ

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ក. ចូរជ្រើសរើសលក្ខណៈដែលពិពណ៌នាពីបរិយាកាសសិក្សាបរិយាបន្ន/មេត្រីសិក្សាពីបញ្ជីខាងក្រោម៖

១. បរិយាកាសដែលមានសុវត្ថិភាព និងស្វាគមន៍

២. បង្កើនការចូលរួមនិងការរៀនសូត្ររបស់សិស្សម្នាក់ៗ

៣. វិធីសាស្ត្រតែមួយសម្រាប់សិស្សគ្រប់គ្នា ដើម្បីទទួលបានចំណេះដឹង និងជំនាញ

៤. ការប្រឡងមានសារៈសំខាន់ក្នុងលំដាប់លេខ២

៥. ផ្តោតជាចម្បងទៅលើមុខវិជ្ជា និងការប្រឡង

៦. ធានាថាសិស្សទទួលបានចំណេះដឹង និងជំនាញផ្សេងៗរួមទាំងវិធីសាស្ត្រ

៧. គ្រូបង្រៀនកំណត់ពីវិធីសាស្ត្រ និងរបៀបដែលសិស្សគួររៀន

៨. ចំណុចចាប់ផ្តើមមេរៀនមួយសម្រាប់សិស្សគ្រប់គ្នា

៩. ពិចារណាលើចំណុចចាប់ផ្តើមមេរៀនដោយផ្តោតលើសិស្សម្នាក់ៗ

១០. ចាប់ផ្តើមពីសមត្ថភាពមូលដ្ឋានបំផុត ដើម្បីកសាងសមត្ថភាពកម្រិតខ្ពស់

១១. ផ្តោតទៅលើសក្តានុពលរបស់សិស្សម្នាក់ៗ

បរិយាកាសសិក្សាដែលងាយស្រួល/រួមបញ្ចូលគ្នា
១,២,៤,៦,៩,១០,១១

ខ. ចូរដាក់ការពិពណ៌នាខាងក្រោមទៅក្នុងកម្រិត ដែលត្រឹមត្រូវនៃការរៀបចំផែនការបែបពីរ៉ាមីត៖

១. សមត្ថភាពដែលសិស្សភាគច្រើនគួរទទួលយកបាន

២.សមត្ថភាពដែលសិស្សទាំងអស់គួរទទួលបាន

៣. សមត្ថភាពដែលសិស្សមួយចំនួនគួរទទួលយកបាន



គ. ចូរជ្រើសរើសចម្លើយត្រឹមត្រូវតែមួយគត់៖

១. ស្រទាប់នៃការរៀបចំផែនការបែបពីរ៉ាមីត

ក. ក្រុមដែលស្ថិតនៅបាតខាងក្រោម នៃការរៀបចំផែនការបែបពីរ៉ាមីត មិនប្រើសម្ភារៈអ្វីទេ។

ខ. ក្រុមដែលស្ថិតនៅបាតខាងក្រោម នៃការរៀបចំផែនការបែបពីរ៉ាមីត ប្រើសម្ភារៈតិចតួចបំផុត។

គ. ក្រុមដែលស្ថិតនៅបាតខាងក្រោម នៃការរៀបចំផែនការបែបពីរ៉ាមីត ប្រើសម្ភារៈច្រើនបំផុត។

២. តើអំណះអំណាងណាដែលត្រឹមត្រូវ?

ក. បញ្ញត្តិដែលបានបង្ហាញនៅក្នុងក្រុម ដែលស្ថិតនៅបាតក្រោម នៃការរៀបចំផែនការបែបពីរ៉ាមីត គឺជាអង្គហេតុបន្ថែមនៃការពង្រីកបញ្ញត្តិមូលដ្ឋាន បញ្ញត្តិពាក់ព័ន្ធ ឬបញ្ញត្តិដែលស្មុគស្មាញជាង

ខ. បញ្ញត្តិដែលបានបង្ហាញនៅក្នុងក្រុម ដែលស្ថិតនៅបាតក្រោម នៃការរៀបចំផែនការបែបពីរ៉ាមីត ត្រូវបានគេដាក់បង្ហាញជូនដាទូទៅ និងទូលំទូលាយ។

គ. បញ្ញត្តិដែលបានបង្ហាញនៅក្នុងក្រុម ដែលស្ថិតនៅបាតក្រោម នៃការរៀបចំផែនការបែបពីរ៉ាមីត មិនត្រូវបានគេចាត់ទុកថាមានសារៈសំខាន់ជាចម្បងនោះទេ ប៉ុន្តែជាព័ត៌មានបន្ថែមបន្ទាប់បន្សំប៉ុណ្ណោះ។

៣. តើអំណះអំណាងណាដែលនិយាយអំពី ដំណើរចូលទៅរកបញ្ញត្តិដែលត្រឹមត្រូវ?

ក. គ្រប់ស្រទាប់នៃការរៀបចំផែនការបែបពីរ៉ាមីត ស្មើនឹងកម្រិតសមត្ថភាពរបស់សិស្ស

ខ. សិស្សម្នាក់ៗត្រូវតែមានច្រកចូលទៅរកស្រទាប់ទាំងបី នៃការរៀបចំផែនការបែបពីរ៉ាមីត។

គ. សិស្សអាចអភិវឌ្ឍតែសមត្ថភាពក្នុងស្រទាប់ណាមួយ នៃការរៀបចំផែនការបែបពីរ៉ាមីតប៉ុណ្ណោះ។

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

៤. តើអ្វីទៅគោលបំណងនៃការរៀបផែនការបែបពីរ៉ាមីត?

ក. ការរៀបចំផែនការបែបពីរ៉ាមីត បែងចែកគ្រូបង្រៀនទៅតាមក្រុម។

ខ. ការរៀបចំផែនការបែបពីរ៉ាមីត បែងចែកសិស្សទៅតាមក្រុម។

គ. ការរៀបចំផែនការបែបពីរ៉ាមីត បែងចែកសមត្ថភាពដែលសិស្សគួរទទួលបាន។

ឃ. ចូរដាក់លក្ខណៈទាំងនេះចូលទៅតាមក្រុមឱ្យបានត្រឹមត្រូវតាមតារាង៖

១. ភាសាសញ្ញា

២. ពិចារណាដល់ចំណេះដឹង ដែលមានស្រាប់របស់សិស្ស

៣. ព័ត៌មានតាមរយៈរូបភាពត្រូវបានដាក់ជាគូ ជាមួយព័ត៌មានតាមពាក្យសម្តី

៤. ពាក្យគន្លឹះត្រូវបានដាក់ឱ្យសិស្ស

៥. ការបង្ហាញចំណេះដឹង និងសមត្ថភាពតាមវិធីមួយ ដែលល្អបំផុតសម្រាប់សិស្សម្នាក់ៗ

៦. ការរាយការណ៍ដោយផ្ទាល់មាត់

៧. សកម្មភាពផ្គុំរូបភាព

៨. វាគ្មិន

៩. សិស្សសាកល្បងប្រើគំនិត

១០. ការនិទានរឿងដោយផ្ទាល់មាត់

១១. រូបភាពវីដេអូ

១២. ការបង្រៀនបែបសិស្សមជ្ឈមណ្ឌល

១៣. ការគូររូបភាព

១៤. ការរាយការណ៍ជាលាយលក្ខណ៍អក្សរ

១៥. វត្ថុដែលមានរាងខុសៗគ្នា

១៦. សិស្សជ្រើសរើសសម្ភារៈសិក្សា ដែលខុសគ្នាទាំងទ្រង់ទ្រាយ និងកម្រិត

១៧. សិស្សមានលទ្ធភាពឆ្លើយតាមរបៀបដែលខុសគ្នា

១៨. សំណួរបើក

១៩. ការចូលរួមរបស់សិស្សយ៉ាងសកម្ម

២០. ការសម្តែងល្ខោន

២១. ការសន្ទនាជាក្រុមតូច

មធ្យោបាយនៃការបង្ហាញជូន	មធ្យោបាយនៃការធ្វើឱ្យមានទំនាក់ទំនងនឹងគ្នា	មធ្យោបាយនៃសកម្មភាព/ការបញ្ជាក់ពីគំនិត
៣	២	១
៤	៧	៥
៨	៩	៦
១០	១២	១៣
១១	១៩	១៤
១៥	២០	១៧
១៦	២១	១៨

ង. ចូរបំពេញចន្លោះដោយប្រើឃ្លាក្នុងប្រអប់ឱ្យបានត្រឹមត្រូវ៖

អនុវត្តជំនាញចាត់ចែងរៀបចំទំនាស់	សម្ភារៈ,តួនាទី និងឱកាសសិក្សា	ជំនាញប្រាស្រ័យទាក់ទងល្អ

១. ការរៀនបែបសហការ ជំរុញឱ្យសិស្សចែករំលែកទំនួលខុសត្រូវ <u>សម្ភារៈ,តួនាទី និងឱកាសសិក្សា</u> ។

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

២. ការរៀនបែបសហការ ជួយឱ្យសិស្សដោះស្រាយបញ្ហាមួយរួមគ្នា ហើយជួយពួកគេឱ្យ អនុវត្ត ជំនាញចាត់ចែងរៀបចំទំនាស់ ។

៣. ការរៀនបែបសហការ ជួយឱ្យសិស្សអនុវត្តលើ ជំនាញប្រាស្រ័យទាក់ទងល្អ ។

ច.ចូរជ្រើសរើសយុទ្ធសាស្ត្របង្រៀនសមស្របសម្រាប់សិស្សមានតម្រូវការពិសេសពីបញ្ជីខាងក្រោម៖

១. រៀបបញ្ញត្តិតាមលំដាប់លំដោយ

២. គ្មានសំណួរដែលពាក់ព័ន្ធនឹងដំណើរការ ឬខ្លឹមសារទេ

៣. លើកឡើងនូវគំនិតដដែលៗ

៤. ផ្តល់ព័ត៌មានត្រឡប់ជារៀងរាល់ថ្ងៃ

៥. ចាប់ផ្តើមពីផ្នែកតូចៗ បន្ទាប់មកកសាងជាខ្លឹមសារ

៦. គ្មានការចូលរួមពីឪពុកម្តាយសិស្សទេ

៧. រៀបចំកិច្ចការតាមលំដាប់លំដោយពីស្រួលទៅលំបាក

៨. សួរសំណួរដែលទាក់ទងទៅនឹងដំណើរការ និងខ្លឹមសារពាក់ព័ន្ធ

៩. គ្មានការបែងចែកកិច្ចការទេ

១០. ភ្ជាប់ការនិយាយជាពាក្យសម្តី ទៅនឹងរូបភាពជាក់ស្តែង

១១. ចាប់ផ្តើមចេញពីគំនិត ដែលស្មុគស្មាញទៅរកគំនិតដែលងាយយល់

១២. បំពេញបន្ថែមចំណុចខ្វះខាតដែលគ្រូបង្រៀនមាន

១៣. ការគាំទ្រពីសំណាក់មិត្តភក្តិ

១៤. ផ្តល់តែការពន្យល់ជាពាក្យសម្តី ឬរូបភាពតែប៉ុណ្ណោះ

យុទ្ធសាស្ត្រសម្រាប់សិស្សដែលមានតម្រូវការពិសេសខាងអប់រំ
១,៣,៤,៥,៧,៨,១០,១២,១៣

ឆ. ចូរបង្ហាញថាអំណះអំណាងខាងក្រោមត្រូវ (ត) ឬ ខុស (ខ)

១. សាលារៀនបរិយាបន្នគាំទ្រលើការវាយតម្លៃសរុប។ ត / ខ

២. ការវាយតម្លៃជាបន្តបន្ទាប់ អាចសម្រេចបានតាមរយៈការសង្កេតមើលផលបត្រសិក្សា

ការវាយតម្លៃលើខ្លួនឯង រួមទាំងតាមរយៈការប្រឡង និងការធ្វើសំណួរខ្លី។ ត / ខ

៣. ការវាយតម្លៃជាបន្តបន្ទាប់ មិនបង្ហាញឱ្យសិស្សបានឃើញថាតើពួកគេកំពុងរៀនបានល្អ

និងវិធានការអ្វីដែលពួកគេត្រូវអនុវត្តដើម្បីឱ្យមានការរីកចម្រើននោះទេ។ ត / ខ

៤. ការប្រឡងចុងឆ្នាំនាំឱ្យមានការយឺតយ៉ាវ សម្រាប់ឪពុកម្តាយក្នុងការជួយកុមារ ដែលត្រូវការគាំទ្រនៅក្នុងដំណើរការរៀនសូត្រ។ ត / ខ

៥. ឧបករណ៍វាយតម្លៃដែលរៀបចំបានត្រឹមត្រូវដូចជា និទ្ទេសបទ ឬបញ្ជីត្រួតពិនិត្យ ធ្វើឱ្យ

សិស្សដែលមានតម្រូវការពិសេសយល់ច្រឡំ ដូច្នេះវាមិនបានជួយពួកគេដោយជោគជ័យ ក្នុងការយល់ពីកិច្ចការរបស់គ្រូបង្រៀន ដែលបានដាក់ឱ្យឡើយ។ ត / ខ

៦. ការវាយតម្លៃលទ្ធផលសិស្ស ដែលផ្តោតលើការពិតជាក់ស្តែង ពឹងផ្អែកជាចម្បងទៅលើការចងចាំចំណេះដឹងមិនសមស្របនឹងបរិបទ។ ត / ខ

ជ. ចូរសរសេរសំណេរបែបខ្លី (ប្រហែលជា៥០០ពាក្យ) សម្រាប់សំណួរការឆ្លុះបញ្ចាំងខាងក្រោម៖

១. ចំពោះអ្នក តើអ្វីទៅជាបរិយាកាសមេត្រីសិក្សា?

២. តើអ្នកមានបទពិសោធអ្វីខ្លះពាក់ព័ន្ធនឹងការបង្ហាញដែលមានអត្ថន័យច្រើន ការចូលរួមដែលមានអត្ថន័យច្រើន និងសកម្មភាព/ការបញ្ចេញគំនិតយោបល់ដែលមានអត្ថន័យច្រើន? តើការធ្វើឱ្យមានភាពចម្រុះគ្នាអ្វីខ្លះដែលអ្នកធ្លាប់បានឆ្លងកាត់ក្នុងរយៈពេលជាច្រើនឆ្នាំដែលអ្នកនៅជាសិស្ស? តើមានការគិតគូរពីភាពចម្រុះគ្នានេះគ្រប់គ្រាន់ឬទេ? តើវាអាចជួយបានដែរឬទេ? តើមានអ្វីទៀតដែលកាលនោះអ្នកត្រូវការចាំបាច់ ដើម្បីជួយឱ្យអ្នកមានអារម្មណ៍ថាត្រូវបានគេជួយគាំទ្រយ៉ាងពេញទំហឹងក្នុងដំណើរការរៀនសូត្ររបស់អ្នក?

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ជំហានទី២៖ ជំហាត់អនុវត្ត

ក. ចូរអានករណីសិក្សាខាងក្រោម បន្ទាប់មកបំពេញតារាងខាងក្រោម៖

ករណីសិក្សាទី១

ប្រធានបទមួយ នៅក្នុងថ្នាក់រៀនមួយក្នុងចំណោមថ្នាក់រៀនជាច្រើនទៀតរបស់ខ្ញុំ ជាប់ទាក់ទងទៅនឹងរដូវ និងផ្លែឈើតាមរដូវ។ ខ្ញុំបានប្រើផ្លែឈើពិត និងរូបភាពផ្លែឈើ ដើម្បីប្រាប់សិស្សអំពីផ្លែឈើទាំងនោះ និងលក្ខណៈរបស់វា។ ក្រោយមកសិស្សមួយចំនួនសរសេរកំណាព្យពីផ្លែឈើ ចំណែកសិស្សផ្សេងទៀតកែច្នៃ និងផលិតរបាំងមុខអំពីផ្លែឈើដែលមានចម្រុះពណ៌។ សិស្សម្នាក់ៗជ្រើសរើសផ្លែឈើជាទីពេញចិត្តរបស់ខ្លួន ពាក់របាំងមុខហើយដើរតួសម្តែងពីតួនាទីនៃផ្លែឈើនោះ។ សិស្សធ្វើការជាក្រុម ដោយអាន និងសរសេរ។ ការរៀបចំកិច្ចតែងការបង្រៀនអាចនឹងចំណាយយពេលវេលា ប៉ុន្តែវាក៏សប្បាយ និងជាកិច្ចសាកល្បងនៃការច្នៃប្រឌិតមួយរបស់ខ្ញុំផងដែរ។ ជួនកាល វាពិបាកក្នុងការទទួលបាននូវប្រភេទធនធានដែលខ្ញុំត្រូវការ ប៉ុន្តែខ្ញុំបានរៀនពីការបញ្ចូលសិស្សក្នុងការរៀបចំមេរៀន។ សិស្ស និងខ្ញុំបាននាំយករបស់របរផ្សេងៗពីផ្ទះ។ យើងក៏បង្កើតសម្ភារៈជាមួយគ្នានៅក្នុងថ្នាក់ ដូចជារបាំងមុខសម្រាប់ការសម្តែង ឧបករណ៍សម្រាប់មុខរបរផ្សេងៗទៀត ការលេងល្បែង និងកំណាព្យ។

ករណីសិក្សាទី២

ក្នុងថ្នាក់រៀនរបស់ខ្ញុំ យើងបានរៀនអំពីមុខរបរក្នុងសហគមន៍របស់យើង។ សិស្សបានប្រាប់ឈ្មោះមុខរបរខុសៗគ្នា។ ពួកគេបាននឹកស្រមើស្រមៃ ហើយដើរតួពីអាជីពដែលគេចង់ធ្វើ។ ពួកគេបានពិភាក្សាគ្នាជាក្រុមអានទាំងព័ត៌មានទាំងឡាយស្តីពីអាជីពទាំងនោះ។ ពួកគេបានលេងល្បែងតម្រៀបរូបភាពជាមួយឧបករណ៍។ យើងក៏មានវាគ្មិនដែលបានធ្វើបទបង្ហាញពីអាជីពរបស់ពួកគេ។ ខ្ញុំតែងតែសាកល្បងរឿងរ៉ាវជាច្រើន ហើយខ្ញុំចាំបាច់ត្រូវធ្វើឱ្យសហគមន៍ក្នុងតំបន់យល់ថា ការរៀនមិនមែនកំណត់តែនៅក្នុងថ្នាក់រៀនប៉ុណ្ណោះទេ។

ករណីទី៣

ខ្ញុំប្រើវត្ថុដែលអាចរកបាននៅផ្ទះ ឬក៏នៅសាលារៀនដើម្បីបង្រៀនពីរាង/មាឌធរណីមាត្រ។ ខ្ញុំបានប្រើប្រអប់ មួក កំប៉ុង បាល់ និងរបស់ផ្សេងៗទៀត។ ខ្ញុំដាក់តាំងវត្ថុទាំងនេះនៅក្នុងថ្នាក់ ដើម្បីបង្ហាញពីរាងខុសៗគ្នាដែលគេអាចប្រទះឃើញនៅខាងក្នុង និងក្រៅថ្នាក់រៀន។ ដោយធ្វើការជាក្រុម សិស្សជ្រើសយកឧទាហរណ៍មួយ ហើយព្យាយាមដោះស្រាយទំនាក់ទំនងរបស់ប្រវែង ជ្រុង ផ្ទៃក្រឡា និងចំណុះ/មាឌ។ ពួកគេបង្កើតជារូបមន្តដែលអាចយកទៅអនុវត្តជាមួយឧទាហរណ៍ដទៃទៀតដែលមានរាងដូចគ្នា។ ក្នុងថ្នាក់រៀន

មួយទៀតសិស្សមួយក្រុមបានចាក់ទឹកបំពេញក្នុងធុងរាងជាសាជីមូលមួយ ដើម្បីប្រៀបធៀបចំណុះរបស់វាជាមួយនឹងចំណុះរបស់ស៊ីឡាំងមួយទៀត។[8]

	អត្ថន័យនៃការបង្ហាញ	អត្ថន័យនៃការចូលរួម	អត្ថន័យនៃសកម្មភាព/ការបញ្ចេញយោបល់
ករណីសិក្សាទី១			
ករណីសិក្សាទី២			
ករណីសិក្សាទី៣			

ខ. ចូរស្តាប់គ្រូបង្រៀនម្នាក់និយាយពីរបៀបដែលគាត់បង្រៀននៅក្នុងថ្នាក់រៀនបរិយាបន្នមួយ(Audio File 4.2.1) ចូរកំណត់ពីវិធីសាស្ត្រដែលបានលើកឡើងចូលក្នុងតារាងខាងក្រោម៖

អត្ថន័យនៃការបង្ហាញ	អត្ថន័យនឹការចូលរួម	អត្ថន័យនៃសកម្មភាព/ការបញ្ចេញយោបល់

ឯកសារពិគ្រោះ

UNESCO. (2015). Booklet 4: Creating Inclusive, Learning-Friendly Classrooms. In: *Embracing Diversity: Toolkit for Creating Inclusive, Learning-Friendly Environments*. UNESCO Bangkok Office. This publication is available in Open Access under the Attribution-ShareAlike 3.0 IGO (CC-BY-SA 3.0 IGO) license (http://creativecommons.org/licenses/by-sa/3.0/igo/).

[8] Adapted from UNESCO/Booklet Four (2015, p. 8; 63). CC BY-SA 3.0. IGO.

ជំហានទី២ ដំណោះស្រាយ

ក. ចូរអានករណីសិក្សាខាងក្រោម បន្ទាប់មកបំពេញតារាងខាងក្រោមៈ

ករណីសិក្សាទី១

ប្រធានបទមួយ នៅក្នុងថ្នាក់រៀនមួយក្នុងចំណោមថ្នាក់រៀនជាច្រើនទៀតរបស់ខ្ញុំ ជាប់ទាក់ទងទៅនឹងរដូវ និងផ្លែឈើតាមរដូវ។ ខ្ញុំបានប្រើផ្លែឈើពិត និងរូបភាពផ្លែឈើ ដើម្បីប្រាប់សិស្សអំពីផ្លែឈើទាំងនោះ និងលក្ខណៈរបស់វា។ ក្រោយមកសិស្សមួយចំនួនសរសេរកំណាព្យពីផ្លែឈើ ចំណែកសិស្សផ្សេងទៀតកែច្នៃ និងផលិតរបាំងមុខអំពីផ្លែឈើដែលមានចម្រុះពណ៌។ សិស្សម្នាក់ៗជ្រើសរើសផ្លែឈើជាទីពេញចិត្តរបស់ខ្លួន ពាក់របាំងមុខហើយដើរតួសម្តែងពី តួនាទីនៃផ្លែឈើនោះ។ សិស្សធ្វើការជាក្រុម ដោយអាន និងសរសេរ។ ការរៀបចំកិច្ចតែងការបង្រៀនអាចនឹងចំណាយពេលវេលា ប៉ុន្តែវាក៏សប្បាយ និងជាកិច្ចសាកល្បងនៃការច្នៃប្រឌិតមួយរបស់ខ្ញុំផងដែរ។ ជួនកាល វាពិបាកក្នុងការទទួលបាននូវប្រភេទធនធានដែលខ្ញុំត្រូវការ ប៉ុន្តែខ្ញុំបានរៀនពីការបញ្ចូលសិស្សក្នុងការរៀបចំមេរៀន។ សិស្ស និងខ្ញុំបាននាំយករបស់របរផ្សេងៗពីផ្ទះ។ យើងក៏បង្កើតសម្ភារៈជាមួយគ្នានៅក្នុងថ្នាក់ ដូចជារបាំងមុខសម្រាប់ការសម្តែង ឧបករណ៍សម្រាប់មុខរបរផ្សេងៗទៀត ការលេងល្បែង និងកំណាព្យ។

ករណីសិក្សាទី២

ក្នុងថ្នាក់រៀនរបស់ខ្ញុំ យើងបានរៀនអំពីមុខរបរក្នុងសហគមន៍របស់យើង។ សិស្សបានប្រាប់ឈ្មោះមុខរបរខុសៗគ្នា។ ពួកគេបាននឹកស្រមើស្រមៃ ហើយដើរតួពីអាជីពដែលគេចង់ធ្វើ។ ពួកគេបានពិភាក្សាគ្នាជាក្រុម អានទាំងព័ត៌មានទាំងឡាយស្តីពីអាជីពទាំងនោះ។ ពួកគេបានលេងល្បែងតម្រៀបរូបភាពជាមួយឧបករណ៍។ យើងក៏មានវាគ្មិនដែលបានធ្វើបទបង្ហាញពីអាជីពរបស់ពួកគេ។ ខ្ញុំតែងតែសាកល្បងរឿងរ៉ាវជាច្រើន ហើយខ្ញុំចាំបាច់ត្រូវធ្វើឱ្យសហគមន៍ក្នុងតំបន់យល់ថា ការរៀនមិនមែនកំណត់តែនៅក្នុងថ្នាក់រៀនប៉ុណ្ណោះទេ។

ករណីទី៣

ខ្ញុំប្រើវត្ថុដែលអាចរកបាននៅផ្ទះ ឬក៏នៅសាលារៀនដើម្បីបង្រៀនពីរាង/មាឌធរណីមាត្រ។ ខ្ញុំបានប្រើប្រអប់ មួក កំប៉ុង បាល់ និងរបស់ផ្សេងៗទៀត។ ខ្ញុំដាក់តាំងវត្ថុទាំងនេះនៅក្នុងថ្នាក់ដើម្បីបង្ហាញពីរាងខុសៗគ្នាដែលគេអាចប្រទះឃើញនៅខាងក្នុង និងក្រៅថ្នាក់រៀន។ ដោយធ្វើការជាក្រុម សិស្សជ្រើសយកឧទាហរណ៍មួយ ហើយព្យាយាមដោះស្រាយទំនាក់ទំនងរបស់ប្រវែង ជ្រុង ផ្ទៃក្រឡា និងចំណុះ/មាឌ។ ពួកគេបង្កើតជារូបមន្តដែលអាចយកទៅអនុវត្តជាមួយឧទាហរណ៍ដទៃទៀតដែលមានរាងដូចគ្នា។ ក្នុងថ្នាក់រៀន

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

មួយទៀតសិស្សមួយក្រុមបានចាក់ទឹកបំពេញក្នុងធុងរាងជាសាជីមូលមួយ ដើម្បីប្រៀបធៀបចំណុះរបស់វាជាមួយនឹងចំណុះរបស់ស៊ីឡាំងមួយទៀត។[9]

	អត្ថន័យនៃការធ្វើការបង្ហាញ	**អត្ថន័យនៃការចូលរួម**	**អត្ថន័យនៃសកម្មភាព/ការបញ្ចេញយោបល់**
ករណីសិក្សាទី១	ផ្លែឈើពិតត្រូវបានប្រើនៅពេលបង្រៀនពីរដូវ និងផ្លែឈើតាមរដូវ	សិស្សអាចជ្រើសរើសជាការសរសេរកំណាព្យពីផ្លែឈើឬផលិតផលរបាំងមុខផ្លែឈើ។ សិស្សធ្វើការជាក្រុមដោយអាន និងសរសេរ	សិស្សម្នាក់ៗជ្រើសរើសផ្លែឈើមួយមុខ ហើយសម្តែងតួជាផ្លែឈើនោះ
ករណីសិក្សាទី២	វាគ្មិនធ្វើបទបង្ហាញពីអាជីព	សិស្សដើរតួជាអាជីពមួយ ពួកគេពិភាក្សាជាក្រុម ពួកគេអានរឿងទាក់ទងនឹងអាជីពទាំងនោះ ហើយលេងល្បែងមួយ	
ករណីសិក្សាទី៣	វត្ថុផ្សេងៗគ្នាប្រើដើម្បីបង្រៀនរាងទាំងឡាយខាងធរណីមាត្រ	សិស្សជ្រើសយកឧទាហរណ៍មួយហើយព្យាយាមធ្វើការដោះស្រាយទំនាក់ទំនងរបស់ប្រវែងជ្រុង ផ្ទៃក្រឡា និងចំណុះ/មាឌ	

[9] Adapted from UNESCO/Booklet Four (2015, p. 8; 63). CC BY-SA 3.0. IGO.

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ខ. ចូរស្តាប់គ្រូបង្រៀនម្នាក់និយាយពីរបៀប ដែលគាត់បង្រៀននៅក្នុងថ្នាក់រៀនបរិយាបន្នមួយ(Audio File 4.2.1) ចូរកំណត់ពីវិធីសាស្ត្រដែលបានលើកឡើងចូលក្នុងតារាងខាងក្រោម៖

អត្ថន័យនៃការធ្វើការបង្ហាញ	អត្ថន័យនៃការចូលរួម	អត្ថន័យនៃសកម្មភាព/ការបញ្ចេញយោបល់
បញ្ចូលរូបភាព និងបទបង្ហាញជាពាក្យសម្តី ព្រមទាំងទិដ្ឋភាពជាចលនាផងដែរ	ការពិភាក្សាដែលជំរុញលើកទឹកចិត្តឱ្យមានជាទស្សនៈផ្សេងៗ ការសន្ទនាដោយបើកចំហរ មានបីកំរិតសម្រាប់សកម្មភាពនីមួយៗ	ឱកាសធ្វើកិច្ចការ អាចជាជាសៀវភៅកម្រង ឬជាសៀវភៅរូបភាព ជាវីឌីអូ ឬចម្លើយជាលាយលក្ខណ៍អក្សរ ពួកគេមិនចាំបាច់អង្គុយធ្វើតេស្តដូចគ្នបង្ហាញពីចំណេះដឹងពួកគេ ដោយមានការបត់បែន

ជំហានទី៣៖ ការរៀបចំសំណុំឯកសារ –សំណួរបែបឆ្លុះបញ្ចាំងផ្ទាល់ខ្លួន

ចូរសរសេរសំណេរតែងសេចក្តី សំណួរបែបឆ្លុះបញ្ចាំងផ្ទាល់ខ្លួនខាងក្រោម។
សំណេរនីមួយៗប្រើពាក្យពី ៣០០ ទៅ៥០០ពាក្យ ហើយប្រើប្រាស់ឃ្លាភ្ជាប់សេចក្តី ដើម្បីបង្កើតបានជាល្បះពេញលេញ។ សំណេរទាំងនេះដាក់ចូលទៅក្នុងសំណុំឯកសារផ្ទាល់ខ្លួនរបស់អ្នក!

១. តើអ្វីទៅជាបរិយាកាសមេត្រីសិក្សារៀនចំពោះអ្នក?

២.តើអ្វីខ្លះជាបទពិសោធរបស់អ្នកទាក់ទងនឹងមធ្យោបាយជាច្រើននៃការបង្ហាញ និងការសម្តែងគំនិតយោបល់? តើអ្នកបានឆ្លងកាត់បទពិសោធ នៃការធ្វើឱ្យមានភាពចម្រុះគ្នាអ្វីខ្លះជាច្រើនឆ្នាំកន្លងមក កាលដែលអ្នកនៅជាសិស្ស? តើមានភាពចម្រុះគ្នាគ្រប់គ្រាន់ដែរឬទេ តើវាបានជួយជាប្រយោជន៍ដែរឬទេ តើមានអ្វីខ្លះទៀតដែលអ្នកប្រហែលជាត្រូវការ ដើម្បីទទួលបានការគាំទ្រជាអតិបរិមាក្នុងដំណើរការសិក្សារបស់អ្នក?

ជំហានទី៤៖ ការរៀបចំសំណុំឯកសារ – គម្រោងការបង្រៀន

ចូររៀបគម្រោងបង្រៀនផ្ទាល់ខ្លួនរបស់អ្នក។ ចូរពណ៌នាពីមធ្យោបាយជាច្រើន នៃការធ្វើបទបង្ហាញ ការចូលរួមនិងសកម្មភាព/ ការបង្ហាញពីគំនិតទៅលើប្រធានបទរបស់អ្នក និងថ្នាក់រៀនដែលបានជ្រើសរើសនៅក្នុង ម៉ូឌុល១.១។ ការរៀបចំសំណុំឯកសារនេះប្រើពាក្យពី ៣០០ ទៅ៥០០ពាក្យចាប់ពី៨០០ ទៅ១០០០ពាក្យ។ គម្រោងការបង្រៀននេះដាក់ចូលទៅក្នុងសំណុំឯកសារផ្ទាល់ខ្លួនរបស់អ្នក!

ឧបសម្ពន្ធ

កំណត់ត្រាពីសំឡេង៖ Audio File 4.2.1

គ្រូបង្រៀន៖ បន្ទាប់មក ខ្ញុំតែងតែព្យាយាមរួមបញ្ចូលការបង្រៀន ដែលមានរបៀបខុសប្លែកពីគ្នា ដូចជា ប្រសិនបើខ្ញុំកំពុងតែឈរបង្រៀន ខ្ញុំនឹងបញ្ចូលសកម្មភាពបង្ហាញជារូបភាព ជាសំឡេង និងការធ្វើចលនាប្តូរទីតាំងបញ្ចូលគ្នាតែមួយ។ ធ្វើដូចនេះសិស្សដែលមានសមត្ថភាពខុសគ្នា អាចយល់ពីអត្ថន័យមេរៀន។ ហើយយើងក៏អនុញ្ញាតឱ្យមានការពិភាក្សា ដែលជំរុញឱ្យមានគំនិតទស្សនៈផ្សេងៗគ្នានៅក្នុងថ្នាក់រៀនដោយមានប្រធានបទជាច្រើន។ ដូច្នេះពួកគេអាចផ្តល់ជាធាតុចូល ចំណែកគ្រូអាចផ្តុំអ្វីៗគ្រប់យ៉ាងហើយសង្ខេបមេរៀនបាននៅចុងម៉ោងសិក្សា។

អ្នកសម្ភាសន៍៖ លោកគ្រូ តើការរៀបចំមេរៀននៅក្នុងថ្នាក់រៀនដែលមានភាពចម្រុះ ខុសគ្នាពីថ្នាក់រៀនធម្មតារបៀបណាខ្លះ?

គ្រូបង្រៀន៖ ខ្ញុំអាចនិយាយបានថា មានកិច្ចការជាច្រើនសម្រាប់គ្រូបង្រៀន ក្នុងការដាក់រួមបញ្ចូលនូវវិធីសិក្សាដែលប្លែកពីគ្នា និងការបង្រៀនចូលទៅក្នុងមេរៀន និងការរៀបចំសកម្មភាពដែលខុសគ្នា។ ជាទូទៅសកម្មភាពមានបីកម្រិតដែលយើងព្យាយាមបង្កើត ហើយនោះជាសកម្មភាពដែលមានកម្រិតខ្ពស់ កម្រិតមធ្យម និងកមកម្រិតស្រួលបំផុត។ ខ្ញុំនឹងបង្រៀនសិស្ស ទៅតាមកម្រិតសមត្ថភាពរបស់ពួកគេ។ ហើយក៏មានការងារតម្រូវតាមបុគ្គលដែលត្រូវធ្វើឡើង ឬកិច្ចការផ្សេងៗទៀតដូចជា កិច្ចការសាលាជាដើម។ ជារួម សិស្សមួយចំនួនពូកែសរសេរ ចំណែកសិស្សខ្លះទៀតពូកែបង្កើតជាវត្ថុផ្សេងៗ។ ដូច្នេះ ខ្ញុំនឹងផ្តល់ឱកាសឱ្យពួកគេនៅពេលដែលកំណត់ពីប្រធានបទនៃកិច្ចការសាលា ដើម្បីបង្កើតសៀវភៅកម្រងអនុស្សាវរីយ៍ សៀវភៅរូបភាព ជាវីដេអូ ឬជាកាសរសេរ។ វាមិនចាំបាច់ថាត្រូវមានវិធីដូចគ្នា ក្នុងការដាក់កិច្ចការនិងដាក់ពិន្ទុឱ្យនោះទេ។ ដូច្នេះ ក្នុងន័យនេះ គ្រូបង្រៀនមានរបៀបជាច្រើនក្នុងការដាក់ពិន្ទុទៅលើការបង្រៀនដែលកុមារអាចធ្វើបាន។ ប៉ុន្តែខ្ញុំគិតថាកិច្ចការនេះផ្តល់នូវលទ្ធផលល្អ សិស្សានុសិស្សមានក្តីរំភើបហើយបង្ហាញសមិទ្ធផលដោយប្រើសមត្ថភាពផ្ទាល់ខ្លួន។

អ្នកសម្ភាសន៍៖ នៅចុងបញ្ចប់ តើអ្នកប្រាកដក្នុងចិត្តថាសិស្សទាំងអស់អាចចូលរួមនៅក្នុងថ្នាក់រៀនដោយមានទំនាក់ទំនងទៅវិញទៅមកបានដោយរបៀបណា?

គ្រូបង្រៀន៖ ខ្ញុំអាចនិយាយបានថា មានកិច្ចការជាច្រើនដែលត្រូវធ្វើដែលជាប់ពាក់ព័ន្ធនឹងទំនាក់ទំនង។ ដូចជាការដែលយើងទាក់ទងជាមួយសិស្សជាប្រចាំ ហើយយើងទទួលស្គាល់ពីសមត្ថភាពរបស់ពួកគេ ដូចជាគ្រូផ្តល់ឱកាសដល់សិស្សដើម្បីបង្ហាញពីទេពកោសល្យ។ ទេពកោសល្យទាំងនោះមានដូចជា ជំនាញតាមរយៈកិច្ចការដែលមានលក្ខណៈបត់បែន តាមរយៈគម្រោងការបង្រៀនដែលចេះបត់បែន ព្រោះអ្នកមិនផ្តល់ចំណាត់ថ្នាក់ដល់ពួកគេក្នុងកម្រិតដែលដូចគ្នាតែមួយនោះទេ ឬក៏អ្នកមិនអាចឱ្យពួកគេអង្គុយធ្វើតេស្តដូចគ្នានោះទេ។ ប៉ុន្តែការធ្វើឱ្យមានបែបផែនខុសគ្នា គឺជាជំនាញសំខាន់ដើម្បីធ្វើឱ្យគេបានចូលរួម ខ្ញុំអាចនិយាយបានដូច្នេះ។

អ្នកសម្ភាសន៍៖ តើអ្នកប្រើប្រាស់អ្វីដើម្បីអភិវឌ្ឍទំនាក់ទំនងសិស្សនៅក្នុងថ្នាក់រៀន?

គ្រូបង្រៀន៖ ទំនាក់ទំនងរវាងគ្នាទៅវិញទៅមកតាមរយៈការពិភាក្សា ខ្ញុំអាចនិយាយបានដូច្នេះ។

ការអនុញ្ញាតឱ្យសិស្សបង្ហាញពីទស្សៈរបស់ខ្លួន ឬការសន្ទនាដោយបើកចំហ ហើយដូចអ្វីដែលខ្ញុំបាននិយាយថាជាកិច្ចការសាលា។ ដូច្នេះនៅពេលដែលអ្នកចេះបត់បែន ហើយផ្តល់ឱកាសមួយដល់ពួកគេ ដើម្បីបង្ហាញពីចំណេះដឹងរបស់គេដោយមានភាពបត់បែន ជាជាងគ្រាន់តែនិយាយថា ចូរសរសេរបាយការណ៍មួយអំពីរឿងនេះ ឬសំណួរនេះត្រូវធ្វើជាសំណេរ ឬទៅរកបរស់នេះ ហើយត្រឡប់មកវិញ អ្នកផ្តល់ឱ្យពួកគេនូវសកម្មភាពខុសប្លែកគ្នា។ ដូចជាសកម្មភាពជាទម្លាប់មួយ ដែលខ្ញុំបានធ្វើគឺការឱ្យសិស្សម្នាក់ បង្កើតជាសៀវភៅរូបភាពចំណែកសិស្សម្នាក់ទៀតថតវីដេអូអំពីអ្វីមួយ។ ហើយបន្ទាប់មកសិស្សម្នាក់ទៀត ធ្វើបទបង្ហាញអំពីថ្ងៃឈប់សម្រាកដែលគេបានចំណាយនារដូវក្តៅមុន។ ហេតុនេះ កិច្ចការទាំងនោះនឹងផ្តល់ឱកាសដល់សិស្សានុសិស្សបង្ហាញចំណេះដឹងពីចម្រុះរបស់គេ ហើយក៏ឱ្យម្លៃលើរឿងនោះផងដែរ។

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

អ្នកអប់រំដែលជោគជ័យត្រូវចេះពីវិធីប្រើប្រាស់ធាតុសំខាន់ៗនៃការបង្រៀន ដែលមានគុណភាពខ្ពស់សម្រាប់ថ្នាក់រៀនរបស់ខ្លួន។ ក្នុងម៉ូឌុលនេះ បង្ហាញពីមូលដ្ឋានមួយចំនួនសម្រាប់ការអនុវត្តការបង្រៀនប្រកបដោយប្រសិទ្ធភាព ដើម្បីធានាថាសមាសភាពសំខាន់នៃការបង្រៀននៅកម្រិតបឋមសិក្សាត្រូវបានពិចារណានៅពេលធ្វើផែនការបង្រៀន អនុវត្តការបង្រៀន វាយតម្លៃដំណើរការបង្រៀន និងរៀន។ តាមរយៈប្រធានបទផ្សេងៗ រួមបញ្ចូលការបង្រៀន និងរៀនសតវត្សទី២១ ការធ្វើកិច្ចតែងការបង្រៀន និងបរិស្ថានសិក្សា អ្នកនឹងតម្រូវឱ្យធ្វើការឆ្លុះបញ្ចាំងពីដំណើរការបង្រៀន និងរៀនដើម្បីសម្រេចលទ្ធផលសិក្សាដោយជោគជ័យ។

សូមសិក្សាដោយរីករាយ!

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

CONTESSA
Contemporary Teaching Skills for South Asia
Co-funded by the Erasmus+ Programme of the European Union

ម៉ូឌុល ៤

ការរួមបញ្ចូលភាពខុសគ្នា៖ គោលវិធីគរុកោលស្យសម្រាប់ភាពចម្រុះគ្នា ភាពមិនស្មើគ្នា និងតម្រូវការពិសេស

៤.៣ ការគ្រប់គ្រងថ្នាក់រៀនដែលមានភាពចម្រុះគ្នា

ការរួមបញ្ចូលភាពខុសគ្នា៖ គោលវិធីគរុកោលស្យសម្រាប់ភាពចម្រុះគ្នា ភាពមិនស្មើគ្នា និងតម្រូវការពិសេស៖ ការគ្រប់គ្រងថ្នាក់រៀនដែលមានភាពចម្រុះគ្នា

មេរៀននេះត្រូវបានបង្កើតឡើងដោយដៃគូសហការនៅក្នុងគម្រោងនៅ វិធីសាស្ត្របង្រៀនសម័យថ្មីនៅអាស៊ីខាងត្បូង (Contemporary Teaching Skill for South Asia) ហៅកាត់ថា CONTESSA ក្រោមការចូលរួមឧបត្ថម្ភថវិកាដោយកម្មវិធី Eramus+ នៃសហភាពអឺរ៉ុបដែលមានលេខគម្រោង598756-EPP-1-2018-1-AT-EPPKKA2-CBHE-JP-/CONTESSA

អ្នកសម្របសម្រួល :

Sandra Hummel, សាកលវិទ្យាល័យហ្គ្រាស UNIVERSITY OF GRAZ (អូទ្រីស)

ក្រោមការចូលរួមសហការពី :

សាកលវិទ្យាល័យបច្ចេកវិទ្យា ជ្រៃសឺល (អាល្លឺម៉ង់)

សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា (កម្ពុជា)

សាកលវិទ្យាល័យកម្ពុជា (កម្ពុជា)

សាកលវិទ្យាល័យអភេននៃប្រទេសស្រីលង្កា (ស្រីលង្កា)

សាកលវិទ្យាល័យយូកំឡូប (ស្រីលង្កា)

អ្នកនិពន្ធ: Regina Elias, Sandra Hummel, Mirjam Brodacz-Geier, Bridget Sheehan

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

សេចក្តីប្រកាស

គណៈកម្មការអឺរ៉ុបសូមធ្វើការគាំទ្រដល់ការបោះពុម្ពឯកសារនេះ ដែលមិនមែនឆ្លុះបញ្ចាំងតែពីទស្សនៈរបស់អ្នកនិពន្ធខាងលើទេ ហើយយើងក៏មិនទទួលខុសត្រូវចំពោះការប្រើប្រាស់ព័ត៌មានដែលដកស្រង់ចេញពីការបោះពុម្ពនេះដោយប្រការណាមួយដែរ។ ព័ត៌មានលម្អិតបន្ថែមនៃមេរៀននេះអាចរកបានដោយបើកចំហ និងឥតគិតថ្លៃនៅលើគេហទំព័រ CONTESSA :

https://contessa_project.eu/

រក្សាសិទ្ធិ

មេរៀននេះត្រូវបានផ្តល់អាជ្ញាប័ណ្ណឱ្យប្រើប្រាស់ក្រោមលក្ខខណ្ឌនៃ Creative Commons

Attribution_ShareAlike 4.0 Internatinal License

(https://creativecommons.org(licenses/by_sa/4.0/)

ដែលអនុញ្ញាតឱ្យប្រើប្រាស់ ចែករំលែក សម្របសម្រួលដើម្បីប្រើប្រាស់បន្ត ចែកចាយផលិតផលសារជាថ្មីក្នុងទ្រង់ទ្រាយណាមួយ ដរាបណាអ្នកប្រើប្រាស់ផ្តល់កិត្តិយសឱ្យបានសមរម្យដល់អ្នកនិពន្ធទាំងអស់។ សូមផ្តល់ជាតំណភ្ជាប់ (link) ទៅកាន់ Creative Commons License និងសូមបញ្ជាក់ផងដែរ បើមានការផ្លាស់ប្តូរណាមួយ។ ប្រសិនបើអ្នកបញ្ចូលគំនិតកែសម្រួល ឬបន្ថែមអត្ថន័យលើមេរៀននេះអ្នកត្រូវតែធ្វើការសុំសិទ្ធិកែសម្រួលឯកសារតាមលក្ខខណ្ឌខាងលើ។ រូបភាព ខ្សែសំឡេង វីដេអូ ក៏ដូចជាឯកសារដទៃទៀតដែលមាននៅក្នុងមេរៀនទាំងនេះមិនត្រូវបានបូកបញ្ចូលទៅក្នុងឯកសារអាជ្ញាប័ណ្ណ Creative Commons ទេ លើកលែងតែមានការអនុញ្ញាតឱ្យប្រើប្រាស់។ ប្រសិនបើផ្នែកណាមួយនៃមេរៀននេះមិនត្រូវបានបញ្ចូលទៅក្នុងឯកសារអាជ្ញាប័ណ្ណ ហើយការប្រើប្រាស់មិនត្រូវបានអនុញ្ញាតដោយច្បាប់ ឬក៏ប្រើប្រាស់លើសពីច្បាប់អនុញ្ញាត ត្រូវតែសុំការអនុញ្ញាតដោយផ្ទាល់ពីម្ចាស់កម្មសិទ្ធិ។

CC BY SA

សេចក្តីផ្តើម

តើវគ្គសិក្សា CONTESSA ជាអ្វី?

វគ្គសិក្សា CONTESSA ជាលទ្ធផលមួយក្នុងចំណោម លទ្ធផលនៃគម្រោងស្តីអំពី "ជំនាញក្នុងការបង្រៀនសម័យថ្មីសម្រាប់អាស៊ីខាងត្បូង" ដែលផ្តល់មូលនិធិរួម ដោយកម្មវិធី Erasmus+ Program នៃសហភាពអឺរ៉ុប។ គោលបំណងរបស់វគ្គសិក្សានេះគឺ ដើម្បីជាការរួមចំណែកក្នុងការបង្កើតកម្មវិធីអប់រំគ្រូបង្រៀនដោយជោគជ័យសម្រាប់គ្រូបឋមសិក្សា ជាពិសេសក្នុងប្រទេសកម្ពុជា និងស្រីលង្កាដែលនឹងនាំដល់ការបង្កើតបានផលវិជ្ជមានរយៈពេលវែងទៅលើប្រព័ន្ធអប់រំទូទៅ។ វាមានសារៈសំខាន់កាន់តែខ្លាំងឡើង សម្រាប់អ្នកអប់រំដែលជោគជ័យក្នុងការតាមឱ្យទាន់សម័យជាមួយនឹងជំនាញ និងវិធីសាស្ត្រក្នុងសម័យថ្មីដើម្បីយកមកប្រើក្នុង និងក្រៅថ្នាក់រៀន។ ដូច្នេះ វគ្គសិក្សា CONTESSA ផ្តល់ជូនមេរៀន ដែលត្រូវបានជ្រើសរើសដោយប្រុងប្រយ័ត្នចំនួន៥ម៉ូឌុល ដែលម៉ូឌុលនីមួយៗមានការផ្តោតការយកចិត្តទុកដាក់ទៅលើចំណុចចំនួនបី ដែលតម្រង់ទៅរកការអភិវឌ្ឍលើជំនាញបង្រៀនបែបសម័យថ្មី។ ម៉ូឌុលទាំងឡាយនិងការផ្តោតការយកចិត្តទុកដាក់របស់វាគឺមានដូចខាងក្រោម៖

ម៉ូឌុល១៖ ការកសាងការយល់ដឹងអំពីការអប់រំនៅបឋមសិក្សា
១.ការបង្រៀន និងការរៀននៅសតវត្សទី២១
២.ការរៀបចំកិច្ចតែងការបង្រៀន និងជំនាញគរុកោសល្យ ៖ គំនិត ឧបករណ៍ និងការអនុវត្ត
៣.ការរៀបចំបរិយាកាសសិក្សា

ម៉ូឌុល២៖ ភាពអស្ចារ្យក្នុងការបង្រៀន៖ សមត្ថភាពជាក់លាក់ប្រកបដោយវិជ្ជាជីវៈរបស់គ្រូបង្រៀនបឋមសិក្សា
១. ការយល់ដឹងពីការបង្រៀន៖ តួនាទី ភារកិច្ច និងមុខងារ
២. ការវាយតម្លៃលទ្ធផលនៃការសិក្សា
៣. ជំនាញវិជ្ជាជីវៈគរុកោសល្យ

ម៉ូឌុល៣៖ការអប់រំឈានមុខគេបែបវិធីសាស្ត្រសិស្ស
មជ្ឈមណ្ឌល៖ ការលើកកម្ពស់ដំណើរការសិក្សាដែលបានបង្កើតរួមគ្នា
១. ការអភិវឌ្ឍលក្ខណៈបុគ្គល និងជំនាញដោះស្រាយបញ្ហា
២. ការអះអាងពីពិភពជីវិតជាក់ស្តែង និងក្តីសង្ឃឹមទៅអនាគត
៣. ការប្តេជ្ញាចិត្តដោយខ្លួនឯង ការផ្តល់សិទ្ធិអំណាច និងប្រសិទ្ធភាពផ្ទាល់ខ្លួន

ម៉ូឌុល៤៖ ការរួមបញ្ចូលភាពខុសគ្នា៖ គោលវិធីគរុកោសល្យសម្រាប់ភាពចម្រុះគ្នា ភាពមិនស្មើគ្នា និងតម្រូវការពិសេស
១. គរុកោសល្យបរិយាបន្ន ៖ គោលវិធី និងយុទ្ធសាស្ត្រ
២. ការបង្រៀន និងរៀនក្នុងភាពចម្រុះគ្នា ៖ ការរៀបចំ ការយល់ដឹងការវាយតម្លៃ
៣. ការគ្រប់គ្រងថ្នាក់រៀនដែលមានភាពចម្រុះគ្នា

ម៉ូឌុល៥៖ ការបង្រៀន និងរៀនតាមបែបឌីជីថល
១. គរុកោសល្យ នៃការសិក្សាពីចម្ងាយ និងបរិយាកាសសិក្សាដែលបំពាក់ទៅដោយបច្ចេកវិទ្យា
២. ប្រព័ន្ធផ្សព្វផ្សាយ និងបច្ចេកទេសឌីជីថល៖ ឧបករណ៍ និងទម្រង់សម្រាប់គោលបំណងនៃការអប់រំ
៣. ការរៀបចំមេរៀន និងដំណើរការបង្រៀនតាមអ៊ីនធឺណែត
នៅពេលដែលបញ្ចប់វគ្គសិក្សានេះ អ្នកចូលរួមនឹងអាចអនុវត្តជំនាញបង្រៀនសម័យថ្មី ដែលទើបទទួលបានធ្វើឱ្យសិស្សទាំងអស់អាចចូលរួមសកម្មភាពក្នុងថ្នាក់ និងរៀនពីវិធីថ្មីៗដើម្បីជួយឱ្យសិស្សឈានទៅដល់ចំណុចសក្តានុពលពេញលេញរបស់ពួកគេ។

តើវគ្គសិក្សា CONTESSA សម្រាប់អ្នកណា?

គម្រោងស្តីពីជំនាញក្នុងការបង្រៀនសម័យថ្មីសម្រាប់អាស៊ីខាងត្បូង មានបំណងក្នុងការលើកតម្កើងជំនាញបង្រៀនសម័យថ្មីសម្រាប់គរុសិស្ស/និស្សិត និងគ្រូបង្រៀនដែលកំពុងបម្រើការក្នុងសាលាបឋមសិក្សានានា។ ឯកសារខាងក្រោមត្រូវបានសម្របសម្រួលជាពិសេសសម្រាប់គរុសិស្ស/និស្សិត។
លើសពីនេះទៅទៀត វគ្គសិក្សា CONTESSA ក៏សម្រាប់អ្នកដែលមានចំណាប់អារម្មណ៍ក្នុងការធ្វើខ្លួនឱ្យទាន់សម័យកាលជាមួយនិងជំនាញបង្រៀនសម័យថ្មី។ ឯកសារមានជាភាសាអង់គ្លេស ហើយក៏មានជាភាសាខ្មែរ ភាសាសិង្ហាលា (Sinhala) និងភាសាតាមីល (Tamil) ដែលប្រើប្រាស់នៅប្រទេសស្រីលង្កា។

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

តើរចនាសម្ព័ន្ធនៃវគ្គសិក្សា CONTESSA មានអ្វីខ្លះ?

ដូចដែលបានលើកឡើងពីមុនរួចហើយ វគ្គសិក្សា CONTESSA នេះរួមមាន៥ម៉ូឌុល ដែលម៉ូឌុលនីមួយៗមានតម្លៃស្មើនឹង៣ ក្រេឌីតតាមប្រព័ន្ធផ្ទេរការសិក្សារបស់អឺរ៉ុប។ ជាការល្អ ម៉ូឌុលទាំងនេះត្រូវបានប្រើប្រាស់រួមគ្នា ពីព្រោះម៉ូឌុលនីមួយៗយោងឯកសារលើម៉ូឌុលដទៃទៀត។ ប៉ុន្តែក្នុងមេរៀន ម៉ូឌុលទាំងនេះក៏ត្រូវបានបង្កើតឡើងក្នុងវិធីមួយ ដែលអាចប្រើបានដោយខ្លួនឯងឯងផ្ទាល់ផងដែរ។ ម៉ូឌុលនីមួយៗមានការផ្តោតលើប្រធានបទចំនួនបី ហើយឯកសារទាំងឡាយក៏បង្កើតឡើងសម្រាប់ការផ្តោតនីមួយៗផងដែរ។ វាបង្កើតឱ្យមានឯកសារសរុបចំនួន១៥ផ្នែកសម្រាប់វគ្គសិក្សា CONTESSA ។ ឯកសារនីមួយៗរួមមានសេចក្តីផ្តើមបែបទ្រឹស្តីចំពោះចំណុចផ្តើម ហើយតាមពីក្រោយដោយលំហាត់អនុវត្ត ដោយផ្អែកលើទ្រឹស្តី។

ជំហាន១ – ទ្រឹស្តី – គឺជាការរំឭកនូវអ្វីដែលបានអាននៅក្នុងសេចក្តីផ្តើមនៃទ្រឹស្តីលំហាត់អនុវត្តទាំងនេះ ត្រួតពិនិត្យការយល់ដឹងនៃអត្ថបទ ដើម្បីប្រាកដថាទ្រឹស្តីជាមូលដ្ឋានដែលត្រូវបានយល់ដឹង។

ជំហាន២ – បទពិសោធ – ផ្តល់ជូននូវឧទាហរណ៍នៃគ្រូបង្រៀនពិតប្រាកដ និងវិធីដែលពួកគាត់អនុវត្តទ្រឹស្តីផ្សារភ្ជាប់នឹងការអនុវត្តជាក់ស្តែង។ ឧទាហរណ៍ទាំងនេះបានភ្ជាប់លំហាត់អនុវត្តទៅនឹងទ្រឹស្តីដែលបានរៀនពីមុនរួចហើយ។ **ជំហាន៣ – ការឆ្លុះបញ្ចាំងដោយខ្លួនឯងផ្ទាល់** – រាប់បញ្ចូលសំណួរបែបឆ្លុះបញ្ចាំងដោយផ្អែកទៅលើចំណុចផ្តោតនីមួយៗ។

ជំហាន៤ – ការអនុវត្ត – គឺជាជំហានចុងក្រោយដែលមានគម្រោងគោលនៃការបង្រៀនមួយត្រូវបានបង្កើតឡើងផ្អែកទៅលើអ្វីដែលបានប្រទះឃើញពីមុននៅក្នុងជំហានទីមួយ និងទីពីរ។

លំហាត់អនុវត្តនៅក្នុងជំហានទីមួយ និងទីពីរអាចត្រូវបានបំពេញដោយផ្ទាល់ក្នុងឯកសារនេះ។ ជំហានទី៣ និងទីបួនជាផ្នែកនៃឯកសារដែលរៀបជាសំណុំដាច់ដោយឡែកដែលនឹងត្រូវបង្កើតដោយបុគ្គលម្នាក់ៗ។ គំរូសម្រាប់ការរៀបចំសំណុំឯកសារ (portfolio) មានជាឯកសារដាច់ដោយឡែកពីគ្នា។

Co-funded by the
Erasmus+ Programme
of the European Union

មាតិកា

១. សារៈសំខាន់នៃការគ្រប់គ្រងរៀបចំថ្នាក់រៀន 1

២. យុទ្ធសាស្ត្រគ្រប់គ្រងថ្នាក់រៀនដែលមានភាពចម្រុះ 2

២.១ ការបង្កើតបរិយាកាសសិក្សារួបវន្ត 2

២.២ ការអភិវឌ្ឍបរិយាកាសសិក្សាបរិយាបន្ន និងការថែទាំ 5

២.៣ ការបង្កើតច្បាប់វិន័យក្នុងថ្នាក់រៀន 6

២.៤ ការបង្កើតទម្លាប់ និងការណែនាំ 9

៣. ការធ្វើទំនាក់ទំនងជាមួយកុមារដែលមានបញ្ហាក្នុងការស្តាប់ 10

៣.១ ស្ថានភាពនៅក្នុងប្រទេសកម្ពុជា 12

៣.២ ស្ថានភាពនៅក្នុងប្រទេសស្រីលង្កា 13

៤. ការជួយកុមារដែលមើលឃើញមិនច្បាស់ 14

៤.១ ស្ថានភាពនៅក្នុងប្រទេសកម្ពុជា 15

៤.២ ស្ថានភាពនៅក្នុងប្រទេសស្រីលង្កា 16

៥. ចំណុចគន្លឹះ 17

ឯកសារពិគ្រោះ 18

ជំហានទី១៖ លំហាត់ពង្រឹងចំណេះដឹង 21

ជំហានទី១ ដំណោះស្រាយ 24

ជំហានទី២៖ លំហាត់អនុវត្ត 28

ជំហានទី២៖ ចម្លើយអនុវត្ត 32

ជំហានទី៣៖ ការរៀបចំសំណុំឯកសារ –សំណួរបែបឆ្លុះបញ្ចាំងផ្ទាល់ខ្លួន 37

ជំហានទី៤៖ ការរៀបចំសំណុំឯកសារ – គម្រោងការបង្រៀន 37

ឧបសម្ពន្ធ.....37

កំណត់ត្រាពីសំឡេងៈ Audio File 4.3.1.....37

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

១. សារៈសំខាន់នៃការគ្រប់គ្រងរៀបចំថ្នាក់រៀន

ពាក្យថា ការគ្រប់គ្រងថ្នាក់រៀន សំដៅទៅលើការគ្រប់គ្រងសកម្មភាពបង្រៀន និងរៀន និងរាល់ទង្វើរបស់គ្រូបង្រៀនដោយរាប់បញ្ចូលទាំងការធ្វើផែនការ ការជួយសម្រួល និងការត្រួតពិនិត្យរាល់សកម្មភាពក្នុងថ្នាក់រៀន។ ការណែនាំនិងការជួយគាំទ្រថ្នាក់រៀននេះ តម្រូវឱ្យគ្រូបង្រៀនមានជំនាញជាច្រើន។ ការទាក់ទងជាពាក្យសម្តី ឬមិនមែនជាពាក្យសម្តីជាមួយសិស្ស ការរៀបចំបរិយាកាសសិក្សាក្នុងថ្នាក់រៀន និងការគ្រប់គ្រងពេលវេលាយ៉ាងមានប្រសិទ្ធភាព គឺពិតជាមានសារៈសំខាន់ដូចគ្នានឹងការបង្កើតច្បាប់ទម្លាប់និងវិន័យផងដែរ។ គោលបំណងនៃការគ្រប់គ្រងថ្នាក់រៀនឱ្យបានជោគជ័យ គឺត្រូវបង្កើនការលើកទឹកចិត្តដល់សិស្ស និងលទ្ធផលសិក្សារបស់សិស្សដោយការរៀបចំមេរៀនបានច្បាស់លាស់។ (Kratochwill, DeRoos & Blair, 2014)។ នៅក្នុងបរិបទសាលារៀនដែលមានភាពចម្រុះ គ្រូទទួលស្គាល់ថានៅពេលដែលសិស្សចូលមកក្នុងថ្នាក់រៀន ពួកគេនាំមកជាមួយនូវបុគ្គលិកលក្ខណៈផ្ទាល់ខ្លួននិងការរំពឹងទុកសម្រាប់ការសិក្សាផ្ទាល់ខ្លួនរបស់ពួកគេ(Harmer, 2015, p. 168) ។ ប្រវត្តិ និងតម្រូវការខុសៗគ្នារបស់ពួកគេ ត្រូវមានការគ្រប់គ្រង និងរៀបចំថ្នាក់រៀនបង្កើតជាបរិយាកាសសិក្សាមួយ ឱ្យក្លាយជាកន្លែងមួយដែលសិស្សជាច្រើនមានអារម្មណ៍ថា ត្រូវបានគេទទួលស្វាគមន៍ និងផ្តល់ការលើកទឹកចិត្តផ្នែកប្រាជ្ញាស្មារតី។ ជាមួយនឹងចំណាត់ការដែលឆ្ពោះទៅរកការអប់រំបរិយាបន្ន សម្រាប់កុមារដែលមានតម្រូវការពិសេស ក៏ក្លាយទៅជាផ្នែកមួយរួមគ្នាជាមួយមិត្តភក្តិរបស់ពួកគេផងដែរ៖

ថ្នាក់រៀនភាគច្រើននាសម័យកាលនេះ គឺជាថ្នាក់រៀនបរិយាបន្ន ដែលលាយឡំគ្នារវាងសិស្សធម្មតា និងសិស្សដែលមានតម្រូវការពិសេស។ សិស្សដែលមានតម្រូវការពិសេសនៅក្នុងថ្នាក់រៀនបរិយាបន្ន ជារឿយៗមានបញ្ហាប្រឈមខាងអាកប្បកិរិយា និងខាងការរៀនសូត្រ។ សម្រាប់សិស្សដែលមានពិការភាពខាងសិក្សា ៤៥%នៃពេលវេលា ពួកគេមានបញ្ហាខាងផ្នែកអារម្មណ៍ និងមានបញ្ហាជាមួយនឹងការរៀបចំ និងចាត់ចែងផងដែរ។

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ការបង្កើតបរិយាកាសសិក្សាមួយសម្រាប់ថ្នាក់រៀនបរិយាបន្នឱ្យបានល្អ ត្រូវមានទម្រង់ផែនការច្បាស់លាស់ និងមានបទដ្ឋានត្រឹមត្រូវដើម្បីការសម្រេចបានភាពជោគជ័យរបស់សិស្ស[...]។(Polirstok, 2015, p. 928)

ក្នុងថ្នាក់រៀនបរិយាបន្ន សិស្សដែលមានតម្រូវការពិសេសត្រូវបានផ្តល់កម្លាំងចិត្ត និងលើកទឹកចិត្តឱ្យពង្រឹងនូវស្វ័យភាព និងការប្តេជ្ញាចិត្តផ្ទាល់ខ្លួន។ គ្រូបង្រៀនគាំទ្រសិស្សានុសិស្សក្នុងដំណើរការទទួលបានសមត្ថភាពចាំបាច់ ដើម្បីធ្វើឱ្យរីកចម្រើនលើផ្នែកនានាដែលគេចាត់ទុកថាមានសំខាន់ចំពោះពួកគេ។ ដូច្នេះវាជាការសម្រេចចិត្តរបស់សិស្សដែលមានតម្រូវការពិសេសទៅលើអ្វី ដែលគេចាត់ទុកថាមានតម្លៃក្នុងការព្យាយាមទទួលយក ហើយវាមិនមែនជាការសម្រេចចិត្តរបស់គ្រូ ឬឪពុកម្តាយ ឬអ្នកដទៃណាមួយនោះទេ។ គោលដៅនៃការផ្តល់កម្លាំងចិត្តនេះគឺត្រូវកំណត់ និងសម្របទៅតាមគំនិតផ្ទាល់ខ្លួនរបស់មនុស្សម្នាក់ៗ។ ទោះបីជាវិធីសាស្ត្រនេះមានសារៈសំខាន់សម្រាប់សិស្សដែលមានតម្រូវការពិសេសក៏ដោយ វាក៏អាចអនុវត្តបានចំពោះសិស្សផ្សេងៗទៀតនៅក្នុងថ្នាក់រៀនបរិយាបន្នផងដែរ។

ការផ្តល់កម្លាំងចិត្ត:ជាសមត្ថភាពបុគ្គល ក្រុម ឬសហគមន៍ក្នុងការគ្រប់គ្រងស្ថានការណ៍របស់ពួកគេ ប្រើប្រាស់សិទ្ធិអំណាចរបស់ពួកគេ ដើម្បីសម្រេចបានគោលដៅខ្លួនផ្ទាល់ និងជាដំណើរដែលអាចជួយខ្លួនគេ និងអ្នកដទៃ ដើម្បីសម្រេចបានគុណភាពនៃជីវិតរបស់ពួកគេ។ (Adams, 2008, p. 17)

២. យុទ្ធសាស្ត្រគ្រប់គ្រងថ្នាក់រៀនដែលមានភាពចម្រុះ

២.១ ការបង្កើតបរិយាកាសសិក្សារូបវន្ត

បរិយាកាសសិក្សារូបវន្ត រួមមានការរៀបចំថ្នាក់រៀន ការកំណត់ទីតាំង គ្រឿងសង្ហារឹម ការរៀបចំតុកៅអីអង្គុយ ទីតាំងនៃតំបន់ពិសេសៗសម្រាប់សកម្មភាពជាក់លាក់មួយចំនួន ការរៀបចំការតាំងបង្ហាញ និងទីតាំងដទៃផ្សេងៗទៀត។ ការរៀបចំថ្នាក់រៀនគួរតែរៀបចំឡើងក្នុងគោលបំណង ដើម្បីបំពេញតម្រូវការខាងសកម្មភាពខាងសង្គម ខាងផ្លូវអារម្មណ៍ និងតម្រូវការសិស្សទាំងអស់ (Shepherd & Linn, 2015)។ ដោយសារថ្នាក់រៀនតែងតែផ្លាស់ប្តូរអាស្រ័យដោយភាពចម្រុះគ្នារបស់សិស្ស គ្រូបង្រៀនគួរតែត្រួតពិនិត្យយ៉ាងទៀងទាត់ និងវាយតម្លៃការតាក់តែងរៀបចំថ្នាក់រៀនរបស់គាត់ និងធ្វើការសម្របសម្រួលជាចាំបាច់ ដើម្បីបំពេញតម្រូវការរបស់សិស្ស (Rose & Howley, 2007)។ ជាឧទាហរណ៍ ការដាក់សិស្សឱ្យអង្គុយបែរមុខទៅរកគ្រូ អាចជាការចាំបាច់នៅពេលត្រូវពន្យល់ ឬបង្ហាញព័ត៌មានទៅកាន់ថ្នាក់រៀនទាំងមូល។ "ទោះជាយ៉ាងនេះក្តី ការងារនេះគាំទ្រលើការធ្វើការជាក្រុមជាជាងការងារបុគ្គល។ សិស្សគ្រប់គ្នាតម្រូវឱ្យធ្វើកិច្ចការដូចគ្នានៅអំឡុងពេលតែមួយ"

សូមមើល ម៉ូឌុល ៣ «ការអប់រំនៅបឋមសិក្សាតាមបែបសិស្សមជ្ឈមណ្ឌល»

សូមមើល ម៉ូឌុល១ ចំណុច ៣ «ការរៀបចំបរិស្ថានសិក្សា»

(Harmer, 2015, p. 178)។ ដើម្បីបង្កើនការសិក្សារបស់សិស្សម្នាក់ៗ សិស្សអាចអង្គុយជាក្រុមតូចៗ ដែលមានតុអង្គុយជាប់ដោយឡែកពីគ្នាជាកន្លែងដែលពួកគេមានឱកាសធ្វើលំហាត់ផ្ទាល់ខ្លួន។ ការរៀបចំឱ្យសិស្សអង្គុយបែបនេះ អាចឱ្យពួកគេបែរមុខរកគ្នា ដែលជាទិដ្ឋភាពសំខាន់មួយនៅពេលដែលធ្វើការជាក្រុម។ ប្រសិនបើគ្រូបង្រៀនចង់ចៀសវាងការបែងចែក ទីតាំងអង្គុយខ្ពស់ទាបនៅក្នុងថ្នាក់រៀន គាត់អាចរៀបចំកន្លែងអង្គុយជារង្វង់ ឬជាក្រចកជើងសេះ *(Harmer, 2015)*។ លោក *Annedore Prengel (2013)* យល់ឃើញថា តុអង្គុយរាងជារង្វង់ ជាកន្លែងសក្តិសមប្រើចំពោះប្រធានបទទាំងអស់នៅក្នុងថ្នាក់រៀន ៖
វាអនុញ្ញាតឱ្យមានការផ្លាស់ប្តូរបទពិសោធ ការធ្វើបទបង្ហាញពីលទ្ធផលការងារ ការលេង ការច្រៀង ការប្រារព្ធពិធីផ្សេងៗ រួមទាំងការដោះស្រាយទំនាស់ជាដើម។
ដោយសារការធ្វើការងារជារង្វង់ ជាកិច្ចការដែលមានការជំរុញពីសំណាក់គ្រូបង្រៀនឬសិស្ស ជាហេតុនាំឱ្យមានការចូលរួមច្រើនពីសិស្សានុសិស្ស ហើយគាំទ្របាននូវទំនាក់ទំនង និងការគោរពគ្នាពីអ្នកចូលរួមទាំងអស់។

នៅពេលដែលមានការរៀបចំថ្នាក់រៀន គ្រូបង្រៀនគួរតែប្រើប្រាស់គោលការណ៍នៃការរៀបចំជាសាកល (Universal Design-UD) ដែលផ្តោតទៅលើសារៈសំខាន់នៃការបង្កើត "សកម្មភាព សម្ភារៈ ឧបករណ៍ដែលមានរូបភាពជាក់ស្តែងហើយអាចប្រើប្រាស់បានសម្រាប់សិស្សទាំងអស់គ្នា" (Bucholz & Sheffler, 2009, p. 3)។ យោងទៅតាម Shepherd and Linn (2015) មានកត្តាចំនួន៤យ៉ាងដែលគាំទ្រគ្រូបង្រៀនក្នុងការរៀបចំកន្លែងអង្គុយ តាមផ្នែកនៅក្នុងថ្នាក់រៀនដែលមានភាពចម្រុះ គឺសិស្សដែលខ្សោយគំហើញ សិស្សផ្លាស់ទីពិបាក សិស្សដែលមានបញ្ហាអូទីហ្សឹម និងសិស្សដែលមានពិការភាពនៅនឹងកន្លែង។ ការផ្លាស់ទីនៅក្នុងថ្នាក់រៀនអាចជាបញ្ហាសម្រាប់សិស្សមានពិការភាពខាងរាងកាយដែលប្រើរទេះរុញ និងសិស្សដែលមានបញ្ហាគំហើញ។ ការកាត់បន្ថយការខូចខាតនៅក្នុងថ្នាក់រៀនគឺវាពិបាកសម្រាប់ក្មេងដែលមានជំងឺអូទីសឹម(Autism) ដែលអាចមានការប្រែប្រួលខ្ពស់ខាងញាណអារម្មណ៍ និងក្មេងដែលមានជំងឺ ADHD (មានបញ្ហាខាងផ្នង់អារម្មណ៍ គ្រប់គ្រងអារម្មណ៍ និងទង្វើនានា) ឬក្មេងដែលមានការលំបាកខាងការរៀនសូត្រ ដែលងាយនឹងបែកអារម្មណ៍ដោយការជំរុញពីបរិយាកាសខាងក្រៅផ្សេងៗ។ លើសពីនេះទៅទៀត ការកំណត់ពន្លឺ សីតុណ្ហភាព និងកម្រិតសូរសំឡេងក្នុងថ្នាក់រៀនអាចពិបាកសម្រាប់ការចូលរួមពីសំណាក់សិស្សដែលមានតម្រូវការពិសេសមួយចំនួន។

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

សូមពិចារណាមតិយោបល់ខាងក្រោម ដើម្បីបង្កើតបរិយាកាសសិក្សារួបវន្តក្នុងថ្នាក់រៀន៖

- រក្សាទុកផ្លូវសម្រាប់ធ្វើដំណើរបានដោយសេរី
- ត្រូវប្រាកដថាសិស្សទាំងអស់អាចមើលឃើញរូបភាព
- ប្រើសញ្ញាជាអក្សរបោះពុម្ពធំៗងាយស្រួលអាន

(Burgstahler *Equal Access: Universal Design of Instruction*, n.d.)

- បង្កើតសម្ភារសិក្សាសម្រាប់ខ្លឹមសារនៃកម្មវិធីសិក្សាស្នូល នៅក្នុងកន្លែងសិក្សាដែលសំខាន់បំផុត និងដែលអាចប្រើប្រាស់បានចំពោះសិស្សានុសិស្សដោយរៀបចំជាធ្លើរ។ (Prengel, 2013)
- សិស្សដែលខ្សោយខាងការស្តាប់ និងគំហើញ ដាក់ឱ្យអង្គុយជិតក្តារខៀន ឬជិតគ្រូ។
- សិស្សដែលមានបញ្ហាផ្ទង់អារម្មណ៍ គ្រប់គ្រងនូវអារម្មណ៍ និងទង្វើនានា (ADHD) ត្រូវអង្គុយឆ្ងាយបំផុតពីសំឡេងរំខាន។ (Gould & Vaughn, 2000)
- ចូរប្រើផែនទីពិភពលោកដែលបង្ហាញពីប្រទេសកំណើតរបស់សិស្ស
- ចូរប្រើសញ្ញា ឬស្លាកបដាស្វាគមន៍សិស្សជាភាសាផ្សេងៗគ្នា ដែលសិស្សនិយាយ *(Uddin & Johnson ,2018, p. 3)*
- ណែនាំការរៀបចំកន្លែងអង្គុយដែលមានទម្រង់ខុសៗគ្នា អាស្រ័យទៅតាមសកម្មភាពរៀនសូត្រ។



- នៅពេលដែលសិស្សកំពុងធ្វើសកម្មភាព ឬគម្រោងនានា(ទោះជាធ្វើការតែឯង ជាគូ ឬជាក្រុម) ចូរធ្វើបម្លាស់ទីឱ្យបានពេញថ្នាក់រៀន។ ធ្វើឱ្យសិស្សដឹងប្រាកដថាអ្នកអាចមានពេលគ្រប់គ្រាន់ឆ្លើយរាល់សំណួរ និងណែនាំដល់ពួកគេ ដើម្បីយកឈ្នះរាល់ឧបសគ្គ។ ជាមួយគ្នានេះដែរ យើងត្រូវប្រើពេលវេលានេះសម្រាប់ធ្វើការវាយតម្លៃផងដែរ។ ឧទាហរណ៍វាយតម្លៃថាតើក្មេងៗកំពុងផ្តោតអារម្មណ៍

ការតាក់តែងជាសាកល ត្រូវបានបង្កើតឡើងដោយស្ថាបត្យករឈ្មោះ Ronald Mace ដែលបានបដិសេធចំពោះវិធីសាស្ត្របុរាណនៃការច្នៃបង្កើតសម្រាប់អ្នកប្រើប្រាស់ត្រឹមកម្រិតមធ្យម និងបានផ្តល់នូវមូលដ្ឋានគ្រឹះនៃការកែច្នៃសម្រាប់ផលិតផល និងបរិយាកាសប្រើប្រាស់បាន។ (Burgstahler *Universal Design in Education: Principles and Applications*, n.d., online)

បានល្អកម្រិតណា និងមើលពីវិធីដែលពួកគេធ្វើការទាក់ទងគ្នាយ៉ាងដូចម្តេច?។ (UNESCO/Booklet Five, 2015, p. 37)

២.២ ការអភិវឌ្ឍបរិយាកាសសិក្សាបរិយាបន្ន និងការថែទាំ

ទំនាក់ទំនងដ៏រឹងមាំរវាងសិស្ស និងសិស្សត្រូវបានបង្កើតឡើងតាមរយៈការរស់នៅ និងរៀនជាមួយគ្នា ជាពិសេសគឺនៅដើមឆ្នាំសិក្សាថ្មីមួយ។ ដូចដែលបានឃើញពីមុនមកហើយ សាលារៀនបែបបរិយាបន្នទទួលស្គាល់ភាពចម្រុះរបស់សិស្សដោយគ្មានការបែងចែកទៅតាមបុគ្គលិកលក្ខណៈ និងតម្រូវការនោះទេ។ អ្នកគ្រប់គ្នាត្រូវបានស្វាគមន៍ ហើយអ្នកគ្រប់គ្នាចូលរួមដោយប្រើចំណុចខ្លាំង ក្នុងដំណើរការបង្រៀន និងរៀនដើម្បីជោគជ័យ។ គ្រូបង្រៀនដើរតួជាគំរូនៃភាពរួសរាយរាក់ទាក់ ការគោរព និងឥរិយាបទបែបបើកចំហរចំពោះភាពចម្រុះ។ ម្យ៉ាងទៀត គ្រូបង្រៀនថ្នាក់បែបបរិយាបន្នចង់បង្កើតទំនាក់ទំនងដែលមាន "ការយកចិត្តទុកដាក់ និងការគោរពជាមួយសិស្ស"ហេតុផលម្យ៉ាងទៀតគឺ "គាត់ចង់បង្កើតជាស្មារតីសហគមន៍មួយផងដែរ" (Uddin & Johnson, 2018, p. 5)។

ដូច្នេះវាមានសារៈសំខាន់ណាស់ក្នុងការបញ្ជាក់ថាថ្នាក់រៀនគឺជាកន្លែងមួយដែលមានសុវត្ថិភាព ដែលសិស្សគ្រប់រូបទទួលបានការស្វាគមន៍ និងតម្រូវការរបស់ពួកគាត់ត្រូវបានគេទទួលស្គាល់។ គ្រូគួរតែបង្ហាញជាសញ្ញាថាសិស្សអាចសាកល្បងឆ្លើយទៅនឹងសំណួរពិបាកៗ ឬក៏កិច្ចការសាលាដោយគ្មានការកាត់ក្តី ឬវិនិច្ឆ័យ ឬទទួលការរិះគន់អ្វីទាំងអស់។ បរាជ័យជាផ្នែកមួយនៃដំណើរការរៀនសូត្រ ហើយគ្មាននរណាម្នាក់ត្រូវភ័យខ្លាចពីផលវិបាកអវិជ្ជមាននោះទេ បើទោះបីជាគេមិនអាចឆ្លើយសំណួរឬបំពេញកិច្ចការមិនបានក៏ដោយ។ (Polirstok, 2015)

- ចូរសរសើរចំពោះចំណុចខ្លាំងរបស់សិស្ស ឧទាហរណ៍នៅពេលដែលពួកគេអាចនិយាយបានពីរភាសា។
- បញ្ចេញមតិយោបល់ដោយរីករាយអំពីភាពចម្រុះគ្នាដែលមានវត្តមាននៅក្នុងថ្នាក់រៀន។ (Uddin and Johnson, 2018)
- "រួមបញ្ចូលគ្នារវាងឧទាហរណ៍ និងទស្សនៈនានាឱ្យទៅជាបញ្ញត្តិច្បាស់លាស់ពាក់ព័ន្ធជាមួយសិស្សដែលមានបុគ្គលិកលក្ខណៈខុសប្លែកគ្នាដូចជា អាយុ សមត្ថភាព ភេទ ជនជាតិ ពូជសាសន៍ សង្គមសេដ្ឋកិច្ច និងផលប្រយោជន៍។"

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

(Burgstahler *Equal Access: Universal Design of Instruction*, n.d., online)

- អ្នកអាចនឹងមានសិស្ស ដែលចូលមករៀនក្នុងថ្នាក់រៀនរបស់អ្នក ដែលមិនអាចនិយាយភាសាដែលប្រើនៅក្នុងថ្នាក់រៀនបាន។ ក្នុងករណីនេះវាសំខាន់ក្នុងការស្វែងយល់ពីអ្វីដែលកុមារម្នាក់នេះអាចធ្វើបាន ។ វានឹងមានភាពប្រសើរឡើង ប្រសិនបើអ្នកអាចនិយាយ ជាមួយកុមារម្នាក់នេះដោយផ្ទាល់តែម្នាក់ឯងដោយប្រើឈ្មោះ និងប្រើភាសាផ្ទាល់ខ្លួនរបស់គាត់។ ប្រសិនបើមិនអាចធ្វើដូច្នេះបាន ចូរស្វែងរកកុមារដទៃ ឬអ្នកដទៃនៅក្នុងសហគមន៍ ដែលអាចជួយអ្នកបានដើម្បីធ្វើការទាក់ទង និងបង្កើតជា បណ្តាញទំនាក់ទំនងរវាងភាសារបស់គាត់ និងសកម្មភាពក្នុងថ្នាក់របស់អ្នក។ឧទាហរណ៍ តើអ្នកអាចយកចម្រៀងមួយបទ ដែលច្រៀងជាភាសាកំណើតរបស់កុមារម្នាក់នេះ ដើម្បីបង្រៀនពាក្យថ្មីៗដល់គេ សម្រាប់ប្រើក្នុងការបង្រៀននៅក្នុងថ្នាក់របស់អ្នកបានដែរឬទេ? ពាក្យក្នុងបទចម្រៀង ដែលក្មេងម្នាក់នេះបានចេះរួចទៅហើយក្នុងភាសារបស់គាត់ អាចជំនួសជាបណ្តើៗជាមួយពាក្យដែលប្រើនៅក្នុងថ្នាក់រៀនរបស់អ្នក។ តើអ្នកអាចប្រើបទចម្រៀងនេះ ដើម្បីបង្រៀនក្មេងទាំងអស់ ពីតម្លៃនៃភាសាខុសគ្នាបានដែរឬទេ? (UNESCO/Booklet Four, 2015, p. 14)
- ចូរស្តាប់ដោយប្រុងប្រយ័ត្ន នៅពេលដែលសិស្សសួរសំណួរមកអ្នក ហើយដោះស្រាយជាមួយពួកគេឱ្យបានហ្មត់ចត់។ ចម្លើយរបស់អ្នកគួរតែឆ្លើយដោយស្មោះត្រង់តាមដែលអាចធ្វើទៅបាន និងត្រូវតាមកម្រិតរបស់ពួកគេ។ (UNESCO/Booklet Four, 2015)

២.៣ ការបង្កើតច្បាប់វិន័យក្នុងថ្នាក់រៀន

ដូចបានឃើញពីមុនមកហើយ ការគ្រប់គ្រងថ្នាក់រៀន សំខាន់ណាស់ក្នុងការបង្កើនការចូលរួមយ៉ាងសកម្មរបស់សិស្សឱ្យបានច្រើន ដើម្បីធ្វើឱ្យលទ្ធផលសិក្សាមានការរីកចម្រើន(Jordan & McGhie-Richmond, 2014)។ បង្កើតបានបរិយាកាសសិក្សាបែបបរិយាបន្ន ធ្វើឱ្យសិស្សទាំងអស់គ្នាអាចចូលរួមយ៉ាងសកម្ម។ ដូច្នេះវាអាចបំពេញនូវសក្តានុពលរៀនសូត្រឱ្យបានដល់កម្រិតជាអតិបរមា។

ការបង្កើតច្បាប់ដែលមានចរិតសាមញ្ញ ច្បាស់លាស់ និង វិន័យវិជ្ជមាន ព្រមទាំងទង្វើដែលគេរំពឹងទុកថា វាជាសមាសភាគចម្រុះក្នុងថ្នាក់រៀនបែប បរិយាបន្ន។ ព្រោះទង្វើនេះផ្តល់នូវការការពារ និងកាត់បន្ថយបញ្ហា ដែលទាក់ទងនឹង អាកប្បកិរិយាថយចុះដល់កម្រិតទាបបំផុត។ ការរំពឹងទុកក្នុងថ្នាក់រៀននេះផ្តល់នូវការណែនាំចំពោះការប្រព្រឹត្តរបស់សិស្ស ហើយគួរតែរៀបចំឱ្យបានល្អ ទុកជាមុនដោយមានការយល់ស្របពីសិស្សានុសិស្ស។ សិស្សចូលរួមបានពេញលេញ លុះត្រាតែពួកគេបានចូលរួមបញ្ចេញមតិ និងមានការគោរពគ្នាបែបប្រជាធិបតេយ្យ។ ដើម្បីធ្វើរឿងនេះបាន សិស្សត្រូវតែចូលរួមក្នុងដំណើរការ នៃការសម្រេចចិត្តទៅតាមកម្រិតដែលអាចធ្វើទៅបាន។ ការចូលរួមអាចនឹងទទួលបានជោគជ័យ ប្រសិនបើចន្លោះនៃអំណាចរវាងមនុស្សពេញវ័យនិងកុមារ មានលក្ខណៈអព្យាក្រឹត្យតាមកម្រិតដែលអាចធ្វើទៅបាន ប្រសិនណាបើក្មេងៗត្រូវបានគេចាត់ទុកថាមានសិទ្ធិស្មើគ្នា (Hansen, 2015)។ ច្បាប់វិន័យក្នុងថ្នាក់ដែលត្រូវបានបង្កើតរួមគ្នា អាចធ្វើឱ្យមានការបង្កើតបរិយាកាសសិក្សាក្នុងសង្គមមួយដែលសិស្ស និងគ្រូធ្វើការរួមគ្នាហើយគោរពគ្នាទៅវិញទៅមក។ ការរំពឹងទុកត្រូវបានបញ្ជាក់តាមរយៈច្បាប់ទម្លាប់គឺមានលក្ខណៈពិតជាក់ស្តែង ដែលទទួលស្គាល់ថាសិស្សជាអ្នកសិក្សាពិតប្រាកដ មិនមែនជាអ្វីដែលពួកគេគួរតែនោះទេ។" (UNESCO/Specialized Booklet One, 2015, p. 34) ។ ទង្វើបែបស្ថាបនាតិចតួច គឺជាផ្នែករួមមួយនៃស្ថានភាពសិក្សាមួយ និងជាទិដ្ឋភាពស្របច្បាប់មួយដែលត្រូវទទួលស្គាល់ក្នុងដំណើរការទទួលយកបាននៃការសិក្សារបស់សិស្ស។ វាមិនមែនជាការគំរាមកំហែងចំពោះសិទ្ធអំណាចរបស់គ្រូនោះទេ" (UNESCO/Specialized Booklet One, 2015, p. 34)។ បរិយាកាសសិក្សាខាងសង្គមដែលនាំទៅដល់បញ្ញត្តិសិក្សា ដែលមានការរំខាន ឬការធ្វើឱ្យបែកអារម្មណ៍ វាជួនកាលចាំបាច់ត្រូវកំណត់ពីគម្លាតក្នុងពេលគាំទ្រការសិក្សា ហើយវាមិនគួរត្រូវបានគេបំបាត់ភ្លាមៗនោះទេ។ ការបង្កើតរចនា សម្ព័ន្ធជាថ្មី ការរៀបចំក្រុមជាថ្មី ការបញ្ជូនជាសញ្ញា ការផ្តល់ជូននូវជំនួយជាក់ស្តែង។ វិធីដោះស្រាយតាមពេលវេលាស្មុគ្រស្មាញ និងការរៀបចំគម្រោងវិលត្រលប់មកវិញដោយច្បាស់លាស់ គឺជាមធ្យោបាយនៃការបញ្ឈប់ស្ថានភាពទំនាស់។ កាលណាហេតុផលត្រូវបានកំណត់កាន់តែច្បាស់ទុកជាមុន នោះគ្រូបង្រៀនងាកទៅរកការដឹកនាំការបង្រៀនវិញ

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

កាន់តែបានឆាប់។ សម្រាប់សិស្សដែលមានជាប់កិច្ចសន្យា ឬទទួលព័ត៌មានត្រឡប់ពីភាពជោគជ័យជាលាយលក្ខណ៍អក្សរដែលមានក្នុងតារាង Smiley ឬនៅក្នុងសន្លឹកក្រដាសព័ត៌មានត្រឡប់ផ្សេងទៀតអាចនឹងយកជាការបាន។ ច្បាប់វិន័យដែលបង្កើតរួមគ្នាទាំងអស់គួរតែត្រូវបានដាក់បង្ហាញឱ្យឃើញច្បាស់នៅក្នុងថ្នាក់រៀន (Weinstein, Curran & Clarke, 2003)។ ការតាំងបង្ហាញរូបភាពច្បាប់វិន័យទាំងអស់នេះដោយប្រើសញ្ញា ឬរូបភាពជាជំនួយ អាចមានប្រយោជន៍យ៉ាងសំខាន់សម្រាប់សិស្សដែលមានតម្រូវការពិសេស ក្នុងការយល់ និងចងចាំច្បាប់ទាំងនេះ។ នៅពេលផ្លាស់ប្តូរទីកន្លែងអង្គុយ ឧទាហរណ៍ រូបភាពនៃការរៀបចំផ្សេងៗគ្នា អាចនឹងត្រូវបានបង្ហាញសាជាថ្មី ហេតុនេះសិស្សនឹងដឹងពីអ្វីដែលពួកគេគួរធ្វើ។

- "សូមធ្វើការណែនាំអំពីថ្នាក់រៀនឱ្យបានច្បាស់លាស់។ ចូររៀបចំ ឲ្យសិស្សធំៗជួយពន្យល់សិស្សតូចៗ ឱ្យពួកគេបានយល់ពីគោលដៅណែនាំដែលអ្នកផ្តល់ឱ្យ"។ (UNESCO/Booklet Four, 2015, p.14)
- អាកប្បកិរិយាដែលផ្តោតលើការយកចិត្តទុកដាក់ នឹងមិនរាលដាល ឬរំខានដល់សុវត្ថិភាព ឬមុខងារថ្នាក់រៀន ត្រូវបានបញ្ឈប់យ៉ាងមានប្រសិទ្ធភាពបំផុតតាមរយៈការមិនអើពើតាមការគ្រោងទុក [...] វិធីសាស្ត្រនេះមិនគួរប្រើជាមួយនឹងទង្វើដែលបង្កភាពប្រទូសរ៉ាយនោះទេ។ សិស្សទាំងអស់នៅក្នុងថ្នាក់រៀនអាចនឹងចាំបាច់ត្រូវបានបង្រៀនឱ្យធ្វើរឿងនេះបានល្អ ព្រោះថាការយកចិត្តទុកដាក់ពីសំណាក់មិត្តភក្តិ អាចមានឥទ្ធិពលជាងការយកចិត្តទុកដាក់ របស់មនុស្សពេញវ័យសម្រាប់សិស្សខ្លះ។ ប្រសិនបើសិស្សម្នាក់ មានសភាពស្ងប់ស្ងាត់ល្មមក្នុងការឆ្លើយឆ្លង មានទំនាក់ទំនងវិជ្ជមានជាមួយគ្រូ ហើយមានសភាពជៀសផុតពីភាពតានតឹងដែលមិនអាចគ្រប់គ្រងខ្លួនឯងបាន ការធ្វើជាសញ្ញាកាយវិការ អាចជារឿងចាំបាច់ដើម្បីជួយគាត់ឱ្យផ្តោតអារម្មណ៍បានមកវិញ។ ការផ្លាស់ប្តូរកន្លែងអង្គុយ ឬកិច្ចការជាក្រុមតូចៗ ដើម្បីជៀសវាងបញ្ហាមួយចំនួន។ ចូរធ្វើកិច្ចការនេះតាមវិធីមួយដោយមិនដាក់ពិន័យ ហើយប្រសិនបើអាច ចូរធ្វើកិច្ចការនេះតាមវិធីកុំឱ្យដឹងខ្លួន។
- ប្រសិនបើសកម្មភាពមួយមិនទទួលបានភាពជោគជ័យ ចូរប្តូរសកម្មភាពនេះឱ្យបានលឿនតាមដែលអាចធ្វើបាន។ វាជារឿងសំខាន់ដែលយើងត្រូវតែមាន

វិន័យក្នុងថ្នាក់រៀន ដែលសមស្របៈស្តាប់យកចិត្តទុកដាក់។ សុំឱ្យមានការពន្យល់ឱ្យបានច្បាស់ប្រសិនបើអ្នកច្រឡំ។ កុំរំខានគ្នា។ ចូរិះ-គន់ពីគំនិតមិនមែនរិះគន់លើបុគ្គលទេ។ ចូរមករៀនទៀងទាត់ម៉ោង។ ព្យាយាមកុំរំខាន និងធ្វើឱ្យមិត្តភក្តិរំខាន។ (Ambrose et al., 2010, p. 249)

ផែនការជំនួយបន្ថែម។ ជួនកាលវាជារឿងដែលល្អបំផុត ក្នុងការផ្លាស់ប្តូរពីល្បែងសិក្សារួមទៅជាល្បែងសិក្សាមួយទៀតដែលធ្វើជាបុគ្គល។ រឿងនេះអាចធ្វើបានដោយរលូន និងគ្មានការដាក់ទោស ឬពិន័យអ្វីនោះទេនៅពេល ដែលក្រុមមួយមានសភាពលក្ខណៈរំភើប សប្បាយខ្លាំង។ នៅពេលខ្លះទៀតការផ្តល់ជម្រើសដល់សិស្សអាចនឹងមានប្រសិទ្ធភាពជាង។ សិស្សអាចជ្រើសរើសការផ្តល់ព័ត៌មានដោយរាយការណ៍ ឬតាមរយៈការពិភាក្សា ឬថតចម្លងពីម៉ាស៊ីន Projector។(UNESCO/Specialized Booklet One, 2015, p.102f.)

២.៤ ការបង្កើតទម្លាប់ និងការណែនាំ

ទម្លាប់ មានសារៈសំខាន់ណាស់សម្រាប់សិស្ស ដែលមានតម្រូវការពិសេស។ ដោយសារតែតម្រូវការជាក់លាក់របស់ពួកគេសិស្សដែលមានតម្រូវការពិសេសងាយនឹងមានបញ្ហាប្រឈមថ្មីៗ ឬ ស្ថានភាពដែលមិនបានរំពឹងទុកមុន។

ទម្លាប់នឹងជួយតម្រង់ទិសដៅរៀនសូត្ររបស់គេ (Harmer, 2015)។ នេះក៏ពន្យល់ពីតម្រូវការរបស់សិស្សដែលមានតម្រូវការពិសេស ដែលគេចាំបាច់ត្រូវរៀបចំទុកជាមុន សម្រាប់ការផ្លាស់ប្តូរ ដែលអាចនឹងកើតមានឡើងក្នុងទម្លាប់ប្រចាំថ្ងៃ ឬជួនកាលត្រូវធ្វើដដែលៗ សារជាថ្មីរយៈពេលជាច្រើនថ្ងៃ។

សម្រាប់សិស្សដែលមានបញ្ហាខាងការគ្រប់គ្រងអារម្មណ៍ ឬបញ្ហាការចងចាំការធ្វើការងារដដែលៗ និងការហាត់សម ទង្វើទាំងអស់នេះមានសារៈសំខាន់ណាស់។ កត្តាដែលចាំបាច់ គឺហ្វឹកហាត់ឱ្យពួកគេមានទម្លាប់ដូចគ្នា មានការសន្ទនាដូចគ្នា។ល។ ចំពោះមេរៀនមួយចំនួន ពួកគេមានឱកាសមួយប្រសើរជាងមុន ក្នុងការបញ្ចូលពត៌មានទៅកាន់ការចងចាំ ដែលមានរយៈពេលយូររបស់ពួកគេ។ ទន្ទឹមគ្នានេះដែរ ការត្រឡប់ទៅរកទម្លាប់ក្នុងថ្នាក់រៀនដូចកាលពីមុនៗមក អាចជួយសិស្សឱ្យចាំពីអ្វីដែលពួកគេត្រូវធ្វើ និងអ្វីដែលពួកគេបានធ្វើរួចហើយ (Harmer,2015,p.150)។

ការចូលរួមសំដៅទៅរកផ្នែកនៃការចូលរួមពាក់ព័ន្ធជាបន្តបន្ទាប់ដែលគេអាចដើរតួយ៉ាងសកម្មមានជម្រើសដែលប្រសើរជាងមុនប្រើប្រាស់សិទ្ធអំណាចបានច្រើនហើយនិងផ្តល់ជូននូវការធ្វើការសម្រេចចិត្តនិងការគ្រប់គ្រងបានយ៉ាងប្រសើរ។ (Adams, 2008, p. 31)

ចូរពិចារណាពីឧទាហរណ៍ខាងក្រោមចំពោះការបង្កើតទម្លាប់ទាំងឡាយ៖

- បង្ហាញសញ្ញាតាមរយៈវិការ ឬទំនាក់ទំនងតាមរយៈរូបភាព

(Rose & Howley, 2007)

- បង្ហាញសិស្សនូវប្លង់មេរៀន
- សង្ខេបពីអ្វីដែលបានបង្រៀននៅខាងចុងមេរៀន
- ប្រាប់ពីខ្លឹមសារដែលសិស្សត្រូវរៀននៅមេរៀនបន្ទាប់

នៅពេលនិយាយពីការណែនាំ គ្រូអាចបង្កើតកាលវិភាគប្រចាំថ្ងៃ និងប្រចាំសប្តាហ៍ដោយដាក់បង្ហាញឱ្យសិស្សមើល និងដោយប្រើរូបសញ្ញា រូបគំនូរ ឬរូបភាព។ កាលវិភាគទាំងនេះគួរតែរក្សាឱ្យមានភាពបត់បែន ដើម្បីឱ្យសិស្សអាចបញ្ចប់កិច្ចការរបស់គេតាមពេលវេលា។

- "បង្កើតសកម្មភាពថ្នាក់រៀន ដែលបានកំណត់តាមផែនការប្រចាំសប្តាហ៍។ ចូរគូសបញ្ជាក់ឱ្យច្បាស់ ថាតើសិស្សរៀនដោយខ្លួនឯង រៀនជាក្រុម ឬជាថ្នាក់ទាំងមូល។ នៅក្នុងថ្នាក់រៀនពហុកម្រិត, ក្រុមនីមួយៗអាចធ្វើការលើសកម្មភាពដែលខុសគ្នា។" (UNESCO/Booklet Five, 2015, p. 36)
- ចូរផ្គូផ្គងការណែនាំជាពាក្យសម្តីជាមួយនឹងការគាំទ្រជារូបភាព (ដូចជា រូបគ្រាចៀកសម្រាប់លំហាត់ដែលសិស្សត្រូវស្តាប់ ឬសៀវភៅដែលសិស្សត្រូវអាន)។
- ចូរប្រើពណ៌សម្គាល់ដើម្បីបញ្ជាក់ពីកិច្ចការដែលខុសគ្នា។ (Harmer, 2015)

៣. ការធ្វើចំណាត់ថ្នាក់ជាមួយកុមារដែលមានបញ្ហាក្នុងការស្តាប់

ក្មេងៗមួយចំនួនដែលកើតមកស្តាប់មិនឮ ប្រហែលជាមិនអាចរៀននិយាយបានទេ។ ពួកគេត្រូវការវិធីផ្សេង ដើម្បីបង្ហាញពីគំនិត តម្រូវការ និងអារម្មណ៍របស់ពួកគេ ដូចជា តាមរយៈសិល្បៈ ឬតាមរយៈចលនា និងកាយវិការ។ ប្រសិនបើកុមារម្នាក់នៅក្នុងថ្នាក់របស់អ្នកដែលស្តាប់មិនឮ ឬនិយាយមិនបាន ចូរប្រើវិធីផ្សេងៗក្នុងការទំនាក់ទំនងដូចជា៖ និយាយ កដោយប្រើដៃ មុខ ចលនា ឬការសរសេរ។ មុនពេលនិយាយទៅរកកុមារម្នាក់ ចូរទាញចំណាប់អារម្មណ៍របស់គេជាមុនសិន។ ធ្វើដូច្នេះគេនឹងដឹងថាអ្នកកំពុងនិយាយទៅកាន់គេ។ ត្រូវដឹងឱ្យប្រាកដថាកុមារនេះ អាច

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

មើលឃើញអ្នកបានច្បាស់។ [...]កុមារដែលមានការលំបាកក្នុងការស្តាប់ ឬការនិយាយជួនកាលឆាប់ខឹងសម្បារ។ ពួកគេអាចនឹងផ្តោតអារម្មណ៍។ ប៉ុន្តែពួកគេត្រូវធ្វើតផ្ទង់ខ្លាំងឲ្យបានច្រើន ដើម្បីស្វែងយល់បានពីអ្វីដែលគេកំពុងនិយាយ ដែលធ្វើឱ្យពួកគេពិបាកក្នុងការផ្តោតអារម្មណ៍ ក្នុងរយៈពេលដែលយូរ។ ចូរសង្កេតមើលពួកគេដោយប្រុងប្រយ័ត្ន។ ប្រសិនបើពួកគេមិនបានផ្តោតអារម្មណ៍ទេ ចូរស្វែងរកវិធីដែលធ្វើឱ្យពួកគេចាប់អារម្មណ៍លើអ្វី ដែលអ្នកកំពុងនិយាយ។ ជាឧទាហរណ៍ អ្នកនិងសិស្សរបស់អ្នក អាចអង្គុយជារង្វង់មូល ដើម្បីឱ្យអ្នកគ្រប់គ្នាមើលឃើញមុខគ្នាទៅវិញទៅមក។ ធ្វើបែបនេះនឹងជួយឱ្យកុមារស្តាប់បាន និងឆាប់យល់។ ចូរប្រើរូបផ្សេងៗដើម្បីណែនាំមេរៀនថ្មី ដូចជា រូបភាព វត្ថុ ឬពាក្យគន្លឹះជាដើម។

ក្មេងៗមួយចំនួនដែលមានបញ្ហាក្នុងការស្តាប់ អាចស្តាប់បានច្បាស់ប្រសិនបើអ្នកដទៃនិយាយដិតត្រចៀករបស់ពួកគេ។ ចូរស្វែងយល់ថា តើធ្វើបែបនេះ អាចជួយក្មេងដែលអ្នកបង្រៀនបានឬទេ។ បើជួយបាន ចូរនិយាយក្បែរត្រចៀករបស់គាត់នៅពេលដែលអ្នកធ្វើការទាក់ទងជាមួយគាត់។ ប្រាប់ក្មេងៗដទៃទៀតឱ្យធ្វើដូចគ្នាដែរ។

នៅពេលដែលអ្នកធ្វើទំនាក់ទំនងជាមួយក្មេងប្រភេទនេះ ចូរផ្តល់ពេលវេលាឱ្យគាត់ស្តាប់ និងគិតឈ្វេងយល់។ ប្រសិនបើគាត់ឆ្លើយដោយបញ្ចេញសំឡេងមិនត្រឹមត្រូវ ចូរនិយាយពាក្យដដែលៗឡើងវិញឱ្យត្រឹមត្រូវ និងយឺតៗ ដើម្បីឱ្យក្មេងនោះព្យាយាមនិយាយសារជាថ្មី។ ចូរប្រាកដថា ក្មេងអាចមើលឃើញមុខរបស់អ្នក នៅពេលដែលអ្នកបញ្ចេញសំឡេងសម្រាប់ពាក្យទាំងនេះ។

នៅពេលអ្នកនិយាយ ចូរធ្វើចលនាដោយប្រើផ្នែកខ្លះនៃរាងកាយរបស់អ្នក ដើម្បីធ្វើឱ្យអ្វីដែលអ្នកនិយាយនោះកាន់តែច្បាស់ជាងមុន ចំពោះក្មេងដែលមានបញ្ហាក្នុងការស្តាប់។ ហើយក៏ត្រូវប្រើដៃរបស់អ្នកជាកាយវិការផងដែរនៅពេលនិយាយ។ ឧទាហរណ៍ អ្នកអាចប្រើដៃរបស់អ្នក ដើម្បីបង្ហាញពីទំហំរបស់វត្ថុទាំងឡាយ។ ចូរប្រើចលនា និងការបញ្ជាក់ទាំងឡាយ ឱ្យបានញឹកញាប់តាមដែលអាចធ្វើបាននៅពេលដែលអ្នកនៅជាមួយក្មេងដែលមានការលំបាកក្នុងការស្តាប់។ ក្មេងនេះនឹងដឹងពីរឿងទាំងនេះ។ បង្រៀនក្មេងៗដទៃទៀតឱ្យប្រើការបញ្ជាក់បង្ហាញ និងធ្វើចលនាដើម្បីទាក់ទងជាមួយក្មេងដែលមានបញ្ហាស្តាប់។ ព្យាយាមរកវិធីពន្យល់ផ្សេងៗ

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ដែលក្មេងប្រភេទនេះអាចយល់បាន។ ហើយបន្តប្រើវិធីសាស្ត្រផ្សេងៗ នៃការធ្វើទំនាក់ទំនងជាមួយក្មេងនេះ ដើម្បីធ្វើឱ្យគេយល់ពីអ្វីដែលអ្នកចង់ឱ្យគេយល់។

សិស្សដែលអាចស្តាប់ឮនៅកម្រិតណាមួយ គួរតែបានបង្រៀនឱ្យនិយាយទៅតាមកម្រិតដែលអាចធ្វើទៅបានតាមការអភិវឌ្ឍខាងផ្នែកភាសា។ [...] អ្នកអាចនឹងទទួលបានជំនួយខ្លះក្នុងការបង្កើនជំនាញភាសាដែលប្រើសញ្ញា តាមរយៈអង្គការក្រៅរដ្ឋាភិបាល មូលនិធិនានា ឬស្ថាប័នអប់រំដែលមានជំនាញ ក្នុងការជួយកុមារមានបញ្ហាខាងការស្តាប់។

ប្រសិនបើឧបករណ៍ជំនួយត្រូវបានប្រើ ចូរប្រាកដច្បាស់ថាឧបករណ៍ទាំងនេះបំពងសំឡេងទាំងអស់ដោយរាប់បញ្ចូលទាំងសំឡេងដុំវិញផងដែរ។ វាអាចនឹងពិបាកបែងចែកសំឡេងច្រើន ប្រសិនបើមនុស្សច្រើននាក់និយាយនៅពេលតែមួយ។[1]

៣.១ ស្ថានភាពនៅក្នុងប្រទេសកម្ពុជា

កម្មវិធីអប់រំពិសេស គឺទទួលខុសត្រូវខាងការអប់រំសម្រាប់កុមារ ដែលមានពិការភាព។ ដើមឡើយកិច្ចការនេះដោះស្រាយតែការអប់រំ ក្នុងសាលាបឋមសិក្សាប៉ុណ្ណោះ។ ទោះជាយ៉ាងនេះក្តី នៅក្នុងខែធ្នូ ឆ្នាំ២០១៦ ទំហំនៃទំនួលខុសត្រូវរបស់កម្មវិធីនេះបានពង្រីកដោយរាប់បញ្ចូលការអប់រំកុមារតូច និងសាលាអនុវិទ្យាល័យផងដែរ។ បច្ចុប្បន្ន ការងារត្រូវបានដំណើរការដោយការិយាល័យ ចំនួនបួនដោយរាប់បញ្ចូលទាំងនាយកដ្ឋានទទួលន្ទុកការរៀបចំផែនការផងដែរ។ នៅក្នុងប្រទេសកម្ពុជា ពិការភាពត្រូវបានបែកចែកជា៩ក្រុម៖ ការចុះខ្សោយគំហើញ ការចុះខ្សោយខាងការស្តាប់ បញ្ហាក្នុងការនិយាយ ជំងឺខាងធ្វើចលនា ភាពមិនប្រក្រតីខាងអាកប្បកិរិយា អសមត្ថភាពខាងការរៀនសូត្រ អសមត្ថភាពខាងប្រាជ្ញាស្មារតី ការរំខានខាងផ្លូវអារម្មណ៍ និងប្រភេទផ្សេងទៀត។[...]

ក្នុងប្រទេសកម្ពុជា វិស័យឯកជនទទួលខុសត្រូវចំពោះការអប់រំកុមារដែលមានពិការភាព។ ទោះបីជាដូចនេះក្តី ចាប់តាំងពីឆ្នាំ ២០២០ មកការអប់រំកុមារដែលមានបញ្ហាខាងគំហើញ និងការស្តាប់ត្រូវបានប្តូរទៅឱ្យវិស័យអប់រំរបស់រដ្ឋវិញ។

[1] Taken from UNESCO/ Booklet Four (2015, p. 42ff.). CC BY-SA 3.0 IGO. Changes made to all CC BY texts used in this theoretical introduction are indicated in italics or square brackets.

[...] មុនពេលនោះ មូលនិធីគ្រួសារថ្មី(ជាអង្គការក្រៅរដ្ឋាភិបាលមួយដែលបានបង្កើតឡើងក្នុងឆ្នាំ១៩៩១ ដែលមានគោលបំណងអប់រំក្មេងៗពីជំរុំជនភៀសខ្លួន) បានបើកដំណើរការសាលាសម្រាប់ក្មេងៗដែលមានបញ្ហាខាងគំហើញ និងការស្តាប់ក្នុងទីក្រុងចំនួន៤៖ ភ្នំពេញ កំពង់ចាម បាត់ដំបង និងសៀមរាប។[...] សាលាទាំងនេះត្រូវបានផ្លាស់ប្តូរទៅជាវិស័យសាធារណៈក្នុងឆ្នាំ២០២០។[2]

មូលនិធិគ្រួសារថ្មីក៏បានចូលរួម ក្នុងការចងក្រងឯកសារប្រព័ន្ធមួយសម្រាប់ភាសាសញ្ញាកម្ពុជាផងដែរ(ចាប់តាំងពីឆ្នាំ១៩៩៧មក) រួមជាមួយនឹងកម្មវិធីអភិវឌ្ឍជំងឺថ្លង់។ ទោះបីជាយ៉ាងនេះក្តីការផ្សព្វផ្សាយ និងការប្រើប្រាស់បានកើនឡើងជាបន្តបន្ទាប់ "នៅក្នុងថ្នាក់រៀនបែបបរិយាបន្ននឹងត្រូវការពេលវេលាខ្លះដើម្បីអនុវត្ត" (Kuroda, Kartika, & Kitamura, 2017, p. 42)។

៣.២ ស្ថានភាពនៅក្នុងប្រទេសស្រីលង្កា

សហគមន៍ដែលមានបញ្ហាខាងស្តាប់ របស់ប្រទេសស្រីលង្កា ប្រើប្រាស់ភាសាសញ្ញាជាចម្បងសម្រាប់ការធ្វើទំនាក់ទំនងទាំងក្នុង និងក្រៅថ្នាក់រៀន។ ភាសាសញ្ញានៅក្នុងប្រទេសស្រីលង្កាមានប្រភពមកពីភាសាតំបន់ជាច្រើនប្រភេទ ដោយភាសាតាមតំបន់នីមួយៗ ឆ្លើយតបទៅនឹងប្រព័ន្ធសញ្ញា ដែលប្រើនៅក្នុងសាលាសម្រាប់អ្នកថ្លង់។ សាលាសម្រាប់អ្នកថ្លង់មានវប្បធម៌ខុសគ្នា ហើយសញ្ញាប្រើសម្រាប់ទាក់ទងគ្នាក៏ខុសគ្នាដែរ។។ មិនមានស្តង់ដារួមសម្រាប់ភាសាសញ្ញាក្នុងប្រទេសស្រីលង្កាទេ។ នេះបណ្តាលឱ្យមានបញ្ហាសម្រាប់ការអប់រំចំពោះអ្នកថ្លង់។ បច្ចុប្បន្ននេះនៅពេលដែលពិចារណាទៅលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធកុមារបានសង្កត់ធ្ងន់ទៅលើ ការអប់រំបែបបរិយាបន្ននៅស្រីលង្ការ ដោយអនុលោមតាមអនុសញ្ញាអង្គការសហប្រជាជាតិ។ កុមារដែលមានបញ្ហាក្នុងការស្តាប់ គឺត្រូវបានអប់រំនៅក្នុងសាលារដ្ឋ ឬសាលាឯកជនអាចតាមរយៈ ការរួមបញ្ចូលក្នុងថ្នាក់រៀនធម្មតា ឬក្នុងអង្គភាពអប់រំពិសេស ដែលភ្ជាប់ទៅនឹងសាលាចំណេះទូទៅ។ ទោះជាយ៉ាងនេះក៏ដោយ នៅមានសិស្សមួយចំនួនដែលមានបញ្ហាស្តាប់មិនឮ ដែលនៅបន្តចូលរៀននៅសាលាអប់រំពិសេស ដោយសារតែកម្រិត នៃទំនាក់ទំនងរបស់ពួកគេ មិន

[2] Taken from Nishio (2019, p. 1754ff.). CC BY 4.0.

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

អាចត្រូវបានដាក់ចូលទៅក្នុងបរិបទណាមួយ ដែលបានលើកឡើងខាងលើនេះបានទេ។(Weerakkody, 2015)គ្រូបង្រៀននៅក្នុងសាលាអប់រំពិសេស សម្រាប់អ្នកថ្លង់មានភាពស្ទាត់ជំនាញក្នុងផ្នែកភាសាសញ្ញាចំពោះសាលារបស់ពួកគេ។ គ្រូដែលបង្រៀនក្នុងបរិបទនេះ រួមបញ្ចូលទាំងការអានតាមចលនាបបូរមាត់។ ក្នុងភាគច្រើនដែលត្រូវបានបង្រៀនក្នុង បរិបទទាំងនោះមានឧបករណ៍ជំនួយក្នុងការស្តាប់។ នៅក្នុងសាលាឯកជន មានគ្រូជំនួយជាច្រើននាក់។

៤. ការជួយកុមារដែលមើលឃើញមិនច្បាស់

នៅពេលដែលកុមារម្នាក់មានការលំបាកក្នុងការមើលឃើញ មកសាលាជាលើកដំបូង ចូរជួបសំណេះសំណាលជាមួយកុមារនោះ និងឪពុកម្តាយរបស់គេដាច់ដោយឡែកពីគ្នា។ ត្រូវឱ្យកុមារនោះបានដឹងថា អ្នកជានរណាដែលគេកំពុងនិយាយជាមួយនេះ និងពន្យល់ពីអ្វីដែលអ្នកកំពុងធ្វើ។ អនុញ្ញាតឱ្យកុមារប៉ះពាល់ឬ ស្ទាបអ្នកផ្ទាល់តែម្តង។ បន្ទាប់មកណែនាំកុមារនេះទៅកាន់មិត្តរួមថ្នាក់របស់គាត់។ ឧបមាថា នៅពេលកុមារម្នាក់នេះទទួលបានជំនួយជាក់លាក់ គាត់ក៏អាចរៀនពីគ្នាទៅវិញទៅមកបាន។ ចូរណែនាំមិត្តរួមថ្នាក់ឱ្យស្គាល់កុមារម្នាក់នេះ ប្រសិនបើកុមារម្នាក់នេះមិនអាចមើលឃើញពួកគេ សូមជួយណែនាំឈ្មោះកុមារផ្សេងៗដល់គាត់។ អនុញ្ញាតឱ្យគាត់និយាយជាមួយក្មេងម្នាក់ ក្នុងចំណោមពួកគេ រហូតដល់គាត់ចងចាំសំឡេងនិងឈ្មោះក្មេងៗទាំងនោះ។ អនុញ្ញាតឱ្យកុមារបានចាប់ប៉ះមិត្តរួមថ្នាក់។ បន្ទាប់មកប្រាប់ពីឈ្មោះរបស់កុមារដទៃទៀត ដើម្បីឱ្យគាត់ចាប់ផ្តើមស្គាល់ ក្មេងៗទាំងអស់នៅក្នុងថ្នាក់។ កុមារដែលមានបញ្ហាក្នុងការមើល ជាធម្មតាមិនដឹងថាមានមនុស្សនៅក្បែរគេនោះទេ។ ពួកគេមើលមិនឃើញមនុស្សដែលគេបានជួបឡើយ។នៅពេលដែលអ្នកនៅជាមួយកុមារម្នាក់ ដែលមើលមិនឃើញច្បាស់ ចូរនិយាយជាមួយគាត់ដើម្បីឱ្យគាត់ដឹងថាអ្នកនៅទីនោះ។ ចូរប្រាប់ក្មេងៗដទៃនៅក្នុងថ្នាក់របស់អ្នកឱ្យធ្វើរឿងដូចគ្នានេះជាមួយគាត់។ ចូរសរសេរអក្សរធំៗនៅលើក្តារខៀនហើយបង្រៀនសិស្សរបស់អ្នកឱ្យចេះ សរសេរតាមរបៀបនេះដែរ។ចូរអានការណែនាំឱ្យឮៗ ចូរកុំសន្និដ្ឋានថា សិស្សគ្រប់គ្នាអាចអាននៅលើក្តារខៀនបាន។ ចូរបញ្ជាក់ពីអ្វីដែលមាននៅលើរូបភាពជំនួយ(ដូចជា "នៅផ្នែកខាងឆ្វេងគឺ"....)។ អនុញ្ញាតឱ្យកុមារចាប់

ស្ថាបនឧបករណ៍ប្រើសម្រាប់បង្រៀនសិនបើពួកគេមិនអាចមើលឃើញ។ ឧទាហរណ៍ ផែនទីអាចជាគម្រោងទ្រង់ទ្រាយដែលមានខ្សែ។ កុមារដែលមានបញ្ហាមើលមិនឃើញត្រូវការអ្នកអានម្នាក់ ដើម្បីជួយគាត់។ អ្នកអាននេះនឹងពន្យល់ពីសៀវភៅទៅកាន់កុមារហើយជួយគាត់ឱ្យរៀនបាន។ អ្នកអានអាចជាមិត្តរួមថ្នាក់ ជាក្មេងដែលធំជាង ជាមិត្តភក្តិ ឬជាគ្រូបង្រៀនស្ម័គ្រចិត្ត។ កុមារដែលអាចមើលឃើញបានខ្លះៗ អាចរៀនអាន និងសរសេរតាមវិធីដូចគ្នា ដែលក្មេងដទៃទៀតរៀនបាន។ ចូរបង្រៀនកុមាររូបនេះឱ្យសរសេរអក្សរ និងលេខពីដំបូង។ អ្នកអាចចាប់ផ្តើមបង្រៀនកុមារនេះដោយសរសេរដាមួយដីសលើក្តារឆ្នូន។ ដាក់បង្គប់កំណាត់ខ្សែលើក្តារឆ្នូនដើម្បីឱ្យកុមារអាចស្ទាប និងប្រើវាបានជាគន្លឹះនាំផ្លូវនៅពេលសរសេរ។ នៅពេលគាត់ចាប់ផ្តើមសរសេរលើក្រដាស ចូរដាក់ខ្សែដូចគ្នានៅលើចម្រៀកឈើបង្រៀន កុមារឱ្យចេះដាក់ក្រដាសនៅខាងក្រោមខ្សែ។ តាមវិធីនេះកុមារអាចប្រើញាណរបស់ខ្លួន ទាំងការមើលព្រមទាំងការស្ទាបកាន់ ដើម្បីបង្ហាញជាផ្លូវនៃដំណើរការសរសេរ។[3]

៤.១ ស្ថានភាពនៅក្នុងប្រទេសកម្ពុជា

ការសិក្សាមួយដែលធ្វើឡើងដោយ Kuroda, Kartika and Kitamura (2017)បានបង្ហាញថា គ្រូបង្រៀនភាគច្រើននៅក្នុងប្រទេសកម្ពុជា មិនមានការបំប៉នបន្ថែមសម្រាប់ការបង្រៀនក្មេងៗ ដែលមានពិការភាពនោះទេ "ដោយរាប់បញ្ចូលទាំងចំណេះដឹងនៃភាពពិការ តម្រូវការទាំងឡាយនៃពិការភាព និងរបៀបដែលត្រូវបានបញ្ជាក់ពីតម្រូវការបែបហ្នឹងនៅកម្រិតថ្នាក់រៀន" (p. 31)។ គ្រូបង្រៀនបានដឹងពីកង្វះខាតនៃការរៀនបំប៉ន និងចាប់អារម្មណ៍ក្នុងការអភិវឌ្ឍជំនាញបង្រៀន ដែលចាំបាច់សម្រាប់បង្រៀនសិស្ស ដែលមានតម្រូវការពិសេស ។

ទាក់ទងទៅនឹងសិស្ស ដែលមានបញ្ហាខាងគំហើញ គ្រូបង្រៀនជាច្រើនមិនដែលបានឮពីអក្សរស្ទាបសម្រាប់អ្នកពិការពីមុននោះទេ "ប៉ុន្តែនៅពេលដែលគេប្រាប់ពីរឿងនេះ មានគ្រូជាច្រើននាក់បញ្ជាក់ថាពួកគាត់ចង់រៀនពីវិធីនេះ ដើម្បីពួកគាត់អាចធ្វើការទំនាក់ទំនងជាមួយសិស្សរបស់គាត់" (Kuroda, Kartika,

[3] Taken from UNESCO/ Booklet Four (2015, p. 41). CC BY-SA 3.0 IGO.

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

&Kitamura, 2017, p. 32) ។ ទោះជាយ៉ាងនេះក្តីគ្រូបង្រៀនភាគច្រើន បានប្រាប់ពីភាពមន្ទិលសង្ស័យរបស់ខ្លួន អំពីការបញ្ចូលសិស្ស ដែលមានពិការភាពចូលទៅក្នុងថ្នាក់របស់ពួកគេ ដោយពួកគេគ្មានទាំងគ្រូ និងគ្មានទាំងធនធានដើម្បីជួយគាំទ្រក្នុងដំណើរការរៀនសូត្រនោះទេ។

៤.២ ស្ថានភាពនៅក្នុងប្រទេសស្រីលង្កា

ក្នុងប្រទេសស្រីលង្កា សិស្សពិការភ្នែកប្រើប្រាស់អក្សរសម្រាប់ពួកគេ ក្នុងការអាននិងសរសេររបស់ពួកគេ ហើយនិងឧបករណ៍គិតលេខបែបចិន និងជប៉ុន សម្រាប់គណិតវិទ្យាមូលដ្ឋាន។ ពួកគេត្រូវបានអប់រំនៅក្នុងបរិបទបែបបរិយាបន្ន។ នៅក្នុងសាលាអប់រំពិសេស គ្រូទាំងអស់ចេះអក្សរសម្រាប់មនុស្សពិការភ្នែកយ៉ាងស្ទាត់ជំនាញក្នុងការអាន ការសរសេរ និងការប្រើឧបករណ៍គិតលេខបែបចិននិងជប៉ុន។ គ្រូចល័តត្រូវបានតែងតាំងដោយរដ្ឋាភិបាលនៃប្រទេសស្រីលង្កា ដើម្បីឱ្យបង្រៀនអក្សរសម្រាប់ជនពិការភ្នែកទៅឱ្យសិស្ស ដែលមានបញ្ហាខាងគំហើញដែលរៀននៅក្នុងបរិបទបរិយាបន្ន។ វិទ្យាស្ថានជាតិទទួលបន្ទុកខាងអប់រំបានបង្កើតជាសារព័ត៌មានអក្សរសម្រាប់អ្នកពិការភ្នែក ដែលផ្តល់ជាសៀវភៅរៀនសម្រាប់គ្រប់មុខវិទ្យាជាអក្សរប្រភេទនេះ (Weerakkody, 2015) ចាប់តាំងពីថ្នាក់ទី១ ដល់ទី ១១។ លើសពីនេះទៅទៀត រដ្ឋាភិបាលផ្តល់ជូនជាសៀវភៅ ដែលបោះពុម្ពព្រឹកជាអក្សរធំៗសម្រាប់មុខវិជ្ជាគណិតវិទ្យានិងភាសា Sinhala (ប្រើក្នុងប្រទេសស្រីលង្កា) សម្រាប់ ក្មេងៗដែលមើលមិនសូវឃើញ រៀននៅក្នុងថ្នាក់ទី២និងទី៣។

គ្រូបង្រៀនក្នុងស្ថាប័នអប់រំទូទៅក្នុងបរិបទបរិយាបន្ន មិនទាន់ត្រូវបានគេបង្រៀនបំប៉នឱ្យបានគ្រប់គ្រាន់ ដើម្បីបំពេញតម្រូវការរបស់កុមារ ដែលមានបញ្ហាភ្នែកនៅឡើយទេ។ ការ គាំទ្រកុមារដែលមានបញ្ហាភ្នែកពីសំណាក់គ្រូអប់រំទូទៅ អាស្រ័យទៅលើកត្តាមួយចំនួនដូចជា ទង្វើនៃការរៀនសូត្ររបស់កុមារ ការគាំទ្រពីអ្នកដទៃ ចំនួនសិស្សនៅក្នុងថ្នាក់រៀន ឬសភាពលក្ខណៈនៃប្រព័ន្ធអប់រំ។ ទោះជាយ៉ាងនេះក៏ដោយ គ្រូបង្រៀនប្រើនូវយុទ្ធសាស្ត្ររៀបចំទីតាំងមួយចំនួនសម្រាប់សិស្សដែលមានបញ្ហាភ្នែក នៅក្នុងដំណាក់កាលនៃការបង្រៀន/រៀនដូចជា ការប្តូរការរៀបចំកន្លែងអង្គុយ ការតែងតាំងមិត្តភក្តិដែលអាចផ្តល់ជំនួយបានឬការផ្តល់ចម្លើយជា ការនិយាយ

និងការណែនាំចំពោះសំណួរនានា(Anuruddhika, 2018)។ នៅពេលឈានទៅដល់ការរៀបចំការប្រឡងថ្នាក់ជាតិ (ដូចជា ក្រដាសវិញ្ញាសារសំណួរអក្សរសម្រាប់អ្នកពិការភ្នែកត្រូវបានបកប្រែមួយម៉ោងមុនពេលប្រឡង អ្នកអានក្រដាសសំណួរ និងការកំណត់ពេល) នេះជានាយកដ្ឋានទទួលបន្ទុកខាងការរៀបចំការប្រឡងរបស់ប្រទេសស្រីលង្កាជាអ្នកផ្តល់នូវការចាត់តាំងចែងទាំងនេះ។

៥. ចំណុចគន្លឹះ

- ✓ ពាក្យថាការគ្រប់គ្រងថ្នាក់រៀនសំដៅលើ គ្រប់សកម្មភាពបង្រៀនទាំងអស់ រួមនិងការប្រព្រឹត្តិរបស់គ្រូ ដោយរាប់បញ្ចូលទាំងការរៀបចំគម្រោងកិច្ចតែងការ ការសម្រួល និងការត្រួតពិនិត្យសកម្មភាពនៅក្នុងថ្នាក់ រួមទាំងការប្រើបរិយាកាសថ្នាក់រៀនទាំងមូល។
- ✓ សិស្សដែលមានតម្រូវការអប់រំពិសេស គួរតែត្រូវបានជំរុញឱ្យពង្រឹងនូវស្វ័យភាព និងការប្តេជ្ញាផ្ទាល់ខ្លួន។
- ✓ បរិយាកាសសិក្សារូបវន្តរាប់បញ្ចូលការរៀបចំថ្នាក់រៀន ការកំណត់ទីតាំងគ្រឿងសង្ហារឹម ការរៀបចំកន្លែងអង្គុយ ទីតាំងនៃតំបន់ពិសេសសម្រាប់សកម្មភាពជាក់លាក់មួយ និងការរៀបចំតាំងបង្ហាញ ។ល។
- ✓ បរិយាកាសសិក្សារូបវន្តក្នុងបរិបទបែបបរិយាបន្ន គួរតែបង្កើតឡើងតាមវិធីមួយដែលសកម្មភាព សម្ភារៈ និងឧបករណ៍ទាំងឡាយអាចមើលឃើញ និងប្រើប្រាស់បានពីសិស្សទាំងអស់គ្នា។
- ✓ វាសំខាន់ក្នុងការបង្ហាញជាព័ត៌មានថា ថ្នាក់រៀនគឺជាកន្លែងដែលមានសុវត្ថិភាព ដែលសិស្សគ្រប់រូបត្រូវបានស្វាគមន៍ ហើយសិស្សគ្រប់គ្នាត្រូវបានទទួលយកទៅតាមតម្រូវការរបស់ពួកគេ។
- ✓ ការរួមគ្នាបង្កើតវិន័យដែលមានភាពច្បាស់លាស់ សាមញ្ញ និងមានភាពវិជ្ជមាន ព្រមទាំងអាកប្បកិរិយាដែលរំពឹងទុក ពីសិស្សទាំងអស់គឺជាធាតុផ្សំដ៏សំខាន់នៃថ្នាក់រៀនតាមបែបបរិយាបន្ន ដែលត្រូវរៀបចំឡើងបានយ៉ាងល្អប្រសើរ ព្រោះវាផ្តល់នូវសក្តានុពលនៃការបញ្ចៀសបញ្ហា និងកាត់បន្ថយបញ្ហាជាអប្បបរមា។

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

- ✓ ទម្លាប់មានសារៈសំខាន់ណាស់សម្រាប់សិស្ស ដែលមានតម្រូវការពិសេស ព្រោះដោយសារតែតម្រូវការជាក់លាក់ ពួកគេអាចនឹងមានបញ្ហាចំពោះស្ថានភាពដែលមិនបានរំពឹងគិតទុកជាមុន ឬបញ្ហាដែលមិនធ្លាប់ជឿងហើយទម្លាប់ នឹងជួយបង្ហាញទិសដៅនៃការរៀនសូត្ររបស់ពួកគេ។
- ✓ កុមារដែលមិនអាចនិយាយ ឬស្តាប់ឮ ត្រូវការវិធីសាស្ត្រទំនាក់ទំនងផ្សេងគ្នាក្រៅពីការនិយាយ ដូចជាកាយវិការ ការបញ្ជាក់តាមរយៈមុខមាត់ ឬរាងកាយ។
- ✓ កុមារដែលមានបញ្ហាភ្នែកមើលមិនឃើញ ត្រូវការវិធីសាស្ត្រដើម្បីអាន និងសរសេរ ដូចជាសម្ភារៈដែលគេអាចប៉ះកាន់ដែលភ្ជាប់ទៅ នឹងក្តារឆ្នួន។

ឯកសារពិគ្រោះ

Adams, R. (2008). *Empowerment, Participation and Social Work*. Basingstoke: Palgrave Macmillan.

Ambrose, S. A., Bridges, M.W., DiPietro, M., Lovett, M.C., & Norman, M.K. (2010). *How Learning Works: Seven Research-Based Principles for Smart Teaching*. San Francisco, CA: Jossey Bass.

Anuruddhika, B.G.H. (2018). Teachers' Instructional Behaviors Towards Inclusion of Children with Visual Impairment in the Teaching Learning Process. *European Journal of Special Education Research*, 3(3).

Bucholz, J. L. & Sheffler, J. L. (2009). Creating a Warm and Inclusive Classroom Environment: Planning for All Children to Feel Welcome. *Electronic Journal for Inclusive Education, 2*(4).

Burgstahler, S. (n.d.). *Equal Access: Universal Design of Instruction*. Retrieved from https://www.washington.edu/doit/equal-access-universal-design-instruction [2021, Apr. 08].

Burgstahler, S. (n.d.). *Universal Design in Education: Principles and Applications*. Retrieved from https://www.washington.edu/doit/universal-design-education-principles-and-applications [2021, Apr. 08].

Gould, A. & Vaughn, S. (2000). Planning for the Inclusive Classroom: Meeting the Needs of Diverse Learners. *Catholic Education: A Journal of Inquiry & Practice*, 3(3), 363-374.

Hansen, R. (2015). Inklusion und Partizipation. In: C. Kieferle, F. Becker-Stoll, M. Wertfein, & E. Reichert-Garschhammer, eds.

Inklusion und Partizipation – Vielfalt als Chance und Anspruch **(pp. 81-96). Göttingen: Vandenhoeck & Ruprecht.**

Harmer, J. (2015). ***The Practice of English Language Teaching*****. Harlow: Pearson Education.**

Jordan, A. & McGhie-Richmond, D. (2014). Identifying Effective Teaching Practices in Inclusive Classrooms. In: C. Forlin & T. Loreman, eds. ***International Perspectives on Inclusive Education, Volume 3: Measuring Inclusive Education*** **(pp. 133-157). Bingley, UK: Emerald Group Publishing.**

Kratochwill, T., DeRoos, R., & Blair, S. (2014). What Works in Classroom Management. In: R.E. Slavin, ed. ***Proven Programs in Education: Classroom Management and Assessment*** **(pp. 60-65). Thousand Oaks, Ca: Corwin Press.**

Kuroda, K., Kartika, D., & Kitamura, Y. (2017). Implications for Teacher Training and Support for Inclusive Education in Cambodia: An Empirical Case Study in a Developing Country. ***JICA_RI Working Paper, Disability and Education,*** **148, 1-47.**

Nishio, A. (2019). History and Current Situation of Education for Children with Disabilities in Cambodia: A Gray Literature Review. ***Creative Education*****, 10, 1753-1763. This work is licensed under the Creative Commons Attribution International License (CC BY 4.0) (https://creativecommons.org/licenses/by/4.0/).**

Polirstok, S. (2015). Classroom Management Strategies for Inclusive Classrooms. ***Creative Education*****, 6, 927- 933. Licensed under the terms of the Creative Commons Attribution 4.0 International License (https://creativecommons.org/licenses/by/4.0/).**

Prengel, A. (2013). ***Inklusive Bildung in der Primarstufe. Eine Wissenschaftliche Expertise des Grundschulverbandes*****. Frankfurt am Main: Grundschulverband e.V.**

Rose, R. & Howley, M. (2007). ***Special Educational Needs in Inclusive Primary Classrooms.*** **London: SAGE Publication**

Shepherd, T.L. & Linn, D. (2015). ***Behavior and Classroom Management in the Multicultural Classroom.*** **London: SAGE Publication**

Uddin, M.M. & Johnson, K.V. (2018). ***Identifying Classroom Management Strategies by Focusing on Diversity and Inclusion*****. Retrieved from https://www.asee.org/public/conferences/106/papers/21263/view [2021, Apr. 08].**

UNESCO. (2015). Booklet 4: Creating Inclusive, Learning-Friendly Classrooms. In: ***Embracing Diversity: Toolkit for Creating Inclusive, Learning-Friendly Environments*****. UNESCO Bangkok Office. This publication is available in Open Access under the Attribution-**

ShareAlike 3.0 IGO (CC-BY-SA 3.0 IGO) license (http://creativecommons.org/licenses/by-sa/3.0/igo/).

UNESCO. (2015). Booklet 5: Managing Inclusive, Learning-Friendly Classrooms. In: *Embracing Diversity: Toolkit for Creating Inclusive, Learning-Friendly Environments*. UNESCO Bangkok Office. This publication is available in Open Access under the Attribution-ShareAlike 3.0 IGO (CC-BY-SA 3.0 IGO) license (http://creativecommons.org/licenses/by-sa/3.0/igo/).

UNESCO. (2015). Positive Discipline in the Inclusive, Learning-Friendly Classroom. In: *Embracing Diversity: Toolkit for Creating Inclusive, Learning-Friendly Environments Specialized Booklet 1*. UNESCO Bangkok Office. This publication is available in Open Access under the Attribution-ShareAlike 3.0 IGO (CC-BY-SA 3.0 IGO) license (http://creativecommons.org/licenses/by-sa/3.0/igo/).

Weerakkody, D.P. M (2015). *DAISY implementation in Sri Lanka*. Japanese Society for Rehabilitation of Persons with Disabilities Retrieved from: https://www.dinf.ne.jp/doc/english/resource/srilanka.html

Weinstein, C., Curran, M., & Clarke, S.T. (2003). Classroom Management in a Diverse Society. *Theory into Practice*, 42(4), 269-276.

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ជំហានទី១៖ លំហាត់ពង្រឹងចំណេះដឹង

ក. ចូរដាក់លក្ខណៈខាងក្រោមដាក់ចូលទៅក្នុងក្រុមឱ្យបានត្រឹមត្រូវ។ ចំពោះលក្ខណៈខ្លះអាចដាក់បានលើសពីមួយក្រុម៖

គ្រូមិនស្ថិតនៅក្នុងទីតាំងដែលខ្ពស់ជាង[1] – អ្នកគ្រប់គ្នាអាចមើលឃើញអ្វីដែលគ្រូបង្ហាញ[2] – វាគាំទ្រការងារក្រុមជាជាងការងារជាបុគ្គល[3] – អ្នកគ្រប់គ្នាត្រូវបានបង្ខំឱ្យធ្វើរឿងដូចគ្នានៅក្នុងអំឡុងពេលតែមួយ[4] – គ្រូស្ថិតក្នុងទីតាំងស្មើគ្នាជាមួយសិស្ស[5] – វាអនុញ្ញាតឱ្យមានការផ្លាស់ប្តូរបទពិសោធ ការបង្ហាញពីលទ្ធផលការងារ ការលេង ការច្រៀង ការប្រារព្ធពិធីផ្សេងៗរួមទាំងការដោះស្រាយទំនាស់[6] – ជំរុញលើកទឹកចិត្តឱ្យមានការសិក្សាជាលក្ខណៈបុគ្គល[7] – សិស្សអាចធ្វើលំហាត់ដោយខ្លួនឯង[8] – សិស្សអាចបែរមុខទៅរកគ្នាបាន[9]

	គុណសម្បត្តិ	គុណវិបត្តិ
		

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ខ. ចូរពិចារណាបញ្ហាប្រឈម ដែលសិស្សមានតម្រូវការពិសេសជួបប្រទះនៅក្នុងថ្នាក់រៀន។ តើបរិយាកាសរូបវន្តក្នុងថ្នាក់រៀនត្រូវបានសម្របសម្រួលយ៉ាងណាដើម្បីបង្កើតបានជាបរិបទបរិយាបន្នមួយបាន? ចូរបំពេញតារាងខាងក្រោម៖

	បញ្ហាប្រឈមដែលសិស្សមានតម្រូវការពិសេសជួបប្រទះ	មតិយោបល់សម្រាប់ការសម្របសម្រួលដោយប្រើឧទាហរណ៍
ការមើលឃើញ		
ការធ្វើចលនា		
ការរំខានតិចបំផុត		
ការរៀបចំកន្លែងអង្គុយ		

គ. ចូរដាក់លក្ខណៈខាងក្រោមដាក់ចូលទៅក្នុងក្រុមដែលត្រឹមត្រូវក្នុងតារាងខាងក្រោម៖

ផ្តល់ការណែនាំច្បាស់លាស់[1] – បង្ហាញពីការសរសើរចំណុចខ្លាំងរបស់សិស្ស[2] – ដាក់ញូលឧទាហរណ៍ និងគំនិតទស្សនៈឱ្យបានច្រើន[3] – រក្សាផ្លូវសម្រាប់ដើរឱ្យបានស្រួល[4] – ផ្តល់មេរៀនសង្ខេប[5] – ប្រព័ន្ធរៀបចំជាធ្នើរ[6] – ឥរិយាបទវិជ្ជមានចំពោះភាពចម្រុះ[7] – ការបង្កើតច្បាប់វិន័យក្នុងថ្នាក់រៀនរួមគ្នា[8] – រៀបចំកន្លែងអង្គុយ/ការពិចារណា[9] – ផ្តល់ជូនគម្រោងប្លង់មេរៀន[10] – ដាក់តាំងបង្ហាញច្បាប់ទម្លាប់ក្នុងថ្នាក់រៀនឱ្យមើលឃើញច្បាស់[11] – រៀបចំផែនការសកម្មភាពក្នុងថ្នាក់ប្រចាំសប្តាហ៍[12]

បរិយាកាសសិក្សាជាក់ស្តែងក្នុងថ្នាក់	**បរិយាកាសសិក្សាដែលមានការយកចិត្តទុកដាក់**	**ច្បាប់វិន័យ**	**ទម្លាប់**

ឃ.ចូរបង្ហាញថា តើប្រយោគខាងក្រោមត្រូវ(ត) ឬ ខុស(ខ)៖

១. ការអប់រំបែបបរិយាបន្ន តម្រូវឱ្យមានការគ្រប់គ្រងថ្នាក់រៀន ដែលបង្កើតជាបរិយាកាសសិក្សាមួយ មួយមានសិស្សចម្រុះគ្នាជាច្រើនមានអារម្មណ៍ថា ត្រូវបានគេទទួលយកហើយត្រូវបានលើកទឹកចិត្ត ផ្នែកប្រាជ្ញាស្មារតី។ ត / ខ

២. ការអប់រំបែបបរិយាបន្នផ្តល់សិទ្ធិ ឱ្យសិស្សអាចសម្រេចចិត្តដោយខ្លួនឯង ពីអ្វីដែលពួកគេគិតថា មានតម្លៃក្នុងរៀនសូត្រ។ ត / ខ

៣. នៅពេលដែលបរិយាកាសសិក្សារួបរួន ក្នុងថ្នាក់មួយត្រូវបានបង្កើតឡើង តាមវិធីមួយដែលវាបំពេញតម្រូវការផ្សេងៗគ្នាបាន វាមិនចាំបាច់ត្រូវបានគេពិចារណាសម្របសម្រួល ឬផ្លាស់ប្តូរសារជាថ្មីនោះទេ។ ត / ខ

៤. ច្បាប់វិន័យក្នុងថ្នាក់រៀនបរិយាកាសបែបបរិយាបន្ន គួរតែត្រូវបានបង្កើតឡើងដោយគ្រូតែម្នាក់ឯងប៉ុណ្ណោះ។ ត / ខ

៥. ទម្លាប់មានសារៈសំខាន់ណាស់ សម្រាប់សិស្ស ដែលមានតម្រូវការពិសេស ព្រោះថាពួកគេអាចនឹងមានបញ្ហាច្រើនទៀតចំពោះស្ថានភាពដែលមិនបានរំពឹងគិតទុកមុន ឬមិនបានដឹងជាមុន។ ត / ខ

៦. ឧបករណ៍ជំនួយក្នុងការស្តាប់ អាចនឹងស្រូប គ្រប់សំឡេងទាំងអស់ដោយរួមបញ្ចូលទាំងសំឡេងនៅជុំវិញដែលអាចធ្វើឱ្យវាមានការលំបាកក្នុងការបែងចែកសំឡេងដែលខុសៗគ្នា។ ត / ខ

៧. កុមារដែលមានបញ្ហាមើលមិនឃើញតែងតែដឹងនៅពេលដែលមានមនុស្សនៅក្បែរពួកគេ។ត / ខ

ង. ចូរសរសេរចម្លើយពិពណ៌នាខ្លី (ប្រហែល៥០០ពាក្យ) ចំពោះសំណួរឆ្លុះបញ្ចាំងពីខ្លួនអ្នកផ្ទាល់លើ៖

១. តើកត្តាអ្វីខ្លះគួរតែលើកយកមកគិតពិចារណា ក្នុងពេលរៀបចំគ្រប់គ្រងថ្នាក់រៀន ដែលមានតម្រូវការចម្រុះរបស់សិស្សដោយរាប់បញ្ចូលទាំងកុមារ ដែលមានតម្រូវការពិសេសខាងផ្នែកអប់រំ?

២. តើអ្នកអាចជួយសម្របសម្រួលតាមរបៀបណា ចំពោះការបង្កើតបរិយាកាសខាងសង្គម និងអារម្មណ៍ផ្លូវចិត្តសម្រាប់ក្មេងៗ ដែលមានតម្រូវការចម្រុះនៅក្នុងថ្នាក់រៀន?

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ជំហានទី១ ដំណោះស្រាយ

ចូរដាក់លក្ខណៈខាងក្រោមដាក់ចូលទៅក្នុងក្រុមឱ្យបានត្រឹមត្រូវ។ ចំពោះលក្ខណៈខ្លះអាចដាក់បានលើសពីមួយក្រុម៖

គ្រូមិនស្ថិតនៅក្នុងទីតាំងដែលខ្ពស់ជាង[1] – អ្នកគ្រប់គ្នាអាចមើលឃើញអ្វីដែលគ្រូបង្ហាញ[2] – វាគាំទ្រការងារក្រុមជាជាងការងារជាបុគ្គល[3] – អ្នកគ្រប់គ្នាត្រូវបានបង្ខំឱ្យធ្វើរឿងដូចគ្នានៅក្នុងអំឡុងពេលតែមួយ[4] – គ្រូស្ថិតក្នុងទីតាំងស្មើគ្នាជាមួយសិស្ស[5] – វាអនុញ្ញាតឱ្យមានការផ្លាស់ប្តូរបទពិសោធ ការបង្ហាញពីលទ្ធផលការងារ ការលេង ការច្រៀង ការប្រារព្ធពិធីផ្សេងៗរួមទាំងការដោះស្រាយទំនាស់[6] – ជំរុញលើកទឹកចិត្តឱ្យមានការសិក្សាជាលក្ខណៈបុគ្គល[7] – សិស្សអាចធ្វើលំហាត់ដោយខ្លួនឯង[8] – សិស្សអាចបែរមុខទៅរកគ្នាបាន[9]

	គុណសម្បត្តិ	គុណវិបត្តិ
	២	៣,៤
	១,២,៥,៦	
	១,២,៥.៦	
	៧,៨,៩	

ខ. ចូរពិចារណាបញ្ហាប្រឈម ដែលសិស្សមានតម្រូវការពិសេសជួបប្រទះនៅក្នុងថ្នាក់រៀន។ តើបរិយាកាសរូបវន្តក្នុងថ្នាក់រៀន ត្រូវបានសម្របសម្រួលយ៉ាងណា ដើម្បីបង្កើតបានជាបរិបទបរិយាបន្នមួយបាន? ចូរបំពេញតារាងខាងក្រោម៖

	បញ្ហាប្រឈមដែលសិស្សមានតម្រូវការពិសេសជួបប្រទះ	មតិយោបល់សម្រាប់ការសម្របសម្រួលដោយប្រើឧទាហរណ៍
ការមើលឃើញ	ចលនាផ្លាស់ទីសម្រាប់សិស្សដែលមានបញ្ហាភ្នែក ការគូសបញ្ជាក់រូបភាព ឬ ពត៌មានជាលាយលក្ខណ៍អក្សរនៅលើក្តារខៀន	ទុកផ្លូវសម្រាប់ការធ្វើដំណើរដោយស្រួលដូចជាគ្មានអ្វីនៅបាំងផ្លូវ ដើម្បីកុំឱ្យក្មេងៗដែលមានបញ្ហាភ្នែកដើរជំពប់ដើងលើវត្តុទាំងនោះ ចូរប្រើសញ្ញាធំៗ អក្សរពុម្ពដែលច្បាស់ និងឱ្យសិស្សដែលមានបញ្ហាភ្នែកអង្គុយក្បែរក្តារខៀន
ការធ្វើចលនា	ចលនាផ្លាស់ទីសម្រាប់សិស្សដែលប្រើរទេះរុញ ទុកចន្លោះផ្លូវទៅរកសម្ភារៈសម្រាប់សិស្សដែលប្រើប្រាស់រទេះរុញ	ទុកផ្លូវសម្រាប់ការធ្វើដំណើរដោយស្រួលដូចជាដាក់តុឱ្យនៅឆ្ងាយពីគ្នាល្មមដែលសិស្សប្រើប្រាស់រទេះរុញអាចផ្លាស់ទីបានដោយគ្មានបញ្ហា បង្កើតសម្ភារៈសិក្សាសម្រាប់មាតិការនៃកម្មវិធីសិក្សាស្នូលនៅក្នុងកន្លែងសិក្សាដែលសំខាន់បំផុតអាចប្រើប្រាស់បានចំពោះក្មេងៗ ដោយប្រើជំនួយពីប្រព័ន្ធរៀបចំជាធ្នើរដែលសិស្សប្រើប្រាស់រទេះរុញអាចឈោងយកដល់
ការរំខានតិចបំផុត	សិស្សដែលមានបញ្ហាខាងផ្តោតអារម្មណ៍និងគ្រប់គ្រងនូវទង្វើផ្សេងៗ **ADHD** ងាយនឹងរំខានពីបរិយាកាសខាងក្រៅ; សិស្សដែលមានជំងឺ **Autism** មានការប្រែប្រួលខ្ពស់ខាងញាណអារម្មណ៍។	ឱ្យសិស្សដែលមានបញ្ហានិងជំងឺ **ADHD** ឬ **Autism** អង្គុយឆ្ងាយពីសំឡេងដែលរំខានទាំងឡាយ

ការរៀបចំកន្លែងអង្គុយ	ចលនាផ្លាស់ទីសម្រាប់សិស្សដែលប្រើប្រាស់រទេះរុញ	ចូររៀបចំកន្លែងអង្គុយដែលអាចឱ្យសិស្សដែលប្រើប្រាស់រទេះរុញឱ្យចូលទៅក្នុងកន្លែងអង្គុយបានងាយស្រួល។ ឧទាហរណ៍ រៀបកន្លែងរាងជារង្វង់មូលដែលរទេះរុញអាចដកចេញបានយ៉ាងងាយស្រួល

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

គ. ចូរដាក់លក្ខណៈខាងក្រោមដាក់ចូលទៅក្នុងក្រុមដែលត្រឹមត្រូវក្នុងតារាងខាងក្រោម៖

ផ្តល់ការណែនាំច្បាស់លាស់[1] – បង្ហាញពីការសរសើរចំណុចខ្លាំងរបស់សិស្ស[2] – ដាក់ញូលឧទាហរណ៍ និងគំនិតទស្សន:ឱ្យបានច្រើន[3] – រក្សាផ្លូវសម្រាប់ដើរឱ្យបានស្រួល[4] – ផ្តល់មេរៀនសង្ខេប[5] – ប្រព័ន្ធរៀបចំជាធ្នើរ[6] – ឥរិយាបទវិជ្ជមានចំពោះភាពចម្រុះ[7] – ការបង្កើតច្បាប់វិន័យក្នុងថ្នាក់រៀនរួមគ្នា[8] – រៀបចំកន្លែងអង្គុយ/ការពិចារណា[9] – ផ្តល់ជូនគម្រោងប្តង់មេរៀន[10] – ដាក់តាំងបង្ហាញច្បាប់ទម្លាប់ក្នុងថ្នាក់រៀនឱ្យមើលឃើញច្បាស់[11] – រៀបចំផែនការសកម្មភាពក្នុងថ្នាក់ប្រចាំសប្តាហ៍[12]

បរិយាកាសសិក្សាជាក់ស្តែងផ្ទាល់ក្នុងថ្នាក់	បរិយាកាសសិក្សាដែលមានការយកចិត្តទុកដាក់	ច្បាប់	ទំលាប់
៤	២	១	៥
៦	៣	៨	១០
៩	៧	១១	១២

ឃ.ចូរបង្ហាញថាតើប្រយោគខាងក្រោមត្រូវ(ត) ឬ ខុស(ខ)៖

១. ការអប់រំបែបបរិយាបន្ន តម្រូវឱ្យមានការគ្រប់គ្រងថ្នាក់រៀន ដែលបង្កើតជាបរិយាកាសសិក្សាមួយមានសិស្សចម្រុះគ្នាជាច្រើនមានអារម្មណ៍ថាត្រូវបាន គេទទួលយកហើយត្រូវបានលើកទឹកចិត្តផ្នែកប្រាជ្ញាស្មារតី។ ត / ខ

២. ការអប់រំបែបបរិយាបន្នផ្តល់សិទ្ធិឱ្យ សិស្សអាចសម្រេចចិត្តដោយខ្លួនឯងពីអ្វី ដែលពួកគេគិតថាមានតម្លៃក្នុងរៀនសូត្រ។ ត / ខ

៣. នៅពេលដែលបរិយាកាសសិក្សារូបវន្តក្នុងថ្នាក់មួយត្រូវបានបង្កើតឡើងតាមវិធីមួយដែលវាបំពេញតម្រូវការផ្សេងៗគ្នាបាន វាមិនចាំបាច់ត្រូវបានគេពិចារណាសម្របសម្រួល ឬផ្លាស់ប្តូរសោរជាថ្មីនោះទេ។ ត / ខ

៤. ច្បាប់វិន័យក្នុងថ្នាក់រៀនបរិយាកាសបែបបរិយាបន្ន គួរតែត្រូវបានបង្កើតឡើងដោយគ្រូតែម្នាក់ឯងប៉ុណ្ណោះ។ ត / ខ

៥. ទម្លាប់មានសារៈសំខាន់ណាស់ សម្រាប់សិស្សដែលមានតម្រូវការពិសេស ព្រោះថាពួកគេអាចនឹងមានបញ្ហាច្រើនទៀតចំពោះស្ថានភាព ដែលមិនបានរំពឹងគិតទុកមុន ឬមិនបានដឹងជាមុន។ ត / ខ

៦. ឧបករណ៍ជំនួយក្នុងការស្តាប់ អាចនឹងស្រួប គ្រប់សំឡេងទាំងអស់ដោយរួមបញ្ចូលទាំងសំឡេងនៅជុំវិញដែលអាចធ្វើឱ្យវាមានការលំបាកក្នុងការបែងចែកសំឡេងដែលខុសៗគ្នា។ ត / ខ

៧. កុមារដែលមានបញ្ហាមើលមិនឃើញតែងតែដឹងនៅពេលដែលមានមនុស្សនៅក្បែរពួកគេ។ត / ខ

ង. ចូរសរសេរចម្លើយពិពណ៌នាខ្លី (ប្រហែល៥០០ពាក្យ) ចំពោះសំណួរឆ្លុះបញ្ចាំងពីខ្លួនអ្នកផ្ទាល់លើ៖

១. តើកត្តាអ្វីខ្លះគួរតែលើកយកមកគិតពិចារណា ក្នុងពេលរៀបចំគ្រប់គ្រងថ្នាក់រៀន ដែលមានតម្រូវការចម្រុះរបស់សិស្សដោយរាប់បញ្ចូលទាំងកុមារ ដែលមានតម្រូវការពិសេសខាងផ្នែកអប់រំ?

២. តើអ្នកអាចជួយសម្របសម្រួលតាមរបៀបណា ចំពោះការបង្កើតបរិយាកាសខាងសង្គម និងអារម្មណ៍ផ្លូវចិត្តសម្រាប់ក្មេងៗដែលមានតម្រូវការចម្រុះនៅក្នុងថ្នាក់រៀន?

ជំហានទី២៖ ជំហាត់អនុវត្ត

ក. ចូរអានករណីសិក្សាជាបន្តបន្ទាប់ហើយបំពេញក្នុងតារាងខាងក្រោម៖

ករណីសិក្សាទី១

សាលា"ក"ប្រើហិបដែក ដើម្បីដាក់សៀវភៅរក្សាទុកព្រោះសត្វកណ្តៀរ និងសត្វល្អិតដទៃទៀតតែងតែមកបំផ្លាញសម្ភារៈសិក្សាទាំងនេះ។

ករណីសិក្សាទី២

ក្តារខៀនមួយចំនួនអាចត្រូវបានប្រទះឃើញជុំវិញថ្នាក់រៀន សម្រាប់កុមារនៅក្នុងសាលា "ខ" ដើម្បីឱ្យពួកគេអង្គុយជាក្រុមហើយប្រើក្តារខៀន ដើម្បីរៀបចំគម្រោង ពិភាក្សាគំនិត ដោះស្រាយបញ្ហា។ល។ នៅក្នុងថ្នាក់រៀនខ្លះ ខ្វះគុ និងកៅអី ។ កន្លែងសិក្សាធំទូលាយមួយ ក្រាលដោយកម្រាល(កន្ទេល)ដែលផលិតក្នុងស្រុក មានអនាម័យល្អ អាចត្រូវបានផ្លាស់ប្តូរ យ៉ាងស្រួលពីកន្លែងសម្រាប់អង្កេតខាងវិទ្យាសាស្ត្រ ទៅជាកន្លែងសម្តែងសិល្បៈ ហើយក្រុមជាច្រើនអាចរៀបចំ ហើយរុះរើជាថ្មីបានដោយមិនរំខានថ្នាក់រៀនដទៃទៀត។

ករណីសិក្សាទី៣

ក្នុងសាលា "គ" ផ្ទៃជញ្ជាំងទាបៗនៃថ្នាក់រៀនត្រូវបានលាបពណ៌ខ្មៅហើយសិស្សានុសិស្សប្រើជញ្ជាំងនេះជាកន្លែងសម្រាប់សរសេរ សម្រាប់គូរគំនូរ និងសម្រាប់សរសេរជាមួយដីស។ អគារសិក្សាភាគច្រើនត្រូវបានច្នៃ និងកសាងជាពិសេសដែលងាយស្រួលសម្រាប់កុមារដូចជា ក្តារខៀនសម្រាប់កុមារដែលបានលើកឡើងខាងលើ។

ករណីសិក្សាទី៤

នៅក្នុងសាលា "ឃ" ឪពុកម្តាយត្បាញកន្ត្រក ដែលត្រូវបានដាក់លើកម្រាលឥដ្ឋ ហើយកន្ត្រកនីមួយៗពោរពេញទៅដោយសំបកខ្យង/លៀស ដុំគ្រួសតូចៗ គ្រាប់ពូជ និងរបស់ផ្សេងៗទៀតដែលអាចប្រើបានសម្រាប់មេរៀនវិទ្យាសាស្ត្រ និងគណិតវិទ្យា។ រឿងសំខាន់ដែលទាក់ទងនឹងសម្ភារៈសិក្សាទាំងនេះគឺថាពួកវាត្រូវបានប្រើប្រាស់ដោយសិស្សជាច្រើននាក់។

ករណីសិក្សាទី៥

នៅក្នុងសាលា "ង" គ្រូម្នាក់ៗបានប្រើប្រាស់ធ័ត្រ ដែលខូចជាគ្រោងសម្រាប់ចងខ្សែក្លាប់ ដោយមានអក្សរអក្ខរក្រម រូបភាពជាដើមសម្រាប់គាំទ្រសកម្មភាពរៀនភាសា។ ខ្សែដែលចងព្យួរវត្ថុជំនួយក្នុងការរៀនសូត្រត្រូវបានត្បាញឡើងពីជក់ត្នោត ឬស្លឹកចេក ជំរិចបុរាណដែលធ្វើឡើងពីផ្លែឈើ។ ឪពុកម្តាយនិងអាណាព្យាបាលដទៃ

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ទៀតបានជួយផ្តល់សម្ភារៈដែលធ្វើបាននៅក្នុងស្រុកទាំងនេះ ហើយពួកគេបានស្វែងយល់បន្ថែមអំពីដំណើរការបង្រៀន និងការរៀន។ ឥឡូវនេះពួកគេអាចនិយាយជាមួយកូនៗអំពីការសិក្សានៅឯសាលារៀន។[4]

	គំនិតសម្រាប់បរិយាកាសសិក្សាជាក់ស្តែងក្នុងថ្នាក់រៀន
ករណីសិក្សាទី១	
ករណីសិក្សាទី២	
ករណីសិក្សាទី៣	
ករណីសិក្សាទី៤	
ករណីសិក្សាទី៥	

ខ. ចូរស្តាប់អ្នកគ្រូម្នាក់និយាយអំពីរបៀប ដែលគាត់បង្រៀននៅក្នុងបរិយាកាសសិក្សាបែបបរិយាបន្ន (Audio File 4.3.1) ។ ចូរឆ្លើយសំណួរខាងក្រោមនេះ៖

១. តើអ្នកគ្រូធានាឱ្យមានបរិយាកាសបង្រៀន និងសម្ភារៈបង្រៀនបានដោយរបៀបណាឱ្យសក្តិសមត្រឹមត្រូវសម្រាប់បរិយាកាសបែបបរិយាបន្នមួយ?

គ. ចូរអានករណីសិក្សាជាបន្តបន្ទាប់ហើយបំពេញតារាងខាងក្រោម៖

ករណីសិក្សាទី១

សាន់ដុន មានអាយុ៨ឆ្នាំ ហើយបានទៅរៀនច្រើនឆ្នាំដែរ។ គាត់ត្រូវបានបង្រៀននៅក្នុងកម្មវិធីសិក្សាទូទៅ ប៉ុន្តែទទួលបានលទ្ធផលសិក្សាទាបជាងមិត្តភក្តិ។ នៅពេលដែលខ្ញុំបានចូលកាន់ថ្នាក់នេះខ្ញុំបានដឹងភ្លាមថា សាន់ដុនមានតម្រូវការពិសេសខាងការសិក្សា ប៉ុន្តែគ្មាននរណាម្នាក់បានកត់សម្គាល់ ឬដោះស្រាយបញ្ហាទាំងនេះទេ។ ខ្ញុំបានទាក់ទងអង្គការក្រៅរដ្ឋាភិបាលនៅក្នុងតំបន់មួយដែលបានចំណាយប្រាក់សម្រាប់ សាន់ដុន

[4] Adapted from UNESCO/Booklet Five (2015, p. 11ff.). CC BY-SA 3.0 IGO.

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ដើម្បីជួបពិភាក្សាជាមួយវេជ្ជបណ្ឌិត។ វេជបណ្ឌិតបានរកឃើញថា សាន់ដុនមានបញ្ហាស្តាប់សំឡេងជាពិសេសនៅពេល ដែលគាត់មិនអាចមើលឃើញមនុស្ស ឬវត្ថុដែលបង្កើតជាសំឡេងទាំងនោះ។ គ្រូពេទ្យបានណែនាំឱ្យសាន់ដុនប្រើប្រាស់ឧបករណ៍ជំនួយក្នុងការស្តាប់ដែលបានជួយសម្រួលការស្តាប់របស់គាត់បានយ៉ាងច្រើន។ ទោះជាយ៉ាងនេះក្តីសាលារបស់យើងនៅក្បែរផ្លូវដែលមានចរាចរណ៍មមាញឹក ហើយថ្នាក់រៀនមានភាពអ៊ូអរខ្លាំងណាស់។ ឧបករណ៍ជំនួយការស្តាប់ធ្វើឱ្យសំឡេងឮខ្លាំងជាងមុន ហើយសាន់ដុន យល់ឃើញថាវាថ្លង់ខ្លាំងនៅពេលពាក់ឧបករណ៍នេះគ្រប់ពេលនៅសាលារៀន។ ខ្ញុំតែងតែឱ្យសាន់ដុន អង្គុយនៅតុជួរខាងមុខថ្នាក់ ហើយខ្ញុំប្រើកាយវិការច្រើននៅពេល ដែលពន្យល់ពីរឿងទាំងឡាយ។ ខ្ញុំក៏ សរសេរការណែនាំនៅលើក្តារខៀនផងដែរ។ ព្រោះថាសាន់ដុន មិនអាចតាមទាន់នូវការបង្រៀននៅឆ្នាំមុន ខ្ញុំចំណាយពេល ដើម្បីស្វែងយល់ពីអ្វី ដែលគាត់បានចេះរួចរាល់ហើយផ្នែកណាខ្លះ ដែលគាត់ត្រូវការការគាំទ្របន្ថែម។ ខ្ញុំផ្តោតទៅលើចំណុចខ្លាំងរបស់សាន់ដុន ដើម្បីជម្នះរាល់ការលំបាករបស់គាត់។ ខ្ញុំក៏បានចាត់ឱ្យសិស្សដទៃទៀតឱ្យជួយគាំទ្រ សាន់ដុននៅពេលញ៉ាំបាយថ្ងៃត្រង់ផងដែរ។ ខ្ញុំបានចំណាយពេលជាមួយគាត់ក្នុងកន្លែងស្ងាត់មួយ។ ខ្ញុំអាចត្រួតពិនិត្យមើលថាតើគាត់បានយល់ពីអ្វីៗ ដែលយើងបានធ្វើនៅក្នុងថ្នាក់ដែរ ឬទេ។

ករណីសិក្សាទី២

ណាមីតា មានអាយុ៨ឆ្នាំហើយតែគាត់ពិការភ្នែក។ នៅក្នុងថ្នាក់រៀន គាត់អង្គុយនៅខាងមុខ ដើម្បីស្តាប់គ្រូឱ្យបានឮ ច្បាស់។ គ្រូរបស់គាត់ក៏បានជួយសម្រួលឧបករណ៍សម្រាប់បង្រៀន ដើម្បីជួយណាមីតាផងដែរ។ ពួកគាត់បានបិទខ្សែនៅលើទំព័រ ឱ្យណាមីតាអាចស្ទាបមើលមុន នៅក្នុងថ្នាក់គណិតវិទ្យា។ ក្នុងថ្នាក់ភូមិវិទ្យាគ្រូបានបិទខ្សែនៅតាមបន្ទាត់នៅលើផែនទី ហើយបានប្រើប៊ូតុងសម្រាប់កំណត់ទីក្រុងទាំងឡាយ។ ឥឡូវណាមីតា អាចទទួលបាននូវការបញ្ជាក់បានថា ប្រទេសស្រីលង្កាមានរូបរាង ទ្រង់ទ្រាយដូចម្តេចបានហើយ។នៅខាងក្រៅថ្នាក់រៀន ក្មេងៗដទៃបានជួយមើល ណាមីតា កុំឱ្យគាត់ដួលនៅពេលដែលគាត់ដើរក្នុងទីធ្លាសាលារៀន។ ពួកគេក៏បានដឹងថា វាមានសារៈសំខាន់ក្នុងការប៉ះគាត់ថ្មមតិចៗ នៅពេលដែលពួកគេចាប់ផ្តើមនិយាយជាមួយគាត់ ហើយនឹងប្រាប់ពីឈ្មោះរបស់ពួកគេ។ បើពួកគេធ្វើដូច្នេះ ណាមីតា ដឹងថា នរណាខ្លះកំពុងនិយាយជាមួយគាត់អាចមើលពួកគេបាន។[5]

	ភាពលំបាក	*មូលហេតុនៃភាពលំបាក*	*ការជួយគាំទ្រខាងគរុកោសល្យ*
សាន់ដុន			

[5] Adapted from Disability Action Council Cambodia (n.d., p. 49ff.)

	ភាពលំបាក	មូលហេតុនៃភាពលំបាក	ការជួយគាំទ្រខាងគរុកោសល្យ
ណាមីតា			

ឃ. ចូរមើលរូបភាពនេះហើយបំពេញតារាងខាងក្រោម៖

ការលំបាក	*មូលហេតុនៃការលំបាក*	*ការជួយគាំទ្រផ្នែកគរុកោសល្យ*

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ឯកសារពិគ្រោះ

Disability Action Council Cambodia. (n.d.). *Children with Special Needs in the Classroom: In-Service Teacher Training Course*.

UNESCO. (2015). Booklet 5: Managing Inclusive, Learning-Friendly Classrooms. In: *Embracing Diversity: Toolkit for Creating Inclusive, Learning-Friendly Environments*. UNESCO Bangkok Office. This publication is available in Open Access under the Attribution-ShareAlike 3.0 IGO (CC-BY-SA 3.0 IGO) license (http://creativecommons.org/licenses/by-sa/3.0/igo/).

ជំហានទី២៖ ចម្លើយអនុវត្ត

ក. ចូរអានករណីសិក្សាជាបន្តបន្ទាប់ហើយបំពេញក្នុងតារាងខាងក្រោម៖

ករណីសិក្សាទី១

សាលា"ក"ប្រើហិបដែក ដើម្បីដាក់សៀវភៅរក្សាទុកព្រោះសត្វកណ្តៀរ និងសត្វល្អិតដទៃទៀតតែងតែមកបំផ្លាញសម្ភារៈសិក្សាទាំងនេះ។

ករណីសិក្សាទី២

ក្តារខៀនមួយចំនួនអាចត្រូវបានប្រទះឃើញ ជុំវិញថ្នាក់រៀនសម្រាប់កុមារនៅក្នុងសាលា "ខ" ដើម្បីឱ្យពួកគេអង្គុយជាក្រុមហើយប្រើក្តារខៀន ដើម្បីរៀបចំគម្រោង ពិភាក្សាគំនិត ដោះស្រាយបញ្ហា។ល។ នៅក្នុងថ្នាក់រៀនខ្លះ ខ្ទះតុ និងកៅអី ។ កន្លែងសិក្សាធំទូលាយមួយ ក្រាលដោយកម្រាល(កន្ទេល)ដែលផលិតក្នុងស្រុកមានអនាម័យល្អ អាចត្រូវបានផ្លាស់ប្តូរយ៉ាងស្រួលពីកន្លែងសម្រាប់អង្កេតខាងវិទ្យាសាស្ត្រ ទៅជាកន្លែងសម្តែងសិល្បៈ ហើយក្រុមជាច្រើនអាចរៀបចំ ហើយរុះរើជាថ្មីបានដោយមិនរំខានថ្នាក់រៀនដទៃទៀត។

ករណីសិក្សាទី៣

ក្នុងសាលា "គ" ផ្ទៃជញ្ជាំងទាបៗ នៃថ្នាក់រៀនត្រូវបានលាបពណ៌ខ្មៅ ហើយសិស្សានុសិស្សប្រើជញ្ជាំងនេះជាកន្លែងសម្រាប់សរសេរ សម្រាប់គូរគំនូរ និងសម្រាប់សរសេរជាមួយដីស។ អគារសិក្សាភាគច្រើនត្រូវបានច្នៃ និងកសាងជាពិសេស ដែលងាយស្រួលសម្រាប់កុមារដូចជា ក្តារខៀនសម្រាប់កុមារ ដែលបានលើកឡើងខាងលើ។

ករណីសិក្សាទី៤

នៅក្នុងសាលា "ឃ" ឪពុកម្តាយត្បាញកន្ត្រកដែលត្រូវបានដាក់លើកម្រាលឥដ្ឋ ហើយកន្ត្រកនីមួយៗពោរពេញទៅដោយសំបកខ្យង/លៀស ដុំគ្រួសតូចៗ គ្រាប់ពូជ និងរបស់ផ្សេងៗទៀតដែលអាចប្រើបានសម្រាប់មេរៀនវិទ្យាសាស្ត្រ និងគណិតវិទ្យា។ រឿងសំខាន់ដែលទាក់ទងនឹងសម្ភារៈសិក្សាទាំងនេះគឺថាពួកវាត្រូវបានប្រើប្រាស់ ដោយសិស្សជាច្រើននាក់។

ករណីសិក្សាទី៥

នៅក្នុងសាលា "ង" គ្រូម្នាក់ៗបានប្រើប្រាស់ធ័ត្រ ដែលខូចជាគ្រោងសម្រាប់ចងខ្សែក្លាប់ ដោយមានអក្សរអក្ខរក្រម រូបភាពជាដើមសម្រាប់គាំទ្រសកម្មភាពរៀនភាសា។ ខ្សែដែលចងព្យួរវត្ថុជំនួយក្នុងការរៀនសូត្រត្រូវបានត្បាញឡើងពីជក់ត្នោត ឬស្លឹកចេក ជំរបិទបុរាណដែលធ្វើឡើងពីផ្លែឈើ។ ឪពុកម្តាយនិងអាណាព្យាបាលដទៃទៀតបានជួយផ្តល់សម្ភារៈដែលធ្វើបាននៅក្នុងស្រុកទាំងនេះ ហើយពួកគេបានស្វែងយល់បន្ថែមអំពីដំណើរការបង្រៀន និងការរៀន។ ឥឡូវនេះពួកគេអាចនិយាយជាមួយកូនៗអំពីការសិក្សានៅឯសាលារៀន។[6]

	គំនិតសម្រាប់បរិយាកាសសិក្សាជាក់ស្តែងក្នុងថ្នាក់រៀន
ករណីសិក្សាទី១	ការប្រើហិបដែកដើម្បីរក្សាទុកសម្ភារៈរបស់សាលា
ករណីសិក្សាទី២	ក្តារខៀនទាំងឡាយនៅត្រឹមកម្រិតដែលក្មេងៗឈោងដល់ កន្លែងសម្រាប់សិក្សាដ៏ធំមួយផ្តល់នូវវិធីជាច្រើននៃការប្រើប្រាស់
ករណីសិក្សាទី៣	ជញ្ជាំងទាបៗនៃថ្នាក់រៀនទាំងឡាយត្រូវបានលាបថ្នាំពណ៌ខ្មៅ ដើម្បីឲ្យក្មេងៗអាចសរសេរនិងគូរលើវាបាន

[6] Adapted from UNESCO/Booklet Five (2015, p. 11ff.). CC BY-SA 3.0 IGO.

ករណីសិក្សាទី៤	កន្ត្រកដែលសិស្សអាចប្រើប្រាស់បានគឺពោរពេញទៅដោយសម្ភារៈចម្រុះគ្នា
ករណីសិក្សាទី៥	ធ័ត្រខូចៗត្រូវបានប្រើជាគ្រោងសម្រាប់ចងខ្សែទៅនឹងវត្ថុផ្សេងៗ

ខ. ចូរស្តាប់អ្នកគ្រូម្នាក់និយាយអំពីរបៀបដែលគាត់បង្រៀននៅក្នុងបរិយាកាសសិក្សាបែបបរិយាបន្ន (Audio File 4.3.1) ។ ចូរឆ្លើយសំណួរខាងក្រោមនេះ៖

១. តើអ្នកគ្រូធានាឱ្យមានបរិយាកាសបង្រៀន និងសម្ភារៈបង្រៀនបានដោយរបៀបណាឱ្យសក្តិសមត្រឹមត្រូវសម្រាប់បរិយាកាសបែបបរិយាបន្នមួយ?

គ. ចូរអានករណីសិក្សាជាបន្តបន្ទាប់ហើយបំពេញតារាងខាងក្រោម៖

ករណីសិក្សាទី១

សាន់ដុន មានអាយុ៨ឆ្នាំ ហើយបានទៅរៀនច្រើនឆ្នាំដែរ។ គាត់ត្រូវបានបង្រៀននៅក្នុងកម្មវិធីសិក្សាទូទៅ ប៉ុន្តែទទួលបានលទ្ធផលសិក្សាទាបជាងមិត្តភក្តិ។ នៅពេលដែលខ្ញុំបានចូលកាន់ថ្នាក់នេះខ្ញុំបានដឹងភ្លាមថា សាន់ដុនមានតម្រូវការពិសេសខាងការសិក្សា ប៉ុន្តែគ្មាននរណាម្នាក់បានកត់សម្គាល់ ឬដោះស្រាយបញ្ហាទាំងនេះទេ។ ខ្ញុំបានទាក់ទងអង្គការក្រៅរដ្ឋាភិបាលនៅក្នុងតំបន់មួយដែលបានចំណាយប្រាក់សម្រាប់ សាន់ដុន ដើម្បីជួបពិភាក្សាជាមួយវេជ្ជបណ្ឌិត។ វេជបណ្ឌិតបានរកឃើញថា សាន់ ដុនមានបញ្ហាស្តាប់សំឡេង ជាពិសេសនៅពេលដែលគាត់មិនអាចមើលឃើញមនុស្ស ឬវត្ថុដែលបង្កើតជាសំឡេងទាំងនោះ។ គ្រូពេទ្យបានណែនាំឱ្យសាន់ដុនប្រើប្រាស់ឧបករណ៍ជំនួយក្នុងការស្តាប់ ដែលបានជួយសម្រួលការស្តាប់របស់គាត់បានយ៉ាងច្រើន។ ទោះជាយ៉ាងនេះក្តីសាលារបស់យើងនៅក្បែរផ្លូវដែលមានចរាចរណ៍មមាញឹក ហើយថ្នាក់រៀនមានភាពអ៊ូអរខ្លាំងណាស់។ ឧបករណ៍ជំនួយការស្តាប់ធ្វើឱ្យសំឡេងឮខ្លាំងជាងមុន ហើយសាន់ដុន យល់ឃើញថាវាថ្លង់ខ្លាំងនៅ ពេលពាក់ឧបករណ៍នេះគ្រប់ពេលនៅសាលារៀន។ ខ្ញុំតែងតែឱ្យសាន់ដុន អង្គុយនៅតុជួរខាងមុខថ្នាក់ ហើយខ្ញុំប្រើកាយវិការច្រើននៅពេល ដែលពន្យល់ពីរឿងទាំងឡាយ។ ខ្ញុំក៏សរសេរការណែនាំនៅលើក្តារខៀនផងដែរ។ ព្រោះថាសាន់ដុន មិនអាចតាមទាន់នូវការបង្រៀននៅឆ្នាំមុន ខ្ញុំចំណាយពេលដើម្បីស្វែងយល់ពីអ្វីដែលគាត់បានចេះរួចរាល់ ហើយផ្នែកណាខ្លះដែលគាត់ត្រូវការការគាំទ្របន្ថែម។ ខ្ញុំផ្តោតទៅលើចំណុចខ្លាំងរបស់សាន់ ដុន ដើម្បីជម្នះរាល់ការលំបាករបស់គាត់។ ខ្ញុំក៏បានចាត់ឱ្យសិស្សដទៃទៀតឱ្យជួយគាំទ្រ សាន់ ដុននៅពេលញ៉ាំបាយថ្ងៃត្រង់ផងដែរ។ ខ្ញុំបានចំណាយពេលជាមួយគាត់ក្នុងកន្លែងស្ងាត់មួយ។ ខ្ញុំអាចត្រួតពិនិត្យមើលថាតើគាត់បានយល់ពីអ្វីៗដែលយើងបានធ្វើនៅក្នុងថ្នាក់ដែរ ឬទេ។

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ករណីសិក្សាទី២

ណាមីតា មានអាយុ៨ឆ្នាំហើយតែគាត់ពិការភ្នែក។ នៅក្នុងថ្នាក់រៀន គាត់អង្គុយនៅខាងមុខ ដើម្បីស្តាប់គ្រូឱ្យបានឮ ច្បាស់។ គ្រូរបស់គាត់ក៏បានជួយសម្រួលឧបករណ៍សម្រាប់បង្រៀន ដើម្បីជួយណាមីតាផងដែរ។ ពួកគាត់បានបិទខ្សែនៅលើទំព័រ ឱ្យណាមីតាអាចស្ទាបមើលមុន នៅក្នុងថ្នាក់គណិតវិទ្យា។ ក្នុងថ្នាក់ភូមិវិទ្យា គ្រូបានបិទខ្សែនៅតាមបន្ទាត់នៅលើផែនទី ហើយបានប្រើប៊ូតុងសម្រាប់កំណត់ទីក្រុងទាំងឡាយ។ ឥឡូវណាមីតា អាចទទួលបាននូវការបញ្ជាក់បានថា ប្រទេសស្រីលង្កាមានរូបរាង ទ្រង់ទ្រាយដូចម្តេចបានហើយ។ នៅខាងក្រៅថ្នាក់រៀន ក្មេងៗដទៃបានជួយមើល ណាមីតា កុំឱ្យគាត់ដួលនៅពេលដែលគាត់ដើរក្នុងទីធ្លាសាលារៀន។ ពួកគេក៏បានដឹងថា វាមានសារៈសំខាន់ក្នុងការប៉ះគាត់ឬមតិចៗ នៅពេលដែលពួកគេចាប់ផ្តើមនិយាយជាមួយគាត់ ហើយនឹងប្រាប់ពីឈ្មោះរបស់ពួកគេ។ បើពួកគេធ្វើដូច្នេះ ណាមីតា ដឹងថា នរណាខ្លះកំពុងនិយាយជាមួយគាត់អាចមើលពួកគេបាន។[7]

	ការលំបាក	*មូលហេតុនៃការលំបាក*	*ការជួយគាំទ្រខាងតុរកោសល្យ*
សាន់ជុន	*ការស្តាប់សំឡេងដែលឡើងខ្ពស់និងចុះទាប*	*បញ្ហាចុះខ្សោយខាងការស្តាប់*	*ការអង្គុយក្បែរគ្រូ ការប្រើកាយវិការច្រើននៅពេលពន្យល់ ការសរសេរការណែនាំ ការចំណាយពេលបន្ថែមទៅលើការគូសបញ្ជាក់ពីភាពលំបាក*
ណាមីតា	*ការមើលមិនឃើញ*	*ភាពពិការភ្នែក*	*ការអង្គុយក្បែរគ្រូ ឧបករណ៍ជំនួយក្នុងការបង្រៀន(ដូចជាខ្សែបិតជាប់ទៅនឹងរាប់ទំព័រដើម្បីស្ទាបមើលមុំក្នុងថ្នាក់គណិតវិទ្យា ខ្សែបិទលើរាល់បន្ទាត់ទាំងអស់លើផែនទីនិងប៊ូតុងដើម្បីកំណត់ទីតាំងទីក្រុងនានា*

[7] Adapted from Disability Action Council Cambodia (n.d., p. 49ff.)

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ឃ. ចូរមើលរូបភាពនេះហើយបំពេញតារាងខាងក្រោម៖

[8] Picture Source: Own Picture

ជំហានទី៣៖ ការរៀបចំសំណុំឯកសារ –សំណួរបែបឆ្លុះបញ្ចាំងផ្ទាល់ខ្លួន

ចូរសរសេរសំណេរតែងសេចក្តីចំពោះសំណួរបែបឆ្លុះបញ្ចាំងផ្ទាល់ខ្លួនខាងក្រោម។សំណេរតែងសេចក្តីនីមួយៗ គួរតែមានពាក្យចាប់ពី ៣០០ទៅ៥០០ពាក្យ ហើយឆ្លើយជាអត្ថបទដែលទាក់ទងគ្នាងាយស្រួលយល់ជាមួយនឹងប្រយោគពេញលេញ។ ចម្លើយបែបសំណេរតែងសេចក្តីទាំងនេះដាក់ចូលទៅក្នុងសំណុំឯកសារផ្ទាល់ខ្លួនរបស់អ្នក!

ក. តាមគំនិតរបស់អ្នក តើគេគួរតែពិចារណាលើកត្តាអ្វីខ្លះក្នុងការរៀបចំចាត់ចែងថ្នាក់រៀនដែលមានតម្រូវ ការចម្រុះជាច្រើនរបស់សិស្ស ដោយរាប់បញ្ចូលទាំងសិស្សមានតម្រូវការពិសេសខាងការអប់រំ?

ខ. តើអ្នកគិតថាអ្នកអាចសម្របសម្រួលការអភិវឌ្ឍបរិយាកាសដែលមានការគាំទ្រផ្នែកសង្គម និងផ្លូវអារម្មណ៍សម្រាប់ប់សិស្សដែលមានតម្រូវការចម្រុះនៅក្នុងថ្នាក់រៀនបានដោយរបៀបណា?

ជំហានទី៤៖ ការរៀបចំសំណុំឯកសារ – គម្រោងការបង្រៀន

ចូរបង្កើតគម្រោងបង្រៀនផ្ទាល់ខ្លួនរបស់អ្នក។ ចូរពិពណ៌នាបរិយាកាសសិក្សារបស់អ្នកពីម៉ូឌុល២.៣ ដើម្បីរៀបរាប់ពីរបៀបដែលត្រូវសម្របសម្រួលបរិយាកាសសិក្សានេះដើម្បីឲ្យវាអាចរួមបញ្ចូលសិស្សទីទៃពីគ្នាជាពិសេសសិស្សដែលមានតម្រូវការពិសេសខាងផ្នែកអប់រំ។ កិច្ចការរៀបចំសំណុំឯកសារនេះគួរប្រើពាក្យចាប់ពី ៨០០ទៅ១០០០ពាក្យ។ គម្រោងការបង្រៀននេះដាក់ចូលទៅក្នុងសំណុំឯកសារផ្ទាល់ខ្លួនរបស់អ្នក!

ឧបសម្ព័ន្ធ

កំណត់ត្រាពីសំឡេង៖ Audio File 4.3.1

គ្រូបង្រៀន៖ កិច្ចការមួយដែលមានលក្ខណៈទំនើបនៅសាលារៀន គឺជាអ្វីដែលយើងព្យាយាមធ្វើ យើងសាកល្បងត្រួតពិនិត្យមើលលទ្ធភាព ដែលអាចធ្វើបានក្នុងការធ្វើបទបង្ហាញទាំងអស់។ ឯកសារ អាចជាWordPDF ឬជាការធ្វើបង្ហាញ យើងពិនិត្យមើលលទ្ធភាពឱ្យបានល្អ មុនពេលវាឈានទៅដល់សិស្ស។ ដូច្នេះនរណាក៏ដោយ ទោះជាក្មេងដែលត្រូវការការអប់រំពិសេស ឬអ្នកដែលមានបញ្ហាអានអក្សរ ឬបញ្ហាអ្វីក៏ដោយ ដែលយល់ឃើញថារឿងរ៉ាវទាំងឡាយមានការលំបាក យើងកែតម្រូវកិច្ចការរបស់គេមុន ដោយយោងទៅតាមតម្រូវការចាំបាច់ បន្ទាប់មកធ្វើកិច្ចការនោះតាមដំហាន។

អ្នកអប់រំដែលជោគជ័យត្រូវចេះពីវិធីប្រើប្រាស់ធាតុសំខាន់ៗនៃការបង្រៀនដែលមានគុណភាពខ្ពស់សម្រាប់ថ្នាក់រៀនរបស់ខ្លួន។. ក្នុងម៉ូឌុលនេះ បង្ហាញពីមូលដ្ឋានមួយចំនួនសម្រាប់ការអនុវត្តការបង្រៀនប្រកបដោយប្រសិទ្ធភាព ដើម្បីធានាថាសមាសភាពសំខាន់ នៃការបង្រៀននៅកម្រិតបឋមសិក្សាត្រូវបានពិចារណានៅពេលធ្វើផែនការបង្រៀន អនុវត្តការបង្រៀន វាយតម្លៃដំណើរការបង្រៀន និងរៀន។ តាមរយៈប្រធានបទផ្សេងៗ រួមបញ្ចូលការបង្រៀន និងរៀនសតវត្សទី២១ ការធ្វើកិច្ចតែងការបង្រៀន និងបរិស្ថានសិក្សា អ្នកនឹងតម្រូវឱ្យធ្វើការឆ្លុះបញ្ចាំងពីដំណើរការបង្រៀន និងរៀនដើម្បីសម្រេចលទ្ធផលសិក្សាដោយជោគជ័យ។

សូមសិក្សាដោយរីករាយ!

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

CONTESSA
Contemporary Teaching Skills for South Asia
Co-funded by the Erasmus+ Programme of the European Union

ម៉ូឌុល ៥

ការបង្រៀន និងការរៀនតាមបែបឌីជីថល

៥.១ គន្លឹះសំខាន់នៃការសិក្សាពីចម្ងាយ និងបរិយាកាសសិក្សាដែលបំពាក់ដោយបច្ចេកវិទ្យា

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ការបង្រៀន និងរៀនតាមបែបឌីជីថល

គរុកោសល្យ/ការបង្រៀនពីចម្ងាយ និងការពង្រឹងបរិយាសនៃការរៀនតាមបែបឌីជីថល

មេរៀននេះត្រូវបានបង្កើតឡើងដោយដៃគូសហការនៅក្នុងគម្រោងនៅ វិធីសាស្ត្របង្រៀនសម័យថ្មីនៅអាស៊ីខាងត្បូង (Contemporary Teaching Skill for South Asia) ហៅកាត់ថា CONTESSA ក្រោមការចូលរួមឧបត្ថម្ភថវិកាដោយកម្មវិធី Eramus+ នៃសហភាពអឺរ៉ុបដែលមានលេខគម្រោង598756-EPP-1-2018-1-AT-EPPKKA2-CBHE-JP-/CONTESSA

អ្នកសម្របសម្រួល :

Sandra Hummel, សាកលវិទ្យាល័យហ្គ្រាស UNIVERSITY OF GRAZ (អូទ្រីស)

ក្រោមការចូលរួមសហការពី :

សាកលវិទ្យាល័យបច្ចេកវិទ្យា ជ្រៃសឺល (អាល្លឺម៉ង់)

សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា (កម្ពុជា)

សាកលវិទ្យាល័យកម្ពុជា (កម្ពុជា)

សាកលវិទ្យាល័យអភេននៃប្រទេសស្រីលង្កា (ស្រីលង្កា)

សាកលវិទ្យាល័យយូកំឡូប (ស្រីលង្កា)

អ្នកនិពន្ធ: Regina Elias, Sandra Hummel, Mirjam Brodacz-Geier, Bridget Sheehan

សេចក្តីប្រកាស

គណៈកម្មការអឺរ៉ុបសូមធ្វើការគាំទ្រដល់ការបោះពុម្ពឯកសារនេះ ដែលមិនមែនឆ្លុះបញ្ចាំងតែពីទស្សនៈរបស់អ្នកនិពន្ធខាងលើទេ ហើយយើងក៏មិនទទួលខុសត្រូវចំពោះការប្រើប្រាស់ព័ត៌មានដែលដកស្រង់ចេញពីការបោះពុម្ពនេះដោយប្រការណាមួយដែរ។ ព័ត៌មានលម្អិតបន្ថែមនៃមេរៀននេះអាចរកបានដោយបើកចំហ និងឥតគិតថ្លៃនៅលើគេហទំព័រ CONTESSA :

https://contessa_project.eu/

រក្សាសិទ្ធិ

មេរៀននេះត្រូវបានផ្តល់អាជ្ញាប័ណ្ណឱ្យប្រើប្រាស់ក្រោមលក្ខខណ្ឌនៃ Creative Commons

Attribution_ShareAlike 4.0 Internatinal License

(https://creativecommons.org(licenses/by_sa/4.0/)

ដែលអនុញ្ញាតឱ្យប្រើប្រាស់ ចែករំលែក សម្របសម្រួលដើម្បីប្រើប្រាស់បន្ត ចែកចាយផលិតផលសារជាថ្មីក្នុងទ្រង់ទ្រាយណាមួយ ដរាបណាអ្នកប្រើប្រាស់ផ្តល់កិត្តិយសឱ្យបានសមរម្យដល់អ្នកនិពន្ធទាំងអស់។ សូមផ្តល់ជាតំណភ្ជាប់ (link) ទៅកាន់ Creative Commons License និងសូមបញ្ជាក់ផងដែរ បើមានការផ្លាស់ប្តូរណាមួយ។ ប្រសិនបើអ្នកបញ្ចូលគំនិតកែសម្រួល ឬបន្ថែមអត្ថន័យលើមេរៀននេះអ្នកត្រូវតែធ្វើការសុំសិទ្ធិកែសម្រួលឯកសារតាមលក្ខខណ្ឌខាងលើ។ រូបភាព ខ្សែសំឡេង វីដេអូ ក៏ដូចជាឯកសារដទៃទៀតដែលមាននៅក្នុងមេរៀនទាំងនេះមិនត្រូវបានបូកបញ្ចូលទៅក្នុងឯកសារអាជ្ញាប័ណ្ណ Creative Commons ទេ លើកលែងតែមានការអនុញ្ញាតឱ្យប្រើប្រាស់។ ប្រសិនបើផ្នែកណាមួយនៃមេរៀននេះមិនត្រូវបានបញ្ចូលទៅក្នុងឯកសារអាជ្ញាប័ណ្ណ ហើយការប្រើប្រាស់មិនត្រូវបានអនុញ្ញាតដោយច្បាប់ ឬក៏ប្រើប្រាស់លើសពីច្បាប់អនុញ្ញាត ត្រូវតែសុំការអនុញ្ញាតដោយផ្ទាល់ពីម្ចាស់កម្មសិទ្ធិ។

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

CONTESSA
Contemporary Teaching Skills for South Asia
Co-funded by the Erasmus+ Programme of the European Union

CC BY SA

សេចក្តីផ្តើម

តើវគ្គសិក្សា CONTESSA ជាអ្វី?

វគ្គសិក្សា CONTESSA ជាលទ្ធផលមួយក្នុងចំណោម លទ្ធផលនៃគម្រោងស្តីអំពី "ជំនាញក្នុងការបង្រៀនសម័យថ្មីសម្រាប់អាស៊ីខាងត្បូង" ដែលផ្តល់មូលនិធិរួម ដោយកម្មវិធី Erasmus+ Program នៃសហភាពអឺរ៉ុប។ គោលបំណងរបស់វគ្គសិក្សានេះ គឺ ដើម្បីជាការរួមចំណែកក្នុងការបង្កើតកម្មវិធីអប់រំគ្រូបង្រៀនដោយជោគជ័យសម្រាប់គ្រូបឋមសិក្សា ជាពិសេសក្នុងប្រទេសកម្ពុជា និងស្រីលង្កាដែលនឹងនាំដល់ការបង្កើតបានផលវិជ្ជមានរយៈពេលវែងទៅលើប្រព័ន្ធអប់រំទូទៅ។ វាមានសារៈសំខាន់កាន់តែខ្លាំងឡើង សម្រាប់អ្នកអប់រំដែលជោគជ័យក្នុងការតាមឱ្យទាន់សម័យជាមួយនឹងជំនាញ និងវិធីសាស្ត្រក្នុងសម័យថ្មី ដើម្បីយកមកប្រើក្នុង និងក្រៅថ្នាក់រៀន។ ដូច្នេះ វគ្គសិក្សា CONTESSA ផ្តល់ជូនមេរៀន ដែលត្រូវបានជ្រើសរើសដោយប្រុងប្រយ័ត្នចំនួន៥ម៉ូឌុល ដែលម៉ូឌុលនីមួយៗមានការផ្តោតការយកចិត្តទុកដាក់ទៅលើចំណុចចំនួនបី ដែលតម្រង់ទៅរកការអភិវឌ្ឍលើជំនាញបង្រៀនបែបសម័យថ្មី។ ម៉ូឌុលទាំងឡាយ និងការផ្តោតការយកចិត្តទុកដាក់របស់វាគឺមានដូចខាងក្រោម៖

ម៉ូឌុល១៖ ការកសាងការយល់ដឹងអំពីការអប់រំនៅបឋមសិក្សា
១.ការបង្រៀន និងការរៀននៅសតវត្សទី២១
២.ការរៀបចំកិច្ចតែងការបង្រៀន និងជំនាញគរុកោសល្យ ៖ គំនិត ឧបករណ៍ និងការអនុវត្ត
៣.ការរៀបចំបរិយាកាសសិក្សា

ម៉ូឌុល២៖ ភាពអស្ចារ្យក្នុងការបង្រៀន៖ សមត្ថភាពជាក់លាក់ប្រកបដោយវិជ្ជាជីវៈរបស់គ្រូបង្រៀនបឋមសិក្សា
១. ការយល់ដឹងពីការបង្រៀន៖ តួនាទី ភារកិច្ច និងមុខងារ
២. ការវាយតម្លៃលទ្ធផលនៃការសិក្សា
៣. ជំនាញវិជ្ជាជីវៈ:គរុកោសល្យ

ម៉ូឌុល៣៖ការអប់រំឈានមុខគេបែបវិធីសាស្ត្រសិស្សមជ្ឈមណ្ឌល៖ ការលើកកម្ពស់ដំណើរការសិក្សាដែលបានបង្កើតរួមគ្នា
១. ការអភិវឌ្ឍលក្ខណៈបុគ្គល និងជំនាញដោះស្រាយបញ្ហា
២. ការអះអាងពីពិភពជីវិតជាក់ស្តែង និងក្តីសង្ឃឹមទៅអនាគត
៣. ការប្តេជ្ញាចិត្តដោយខ្លួនឯង ការផ្តល់សិទ្ធិអំណាច និងប្រសិទ្ធភាពផ្ទាល់ខ្លួន

ម៉ូឌុល៤៖ ការរួមបញ្ចូលភាពខុសគ្នា៖ គោលវិធីគរុកោសល្យសម្រាប់ភាពចម្រុះគ្នា ភាពមិនស្មើគ្នា និងតម្រូវការពិសេស
១. គរុកោសល្យបរិយាបន្ន ៖ គោលវិធី និងយុទ្ធសាស្ត្រ
២. ការបង្រៀន និងរៀនក្នុងភាពចម្រុះគ្នា ៖ ការរៀបចំ ការយល់ដឹងការវាយតម្លៃ
៣. ការគ្រប់គ្រងថ្នាក់រៀនដែលមានភាពចម្រុះគ្នា

ម៉ូឌុល៥៖ ការបង្រៀន និងរៀនតាមបែបឌីជីថល
១. គរុកោសល្យ នៃការសិក្សាពីចម្ងាយ និងបរិយាកាសសិក្សាដែលបំពាក់ទៅដោយបច្ចេកវិទ្យា
២. ប្រព័ន្ធផ្សព្វផ្សាយ និងបច្ចេកទេសឌីជីថល៖ ឧបករណ៍ និងទម្រង់សម្រាប់គោលបំណងនៃការអប់រំ
៣. ការរៀបចំមេរៀន និងដំណើរការបង្រៀនតាមអ៊ិនធឺណែត

នៅពេលដែលបញ្ចប់វគ្គសិក្សានេះ អ្នកចូលរួមនឹងអាចអនុវត្តជំនាញបង្រៀនសម័យថ្មី ដែលទើបទទួលបានធ្វើឱ្យសិស្សទាំងអស់អាចចូលរួមសកម្មភាពក្នុងថ្នាក់ និងរៀនពីវិធីថ្មីៗដើម្បីជួយឱ្យសិស្សឈានទៅដល់ចំណុចសក្តានុពលពេញលេញរបស់ពួកគេ។

តើវគ្គសិក្សា CONTESSA សម្រាប់អ្នកណា?

គម្រោងស្តីពីជំនាញក្នុងការបង្រៀនសម័យថ្មីសម្រាប់អាស៊ីខាងត្បូង មានបំណងក្នុងការលើកតម្កើងជំនាញបង្រៀនសម័យថ្មីសម្រាប់គរុសិស្ស/និស្សិត និងគ្រូបង្រៀនដែលកំពុងបម្រើការក្នុងសាលាបឋមសិក្សានានា។ ឯកសារខាងក្រោមត្រូវបានសម្របសម្រួលជាពិសេសសម្រាប់គរុសិស្ស/និស្សិត។ លើសពីនេះទៅទៀត វគ្គសិក្សា CONTESSA ក៏សម្រាប់អ្នកដែលមានចំណាប់អារម្មណ៍ក្នុងការធ្វើខ្លួនឱ្យទាន់សម័យកាលជាមួយនិងជំនាញបង្រៀនសម័យថ្មី។ ឯកសារមានជាភាសាអង់គ្លេស ហើយក៏មានជាភាសាខ្មែរ ភាសាសិង្ហាលា (Sinhala) និងភាសាតាមីល (Tamil) ដែលប្រើប្រាស់នៅប្រទេសស្រីលង្កា។

តើវេទនាសម្ព័ន្ធនៃវគ្គសិក្សា CONTESSA មានអ្វីខ្លះ?

ដូចដែលបានលើកឡើងពីមុនរួចហើយ វគ្គសិក្សា CONTESSA នេះរួមមាន៥ម៉ូឌុល ដែលម៉ូឌុលនីមួយៗមានតម្លៃស្មើនឹង៣ក្រេឌីតតាមប្រព័ន្ធផ្ទេរការសិក្សារបស់អឺរ៉ុប។ ជាការល្អ ម៉ូឌុល

ទាំងនេះត្រូវបានប្រើប្រាស់រួមគ្នា ពីព្រោះម៉ូឌុលនីមួយៗយោងឯកសារលើម៉ូឌុលដទៃទៀត។ ប៉ុន្តែក្នុងមេរៀន ម៉ូឌុលទាំងនេះក៏ត្រូវបានបង្កើតឡើងក្នុងវិធីមួយ ដែលអាចប្រើបានដោយខ្លួនឯងឯងផ្ទាល់ផងដែរ។ ម៉ូឌុលនីមួយៗមានការផ្តោតលើប្រធានបទចំនួនបី ហើយឯកសារទាំងឡាយក៏បង្កើតឡើងសម្រាប់ការផ្តោតនីមួយៗផងដែរ។ វាបង្កើតឱ្យមានឯកសារសរុបចំនួន១៥ផ្នែកសម្រាប់វគ្គសិក្សា CONTESSA ។ ឯកសារនីមួយៗរួមមានសេចក្តីផ្តើមបែបទ្រឹស្តីចំពោះចំណុចផ្តើម ហើយតាមពីក្រោយដោយលំហាត់អនុវត្ត ដោយផ្អែកលើទ្រឹស្តី។

ជំហាន១ – ទ្រឹស្តី – គឺជាការរំឭកនូវអ្វីដែលបានអាននៅក្នុងសេចក្តីផ្តើមនៃទ្រឹស្តីលំហាត់អនុវត្តទាំងនេះ ត្រួតពិនិត្យការយល់ដឹងនៃអត្ថបទ ដើម្បីប្រាកដថាទ្រឹស្តីជាមូលដ្ឋានដែលត្រូវបានយល់ដឹង។

ជំហាន២ – បទពិសោធ – ផ្តល់ជូននូវឧទាហរណ៍នៃគ្រូបង្រៀនពិតប្រាកដ និងវិធីដែលពួកគាត់អនុវត្តទ្រឹស្តីផ្សារភ្ជាប់នឹងការអនុវត្តជាក់ស្តែង។ ឧទាហរណ៍ទាំងនេះបានភ្ជាប់លំហាត់អនុវត្តទៅនឹងទ្រឹស្តីដែលបានរៀនពីមុនរួចហើយ។ **ជំហាន៣ – ការឆ្លុះបញ្ចាំងដោយខ្លួនឯងផ្ទាល់** – រាប់បញ្ចូលសំណួរបែបឆ្លុះបញ្ចាំងដោយផ្អែកទៅលើចំណុចផ្តោតនីមួយៗ។

ជំហាន៤ – ការអនុវត្ត – គឺជាជំហានចុងក្រោយដែលមានគម្រោងគោលនៃការបង្រៀនមួយត្រូវបានបង្កើតឡើងផ្អែកទៅលើអ្វីដែលបានប្រទះឃើញពីមុននៅក្នុងជំហានទីមួយ និងទីពីរ។

លំហាត់អនុវត្តនៅក្នុងជំហានទីមួយ និងទីពីរអាចត្រូវបានបំពេញដោយផ្ទាល់ក្នុងឯកសារនេះ។ ជំហានទី៣ និងទីបួនជាផ្នែកនៃឯកសារដែលរៀបជាសំណុំដាច់ដោយឡែកដែលនឹងត្រូវបង្កើតដោយបុគ្គលម្នាក់ៗ។ គំរូសម្រាប់ការរៀបចំសំណុំឯកសារ (portfolio) មានជាឯកសារដាច់ដោយឡែកពីគ្នា។

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

មាតិកា

១. ការពង្រឹងតាមបែបឌីជីថល និងគរុកោសល្យ/ការបង្រៀនពីចម្ងាយ.....1

១.១ ស្ថានភាពនៅក្នុងប្រទេសកម្ពុជា..... 3

១.១ ស្ថានភាពនៅក្នុងប្រទេសស្រីលង្កា.....4

២. ការពង្រឹងបរិយាកាសនៃការសិក្សាតាមបែបឌីជីថល..... 5

៣. គន្លឹះសំខាន់ៗ 18

៤. ឯកសារពិគ្រោះ.....19

ជំហានទី១ លំហាត់អនុវត្ត 21

ជំហានទី១ លំហាត់អនុវត្ត ដំណោះស្រាយ..... 25

ជំហានទី២.....29

ជំហានទី២ - ដំណោះស្រាយ.....31

ជំហានទី៣៖ កិច្ចការរៀបចំសំណុំឯកសារ –សំណួរបែបឆ្លុះបញ្ចាំងផ្ទាល់ខ្លួន..... 33

ជំហានទី៤៖ កិច្ចការរៀបចំសំណុំឯកសារ – គម្រោងការបង្រៀន..... 33

ឧបសម្ព័ន្ធ.....34

កំណត់ត្រាពីសំឡេង៖ Audio File 5.1.1.....34

កំណត់ត្រាពីសំឡេង៖ Audio File 5.1.2..... 35

កំណត់ត្រាពីសំលេង៖ Video File 5.1.1 35

Co-funded by the
Erasmus+ Programme
of the European Union

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

១. ការពង្រឹងតាមបែបឌីជីថល និងគរុកោសល្យ/ការបង្រៀនពីចម្ងាយ

បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (អាយស៊ីធី) បានមើលឃើញពីការកើនឡើងនូវសារៈសំខាន់យ៉ាងខ្លាំងដោយសារការកើនឡើងនៃ" ទូរស័ព្ទដៃអ៊ិនធឺណិត និងសូហ្វវែរទំនាក់ទំនង" (បាលឺអូឆ្នាំ ២០១៦ ទំព័រ ២៥១) ចាប់តាំងពីទសវត្សរ៍ឆ្នាំ ១៩៩០។ បច្ចេកវិទ្យាបានផ្លាស់ប្តូររបៀបដែលមនុស្សប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមក។ បច្ចុប្បន្នកូនៗធំឡើងជាមួយការប្រាស្រ័យទាក់ទងបែបនេះ។ ដូច្នេះការអប់រំគួរតែពិចារណាលទ្ធភាព (វិធីសាស្ត្រ) អាយស៊ីធីអាចផ្តល់ជូនសម្រាប់ការទទួលបានខ្លឹមសារធ្វើការលើកិច្ចការ ឬការអភិវឌ្ឍសមត្ថភាព (ការូណាណាយ៉ាកា ២០០៦) ជាពិសេសដោយសារអាយស៊ីធីបានអនុញ្ញាតឱ្យមានការផ្លាស់ប្តូរពី" ការផ្តោតលើគ្រូបង្រៀន និងការបង្រៀនផ្អែកលើសិស្ស" -បរិយាកាសសិក្សាដែលផ្តោតលើអន្តរកម្ម" (យូណេស្កូឆ្នាំ ២០០២ ទំព័រ ៣) ។ ការបង្រៀននៅសតវត្សរ៍ទី ២១ ទាមទារឱ្យមានវិធីសាស្ត្រផ្តោតលើនិស្សិតបន្ថែមទៀតដែលធ្វើឱ្យនិស្សិតចូលរួមក្នុងការកសាងចំណេះដឹង និងការចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការសិក្សា។ ខណៈដែលគរុកោសល្យផ្តោតលើគ្រូបង្រៀននឹងសង្កត់ធ្ងន់លើការផ្តល់នូវមាតិកាសិក្សា ការរៀនសូត្រផ្តោតលើសិស្ស និងផ្តោតលើការបង្កើតឱកាសសម្រាប់ការកសាងចំណេះដឹងដោយអ្នកសិក្សា។

• ការពង្រីកឱកាសមិនចេះរីងស្ងួត៖ ភាពប្រែប្រួលនៃ OER បង្កប់ន័យថា ពួកគេអាច សម្របខ្លួនបានយ៉ាងងាយស្រួល ដើម្បីឱ្យស៊ីគ្នានឹងលក្ខខណ្ឌនៃការសិក្សាខុសគ្នា និងជួយសម្រួលដល់ការដាក់បញ្ចូលសិស្សទៅក្នុងដំណើរការសម្របខ្លួនទាំងនេះ។ ចាប់តាំងពី OER ភាគច្រើនលើសលប់ត្រូវបានផលិតតាមទម្រង់

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ឌីជីថល និងចែកចាយតាមអ៊ិនធឺណែត ការប្រើប្រាស់ជារឿយៗដំរុញការអនុវត្តសេណារីយ៉ូនៃការសិក្សាបើកចំហ និងច្នៃប្រឌិតថ្មី (ផ្អែកលើគំនិតដូចជាការរៀនសូត្រលាយបញ្ចូលគ្នាជាមួយការបង្រៀនក្នុងថ្នាក់រៀនជាដើម)។

- ភាពមើលឃើញកាន់តែច្រើនសម្រាប់ការបង្រៀនប្រកបដោយគុណភាព៖ គ្រូដែលបង្កើតសម្ភារៈសិក្សាផ្ទាល់ខ្លួន និងចែកចាយជា OER អាចរំពឹងថានឹងទទួលបានមនុស្សកាន់តែច្រើនជាមួយនឹងមាតិការបស់ពួកគេ គ្រូនិងសិស្សដទៃទៀត ព្រមទាំងអ្នកដែលចាប់អារម្មណ៍លើប្រធានបទនេះ។ ជាលទ្ធផល កិច្ចខិតខំប្រឹងប្រែងនិងសមិទ្ធិផលរបស់បុគ្គលិកអប់រំអាចត្រូវបានគេមើលឃើញ និងកោតសរសើរលើសពីថ្នាក់រៀន ដែលអាចជាការអភិវឌ្ឍដ៏មានសារសំខាន់ក្នុងយុគសម័យនៃការបង្កើនឌីជីថលមួយ [...] ។

បញ្ហាប្រឈមនៃធនធានអប់រំបើកចំហ (OER)៖

- បរិមាណវត្ថុធាតុដើមដែលមានស្រាប់៖ ចលនា OER បានចាប់ផ្តើមនៅដើមទសវត្ស ឆ្នាំ២០០០ ហើយចាប់តាំងពីពេលនោះមកបរិមាណធនធានដែលមានស្រាប់បានកើនឡើងគួរឱ្យកត់សម្គាល់។ ទោះយ៉ាងណា ការស្វែងរកសម្ភារៈដែលគ្របដណ្តប់លើប្រធានបទជាក់លាក់មួយនឹងមិនមានលទ្ធផលទេ [...]។ ហេតុដូច្នេះហើយ ការបង្កើតវត្ថុធាតុដើមថ្មីៗ គឺមានតម្រូវការយ៉ាងខ្លាំង ប៉ុន្តែមិនមានច្រើនដែលអាចប្រើជាថ្នូរនោះទេ។ ទោះយ៉ាងណា ប្រសិនបើមនុស្សកាន់តែច្រើនចូលរួមការងាររបស់ពួកគេ ធនធានកាន់តែច្រើននឹងមាន ហើយស្ថានភាពនឹងកាន់តែប្រសើរឡើងឆាប់។
- ការប្រមូល OER បែបរមែជ្ឈការ៖ នៅពេលរកមើលធនធានអប់រំដែលមានប្រយោជន៍តាមអ៊ិនធឺណែត អ្នកនឹងដឹងថាមានការប្រមូលផ្តុំជាច្រើននៅទីតាំងផ្សេងគ្នា (ដែលគេហៅថា ឃ្លាំង)។ វាចាំបាច់ក្នុងការអភិវឌ្ឍបទពិសោធខ្លះ និងស្គាល់គេហទំព័រ OER ដើម្បីស្វែងរកមាតិកាដែលចង់បាន និងប្រសិទ្ធភាពដែលត្រូវការពេលវេលា និងការអនុវត្តតិចតួច។ ទោះជាយ៉ាងណា យើងគួរចងចាំថាទិដ្ឋភាព OER គឺកំពុងផ្លាស់ប្តូរឥតឈប់ឈរ [...] ។
- គ្មានលក្ខណៈវិនិច្ឆ័យដែលមានលក្ខណៈស្តង់ដាសម្រាប់គុណភាព៖ សម្ភារៈអប់រំដែលត្រូវបានបញ្ចេញជា OER ជាធម្មតាមិនឆ្លងកាត់ការត្រួតពិនិត្យគុណភាពជាផ្លូវការណាមួយឡើយ។ ជាលទ្ធផល ការវាយតម្លៃចុងក្រោយពីបញ្ហាគុណភាពទាំងអស់គឺជាទំនួលខុសត្រូវរបស់អ្នកប្រើប្រាស់។ ទោះយ៉ាងណា

ការសន្មតថានឹងមានការអភិវឌ្ឍថ្មីទាក់ទងនឹងការបង្កើត និងការបញ្ចាក់ពីស្តង់ដាគុណភាពនាពេលអនាគត គឺមានសុវត្ថិភាព (ឧទាហរណ៍៖ ការអនុវត្តជម្រើសវាយតម្លៃសម្រាប់ OER គ្រឿងបរិក្ខារសម្រាប់ការផ្តល់និងទទួលបានការឆ្លើយតប ឬ ការផ្តល់រង្វាន់ផ្លាកសញ្ញា) ដល់អ្នកបង្កើត OER ដែលមានគុណភាពខ្ពស់។

- ភាពស្របច្បាប់ពេញលេញគឺមិនអាចធ្វើទៅបានទេ៖ ទោះបីមានការយកចិត្តទុកដាក់ខ្ពស់ដើម្បី អនុវត្តនិងប្រើប្រាស់អាជ្ញាបណ្ណសមស្របក្នុងការប្រើប្រាស់និងការបង្កើត OER ក៏ដោយ ការបំពានច្បាប់កម្មសិទ្ធបញ្ញានៅតែកើតមានឡើងដោយសារតែការកាន់ច្រឡំរបស់បុគ្គល ឬ ក្រុមមនុស្ស។ សុវត្ថិភាពផ្នែកច្បាប់ពេញលេញមិនមែនជាសមិទ្ធិផលដែលអាចកើតឡើងបានដោយសារហេតុផលជាច្រើនដូចជា ភាពមិនត្រឹមត្រូវ និងភាពមិនសមហេតុផលក្នុងក្រមនីតានុកូលកម្ម ភាពខុសគ្នានៃជាតិក្នុងការអនុវត្តអត្ថបទច្បាប់ទាំងនេះ និងសំណួរដែលមិនទាន់បានដោះស្រាយទាក់ទងនឹងការប្រើប្រាស់ធាតុមួយចំនួន (ឧទាហរណ៍៖ ការដកស្រង់) ក្នុងផលិតកម្ម OER ។

២១.៤.-ស្ថានភាពនៅប្រទេសស្រីលង្កា

នៅក្នុងប្រទេសស្រីលង្កា ក្រសួងអប់រំ គឺជាក្រសួងសាមីនាំមុខ (Line Ministry) [...] និងមានមន្ទីរអប់រំខេត្តចំនួនប្រាំបួន ដែលតំណាងឱ្យខេត្តទាំងប្រាំបួននៃប្រទេសដូចជា កណ្តាល ខាងកើតខាងជើង ខាងជើង, ខាងកើតខាងជើង ខាងជើង ខាងលិច, Sabaragamuwa, Southern, Uwa និងលោកខាងលិច។ ក្រសួងបរិស្ថានមានទំនួលខុសត្រូវក្នុងការរៀបចំផែនការយុទ្ធសាស្ត្រជាតិស្តីពីវិស័យអប់រំដោយផ្អែកលើគោលនយោបាយអប់រំជាតិ អាចទទួលយកគោលនយោបាយនានាដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ខេត្តនីមួយៗដោយផ្អែកលើគោលនយោបាយអប់រំជាតិ និងកំណែទម្រង់បច្ចុប្បន្ន (គេហទំព័រក្រសួងអប់រំ)។ ជាមួយនឹងគោលបំណងនៃការផ្តល់ទិសដៅក្នុងការប្រើប្រាស់ធនធានអប់រំបើកទូលាយ (OER) ដើម្បីបង្កើនការចូលរួម និងគាំទ្រដល់ការបង្រៀន និងរៀនប្រកបដោយគុណភាពនៅក្នុងប្រព័ន្ធអប់រំទូទៅ នៅប្រទេសស្រីលង្កាកម្មវិធីតស៊ូមតិមួយត្រូវបានរៀបចំដោយ COL [Commonwealth of Learning] ដើម្បីបង្កើតសេចក្តីព្រាងគោលនយោបាយ OER សម្រាប់មន្ទីរអប់រំខេត្តទាំង៩ ដោយមានការយល់ព្រម និងគាំទ្រពីក្រសួងអប់រំ។

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

៣-សមត្ថភាពរបស់គ្រូសម្រាប់ការបង្រៀនតាមបែបឌីជីថល

គ្រូម្នាក់ដែលប្រើប្រព័ន្ធផ្សព្វផ្សាយឌីជីថលនិងបច្ចេកវិទ្យានៅក្នុងថ្នាក់រៀន ត្រូវមានសមត្ថភាពបន្ថែម បើប្រៀបធៀបនឹងការបង្រៀនដែលមិនមែនតាមបែបឌីជីថល។ តារាងខាងក្រោមបង្ហាញពីសមត្ថភាពបន្ថែម និងកម្រិតដែលអាចសម្រេចបាន៖

តំបន់សមត្ថភាព	សមត្ថភាព
ព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ	១.១-ការស្រាវជ្រាវរុករកនិងគ្រប់គ្រងព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយឌីជីថល ១.២-ការវាយតម្លៃព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយឌីជីថល ១.៣-ការគ្រប់គ្រងព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយឌីជីថល
ទំនាក់ទំនង និងការសហការ	២.១-ការធ្វើអន្តរកម្ម តាមរយៈប្រព័ន្ធផ្សព្វផ្សាយ ឌីជីថល និងបច្ចេកវិទ្យា ២.២-ការចែករំលែក តាមរយៈប្រព័ន្ធផ្សព្វផ្សាយឌីជីថល និងបច្ចេកវិទ្យា ២.៣-ការចូលរួមក្នុងភាពជាពលរដ្ឋ តាមរយៈប្រព័ន្ធផ្សព្វផ្សាយឌីជីថល និងបច្ចេកវិទ្យា ២.៤-ការសហការ តាមរយៈប្រព័ន្ធផ្សព្វផ្សាយឌីជីថល និងបច្ចេកវិទ្យា ២.៥-ណេតធីត ២.៦-ការគ្រប់គ្រងអត្តសញ្ញាណឌីជីថល
ការបង្កើតមាតិកាឌីជីថល	៣.១-ការអភិវឌ្ឍមាតិកាឌីជីថល ៣.២-ការរួមបញ្ចូល និងការពណ៌នាខ្លឹមសារឌីជីថលឡើងវិញ ៣.៣-ការរក្សាសិទ្ធិ និងអាជ្ញាបណ្ណ ៣.៤-ការសរសេរកម្មវិធី

សុវត្ថិភាព	៤.១-ការថែរក្សាឧបករណ៍ ៤.២-ការថែរក្សាទិន្នន័យផ្ទាល់ខ្លួន និងឯកជនភាព ៤.៣-ការការពារសុខភាព និងសុខមាលភាព ៤.៤-ការការពារបរិស្ថាន
ដោះស្រាយបញ្ហា	៥.១-ការដោះស្រាយបញ្ហាបច្ចេកទេស ៥.២-ការកំណត់តម្រូវការ និងការឆ្លើយតបផ្នែក បច្ចេកវិទ្យា ៥.៣-ការច្នៃប្រឌិតដោយប្រើប្រព័ន្ធផ្សព្វផ្សាយឌីជីថល និងបច្ចេកវិទ្យា ៥.៤-ការកំណត់គម្លាតសមត្ថភាពឌីជីថល

តារាងទី ៥៖ ក្របខណ្ឌសមត្ថភាពឌីជីថល

៣១.-ចំណេះដឹងផ្នែកព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ

ដើម្បីឱ្យគ្រូផ្តល់ការបង្រៀន និងរៀនតាមបែបឌីជីថលកាន់តែប្រសើរ ពួកគេត្រូវមានជំនាញស្នូលអំពីប្រព័ន្ធផ្សព្វផ្សាយឌីជីថល និងបច្ចេកវិទ្យា។ នៅពេលមានភាពស្ទាត់ជំនាញស្នូលទាំងនេះ គ្រូនឹងមានការយល់ដឹងអំពីរបៀបប្រើឧបករណ៍ទាំងនេះតាមរបៀបដែលមានគោលបំណងគរុកោសល្យ។ កិច្ចការនេះរួមបញ្ចូលការយល់ដឹងអំពីវិធីដែលវិធីសាស្ត្រឌីជីថលអាចជួយរួមចំណែកដល់ការសម្រេចបាននូវគោលបំណងនៃការសិក្សា ជំនួសឱ្យការពិចារណាលើការប្រើប្រាស់ដាច់ដោយឡែកពីដំណើរការបង្រៀននិងរៀនដែលនៅសេសសល់។

៣២.. ទំនាក់ទំនង និងការសហការ

គ្រូមានសមត្ថភាពក្នុងការរៀបចំផែនការ និងកែច្នៃបរិយាកាសសិក្សាបែបឌីជីថលដែលធ្វើឱ្យសិស្សផ្តោតការយកចិត្តទុកដាក់លើបទពិសោធនៃការបង្រៀន និងរៀន ហើយប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយឌីជីថល និងបច្ចេកវិទ្យាតាមរបៀបដែលគាំទ្រដល់តម្រូវការអ្នកសិក្សា។ ពួកគេទទួលយកជាពិសេសសម្រាប់ការប្រាស្រ័យទាក់ទង និងការសហការគ្នារវាងសិស្សនិងសិស្ស និងរវាងគ្រូនិងសិស្ស។ គ្រូគួរតែប្រើប្រព័ន្ធផ្សព្វផ្សាយឌីជីថល និងបច្ចេកវិទ្យាសម្រាប់ធ្វើទំនាក់

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ទំនង និងសហការជាមួយមិត្តរួមអាជីព និងមាតាបិតាសិស្ស ដើម្បីគាំទ្របន្ថែមដល់សិស្សនៅក្នុងដំណើរការសិក្សា។

៣.៣-ការបង្កើតមាតិកាឌីជីថល

ជំនាញស្នូលក្នុងការបង្រៀន និងរៀនតាមបែបឌីជីថលដែលផ្គូផ្គងជាមួយនឹងការឆ្លុះបញ្ចាំងគរុកោសល្យ គឺសំដៅដល់ការបង្កើនសមត្ថភាពគ្រូដើម្បីបង្កើតសម្ភារៈសិក្សា និងឱកាសសិក្សាដែលពង្រឹងតាមបែបឌីជីថល។ គ្រូបង្រៀនមានសមត្ថភាពកំណត់រក ទីតាំង និងជ្រើសរើសប្រព័ន្ធផ្សព្វផ្សាយឌីជីថលនិងបច្ចេកវិទ្យា និងវាយតម្លៃប្រព័ន្ធផ្សព្វផ្សាយ យោងទៅលើភាពត្រឹមត្រូវ និងភាពសមស្របសម្រាប់មុខវិជ្ជា និងក្រុមអាយុជាក់លាក់។ នៅពេលបង្កើតប្រព័ន្ធផ្សព្វផ្សាយឌីជីថល គ្រូត្រូវមានការយល់ដឹងអំពីកម្មសិទ្ធបញ្ញា។ ប្រព័ន្ធត្រូវតែមានភាពខុសគ្នារវាងប្រព័ន្ធផ្សព្វផ្សាយឌីជីថលដែលប្រើប្រាស់សម្រាប់ជូនដំណឹងដល់ខ្លួនឯង ប៉ុន្តែមិនមែនសម្រាប់ប្រើប្រាស់នៅក្នុងថ្នាក់រៀន និងប្រព័ន្ធផ្សព្វផ្សាយឌីជីថល អាចប្រើដោយសេរីនៅក្នុង និងក្រៅថ្នាក់រៀន។ បន្តមក ឧបករណ៍ប្រព័ន្ធត្រូវបានបោះពុម្ពផ្សាយដោយមានអាជ្ញាបណ្ណរក្សាសិទ្ធិសមស្រប។ អាជ្ញាបណ្ណរក្សាសិទ្ធិរីករាលដាលតាមទម្រង់ផ្សេងគ្នានៃឯកសារបើកចំហត្រូវបានផ្តល់ជូនដោយ Creative Commons។ ដំណោះស្រាយបញ្ហាដើម្បីធានាបាននូវបទពិសោធនៃការបង្រៀន និងរៀនតាមបែបឌីជីថលប្រកបដោយភាពជោគជ័យ គ្រូត្រូវរក្សាលក្ខខណ្ឌនៃចំណេះដឹង និងជំនាញរបស់ពួកគេ។ ដូច្នេះគ្រូត្រូវមានការយល់ដឹងអំពីសមត្ថភាពឌីជីថល។ លើសពីនេះទៀត គ្រូត្រូវឆ្លុះបញ្ចាំងជាប្រចាំលើការអនុវត្ត និងប្រសិទ្ធភាពនៃឧបករណ៍ដែលបានប្រើ និងរបៀបដែលបច្ចេកវិទ្យាផ្លាស់ប្តូរការបង្រៀននិងរៀន។ គ្រូគួរប្រើប្រព័ន្ធផ្សព្វផ្សាយឌីជីថលនិងបច្ចេកវិទ្យា ដើម្បីបង្កើនសមត្ថភាពខ្លួនឯងលើខ្លឹមសារនៃប្រធានបទ ការអភិវឌ្ឍគរុកោសល្យវិជ្ជាជីវៈ និងភាពជឿនលឿនផ្នែកបច្ចេកទេស។

៤. ការពិចារណាសម្រាប់ការបង្រៀនតាមបែបឌីជីថល

ការបង្រៀនបែបឌីជីថលនៅក្នុងថ្នាក់រៀន គឺមានភាពខុសប្លែកពីការបង្រៀនបែបប្រពៃណីនៅក្នុងថ្នាក់រៀន និងប្រឈមនឹងហានិភ័យនិងការលំបាកផ្សេងៗ ដូច្នេះ ចាំបាច់ត្រូវត្រៀមចំពោះការលំបាកនិងបញ្ហាប្រឈម និងការឆ្លើយតប។

•ត្រូវត្រៀមខ្លួនជានិច្ចសម្រាប់ពេលវេលាដែលឧបករណ៍មិនដំណើរការ។ ប្រសិនបើអ្នកប្រើបច្ចេកវិទ្យាឌីជីថល អ្នកតែងតែជួបប្រទះនូវឧបករណ៍ដែលមិន

ដំណើរការនៅពេលអ្នកប្រើប្រាស់។ អ្នកគួរតែពិនិត្យមើលឧបករណ៍និងបច្ចេកវិទ្យាជាចាំបាច់ មុនពេលបង្រៀន ដើម្បីដឹងថាតើឧបករណ៍ណាមួយដំណើរការ។ ប្រសិនបើឧបករណ៍ និង បច្ចេកវិទ្យាមិនអាចប្រើបានក្នុងថ្នាក់ អ្នកត្រូវការផែនការ។ ឧទាហរណ៍ ប្រសិនបើអ្នកឱ្យសិស្សរបស់អ្នកធ្វើកិច្ចការតាមអ៊ិនធឺណែត ហើយភ្លាមៗនោះអ្នកមិនមានចរន្ត អគ្គិសនី ឬ ការតភ្ជាប់អ៊ីធឺណែតត្រូវបានកាត់ផ្តាច់ អ្នកគួរតែកាន់កំណែដែលបានបោះពុម្ព។ វិធីនេះ និស្សិតអាចបន្តធ្វើកិច្ចការលើកម្រងសំណួរជាឯកសារក្រដាស។ សូមចងចាំថា អ្នកត្រូវបោះពុម្ពកម្រងសំណួរមុនបង្រៀន ព្រោះក្នុងអំឡុងពេលដាច់ចរន្ត អគ្គិសនី ម៉ាស៊ីនព្រីនធ័រមិនដំណើរការទេ។ ចំណុចមួយទៀតគឺ គុណភាពខុសគ្នានៃផ្នែករឹង។ ជួនកាល សាលារៀនមិនមានបច្ចេកវិទ្យាទំនើបចុងក្រោយទេ ហេតុនេះ ឧបករណ៍ផ្ទាល់ខ្លួន និងឧបករណ៍ក្នុងស្រុក អាចនឹងមិនស៊ីគ្នាទេ ដូចនេះ អ្នកត្រូវរៀបចំអាដាប់ធ័រជាមុន។ ប្រសិនបើអ្នកបានរៀបចំការកិច្ចជាមួយឧបករណ៍តាមអ៊ិនធឺណែតដោយមិនមាននៅលើឧបករណ៍សាលារៀន ឬ ឧបករណ៍របស់សិស្សអ្នកត្រូវត្រៀម ឬ ត្រួតពិនិត្យជាមុនថាតើឧបករណ៍នេះអាចប្រើបាន ឬអត់។

- កន្លែងអង្គុយនៅក្នុងថ្នាក់រៀនឌីជីថល អាចមានភាពខុសគ្នាច្រើនពីថ្នាក់រៀនបែបបុរាណ។ កន្លែងអង្គុយគួរតែអាចបត់បែនបាន តុនិងកៅអីគួរតែត្រូវបានរៀបចំផ្អែកលើតម្រូវការតាមថ្ងៃសម្រាប់ការងារក្រុម ហើយតារាងដាច់ដោយឡែកអាចដាក់ជាមួយគ្នាសម្រាប់សិស្សទល់មុខគ្នា។ និស្សិតមានថេបប្លេត ឬ ស្មាតហ្វូនដើម្បីធ្វើកិច្ចការជាមួយ ឬ ពួកគេត្រូវបានរៀបចំនៅជុំវិញកុំព្យូទ័ររួមគ្នា។ ដូចគ្នានេះ ទីតាំងគ្រូនៅខាងមុខក្នុងថ្នាក់ត្រូវបានផ្លាស់ប្តូរនៅពេលដែលវេទិកាត្រូវបានផ្លាស់ទីជុំវិញក្នុងថ្នាក់រៀន ឬ ត្រូវបានផ្លាស់ទីទៅចំហៀងក្នុងថ្នាក់រៀន ឬ នៅខាងក្រៅមើលឃើញទាំងស្រុង។ ប្រសិនបើមានគ្រូលើសពីម្នាក់នៅក្នុងថ្នាក់រៀន ក្រុមនេះអាចបំបែកគ្នា ហើយប្រើបន្ទប់ផ្សេងគ្នាសម្រាប់ការសិក្សា។ សំខាន់ជាងនេះ បច្ចេកវិទ្យាជួយឱ្យគ្រូមានភាពបត់បែនកាន់តែច្រើនជាមួយនឹងការផ្លាស់ទីនៅក្នុងបន្ទប់។ គ្រូមិនចាំបាច់នៅខាងមុខក្នុងថ្នាក់ហើយ សរសេរនៅលើក្តារខៀនទេ។ គ្រូអាចជាផ្នែកមួយនៃក្រុមដែលអង្គុយនៅតុ ហើយផ្តល់ព័ត៌មានថ្មីដោយចាក់បញ្ចាំងនៅលើជញ្ជាំងផ្ទាល់ពីថេបប្លេត។
- ជារួម ថាតើថ្នាក់ឆ្លាតវៃមានប្រយោជន៍ ឬ អត់ គឺអាស្រ័យលើឆន្ទៈរបស់គ្រូក្នុងការប្រើប្រាស់បច្ចេកវិទ្យាសម្រាប់ថ្នាក់រៀនរបស់គាត់ ប្រសិនបើសមស្រប

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

សម្រាប់សិស្ស ហើយសិស្សមានទឹកចិត្តក្នុងការប្រើប្រាស់បច្ចេកវិទ្យា និងមានឆន្ទៈបំពេញកិច្ចការរបស់គ្រូ។

៥. ចំណុចសំខាន់ៗ

គំរូ SAMR មានកម្រិតផ្សេងគ្នាដែលបច្ចេកវិទ្យាឌីជីថលអាចដាក់បញ្ចូលទៅក្នុងដំណើរការបង្រៀន និងរៀន ។
បច្ចេកវិទ្យាអាចដើរតួជំនួសដោយមិនបន្ថែមការផ្លាស់ប្តូរមុខងារ (ជំនួស); បច្ចេកវិទ្យាអាចដើរតួជំនួសដោយការបន្ថែមការផ្លាស់ប្តូរមុខងារ (ការបន្ថែម); បច្ចេកវិទ្យាអាចកែប្រែភារកិច្ចបានយ៉ាងសំខាន់ និង (ការកែប្រែ) បច្ចេកវិទ្យាអាចកំណត់ភារកិច្ចឡោះងវិញតាមរបៀបដែលមិនអាចយល់បាន (កំណត់ឡើងវិញ) ពីមុន។

ការសិក្សាក្រៅថ្នាក់រៀនសិស្សទទួលបានចំណេះដឹងនៅផ្ទះដោយមានជំនួយពីប្រភពផ្សេងៗ និងធ្វើឱ្យចំណេះដឹងកាន់តែស៊ីជម្រៅជាមួយគ្រូនៅក្នុងថ្នាក់។ បច្ចេកវិទ្យាអាចប្រើដើម្បីជួយឱ្យមានកិច្ចសហការដូចជា ការបង្កើតខ្សែអាត់វីដេអូ ដើម្បីធ្វើការរួមគ្នាជាមួយសាលារៀនដទៃទៀត។ ការនិទានរឿងឌីជីថលជួយបង្កើនលទ្ធភាពប្រាប់រឿងរ៉ាវដ៏មានឥទ្ធិពលដោយមានជំនួយពីអត្ថបទ និងសំឡេងផងដែរ។ ធនធានអប់រំបើកចំហ គឺជាសម្ភារៈបង្រៀន និងរៀនដែលមនុស្សគ្រប់គ្នាអាចចូលប្រើប្រាស់បានដោយសេរី។

អាជ្ញាបណ្ណផ្តល់ព័ត៌មានអំពីរបៀបដែលសម្ភារៈអាចត្រូវបានប្រើប្រាស់ឡើងវិញ កែសម្រួល ឬ ចែកចាយ។ ក្រៅពីមានព័ត៌មាននិងចំណេះដឹងអំពីប្រព័ន្ធផ្សព្វផ្សាយ គ្រូនៅក្នុងថ្នាក់រៀនតាមបែបឌីជីថលតែងតែត្រៀមសម្រាប់ពេលវេលាដែលឧបករណ៍មិនដំណើរការ ឬ គុណភាពនៃផ្នែករឹងខុសៗគ្នា។ ពួកគេត្រូវពិចារណាលើប្លង់រូបវន្តខុសៗគ្នានៃបរិយាកាសសិក្សាផ្សេងពីថ្នាក់រៀនដែលមិនមែនបែបឌីជីថល។

ឯកសារយោង

About CC Licenses. (n.d.). Retrieved from: https://creativecommons.org/about/cclicenses/ [2021, Feb. 20].

Brägger, G. (n.d.). *Mit dem SAMR-Modell zu einer Digitalen Aufgabenkultur*. Retrieved from: https://www.iqesonline.net/bildung-digital/digitale-schulentwicklung/modelle-zur-digitalisierung-von-schule-und-unterricht/das-samr-model/ [2021, Apr. 09].

Collaborative Learning in Primary Schools. (n.d.). Retrieved from: https://resourced.prometheanworld.com/collaborative-learning-primary-schools/ [2021, Apr. 09].

Commonwealth of Learning. (2016). *Provincial OER Policy Development, Sri Lanka: Consultant's report.* Retrieved from: http://oasis.col.org/bitstream/handle/11599/2386/2016_Provincial-OER-Policy-Development-Sri%20Lanka-Consultant-Report.pdf?sequence=1&isAllowed=y [2021, Apr. 09]. This publication is available in Open Access under the Creative Commons Attribution 4.0 (CC BY 4.0) license (https://creativecommons.org/licenses/by/4.0/).

EACEA Education, Audiovisual and Culture Executive Agency. (2019). *Digital Education at School in Europe*. Retrieved from: https://eacea.ec.europa.eu/national-policies/eurydice/sites/eurydice/files/en_digital_education_n.pdf [2021, Apr. 09].

Hamilton, E.R., Rosenberg, J.M., & Akcaoglu, M. (2016). The Substitution Augmentation Modification Redefinition (SAMR) Model: A Critical Review and Suggestions for its Use. *TechTrends*, 60, 433-441.

Hang, Z. (2019). *The Application of Flipping Classroom Teaching Model in the Teaching of Western Economics*. UK: Francis Academic Press.

Huang, Y. (2019). *The Function and Method of Flipping Classroom in English Teaching*. UK: Francis Academic Press.

Iglesias Rodríguez, A., García Riaza, B., & Cruz Sánchez Gómez, M. (2017). Collaborative Learning and Mobile Devices: An Educational Experience in Primary Education. *Computers in Human Behavior*, 72, 664-677.

Karunanayaka, S. (2006). Computer Assisted Learning: A Challenge for Teachers and Learners. *Journal of the National Science Foundation of Sri Lanka*, 34(2), 107-108.

Koper, R. (2014). Conditions for Effective Smart Learning Environments. *Smart Learning Environments*, *1*(5).

Li, J., Zhang, X., Hu, Z. (2018) The Design and Application of Flip Classroom Teaching Based on Computer Technology. *International Journal of Emerging Technologies in Learning*, 13(10), 95-106

Morrel, E., Duenas, R., Garcia, V. & Lopez, J. (2013). *Critical Media Pedagogy: Teaching for Achievement in City Schools*. Columbia University.

Robin, B.R. (2008). Digital Storytelling: A Powerful Technology Tool for the 21st Century Classroom. *Theory into Practice*, 47, 220-228.

Smeda, N., Dakich, E., & Sharda, N. (2014). The Effectiveness of Digital Storytelling in the Classrooms: A Comprehensive Study. *Smart Learning Environments*. 1(6). This publication is available in Open Access under the Creative Commons Attribution 4.0 (CC BY 4.0) license (https://creativecommons.org/licenses/by/4.0/).

Townsend, D. (n.d.). *Das SAMR Modell*. Retrieved from: http://sgo2016.pbworks.com/w/page/116225493/Das%20SAMR%20Modell [2021, Feb. 17]. This publication is available in Open Access under the Creative Commons Attribution 4.0 (CC BY 4.0) license (https://creativecommons.org/licenses/by/4.0/).

UNESCO. (2014). *ICT in Primary Education. Analytic Survey. Volume 2. Policy, Practices, and Recommendations*. Retrieved from: https://iite.unesco.org/pics/publications/en/files/3214735.pdf [2021, Apr. 09]. This publication is available in Open Access under the Creative Commons Attribution-Share Alike 3.0 (CC BY-SA 3.0) license (https://creativecommons.org/licenses/by-sa/3.0/).

Zickwolf, K. & Kauffeld, S. (2019). Inverted Classroom. In: S. Kauffeld, J. Othmer, eds. *Handbuch Innovative Lehre* (pp. 45-51). Wiesbaden: Springer Fachmedien.

Zimmermann, C. (2018). *Guideline for the Creation of Open Educational Resources: Information and Practical Exercises for Lectures in Higher Education*. Retrieved from: https://www.openeducation.at/fileadmin/user_upload/p_oea/OEA-Guideline_online_final_english.pdf [2021, Apr. 09]. This publication is available in Open Access under the Creative Commons Attribution 4.0 (CC BY 4.0) license (https://creativecommons.org/licenses/by/4.0/).

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

លំហាត់អនុវត្ត

ក. ទាញ និងទម្លាក់ការពន្យល់ខាងក្រោមទៅក្នុងប្រភេទដែលសមស្របនៃគំរូ SAMR

បច្ចេកវិទ្យាជួយឱ្យបង្កើតភារកិច្ចថ្មីដែលមិនអាចយល់បានពីមុន៖ បច្ចេកវិទ្យាជាឧបករណ៍ជំនួសដោយផ្ទាល់ជាមួយនឹងការកែលម្អមុខងារ។ បច្ចេកវិទ្យាជួយឱ្យរៀបចំឡើងវិញនូវមុខងារសំខាន់ៗ។ បច្ចេកវិទ្យាជើរតួជំនួសឧបករណ៍ដោយផ្ទាល់ដោយគ្មានការផ្លាស់ប្តូរមុខងារ។

ខ. ឆ្លើយសំណួរពហុជ្រើសរើសខាងក្រោម៖ (អាចមានចម្លើយត្រឹមត្រូវលើសពីមួយ)

១. តើឧទាហរណ៍នៃប្រភេទការជំនួសរបស់គំរូ SAMR គឺជាអ្វី?

ក) ការប្រើប្រាស់កុំព្យូទ័រជាមួយសូហ្វវែរសរសេរជំនួសអត្ថបទសរសេរដោយដៃ

ខ) រក្សាទុកអត្ថបទដែលសរសេរនៅលើក្តារឆ្លាតវៃ ហើយបញ្ជូនទៅឱ្យសិស្ស

គ) សរសេរនៅលើក្តារឆ្លាតវៃជំនួសឱ្យក្តារខៀន។

២. តើឧទាហរណ៍នៃប្រភេទការដាក់បញ្ចូលគ្នារបស់គំរូ SAMR គឺជាអ្វី?

ក) ការប្រើប្រាស់កុំព្យូទ័រជាមួយសូហ្វវែរសរសេរជំនួសអត្ថបទសរសេរដោយដៃ

ខ) ប្រើកម្មវិធីពិនិត្យអក្ខរាវិរុទ្ធក្នុងកម្មវិធីសរសេរ

គ) រក្សាទុកអត្ថបទដែលសរសេរនៅលើក្តារឆ្លាតវៃ ហើយផ្ញើទៅឱ្យសិស្ស។

៣. តើឧទាហរណ៍នៃប្រភេទការដាក់បញ្ចូលគ្នារបស់គំរូ SAMR គឺជាអ្វី?

ក) សហការតាមរយៈឧបករណ៍ផ្អែកលើអ៊ីនធឺណែត

ខ) សរសេរនៅលើក្តារឆ្លាតវៃជំនួសឱ្យក្តារខៀន

គ) ការប្រើប្រាស់កម្មវិធីពិនិត្យអក្ខរាវិរុទ្ធនៅក្នុងកម្មវិធីសរសេរ។

៤. តើឧទាហរណ៍នៃប្រភេទការដាក់បញ្ចូលគ្នារបស់គំរូ SAMR គឺជាអ្វី?

ក) ការប្រើប្រាស់កុំព្យូទ័រជាមួយសូហ្វវែរសរសេរជំនួសអត្ថបទសរសេរដោយដៃ

ខ) សហការតាមរយៈឧបករណ៍ផ្អែកលើអ៊ីនធឺណែត

គ) បង្កើត និងកែសម្រួលវីដេអូនីមួយៗ។

គ. ទាញ និងទម្លាក់លក្ខណៈខាងក្រោមទៅក្នុងប្រភេទសមស្របនៃតារាងខាងក្រោម៖

សិក្សាមាតិកាជាមូលដ្ឋានមុនចូលរៀន និងធ្វើឱ្យស៊ីជម្រៅចំណេះដឹងនៅក្នុងថ្នាក់ - រុករក - ដោះស្រាយបញ្ហា ការពង្រីកគំនិត និងការអនុវត្ត - ការបញ្ចូលគ្នានូវវិធីសាស្ត្រច្រើន - ការណែនាំសិក្សា និងសម្របសម្រួល - សម្ភារៈពហុព័ត៌មានអ៊ិនធឺណែត សៀវភៅសិក្សា ពហុតំណ និងពហុមធ្យោបាយ

ទម្រង់បង្រៀនក្នុងថ្នាក់រៀននៅក្នុងការបង្រៀនក្រៅថ្នាក់	
គ្រូ	គ្រូណែនាំការសិក្សា និងសម្របសម្រួល
និស្សិត	
ប្រព័ន្ធផ្សព្វផ្សាយសម្រាប់ការបង្រៀន	

វិធីសាស្ត្របង្រៀន	
ទម្រង់បង្រៀន	
មាតិកាថ្នាក់រៀន	
វិធីសាស្ត្រវាយតម្លៃ	

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ឃ. ផ្តល់ការពន្យល់សមស្របនឹងអាជ្ញាបណ្ណ៖

	CC BY	គុណសម្បត្តិ៖ អាជ្ញាបណ្ណនេះអនុញ្ញាតឱ្យអ្នកប្រើប្រាស់ ចែកចាយ លាយបញ្ចូលគ្នា និងបង្កើតសម្ភារៈនៅលើឧបករណ៍ផ្ទុក ឬ ទ្រង់ទ្រាយណាមួយ ដរាបណាការបញ្ជាក់ត្រូវបានផ្តល់ទៅឱ្យអ្នកបង្កើត។ អាជ្ញាបណ្ណអនុញ្ញាតឱ្យប្រើប្រាស់ពាណិជ្ជកម្ម។
	CC BY-SA	គុណលក្ខណៈShareAlike៖ អាជ្ញាបណ្ណនេះអនុញ្ញាតឱ្យអ្នកប្រើប្រាស់ចែកចាយ បង្កើតឡើងវិញ និងបង្កើតលើសម្ភារៈជាមធ្យោបាយ ឬ ទ្រង់ទ្រាយណាមួយ ដរាបណាការបញ្ជាក់ត្រូវបានផ្តល់ទៅឱ្យអ្នកបង្កើត។ អាជ្ញាបណ្ណអនុញ្ញាតឱ្យប្រើប្រាស់ពាណិជ្ជកម្ម។ ប្រសិនបើអ្នកបញ្ចូល សម្របសម្រួល ឬ កសាងសម្ភារៈ អ្នកត្រូវផ្តល់អាជ្ញាបណ្ណសម្ភារៈដែលបានកែប្រែក្រោមលក្ខខណ្ឌដូចគ្នា។
	CC BY-NC	គុណលក្ខណៈមិនមែនពាណិជ្ជកម្ម៖ អាជ្ញាបណ្ណនេះអនុញ្ញាតឱ្យអ្នកប្រើប្រាស់ចែកចាយ បញ្ចូល និងបង្កើតលើសម្ភារៈជាទ្រង់ទ្រាយមធ្យម ឬ ទ្រង់ទ្រាយណាមួយ សម្រាប់គោលបំណងមិនមែនពាណិជ្ជកម្មតែប៉ុណ្ណោះ ដរាបណាការបញ្ជាក់ត្រូវបានផ្តល់ជូនអ្នកបង្កើត។
	CC BY-NC-SA	គុណលក្ខណៈមិនមែនពាណិជ្ជកម្មShareAlike៖ អាជ្ញាបណ្ណនេះអនុញ្ញាតឱ្យអ្នកប្រើប្រាស់ ចែកចាយ តម្រូវការ និងបង្កើតសម្ភារៈតាមទម្រង់មធ្យម ឬ ទ្រង់ទ្រាយណាមួយសម្រាប់គោលបំណងមិនមែនពាណិជ្ជកម្មតែប៉ុណ្ណោះ ដរាបណាការបញ្ជាក់ត្រូវបានផ្តល់ជូនអ្នកបង្កើត។ ប្រសិនបើជាអ្នកបញ្ចូល សម្របសម្រួល ឬ កសាងសម្ភារៈ អ្នកត្រូវផ្តល់អាជ្ញាបណ្ណសម្ភារៈដែលបានកែប្រែក្រោមលក្ខខណ្ឌដូចគ្នា។

	CC BY-ND	គុណលក្ខណៈ៖ អាជ្ញាបណ្ណនេះអនុញ្ញាតឱ្យអ្នកប្រើប្រាស់អាចថតចម្លង និងចែកចាយឯកសារ ជាទ្រង់ទ្រាយមធ្យម ឬ ជាទម្រង់ណាដែលមិនមានសុពលភាព ហើយមានតែការបញ្ជាក់អោយអ្នកបង្កើតប៉ុណ្ណោះ។ អាជ្ញាបណ្ណអនុញ្ញាតឱ្យប្រើប្រាស់ពាណិជ្ជកម្ម។
	CC BY-NC-ND	គុណលក្ខណៈមិនមែនពាណិជ្ជកម្ម៖ អាជ្ញាបណ្ណនេះអនុញ្ញាតឱ្យអ្នកប្រើប្រាស់ថតចម្លង និងចែកចាយសម្ភារៈជាទ្រង់ទ្រាយមធ្យម ឬ ទ្រង់ទ្រាយណាមួយក្នុងទម្រង់មិនមែនជាគោលបំណងសម្រាប់តែមិនមែនពាណិជ្ជកម្ម តែប៉ុណ្ណោះហើយមានតែការបញ្ជាក់ប៉ុណ្ណោះដែលត្រូវបាន ផ្តល់ដល់អ្នកបង្កើត។
	CC0	ជាសកល៖ ជាឧបករណ៍សាធារណៈដែលអនុញ្ញាតឱ្យអ្នកច្នៃប្រឌិតលះបង់សិទ្ធិអ្នកនិពន្ធ និងដាក់ស្នាដៃរបស់ខ្លួនទៅក្នុងដែនសាធារណៈទូទាំងពិភពលោក។ ស៊ីស៊ី ០ អនុញ្ញាតឱ្យអ្នកប្រើប្រាស់ចែកចាយ បញ្ចូលឡើងវិញ និងបង្កើតសម្ភារៈលើឧបករណ៍ផ្ទុក ឬ ទ្រង់ទ្រាយណាមួយដោយគ្មានលក្ខខណ្ឌ។

លំហាត់អនុវត្ត និងដំណោះស្រាយ

ក. ទាញ និងទម្លាក់ការពន្យល់ខាងក្រោមទៅក្នុងប្រភេទដែលសមស្របនៃគំរូ SAMR

បច្ចេកវិទ្យាជួយឱ្យបង្កើតភារកិច្ចថ្មីដែលមិនអាចយល់បានពីមុន(ការកំណត់ឡើងវិញ) – បច្ចេកវិទ្យាជាឧបករណ៍ជំនួសដោយផ្ទាល់ជាមួយនឹងការកែលម្អមុខងារ (ការដាក់ជាកញ្ចប់) - បច្ចេកវិទ្យាអនុញ្ញាតឱ្យរៀបចំឡើងវិញនូវមុខងារសំខាន់ៗ (ការកែប្រែ) - បច្ចេកវិទ្យាដើរតួជំនួសឧបករណ៍ដោយផ្ទាល់គ្មានការផ្លាស់ប្តូរមុខងារ (ការជំនួស)។



t.me/moeysnews
ela.moeys.gov.kh
youtube.com/moeyscambodia

ខ. ឆ្លើយសំណួរពហុជ្រើសរើសដូចខាងក្រោម៖) អាចមានចម្លើយត្រឹមត្រូវលើសពីមួយ)

១. តើឧទាហរណ៍នៃប្រភេទការជំនួសរបស់គំរូ SAMR គឺជាអ្វី ?

ក) ការប្រើប្រាស់កុំព្យូទ័រជាមួយសូហ្វវែរសរសេរជំនួសអត្ថបទសរសេរដោយដៃ

ខ) រក្សាទុកអត្ថបទដែលសរសេរនៅលើក្តារឆ្លាតវៃ ហើយបញ្ជូនទៅឱ្យសិស្ស

គ) សរសេរនៅលើក្តារឆ្លាតវៃជំនួសឱ្យក្តារខៀន។

២. តើឧទាហរណ៍នៃប្រភេទការដាក់បញ្ចូលគ្នារបស់គំរូ SAMR គឺជាអ្វី ?

ក) ការប្រើប្រាស់កុំព្យូទ័រជាមួយសូហ្វវែរសរសេរជំនួសអត្ថបទសរសេរដោយដៃ

ខ) ប្រើកម្មវិធីពិនិត្យអក្ខរាវិរុទ្ធក្នុងកម្មវិធីសរសេរ

គ) រក្សាទុកអត្ថបទដែលសរសេរនៅលើក្តារឆ្លាតវៃ ហើយផ្ញើទៅឱ្យសិស្ស

៣. តើឧទាហរណ៍នៃប្រភេទការដាក់បញ្ចូលគ្នារបស់គំរូ SAMR គឺជាអ្វី ?

ក) សហការតាមរយៈឧបករណ៍ផ្តែកលើអ៊ីនធឺណែត

ខ) សរសេរនៅលើក្តារឆ្លាតវៃជំនួសឱ្យក្តារខៀន

គ) ការប្រើប្រាស់កម្មវិធីពិនិត្យអក្ខរាវិរុទ្ធនៅក្នុងកម្មវិធីសរសេរ។

៤. តើឧទាហរណ៍នៃប្រភេទការដាក់បញ្ចូលគ្នារបស់គំរូ SAMR គឺជាអ្វី ?

ក) ការប្រើប្រាស់កុំព្យូទ័រជាមួយសូហ្វវែរសរសេរជំនួសអត្ថបទសរសេរដោយដៃ

ខ) សហការតាមរយៈឧបករណ៍ផ្តែលលើអ៊ីនធឺណែត

គ.(បង្កើត និងកែសម្រួលវីដេអូនីមួយៗ)។

គ. ទាញ និងទម្លាក់លក្ខណៈដូចខាងក្រោមទៅក្នុងប្រភេទសមស្របនៃតារាងខាងក្រោម៖

សិក្សាមាតិកាជាមូលដ្ឋានមុនចូលរៀន និងធ្វើឱ្យស៊ីជម្រៅចំណេះដឹងនៅក្នុងថ្នាក់ - រុករក - ដោះស្រាយបញ្ហា ការពង្រីកគំនិត និងការអនុវត្ត - ការបញ្ចូលគ្នានូវវិធីសាស្ត្រច្រើន - ការណែនាំសិក្សា និងសម្របសម្រួល - សម្ភារៈពហុព័ត៌មានអ៊ិនធឺណែត សៀវភៅសិក្សា ពហុតំណ និងពហុមធ្យោបាយ

ទម្រង់បង្រៀនក្នុងថ្នាក់រៀននៅក្នុងការបង្រៀនក្រៅថ្នាក់	
គ្រូ	គ្រូណែនាំការសិក្សា និងសម្របសម្រួល
និស្សិត	អ្នករុករក
ប្រព័ន្ធផ្សព្វផ្សាយសម្រាប់ការបង្រៀន	ផ្លាស់ប្តូរសម្ភារៈពហុព័ត៌មាន អ៊ិនធឺណែត សៀវភៅសិក្សា ...
វិធីសាស្ត្របង្រៀន	ការរួមបញ្ចូលគ្នានៃវិធីសាស្ត្រច្រើន
ទម្រង់បង្រៀន	រៀនមាតិកាមូលដ្ឋានមុនពេលចូលរៀន និងធ្វើឱ្យចំណេះដឹងនោះនៅក្នុងថ្នាក់កាន់តែស៊ីជម្រៅ
មាតិកាថ្នាក់រៀន	ការដោះស្រាយបញ្ហា ការពង្រីកគំនិត និងការអនុវត្ត
វិធីសាស្ត្រវាយតម្លៃ	ពហុតំណ និងពហុមធ្យោបាយ

ឃ. ផ្តល់ការពន្យល់សមស្របនឹងអាជ្ញាបណ្ណ៖

	CC BY	គុណសម្បត្តិ៖ អាជ្ញាបណ្ណនេះអនុញ្ញាតឱ្យអ្នកប្រើប្រាស់ ចែកចាយ លាយបញ្ចូលគ្នា និងបង្កើតសម្ភារៈនៅលើឧបករណ៍ផ្ទុក ឬ ទ្រង់ទ្រាយណាមួយ ដរាបណាការបញ្ជាក់ត្រូវបានផ្តល់ទៅឱ្យអ្នកបង្កើត។ អាជ្ញាបណ្ណអនុញ្ញាតឱ្យប្រើប្រាស់ពាណិជ្ជកម្ម។
	CC BY-SA	គុណលក្ខណៈ ShareAlike៖ អាជ្ញាបណ្ណនេះអនុញ្ញាតឱ្យអ្នកប្រើបប្រាស់ ចែកចាយ បង្កើតឡើងវិញ និងបង្កើតលើសម្ភារៈដាមធ្យោបាយ ឬ ទ្រង់ទ្រាយណាមួយ ដរាបណាការបញ្ជាក់ត្រូវបានផ្តល់ទៅឱ្យអ្នកបង្កើត។ អាជ្ញាបណ្ណអនុញ្ញាតឱ្យប្រើប្រាស់ពាណិជ្ជកម្ម។ ប្រសិនបើអ្នកបញ្ចូលសម្របសម្រួល ឬ កសាងសម្ភារៈ អ្នកត្រូវផ្តល់អាជ្ញាបណ្ណ សម្ភារៈដែលបានកែប្រែក្រោមលក្ខខណ្ឌដូចគ្នា។

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

	CC BY-NC	គុណលក្ខណៈមិនមែនពាណិជ្ជកម្ម៖ អាជ្ញាបណ្ណនេះអនុញ្ញាតឱ្យអ្នកប្រើប្រាស់ ចែកចាយ បញ្ចូល និងបង្កើតលើសម្ភារៈជាទ្រង់ទ្រាយមធ្យម ឬទ្រង់ទ្រាយណាមួយសម្រាប់គោលបំណងមិនមែនពាណិជ្ជកម្មតែប៉ុណ្ណោះ ដរាបណាការបញ្ជាក់ត្រូវបានផ្តល់ជូនអ្នកបង្កើត។
	CC BY-NC-SA	គុណលក្ខណៈមិនមែនពាណិជ្ជកម្មShareAlike៖ អាជ្ញាបណ្ណនេះអនុញ្ញាតឱ្យអ្នកប្រើប្រាស់ ចែកចាយ តម្រូវ និងបង្កើតសម្ភារៈតាមទម្រង់មធ្យម ឬទ្រង់ទ្រាយណាមួយសម្រាប់គោលបំណងមិនមែនពាណិជ្ជកម្មតែប៉ុណ្ណោះ ដរាបណាការបញ្ជាក់ត្រូវបានផ្តល់ជូនអ្នកបង្កើត។ ប្រសិនបើអ្នកបញ្ចូល សម្របសម្រួល ឬ កសាងសម្ភារៈ អ្នកត្រូវផ្តល់អាជ្ញាបណ្ណ សម្ភារៈដែលបានកែប្រែក្រោមលក្ខខណ្ឌដូចគ្នា។
	CC BY-ND	គុណលក្ខណៈ៖ អាជ្ញាបណ្ណនេះអនុញ្ញាតឱ្យអ្នកប្រើប្រាស់អាចថតចម្លង និងចែកចាយឯកសារជាទ្រង់ ទ្រាយមធ្យម ឬ ជាទម្រង់ណាដែលមិនមានសុពលភាព ហើយមានតែការបញ្ជាក់ឱ្យអ្នកបង្កើតប៉ុណ្ណោះ។ អាជ្ញាបណ្ណអនុញ្ញាតឱ្យប្រើប្រាស់ពាណិជ្ជកម្ម។
	CC BY-NC-ND	គុណលក្ខណៈមិនមែនពាណិជ្ជកម្ម៖ អាជ្ញាបណ្ណនេះអនុញ្ញាតឱ្យអ្នកប្រើប្រាស់ថតចម្លង និងចែកចាយ សម្ភារៈជាទ្រង់ទ្រាយមធ្យម ឬទ្រង់ទ្រាយណាមួយ ក្នុងទម្រង់មិនមែនជាគោលបំណងសម្រាប់តែមិនមែនពាណិជ្ជកម្មតែប៉ុណ្ណោះ ហើយមានតែការបញ្ជាក់ប៉ុណ្ណោះដែលត្រូវបានផ្តល់ដល់អ្នកបង្កើត។
	CC0	ជាសកល៖ ជាឧបករណ៍សាធារណៈដែលអនុញ្ញាតឱ្យអ្នកច្នៃប្រឌិតលះបង់សិទ្ធិអ្នកនិពន្ធ និងដាក់ស្នាដៃរបស់ខ្លួនទៅក្នុងដែនសាធារណៈទូទាំងពិភពលោក។ ស៊ីស៊ី ០ អនុញ្ញាតឱ្យអ្នកប្រើប្រាស់ចែកចាយ បញ្ចូលឡើងវិញ និងបង្កើតសម្ភារៈលើឧបករណ៍ផ្ទុក ឬ ទ្រង់ទ្រាយណាមួយដោយគ្មានលក្ខខណ្ឌ។

ជំហានទី២

ក. សូមអានករណីសិក្សាខាងក្រោម និងបំពេញតារាងខាងក្រោម៖

ករណីសិក្សាទី១

លោកគ្រូ ដាវ៉ា បង្រៀនសិស្សអំពីភូមិសាស្ត្រ និងទីកន្លែងផ្សេងៗគ្នានៅលើពិភពលោកដោយបង្ហាញនៅលើផែនទីហ្គូហ្គលដោយមានជំនួយពីក្តារឆ្លាតវៃក្នុងថ្នាក់រៀន។ សិស្សត្រូវបានរៀបចំជាក្រុមតូចៗ និងចាត់ឱ្យមានកន្លែងផ្សេងៗគ្នា ដើម្បីបង្ហាញដល់សិស្សផ្សេងទៀត។ សិស្សរៀបចំបទបង្ហាញតាមអ៊ិនធឺណែតដោយមានជំនួយពីប្រព័ន្ធគ្រប់គ្រងថ្នាក់រៀន។ បន្ទាប់មក ពួកគេធ្វើបទបង្ហាញនៅលើក្តារឆ្លាតវៃ។ ពួកគេធ្វើអន្តរកម្មជាមួយផែនទីហ្គូហ្គល ដោយប៉ះលើទីតាំងតាំងនៅដោយផ្ទាល់នៅលើក្តារឆ្លាតវៃ រួចបង្ហាញដល់សិស្សផ្សេងទៀត។

ករណីសិក្សាទី២

លោកគ្រូ សុធា បានរៀបចំបទបង្ហាញ PowerPoint ដើម្បីបង្រៀនសិស្សអំពីភូមិសាស្ត្រ និងទីកន្លែងផ្សេងៗនៅលើពិភពលោក។ បទបង្ហាញនេះរួមមានផែនទី អត្ថបទ និងរូបភាពកន្លែងផ្សេងៗគ្នា។ ដើម្បីធ្វើបទបង្ហាញនេះ គ្រូប្រើកុំព្យូទ័រថ្នាក់រៀន និងម៉ាស៊ីនបញ្ចាំង។ បន្ទាប់មកសិស្សចូលបន្ទប់កុំព្យូទ័ររបស់សាលារៀនដែលពួកគេប្រើសៀវភៅអេឡិចត្រូនិក ដើម្បីស្រាវជ្រាវរកកន្លែងជាក់លាក់តាមអ៊ិនធឺណែត។

ករណីសិក្សាទី៣

អ្នកគ្រូ ធីតា ប្រើ Google Earth ដើម្បីបង្ហាញសិស្សនៅកន្លែងផ្សេងៗគ្នានៅលើពិភពលោក។ គ្រូបានបង្កើតរឿងនិទានឌីជីថលដោយមានជំនួយពី Google Earth ដែលនាំសិស្សទៅកន្លែងជាក់លាក់។ ដំណើរកម្សាន្តបានប្រើការនិទានកថារបស់គ្រូ រូបភាព និងវីដេអូ។ បន្ទាប់មក អ្នកគ្រូអនុញ្ញាតឱ្យសិស្សបង្កើតខិត្តបណ្ណធ្វើដំណើរឌីជីថលផ្ទាល់ខ្លួនអំពីកន្លែងដែលបានកំណត់។ ខិត្តបណ្ណធ្វើដំណើរឌីជីថលទាំងនេះរួមមានរូបភាព និងអត្ថបទ និងវីដេអូដែលបង្កើតដោយសិស្ស និងទ្រង់ទ្រាយពហុមេឌាផ្សេងៗទៀត។

ករណីសិក្សាទី៤

អ្នកគ្រូ សុភាព បង្រៀនសិស្សអំពីភូមិសាស្ត្រ និងកន្លែងផ្សេងៗគ្នានៅលើពិភពលោកដោយបង្ហាញផែនទីរូបវន្ត។ គាត់ព្យួរផែនទីនៅខាងមុខក្នុងថ្នាក់រៀនដែលសិស្សគ្រប់គ្នាអាចមើលឃើញ។ លើសពីនេះ គាត់បានរៀបចំផ្ទាំងរូបភាពនៅលើកន្លែងផ្សេងៗគ្នាដែលមានអត្ថបទ និងរូបភាពដែលកាត់ចេញពីទស្សនាវដ្តី ដើម្បីបង្ហាញពីទីកន្លែងទាំងនេះ។ បន្ទាប់មក និស្សិតស្រាវជ្រាវរកកន្លែងជាក់លាក់មួយដោយមានជំនួយពីសៀវភៅសិក្សា និងសម្ភារៈបន្ថែមរបស់គ្រូ។

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ករណីសិក្សាទី៥

លោកគ្រូ ដារ៉ា បង្រៀនសិស្សអំពីភូមិសាស្ត្រ និងទីកន្លែងផ្សេងៗគ្នានៅលើពិភពលោក ដោយបង្ហាញនៅលើផែនទីហ្គូហ្គលដោយមានជំនួយពីកុំព្យូទ័រ និងម៉ាស៊ីនបញ្ចាំង។ លោកគ្រូពង្រីក និងគូសផែនទី ដើម្បីបង្ហាញសិស្សអំពីទីតាំងនៃកន្លែងនីមួយៗ។ ដូចគ្រូបង្រៀន សុធា លោកគ្រូ ដារ៉ា ប្រើបទបង្ហាញ PowerPoint អំពីកន្លែងផ្សេងៗគ្នានៅលើពិភពលោក។ ទោះជាយ៉ាងណា បទបង្ហាញរបស់គាត់មិនប្រើអត្ថបទ និងរូបភាពទេ។ នៅក្នុងបទបង្ហាញ គ្រូបានបញ្ចូលវីដេអូអំពីទីកន្លែង និងការថតសំឡេងអំពីមនុស្សដែលរស់នៅទីនោះ និងរៀបរាប់ពីស្រុកកំណើត។ គ្រូបានបញ្ចូលតំណខ្ពស់ដែលនាំទៅដល់គេហទំព័ររបស់ការិយាល័យទេសចរណ៍នៃកន្លែងដែលខ្លួនកំពុងនិយាយ។ បន្ទាប់ពីបង្រៀន គ្រូបានផ្ញើបទបង្ហាញទៅសិស្សរបស់គាត់ដែលអវត្តមាននៅថ្ងៃនោះ។ បន្ទាប់មកសិស្សចូលបន្ទប់កុំព្យូទ័ររបស់សាលារៀន ដើម្បីស្រាវជ្រាវរកកន្លែងជាក់លាក់តាមអ៊ីនធឺណែត។

កម្រិតនៃបច្ចេកវិទ្យា	ករណីសិក្សា
ទម្រង់បែបបទកែលម្អដោយមិនផ្អែកលើឌីជីថល	
ការជំនួស	
ការដាក់ជាកញ្ចប់	
ការកែប្រែ	
ការកំណត់ឡើងវិញ	

ខ. សូមអានករណីសិក្សា និងបំពេញតារាងខាងក្រោម៖

ករណីសិក្សាទី១

អ្នកគ្រូ អេ បានបង្កើតសម្ភារៈសម្រាប់សិស្សសិក្សាដោយខ្លួនឯង៖ វីដេអូ និងភារកិច្ចដែលមានមូលដ្ឋានលើវីដេអូនេះគឺ សិស្សមើលវីដេអូ រួចធ្វើកិច្ចការដែលទាក់ទងនឹងខ្លួនឯងនៅផ្ទះ។ សិស្សត្រូវបានត្រួតពិនិត្យដោយឪពុកម្តាយរបស់ពួកគេដែលបានទទួលការណែនាំពីគ្រូជាមុន។ សិស្សមានជម្រើសក្នុងការផ្ញើអ៊ីមែលទៅគ្រូរបស់ពួកគេ ក្នុងករណីដែលឪពុក ម្តាយមិនអាចជួយពួកគេលើកិច្ចការណាមួយ។ នៅក្នុងមេរៀនបន្ទាប់របស់ពួកគេនៅសាលារៀន គ្រូពិភាក្សាជាមួយសិស្សនូវអ្វីដែលសិស្សបានរៀនដោយមានជំនួយពីវីដេអូ។ ពួកគេប្រៀបធៀប

ការយល់ដឹងដោយនិយាយអំពីសំណួរដែលមិនទាន់ដោះស្រាយ និងលទ្ធផលនៃការសិក្សាដោយខ្លួនឯង។ គ្រូបំពេញគម្លាតចំណេះដឹងដែលមានសក្តានុពលនៅចុងបញ្ចប់ សិស្សបំពេញការកិច្ចជាក់ស្តែងមួយទៀតដោយមានការត្រួតពិនិត្យរបស់គ្រូ និងផ្តល់យោបល់ជាលក្ខណៈបុគ្គល តាមរយៈអ៊ីមែល ការប្រជុំតាមអ៊ិនធឺណែត ប្រព័ន្ធគ្រប់គ្រងការសិក្សា ឬ ការប្រជុំជាបុគ្គល។

ករណីសិក្សាទី២

គ្រូ ប៊ី អនុញ្ញាតឱ្យសិស្សបង្កើតរឿងនិទានឌីជីថលផ្ទាល់ខ្លួនជាមួយអត្ថបទ រូបភាព សំឡេង និងថតសំឡេងរបស់ពួកគេ ជាផ្នែកមួយនៃកម្មវិធីសិក្សាភាសា។ សិស្សកម្រិតបឋមសិក្សា ថ្នាក់ទី១ ដល់ទី៣ បង្កើតរឿងនិទានឌីជីថលផ្ទាល់ខ្លួននៅក្នុងថ្នាក់ភាសារបស់ពួកគេ (ឧទាហរណ៍៖ ភាសាអង់គ្លេស និងភាសាកំណើត - ស៊ីនហាឡា និងតាមិល)។ សិស្សបង្កើតរឿងនិទានឌីជីថលដោយរំឭកពីបទពិសោធរបស់ពួកគេនៅក្នុងដំណើរសិក្សាដូចជាសួនសត្វ។ រឿងនិទានឌីជីថលទាំងនេះគឺទាក់ទងនឹងរូបថត ដែលថតដោយនិស្សិត និងការនិទានកថាដែលត្រូវបានកត់ត្រានៅពេលពួកគេរំឭកពីបទពិសោធរបស់ខ្លួន និងចែករំលែកការឆ្លុះបញ្ចាំងរបស់ពួកគេ។ តន្ត្រីត្រូវបានបញ្ចូលទៅក្នុងរឿងនិទានឌីជីថល ដើម្បីឆ្លុះបញ្ចាំងពីអារម្មណ៍នៃការរៀបរាប់ផ្ទាល់ខ្លួន។

ករណីសិក្សាទី៣

សម្រាប់ករណីសិក្សាទី ៣ សូមមើលវីដេអូខាងក្រោម៖

https://www.youtube.com/watch?v=9vn8QXF2Kfs

	ទម្រង់បែបបទនៃមេរៀនដែលត្រូវបានកែលម្អតាមបែបឌីជីថល
ករណីសិក្សាទី១	
ករណីសិក្សាទី២	
ករណីសិក្សាទី៣	

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

មើលរូបភាព CC នេះ និងស្លាករបស់វា។ ទាញនិងទម្លាក់សមាសធាតុរបស់ស្លាក ចូលទៅក្នុងប្រភេទសមស្រប នៅក្នុងតារាងខាងក្រោម៖ Stand With Malala@ICT Discovery – ITU Pictures – CC BY 2.0 – CC Search



Stand With Malala@ICT Discovery, ITU Pictures, CC BY 2.0, CC Search

ចំណងជើង	
អ្នកនិពន្ធ	
ប្រភព	
អាជ្ញាបណ្ណ	

ក. ស្តាប់គ្រូនិយាយអំពីការរៀបចំមេរៀនតាមអ៊ុនធឺណែត (ឯកសារជាសំឡេង ៥.៣.១)។ ចូរឆ្លើយសំណួរខាងក្រោម (អាចមានចម្លើយត្រឹមត្រូវលើសពីមួយ)៖

១. តើចំណុចអ្វីខ្លះដែលគ្រូលើកឡើងយកមកពិចារណានៅពេលរៀបចំមេរៀនតាមអ៊ុនធឺណែត?

ក) ខ្លឹមសារត្រូវមានភាពច្បាស់លាស់តាមដែលអាចធ្វើទៅបាន

ខ) ឯកសារមេឌាចាំបាច់ត្រូវត្រួតពិនិត្យ ប្រសិនបើសិស្សអាចបើកវានៅលើឧបករណ៍ផ្សេងៗ

គ) រាល់កិច្ចការត្រូវសរសេរជាលាយលក្ខណ៍អក្សរជាមុន

ឃ) គ្រូបង្រៀនត្រូវការសមត្ថភាពធ្វើការជាមួយបច្ចេកវិទ្យាផ្សេងៗគ្នា

ង) ទម្រង់សម្រាប់វាយតម្លៃសិស្សត្រូវរកឱ្យឃើញ។

ខ. សរសេរចម្លើយអត្ថបទខ្លីៗ (ប្រហែល ៥០០ពាក្យ ក្នុងមួយសំណួរ) ចំពោះសំណួរឆ្លុះបញ្ចាំងផ្ទាល់ខ្លួន ដូចខាងក្រោម៖

១. តើអ្នកអាចនិយាយអ្វីខ្លះពីគុណសម្បត្តិនៃការបង្រៀនជាមួយនឹងឧបករណ៍សន្និសីទដូចជា ZOOM (ឧទាហរណ៍៖ ការប្រាស្រ័យទាក់ទងគ្នា) ក្នុងការប្រៀបធៀបនឹងការបង្រៀនជាមួយប្រព័ន្ធគ្រប់គ្រងការសិក្សា (ឧទាហរណ៍៖ ការប្រាស្រ័យទាក់ទងអសមកាល)?

ឯកសារយោង

"How to Record a Lesson" by Teach for Life. Retrievedfrom: https://www.youtube.com/watch?v=9vn8QXF2Kfs [2021, Mar. 02]. This publication is available in Open Access under the Attribution 3.0 Unported (CC BY 3.0) license (https://creativecommons.org/licenses/by/3.0/legalcode).

Stand With Malala@ICT Discovery by ITU Pictures. Retrieved from: https://search.creativecommons.org/photos/a5beb203-6ead-44eb-8d19-347440be6390 [2021, Mar. 02]. This publication is available in Open Access under the Attribution 2.0 Generic (CC BY 2.0) license (https://creativecommons.org/licenses/by/2.0/).

UNESCO. (2014). *ICT in Primary Education. Analytic Survey. Volume 2. Policy, Practices, and Recommendations*. Retrieved from: https://iite.unesco.org/pics/publications/en/files/3214735.pdf [2021, Apr. 09]. This publication is available in Open Access under the Creative Commons Attribution-Share Alike 3.0 (CC BY-SA 3.0) license (https://creativecommons.org/licenses/by-sa/3.0/).

ដំហានទី ២៖ ដំណោះស្រាយ

ក. សូមអានករណីសិក្សា និងបំពេញតារាងខាងក្រោម៖

ករណីសិក្សាទី១

លោកគ្រូ ដាវ៉ា បង្រៀនសិស្សអំពីភូមិសាស្ត្រ និងទីកន្លែងផ្សេងៗគ្នានៅលើពិភពលោកដោយបង្ហាញនៅលើផែនទីហ្គូហ្គលដែលមានជំនួយពីក្តារឆ្លាតវៃក្នុងថ្នាក់រៀន។ សិស្សត្រូវបានរៀបចំជាក្រុមតូចៗ និងចាត់ឱ្យមានកន្លែងផ្សេងៗគ្នាដើម្បីបង្ហាញដល់សិស្សផ្សេងទៀត។ ពួកគេរៀបចំបទបង្ហាញតាមអ៊ិនធឺណែតដោយមានជំនួយពីប្រព័ន្ធគ្រប់គ្រងថ្នាក់រៀន។ បន្ទាប់មក ពួកគេធ្វើបទបង្ហាញនៅលើក្តារឆ្លាតវៃ រួចធ្វើអន្តរកម្មជាមួយផែនទីហ្គូហ្គលដោយប៉ះលើទីតាំងដែលខ្លួនតាំងនៅដោយផ្ទាល់នៅលើក្តារឆ្លាតវៃ រួចពួកគេបង្ហាញដល់សិស្សផ្សេងទៀត។

ករណីសិក្សាទី២

លោកគ្រូ សុធា បានរៀបចំបទបង្ហាញ PowerPoint ដើម្បីបង្រៀនសិស្សអំពីភូមិសាស្ត្រ និងទីកន្លែងផ្សេងៗនៅលើពិភពលោក។ បទបង្ហាញនេះរួមមានផែនទី អត្ថបទ និងរូបភាពនៃកន្លែងផ្សេងគ្នា។ ដើម្បីធ្វើបទបង្ហាញនេះ គ្រូប្រើកំព្យូទ័រថ្នាក់រៀន និងម៉ាស៊ីនបញ្ចាំង។ បន្ទាប់មក សិស្សចូលបន្ទប់កុំព្យូទ័ររបស់សាលារៀន និងប្រើសៀវភៅអេឡិចត្រូនិកដើម្បីស្រាវជ្រាវរកកន្លែងជាក់លាក់តាមអ៊ិនធឺណែត។

ករណីសិក្សាទី៣

អ្នកគ្រូ ធីតា ប្រើ Google Earth ដើម្បីបង្ហាញសិស្សអំពីទីកន្លែងផ្សេងៗគ្នានៅលើពិភពលោក។ អ្នកគ្រូបានបង្កើតរឿងនិទានឌីជីថលដោយមានជំនួយពី Google Earth ដែលនាំសិស្សទៅកន្លែងជាក់លាក់។ ដំណើរកម្រាន្តមានការនិទានរឿងនិទានកថារបស់គ្រូ រូបភាព និងវីដេអូ។ បន្ទាប់មក អ្នកគ្រូអនុញ្ញាតឱ្យសិស្សបង្កើតខិត្តបណ្ណ និងដំណើរការឌីជីថលផ្ទាល់ខ្លួនអំពីកន្លែងដែលបានកំណត់។ ខិត្តបណ្ណដំណើរការតាមឌីជីថលទាំងនេះរួមមានរូបភាព អត្ថបទ និងមានវីដេអូបង្កើតដោយសិស្ស និងទ្រង់ទ្រាយពហុមេឌាផ្សេងទៀត។

ករណីសិក្សាទី៤

អ្នកគ្រូ សុភាព បង្រៀនសិស្សអំពីភូមិសាស្ត្រ និងកន្លែងផ្សេងៗគ្នានៅលើពិភពលោកដោយបង្ហាញផែនទីរូបវន្ត។ គាត់ព្យួរផែនទីនៅខាងមុខថ្នាក់រៀនដែលសិស្សគ្រប់គ្នាអាចមើលឃើញ។ លើសពីនេះ គ្រូបានរៀបចំផ្ទាំងរូបភាពនៅលើកន្លែងផ្សេងៗគ្នាដែលមានអត្ថបទ និងរូបភាពដែលកាត់ចេញពីទស្សនាវដ្តី ដើម្បីបង្ហាញនូវអ្វីដែលកន្លែងទាំងនេះមើលទៅ។ បន្ទាប់មកនិស្សិតស្រាវជ្រាវរកកន្លែងជាក់លាក់មួយដោយមានជំនួយពីសៀវភៅសិក្សា និងសម្ភារៈបន្ថែមរបស់គ្រូ។

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ករណីសិក្សាទី៥

លោកគ្រូ ដាវ៉ា បង្រៀនសិស្សអំពីភូមិសាស្ត្រ និងទីកន្លែងផ្សេងៗគ្នានៅលើពិភពលោកដោយបង្ហាញនៅលើផែនទី ហ្គូហ្គលដែលមានជំនួយពីកុំព្យូទ័រ និងថ្នាក់បញ្ចាំង។ លោកគ្រូពង្រីក និងតូសផែនទី ដើម្បីបង្ហាញសិស្សអំពីទីតាំងនៃកន្លែងនីមួយៗ។ ដូចគ្រូបង្រៀន សុធា គាត់ប្រើបទបង្ហាញ PowerPoint អំពីកន្លែងផ្សេងៗគ្នានៅលើពិភពលោក។ ទោះជាយ៉ាងណា បទបង្ហាញរបស់គ្រូមិនត្រូវបានកំណត់ចំពោះអត្ថបទ និងរូបភាពទេ។ នៅក្នុងបទបង្ហាញ លោកគ្រូបានបញ្ចូលវីដេអូអំពីទីកន្លែង ការថតសំឡេងពីមនុស្សដែលរស់នៅទីនោះ និងរៀបរាប់ពីស្រុកកំណើត។ គ្រូបានបញ្ចូលតំណខ្ពស់ដែលនាំទៅដល់គេហទំព័ររបស់ការិយាល័យទេសចរណ៍នៃកន្លែងដែលគាត់កំពុងនិយាយ។ បន្ទាប់ពីមេរៀន គ្រូបានផ្ញើបទបង្ហាញទៅសិស្សរបស់គាត់ដែលអវត្តមាននៅថ្ងៃនោះ។ បន្ទាប់មកសិស្សចូលបន្ទប់កុំព្យូទ័ររបស់សាលារៀន ដើម្បីស្រាវជ្រាវរកកន្លែងជាក់លាក់តាមអ៊ីនធឺណែត។

កម្រិតនៃបច្ចេកវិទ្យា	ករណីសិក្សា
ទម្រង់បែបបទកែលម្អដោយមិនផ្អែកលើឌីជីថល	ករណីសិក្សាទី៤
ការជំនួស	ករណីសិក្សាទី២
ការជាក់ជាកញ្ចប់	ករណីសិក្សាទី៥
ការកែប្រែ	ករណីសិក្សាទី១
ការកំណត់ឡើងវិញ	ករណីសិក្សាទី៣

ខ. សូមអានករណីសិក្សាខាងក្រោម និងបំពេញតារាងខាងក្រោម៖

ករណីសិក្សាទី១

អ្នកគ្រូ អេ បានបង្កើតសម្ភារៈសម្រាប់សិស្សសិក្សាដោយខ្លួនឯង៖ វីដេអូ និងការកិច្ចដែលមានមូលដ្ឋានលើវីដេអូនេះគឺ សិស្សមើលវីដេអូ និងធ្វើកិច្ចការរបស់ខ្លួននៅផ្ទះ។ សិស្សត្រូវបានត្រួតពិនិត្យដោយឪពុកម្តាយរបស់ពួកគេដោយបានទទួលការណែនាំពីគ្រូជាមុន។ សិស្សក៏មានជម្រើសក្នុងការផ្ញើអ៊ីមែលទៅគ្រូរបស់ពួកគេ ក្នុងករណីដែលឪពុកម្តាយមិនអាចជួយពួកគេលើកិច្ចការណាមួយ។ នៅក្នុងមេរៀនបន្ទាប់របស់ពួកគេនៅឯសាលារៀន គ្រូពិភាក្សាជាមួយសិស្សនូវអ្វីដែលពួកគេបានរៀនដោយមានជំនួយពីវីដេអូ។ សិស្សប្រៀបធៀបការយល់ដឹងរបស់ពួកគេ និយាយអំពីសំណួរដែលមិនទាន់ដោះស្រាយ និងលទ្ធផលនៃការសិក្សាដោយខ្លួនឯង ហើយគ្រូបំពេញការខ្វះចន្លោះនៃចំណេះដឹងរបស់សិស្ស។ នៅចុងបញ្ចប់ សិស្សបំពេញភារកិច្ចជាក់ស្តែងមួយទៀតដែលគ្រូពិនិត្យមើល និងផ្តល់យោបល់ជាលក្ខណៈបុគ្គលដល់សិស្សម្នាក់ៗ តាមរយៈអ៊ីម៉ែល ការប្រជុំតាមអ៊ីនធឺណែតប្រព័ន្ធគ្រប់គ្រងការសិក្សា ឬ ការប្រជុំជាបុគ្គល។

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ករណីសិក្សាទី២

គ្រូ បី អនុញ្ញាតឱ្យសិស្សបង្កើតរឿងនិទានឌីជីថលផ្ទាល់ខ្លួនជាមួយអត្ថបទ រូបភាព សំឡេង និងថតសំឡេងរបស់ពួកគេ ជាផ្នែកមួយនៃកម្មវិធីសិក្សាភាសា។ សិស្សបឋមសិក្សា ពីថ្នាក់ទី១ ដល់ទី៣ បង្កើតរឿងនិទានឌីជីថលផ្ទាល់ខ្លួននៅក្នុងថ្នាក់ភាសារបស់ពួកគេ (ឧទាហរណ៍៖ ភាសាអង់គ្លេស និងភាសាកំណើត - ស៊ីនហាឡា និងតាមិល)។ សិស្សបង្កើតរឿងនិទានឌីជីថលដោយរំឭកពីបទពិសោធរបស់ពួកគេនៅក្នុងដំណើរសិក្សាដូចជាសួនសត្វ។ រឿងនិទានឌីជីថលទាំងនេះទាក់ទងនឹងរូបថតដែលថតដោយនិស្សិត និងការនិទានកថាដែលបានកត់ត្រាដោយសិស្សនៅពេលពួកគេរំឭកបទពិសោធផ្ទាល់ខ្លួន និងចែករំលែកការឆ្លុះបញ្ចាំង។ តន្ត្រីត្រូវបានបញ្ចូលទៅក្នុងរឿងនិទានឌីជីថលដើម្បីឆ្លុះបញ្ចាំងពីអារម្មណ៍រៀបរាប់ផ្ទាល់ខ្លួន។

ករណីសិក្សាទី៣

សម្រាប់ករណីសិក្សាទី ៣ សូមមើលវីដេអូខាងក្រោម៖

https://www.youtube.com/watch?v=9vn8QXF2Kfs

	ទម្រង់បែបបទនៃមេរៀនតាមបែបឌីជីថល
ករណីសិក្សាទី១	ការបង្រៀនតាមអ៊ិនធឺណែត និងការបង្រៀនក្រៅថ្នាក់
ករណីសិក្សាទី២	រឿងនិទានតាមប្រព័ន្ធឌីជីថល
ករណីសិក្សាទី៣	ការបង្រៀនតាមអ៊ិនធឺណែត និងការបង្រៀនក្រៅថ្នាក់

មើលរូបភាព CC នេះ និងស្លាករបស់វា ទាញនិងទម្លាក់សមាសធាតុនៃស្លាកចូលទៅក្នុងប្រភេទសមស្របនៅក្នុងតារាងខាងក្រោម៖ Stand With Malala@ICT Discovery – ITU Pictures – CC BY 2.0 – CC Search

Stand With Malala@ICT Discovery, ITU Pictures, CC BY 2.0, CC Search

ចំណងជើង	Stand With Malala@ICT Discovery
អ្នកនិពន្ធ	ITU Pictures
ប្រភព	CC Search
អាជ្ញាបណ្ណ	CC BY 2.0

ក. ស្តាប់គ្រូនិយាយអំពីការរៀបចំមេរៀនតាមអ៊ីនធឺណែត (ឯកសារសំឡេង ៥.៣.១)។ ចូរឆ្លើយសំណួរខាងក្រោម (អាចមានចម្លើយត្រឹមត្រូវលើសពីមួយ)៖

១. តើចំណុចអ្វីខ្លះដែលគ្រូលើកឡើងយកមកពិចារណានៅពេលរៀបចំមេរៀនតាមអ៊ីនធឺណែត?

ក) ខ្លឹមសារត្រូវមានភាពច្បាស់លាស់តាមដែលអាចធ្វើទៅបាន

ខ) ឯកសារមេឌាចាំបាច់ត្រូវត្រួតពិនិត្យ ប្រសិនបើសិស្សអាចបើកនៅលើឧបករណ៍ផ្សេងៗ

គ) រាល់កិច្ចការត្រូវសរសេរជាលាយលក្ខណ៍អក្សរជាមុន

ឃ) គ្រូបង្រៀនត្រូវការសមត្ថភាពធ្វើការជាមួយបច្ចេកវិទ្យាផ្សេងៗគ្នា

ង) ទម្រង់សម្រាប់វាយតម្លៃសិស្សត្រូវរកអោយឃើញ។

ខ. សរសេរចម្លើយអត្ថបទខ្លីៗ (ប្រហែល ៥០០ពាក្យ ក្នុងមួយសំណួរ) ចំពោះសំណួរឆ្លុះបញ្ចាំងផ្ទាល់ខ្លួន ដូចខាងក្រោម៖

១. តើអ្នកអាចនិយាយអ្វីខ្លះពីគុណសម្បត្តិនៃការបង្រៀនជាមួយនឹងឧបករណ៍សន្និសីទដូចជា ZOOM (ឧទាហរណ៍៖ ការប្រាស្រ័យទាក់ទងគ្នា) ក្នុងការប្រៀបធៀបនឹងការបង្រៀនជាមួយប្រព័ន្ធគ្រប់គ្រងការសិក្សា (ឧទាហរណ៍៖ ការប្រាស្រ័យទាក់ទងអសមកាល)?

ជំហានទី៣៖ កិច្ចការរៀបចំសំណុំឯកសារ –សំណួរបែបឆ្លុះបញ្ចាំងផ្ទាល់ខ្លួន

ចូរសរសេរចម្លើយបែបសំណេរតែងសេចក្តីចំពោះសំណួរបែបឆ្លុះបញ្ចាំងផ្ទាល់ខ្លួនខាងក្រោម។ ចម្លើយបែបសំណេរតែងសេចក្តីនីមួយៗគួរចាប់ពី ៣០០ពាក្យ ទៅ ៥០០ពាក្យ ហើយឆ្លើយជាអត្ថបទដែលទាក់ទងគ្នាងាយស្រួលយល់ជាមួយនឹងប្រយោគពេញលេញ។ ចម្លើយបែបសំណេរតែងសេចក្តីទាំងនេះដាក់ចូលទៅក្នុងសំណុំឯកសារផ្ទាល់ខ្លួនរបស់អ្នក!

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

១. តើអ្នកអាចនិយាយអ្វីបានខ្លះចំពោះគុណសម្បត្តិនៃការបង្រៀនដោយប្រើឧបករណ៍សន្និសីទ ដូចជា ZOOM (ជាការប្រាស្រ័យទាក់ទងគ្នាមួយដោយផ្ទាល់) ក្នុងការប្រៀបធៀបគ្នានឹងការបង្រៀនជាមួយប្រព័ន្ធគ្រប់គ្រងការសិក្សា (ជាការប្រាស្រ័យទាក់ទងគ្នាដែលមិនកើតឡើងក្នុងពេលដំណាលគ្នា)?

ជំហានទី៤៖ កិច្ចការរៀបចំសំណុំឯកសារ – គម្រោងការបង្រៀន

ចូរបង្កើតគម្រោងបង្រៀនផ្ទាល់ខ្លួនរបស់អ្នក។ ចូរបញ្ចូលលទ្ធភាពទាំងឡាយនៃការបង្កើតការបង្រៀន និងរៀនតាមប្រព័ន្ធឌីជីថលទៅក្នុងគម្រោងការបង្រៀនរបស់អ្នក (ពោលគឺមានដូចជា ថ្នាក់រៀនដែលរួមបញ្ចូលគ្នា ឬ ផ្លាស់គ្នា ឬ ការនិទានរឿងតាមបែបឌីជីថល)។ ប្រសិនបើអ្នកមិនប្រើប្រាស់ទម្រង់តាមបែបឌីជីថលក្នុងគំនិតរបស់អ្នកទេ អ្នកគួរតែដោះស្រាយជាមួយនឹងប្រធានបទនេះឲ្យបានច្បាស់លាស់នៅក្នុងកិច្ចការរបស់អ្នក ហើយពន្យល់តាមបែបគរុកោសល្យ (ដោយយោងទៅតាមអត្ថន័យមាតិការបស់ម៉ូឌុល)។ អ្វីដែលមានមតិជំទាស់ទៅនឹងឱកាសនៃការសិក្សាតាមបែបឌីជីថល។ កិច្ចការរៀបចំសំណុំឯកសារនេះ គួរតែចាប់ពី ៨០០ពាក្យ ទៅ ១០០០ពាក្យ។គម្រោងការបង្រៀនដាក់ចូលទៅក្នុងសំណុំឯកសារផ្ទាល់ខ្លួនរបស់អ្នក!

ឧបសម្ព័ន្ធ

កំណត់ត្រាពីសំឡេងៈ Video File

ខ្ញុំឈ្មោះ ចាណែត ជាគ្រូបង្រៀនបឋមសិក្សាម្នាក់ អស់រយៈពេលជាង ២០ឆ្នាំហើយ។ សូមអនុញ្ញាតឲ្យខ្ញុំបានប្រាប់អ្នកបន្តិចនៅពេលមានការសុំឲ្យខ្ញុំនិយាយជាមួយពួកគេអំពីការបង្កើតវីដេអូសម្រាប់បង្រៀនមេរៀនដែលខ្ញុំចូលចិត្តបង្រៀនជារៀងរាល់ថ្ងៃ ខ្ញុំមានអារម្មណ៍ថាភ័យដែរ ប៉ុន្តែចាំខ្ញុំប្រាប់អ្នកពីការពិត។ វាជារឿងសាមញ្ញណាស់ និងជាវិធីដ៏ល្អមួយ ដើម្បីផ្តល់ប្រយោជន៍ដល់ពិភពលោក។ យើងអាចទាក់ទងជាមួយគ្រូបានគ្រប់ទីកន្លែង ចែករំលែកពីគំនិតរបស់យើង បង្កើតសហគមន៍សម្រាប់អ្នកអប់រំនៅលើសកលលោក។ អ្វីដែលចាំបាច់គឺមានដំហានសាមញ្ញបី។ ជ្រើសរើសទីតាំងរបស់អ្នក រៀបចំឧបករណ៍ថត និងថត។ បន្ទាប់មក ទេពកោសល្យដ៏ល្អរបស់អ្នកនឹងត្រូវបានចែករំលែកពាសពេញពិភពលោក។ ស្ទើរតែគ្រប់ទីតាំងទាំងអស់អាចនឹងថតបាន អាចជាថ្នាក់រៀនរបស់អ្នក ឬ ជាបន្ទប់មួយនៅសាលារៀនរបស់អ្នក ឬ ជាបន្ទប់មួយក្នុងផ្ទះរបស់អ្នក ឬ ជាកន្លែងណាដែលអ្នកយល់ថាមានផាសុខភាពបំផុតក្នុងការធ្វើកិច្ចការ។ បន្ទប់ទាំងនោះគួរតែស្ងប់ស្ងាត់ មានពន្លឺច្បាស់ល្អដើម្បីឲ្យយើងអាចមើលឃើញ និងស្តាប់ឮពីមេរៀនដែលអ្នកកំពុងចែករំលែក។ ដំហានទីពីរ ក្នុងដំណើរការនៃការបង្កើតវីដេអូគឺការរៀបចំឧបករណ៍ថតរបស់អ្នក។ គ្រប់កាមេរ៉ាឌីជីថលអាចថតបាន ឬ គ្រប់ឧបករណ៍ដែលអ្នកអាចថតវីដេអូបានគួរមានលក្ខណៈល្អសមស្រប។ ឧបករណ៍ដែលយើងភាគច្រើនប្រើបានមកពីការផលិតជា វីដេអូគឺ ទូរស័ព្ទដៃ។ យើងដឹងពីរបៀបប្រើប្រាស់ឧបករណ៍ និងប្រើសម្រាប់ថតវីដេអូបានសមស្រប ប៉ុន្តែត្រូវប្រាកដថាកាមេរ៉ាមានលំនឹងស្មើ។ អ្នកអាចប្រើជើងទ្រដែលមានជើងបី ប្រសិនបើអ្នកមាន។ អ្នកអាចតម្រៀបសៀវភៅខ្លះហើយដាក់ផ្អែកទៅនឹងអ្វីមួយ (ឧៈ ពែងកាហ្វេ)។ ប្រសិនបើអ្នកប្រើប្រាស់ជើងទម្រជាបង្គោល អ្នកត្រូវប្រាកដថាបង្គោលទាំងអស់គឺមានស៊ុម។ ដំហានចុងក្រោយនៃការផលិតវីដេអូដើម្បីចែករំលែកគំនិតរបស់អ្នកជាមួយអ្នកដទៃគឺ ស្នាដៃនៃការថត។ សាកទាយទៅមើល? វាអាចជារឿងដែលងាយស្រួលបំផុត។ ខ្ញុំមិនមែននិយាយលេងទេ គឺមិនលំបាកខ្លាំងណាស់ណាទេ។ ប៉ុន្តែចំណុចចម្បង គឺថាយើងមិនមែនជាអ្នកសំដែងអាជីពនោះទេ។ យើងជាគ្រូបង្រៀន វីដេអូក៏មិនចាំបាច់ត្រូវតែល្អឥតខ្ចោះនោះទេ។ យើងពិតជាមានដំបូន្មានមួយចំនួនសម្រាប់ពេលថត។ ប្រាកដក្នុងចិត្តថា អ្នកនិយាយលឺៗ ប្រើល្បឿនសមស្រប ច្បាស់លាស់ និងងាយស្រួល (កុំលឿនពេក ប៉ុន្តែកុំយឺតពេក)។ ចូរគិតដល់សិស្សរបស់អ្នកនៅក្នុងថ្នាក់ ដោយគ្រាន់តែនិយាយទៅកពួកគេ។ នៅពេលដែលអ្នកមានទីតាំងដែលបានកំណត់ អ្នកត្រៀមខ្លួនចាប់ផ្តើម អង្គុយចុះដកដង្ហើមឲ្យវែង ឈោងចុចប៊ូតុងថត ចាប់ផ្តើមបង្កើតដោយខ្លួនអ្នកផ្ទាល់ ហើយបង្រៀនពីមេរៀនដ៏ល្អរបស់អ្នក។ នៅពេលមេរៀនចប់ ឈប់មួយសន្ទុះ ញញឹមនិងឈោងបិទការថត។ នេះជាអ្វីចាំបាច់ក្នុងការចែករំលែកមេរៀនល្អៗដែលអ្នកកំពុងបង្រៀនជារៀងរាល់ថ្ងៃ។ គ្រប់ វីដេអូរបស់អ្នក ចាំបាច់ត្រូវដាក់បញ្ចូលទៅក្នុងអ៊ីនធឺណែត ហើយអ្នកកំពុងតែឈានដល់ការចែករំលែក

គំនិតរបស់អ្នកជាមួយនឹងពិភពលោក។ ចូររីករាយជាមួយនឹងការបង្កើតវីដេអូរបស់អ្នក! អ្នកកំពុងតែជួយគ្រូបង្រៀនរាប់លានអ្នកនៅជុំវិញពិភពលោក។ សូមស្វាគមន៍ចំពោះ Teach for Life Movement។

កំណត់ត្រាសំឡេង៖ Audio File 5.3.1

អ្នកសម្ភាស៖ តើការរៀបចំមេរៀននៅក្នុងថ្នាក់តាមអនឡាញបែបសម័យទំនើប ខុសពីថ្នាក់ធម្មតា(មិនមែនបែបឆ្លាតវៃ) ដោយរបៀបណា?

គ្រូបង្រៀន៖ នៅពេលអ្នកបង្កើតមេរៀនតាមប្រព័ន្ធអនឡាញ ឬ សម្រាប់ថ្នាក់រៀនឆ្លាតវៃ អ្នកត្រូវតែគិតដល់មធ្យោបាយខុសគ្នាទាំងអស់ ដែលសិស្សនឹងយល់ពីអ្វីដែលអ្នកកំពុងធ្វើ។ មានន័យថា វាចាំបាច់ត្រូវតែច្បាស់លាស់តាមដែលអាចធ្វើទៅបាន។ គ្រូត្រូវតែត្រួតពិនិត្យអ្វីៗគ្រប់យ៉ាងដែលអ្នកបង្ហោះ ថាតើសិស្សអាចបើកឯកសារនេះបាន អាចមើលវីដេអូយើញ អាចស្តាប់ឯកសារនេះបាន ព្រោះថាមានទូរស័ព្ទ និងឧបករណ៍ប្រភេទខុសៗគ្នា។ គ្រូចាំបាច់ត្រូវបើកបានគ្រប់ឧបករណ៍ពេលត្រូវប្រើ ទោះជាអ៊ីនធឺណែតតាមកុំព្យូទ័រ ឬ តាមទូរស័ព្ទ។ គ្រូត្រូវគិតគ្រប់រឿងរ៉ាវ និងគ្រប់កត្តាទាំងនោះ។ តាមពិត ការរៀបចំមេរៀនត្រូវការពេលច្រើនជាងនៅពេលគ្រូគិតពីអ្វីដែលអ្នកនឹងបង្រៀននៅក្នុងថ្នាក់សម្រាប់ថ្ងៃបន្ទាប់ គ្រូគ្រាន់តែចងចាំ ប៉ុន្តែនៅពេលដែលអ្នកធ្វើតាមអនឡាញជាក់ស្តែង គ្រូត្រូវវាយបញ្ចូលជាអក្សរគ្រប់យ៉ាងដែលខ្លួនចង់និយាយ។ គ្រូត្រូវថតជាសំឡេង បន្ទាប់មកត្រូវធ្វើការផ្លាស់ប្តូរទៅជាទម្រង់ត្រឹមត្រូវ អាចឲ្យគេប្រើប្រាស់បាន ដាក់ចូលទៅក្នុងប្រព័ន្ធអនឡាញយ៉ាងហោចណាស់សម្រាប់ប្រព័ន្ធ។ ប្រព័ន្ធ Zoom មានភាពងាយស្រួលច្រើនក្នុងការរៀបចំថ្នាក់ គ្រូគ្រាន់តែប្រើក្តារខៀន មានជម្រើសក្នុងការប្រើក្តារខៀន អាចសរសេរលើទូរស័ព្ទ ឬ នៅក្នុងតារាងនូវអ្វីដែលគ្រូមាន និងបង្ហាញវាទៅកាន់សិស្សរបស់ខ្លួន។ ការរៀបចំថ្នាក់តាម Zoom នឹងមិនប្រើពេលវេលាច្រើនដូចការរៀបចំសម្រាប់តាមគេហទំព័រ schoology ដែលយើងប្រើនៅក្នុងសាលារៀននោះទេ ប៉ុន្តែមានការចំណាយពេលច្រើនជាងការបង្កើត។ គ្រូចាំបាច់ត្រូវធ្វើការជាមួយបច្ចេកវិទ្យាផ្សេងៗ ដើម្បីអាចបង្កើតជាមេរៀនក្នុងការជួយលើកទឹកចិត្តដែលមានលក្ខណៈសម្បូរបែប និងគួរជាទីចាប់អារម្មណ៍សម្រាប់សិស្ស។ គ្រូចាំបាច់ត្រូវគិតពីវិធីក្នុងការធ្វើតេស្តការយល់ដឹង ចាំបាច់បង្កើតជាសំណួរ និងរបៀបវាយតម្លៃការយល់ដឹងរបស់សិស្ស។ ជារួម គ្រូត្រូវគិតដល់កត្តាទាំងអស់ខាងលើនេះ។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

យុគសម័យឌីជីថលបានផ្តល់នូវឧបករណ៍អប់រំថ្មីៗជាច្រើនសម្រាប់ថ្នាក់រៀន ហើយអ្នកអប់រំដែលទទួលបានជោគជ័យយល់ពីសារៈសំខាន់នៃការបញ្ចូលពួកគេទៅក្នុងការបង្រៀនរបស់ពួកគេ។ នៅក្នុងម៉ូឌុលនេះអ្នកនឹងឃើញពីរបៀបប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ (អាយស៊ីធី) ប្រកបដោយប្រសិទ្ធភាពដើម្បីឱ្យវាត្រូវនឹងគោលបំណងសិក្សាប្រធានបទ និងការវាយតម្លៃនៅក្នុងថ្នាក់។ តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាជាក់ស្តែងឱកាសដែលផ្តល់ដោយប្រព័ន្ធផ្សព្វផ្សាយឌីជីថលនឹងត្រូវបានបង្ហាញដើម្បីគាំទ្រ និងបង្កើនការរចនានិងការអនុវត្តដំណើរការបង្រៀន និងរៀន ហើយសំណុំជំនាញឌីជីថលសំខាន់ៗនឹងត្រូវបានបង្កើតឡើងដើម្បីឱ្យអ្នកអាចប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយឌីជីថលបានកាន់តែប្រសើរ
បរិបទគរុកោសល្យ។

សូមសិក្សាដោយរីករាយ!